# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងអប់រំ យុវជន និងកីឡា

សិក្សាបញ្ញត្តិដើម្បីអភិវឌ្ឍគុណសម្បទាសតវត្សរ៍ទី២១

ប្រវត្តិវិទ្យា

មធ្យមសិក្សា




ភ្នំពេញ ២០២១

អ្នករៀបរៀង ជាអ្នកទទួលខុសត្រូវចំពោះការជ្រើសរើស ប្រើប្រាស់ និងបង្ហាញរូបភាព ក្រាហ្វ អង្គហេតុ គោលការណ៍ និងទ្រឹស្តី ក្នុងសៀវភៅនេះ។ ការបញ្ចេញទស្សនៈ និងការប្រើភាសា ក្នុងសៀវភៅនេះជាការទទួលខុសត្រូវរបស់អ្នករៀបរៀង។

ក្រសួងអប់រំ យុវជន និងកីឡា សូមទទួលស្គាល់ និងឱ្យតម្លៃខ្ពស់ចំពោះការប្រឹងប្រែងរបស់អ្នករៀបរៀង និងលោកគ្រូ អ្នកគ្រូដែលបានចូលរួមផ្តល់យោបល់ដល់ការរៀបរៀងសៀវភៅនេះ។

**ឯកសារនេះត្រូវបានផ្តួចផ្តើមផលិត និងតម្រង់ទិសដោយ ៖**

ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា

**អ្នករៀបរៀង** ៖ ខៀវ វិជ្ជានន្ទ និង បណ្ឌិត ឃួន វិច្ចិកា

**អ្នកផ្តល់យោបល់ ៖** បណ្ឌិត វង់ សុធារ៉ា, បណ្ឌិត សុខ សូត្រ, ម៉ម សុជាតិ, សុត វិសាល, ណុប សុខា, មួង សុផាត, មាស ភិរុណ, ចេង ហុង, ស៊ីវ ធួន, ហ៊ា ស៊ីវី, ទី សុផល, ឆេ ឡេ, គឹម ផេង, ស៊ិន ផុន, ហុង សុវណ្ណ, ម៉ៅ តាន់ណារី, វ៉ាន់ សុភី, ម៉ៅ មុំ, ចាន់ មករា, កែវ ដួង, ម៉ែន សំណាង

**ជំនួយការរៀបរៀង៖** ជិត ចាន់វន្ធី, សន សារី, ញឹប ភារី

**ភ្នំពេញ ឆ្នាំ ២០២១**

រក្សាសិទ្ធិគ្រប់យ៉ាងដោយអនុគណៈកម្មការមុខវិជ្ជាប្រវត្តិវិទ្យា នៃក្រសួងអប់រំ យុវជន និងកីឡា

ភាពជាគំរូនៃការអាន សរសេរសៀវភៅ និងការលើកទឹកចិត្ត របស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា នាំចិត្តអ្នករៀបរៀង ឱ្យសរសេរសៀវភៅនេះ ជាលើកដំបូង សម្រាប់ចែករំលែកដល់លោកគ្រូ អ្នកគ្រូ និងអ្នកអានទូទៅ។

# អ្នករៀបរៀង ខៀវ វិជ្ជានន្ទ

ខៀវ វិជ្ជានន្ទ បញ្ចប់សញ្ញាបត្របរិញ្ញាបត្រអប់រំ ផ្នែកបង្រៀនភាសាអង់គ្លេស ពីសាកលវិទ្យាល័យ ភូមិន្ទភ្នំពេញ ក្នុងឆ្នាំ១៩៩៥។ ខៀវ វិជ្ជានន្ទ បញ្ចប់ការសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគោលនយោបាយសាធារណៈផ្ដោតការស្រាវជ្រាវលើគោលនយោបាយអប់រំ នៅសាកលវិទ្យាល័យព្រុយណេដារូសាឡាំ នៃប្រទេសព្រុយណេ ក្នុងឆ្នាំ២០០២។

ខៀវ វិជ្ជានន្ទ មានបទពិសោធការងារ ក្នុងតំណែងជាច្រើនក្នុងវិស័យអប់រំ ជាគ្រូបង្រៀនភាសាអង់គ្លេស និងជាអ្នកបកប្រែភាសាអង់គ្លេសជាង១០ឆ្នាំ ជាប្រធានកម្មវិធីអប់រំ នៃអង្គការ UNESCO ក្នុងឆ្នាំ១៩៩៥ដល់១៩៩៨ នៃអង្គការUNFPA ក្នុងឆ្នាំ១៩៩៨ដល់២០០៤ និងប្រធានកម្មវិធីអប់រំសម្រាប់ទាំងអស់គ្នា នៃអង្គការUNESCO ឆ្នាំ២០០៤ដល់២០០៥។

ខៀវ វិជ្ជានន្ទ មានបទពិសោធជាទីប្រឹក្សា និងអ្នកស្រាវជ្រាវឱ្យស្ថាប័នជាតិ និងអន្តរជាតិជាច្រើន។ ខៀវ វិជ្ជានន្ទ ជាទីប្រឹក្សាក្នុងវិស័យសង្គម ផ្ដល់ការងារឱ្យធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារពិភពលោក ជំនួយអភិវឌ្ឍន៍សហរដ្ឋអាមេរិក អង្គការជាតិ និងអន្តរជាតិ ពីឆ្នាំ២០០៥ដល់២០០៨។

ខៀវ វិជ្ជានន្ទ ចូលរួមក្នុងរដ្ឋាភិបាល ក្នុងតំណែងជាអគ្គលេខាធិការរង នៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំ នៃកម្ពុជា ពីឆ្នាំ២០០៨ដល់២០១៥។ ខៀវ វិជ្ជានន្ទ ជាអគ្គាធិការរង នៃក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៥ដល់២០២០។ ក្នុងវិស័យអប់រំ ខៀវ វិជ្ជានន្ទ ជាសមាជិកស្រាវជ្រាវ នៃក្រុមប្រឹក្សាស្រាវជ្រាវអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា និងបានស្រាវជ្រាវរួមចំណែកដល់កំណែទម្រង់វិស័យអប់រំ។ ការស្រាវជ្រាវផ្ដោតលើកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន និងការបណ្ដុះបណ្ដាលគ្រូបង្រៀន។

នៅកម្រិតអន្តរជាតិ ខៀវ វិជ្ជានន្ទ ជាសមាជិកគណៈកម្មការប្រតិបត្តិ នៃបណ្ដាញធានាគុណភាពអប់រំអាស៊ាន (AQAN) ពីឆ្នាំ២០១២ ដល់ ២០១៣ និងជាសមាជិកគណៈកម្មការប្រតិបត្តិនៃបណ្ដាញធានាគុណភាពអប់រំអាស៊ីប៉ាស៊ីភិច (APQN) ពីឆ្នាំ២០១៣ដល់២០១៤។

ក្នុងឆ្នាំ២០២១ ខៀវ វិជ្ជានន្ទ ជាអគ្គនាយករង នៃវិទ្យាស្ថានជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ នៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

# អ្នករៀបរៀង បណ្ឌិត ឃួន វិច្ឆិកា

ឃួន វិច្ឆិកា បានបញ្ចប់សញ្ញាបត្របរិញ្ញាបត្រអប់រំ ផ្នែកបង្រៀនភាសាបារាំងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ក្នុងឆ្នាំ២០០៥។ ឃួន វិច្ឆិកា បានបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកប្រវត្តិសាស្ត្រប្រៀបធៀប នៅសាកលវិទ្យាល័យប៉ារីស៧-ដឺនីឌីដឺរ៉ូ សាធារណរដ្ឋបារាំង ឆ្នាំ ២០០៧។ ឃួន វិច្ឆិកា បានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកប្រវត្តិសាស្ត្រ និងអរិយធម៌នៅសាកលវិទ្យាល័យ ប៉ារីស៧-ដឺនីឌីដឺរ៉ូ សាធារណរដ្ឋបារាំង ក្នុងឆ្នាំ ២០១៥។

ឃួន វិច្ឆិកា មានបទពិសោធជាគ្រូបង្រៀនភាសាបារាំង និងប្រវត្តិសាស្ត្រ នៅសាកលវិទ្យាភូមិន្ទភ្នំពេញ ពីឆ្នាំ ២០០៥ដល់២០១៥។ ក្នុងតួនាទីជាអគ្គនាយករង នៃក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីឆ្នាំ២០១៦ មកដល់បច្ចុប្បន្ន។ ឃួន វិច្ឆិកា បានរួមចំណែកដល់កំណែទម្រង់វិស័យអប់រំ ដូចជាការអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅនៃមុខវិជ្ជាប្រវត្តិវិទ្យា ការរៀបរៀងកម្រងសំណួរ អត្ថបទ និងសៀវភៅប្រវត្តិវិទ្យាសម្រាប់គាំទ្រការរៀន និងបង្រៀនប្រវត្តិវិទ្យា ការងារលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀន ក្នុងបរិបទថ្មី និងការអភិវឌ្ឍគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន។

# សេចក្តីថ្លែងអំណរគុណ

អ្នករៀបរៀងសៀវភៅនេះសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអ្នកគ្រូ លោកគ្រូ ឯកទេសប្រវត្តិវិទ្យាដែលបានចូលរួមក្នុងដំណើរការស្រាវជ្រាវ អំពីទម្លាប់ និងវិធីសាស្ត្របង្រៀនប្រវត្តិវិទ្យាដឹកនាំដោយក្រុមប្រឹក្សាស្រាវជ្រាវអប់រំ នៃក្រសួង អប់រំ យុវជន និងកីឡា កាលពីឆ្នាំ២០១៨។ សេចក្តីថ្លែងអំណរគុណ ក៏ត្រូវបញ្ជូនដល់លោកគ្រូ អ្នកគ្រូ នាយក នាយិកាសាលាមធ្យមសិក្សា និងបឋមសិក្សាដែលបានទទួលយកការសាកល្បងបង្រៀនមេរៀនប្រវត្តិវិទ្យា និងវិធីសាស្ត្របង្រៀន និងដឹកនាំការរៀន តាមវិធីសាស្ត្រសិក្សាបញ្ញត្តិ។

សេចក្តីថ្លែងអំណរគុណ ក៏សូមបញ្ជូនដល់ថ្នាក់ដឹកនាំ លោកគ្រូ អ្នកគ្រូ មន្ត្រីជំនាញនៃនាយកដ្ឋាន និងមន្ទីរនានានៃក្រសួងអប់រំ យុវជន និងកីឡា ដែលបានចូលរួមសម្រួលដល់ការរៀបចំសិក្ខាសាលា និងសាកល្បងការបង្រៀន នៅតាមសាលារៀន។

អ្នករៀបរៀង ក៏សូមឱ្យតម្លៃខ្ពស់បំផុតចំពោះភាពជាគំរូ នៃការអាន និងសរសេរសៀវភៅរបស់ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។ ភាពជាគំរូនេះជាមូលធននៃចិត្តប្រឹងប្រែងរបស់អ្នករៀបរៀងសៀវភៅនេះ។

សេចក្តីថ្លែងអំណរគុណ ក៏ត្រូវផ្តល់ជូនយ៉ាងធំ និងច្រើនបំផុត សម្រាប់សមាជិកគ្រួសារ របស់យើងខ្ញុំ គឺភរិយា ស្វាមី និងកូនដែលតែងផ្តល់ភាពកក់ក្តៅ ក្នុងដំណើរការសរសេរ។

អ្នករៀបរៀងក៏សូមទទួលស្គាល់តម្លៃនៃការអានដំបូង និងផ្តល់ទស្សនៈផ្ទាល់ របស់ ៖

បណ្ឌិត សាន វឌ្ឍនា, អនុរដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និងកីឡា
បណ្ឌិត ជេត ជាលី, សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
បណ្ឌិត គួក ហ្វីដេរ៉ូ, អគ្គនាយក វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
បណ្ឌិត ហ៊ុល សៀងហេង, អគ្គនាយក អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
បណ្ឌិត ឌី សមស៊ីដេត, អគ្គនាយករង នៃក្រសួងអប់រំ យុវជន និងកីឡា
លោកស្រី ទេព កូឡាប, នាយិកា នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ
បណ្ឌិត បូ ច័ន្ទគុលិកា, ប្រធាននាយកដ្ឋានគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា
បណ្ឌិត ឈិញ ស៊ីថា, អ្នកស្រាវជ្រាវ និងជាទីប្រឹក្សាបច្ចេកទេស ក្នុងវិស័យអប់រំ
លោក ហែម បូណារិន, នាយកវិទ្យាស្ថាន LSI, BUSINESS SCHOOL

# បុព្វកថា

ប្រវត្តិវិទ្យាជាមុខវិជ្ជាមួយគួរទាញការចាប់អារម្មណ៍ ដល់អ្នកសិក្សាគ្រប់វ័យ គ្រប់ជំនាន់។ ប្រវត្តិវិទ្យាបង្រៀនមនុស្សឱ្យយល់ស៊ីជម្រៅអំពីព្រឹត្តិការណ៍ មនុស្ស និងពុទ្ធិរបស់មនុស្ស ក្នុងគ្រប់កាល បរិបទ និងគ្រប់វិស័យ។ ប្រវត្តិវិទ្យាបង្រៀនមនុស្សឱ្យប្រតិបត្តិសេចក្តីពិតគ្រប់កាល។ ប្រវត្តិសាស្ត្របង្រៀនមនុស្សឱ្យក្លាយជាអ្នកដឹកនាំមនុស្សទៅរកសង្គមមួយជឿនលឿន។

ការភ្ជាប់ប្រវត្តិសាស្ត្រជាមួយនឹងតម្រូវការរបស់មនុស្ស ក្នុងបច្ចុប្បន្ន និងអនាគត ជាគន្លឹះនាំចិត្តអ្នកសិក្សាឱ្យចង់អាន ចង់រៀន និងចង់តាមដានប្រវត្តិសាស្ត្រ។ បុគ្គលពូកែខាងប្រវត្តិសាស្ត្រ គឺពោរពេញដោយសមត្ថភាព ភ្ជាប់ពុទ្ធិមនុស្ស ព្រឹត្តិការណ៍ សមត្ថភាពមនុស្ស ក្នុងប្រវត្តិសាស្ត្រជាមួយនឹងតម្រូវការរបស់មនុស្សក្នុងបច្ចុប្បន្ន និងអនាគត។

បុគ្គលពូកែខាងប្រវត្តិសាស្ត្រនឹងចូលរួមបង្កើតសង្គមមួយ ពោរពេញដោយក្តីស្រឡាញ់ មេត្រីភាព និងមេត្តា។ ការរៀន និងបង្រៀនប្រវត្តិវិទ្យា ជួយសិស្សឱ្យអភិវឌ្ឍគុណតម្លៃ និងចរណមនុស្ស គុណសម្បទាសតវត្សរ៍ទី២១ និងភាពជាពលរដ្ឋសកល សម្រាប់បម្រើការងារ រស់នៅ និងរៀនបន្ត ក្នុងបច្ចុប្បន្ន និងអនាគត។

ការរៀនប្រវត្តិសាស្ត្រ នឹងទទួលបានសមត្ថភាពច្រើនបែបច្រើនយ៉ាង ដូចជា៖

- ឱ្យតម្លៃចំពោះភាពរួម ភាពដោយឡែក នានាភាព និងពហុភាព នៃវប្បធម៌ សាសនា ទំនៀមទម្លាប់ ជំនឿ នយោបាយ សេដ្ឋកិច្ច និងប្រពៃណី ក្នុងប្រវត្តិសាស្ត្រ ក្នុងប្រទេស តំបន់ និងពិភពលោក
- ភ្ជាប់គុណតម្លៃនៃមរតកប្រវត្តិសាស្ត្រទៅនឹងតម្រូវការសង្គម និងជីវភាពមនុស្ស ក្នុងបច្ចុប្បន្ន និងអនាគត
- បណ្តុះទម្លាប់ប្រតិបត្តិគោលការណ៍សុជីវធម៌ សីលធម៌ គុណធម៌
- បង្រៀនមនុស្សឱ្យបង្កើតនវកម្មគំនិត ដោយរៀនសូត្រពីមរតកប្រវត្តិសាស្ត្រ។

ស្រឡាញ់ជាការចាប់ផ្តើមអ្វីគ្រប់យ៉ាង។ ការរៀនប្រវត្តិវិទ្យាឱ្យក្លាយជាបុគ្គលពូកែ ត្រូវចាប់ផ្តើមដាំបណ្តុះក្តីស្រឡាញ់ជាមួយសិស្សជាមុនសិន។ នវកម្មគំនិត ការបង្កើតគំនិតច្នៃប្រឌិត និងគំនិតថ្មីៗឱ្យបង្កើតបានផលិតផលថ្មី ពុំអាចចាប់កំណើត ដោយពុំផ្តើមបណ្តុះក្តីស្រឡាញ់ជាមុនបានទេ។ ការបណ្តុះក្តីស្រឡាញ់ចំពោះការរៀនមុខវិជ្ជាប្រវត្តិវិទ្យា និងបណ្តុះសិស្សឱ្យក្លាយជាអ្នកយល់ និងប្រើប្រវត្តិសាស្ត្រជាប្រយោជន៍មនុស្ស គ្រូបង្រៀនត្រូវចាប់ផ្តើមឱ្យសិស្សស្គាល់ យល់ និងផ្តល់

តម្លៃចំពោះប្រវត្តិសាស្ត្រ។ ការរៀន និងបង្រៀនដើម្បីដឹង យល់ និងផ្តល់តម្លៃចំពោះប្រវត្តិសាស្ត្រ ទាមទារឱ្យគ្រូបង្រៀន និងសិស្សយកបញ្ញត្តិប្រវត្តិវិទ្យាទៅអនុវត្តជាប្រចាំ ភ្ជាប់នឹងជីវភាពប្រចាំថ្ងៃ ការងារ និងរៀនបន្ត ក្នុងបច្ចុប្បន្ន និងអនាគត ។

ខ្លឹមសារ និងការពន្យល់ក្នុងសៀវភៅនេះ ដឹកនាំគ្រូបង្រៀន សិស្ស និងអ្នកអានទូទៅឱ្យបង្កើតធាតុ និងរកធាតុគួរជាទីចាប់ចិត្ត និងចាប់អារម្មណ៍ក្នុងការបង្រៀន និងរៀនមុខវិជ្ជាប្រវត្តិវិទ្យា។ អ្នករៀបរៀងសៀវភៅនេះបានជ្រើសរើសយកទ្រឹស្តី និងវិទ្យាសាស្ត្រនៃការរៀន និងដឹកនាំការរៀន ដោយផ្តើមចេញពីការជ្រើសរើស និងប្រើបញ្ញត្តិ ក្នុងដំណើរការរៀន និងបង្រៀន។

អ្នករៀបរៀងសៀវភៅនេះ ពន្យល់ច្បាស់ថា បញ្ញត្តិជាគ្រឿងសង្ហារិម ឬជាអលង្ការនៃចិត្ត។ ចិត្តដែលមានបំពាក់គ្រឿងសង្ហារិម ឬអលង្ការល្អៗ ជាប្រភពផ្តល់បីតិ ជោគជ័យ និងភាពជាពលរដ្ឋពូកែ។ អានចប់សៀវភៅនេះ អ្នកគ្រូ លោកគ្រូ សិស្ស និងអ្នកអានទូទៅ នឹងបណ្តុះសទ្ធាចំពោះដំណើរការរៀន ដោយចាប់ផ្តើមពីបញ្ញត្តិ ដោយប្រើសកម្មភាពសង្កេត ឆ្ងល់ គិត បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ភាពពិត ត្រឹមត្រូវ និងច្បាស់ចំពោះបញ្ញត្តិដែលត្រូវរៀន។

**ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ការអប់រំសំដៅបណ្តុះបណ្តាលចិត្តឱ្យគិតកម្រិតខ្ពស់ ប្រតិបត្តចិត្តមេត្តា មេត្រីភាព និងស្រឡាញ់ គ្រប់កាល និងបរិបទ។**

# សេចក្តីសរសើរចំពោះសៀវភៅសិក្សាបញ្ញត្តិ

អាជីពការងារគ្រប់ប្រភេទ ក្នុងយុគឧស្សាហកម្ម៤.០ ត្រូវការពលរដ្ឋ ពោរពេញដោយវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ច្រើនប្រភេទ ច្រើនយ៉ាងណាស់។ សៀវភៅនេះពន្យល់លម្អិតអំពីគុណសម្បទាសតវត្សរ៍ទី២១ និងពលរដ្ឋសកលដែលយុវជន និងពលរដ្ឋគ្រប់រូបត្រូវការដោយខានពុំបាន។ សៀវភៅនេះទាញចិត្តខ្ញុំឱ្យអាន និងកត់ត្រាទុកនូវគុណសម្បទា ដែលបុគ្គលគ្រប់រូបត្រូវយកទៅប្រើក្នុងការងារប្រចាំថ្ងៃ និងរៀនបន្ត។ សៀវភៅនេះជួយបណ្តុះឆន្ទៈអ្នកអានឱ្យយកគុណសម្បទាសតវត្សរ៍ទី២១ ទៅប្រតិបត្តិប្រចាំជីវិត។

**បណ្ឌិត សាន វឌ្ឍនា, អនុរដ្ឋលេខាធិការ នៃក្រសួងអប់រំ យុវជន និងកីឡា**

សៀវភៅនេះ សំខាន់សម្រាប់គ្រូបង្រៀន អ្នកដឹកនាំក្នុងវិស័យអប់រំ និងអ្នកអប់រំ។ បុគ្គលបានអានសៀវភៅនេះនឹងមានបីតិដោយផលនៃការអប់រំ។ ផលនៃការអប់រំ គឺសិស្សក្លាយជាបុគ្គលពូកែគិត ឆ្លុះ បង្កើតសំណួរ និងសួរសំណួរ ក្នុងដំណើរការបង្រៀន និងរៀន។ សៀវភៅនេះថ្កក់ចិត្តខ្ញុំខ្លាំងណាស់ ដោយមានបញ្ចូលវិធីសាស្ត្របង្រៀន ដែលស្របតាមចរិត និងវប្បធម៌ខ្មែរ។

**បណ្ឌិត ជេត ជាលី សាកលវិទ្យាធិការ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

អ្នកនិពន្ធពន្យល់យ៉ាងលម្អិត និងលើកជាឧទាហរណ៍ងាយៗ អំពីលំនាំនៃការបង្រៀនដើម្បីដឹកនាំសិស្សឱ្យបន្ថែមជម្រៅនៃការគិត និងពង្រីកវិសាលភាពនៃគំនិតឱ្យដូចអ្នកវិទ្យាសាស្ត្រ។ លំនាំនៃការគិតរបស់អ្នកវិទ្យាសាស្ត្រ ផ្តើមចេញពីការសង្កេតបញ្ញត្តិ បង្កើតសំណួរ កំណត់សម្មតិកម្ម ព្យាករព្រឹត្តិការណ៍ ពិសោធរបកគំហើញ បញ្ជាក់ភាពត្រឹមត្រូវនៃការព្យាករណ៍ និងសម្មតិកម្ម។ សៀវភៅនេះត្បិតសរសេរសម្រាប់គ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា ប៉ុន្តែមានតម្លៃស្នួលសម្រាប់ការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រផងដែរ។

**បណ្ឌិត គួក ហ្វីដេរ៉ូ អគ្គនាយក វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

ការសិក្សាប្រវត្តិសាស្ត្របែបវិភាគដើរតួរនាទីលើសពីដែន នៃការអបរំ ការរៀន និងបង្រៀនក្នុងសាលា ទៅរកការរស់នៅ គ្រប់គ្រង ដឹកនាំ និងព្យាករណ៍ទៅថ្ងៃមុខ។ សៀវភៅមួយក្បាលនេះជួយបំពេញមន្ថែមនូវតម្លៃការសិក្សាប្រវត្តិសាស្ត្រដែលមានលក្ខណៈវិភាគ តាមបរិបទក្នុងសតវត្សទី២១ និងផ្តល់វិធីសាស្ត្រល្អមួយសម្រាប់អ្នកសិក្សាបច្ចុប្បន្ន និងជំនាន់ក្រោយ។ តម្លៃនៃអត្ថន័យ និងអត្ថរសសរសេរក្នុងសៀវភៅនេះ ផ្តល់ដោយផ្ទាល់ជាពុទ្ធិដ៏ឧត្តុងឧត្តម ដល់សហគមន៍អ្នកសិក្សាស្រាវជ្រាវ និងដោយប្រយោលជាការអភិវឌ្ឍបែបថ្មីមួយដល់សង្គមមនុស្ស។

**បណ្ឌិត ហ៊ុល សៀងហេង អគ្គនាយក នៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

ការបំពាក់បំប៉នគុណសម្បទាសតវត្សរ៍ទី២១ ដល់មនុស្សគ្រប់វ័យ គឺជាកាតព្វកិច្ចចម្បងរបស់គ្រឹះស្ថានអប់រំគ្រប់កម្រិត និងគ្រូបង្រៀនគ្រប់រូប។ សៀវភៅសិក្សាបញ្ញត្តិនេះ ផ្តល់សេចក្តីណែនាំលម្អិតអំពីលំនាំនៃការធ្វើផែនការដឹកនាំការរៀន ឱ្យសិស្សប្រើគុណសម្បទាសតវត្សរ៍ទី២១ ក្នុងគ្រប់បរិបទនៃជីវភាព ការងារ និងរៀនបន្ត។ សៀវភៅនេះពុំត្រឹមមានសារសំខាន់សម្រាប់គ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា នៅមធ្យមសិក្សាទេ។ គ្រូបង្រៀនកម្រិតឧត្តមសិក្សា ក៏ត្រូវអាន និងយកទៅអនុវត្ត ដើម្បីដឹកនាំការរៀនឱ្យសិស្សពេញចិត្ត និងចូលរួមក្នុងសកម្មភាពថ្នាក់រៀន។

**លោកជំទាវ ទេព កូឡាប, នាយិកា នៃសាកលវិទ្យាល័យភ្នំពេញអន្តរជាតិ**

សៀវភៅនេះជួយស្រាយចម្ងល់ និងឆ្លើយសំណួររបស់គ្រូបង្រៀន អំពីអ្វីជាបញ្ញត្តិ សិក្សាបញ្ញត្តិ វិធីសាស្ត្រសិក្សាបញ្ញត្តិ និងគោលវិធីសិក្សាបញ្ញត្តិបានមួយកម្រិត។ បើទោះបីជាសៀវភៅនេះផ្តោតការយកចិត្តទុកដាក់លើមុខវិជ្ជាប្រវត្តិវិទ្យា លោកគ្រូ អ្នកគ្រូបង្រៀនមុខវិជ្ជាផ្សេងក៏នឹងទទួលបានប្រយោជន៍ដែរ។ គ្រូបង្រៀន គ្រូឧទ្ទេស និងអ្នកអប់រំគ្រប់លំដាប់ថ្នាក់គួរតែមានសៀវភៅនេះម្នាក់មួយក្បាល ដើម្បីធ្វើឱ្យការពិភាក្សាអំពីបញ្ញត្តិ និងសិក្សាបញ្ញត្តិកាន់តែមានសង្គតិភាព។

**បណ្ឌិត ឌី សមស៊ីដេត អគ្គនាយករង ក្រសួងអប់រំ យុវជន និងកីឡា**

សិក្សាបញ្ញត្តិជាឃ្លាមួយថ្មីក្នុងបរិបទ នៃការរៀន និងបង្រៀននៅកម្ពុជា។ អ្នកនិពន្ធបានលើកយកបញ្ញត្តិ អង្គហេតុ ប្រធានបទ គោលគំនិត ឬគំនិតធំមកពិភាក្សាយ៉ាងល្អិតល្អន់។ ដំណើរការពិភាក្សាក៏ផ្តោតការយកចិត្តទុកដាក់លើទ្រឹស្តីអប់រំ វិទ្យាសាស្ត្រនៃការរៀន វិធីសាស្ត្រដឹកនាំការរៀន និងបង្រៀន។ អ្នកនិពន្ធបានប្រើឧទាហរណ៍ និងភស្តុតាង ធ្វើឱ្យអ្នកអានទាញប្រយោជន៍បានពីការអានសៀវភៅនេះ។ លើសពីនេះទៀត សៀវភៅនេះផ្តល់ពុទ្ធិច្រើនកម្រិត សម្រាប់លោកគ្រូ អ្នកគ្រូយកទៅអនុវត្តក្នុងថ្នាក់ជាមួយសិស្ស និងអ្នកអប់រំយកទៅកែលម្អប្រព័ន្ធគុណភាពអប់រំ។

**បណ្ឌិត បូ ច័ន្ទគុលិកា ប្រធាននាយកដ្ឋានគោលនយោបាយ ក្រសួងអប់រំ យុវជន និងកីឡា**

សៀវភៅនេះជាទស្សនវិជ្ជាផង និងវិធីសាស្ត្រផង។ សៀវភៅនេះបង្ហាញវិធីជាជំហានៗសម្រាប់គ្រូបង្រៀនរៀបចំកិច្ចតែងការ និងដឹកនាំសកម្មភាពសិក្សា ដើម្បីធានាឱ្យសិស្សសម្រេចប្រាជ្ញាភិវឌ្ឍន៍ ក្នុងការប្រតិបត្តិគុណសម្បទាសតវត្សរ៍ទី២១ឱ្យកាន់តែមានគម្ពីរភាព និងវិត្ថារភាព។

**បណ្ឌិត ឈិញ ស៊ីថា អ្នកស្រាវជ្រាវ និងជាទីប្រឹក្សាបច្ចេកទេស ក្នុងវិស័យអប់រំ**

អាជីពការងារគ្រប់ប្រភេទ និងអ្នកជំនួញត្រូវការបំណិនគិតកម្រិតខ្ពស់ ស្រាយបញ្ហា និងគុណតម្លៃមនុស្ស។ សៀវភៅនេះផ្តល់សេចក្តីពន្យល់អំពីវិធី និងឧទាហរណ៍ឱ្យសិស្សអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ និងលំនាំនៃការស្រាយបញ្ហា។ ពិសេសបំផុត សៀវភៅនេះបង្រៀនមនុស្សគ្រប់រូប និងគ្រប់វ័យឱ្យប្រតិបត្តិគុណតម្លៃមនុស្សប្រចាំជីវិត ព្រោះគុណតម្លៃមនុស្សជាយានដឹកនាំបុគ្គលឱ្យប្រកបរបរ និងការងារឱ្យកើតជាផលអតិប្បរមា។

**លោក ហែម បូណារិន, នាយកវិទ្យាស្ថាន LSI, BUSINESS SCHOOL**

# មាតិកា


សង្ខិត្តន័យ ..... xvi

១. លំនាំដើម ..... ១

២. សនិទានកម្ម ..... ៣

៣. គោលបំណង ..... ៧

៤. ម្ចាស់ទានគ្រប់ជំនាន់មនុស្ស ..... ១០

៥. បញ្ហាកម្ម (ការវិភាគបញ្ហា) ..... ១១

៦. អ្នកសិក្សាក្នុងយុគឧស្សាហកម្ម៤.០ ..... ១៦

៧. គុណសម្បទាប្រវត្តិវិទ្យា ..... ១៩

៧.១ វិជ្ជាសម្បទា ..... ១៩

៧.២ បំណិនសម្បទា ..... ២០

៧.៣ ចរិយាសម្បទា ..... ២០

៨. គុណសម្បទានៃការអប់រំពលរដ្ឋសកល ..... ២០

៨.១ វិជ្ជាសម្បទា ..... ២១

៨.២ បំណិនសម្បទា ..... ២១

៨.៣ ចរិយាសម្បទា ..... ២២

៨.៤ គុណតម្លៃពលរដ្ឋសកល ..... ២២

៩. យុគនៃបដិវត្តន៍ឧស្សាហកម្ម៤.០ ..... ២២

៩.១ នវកម្មគំនិត ..... ២៤

៩.២ បច្ចេកវិទ្យានៃការរៀន និងបង្រៀន ..... ២៦

៩.៣ ដៃគូអប់រំ-ឧស្សាហកម្ម ..... ២៧

៩.៤ អាជីពសកល ..... ២៨

៩.៥ វិស័យការងារ ..... ២៩

១០. គុណសម្បទា និងគុណតម្លៃមនុស្សសម្រាប់សតវត្សរ៍ទី២១ ..... ២៩

១០.១ គុណតម្លៃនៃការរៀន ..... ៣៣

១០.១.១ ការរៀនពេញមួយជីវិត ..... ៣៤

១០.១.២ ភាសាអង់គ្លេស ........ ៣៩
១០.១.៣ បុច្ចនវិជ្ជា ........ ៣៩
១០.២ គុណតម្លៃឌីជីថល ........ ៤៥
១០.២.១ គណនីក្នុងអន្តរបណ្តាញអ៊ិនធឺណេត ........ ៤៦
១០.២.២ អន្តរបណ្តាញអ៊ិនធឺណេត ឬបណ្ណាល័យទូរនិម្មិត ........ ៤៧
១០.២.៣ ភស្តុតាងស្រាវជ្រាវ ........ ៤៨
១០.៣ គុណតម្លៃការងារ ........ ៤៩
១០.៣.១ បញ្ហាវិជ្ជា (វិជ្ជាស្រាយបញ្ហា) ........ ៥០
១០.៣.២ ប្រាស្រ័យមនុស្ស និងគ្រប់គ្រងទំនាក់ទំនង ........ ៥២
១០.៣.៣ ភាពជាអ្នកដឹកនាំ និងអាត្មាវិជ្ជា ........ ៥៤
១០.៣.៤ ការសហការក្រុម ........ ៥៩
១០.៣.៥ គណនេយ្យភាព ........ ៥៩
១០.៤ គុណតម្លៃបុគ្គល ........ ៦០
១០.៤.១ សុជីវធម៌ ........ ៦១
១០.៤.២ សីលធម៌ ........ ៦២
១០.៤.៣ គុណធម៌ ........ ៦៣
១០.៤.៤ ការប្រតិបត្តិសេចក្តីពិត និងសុចរិតភាព ........ ៦៤
១០.៤.៥ ភាពទន់ភ្លន់ និងសម្រួបចិត្ត ........ ៦៦
១០.៤.៦ ការផ្តើមគំនិតត្រូវធ្វើ ........ ៦៨
១០.៤.៧ នវកម្មគំនិត ........ ៧០
១០.៥ គុណតម្លៃសង្គម ........ ៧៨
១០.៥.១ ភាពជាពលរដ្ឋសកល ........ ៧៩
១០.៥.២ អន្តរវប្បធម៌ ........ ៨០
១១. ទស្សនវិជ្ជាអប់រំ និងវិទ្យាសាស្ត្រនៃការរៀន ........ ៨១
១១.១ ពីរ៉ាមីតនៃការរៀន ........ ៨១
១១.២ ទស្សវិជ្ជាអប់រំ ........ ៨៥

១១.២.១ ព្រះពុទ្ធ (Siddhartha Gautama, ៥៦៣ឬ៤៨០-៤៨៣មុនគ.ស) .៨៧
១១.២.២ សូក្រាត (Socrates, ឆ្នាំ៤៧០ - ឆ្នាំ៣៩៩ មុន គ.ស) ................ ៨៩
១១.២.៣ ប្លាតូ (Plato, ៤២៤/៤២៣ -៣៤៨/៣៤៧ មុន គ.ស)................ ៨៩
១១.២.៤ ចន ឌូវី (John Dewey, ១៨៥៩-១៩៥២) ................ ៩០
១១.២.៥ ស្គីណឺ (Burrhus Frederic Skinner, ១៩០៤-១៩៩០) ................ ៩០
១១.២.៦ ឡេវ វីហ្កុតស្គី (Lev Vygotsky, ១៩៧៨) ................ ៩០
១១.២.៧ ដេវីដ ខូប (David A. Kolb, ១៩៣៩-បច្ចុប្បន្ន)................ ៩១
១២. គ្រូបង្រៀនពូកែ................ ៩១
១២.១ បរិបទសិស្ស................ ៩១
១២.២ ការរៀនបន្តជាមួយសិស្ស ................ ៩៣
១៣. វិជ្ជានុក្រមប្លូម (BLOOM) និងរចនាសម្ព័ន្ធនៃពុទ្ធិ................ ៩៥
១៣.១ វិជ្ជានុក្រម ប្លូម (BLOOM) ................ ៩៦
១៣.២ រចនាសម្ព័ន្ធនៃពុទ្ធិ ................៩៧
១៣.២.១ វិញ្ញាណ និងណឺរ៉ូន ................៩៨
១៣.២.២ មនោ ចិត្ត និងវិញ្ញាណ................ ៩៩
១៣.២.៣ ពុទ្ធិ ................ ១០០
១៣.២.៤ ព័ត៌មាន ................ ១០៣
១៣.២.៥ ចំណេះដឹង ................ ១០៥
១៣.២.៦ វិជ្ជា ................១០៧
១៣.២.៧ បញ្ញា ................ ១០៩
១៣.៣ ប្រតិបត្តិវិជ្ជានុក្រមប្លូម (BLOOM) និងរចនាសម្ព័ន្ធនៃពុទ្ធិ ................១១២
១៣.៤ ប្រតិបត្តិវិជ្ជានុក្រម ក្នុងការសរសេរលទ្ធផលសិក្សា................១១៧
១៤. គោលវិធី និងវិធីសាស្ត្រ................១២៣
១៤.១ គោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល................១២៨
១៤.១.១ សិក្សាទ្រឹស្តី................១៣២
១៤.១.២ បញ្ហាប្រឈម ................ ១៣៥

១៤.១.៣ គោលការណ៍ ..........................................................................១៣៧
១៤.១.៤ គុណប្រយោជន៍ .......................................................................... ១៥៤
១៤.២ បុច្ឆនសិក្សា.......................................................................... ១៥៦
១៤.២.១ សិក្សាទ្រឹស្តី.......................................................................... ១៥៨
១៤.២.២ គុណប្រយោជន៍..........................................................................១៧៤
១៤.៣ សិក្សាបញ្ញត្តិ..........................................................................១៧៨
១៤.៣.១ លំនាំដើម ..........................................................................១៧៨
១៤.៣.២ កម្មវិធីសិក្សាបុរាណ.......................................................................... ១៨៣
១៤.៣.៣ តើសិក្សាបញ្ញត្តិជាអ្វី?..........................................................................១៨៧
១៤.៣.៤ សិក្សាបញ្ញត្តិ និងតម្រូវការសង្គម .......................................................................... ១៨៨
១៤.៣.៥ សិក្សាបញ្ញត្តិ និងរចនាសម្ព័ន្ធនៃពុទ្ធិ .......................................................................... ១៩០
១៤.៣.៦ សិក្សាបញ្ញត្តិក្នុងបរិបទថ្មី ..........................................................................១៩២
១៤.៣.៧ កម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ ..........................................................................២១១
១៥. ប្រតិបត្តិសិក្សាបញ្ញត្តិ..........................................................................២២១
១៥.១ ឧទាហរណ៍បញ្ញត្តិ..........................................................................២២៣
១៥.២ លំនាំដឹកនាំការរៀនតាមសិក្សាបញ្ញត្តិ ..........................................................................២២៦
ឯកសារពិគ្រោះ..........................................................................២៧១

# សង្ខិត្តន័យ

១. លំនាំដើម

ការរៀបចំកម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ និងការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ សិស្សនឹងក្លាយជាពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ។ ពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ ពោរពេញដោយវិជ្ជា និងចរណៈ (Khmer Buddhism Institute , 1931) ។ សិស្សពោរពេញដោយវិជ្ជា និងចរណៈនឹងបម្រើការងារ ក្នុងគ្រប់វិស័យឧស្សាហកម្មដោយមោទនភាព មានគណនេយ្យភាព ទទួលខុសត្រូវខ្ពស់ និងចូលរួមលើកតម្កើងគុណតម្លៃសង្គម។ ពលរដ្ឋពោរពេញដោយវិជ្ជា និងចរណៈនឹងដឹកនាំកម្ពុជាទៅដល់ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ ត្រឹមឆ្នាំ ២០៣០ និងចំណូលខ្ពស់ ត្រឹមឆ្នាំ២០៥០។

២. កម្មវិធីសិក្សាតាមសិក្សាបញ្ញត្តិ

ការរៀបចំកម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ ត្រូវផ្តោតការយកចិត្តទុកដាក់លើវិមាត្រ៣៖ ១. បញ្ញត្តិ ២. អង្គហេតុ ៣. បំណិន និងដំណើរការ។ ទម្លាប់រៀបចំកម្មវិធីសិក្សាបែបប្រពៃណី ផ្តោតការយកចិត្តទុកដាក់លើវិមាត្រ២ ៖ ១. អង្គហេតុ (មាតិកា) ២. បំណិន និងដំណើរការ។

*រូបភាព ០១. កម្មវិធីសិក្សាបែបប្រពៃណី*



*រូបភាព ០២. កម្មវិធីសិក្សាតាមសិក្សាបញ្ញត្តិ*




បញ្ញត្តិជាគ្រឿងសង្ខារិមនៃចិត្ត។ ចិត្តដែលមានបំពាក់គ្រឿងសង្ខារិមល្អៗ ជាប្រភពផ្តល់បីតិ ជោគជ័យ និងភាពជាពលរដ្ឋពូកែ (Parker, 2012 )។ បញ្ញត្តិជាធាតុសម្រាប់ដឹកនាំចិត្ត នាំផ្លូវគិតរបស់សិស្ស និងភ្ជាប់ជាមួយតម្រូវការនៃការរៀនបន្ត រស់នៅ និងធ្វើការ។ បញ្ញត្តិអាចបង្កប់ក្នុងគំនិតទូទៅ គោលគំនិត ឬគំនិតធំរបស់អ្នកនិពន្ធ។ បញ្ញត្តិអាចបង្ហាញក្នុងគំនិតទូទៅ គំនិតធំ ឬគោលគំនិតរបស់អ្នកនិពន្ធ។ ការស្គាល់ និងយល់បញ្ញត្តិ ជាការចាប់ផ្តើមស្វែងពុទ្ធិគ្រប់កម្រិត និងផ្តើមការស្រាវជ្រាវពីកម្រិតតូច ដល់កម្រិតធំ។ ដូច្នេះ អ្នកគ្រូ លោកគ្រូត្រូវកំណត់រកបញ្ញត្តិចេញពីមេរៀន ឯកសារអំណាន ឬកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជាតាមកម្រិតថ្នាក់ដែលអ្នកគ្រូ លោកគ្រូត្រូវបង្រៀន។

៣. បញ្ញត្តិ និងចិត្តសិស្ស

របកគំហើញនៃការស្រាវជ្រាវរបស់ Ignatavicius (2017), Giddens & Brady (2007), Kluwer (2017) អំពីសិស្សរៀនពេទ្យពន្យល់ថា ការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ និងកម្មវិធីសិក្សាបញ្ញត្តិ សិស្សអាចភ្ជាប់បញ្ញត្តិរៀនពីសាលាជាមួយនឹងការងារជាក់ស្តែងក្នុងវិស័យពេទ្យ។ Kluwer (2017), Erickson L. H (2008), Erickson, Lanning, & French (2017), Erickson & Lanning (2014), និង

Stern, Lauriault, & Ferraro (2018) បញ្ជាក់បន្ថែមថា ការដឹកនាំសិស្សឱ្យរៀនតាមកម្មវិធីសិក្សាបញ្ញត្តិ សិស្សពេញចិត្តចូលរួមក្នុងដំណើរការរៀន ដោយសារ៖

១. សិស្សបន្ថយការរៀនបែបចូលត្រចៀកស្តាំ ចេញត្រចៀកឆ្វេង
២. សិស្សប្រើព័ត៌មានសម្បូរបែបពីច្រើនប្រភព និងគួរឱ្យទុកចិត្ត
៤. សិស្សបានអភិវឌ្ឍបំណិនច្រើនយ៉ាង គិតកម្រិតខ្ពស់ ស្រាយបញ្ហា
៥. សិស្សអភិវឌ្ឍសមត្ថភាពគិតដូចអ្នកវិទ្យាសាស្ត្រ ដោយប្រើបញ្ញត្តិ
៦. សិស្សមានសេរីភាព និងឯករាជ្យក្នុងដំណើរការរៀន
៧. សិស្សអភិវឌ្ឍសមត្ថភាពច្នៃប្រឌិត
៨. សិស្សក្លាយជាបុគ្គលពូកែឆ្លល់ និងសួរសំណួរ
៩. សិស្សក្លាយជាបុគ្គលមានជម្រើសនៃការស្រាយបញ្ហា។

៤. វិជ្ជានុក្រម BLOOM

ចេតនានៃមាតាបិតា និងអាណាព្យាបាលមួយចំនួន បញ្ជូនកូនចូលសាលាសំដៅឱ្យកូនក្លាយជាពលរដ្ឋពូកែ ពោរពេញដោយវិជ្ជា និងចរណៈ។ ចេតនាមាតាបិតា និងអាណាព្យាបាលខ្លះទៀត ចង់ឱ្យកូនមានបំណិនសតវត្សរ៍ទី២១។ ចេតនានៃបុគ្គលមួយចំនួនចង់រៀនមានចំណេះដឹងបច្ចេកទេស និងរៀនឱ្យដល់កម្រិតបញ្ញា។ ចេតនានៃប្រព័ន្ធអប់រំរបស់កម្ពុជា ចង់ឱ្យសិស្សទទួលបាន និងប្រើវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាក្នុងការងារ។ ចម្ងល់មួយយ៉ាងសាមញ្ញចោទជាសំណួរថា មានមធ្យោបាយ និងវិធីអ្វីដែលល្អបំពេញចេតនានេះ?

ការធានាសម្រេចចេតនានេះ គឺមានមធ្យោបាយ និងវិធីច្រើន។ សៀវភៅនេះជ្រើសយកគោលវិធីសិក្សាបញ្ញត្តិសម្រាប់សរសេរកម្មវិធីសិក្សា និងវិធីសាស្ត្រសិក្សាបញ្ញត្តិសម្រាប់ដឹកនាំការរៀន មកបរិយាយ។

បុគ្គលគ្រប់រូបប្រហែលជាចង់បានបំណិនគិតកម្រិតខ្ពស់រហូត ***បង្កើតថ្មី*** សម្រាប់ប្រើការក្នុងការងារ រស់នៅ និងធ្វើការ។ Benjamin BLOOM (1956) បង្កើតតារាងមួយហៅថា វិជ្ជានុក្រមប្លូម (BLOOM)។ Anderson, Krathwohl, & Airasian (2001) កែសម្រួលតារាងវិជ្ជានុក្រមនេះ ឱ្យមាន៦កម្រិត នៃសមត្ថភាពគិតដូចតារាងវិជ្ជានុក្រមដើម BLOOM (1956) គឺ ***បង្កើតថ្មី*** (រូបភាព០៣)។

*រូបភាព ០៣. វិជ្ជានុក្រម Bloom និងរចនាសម្ព័ន្ធនៃពុទ្ធិ*




៥. រចនាសម្ព័ន្ធនៃពុទ្ធិ

គ្រូបង្រៀនកម្ពុជាគ្រប់រូបពិតជាធ្លាប់ឮ សរសេរ អាន និងប្រើពាក្យ **ពុទ្ធិ ព័ត៌មាន ចំណេះដឹង វិជ្ជា និងបញ្ញា** ញឹកញាប់ណាស់។ គ្រូបង្រៀនពិតជាមានចេតនាបង្រៀនសិស្ស និងរៀនដោយខ្លួនឯងឱ្យអភិវឌ្ឍពុទ្ធិដល់កម្រិតបញ្ញា។

៥.១ ព័ត៌មាន

ធាតុផ្សំដំបូង មូលដ្ឋាន ឬផ្ទៃខាងលើនៃធាតុនានាដែលអ្នកសិក្សាត្រូវទទួលបានដំបូង យកមកចាំទុក និងសម្គាល់ទុក។ ជាទូទៅ អ្នកសិក្សាចាំទុក ឬសម្គាល់ទុកនូវរូបវត្ថុ ឬនាមវត្ថុមួយចំនួននៃអង្គហេតុ ឬព្រឹត្តិការណ៍ ក្នុងវិញ្ញាណតាមរយៈភ្នែក ត្រចៀក អណ្តាត ច្រមុះ ឬរាងកាយ។ ការចាំទុក ឬសម្គាល់ទុកជាចំណុចចាប់ផ្តើមនៃការរៀនដំបូងបំផុត។

៥.២ ចំណេះដឹង

មានព័ត៌មាន មិនទាន់មានចំណេះដឹងទេ។ ការមានចំណេះដឹង គឺបានស្វែងភាពពិត ត្រឹមត្រូវ ឬច្បាស់លាស់នៃព័ត៌មានពីច្រើនប្រភពដែលគួរឱ្យទុកចិត្ត

និងប្រើការបាន។ ការមានចំណេះដឹង គឺប្រមូលបានកញ្ចប់នៃធាតុផ្សំជាច្រើន បង្កប់ក្នុងកញ្ចប់ព័ត៌មានមូលដ្ឋានពីច្រើនប្រភព។ ការមានចំណេះដឹង គឺស្គាល់មុខងារ តួនាទី និងរចនាសម្ព័ន្ធនៃធាតុផ្សំនីមួយៗក្នុងកញ្ចប់ព័ត៌មាន ស្របតាមលក្ខខណ្ឌ កាល និងបរិបទ។ ការមានចំណេះដឹង គឺកើតឡើងដោយប្រើចិត្តយកទៅគិត ឆ្ងល់ បង្កើតសំណួរ សួរ និងរកការពន្យល់ពីច្រើនប្រភព។ ដើម្បីបានជាចំណេះដឹង សិស្សត្រូវឆ្លើយសំណួរមួយ។ តើព័ត៌មាននោះពិត ត្រឹមត្រូវ និងប្រើការបានកម្រិតណា? មានចំណេះដឹង គឺបំបែកធាតុនានា និងបរិមាណនៃធាតុបង្កប់ក្នុងព័ត៌មាន ឬក្នុងសញ្ញាណទទួលបានក្នុងជំហានដំបូង។

៥.៣ វិជ្ជា

មានវិជ្ជាគឺមានចំណេះដឹង ប៉ុន្តែត្រូវភ្ជាប់ដោយភស្តុតាងវិទ្យាសាស្ត្រ។ មានវិជ្ជា គឺយល់ពីធាតុលម្អិត និងមុខងារនៃធាតុនីមួយៗបង្កប់ក្នុងចំណេះដឹង។ មានវិជ្ជាត្រូវមានភស្តុតាងវិទ្យាសាស្ត្របញ្ជាក់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ នៃធាតុផ្សំនៃចំណេះដឹង។ ការមានវិជ្ជា មនុស្សអាចយកទៅប្រតិបត្តិបាន ស្របតាមកាល បរិបទ និងលក្ខខណ្ឌ។ ការមានវិជ្ជា គឺមានភាពច្បាស់លាស់ពិត និងត្រឹមត្រូវអំពីរបៀបយកធាតុលម្អិតក្នុងចំណេះដឹងទៅអនុវត្ត និងចែករំលែកជាប្រយោជន៍មនុស្ស។ មានវិជ្ជា គឺយល់ច្បាស់ និងយល់ត្រូវ អំពីលក្ខណៈវិនិច្ឆ័យ បច្ចេកទេស ទ្រឹស្តី វិធីសាស្ត្រ វិធី យុទ្ធវិធី មុខងារ គោលការណ៍ ក្បួនរចនាសម្ព័ន្ធ។ល។ដែលពាក់ព័ន្ធនឹងធាតុលម្អិតរបស់ចំណេះដឹង សម្រាប់យកទៅប្រតិបត្តិប្រចាំជីវិត និងចែករំលែកជាប្រយោជន៍មនុស្ស។

៥.៤ បញ្ញា

ការមានចំណេះដឹង ឬវិជ្ជាច្រើនឬជម្រៅប៉ុនណា ដោយបានអានច្រើនប៉ុនណា ឬរៀនចប់អស់ថ្នាក់រៀន ក៏ពុំទាន់មានបញ្ញាដែរ។ បញ្ញាកើតចេញពីការប្រតិបត្តិ។ ប្រតិបត្តិសំដៅបញ្ជាក់ភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃចំណេះដឹង និងវិជ្ជា ជាប្រយោជន៍នៃមនុស្ស។ មានបញ្ញា គឺប្រមូលបានទិន្នន័យប្រកបដោយគុណភាព គ្រប់គ្រាន់ ទុកចិត្ត ត្រឹមត្រូវ និងច្បាស់លាស់ពីការប្រតិបត្តិ ឬពិសោធន៍

ដោយផ្ទាល់ខ្លួន។ មានបញ្ញា គឺបានប្រើទិន្នន័យប្រកបដោយគុណភាព ទៅបង្កើតទ្រឹស្តី គោលការណ៍ វិធីសាស្ត្រ លក្ខខណ្ឌថ្មី ស្របតាមកាល និងបរិបទ។

*រូបភាព០៤. ធាតុគោលនៃសិក្សាបញ្ញត្តិ*




៦.    ដំណើរការរៀនតាមសិក្សាបញ្ញត្តិ

ការរៀបចំកម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ សំដៅបន្ថែមជម្រៅនៃការគិត និងពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែប។ ដំណើរការរៀន និងដឹកនាំការរៀនតាមកម្មវិធីសិក្សាតាមខ្លឹមសារមេរៀន សំដៅឱ្យសិស្សទន្ទេញរត់មាត់ ចាំខ្លឹមសារមេរៀន។ ខ្លឹមសារមេរៀនមាន អង្គហេតុ ឧទាហរណ៍ ព្រឹត្តិការណ៍ តួលេខ រូបមន្ត គំនិតទូទៅ ទ្រឹស្តី ព័ត៌មាន និងទិន្នន័យ (Erickson & Lanning, 2014; Stern, Lauriault, & Ferraro, 2018; Erickson, Lanning, & French, 2017)។ ការរៀនទន្ទេញចាំរត់មាត់ គឺសម្រាប់ឆ្លើយសំណួរកម្រិតទាបបំពេញតម្រូវការប្រឡងតែប៉ុណ្ណោះ។ សិស្សមានសមត្ថភាពប្រើបំណិនតាមកិរិយាសព្ទសកម្ម កំណត់ក្នុងតារាងវិជ្ជានុក្រមប្លូម (BLOOM, ១៩៥៧) (Stern, Lauriault, & Ferraro, 2018; Kluwer, 2017; Erickson & Lanning, 2014)។

ដំណើរការរៀន និងការដឹកនាំការរៀនតាមកម្មវិធីសិក្សាតាមសិក្សាបញ្ញត្តិ និងប្រើវិធីសាស្ត្របង្រៀនតាមសិក្សាបញ្ញត្តិ សំដៅឱ្យសិស្ស ១. ស្គាល់ ២. យល់ និង៣. ធ្វើ (Erickson, Lanning, & French, 2017)។

*រូបភាព០៥. ដំណើរការរៀនតាមសិក្សាបញ្ញត្តិ*




- **សិស្សស្គាល់**សំដៅឱ្យសិស្សភ្ជាប់ជាមួយបញ្ញត្តិ ប្រធានបទ គំនិតទូទៅ គោលគំនិត គំនិតធំ ទ្រឹស្តី ឬគោលការណ៍រៀនពីសាលាជាមួយបទពិសោធ ឬការធ្លាប់ស្គាល់
- **សិស្សស្គាល់** សំដៅឱ្យសិស្សប្រើបទពិសោធ និងចំណេះដឹងមានស្រាប់
- **សិស្សយល់** សំដៅឱ្យសិស្សពង្រីកសេចក្តីយល់ស៊ីជម្រៅលើគំនិតទូទៅ គោលគំនិត ឬគំនិតធំ ទ្រឹស្តី ឬគោលការណ៍ និងបញ្ញត្តិ។
- **សិស្សយល់** សំដៅដល់ការបំបែក និងញែកធាតុ ឬផ្គុំធាតុនៃបញ្ញត្តិ ប្រធានបទ គំនិតទូទៅ គោលគំនិត គំនិតធំ គោលការណ៍ ឬទ្រឹស្តី។

*រូបភាព៥. បញ្ញត្តិមេរោគ និងអនាម័យ*




- **សិស្សធ្វើឬប្រតិបត្តិ** សំដៅឱ្យសិស្សភ្ជាប់បញ្ញត្តិរៀនពីសៀវភៅ ពីគ្រូបង្រៀន និងមិត្តភក្តិក្នុងសាលារៀន ជាមួយនឹងតម្រូវការប្រចាំថ្ងៃ ធ្វើការ និងរៀនបន្ត ក្នុងគ្រប់បរិបទ លក្ខខណ្ឌ និងកាល។ ឧទាហរណ៍ *ចូរកូនលាងដៃនឹងសាប៊ូ!* ប្រសិនបើការបង្រៀនផ្តោតការយកចិត្តទុកដាក់តែលើការលាងដៃ សិស្សបានត្រឹមដឹងអំពីលាងដៃ។ ក្នុងបរិបទនៃកូវីដ-១៩ ការបង្រៀនតាមសិក្សាបញ្ញត្តិ គឺលើសពីលាងដៃនឹងសាប៊ូ។ ការរៀនគឺផ្តោតការយកចិត្តទុកដាក់លើការយល់បញ្ញត្តិ និងបំណិនស្រាយបញ្ហា។ បញ្ញត្តិដែលត្រូវរៀន គឺមេរោគ និងអនាម័យ។ *មេរោគ និងអនាម័យ* អាចភ្ជាប់រៀនជាមួយមុខវិជ្ជាផ្សេងដូចជា ជីវវិទ្យា គេហវិទ្យា សីលធម៌។ល។ បញ្ញត្តិ*មេរោគ និងអនាម័យ* មានលក្ខណៈសកល មនុស្សយល់ដូចៗគ្នា។ បញ្ញត្តិ*មេរោគ និងអនាម័យ* យកមកប្រើគ្រប់កាល។ ទោះអត់កូវីដ ១៩ ឬមានកូវីដ ១៩ ក៏ត្រូវតែលាងដៃនឹងសាប៊ូ។

៧. បញ្ញត្តិជាអ្វី?

សិស្សរៀនមេរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ មានសមត្ថភាពប្រែក្លាយព័ត៌មានឱ្យទៅជាចំណេះដឹង ទៅជាវិជ្ជា និងបន្ថែមជម្រៅរហូតដល់បញ្ញា។ សិស្សមានសមត្ថភាពគិត និងប្រើព័ត៌មានជាប្រយោជន៍គ្រប់កាល និងបរិបទ។

សិស្សអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ ដូចជាវិភាគ វាយតម្លៃ និងច្នៃប្រឌិត ដោយផ្តើមចេញពីទិន្នន័យគ្រប់ជ្រុងជ្រោយ និងព័ត៌មានពិតប្រាកដ និងច្បាស់លាស់។ ពាក្យនិយមប្រើក្នុងការសរសេរកម្មវិធីសិក្សា តាមគោលវិធីសិក្សាបញ្ញត្តិ មាន ៖ **ការយល់ទូទៅ គំនិតទូទៅ គោលគំនិត គំនិតធំ បញ្ញត្តិ ប្រធានបទ និងអង្គហេតុ។**

*រូបភាព ០៦. ពាក្យបច្ចេកទេសក្នុងសិក្សាបញ្ញត្តិ*




បញ្ញត្តិមានបង្កប់ក្នុងប្រយោគនៃការនិយាយ ឬសរសេរ អាចជាពាក្យមួយ ឬការផ្សំផ្គុំពាក្យពីរ ឬឃ្លាខ្លីមួយ។ បញ្ញត្តិអាចរំលេចចេញក្នុងប្រយោគ នៃគោលគំនិត គំនិតទូទៅ ឬគំនិតធំ។ បញ្ញត្តិអាចយកទៅប្រើការបាន និងភ្ជាប់បាននឹងតម្រូវការគ្រប់កាល និងបរិបទ។ ពាក្យ ឬឃ្លាខ្លីមួយអាចចាត់ទុកជាបញ្ញត្តិ ត្រូវគោរពលក្ខខណ្ឌ ៖ ១. លក្ខណៈសកល ២. អរូបី ៣. តំណភ្ជាប់ ៤. គ្រប់កាល។

ការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ និងតាមកម្មវិធីសិក្សាបញ្ញត្តិ ជាការតម្រៀបអង្គហេតុ ឬព័ត៌មានឱ្យមានរចនាសម្ព័ន្ធ។ ព័ត៌មាន ឬអង្គហេតុមានរចនាសម្ព័ន្ធ ជាគ្រឹះនៃដំណើរការរៀន ដើម្បីអភិវឌ្ឍបំណិនគិត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ ស្វែងសេចក្តីពន្យល់ និងបញ្ជាក់សេចក្តីពិត ត្រឹមត្រូវ និងច្បាស់លាស់ ដូចរបៀបនៃការគិតរបស់ អ្នកវិទ្យាសាស្ត្រ។ ឧទាហរណ៍ អ៊ីសាក់ ញូ

តុន (Isaac Newton, ឆ្នាំ១៦៤៣-១៧២៧) ស្វែងការពន្យល់អំពីមូលហេតុនៃការធ្លាក់ផ្លែប៉ោម។ លោកពន្យល់ទ្រឹស្តីទម្លាក់សេរី និងបង្កើតបានរូបមន្តកម្លាំងទំនាញមួយឱ្យអ្នកវិទ្យាសាស្ត្ររៀនជាហូរហែ។ ចម្លល់របស់ អ៊ីសាក់ ញូតុន ចាប់ផ្តើមពីការគិត សង្កេត ឆ្ងល់ បង្កើតសំណួរ ចោទសំណួរ និងស្វែងការពន្យល់។

*រូបភាព០៩. ភាពខុសគ្នារវាងបញ្ញត្តិ និងប្រធានបទ និងអង្គហេតុ*




៨. ការវាយតម្លៃការរៀនតាមសិក្សាបញ្ញត្តិ

រូបភាពពន្យល់ថា ក្របខ័ណ្ឌពង្រីកពុទ្ធិរបស់ WEBB (1997) មាន៤កម្រិត៖ ១. រំឭកនិងពង្រីកការចងចាំ ២. បំណិននិងបញ្ញត្តិ ៣. គិតបែបយុទ្ធសាស្ត្ររយៈពេលខ្លី ៤. ពង្រីកវិសាលភាពនៃគំនិត។ ជាទូទៅ ប្រព័ន្ធអប់រំជាច្រើនកន្លែងប្រើក្របខ័ណ្ឌពង្រីកពុទ្ធិរបស់ WEBB (1997) សម្រាប់តាក់តែងលំនាំ នៃការវាយតម្លៃលទ្ធផសិក្សារបស់សិស្ស។ គ្រូបង្រៀនគួរប្រតិបត្តិទម្លាប់តាក់តែងលំនាំវាយតម្លៃលទ្ធផលសិក្សាតាមកម្រិតនីមួយៗ។

ការវាយតម្លៃលទ្ធផលសិក្សារំពឹងទុក (វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាកំណត់ក្នុងកម្មវិធីសិក្សា) ជាដំណើរការនិរន្តរ៍សម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំងភស្តុតាងអំពីកម្រិតនៃការទទួលវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់សិស្ស។ ការវាយតម្លៃសំដៅរកព័ត៌មាន ទិន្នន័យ ឬភស្តុតាង

ដើម្បីសន្និដ្ឋាន សម្រេចចិត្តអំពីដំណើរការរៀន និងការដឹកនាំការរៀន។ ការវាយតម្លៃសំដៅរកវិធី និងផ្តល់ធាតុចូល ដើម្បីជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូ។ ការវាយតម្លៃសំដៅដល់ការពិនិត្យឡើងវិញលើទម្រង់ ទម្លាប់ និងវិធាននៃការគ្រប់គ្រងថ្នាក់រៀន និងប្រព័ន្ធអប់រំ។

ការវាយតម្លៃជួយគ្រូបង្រៀន ៖

- ឱ្យស្គាល់បរិបទសិស្សច្បាស់
- ឱ្យប្រើព័ត៌មានអំពីការចងចាំ ការយល់ និងឥរិយាបថរបស់សិស្ស
- ឱ្យរកព័ត៌មានពីលទ្ធផលសិក្សា តាមប្រភេទសិស្ស
- ឱ្យស្គាល់ច្បាស់អំពីឥរិយាបថ ទម្លាប់ និងវិធីរៀនរបស់សិស្ស
- ឱ្យកែលម្អឥរិយាបថ ទម្លាប់ និងវិធីរៀនក្នុង និងក្រៅថ្នាក់
- ឱ្យធ្វើផែនការរយៈពេលខ្លី ក្នុងការកែលម្អឥរិយាបថ ទម្លាប់ និងវិធីរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ
- ឱ្យកែលម្អទម្លាប់ និងវិធីបង្រៀន ក្នុងថ្នាក់ និងក្រៅថ្នាក់។

*រូបភាព១០. គោលការណ៍វាយតម្លៃការសិក្សា*




*ប្រភព ៖ សម្រួលពី* WEBB (1997)

## ៩. លំនាំនៃការតាក់តែងផែនការដឹកនាំការរៀនតាមសិក្សាបញ្ញត្តិ

| ១. គោលបំណង | ១.២ បញ្ញត្តិ | ១.៣ លទ្ធផលសិក្សា | ១.៤ បំណិនដើម្បីជោគជ័យ |
|---|---|---|---|
| ១.១ មេរៀនទី២ | វិភាព សង្គ្រាម ជំលោះ នយោបាយ អំណាច ធនធាន តំបន់ ទីកន្លែង ភាពជាពលរដ្ឋ អធិបតេយ្យភាព ការចូលរួម | សូមអានសេចក្តីពន្យល់ | ▪ បង្កើតសំណួរ<br>▪ កែលម្អសំណួរ<br>▪ សួរសំណួរ<br>▪ កត់ត្រាចម្លើយ<br>▪ វាយការណ៍លទ្ធផល |

| ២. ដំណើរការរៀន និងដឹកនាំការរៀន | ២.១ សំណួរគន្លឹះ | ២.២ យុទ្ធវិធី |
|---|---|---|
| សំណួរ០១.<br>សំណួរ០២.<br>សំណួរ០៣. | សូមអានសេចក្តីពន្យល់ | យុទ្ធវិធី០១៖<br>យុទ្ធវិធី០២៖<br>យុទ្ធវិធី០៣៖   សូមអានសេចក្តីពន្យល់ |

| ៣. វាយតម្លៃការសិក្សា | ៣.១ វាយតម្លៃដើម្បីការរៀនបន្ត | ៣.២ ផែនការជួយសិស្សរៀនយឺត |
|---|---|---|
| វាយតម្លៃ០១.<br>វាយតម្លៃ០២.<br>វាយតម្លៃ០៣. | សូមអានសេចក្តីពន្យល់ | ផែនការ០១.<br>ផែនការ០២.<br>ផែនការ០៣.   សូមអានសេចក្តីពន្យល់ |

# ១.	លំនាំដើម

កម្ពុជាបានឆ្លងកាត់វិបត្តិសង្គមជាច្រើនទសវត្សរ៍ រហូតដល់ទសវត្សរ៍ឆ្នាំ ១៩៩០។ វិបត្តិសង្គមរួមមាន សង្គ្រាមស៊ីវិល ការសម្លាប់រង្គាល ជម្លោះហិង្សាប្រដាប់អាវុធ និងការបែកបាក់ជាតិចាប់ពីទសវត្សរ៍ឆ្នាំ១៩៦០ដល់ទសវត្សរ៍ឆ្នាំ ១៩៩០។ វិបត្តិសង្គមនេះបន្សល់ទុកនូវការឈឺចាប់ ព្រាត់ បែកបាក់សមាជិកគ្រួសារ ជំងឺផ្លូវចិត្តបុគ្គល ជំងឺទើសសង្គម និងជំងឺចិត្តសង្គម។ វិបត្តិសង្គមក៏បង្កើតទំនោរមិនទុកចិត្តមនុស្ស និងអយុត្តិធម៌សង្គមផងដែរ។ វិបត្តិសង្គមក៏ធ្វើឱ្យថមថយការប្រតិបត្តិនូវគោលការណ៍សុជីវធម៌ សីលធម៌ គុណធម៌ និងសេចក្ដីពិតក្នុងជីវិតផងដែរ។

របកគំហើញនៃការស្រាវជ្រាវជាច្រើនពន្យល់ថា ការរៀនប្រកបដោយគុណភាព ឬរៀនពិតប្រាកដជួយលើកតម្កើងតម្លៃនៃការប្រតិបត្តិគោលការណ៍សុជីវធម៌ សីលធម៌ គុណធម៌ និងសេចក្ដីពិតក្នុងជីវិត។ ការរៀនមុខវិជ្ជាប្រវត្តិវិទ្យាប្រកបដោយគុណភាព ឬរៀនពិតប្រាកដរួមចំណែកផ្សះផ្សារការបែកបាក់ជាតិ។ ការរៀនមុខវិជ្ជាប្រវត្តិវិទ្យាប្រកបដោយគុណភាព ឬរៀនពិតប្រាកដ រួមចំណែកដល់ចីរភាពអភិវឌ្ឍន៍ និងសន្តិភាព។

ការរៀនប្រវត្តិវិទ្យាប្រកបដោយគុណភាព ឬរៀនពិតប្រាកដ មិនត្រឹមឱ្យសិស្សទន្ទេញចាំមាត់ សូត្រព្រឹត្តិការណ៍ កាល ឈ្មោះមនុស្ស អង្គហេតុ និងកន្លែងនៃប្រវត្តិសាស្ត្រទេ។ ការរៀនប្រវត្តិវិទ្យាពិតប្រាកដ សំដៅដល់ការដឹកនាំសិស្សឱ្យប្រើភស្តុតាង វាយតម្លៃព្រឹត្តិការណ៍ និងប្រមាណអំពីអនាគត។ ការរៀនប្រវត្តិវិទ្យាពិតប្រាកដ សំដៅដល់ការដឹកនាំសិស្សឱ្យចេះស្រាយបញ្ហា បង្កើតគំនិតថ្មី និងផលិតផលថ្មី សម្រាប់បច្ចុប្បន្ន និងអនាគត។ ការរៀនប្រវត្តិវិទ្យាពិតប្រាកដជាដំណើរការ សិល្បៈ និងវិទ្យាសាស្ត្រ សម្រាប់បណ្ដុះបណ្ដាលចិត្តឱ្យគិត និងប្រតិបត្តិចិត្តមេត្តា ស្រឡាញ់ មេត្រីភាព និងសេចក្ដីពិត។

របកគំហើញនៃការស្រាវជ្រាវជាច្រើនពន្យល់ថា ដំណើរការរៀនប្រកបដោយគុណភាព ឬការរៀនពិតប្រាកដជួយព្យាបាលជំងឺផ្លូវចិត្តបុគ្គល ជំងឺទើស

សង្គម និងជំងឺចិត្តសង្គមក្រោយសង្គ្រាម ។ ការព្យាបាលជំងឺទាំងអស់នេះ សំដៅ ដាំបណ្ដុះចិត្តវិជ្ជមាន ក្ដីសង្ឃឹម លើកតម្កើងតម្លៃនៃសាមគ្គីបុគ្គល និងអប់រំមនុស្ស ឱ្យមានចាគទម្លាប់ គឺទម្លាប់គិតប្រយោជន៍សាធារណៈជាចម្បង។ ការព្យាបាល ជំងឺនេះ សំដៅបញ្ចៀសកំហុសនៃវិបត្តិសង្គមច្រំដែលៗ ដែលមានផលអាក្រក់ប៉ះ ពាល់ដល់សេចក្ដីចម្រើននៃសង្គម ។

រូបភាព០១. ក្របខ័ណ្ឌកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា




ការរៀនប្រកបដោយគុណភាព ឬរៀនពិតប្រាកដ ទាមទារឱ្យគ្រូបង្រៀន ពោរពេញដោយគុណសម្បទាជាគ្រូបង្រៀនពូកែ ឬគុណសម្បទាមនុស្សពូកែ។

ប្រទេសជាច្រើន ដូចជា ម៉ាឡេស៊ី អូស្ត្រាលី សឹង្ហបុរី ហ្វីលីពីន ឥណ្ឌូនេស៊ី ឥណ្ឌា សហរដ្ឋអាមេរិក កាណាដា និងប្រទេសជាច្រើននៅអ៊ឺរ៉ុប កំណត់ស្តង់ដាគ្រូបង្រៀន ឬស្តង់ដាគុណភាពគ្រូបង្រៀន។ ស្តង់ដាគុណភាពគ្រូបង្រៀនបញ្ជាក់អំពីភាពពូកែរបស់គ្រូបង្រៀន។ ភាពពូកែរបស់គ្រូបង្រៀនបរិយាយក្នុងបរិបទនេះសំដៅដល់គ្រូបង្រៀនដែលពោរពេញដោយចំណេះដឹង និងវិជ្ជាឯកទេស យល់ស៊ីជម្រៅលើបញ្ញត្តិនៃមុខវិជ្ជា គោលការណ៍នៃកម្មវិធីសិក្សា វិធីសាស្ត្រគរុកោសល្យ វិធីវាយតម្លៃការសិក្សា និងបរិបទសិស្ស (Gallie & Keevy, 2014; Darling-Hammond, 1999; Bonwell & Eison, 1991; Kilbane & Milman, 2014; Andersen & Andersen, 2017; Biggs & Tang, 2011; Kyriacou, 2009; Alberta Learning, 2004; Hughes & Acedo, 2016)។

គម្ពីរព្រះត្រៃបិដក នៃព្រះពុទ្ធសាសនាពន្យល់អំពីគុណសម្បទានៃមនុស្សពូកែ គឺពោរពេញដោយវិជ្ជា និងចរណៈ (Khmer Buddhism Institute , 1931)។ William Arthur Ward (ឆ្នាំ១៩២១-១៩៩៤) ពន្យល់ថា *"គ្រូបង្រៀនពូកែ គឺអន្ទងចិត្តសិស្សឱ្យចូលរួមក្នុងសកម្មភាពរៀន ដាំបណ្តុះចិត្តវិជ្ជមាន និងក្តីសង្ឃឹមសម្រាប់ការរៀន ការងារ និងជីវិត* (Ward , 1970) *។"* ក្របខ័ណ្ឌកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៦ មានចេតនាបណ្តុះពលរដ្ឋពេញលេញ ដូចរូបភាព០១ ពន្យល់។

## ២. សនិទានកម្ម

គ្រូបង្រៀន អ្នកស្រាវជ្រាវ អ្នកធ្វើផែនការអប់រំ អ្នកដឹកនាំក្នុងវិស័យអប់រំ អ្នកនយោបាយ មាតាបិតា និយោជក និយោជិត និងសិស្សទទួលស្គាល់ជាទូទៅថា គុណភាពរបស់គ្រូបង្រៀន គោលវិធីបង្រៀន យុទ្ធវិធីដឹកនាំការរៀន វិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀន កម្មវិធីសិក្សា និងសៀវភៅសិក្សា មានចំណងជាប់គ្នាយ៉ាងតឹង និងជាចំណែកមួយ នៃដំណើរការធានាឱ្យមានការរៀនពិតប្រាកដ ឬរៀនប្រកបដោយគុណភាព (Kyriacou, 2009; Darling-Hammond, 1999; Blomeke, Olsen, & Suhl, 2016; Association of Teacher Educators and Rowman & Littlefield

Education, 2009; Niss, 2002; Nilsen, Gustafsson, & Blomeke, 2016; United Nations Educational, Scientific and Cultural Organization, 2018a; OECD, 2013; Simsek & Kabapinar, 2010) ។

គោលវិធី និងវិធីសាស្ត្រដឹកនាំការរៀន និងការបង្រៀនមានច្រើនប្រភេទ និងទម្រង់។ គោលវិធី និងវិធីសាស្ត្រដឹកនាំការរៀន និងបង្រៀន ត្រូវបាននិយាយជជែក សរសេរ និងអនុវត្ត តាមគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន តាមសាលារៀន និងក្នុងសៀវភៅសិក្សានៅកម្ពុជាតាំងពីទសវត្សរ៍ឆ្នាំ១៩៨០។ គោលវិធីបង្រៀនពេញនិយមជជែកគ្នាក្នុងចំណោមគ្រូបង្រៀន គ្រូឧទ្ទេស និងអ្នកអប់រំ ៖

- វិធីសាស្ត្របង្រៀនបែបរិះរក
- វិធីសាស្ត្របង្រៀនបែបសហការ
- វិធីសាស្ត្របង្រៀនតាមគម្រោង
- វិធីសាស្ត្របង្រៀនតាមបញ្ហា
- វិធីសាស្ត្របង្រៀនបែបស្រាវជ្រាវ

ទោះបីជាយ៉ាងនេះក្ដី ពុំទាន់មានការស្រាវជ្រាវសម្បូរបែបរកឃើញអំពីធាតុលម្អិត និងប្រសិទ្ធភាពនៃការប្រើយុទ្ធវិធី វិធី សកម្មភាព ល្បិច និងទម្លាប់បង្រៀនក្នុងគោលវិធី និងវិធីសាស្ត្រនីមួយៗ ក្នុងបរិបទអប់រំនៅកម្ពុជាទេ។ បរិបទអប់រំកម្ពុជា រួមមានបន្ទប់រៀន ការចាត់ចែងបន្ទប់រៀន គុណវុឌ្ឍិគ្រូបង្រៀន និងធនធានរូបវន្តក្នុងប្រព័ន្ធអប់រំ និងសាលារៀន ។ ប្រសិនបើបានសម្ភាស ឬសួរគ្រូបង្រៀនឱ្យល្អិតល្អន់ ដោយឱ្យគ្រូបង្រៀនផ្ដល់ឧទាហរណ៍ពីរ ឬបីអំពីវិធី ឬយុទ្ធវិធីក្នុងគោលវិធីសិស្សមជ្ឈមណ្ឌល ប្រហែលជាមានតែការពិភាក្សាក្រុមទេដែលពេញនិយម (Education Research Council, 2018) ។

*គុណផលសិក្សារបស់សិស្សសំដៅដល់លទ្ធផលច្រើនយ៉ាងពាក់ព័ន្ធនឹងការសិក្សារបស់សិស្ស ដូចជា សកម្មភាពសិស្សចូលរួមក្នុងថ្នាក់ សមត្ថភាពឆ្លើយសំណួរតេស្តច្រើនយ៉ាង កិច្ចការផ្ទះរបស់សិស្ស។ល។*

គ្រូបង្រៀនតាមសាលារៀន និងគ្រូឧទ្ទេសតាមគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន ស្គាល់គោលវិធី វិធីសាស្ត្រ និងយុទ្ធវិធីបង្រៀនច្រើនបែបច្រើនយ៉ាង។ទោះបីជាយ៉ាងណា គុណផលសិក្សា

របស់សិស្សនៅកម្ពុជា ឋិតក្នុងកម្រិតជជែកគ្នាខ្លាំងគួរឱ្យកត់សម្គាល់។ អ្នកអប់រំក្នុងរដ្ឋាភិបាល និងអ្នកទិតៀនប្រព័ន្ធអប់រំ តែងមានគំនិតខ្វែងគ្នា អំពីគុណផលសិក្សារបស់សិស្ស។ អ្នកទិតៀនប្រព័ន្ធអប់រំ ច្រើនយកលទ្ធផលប្រឡងមធ្យមសិក្សាទុតិយភូមិមកដាក់បន្ទុកជាអង្គហេតុ។ សិស្សកម្ពុជាភាគច្រើនប្រឡងមិនជាប់ បើទោះបីជាវិញ្ញាសាប្រឡងមិនសូវពិបាកក៏ដោយ។ ការប្រឡងមធ្យមសិក្សាទុតិយភូមិ ក្នុងឆ្នាំខ្លះ គឺសិស្សមកអង្គុយចម្លងគ្នា។ អ្នកទិតៀនចោទថា សិស្សពុំសូវទទួលវិជ្ជា បំណិន និងចរិយា ដូចការចង់បានជាសាធារណៈ និងការកំណត់ក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា។

របាយការណ៍របស់ស្ថាប័នអន្តរជាតិបំពេញការងារក្នុងវិស័យអប់រំ និងអភិវឌ្ឍន៍បានបន្ទរឱ្យការទិតៀនលើប្រព័ន្ធអប់រំកម្ពុជា ពិសេសគុណផលសិក្សារបស់សិស្ស កាន់តែមានតម្លៃ។ អង្គការអភិវឌ្ឍន៍សហប្រជាជាតិ UNDP (2011), ធនាគារអភិវឌ្ឍន៍អាស៊ី ADB (2015) និង ធនាគារពិភពលោក World BanK (2015) រាយការណ៍ថា យុវជនកម្ពុជាដែលបានចូលរៀន និងបានរៀនចប់ចេញមកធ្វើការក្នុងឧស្សាហកម្ម គឺខ្វះជំនាញ និងបំណិន ក្នុងការបំពេញការងារ។ របាយការណ៍ទាំងនោះបញ្ជាក់ថា ការខ្វះបំណិន និងជំនាញបំពេញការងារកើតឡើង ដោយសារបញ្ហាខ្សោយគុណភាពនៃការរៀន បង្រៀន ការអប់រំ និងការបណ្តុះបណ្តាល។

ប្រសិនបើជជែកគ្នាជាមួយតំណាងក្រុមហ៊ុន ឬអ្នកជំនួញនៅកម្ពុជាអំពីឥរិយាបថរបស់និយោជិតបម្រើការងារក្នុងក្រុមហ៊ុន និយោជកច្រើនលើកឡើងថា និយោជិតកម្ពុជាខ្វះកម្មន្តបំណិន ឬបំណិនការងារ និងគុណតម្លៃការងារ (អានលម្អិតក្នុងផ្នែក១០.៣) របស់បុគ្គលពូកែ។ ពិសេស និយោជិតកម្ពុជាមានលេសច្រើនដើម្បីអវត្តមានពីការងារ និងខ្វះការទទួលខុសត្រូវចំពោះគុណផលការងារ។

ដំណើរការរៀនពិតប្រាកដ ឬការរៀនប្រកបដោយគុណភាព គឺសិស្សសម្បូរសកម្មភាព និងប្រតិបត្តិដំណើរការរៀនដោយឯករាជ្យ និងពោរពេញដោយសេរីភាព។ ការរៀនពិតប្រាកដនៅកម្ពុជា ប្រហែលជាពិបាករក។ ការស្រាវជ្រាវមួយស្តីពី “ទម្លាប់ និងយុទ្ធវិធីបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យាកម្រិតមធ្យមសិក្សាបឋមភូមិ ថ្នាក់ទី៨“ ត្រូវបានធ្វើឡើង ដោយក្រុមអ្នកស្រាវជ្រាវរបស់ក្រុមប្រឹក្សាស្រាវ

ជ្រាវអប់រំ (Education Research Council, 2018) នៃក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៨។ ការស្រាវជ្រាវនេះប្រមូលទិន្នន័យតាមសាលារៀនគោលដៅ ក្នុងខេត្តចំនួនបី ៖ ១. ខេត្តបាត់ដំបង ២. ខេត្តកំពង់ចាម ៣. ខេត្តកំពត។ លទ្ធផលស្រាវជ្រាវបង្ហាញថា គ្រូបង្រៀនប្រវត្តិវិទ្យាថ្នាក់ទី៨ស្ទើរតែទាំងអស់និយមប្រើ និងឱ្យតម្លៃចំពោះគោលវិធីបង្រៀន មិនសូវប្រើគោលវិធីដឹកនាំការរៀនទេ។ យុទ្ធវិធីនិយមប្រើក្នុងគោលវិធីបង្រៀន ដូចជា រ៉ាយរ៉ាប់ រៀបរាប់ ពន្យល់ និងបកស្រាយខ្លឹមសារមេរៀនទាំងស្រុងប្រាប់សិស្ស។ គ្រូបង្រៀនពឹងជាធំលើព័ត៌មាន អង្គហេតុក្នុងមេរៀន នៃសៀវភៅសិក្សាគោល និងតាមការចេះចាំរបស់គ្រូបង្រៀន។

ការស្រាវជ្រាវនេះរកឃើញទៀតថា គ្រូបង្រៀនដែលមានបទពិសោធយូរឆ្នាំ ចូលចិត្តលើកយកយុទ្ធវិធី រ៉ាយរ៉ាប់ រៀបរាប់ ពន្យល់ និងបកស្រាយ។ លោកគ្រូអ្នកគ្រូដែលមានបទពិសោធបង្រៀនយូរឆ្នាំ ច្រើនផ្តល់ទស្សនៈការពារថា សិស្សចូលចិត្តស្តាប់គ្រូបង្រៀនរៀបរាប់ បកស្រាយ រាយរ៉ាប់ និងពន្យល់។

របកគំហើញនៃការស្រាវជ្រាវនេះ បានបញ្ជាក់អំពីយុទ្ធវិធីពេញនិយមប្រើមួយទៀត។ គ្រូបង្រៀននិយមឱ្យសិស្សអានអត្ថបទមេរៀនបន្តគ្នា អានបណ្តាក់គ្នា អានប្រដេញគ្នា ពីសិស្សម្នាក់ទៅសិស្សម្នាក់ទៀត រហូតចប់អត្ថបទមេរៀនដែលត្រូវលើកយកមកសិក្សាក្នុងម៉ោងនីមួយៗ។ យុទ្ធវិធីបង្រៀនពេញនិយមក្នុងចំណោមគ្រូបង្រៀនប្រវត្តិវិទ្យាហៅថា "**អានបន្ត អានបណ្តាក់ អានប្រដេញ**"។

"**អានបន្ត អានបណ្តាក់ អានប្រដេញ**" គឺបានព្ធសំឡេង និងខ្វះសកម្មភាពរបស់សិស្ស ក្នុងការសង្កេត ឆ្ងល់ គិត បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ នៃខ្លឹមសារមេរៀន និងបញ្ញត្តិនៃមេរៀន។ **អានបន្ត អានបណ្តាក់ អានប្រដេញ** ខ្វះសកម្មភាពរកបញ្ញត្តិ យល់បញ្ញត្តិ និងភ្ជាប់បញ្ញត្តិនៃមេរៀនជាមួយនឹងមេរៀន នៃមុខវិជ្ជាផ្សេង ជីវភាពប្រចាំថ្ងៃ និងការរៀនបន្ត។ សកម្មភាពក្រោយចប់អំណាន គឺត្រឹមឱ្យសិស្សរកពាក្យពិបាក ឬពាក្យគន្លឹះក្នុងមេរៀន និងខ្វះការអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ និងភ្ជាប់នឹងតម្រូវការពិត។

សកម្មភាពបំផុសសិស្សឱ្យសង្កេត គិត ឆ្ងល់ បង្កើតសំណួរ សួរ រកការបំភ្លឺ និងការពន្យល់ ពុំមែនជាទម្លាប់ ឬយុទ្ធវិធីរបស់គ្រូបង្រៀនប្រវត្តិវិទ្យាជាទូទៅ ក្នុង

បច្ចុប្បន្ននេះទេ។ សកម្មភាពឱ្យសិស្សរកព័ត៌មានពីប្រភពផ្សេងៗ ដូចជា សម្ភាសចាស់ៗ និងសរសេរអត្ថបទខ្លីអំពីប្រវត្តិ នៃកន្លែងធ្លាប់ស្គាល់ កន្លែងពេញនិយម ឬប្រវត្តិមនុស្សពូកែៗក្នុងសហគមន៍ គឺរកមិនបាន ក្នុងចំណោមគ្រូបង្រៀនប្រវត្តិវិទ្យាដែលបានចូលរួមក្នុងដំណើរការស្រាវជ្រាវទេ។

រកគំហើញ នៃការស្រាវជ្រាវនេះបញ្ជាក់បន្ថែមមួយចំណុចទៀត។ គ្រូបង្រៀនប្រកាន់ជំហរ ជំនឿ និងទស្សនៈមាំទាំគួរពិចារណា។ គ្រូបង្រៀនបញ្ជាក់ថាការមិនផ្តល់សញ្ញាណមុន ឬមិនប្រាប់មុន សិស្សរៀនមិនចេះទេ។ ការបារម្ភធំរបស់គ្រូបង្រៀន គឺភ័យខ្លាចសិស្សរៀនមិនចេះ និងពុំទាន់មានព័ត៌មាន ឬចំណេះដឹងមូលដ្ឋានមុន។ ដូច្នេះ គ្រូបង្រៀនត្រូវប្រាប់ រ៉ាយរ៉ាប់ រៀបរាប់ ពន្យល់ និងបកស្រាយឱ្យសិស្សមានមូលដ្ឋាននៃចំណេះដឹងជាមុន ជាភាពចាំបាច់។

រកគំហើញនៃការស្រាវជ្រាវនេះបញ្ជាក់បន្ថែមថា ការបញ្ចប់មេរៀនតាមចំណងជើងគោល និងចំណងជើងរងក្នុងសៀវភៅសិក្សាគោល ជាកាតព្វកិច្ចនិងបំពេញចិត្តអធិការកិច្ច។ មន្ត្រីជំនាញអធិការកិច្ច រួមមាន នាយកសាលាការិយាល័យអប់រំស្រុក មន្ទីរអប់រំខេត្ត និងពីក្រសួង។ អធិការកិច្ចជាបន្ទុក និងការបារម្ភរបស់គ្រូបង្រៀនក្នុងការបញ្ចប់មេរៀនតាមចំណងជើង ឬការបង្រៀនឱ្យចប់មេរៀនតាមសៀវភៅ។ ការបង្រៀនដោយឱ្យសិស្សសង្កេត គិត ឆ្លុះ បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ ពីច្រើនប្រភព គឺបង្រៀនមិនចប់មេរៀនតាមម៉ោងកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡាទេ។ ការស្រាវជ្រាវនោះ ពុំបានវែកញែក និងវិភាគឱ្យល្អិតល្អន់ អំពីភាពពិតប្រាកដ និងច្បាស់លាស់អំពីបន្ទុករបស់គ្រូបង្រៀន ដើម្បីបញ្ចប់មេរៀនឱ្យពេញចិត្តអធិការកិច្ចគ្រប់កម្រិតទេ។

## ៣. គោលបំណង

ប្រវត្តិវិទ្យា គួរជាមុខវិជ្ជាផ្តក់អារម្មណ៍របស់អ្នកសិក្សាឱ្យចង់រៀន និងចង់អាន។ ប្រវត្តិវិសាស្ត្របង្រៀនមនុស្សឱ្យយល់ស៊ីជម្រៅ អំពីពុទ្ធិរបស់មនុស្សជវភាព និងការវិវឌ្ឍនៃសង្គមនិងប្រជាសាស្ត្រ ព្រឹត្តិការណ៍ ទីកន្លែង វប្បធម៌ អរិយធម៌។ ប្រវត្តិសាស្ត្របង្រៀនមនុស្ស ឱ្យមានសមត្ថភាពភ្ជាប់ពុទ្ធិមនុស្សក្នុង

ប្រវត្តិសាស្ត្រ ជាមួយនឹងតម្រូវការរបស់មនុស្សក្នុងបច្ចុប្បន្ន និងអនាគត។ ប្រវត្តិសាស្ត្របង្រៀនមនុស្ស ឱ្យក្លាយជាអ្នកដឹកនាំមនុស្សឈានទៅរកចម្រុងចម្រើន។ ប្រវត្តិសាស្ត្របង្រៀនមនុស្សឱ្យមានចិត្តទូលាយ ចូលរួមបង្កើតសង្គមមួយពោរពេញដោយចិត្តមេត្តា មេត្រីភាព ក្តីស្រលាញ់ និងសង្គ្រោះ។

គុណតម្លៃមនុស្ស មានសុជីវធម៌ សីលធម៌ និងគុណធម៌។

ដូច្នេះ គ្រូបង្រៀនពូកែត្រូវមានសមត្ថភាពភ្ជាប់ពុទ្ធិមនុស្ស និងព្រឹត្តិការណ៍ ក្នុងប្រវត្តិសាស្ត្រ ទៅនឹងតម្រូវការរបស់មនុស្សក្នុងបច្ចុប្បន្ន និងអនាគត។ ការភ្ជាប់ប្រវត្តិសាស្ត្រជាមួយនឹងតម្រូវការរបស់មនុស្ស ក្នុងបច្ចុប្បន្ន និងអនាគត សំដៅធានាឱ្យមុខវិជ្ជាប្រវត្តិវិទ្យាពេញនិយមក្នុងការរៀន។

សៀវភៅនេះ សរសេរក្នុងគោលបំណងបើកផ្លូវគិត និងពង្រីកវិសាលភាពនៃគំនិតរបស់គ្រូបង្រៀនប្រវត្តិវិទ្យាឱ្យកាន់តែទូលំទូលាយអំពីគោលវិធី វិធីសាស្ត្រ និងយុទ្ធវិធីដឹកនាំការរៀនឱ្យសម្បូរបែប។ គ្រូបង្រៀនដែលមានគំនិតទូលំទូលាយ មានបេះដូងជាម្ចាស់ទាននៃពុទ្ធិ ដល់មនុស្សគ្រប់ជំនាន់។ គ្រូបង្រៀនចិត្តទូលាយ និងមានវុឌ្ឍិចរិត (ចរិតជឿនលឿនទៅរកសេចក្តីល្អ) តែងស្វែងវិជ្ជាបន្ថែមលើគោលវិធី វិធីសាស្ត្រ និងយុទ្ធវិធីដឹកនាំការរៀន និងបង្រៀនឱ្យសម្បូរបែប។ សៀវភៅនេះផ្តោតការយកចិត្តទុកដាក់លើ ៖

- គោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល
- សិក្សាបញ្ញត្តិ
- បុច្ឆនសិក្សា
- ទិសវិធីដឹកនាំការរៀន
- ដំណើរការវាយតម្លៃលទ្ធផលសិក្សាកម្រិតថ្នាក់រៀន។

សៀវភៅនេះផ្តល់ការសន្ទតិមួយ ៖ *"សិស្សនឹងចូលរួមបង្កើតសង្គមមួយពោរពេញដោយចិត្តមេត្តា មេត្រីភាព និងក្តីស្រលាញ់។ ការដឹកនាំការរៀនប្រកបដោយគុណភាព ឬការរៀនពិតប្រាកដ សំដៅធានាឱ្យសិស្សមានឯករាជ្យ និងសេរីភាពក្នុងការស្វែងវិជ្ជា ឬដឹកនាំសិស្សឱ្យគិតដូចអ្នកវិទ្យាសាស្ត្រ។ ការស្វែងវិជ្ជា និងការគិតដូចអ្នកវិទ្យាសាស្ត្រ សំដៅដាំបណ្តុះចិត្តសិស្សឱ្យចាប់ផ្តើមពី*

*ការសង្កេត ឆ្លុះ គិត បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់។ ដំណើរការរៀនបែបនេះនឹងទាក់ទាញការចូលរួមរបស់សិស្សយ៉ាងសកម្ម ក្នុងដំណើរការរៀននៃមេរៀនប្រវត្តិវិទ្យា។ ដំណើរការរៀនបែបនេះអភិវឌ្ឍវិជ្ជា បំណិន ចរិយា ការប្រព្រឹត្តិ និងបញ្ញា សម្រាប់ជីវភាពប្រចាំថ្ងៃ ការងារ និងរៀនបន្ត។"*

លម្អិតជាងនេះទៀត សៀវភៅនេះផ្សំផ្គុំសិក្សាបញ្ញត្តិ និងបុច្ចនសិក្សា ដើម្បីតាក់តែងលំនាំនៃការដឹកនាំការរៀន ឱ្យសិស្សពង្រីកវិសាលភាព នៃគំនិត និងបន្ថែមជម្រៅនៃការគិត ដូចអ្នកវិទ្យាសាស្ត្រ។ លំនាំនៃការដឹកនាំការរៀនជាផែនការដំបូងមួយ សម្រាប់តាក់តែងកិច្ចតែងការបង្រៀន។ ទិសវិធីដឹកនាំការរៀន ជាលំនាំនៃសកម្មភាពបន្ថែមសម្រាប់គ្រូបង្រៀនប្រតិបត្តិប្រចាំម៉ោង និងប្រចាំថ្ងៃ យកទៅដាក់បញ្ចូលក្នុងដំណើរការដឹកនាំការរៀនក្នុង និងក្រៅថ្នាក់ តាមវិធីសាស្ត្រសិក្សាបញ្ញត្តិ និងបុច្ចនសិក្សា។

> ទិសវិធីដឹកនាំការរៀនជាលំនាំ ឬវិធីសាស្ត្របង្រៀនមួយបែប សម្រាប់បង្រៀនសិស្សចម្រុះសមត្ថភាព។ សិស្សមានជម្រើសក្នុងការរៀនបញ្ញត្តិ និងសង្កេតតាមសមត្ថភាពគិតរៀងខ្លួន។

ទិសវិធីដឹកនាំការរៀន មានភាពចាំបាច់សម្រាប់បំពេញបន្ថែម ក្នុងដំណើរការដឹកនាំការរៀនក្នុងបរិបទអប់រំ និងសាលារៀនរបស់កម្ពុជា។ ទិសវិធីសំដៅដល់ការបែងចែកវិធី និងយុទ្ធវិធីរៀន ទៅតាមសមត្ថភាពគិត តម្រូវការ បទពិសោធ និងទម្លាប់រៀនរបស់សិស្ស។

ប្រព័ន្ធសាលារៀន និងថ្នាក់រៀនកម្ពុជា មានសិស្សចម្រុះសមត្ថភាព និងសាវតារនៃសេដ្ឋកិច្ច និងសង្គម នៃគ្រួសារសិស្សកម្ពុជា មានច្រើនប្រភេទ។ ប្រព័ន្ធសាលារៀនកម្ពុជា និងថ្នាក់រៀន មានសិស្សច្រើនប្រភេទ គិតទាំងសិស្សរៀនខ្សោយ រៀនយឺត និងសិស្សមានតម្រូវការពិសេស រៀនជាមួយគ្នា។

ចេតនានៃការណែនាំទិសវិធីដឹកនាំការរៀន សំដៅបំពេញបន្ថែមទម្លាប់ដែលអ្នកគ្រូ លោកគ្រូ កំពុងអនុវត្ត ក្នុងពេលបច្ចុប្បន្ន។ ទម្លាប់អនុវត្តបច្ចុប្បន្ន ក្នុងដំណើរការបង្រៀនក្នុងថ្នាក់ គឺគ្រូបង្រៀនភាគច្រើនប្រើយុទ្ធវិធីមួយសម្រាប់

សិស្សគ្រប់ប្រភេទ។ ទម្លាប់បង្រៀនបច្ចុប្បន្ន គឺគ្រូបង្រៀននិយមរាយរាប់រៀបរាប់ បកស្រាយ និងពន្យល់ អានបន្ត អានបណ្ដាក់ និងអានប្រដេញ។

សៀវភៅនេះបញ្ចូលវិធី និងយុទ្ធវិធីវាយតម្លៃលទ្ធផលសិក្សា ដើម្បីកែលម្អដំណើរការរៀន និងដឹកនាំការរៀន។ ការវាយតម្លៃលទ្ធផលសិក្សានេះ នឹងត្រូវប្រើជាមធ្យោបាយសម្រាប់ជួយលើកកម្ពស់គុណផលសិក្សារបស់សិស្ស ក្នុងដំណើរការរៀន។ លទ្ធផលនៃការអនុវត្តវិធីសាស្ត្រដឹកនាំការរៀន និងការវាយតម្លៃធានាឱ្យប្រព័ន្ធអប់រំមានគុណភាព។ ប្រព័ន្ធអប់រំនឹងផ្គត់ផ្គង់កម្លាំងពលកម្មប្រកបដោយគុណភាព សម្រាប់ធានាកំណើនសេដ្ឋកិច្ច ចីរភាពអភិវឌ្ឍន៍។ ដូច្នេះកម្ពុជានឹងក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ ត្រឹមឆ្នាំ២០៣០ ឬចំណូលខ្ពស់ ត្រឹមឆ្នាំ២០៥០។

## ៤. ម្ចាស់ទានគ្រប់ជំនាន់មនុស្ស

ព្រះពុទ្ធ (Siddhartha Gautama, ឆ្នាំ៥៦៣ ឬ ៤៨០មុន គ.ស - ឆ្នាំ៤៨៣ ឬ៤០០ មុនគ.ស) និងអ្នកដឹកនាំសាសនាផ្សេងទៀត ក៏សុទ្ធតែបង្រៀនមនុស្សឱ្យក្លាយជាបុគ្គលពូកែ។ គម្ពីរព្រះត្រៃបិដកនៃព្រះពុទ្ធសាសនាជាភាសាខ្មែរ (Khmer Buddhism Institute , 1931) និង Dhammapada ជាភាសាអង់គ្លេស (wisdom library, 2008; Burma Tipitaka Association , 2020) បង្រៀនមនុស្សឱ្យបណ្ដុះគុណសម្បទាពីរ ១. វិជ្ជា និង២. ចរណៈ។ មនុស្សមួយនាក់មានវិជ្ជាខ្ពង់ខ្ពស់ បើទោះបីជាបានរៀនដល់កម្រិតណា អានសៀវភៅចប់មួយបណ្ណាល័យ ចេះចាំមន្តនិងយល់សេចក្ដីក្នុងគ្រប់គម្ពីរអស់ក៏ដោយ ប៉ុន្តែមនុស្សខ្វះចរណៈ មនុស្សនោះពុំអាចក្លាយជាបុគ្គលពូកែបានទេ។

គោលបំណង នៃការរៀនរបស់មនុស្សគ្រប់រូប និងការចង់បានរបស់មាតាបិតា អាណាព្យាបាល និយោជក និងសិស្ស សំដៅអភិវឌ្ឍវិជ្ជា និងចរណៈដើម្បីក្លាយជាពលរដ្ឋពូកែ។ គ្រូបង្រៀនជាអ្នកដឹកនាំមនុស្សឱ្យរៀនរហូតអភិវឌ្ឍទាំងវិជ្ជា និងចរណៈ។

> អារីស្តូត ទស្សនវិទូជាតិ ក្រិកកើតថ្ងៃទី១៩មិថុនា ឆ្នាំ៣៨៤ មុនគ.ស. និងស្លាប់នៅថ្ងៃ៧មីនាឆ្នាំ ៣២២ មុនគ.ស.។ អាឡិចហ្សង់ មហារាជ ជាក្សត្រនៃព្រះរាជាណាចក្រក្រិក នៃម៉ាសេដូនៀ និងកើតក្នុងខែកក្កដា ឆ្នាំ៣៥៦ មុនគ.ស. ស្លាប់ក្នុងខែមិថុនា ឆ្នាំ៣២៣ មុនគ.ស.។

អារីស្តូត Aristotle ប្រាប់ដល់សិស្សគាត់ *"ការអប់រំដែលចេញពីគ្រូបង្រៀន គឺល្វីង ប៉ុន្តែផ្លែបានពីការអប់រំ របស់គ្រូបង្រៀនផ្អែមមុត។"* អាឡិចហ្សង់មហារាជ (Alexander the Great) ឱ្យតម្លៃខ្ពស់បំផុតចំពោះគ្រូបង្រៀន។ អាឡិចហ្សង់មហារាជនិយាយថា *"សិស្សជំពាក់បំណុលម្តាយ ឪពុក ត្រឹមជីវិតរស់លើផែនដី ប៉ុន្តែជំពាក់បំណុលគ្រូបង្រៀន គឺជីវិតសម្បូរទ្រព្យ។"*

ដោយសារហេតុផលនេះ គ្រូបង្រៀនមានបញ្ញាប្រាកដ អំពីដំណើរនៃការរៀនដែលគ្មានទីបញ្ចប់ និងសម្លឹងអនាគតវែងឆ្ងាយ សម្រាប់មនុស្សគ្រប់ជំនាន់។ គ្រូបង្រៀនតែងចង់ឱ្យសិស្សជោគជ័យក្នុងជីវិត ជួយដល់ផែនដី និងចក្រវាលនេះឱ្យបានច្រើនតាមលទ្ធភាព និងសមត្ថភាព ដោយប្រើទាំងវិជ្ជា និងចរណៈ។

ការបំពេញងារជាម្ចាស់ទាន គ្រូបង្រៀនពិតជាមានមោទនភាពណាស់។ គ្រូបង្រៀនជាអ្នកបណ្តុះពូជនៃចិត្តមេត្តា ស្រឡាញ់ មេត្រីភាព និងសេចក្តីពិត។ គ្រូបង្រៀនជាអ្នកដាំបណ្តុះពូជនៃវុឌ្ឍិវិជ្ជា វុឌ្ឍិបំណិន និងវុឌ្ឍិចរិយា ឱ្យមនុស្សចម្រើនគ្រប់ជំនាន់ ដោយមិនប្រកាន់ប្រភេទ វណ្ណៈ ជាតិសាសន៍។ល។ វុឌ្ឍិវិជ្ជា វុឌ្ឍិបំណិន និងវុឌ្ឍិចរិយាជាយានដឹកនាំមនុស្សទៅរកសេចក្តីចម្រើន និងរស់ក្នុងសុខុមាលភាព។ មោទនាភាពរបស់គ្រូបង្រៀន គឺវិស្វករព្រលឹងបង្កើតសង្គមពោរពេញដោយចិត្តមេត្តា មេត្រីភាព ក្តីស្រលាញ់ និងសង្គ្រោះ។

## ៥. បញ្ហាកម្ម (ការវិភាគបញ្ហា)

ការរៀនពិតប្រាកដដែលមិនអាចកើតឡើងសម្រាប់សិស្សគ្រប់រូប អង្គុយក្នុងថ្នាក់រៀន មានសេចក្តីពន្យល់ផ្សេងគ្នា តាមជ្រុងនៃទិន្នន័យរបស់អ្នកពន្យល់ផ្សេងគ្នា។ ប្រសិនបើ សួរគ្រូបង្រៀនពីរនាក់ដែលដឹកនាំការរៀននៅថ្នាក់តែមួយក្នុងឆ្នាំសិក្សាតែមួយ សិស្សក្នុងក្រុមតែមួយ គ្រូបង្រៀននឹងផ្តល់ចម្លើយផ្សេងគ្នា។

ចម្លើយសាមញ្ញរបស់គ្រូបង្រៀនខ្វះគុណសម្បទាគ្រូបង្រៀនពូកែ ភាគច្រើន ចោទកត្តាក្រៅខ្លួន ៖

- សិស្សមិនប្រឹងរៀន ដោយខ្លួនវា
- គ្រួសារពុំជួយ ឬពុំសួរខ្វល់អំពីកូនរៀននៅផ្ទះ
- សម្ភារៈអូសទាញ ដូចជា ទូរស័ព្ទ ម៉ូតូថ្មី
- ការងាររោងចក្រអូសទាញ ។

គ្រូបង្រៀន ឬអ្នកស្រាវជ្រាវអាចពន្យល់ហេតុផលច្រើនផ្សេងទៀត ៖

- សិស្សខ្វះសៀវភៅសិក្សាគោល
- បណ្ណាល័យមិនដំណើរការ
- ម៉ោងបង្រៀនខ្លីពេក
- ថ្នាក់រៀនដាក់សិស្សចំនួនច្រើនពេក
- គ្រូបង្រៀនពុំបានបំប៉នវិធីសាស្ត្របង្រៀនថ្មីៗ
- គ្រូបង្រៀនពុំបានទទួលសុក្រឹតការពីបច្ចេកវិទ្យាឌីជីថលសម្រាប់បង្រៀន
- គ្រូបង្រៀនប្រាក់ខែតិច
- មាតាបិតា តំណាងសហគមន៍ពុំសូវសកម្ម និងចូលរួមធានាគណនេយ្យភាពក្នុងដំណើរការសាលារៀន

សិស្សមកអង្គុយក្នុងថ្នាក់រៀន ពុំមែនបានរៀនគ្រប់ៗគ្នា ដូចៗគ្នា និងទទួលបានកម្រិត ជម្រៅ និងទំហំនៃពុទ្ធិដូចគ្នាទេ។ ក្រោយពីអង្គុយរៀនចប់មួយម៉ោង ចប់មួយមេរៀន សិស្សមួយចំនួន ពុំអាចប្រាប់ឡើងវិញអំពីខ្លឹមសារគោលមួយ ឬគោលគំនិតមួយ។ សិស្សខ្លះរៀនចប់មួយមេរៀន សូម្បីចាំពាក្យគន្លឹះមួយមិនបានផង។ សិស្សខ្លះរៀនចប់មួយឆ្នាំ ពុំបានរៀនចាំខ្លឹមសារគោលនៃមេរៀនសម្រាប់ការប្រឡងជាប់ប្រចាំឆ្នាំផង។ តើសិស្សពុំចាំខ្លឹមសារគោល គោលគំនិត ឬពាក្យគន្លឹះក្រោយពីរៀនចប់មេរៀនមួយ និងប្រឡងធ្លាក់ក្រោយចប់ឆ្នាំសិក្សា មានបញ្ហាអ្វីគួរឱ្យកត់សម្គាល់ដែរឬទេ?

អ្នកគ្រូ លោកគ្រូអាចសង្កេតជាប្រចាំឱ្យបានរយៈពេល៤សប្ដាហ៍ជាប់គ្នាលើទម្លាប់ និងសកម្មភាពរបស់អ្នកគ្រូ លោកគ្រូផ្ទាល់។ សូមលោកគ្រូ អ្នកគ្រូ កុំ

ទាន់ចោទសិស្សមិនខំប្រឹងរៀន ឪពុកម្តាយមិនជួយណែនាំនៅផ្ទះ ឬសង្គមបំពុលក្មេងដោយសម្ភារៈ។ល។ បន្ទាប់មក សូមអ្នកគ្រូ លោកគ្រូ កត់ត្រាលទ្ធផលនៃការសង្កេត និងឆ្លើយសំណួរមួយចំនួនខាងក្រោម ៖

- តើខ្ញុំចូលដល់ក្នុងថ្នាក់ទាន់ម៉ោងឬទេ?
- តើខ្ញុំចំណាយពេលនិយាយ រៀបរាប់ រ៉ាយរ៉ាប់ បកស្រាយច្រើនជាងពេលវេលាខ្ញុំទុកឱ្យសិស្សគ្រប់ៗរូប ធ្វើសកម្មភាពឬទេ?
- តើខ្ញុំចំណាយពេលប៉ុន្មាននាទី ក្នុងមួយម៉ោងសិក្សា ផ្តល់ឱកាសឱ្យសិស្សរកការពន្យល់លើបញ្ញត្តិនៃមេរៀនពីប្រភពផ្សេង ក្រៅពីសៀវភៅ?
- តើខ្ញុំបង្កបរិយាកាសឱ្យសិស្សសង្កេត គិត ឆ្ងល់ បង្កើតសំណួរ លម្អសំណួរសួរសំណួរ និងស្វែងការពន្យល់ដោយឯករាជ្យ និងសេរីភាពកម្រិតណា?
- តើខ្ញុំចោទសួរសិស្សដោយប្រើប្រភេទ និងកម្រិតលំបាកនៃសំណួរឬទេ?
- តើខ្ញុំកំពុងគិតថា ខ្ញុំកំពុងបណ្តោយសិស្សឱ្យមានសេរីភាព និងឯករាជ្យច្រើនពេក ខ្ញុំមិនអាចបង្រៀនសិស្សឱ្យចប់មេរៀនឬទេ?
- តើខ្ញុំវាយតម្លៃការសិក្សា ចាំដាច់ខែ ឬឆមាសបានធ្វើឬយ៉ាងណា?
- តើខ្ញុំប្រើទ្រឹស្តីអ្វីសម្រាប់វាយតម្លៃការសិក្សារបស់សិស្ស?
- តើក្នុងមួយសប្តាហ៍ ខ្ញុំប្រើវិធី ឬ យុទ្ធវិធីប៉ុន្មានវាយតម្លៃការសិក្សា?
- តើខ្ញុំបានប្រើលទ្ធផលវាយតម្លៃការសិក្សារបស់សិស្ស ដើម្បីកែលម្អដំណើរការរៀន និងដឹកនាំការរៀនបានច្រើនប៉ុនណា?
- តើខ្ញុំចាត់ទុកការវាយតម្លៃការសិក្សាជាវិធីដឹកនាំការរៀនឬទេ?

ដំណើរការដឹកនាំការរៀនពិតប្រាកដ គឺអន្ទងព្រលឹង ឬបើកចិត្តសិស្សឱ្យសង្កេត ពង្រីកការគិត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ ចង់អាន ចូលរួម ចង់ស្តាប់ ចង់ឡើងនិយាយ និងចង់ចែករំលែកគំនិត និងបទពិសោធ។ តើសិស្សរបស់ខ្ញុំមានចំនួនប៉ុន្មាននាក់ដែលបើកចិត្តទូលាយបែបនេះ? របកគំហើញនៃការស្រាវជ្រាវជាច្រើនបញ្ជាក់ថា លើកលែងសិស្សមានជំងឺប្រព័ន្ធប្រសាទ ទើបរៀនមិនចាំ មិនចេះ ប្រសិនបើដំណើរការរៀនពិតប្រាកដ ឬប្រកបដោយគុណភាព កើតឡើង

ជាមួយគ្រូបង្រៀន និងជាមួយសិស្សរួមថ្នាក់ (Darling-Hammond, 1999; Coffman, 2013; Westwood, 2008; Tomlinson , 1999)។

ចូរលោកគ្រូ អ្នកគ្រូ សាកល្បងរំឭកអំពីសកម្មភាព នៃការរៀនរបស់យើង ៥៩វិនាទី! រាល់ពេលយើងរៀន ខួរក្បាលរបស់យើងរៀបចំប្រព័ន្ធគិត រំឭកអង្គហេតុ ពង្រីកភាពចងចាំ និងភ្ជាប់ធាតុដែលកំពុងរៀនជាមួយអ្វីដែលធ្លាប់ដឹងតិចតួច និងដឹងច្រើន។ តើពិតមែនឬទេ?

ដូច្នេះ ដើម្បីដឹកនាំការរៀនពិតប្រាកដជាមួយសិស្សគ្រប់ប្រភេទ គ្រូបង្រៀនត្រូវចាំថា យើងកំពុងធ្វើដំណើរជាមួយសិស្ស ដើម្បីភាពរីកចម្រើននូវប្រព័ន្ធគិត ឬម៉ាស៊ីនគិតរបស់សិស្ស។ ដើម្បីធានាឱ្យប្រព័ន្ធគិត ឬម៉ាស៊ីនគិតរបស់សិស្សដំណើរការល្អ អ្នកគ្រូ លោកគ្រូត្រូវគិតអំពីអ្វីដែលសិស្សធ្លាប់ស្គាល់ ឬធ្លាប់ដឹង ទោះបីតិចតួចក្តី ឬច្រើនក្តី។ និយាយភាសាសាមញ្ញមួយទៀត គឺដឹកនាំការរៀនជាមួយសិស្ស ដោយប្រើបទពិសោធរបស់សិស្ស។

ប្រព័ន្ធអប់រំ សាលារៀន ឬថ្នាក់រៀនកម្ពុជា កំពុងប្រឈមនឹងបញ្ហាសិស្សមិនបានរៀនពិតប្រាកដ។ តើសិស្សជាច្រើននាក់រៀនមិនចេះ រៀនមិនចាំខ្លឹមសារគោលគំនិត ពាក្យគន្លឹះ ក្នុងមេរៀនមានបញ្ហាប្រព័ន្ធប្រសាទ ឬយ៉ាងណា? តើមានវិធីអ្វីជួយសិស្សដែលរៀនមិនចេះ រៀនមិនចាំ រៀនមិនយល់ដែរឬទេ?

គុណភាពនៃការរៀន ក្នុងបរិបទអប់រំកម្ពុជាប្រហែលជាពិបាករកបន្តិច។ តេស្តថ្នាក់ទី៣ ទី៦ និងទី៨ លើមុខវិជ្ជាភាសាខ្មែរ និងគណិតវិទ្យាជាឧទាហរណ៍ ក្នុងឆ្នាំ២០១៥ ឆ្នាំ២០១៦ និងឆ្នាំ២០១៧ រៀបចំដោយនាយកដ្ឋានធានាគុណភាពអប់រំ នៃក្រសួង អប់រំ យុវជន និងកីឡា បង្ហាញលទ្ធផលគួរឱ្យពិចារណា។ សិស្សដែលបានមកអង្គុយរៀនក្នុងថ្នាក់ពេញមួយឆ្នាំ ប៉ុន្តែមិនបានទទួលចំណេះដឹង និងវិជ្ជានៃមុខវិជ្ជាដែលបានរៀនជាមួយគ្រូបង្រៀន និងជាមួយសិស្សក្នុងថ្នាក់។ ដូច្នេះ សិស្សប្រហែលពី៤០ទៅ៥០ភាគរយប្រឡងជាប់តេស្តវាយតម្លៃ (Ministry of Education, Youth and Sport, 2018)។ លទ្ធផលនេះពុំបានវិភាគឱ្យគ្រប់ជ្រុងជ្រោយ និងស៊ីជម្រៅអំពីកម្រិតលំបាក និងភាពងាយនៃវិញ្ញាសាតេស្ត និងសុក្រឹតភាពនៃដំណើរការ និងរដ្ឋបាលនៃការធ្វើតេស្តតាមសាលារៀនទេ។

គុណភាពនៃការរៀននៅកម្រិតខ្ពស់ក៏ពិបាករកទៀត។ ការប្រឡងមធ្យមសិក្សាទុតិយភូមិចាប់ពីឆ្នាំ២០១៤ដែលបានធានារដ្ឋបាលប្រឡង បានយ៉ាងត្រឹមមានសិស្សប្រឡងជាប់មិនដល់៣០ភាគរយទេ។ ការប្រឡងនៃឆ្នាំបន្តបន្ទាប់ពីឆ្នាំ២០១៥ដល់២០១៨ សិស្សប្រឡងជាប់ខ្ពស់បំផុត ចន្លោះ៥០ឬ៦០ភាគរយ ក្នុងឆ្នាំ២០១៨ (Ministry of Education, Youth and Sport, 2018)។ ទោះបីជាយ៉ាងណាពុំទាន់មានការស្រាវជ្រាវណាមួយបញ្ជាក់ អំពីតម្លៃនៃពិន្ទុ សម្រាប់ប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ ក្នុងចន្លោះឆ្នាំទាំងនោះទេ។

លទ្ធផល នៃការវាយតម្លៃការសិក្សារបស់សិស្សកម្ពុជា កម្រិតអន្តរជាតិអាយុ១៥ឆ្នាំ (PISA-D ២០១៨) ពន្យល់ថា សិស្សកម្ពុជាខ្សោយគណិតវិទ្យា និងអំណាន។ លទ្ធផលវាយតម្លៃនេះនាំផ្លូវចិត្តរបស់អ្នកដឹកនាំអប់រំ និងគ្រូបង្រៀនឱ្យគិតរកមធ្យោបាយ វិធីសាស្ត្រដឹកនាំការរៀន និងយុទ្ធវិធីបង្រៀនថ្មីៗដែលនាំឱ្យសិស្សប្រតិបត្តិច្រើនជាង ការអាន និងស្តាប់គ្រូបង្រៀនពន្យល់ បកស្រាយ និងរៀបរាប់ដែលកំពុងពេញនិយម ក្នុងចំណោមគ្រូបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា (Education Research Council, 2018)។

ការរៀនពិតប្រាកដ គឺ សិស្សត្រូវរៀនលើសពីត្រឹមទទួលព័ត៌មាន ឬត្រឹមចាំចំណងជើង ចំណងជើងរង អង្គហេតុ ពាក្យគន្លឹះ និងខ្លឹមសារ សរសេរក្នុងសៀវភៅសិក្សាគោល។ ការស្រាវជ្រាវជាច្រើនបញ្ជាក់ដូចៗគ្នាថា សិស្សមិនបានរៀនពិតប្រាកដ ឬការរៀនមិនប្រកបដោយគុណភាព គឺមួយចំណែកធំបង្កឡើងដោយសារជំងឺកើតឡើងក្នុងដំណើរការបង្រៀន ការរៀន ឬការដឹកនាំការរៀន (Tomlinson , 1999)។

ជំងឺក្នុងដំណើរការរៀន បង្រៀន និងដឹកនាំការរៀន អាចកើតឡើងក្នុងដំណាក់កាលជាច្រើន។ ជំងឺអាចកើតឡើងក្នុងដំណើរការតាក់តែងកម្មវិធីសិក្សា និងខ្លឹមសារនៃសៀវភៅសិក្សា ដំណើរការជ្រើសរើសគរុសិស្ស និងនិស្សិត កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន កម្មវិធីរិក្រឹតការ និងសុក្រឹតការគ្រូបង្រៀន ដំណើរការថ្នាក់រៀន ការគ្រប់គ្រងសាលារៀន។ល។

ដើម្បីធានាឱ្យដំណើរការ នៃការរៀនពិតប្រាកដ កើតឡើងចំពោះសិស្សគ្រប់រូប Tomlinson (1999), King, Erickson & Sebranek (2012), Jacobs, Renandya & Power (2016), Nilsen, Gustafsson, & Blomeke (2016) និង Blomeke, Olsen & Suhl (2016) ផ្តល់យោបល់ឱ្យអ្នកអប់រំ អ្នកដឹកនាំសាលារៀន និងគ្រូបង្រៀនពិនិត្យឡើងវិញចំពោះគុណភាពរបស់គ្រូបង្រៀន និងប្រសិទ្ធភាពនៃដំណើរការដឹកនាំការរៀន ឬការបង្រៀនរបស់គ្រូបង្រៀន។

របកគំហើញនៃការស្រាវជ្រាវរបស់ Darling-Hammond (1999), Niss (2002), Association of Teacher Educators and Rowman & Littlefield Education (2009), Kyriacou (2009), Alfrieri, Brooks, Aldrich, & Harriet (2011), McEwan (2014), Nilsen, Gustafsson, & Blomeke (2016), Blomeke, Olsen & Suhl (2016), Westwood (2008) និង Stern, Lauriault, & Ferraro, (2018) ពន្យល់អំពីចំណងជាប់គ្នាជាច្រវាក់យ៉ាងរឹងមាំ រវាងការដឹកនាំការរៀន និងការប្រើវិធីសាស្រ្តបង្រៀន ដឹកនាំការរៀន ការវាយតម្លៃលទ្ធផលសិក្សា និងគុណវុឌ្ឍិរបស់គ្រូបង្រៀន។

ការស្រាវជ្រាវខាងលើពន្យល់ថា សិស្សទទួលបានគុណផលសិក្សាខ្ពស់ ប្រសិនបើសិស្សរៀនជាមួយគ្រូបង្រៀន ដែលយល់អំពីបញ្ញត្តិនៃមុខវិជ្ជាឯកទេស បរិបទសិស្ស វិធីសាស្រ្តវាយតម្លៃ និងគោលការណ៍នៃការអភិវឌ្ឍកម្មវិធីសិក្សា។ ដូច្នេះ ដំណោះស្រាយបញ្ហានៃការមិនបានរៀនពិតប្រាកដរបស់សិស្សកម្ពុជា ត្រូវផ្តោតការយកចិត្តទុកដាក់ និងផ្តល់អាទិភាពលើគ្រូបង្រៀន។

## ៦. អ្នកសិក្សាក្នុងយុគឧស្សាហកម្ម៤.០

ការយល់អំពីបរិបទសិស្សជាចំណែកដ៏ធំមួយ ក្នុងការធានារកយុទ្ធវិធីដឹកនាំការរៀនឱ្យស្របតាមតម្រូវការ ការចូលចិត្ត និងទម្លាប់របស់សិស្ស។ សិស្សមកអង្គុយក្នុងថ្នាក់រៀន ពុំមែនជាប្រអប់ទទេទេ។ សិស្សមកអង្គុយរៀនក្នុងថ្នាក់ នាំមកក្នុងថ្នាក់រៀននូវបទពិសោធ សម្រាប់ប្រើក្នុងដំណើរការរៀន និងចែក

វិលែកជាមួយសិស្ស និងគ្រូបង្រៀន។ ដូច្នេះ គ្រូបង្រៀនត្រូវដឹកនាំការរៀន ដោយប្រើបទពិសោធរបស់សិស្សជាចាំបាច់ ទោះកម្រិតឬទំហំណាក៏ដោយ។

ជវភាពសំដៅដល់ការប្រែប្រួលលឿនដែលមិនអាចឃាត់ជាប់។

ការដឹកនាំការរៀន ឱ្យឆ្លើយតបនឹងជវភាពសង្គម សេដ្ឋកិច្ច ប្រជាសាស្ត្រ វិទ្យាសាស្ត្រ បច្ចេកវិទ្យា សុខាភិបាល រដ្ឋបាល និងឧស្សាហកម្ម គ្រូបង្រៀនត្រូវយល់បរិបទសិស្ស។ សិស្សមានការគិត តម្រូវការ ចំណូលចិត្ត និងព័ត៌មានច្រើនជាងមនុស្សជំនាន់មុន ឬជំនាន់ឪពុកម្តាយ។ ក្នុងយុគឧស្សាហកម្ម៤.0 សិស្សសម្បូរព័ត៌មានក្នុងបាតដៃតាំងពីវ័យក្មេង ទាំងពិត និងមិនពិត។ សិស្សមានឧបករណ៍ឌីជីថលជាជំនួយក្នុងការរៀន និងប្រើប្រព័ន្ធអ៊ិនធឺណេត។ សិស្សអាចរកឯកសារ ឬសៀវភៅពីប្រព័ន្ធអ៊ិនធឺណេត យ៉ាងលឿន។

សិស្សអង្គុយក្នុងថ្នាក់រៀន និងចូលសាលារៀន ក្នុងយុគឧស្សាហកម្ម៤.0 ត្រូវទទួលបាននូវគុណសម្បទាសម្រាប់ការងារ ជីវភាពប្រចាំថ្ងៃ និងរៀនបន្ត ពីដំណើរការរៀនប្រកបដោយគុណភាព។ គុណសម្បទា រួមមាន វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា (ក្របខ័ណ្ឌកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៦)។ បន្ថែមពីលើនេះទៀត សិស្សក្នុងយុគឧស្សាហកម្ម៤.0 ត្រូវការបណ្តុះគុណសម្បទាពលរដ្ឋសកល គុណសម្បទាសតវត្សរ៍ទី២១ គុណតម្លៃ និងចរណៃមនុស្ស ដើម្បីសម្របខ្លួនក្នុងការងារ រស់នៅ និងរៀនបន្ត ក្នុងប្រទេស និងក្រៅប្រទេស ក្នុងបច្ចុប្បន្ន និងអនាគត។

ការរស់នៅ ការងារ និងការរៀនបន្ត ក្នុងយុគឧស្សាហកម្ម៤.0 មនុស្សត្រូវអាស្រ័យជាមួយបច្ចេកវិទ្យាព័ត៌មាន ឧបករណ៍អ៊ិនធឺណេត វិទ្យាសាស្ត្រ បំណិនប្រាស្រ័យមនុស្ស បំណិនគិតកម្រិតខ្ពស់ និងវិជ្ជាស្រាយបញ្ហា។ ចេតនានៃកម្មវិធីសិក្សាលម្អិត មុខវិជ្ជាប្រវត្តិវិទ្យាគ្រប់កម្រិត ដែលរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អនុម័តក្នុងឆ្នាំ២០១៨ សំដៅរួមចំណែកបណ្តុះគុណសម្បទាពលរដ្ឋពូកែ ឬពលរដ្ឋពេញលេញ។ គោលការណ៍ គុណសម្បទា និងបំណិនរបស់ពលរដ្ឋពូកែ ឬពលរដ្ឋពេញលេញ ដូចជា ៖

- **ទទួលខុសត្រូវខ្ពស់**ចំពោះការគិត សម្រេចចិត្ត និងការប្រព្រឹត្តិ

- **ហេតុផល ដឹងខុសដឹងត្រូវ ពិចារណា និងប៉ាន់ប្រមាណ**អំពីឧបសគ្គ
- **គំនិតផ្តួចផ្តើម និងការច្នៃប្រឌិត** ក្នុងការរកដំណោះស្រាយបញ្ហា
- **សុទិដ្ឋិនិយម អត់ធ្មត់ និងមិនទន់ជ្រាយ**ចំពោះឧបសគ្គ ឬការលំបាក
- **ភាពជឿជាក់ និងឧត្តមភាព** សហការក្រុមជាប្រយោជន៍មនុស្សជាតិ
- **មានសុជីវធម៌ សីលធម៌ និងគុណធម៌** ព្រមទាំង
- **គិតអំពីប្រយោជន៍មនុស្សជាតិជាចម្បង**។
- ស្វែងវិជ្ជាជាប្រចាំ ឬរៀនពេញមួយជីវិត
- គិត វិភាគ វាយតម្លៃ និងប្រើទិន្នន័យគ្រប់ជ្រុងជ្រោយ
- ឆ្ងល់ និងសង្កេតអំពីជីវិតដែលប្រពៃសម្រាប់សុខុមាលភាពសាធារណៈ
- ប្រាស្រ័យមនុស្ស ទាំងស្តាប់ ទទួលគំនិត និងផ្តល់គំនិត
- ស្រាយបញ្ហា ប្រកបដោយនវកម្មគំនិត
- សម្រេចចិត្ត ដោយប្រើទិន្នន័យគ្រប់ជ្រុងជ្រោយ
- បំពេញកិច្ចការអស់ពីចិត្ត និងប្រកបដោយគណនេយ្យភាព
- ប្រតិបត្តិចិត្តមេត្តា មេត្រីភាព ស្រឡាញ់ និងសង្គ្រោះ
- មានទំនុកចិត្តចំពោះសម្តី និងការប្រព្រឹត្តិរបស់ខ្លួន

អ្នកគ្រូ លោកគ្រូពិតជាឯកភាព ចង់បង្រៀនកូនឱ្យក្លាយជាពលរដ្ឋពូកែឬពលរដ្ឋពេញលេញ យ៉ាងដូច្នេះមែន។ តើលោកគ្រូ អ្នកគ្រូត្រូវធ្វើយ៉ាងដូចម្តេចខ្លះ និងធ្វើអ្វីខ្លះដើម្បីបណ្តុះកូនៗ និងសិស្សឱ្យពូកែយ៉ាងដូច្នេះ? មុននឹងឆ្លើយសំណួរនេះ សូមអ្នកគ្រូ លោកគ្រូសួរខ្លួនឯងពីរសំណួរជាមុនសិន។

- តើខ្ញុំមានគោលការណ៍ គុណសម្បទា និងបំណិនអ្វីខ្លះ?
- តើខ្ញុំបានគោលការណ៍ គុណសម្បទា និងបំណិនខាងលើ ដើម្បីប្រែក្លាយខ្លួនជាពលរដ្ឋពូកែ ឬពលរដ្ឋពេញលេញ?

គ្រូបង្រៀនអាចពុំមែនជាពលរដ្ឋពូកែ ឬពលរដ្ឋពេញលេញ ពេលនេះ។ អ្នកគ្រូ លោកគ្រូអាចដឹកនាំសិស្សឱ្យក្លាយជាពលរដ្ឋពូកែ ឬពលរដ្ឋពេញលេញ។ គ្រូបង្រៀនដែលដឹកនាំសិស្សឱ្យក្លាយជាពលរដ្ឋពូកែ ឬពលរដ្ឋពេញលេញជាម្ចាស់ទាននៃពុទ្ធិសម្រាប់មនុស្សគ្រប់ជំនាន់។

## ៧. គុណសម្បទាប្រវត្តិវិទ្យា

កម្មវិធីសិក្សាលម្អិត នៃមុខវិជ្ជាប្រវត្តិវិទ្យាចាប់ពីបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ អនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ ២០១៨ មានចេតនាបណ្ដុះពលរដ្ឋពេញលេញ។ គុណសម្បទាជាពលរដ្ឋពេញលេញ សំដៅអភិវឌ្ឍវុឌ្ឍិវិជ្ជា វុឌ្ឍិបំណិន និងវុឌ្ឍិចរិយាដែលជាយាន សម្រាប់ដឹកនាំបុគ្គលម្នាក់ៗឱ្យឈានទៅជោគជ័យ។ ជោគជ័យក្នុងបរិបទនេះ សំដៅដល់ការបង្រៀនបុគ្គលគ្រប់រូបឱ្យមានចិត្តមេត្តា មេត្រីភាព ស្រឡាញ់ សង្គ្រោះ និងប្រតិបត្តិសេចក្ដីពិត ដើម្បីធានាសុខុមាលភាពរបស់មនុស្ស ធម្មជាតិ និងមរតករបស់ប្រវត្តិសាស្ត្រ។

កាលបើសិស្សបានសិក្សាមេរៀន តាមកម្មវិធីសិក្សាលម្អិត នៃមុខវិជ្ជាប្រវត្តិវិទ្យា នៅសាលារៀនចំណេះទូទៅ និងបច្ចេកទេស ចាប់ពីបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ សិស្សមានឱកាសអភិវឌ្ឍគុណសម្បទាពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ។ សិស្សរៀនប្រវត្តិវិទ្យា គឺសិស្សចេះប្រើភស្តុតាងប្រវត្តិសាស្ត្រ និងវិទ្យាសាស្ត្រ ដោយសេចក្ដីពិតដើម្បីបម្រើប្រយោជន៍មនុស្សជាតិ។ គុណសម្បទាក្នុងកម្មវិធីសិក្សាលម្អិត នៃមុខវិជ្ជាប្រវត្តិវិទ្យា ក្នុងកម្រិតមធ្យមសិក្សាបឋមភូមិ បែងចែកជាបីកម្រិត ១. វិជ្ជាសម្បទា ២. បំណិនសម្បទា ៣. ចរិយាសម្បទា ៖

### ៧.១ វិជ្ជាសម្បទា

- សន្និដ្ឋានរួមអំពីគោលបំណង និងចំណងពាក់ព័ន្ធនៃប្រវត្តិសាស្ត្រ (អតីតកាល) ភ្ជាប់ទៅនឹងជីវភាពប្រចាំថ្ងៃរបស់មនុស្ស និងធម្មជាតិក្នុងបច្ចុប្បន្ន និងអនាគត
- ពន្យល់ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ទាំងមើលឃើញ និងបាត់បង់ ដូចជា មនុស្ស កន្លែង និងព្រឹត្តិការណ៍ ដោយប្រើភស្តុតាងបុរាណវិទ្យា ប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រ
- ចងក្រងប្រវត្តិសាស្ត្រនៃបម្រែបម្រួលសង្គម ព្រឹត្តិការណ៍ មនុស្ស មរតកវប្បធម៌ ទីកន្លែង និងធម្មជាតិក្នុងអតីតកាល ដែលបាត់បង់ និងបន្តនិរន្តរភាពមកដល់បច្ចុប្បន្ន និងទៅអនាគត។

៧.២ បំណិនសម្បទា

- បង្កើតទម្រង់ និងមធ្យោបាយនៃការប្រាស្រ័យល្អ និងវិជ្ជមានជាមួយមនុស្ស ធម្មជាតិ និងមរតកប្រវត្តិសាស្ត្រ
- វិភាគចលករនៃបម្រែបម្រួលប្រជាសាស្ត្រ នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលបានបង្កើតប្រវត្តិសាស្ត្រក្នុងប្រទេស តំបន់ ពិភពលោក
- បង្កើតជម្រើស និងមធ្យោបាយនៃការស្រាយបញ្ហា ពាក់ព័ន្ធវប្បធម៌ សង្គម សេដ្ឋកិច្ច នយោបាយ និងប្រជាសាស្ត្រ ដោយការទទួលខុសត្រូវ តាមក្រមសីលធម៌វិជ្ជាជីវៈ សហការ និងច្នៃប្រឌិត។

៧.៣ ចរិយាសម្បទា

- ឱ្យតម្លៃចំពោះភាពរួម ភាពដោយឡែក នានាភាព និងពហុភាព នៃវប្បធម៌ សាសនា ទំនៀមទម្លាប់ ជំនឿ នយោបាយ និងប្រពៃណី ក្នុងប្រវត្តិសាស្ត្រ ក្នុងប្រទេស តំបន់ និងពិភពលោក
- ភ្ជាប់គុណតម្លៃមរតកប្រវត្តិសាស្ត្រនឹងជីវភាពបច្ចុប្បន្ន និងអនាគត
- ដាំបណ្ដុះសុជីវធម៌ សីលធម៌ គុណធម៌ សម្មាទិដ្ឋិ និងនវកម្មគំនិតដោយរៀនសូត្រពីមរតកប្រវត្តិសាស្ត្រ។

## ៨. គុណសម្បទានៃការអប់រំពលរដ្ឋសកល

គុណសម្បទាពរដ្ឋសកល ជាមូលធន និងជាដើមទុនសម្រាប់ការរីកចម្រើនសកល។ របកគំហើញនៃការស្រាវជ្រាវជាច្រើនពន្យល់ថា មនុស្សពោរពេញដោយ គុណសម្បទាពលរដ្ឋសកល អាចរស់និងធ្វើការ ដោយក្ដីពេញចិត្ត មេត្តា មេត្រីភាព សង្គ្រោះ ស្រឡាញ់ និងសេចក្ដីពិតចំពោះអ្វីដែលមាន។ មនុស្សពោរពេញដោយគុណសម្បទាពលរដ្ឋសកល អាចរស់និងធ្វើការ ក្នុងគ្រប់បរិបទសង្គម ប្រពៃណី ទំនៀមទម្លាប់ នយោបាយ សាសនា សេដ្ឋកិច្ច វប្បធម៌ ជាតិសាសន៍ និងជំនឿ។ មនុស្សពោរពេញដោយគុណសម្បទាពលរដ្ឋសកល មាន

សមត្ថភាពបរិបូរ រួមចំណែកដល់ចីរភាពអភិវឌ្ឍន៍ និងសន្តិភាពពិភពលោក (United Nations Educational, Scientific and Cultural Organization , 2015) ។

មនុស្សជំនាន់ក្រោយ នឹងរស់ក្នុងសុខ វឌ្ឍនភាព និងសន្តិភាព ជាមួយពិភពលោក នៅពេលប្រព័ន្ធអប់រំកម្ពុជា ចាប់ពីបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ អភិវឌ្ឍគុណសម្បទាពលរដ្ឋសកល ដល់សិស្សទូទៅ។ គុណសម្បទាពលរដ្ឋសកលមានសរសេរ ក្នុងកម្មវិធីសិក្សាលម្អិត នៃមុខវិជ្ជាប្រវត្តិវិទ្យា អនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៨។ កម្មវិធីសិក្សាលម្អិតប្រវត្តិវិទ្យា ក៏អនុវត្តតាមគោលការណ៍អប់រំពលរដ្ឋសកល របស់អង្គការយូណេស្កូ បោះពុម្ពក្នុង ឆ្នាំ២០១៥ដែរ (United Nations Educational, Scientific and Cultural Organization , 2015) ។

៨.១ វិជ្ជាសម្បទា

- បកស្រាយពីផលនៃអតីតកាលបន្សល់ទុកឱ្យបច្ចុប្បន្ន និងរក្សាឱ្យអនាគត នូវទំនាក់ទំនង រវាងមនុស្ស និងធម្មជាតិ ក្នុងសហគមន៍ ថ្នាក់ប្រទេស តំបន់ និងពិភពលោក
- ពន្យល់អំពីបញ្ហាកើតឡើងក្នុងសហគមន៍ ថ្នាក់ប្រទេស តំបន់ និងពិភពលោក
- ពន្យល់អំពីអន្តរទំនាក់ទំនងនៃផលប៉ះពាល់នៃបញ្ហាលើពលរដ្ឋគ្រប់រូប ទាំងក្នុងសហគមន៍ ថ្នាក់ប្រទេស តំបន់ និងពិភពលោក
- វាយលម្អិតនូវទម្លាប់ និងទង្វើដែលលើកកម្ពស់មេត្រីភាព សាមគ្គីភាព ក្ដីស្រឡាញ់ គោរព និងឱ្យតម្លៃចំពោះភាពរួម ភាពដោយឡែក នានាភាព ពហុភាព និងភាពចម្រុះនៃវប្បធម៌ នយោបាយ សាសនា ទំនៀមទម្លាប់ ប្រពៃណី និងជំនឿក្នុងសហគមន៍ ប្រទេស តំបន់ និងពិភពលោក។

៨.២ បំណិនសម្បទា

- វិភាគបាតុភូត ចលករ និងព្រឹត្តិការណ៍ប្រជាសាស្ត្រ សង្គម វប្បធម៌ សេដ្ឋកិច្ច និងនយោបាយ ដោយប្រើភស្តុតាងបុរាណវិទ្យា វិទ្យា

សាស្ត្រ និងវិធីសាស្ត្រប្រវត្តិសាស្ត្រ នៅកម្រិតសហគមន៍ ថ្នាក់ប្រទេស តំបន់ និងពិភពលោក។

៨.៣ ចរិយាសម្បទា

- ចាត់របៀបនៃការប្រតិបត្តិនូវទម្លាប់ និងទង្វើនៃសេចក្ដីពិត ដើម្បីលើកកម្ពស់មេត្រីភាព សាមគ្គីភាព ក្ដីស្រឡាញ់ គោរព និងឱ្យតម្លៃចំពោះភាពរួមគ្នា ភាពដោយឡែក នានាភាព ពហុភាព និងភាពចម្រុះនៃវប្បធម៌ នយោបាយ សាសនា ទំនៀមទម្លាប់ ប្រពៃណី និងជំនឿ ក្នុងសហគមន៍ ថ្នាក់ប្រទេស តំបន់ និងពិភពលោក។
- បង្កើតទម្រង់ និងជម្រើសនៃដំណោះស្រាយបញ្ហាប្រជាសាស្ត្រ សង្គម វប្បធម៌ នយោបាយ និងសេដ្ឋកិច្ច ប្រកបដោយការទទួលខុសត្រូវ សហការ ច្នៃប្រឌិត ដោយប្រើវិធីប្រវត្តិសាស្ត្រ និងប្រកាន់ខ្ជាប់គោលការណ៍សន្តិភាពសម្រាប់ជាប្រយោជន៍ដល់មនុស្សជាតិ។

៨.៤ គុណតម្លៃពលរដ្ឋសកល

- ដាំបណ្ដុះទម្លាប់គិតគ្រប់ជ្រុងជ្រោយ ប្រមាណអនាគត ប្រាស្រ័យមនុស្ស និងឱ្យតម្លៃចំពោះនានាភាព ពហុភាព ភាពរួម និងភាពដោយឡែកនៃគំនិត។
- ទទួលខុសត្រូវ និងចូលរួមក្នុងសកម្មភាពលើកតម្កើងតម្លៃសង្គមទាំងកម្រិតសហគមន៍ ថ្នាក់ប្រទេស តំបន់ និងពិភពលោក។

## ៩. យុគនៃបដិវត្តន៍ឧស្សាហកម្ម៤.០

ក្នុងប្រវត្តិសាស្ត្រមនុស្ស ភាពចម្រុងចម្រើនខាងឧស្សាហកម្ម វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបានកើតឡើងជាច្រើនលើក និងបន្តនិរន្តរភាពមកដល់បច្ចុប្បន្ន និងទៅអនាគត។ វឌ្ឍនភាពធំៗ និងចុងក្រោយបំផុតដែលមនុស្សភាគច្រើនបាន និងកំពុងប្រតិបត្តិ គឺឧស្សាហកម្មប្រើម្រាមដៃ។ មនុស្សក្នុងយុគនេះពេញនិយមប្រើម្រាមដៃដើម្បីទូទាត់ការចំណាយ រកចំណូល រកព័ត៌មាន និងផ្សព្វផ្សាយព័ត៌មាន និងផលិតផល ទិញនិងលក់ ដំណើរការថ្នាក់រៀន ប្រាស្រ័យមនុស្ស

ទំនាក់ទំនងពាណិជ្ជកម្ម។ ភាពអស្ចារ្យនៃមនុស្ស គឺអភិវឌ្ឍបញ្ញាសម្រាប់បម្រើប្រយោជន៍មនុស្សជំនាន់ក្រោយ។ REESE (2018) បានសរសេរសៀវភៅមួយអំពីមនុស្សយន្ត និងកុំព្យូទ័រមានវិញ្ញាណបានពន្យល់ថា បដិវត្តន៍ឧស្សាហកម្មរបស់មនុស្សមានបួនលើក ៖

- **យុគនៃបដិវត្តន៍ឧស្សាហកម្ម១.០ ១០០០០០ឆ្នាំមុន** ៖ ភាសា និងភ្លើង
- **យុគនៃបដិវត្តន៍ឧស្សាហកម្ម២.០ ១០០០០ឆ្នាំមុន** ៖ កសិកម្ម និងទីក្រុង
- **យុគនៃបដិវត្តន៍ឧស្សាហកម្ម៣.០ ៥០០០ឆ្នាំមុន** ៖ សំណេរ និងលុយ
- **យុគនៃបដិវត្តន៍ឧស្សាហកម្ម៤.០** បច្ចុប្បន្ន៖ មនុស្សយន្ត បញ្ញាសិប្បនិម្មិត

រូបភាព០២. អាជីពការងារ ក្នុងយុគឧស្សាហកម្ម៤.០




ការរស់នៅ ការងារ និងរៀនបន្តក្នុងយុគនៃបដិវត្តន៍ឧស្សាកម្ម៤.០ ត្រូវការមនុស្សមានគុណសម្បទាច្រើនប្រភេទ។ ការងារក្នុងទសវត្សរ៍នេះអាចបាត់

បង់ ឬហួសសម័យក្នុងទសវត្សរ៍ក្រោយ។ បដិវត្តន៍នៃឧស្សាហកម្ម៤.0 សម្រាប់សិស្សរៀនតាមសាលារៀនមានច្រើន ប៉ុន្តែសៀវភៅនេះ ចែកជាក្របខ័ណ្ឌ៤៖

- នវកម្មគំនិត
- នវកម្មនៃការរៀននិងបង្រៀន
- ដៃគូអប់រំ-ឧស្សាហកម្ម
- អភិវឌ្ឍន៍អាជីពសកល

៩.១ នវកម្មគំនិត

> ដើម្បីយល់បន្ថែម អំពីបញ្ញត្តិនៃពាក្យ **នវៈ** គ្រូបង្រៀនអាចរកន័យ និងបញ្ញត្តិ **នវៈ** តាមទូរនិម្មិតបណ្ណាល័យ ដូចជា GOOGLE សរសេរជាឡាតាំង nava។

នវៈ (nava) ភាសាសំស្ក្រឹត សម្បូរន័យណាស់។ សៀវភៅនេះយកន័យបីមកពិចារណា ១. បង្កើតថ្មី ២. ប្តូរពីចាស់មកថ្មី ៣. មកដល់ថ្មី ឬបញ្ចេញថ្មី (wisdom library, 2008)។ ដូច្នេះ នវកម្មគំនិតមានន័យថា ការបង្កើតគំនិតថ្មី បញ្ចេញគំនិតថ្មី ឬប្តូរគំនិតចាស់ទៅរកគំនិតថ្មី។

ភាពអស្ចារ្យ នៃបញ្ញារបស់មនុស្ស ក្នុងគ្រប់យុគនៃបដិវត្តន៍ឧស្សាហកម្ម គឺកើតចេញពីបំណិនគិតកម្រិតខ្ពស់ គឺនវកម្មគំនិត។ នវកម្មគំនិតត្រូវកើតចេញពីការសង្កេត គិត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ ស្វែងការពន្យល់ និងបង្កើតថ្មី។ អ្នកគ្រូ លោកគ្រូ ធ្លាប់មានបទពិសោធទាក់ទងនឹងការប្រើឧបករណ៍អ៊ិនធឺណេត បច្ចេកវិទ្យា និងឌីជីថល ដូចជា កុំព្យូទ័រ ទូរសព្ទ សុទ្ធតែកើតចេញពីបញ្ញាមនុស្ស។

REESE (2018)សរសេរសៀវភៅមួយអំពីមនុស្សយន្ត កុំព្យូទ័រមានវិញ្ញាណ និងអនាគតមនុស្សដែលត្រូវរស់ជាមួយបញ្ញាសិប្បនិម្មិត និងមនុស្សយន្ត និងបានចែកបដិវត្តន៍ឧស្សាហកម្ម ជាបួនយុគ ៖

- ក្នុង**យុគនៃបដិវត្តន៍ឧស្សាហកម្ម១.0** មនុស្សបង្កើតភាសាប្រើ**ទំនាក់**ទំនង ដើម្បីបំពេញតម្រូវការសង្គម ឧស្សាហកម្ម និងប្រជាសាស្ត្រ។ លើសពីនេះទៀត មនុស្សបង្កើតអរិយធម៌ថ្មីៗជាបន្តបន្ទាប់។ ក្នុងយុគនៃបដិវត្តន៍ឧស្សាហកម្ម១.0 មនុស្សបានរកឃើញភ្លើងបន្ថែមទៀត។ ភ្លើងបាន និងកំពុងបម្រើប្រយោជន៍មនុស្សច្រើនយ៉ាង៖ ចម្អិនអាហារ ជម្នះធម្មជាតិ។

- ក្នុង**យុគនៃបដិវត្តន៍ឧស្សាហកម្ម២.០** មនុស្សបង្កើត**បាន**កសិកម្មដើម្បីជីវភាព និងបន្តនិរន្តរភាពរបស់មនុស្ស។ យុគនៃបដិវត្តន៍ឧស្សាហកម្ម ២.០ មនុស្សបានបង្កើតទីក្រុង និងរស់នៅប្រមូលផ្តុំគ្នាជាសហគមន៍។ ការរស់នៅប្រមូលផ្តុំគ្នាជាសហគមន៍ មនុស្សបានបង្កើត និងពង្រីកសកម្មភាពសេដ្ឋកិច្ចសម្បូរបែប ឬហៅថាពិពិធកម្មសេដ្ឋកិច្ច។
- ក្នុង**យុគនៃបដិវត្តន៍ឧស្សាហកម្ម៣.០** មនុស្សបង្កើតសំណៅនៃសំណេរ។ ពុទ្ធិរបស់មនុស្សអំពីប្រវត្តិសាស្ត្រ ងាយភ្លេច ឬបាត់បង់ ប្រសិនបើពុំមានសំណៅនៃសំណេរ ឬគំនូររក្សាទុកទេ។ ភស្តុតាងប្រវត្តិសាស្ត្រជាច្រើនបន្សល់ទុកឱ្យយើងរៀន ក្នុងបច្ចុប្បន្ន គឺសំណៅនៃសំណេរ និងគំនូរ។ ក្នុងយុគនៃបដិវត្តន៍ឧស្សាហកម្ម៣.០ មនុស្សបង្កើតលុយសម្រាប់ផ្លាស់ប្តូរទំនិញ ឬផលិតផលកសិកម្ម និងពិពិធកម្មសេដ្ឋកិច្ច។ ក្រោយពីមនុស្សបង្កើតភ្លើង ភាសា ទីក្រុង សំណេរ លុយ និងកសិកម្ម មនុស្សបង្កើតព្រឹត្តិការណ៍ និងផលិតផលបន្សល់ទុកឱ្យមនុស្សជំនាន់ក្រោយៗ ជាច្រើនទៀត (REESE , 2018)។
- ក្នុង**យុគនៃបដិវត្តន៍ឧស្សាហកម្ម៤.០** មនុស្សបង្កើតវិទ្យាសាស្ត្រ សិល្បៈ និងបច្ចេកវិទ្យាជាច្រើន គិតទាំងបញ្ញាសិប្បនិម្មិត មនុស្សយន្ត និងកុំព្យូទ័រមានវិញ្ញាណ។ល។ បញ្ញាសិប្បនិម្មិតអាចជំនួសការងាររបស់មនុស្សបានច្រើនយ៉ាង និងច្រើនទម្រង់។ បច្ចេកវិទ្យា វិទ្យាសាស្ត្រ ឧបករណ៍អ៊ិនធឺណេត និងឌីជីថល ជួយគ្រូបង្រៀនបានច្រើនយ៉ាង និងច្រើនទម្រង់។ ឧទាហរណ៍ គ្រូបង្រៀនពុំសូវភ័យអំពីភាពស្ទាត់ជំនាញនៃភាសាពេកទេ។ Google Translate ជួយអ្នកគ្រូ លោកគ្រូបានច្រើនក្នុងការបកប្រែ។ អ្នកគ្រូ លោកគ្រូ គ្រាន់តែនិយាយ ឬអានបញ្ចេញសំឡេង ឬវាយអត្ថបទជាភាសាដើម Google Translate បកប្រែឱ្យអ្នកគ្រូ លោកគ្រូទាំងស្រុង។ បញ្ញាសិប្បនិម្មិតជួយគ្រូបង្រៀនឱ្យបង្កើតមេរៀន និងដឹកនាំសិស្សរៀនប្រកបដោយការពេញចិត្តផងដែរ។ លើសពីនេះទៀត បច្ចេកវិទ្យា វិទ្យាសាស្ត្រ ឧបករណ៍អ៊ិនធឺណេត និងឌីជីថលជួយគ្រូបង្រៀន ឱ្យវាយតម្លៃ

លទ្ធផលសិក្សារបស់សិស្ស និងប្រើលទ្ធផលវាយតម្លៃសម្រាប់កែលម្អដំណើរការរៀន និងបង្រៀន។ បញ្ញាសិប្បនិម្មិតអាចបកស្រាយទិន្នន័យស្មុគស្មាញឱ្យទៅជាលទ្ធផលសាមញ្ញ ងាយយល់ និងងាយប្រតិបត្តិ។

- ក្នុង**យុគនៃបដិវត្តន៍ឧស្សាហកម្ម៤.0** វិទ្យាសាស្ត្រ បច្ចេកវិទ្យា ឧបករណ៍អ៊ិនធឺណេត និងឌីជីថលបានរីកចម្រើនយ៉ាងខ្លាំង។ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ឧបករណ៍អ៊ិនធឺណេត និងឌីជីថល ជួយបំពេញតម្រូវការ និងចំណូលចិត្តរបស់សិស្ស និងគ្រូបង្រៀនក្នុងយុគឧស្សាហកម្ម៤.0។ គ្រូបង្រៀនដែលស្ទាត់ជំនាញកុំព្យូទ័រ និងឧបករណ៍អ៊ិនធឺណេត អាចសរសេរមេរៀនឱ្យសិស្សចាប់អារម្មណ៍ និងចង់រៀនបានច្រើនបែបច្រើនយ៉ាង។ គ្រូបង្រៀនអាចបង្កើតមេរៀនជាទម្រង់ជីវចល ឬគំនូរដោយមានសំឡេង និងអក្សរឱ្យសិស្សរៀន។ វិបត្តិនៃជំងឺកូវីដ១៩ បានផ្តល់ហេតុផលឱ្យមនុស្សប្រឹងប្រែងបន្តទៀត ដើម្បីឱ្យការរៀនមានភាពងាយស្រួល ដោយប្រើបច្ចេកវិទ្យា ឧបករណ៍អ៊ិនធឺណេត និង ឌីជីថលយ៉ាងសម្បូរបែប។

ឌីជីថល (Digital) សំដៅដល់ប្រព័ន្ធគ្រប់គ្រង និងប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន។

## ៩.២ បច្ចេកវិទ្យានៃការរៀន និងបង្រៀន

បច្ចេកវិទ្យា ឧបករណ៍អ៊ិនធឺណេត និងឌីជីថលសម្រួលការលំបាកដល់ការអប់រំ ការបង្រៀន និងការរៀន។ ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និង២000 មនុស្សជួបការលំបាក ក្នុងការបញ្ជូនឯកសារ សៀវភៅ វីដេអូ សំឡេង និងរូបថត តាមអន្តរបណ្តាញអ៊ិនធឺណេត ក្នុងទម្រង់ធំច្រើនមេហ្គាបៃ (Megabytes)។

មេហ្គាបៃ (Megabytes) សំដៅដល់ទំហំឯកសារ រូបភាព សំឡេង វីដេអូ រក្សាទុកក្នុងប្រព័ន្ធឌីជីថល។ សរសេរកាត់
1MB = 1024000 bytes

ក្នុងយុគឧស្សាហកម្ម៤.0 គ្រូបង្រៀន សិស្ស និងមនុស្សទូទៅ ឈប់ពិបាកបញ្ជូនឯកសារច្រើនទម្រង់ ដូចជា រូបភាព វីដេអូ អក្សរ សៀវភៅ និងសំឡេងទៀតហើយ។ ដូច្នេះ គ្រូបង្រៀនត្រូវផ្តើមពីនវកម្ម

គំនិតនៃការរៀន ចេះប្រើបច្ចេកវិទ្យា ឧបករណ៍អ៊ិនធឺណេត និងឌីជីថល កុំព្យូទ័រ កម្មវិធីកុំព្យូទ័រ និងអន្តរបណ្តាញអ៊ិនធឺណេត សម្រាប់ការរៀន និងបង្រៀន។

គ្រូបង្រៀនត្រូវប្រើវិជ្ជាឌីជីថល សម្រាប់ដំណើរការថ្នាក់រៀន ឱ្យកាន់តែទាក់ទាញអារម្មណ៍សិស្ស ឱ្យចង់រៀន ចង់អាន ចង់ចែករំលែក និងចង់ចូលរួមក្នុងសកម្មភាពថ្នាក់រៀន។ គ្រូបង្រៀនអាចប្រើវិជ្ជាឌីជីថល (លម្អិតក្នុងផ្នែក១០.២) ដើម្បីបង្រៀនសិស្សពីចម្ងាយ ឬហៅថា ថ្នាក់រៀនទូរនិម្មិត។

ក្នុងយុគឧស្សាហកម្ម៤.0 យុវជនមានតម្រូវការ ព័ត៌មាន ទិន្នន័យ និងការគិតខុសពីមនុស្សជំនាន់ម្តាយឪពុកក្នុងទសវត្សរ៍មុន និងទសវត្សរ៍នេះ។ សិស្សអាចរកខ្លឹមសារមេរៀនជាច្រើនទម្រង់ ដូចជាអត្ថបទ វីដេអូ ជីវចល និងរូបភាពពីអន្តរបណ្តាញអ៊ិនធឺណេត។ សិស្សគ្រាន់តែបើក Google, YouTube ឬទម្រង់ផ្សេងទៀត និងរកពាក្យគន្លឹះជាភាសាអង់គ្លេស ឬខ្មែរ សិស្សអាចរកខ្លឹមសារ និងបញ្ញត្តិនៃមេរៀនបានយ៉ាងច្រើនសម្បូរបែប។ ដូច្នេះ ប្រព័ន្ធសាលារៀន ថ្នាក់រៀន និងគ្រូបង្រៀន ត្រូវស្ទាត់ជំនាញ និងបង្កបរិយាកាសរៀន ដោយប្រើបច្ចេកវិទ្យា ឧបករណ៍អ៊ិនធឺណេត និងឌីជីថល។ គ្រូបង្រៀនត្រូវប្រើបច្ចេកវិទ្យា ឧបករណ៍អ៊ិនធឺណេត និងឌីជីថល ដូចជា ទូរស័ព្ទ និងកុំព្យូទ័រ ដើម្បីបង្កបរិយាកាសឱ្យសិស្សពេញចិត្ត និងចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀន។

៩.៣ ដៃគូអប់រំ-ឧស្សាហកម្ម

គុណសម្បទារួមមាន វិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា គុណតម្លៃ និងចរណមនុស្ស គុណសម្បទាពលរដ្ឋសកល រៀនចេះ និងចេញពីសាលារៀនជាដើមទុន និងមូលធនសម្រាប់បម្រើការងារ ក្នុងគ្រប់ប្រភេទឧស្សាហកម្ម គ្រប់ផ្នែក និងគ្រប់វិស័យ។ ដូច្នេះ គុណសម្បទាទទួលបានពីដំណើរការរៀនក្នុងថ្នាក់រៀន និងសាលារៀន ត្រូវភ្ជាប់ជាមួយនឹងតម្រូវការរបស់ឧស្សាហកម្ម។ ដំណើរការរៀនពុំអាចភ្ជាប់គុណសម្បទា ទៅនឹងតម្រូវការរបស់ឧស្សាហកម្ម គឺពុំមែនជាដំណើរការរៀនពិតប្រាកដ និងប្រកបដោយគុណភាពទេ។

ឧទាហរណ៍ ទេសចរណ៍ជាប្រភពចំណូលថវិកាជាតិយ៉ាងធំរបស់កម្ពុជាក្នុងបច្ចុប្បន្ន និងអនាគត។ លោកគ្រូ អ្នកគ្រូអាចគិត៥៩វិនាទីលើសំណួរ៖

- តើតំណែង និងតួនាទីការងារក្នុងឧស្សាហកម្មទេសចរណ៍នេះមានអ្វីខ្លះ?
- តើវិស័យទេសចរណ៍នេះត្រូវការមនុស្សដែលមានគុណសម្បទាអ្វីខ្លះ?

ចូរលោកគ្រូ អ្នកគ្រូចំណាយពេល៥៩វិនាទីគិតបន្តិច! តើមានតួនាទី និងតំណែងអ្វីខ្លះក្នុងអនុវិស័យសណ្ឋាគារ? ក្នុងតំណែងនីមួយៗ តើនិយោជកត្រូវការមនុស្សដែលមានវិជ្ជានិងបំណិនអ្វីខ្លះ? ចរិយាប្រភេទណា? គុណតម្លៃ និងចរណមនុស្សបែបណាខ្លះ? ដូច្នេះ វិជ្ជា បំណិន ចរិយា គុណតម្លៃ និងចរណមនុស្សរៀនចេញពីសាលារៀន សុទ្ធតែត្រូវការក្នុងគ្រប់វិស័យឧស្សាហកម្មទាំងអស់។

៩.៤ អាជីពសកល

មុន និងក្នុងឆ្នាំនៃវិបត្តិកូវីដ១៩ យុវជនខ្មែរច្រើនជាង១លាននាក់កំពុងបម្រើការងារនៅបរទេស ដូចជា ប្រទេសថៃ ម៉ាឡេស៊ី កូរ៉េ ជប៉ុន សិង្ហបុរី និងប្រទេសផ្សេងៗ។ តើលោកគ្រូ អ្នកគ្រូដឹងថា យុវជនខ្មែរបាននិងកំពុងប្រើគុណតម្លៃ និងចរណមនុស្សប្រភេទអ្វីខ្លះ ដើម្បីបំពេញការងារនៅបរទេស? តើគុណតម្លៃ និងចរណមនុស្សដែលត្រូវប្រើក្នុងការងារនៅបរទេស បានរៀនពីសាលារៀនដែរឬទេ? តើនិយោជកបរទេសត្រូវការនិយោជិតដែលមានគុណតម្លៃ និងចរណមនុស្សប្រភេទអ្វីខ្លះ? តើគុណតម្លៃ និងចរណមនុស្សប្រភេទណា ទើបធ្វើការបានប្រាក់ចំណូលខ្ពស់? តើគុណតម្លៃ និងចរណមនុស្សប្រភេទណា ទើបនិយោជកបរទេស ត្រូវការគ្រប់កាល បរិបទ និងលក្ខខណ្ឌ?

អាជីពសកលត្រូវការកម្លាំងពលកម្មមនុស្ស ដែលមនុស្សយន្ត ឬបញ្ញាសិប្បនិម្មិតមិនអាចជំនួសបាន។ មនុស្សយន្ត ឬបញ្ញាសិប្បនិម្មិតមិនអាចជំនួសមនុស្សបាន ត្រង់ថា មនុស្សមានគុណតម្លៃ និងចរណៈ។ គុណតម្លៃមនុស្ស មានសុជីវធម៌ សីលធម៌ គុណធម៌ និងការប្រតិបត្តិសេចក្តីពិត។ ចរណមនុស្សជាទង្វើ និងការប្រព្រឹត្តិប្រកបដោយចិត្តមេត្តា ក្តីស្រឡាញ់ សង្គ្រោះ និងភាពស្មោះត្រង់។ ដូច្នេះ ប្រព័ន្ធអប់រំត្រូវបំពាក់គុណតម្លៃ និងចរណមនុស្សដល់សិស្ស ព្រោះសិស្សជាមូលធននៃកម្លាំងពលកម្មសកល។ មូលធននៃពលកម្មសកល មិនមែនរៀនដើម្បីបំពេញការងារត្រឹមក្នុងស្រុក ឬក្នុងប្រទេសទេ។ មូលធននៃពលកម្មសកលសំដៅបំពេញតម្រូវការទីផ្សារការងារកម្រិតតំបន់ និងពិភពលោក។

### ៩.៥ វិស័យការងារ

វិស័យការងារមានអត្ថិភាពបច្ចុប្បន្ន អាចបាត់បង់ និងហួសសម័យក្នុងពេលណាមួយ។ មនុស្សសម័យនេះអាចមិនដែលស្គាល់អាជីពការងារថ្មី។ អាជីពការងារថ្មីអាចមិនទាន់កើតមានក្នុងពេលបច្ចុប្បន្ន។ សិស្សរៀនថ្នាក់ទី១ ក្នុងឆ្នាំ ២០២០ អាចរៀនចប់ពីសាលារៀនចំណេះទូទៅ ក្នុង១២ឆ្នាំក្រោយ។ ដូច្នេះ សិស្សនឹងត្រូវទៅបម្រើការងារក្នុងវិស័យឧស្សាហកម្មមួយចំនួន ដែលកំពុងកើតមាន និងពុំទាន់កើតមាន។ ការងារក្នុងយុគឧស្សាហកម្ម៤.០ អាចសម្បូរបែបដែលមនុស្សភាគច្រើនក្នុងវេលានេះមិនទាន់ស្គាល់ និងពុំធ្លាប់មានបទពិសោធ។ អាជីពការងារក្នុងអនាគតអាចមាន មេហ្កាត្រូនិច ឃ្លាំងទិន្នន័យកុំព្យូទ័រ សន្តិសុខទិន្នន័យ បញ្ញាសិប្បនិម្មិត ធុរកិច្ចទូរនិម្មិត វិទ្យាសាស្ត្រទិន្នន័យ បច្ចេកវិទ្យាទូរស័ព្ទ ផ្សាយទីផ្សារទូរនិម្មិត ហិរញ្ញវត្ថុទូរនិម្មិត និងអន្តរបណ្តាញអ៊ិនធឺណេត។ វិស័យការងារទាំងនេះ និងវិស័យការងារដែលកំពុងកើតមានក្នុងទីផ្សារបច្ចុប្បន្ន ត្រូវការមនុស្សដែលមានគុណសម្បទាសតវត្សរ៍ទី២១ គុណសម្បទាពលរដ្ឋសកល គុណតម្លៃ និងចរណមនុស្ស រៀនចេញពីសាលារៀន។

## ១០. គុណសម្បទា និងគុណតម្លៃមនុស្សសម្រាប់សតវត្សរ៍ទី២១

> ស្ថាប័នខ្លះ ហៅគុណសម្បទាសតវត្សរ៍ទី២១ និងខ្លះហៅបំណិនសតវត្សរ៍ទី២១។ ឯកសារនេះ ហៅគុណសម្បទាសតវត្សរ៍ទី២១ ព្រោះគុណសម្បទាមានវិសាលភាពលើចំណេះដឹង វិជ្ជា ឥរិយាបថ និងការប្រព្រឹត្តិ។

ក្របខ័ណ្ឌកម្មវិធីសិក្សា សម្រាប់ការអប់រំចំណេះទូទៅ និងបច្ចេកទេសពីមត្តេយ្យសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ អនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ ២០១៦ សំដៅបណ្តុះអ្នកសិក្សាឱ្យក្លាយជាពលរដ្ឋពេញលេញ។

លក្ខណៈសម្បត្តិនៃពលរដ្ឋពេញលេញ កំណត់ក្នុងក្របខ័ណ្ឌនៃកម្មវិធីសិក្សាមាន ១. វិជ្ជាសម្បទា ២. បំណិនសម្បទា ៣. ចរិយាសម្បទា សម្រាប់បំពេញតម្រូវការសង្គម ក្នុងយុគឧស្សាហកម្ម៤.០។ បន្ថែមលើគុណសម្បទា សរសេរក្នុង

ក្របខ័ណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦ កម្មវិធីសិក្សាលម្អិតមុខវិជ្ជាប្រវត្តិវិទ្យា អនុម័ត ដោយរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៨ បញ្ចូលបំណិន និង គុណសម្បទាសតវត្សរ៍ទី២១ និងអប់រំពលរដ្ឋសកល។

និយោជកច្រើនសួរអ្នកដឹកនាំគ្រឹះស្ថានអប់រំមួយសំណួរ។ តើសិស្ស និស្សិតរៀនចប់ចេញពីសាលារៀន ឬសាកលវិទ្យាល័យ បានទទួលវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា គុណតម្លៃ និងចរណៈមនុស្សអ្វីខ្លះ ត្រៀមបម្រុង សម្រាប់បំពេញតម្រូវការនៃការងារក្នុងឧស្សាហកម្ម (OECD, 2013)?

សំណួរមួយនេះបើកផ្លូវគិតច្រើនទិស និងបន្ថែមជម្រៅនៃការគិត សម្រាប់អ្នកអប់រំ និងគ្រូបង្រៀន។ និយោជកតែងចង់បាននិយោជិតដែលមាន គុណសម្បទា គុណតម្លៃ និងចរណៈមនុស្ស ឆ្លើយតបនឹងតម្រូវការ ក្នុងគ្រប់វិស័យ ឧស្សាហកម្ម។ ភ្ជាប់សំណួរមួយខាងលើជាមួយនឹងការរៀនប្រវត្តិវិទ្យាក្នុងបរិបទ អប់រំកម្ពុជាបច្ចុប្បន្ន ចម្ងល់នឹងកើតមានកាន់តែធំ។ សំណួរខាងលើនេះបើកផ្លូវ ឱ្យអ្នកអ្នកអប់រំ គ្រូបង្រៀន និងអ្នកស្រាវជ្រាវអំពីការអប់រំ គិតកាន់តែជ្រៅ និង ពង្រីកវិសាលភាពនៃគំនិតកាន់តែសម្បូរបែប។ កាន់តែគិត និងកាន់តែស្រាវជ្រាវ រកសេចក្តីពន្យល់ចំពោះសំណួរមួយខាងលើនេះ គឺកាន់តែនាំចិត្តអ្នកអប់រំ និងគ្រូ បង្រៀនឱ្យរកមធ្យោបាយ និងវិធីសាស្ត្រសម្បូរបែបដើម្បីបំពេញតម្រូវការនេះ។

ការរៀនប្រវត្តិវិទ្យា គ្រាន់តែចាំអង្គហេតុ ឈ្មោះមនុស្ស ក្សត្រប្រទេស កន្លែង កាល វត្ថុបុរាណ ឆ្នាំគ្រងរាជ្យ ប្រាសាទបុរាណ និងព្រឹត្តិការណ៍ មិនអាច ឆ្លើយតបនឹងតម្រូវការ នៃទីផ្សារការងារក្នុងយុគឧស្សាហកម្ម៤.០ទេ។ ការរៀន ការបង្រៀន និងការដឹកនាំការរៀន ត្រូវឆ្លើយតបនឹងជវភាពនៃតម្រូវការសង្គម វប្បធម៌ សុខាភិបាល រដ្ឋបាល សេដ្ឋកិច្ច ពាណិជ្ជកម្ម ឧស្សាហកម្ម នយោបាយ វិទ្យាសាស្ត្រ បច្ចេកវិទ្យា អភិបាលកិច្ច និងប្រជាសាស្ត្រ ក្នុងយុគឧស្សាហកម្ម៤.០។

អ្នកដឹកនាំពិភពលោក អ្នកនយោបាយ អ្នកអប់រំ និយោជក និងអ្នក ស្រាវជ្រាវមានគំនិតឯកភាពគ្នាលើតម្រូវការគុណសម្បទា គុណតម្លៃ និងបំណិន សម្រាប់សតវត្សរ៍ទី២១។ ប្រព័ន្ធអប់រំ សាលារៀន ថ្នាក់រៀន និងគ្រូបង្រៀនត្រូវ បង្កើតកម្មវិធីសិក្សា តាក់តែងលំនាំនៃការរៀន បង្រៀន ដឹកនាំសិស្សរៀន និង

វាយតម្លៃលទ្ធផលសិក្សា ដើម្បីបំពាក់គុណសម្បទា គុណតម្លៃ និងបំណិនសម្រាប់សតវត្សរ៍ទី២១ដល់អ្នកសិក្សា (World Economic Forum, 2016; Trilling & Fadel, 2009; Chu, Reynolds, Tavares, Notari, & Wing Yi Lee, 2017; Hughes & Acedo, 2016; Kuhlthau, Leslie, & Caspari, 2007; King, Erickson, & Sebranek, 2012; Agarwal & Bain, 2019)។

សិស្សត្រូវយកគុណសម្បទា គុណតម្លៃ និងបំណិនសម្រាប់សតវត្សរ៍ទី២១ ទៅរៀនបន្ត ធ្វើការ និងរួមចំណែកបង្កើតសង្គមមួយប្រសើរ។ សង្គមមួយប្រសើរ គឺ មានពលរដ្ឋពោរពេញដោយចិត្តមេត្តា ក្ដីស្រឡាញ់ មេត្រីភាព គុណធម៌ និងប្រតិបត្តិសេចក្ដីពិតជាប្រចាំ។

ក្នុងយុគឧស្សាហកម្ម៤.០ ពលរដ្ឋកម្ពុជាគ្រប់រូប ត្រូវការគុណសម្បទា គុណតម្លៃ និងបំណិនសម្រាប់សតវត្សរ៍ទី២១ ដោយខានពុំបាន។ ពលរដ្ឋកម្ពុជាពីជំនាន់នេះ បន្តរហូតជំនាន់ក្រោយទៀតត្រូវមាន និងប្រតិបត្តិគុណសម្បទា គុណតម្លៃ និងបំណិន សម្រាប់សតវត្សរ៍ទី២១។ សិស្សនឹងយកគុណសម្បទា គុណតម្លៃ និងបំណិន ទៅរួមចំណែកយ៉ាងសកម្ម ប្រែក្លាយកម្ពុជាពីប្រទេសចំណូលមធ្យមក្នុងឆ្នាំ២០២០ ទៅចំណូលមធ្យមកម្រិតខ្ពស់ ត្រឹមឆ្នាំ២០៣០ និងចំណូលខ្ពស់ ត្រឹមឆ្នាំ២០៥០។ សង្គមកម្ពុជានឹងប្រសើរ និងពោរពេញដោយបុគ្គលមានចិត្តមេត្តា ស្រឡាញ់ មេត្រីភាព គុណធម៌ និងប្រតិបត្តិសេចក្ដីពិតជាប្រចាំ។

ការរៀនគ្រប់មុខវិជ្ជាក្នុងក្របខ័ណ្ឌកម្មវិធីសិក្សារបស់ប្រព័ន្ធអប់រំ មិនអាចបន្តឱ្យសិស្សរៀនត្រឹមតែការដឹង ស្គាល់ ចាំ និងសូត្ររត់មាត់ លើខ្លឹមសារមេរៀន តួលេខ អង្គហេតុ ឬព្រឹត្តិការណ៍តាមសៀវភៅសិក្សាគោល ឬពីគ្រូបង្រៀនប្រាប់បន្តទៀតទេ។ ការរៀនដើម្បីសូត្ររត់មាត់ ទន្ទេញចាំអំពីព្រឹត្តិការណ៍ កាល ឈ្មោះមនុស្ស ទីកន្លែងមិនអាចគ្រប់គ្រាន់ សម្រាប់រៀន ការងារ និងជីវភាពប្រចាំថ្ងៃ ក្នុងយុគឧស្សាហកម្ម៤.០ បានតទៅទៀតឡើយ។

មុនគិតអំពីគុណសម្បទា គុណតម្លៃ និងបំណិនសម្រាប់សតវត្សរ៍ទី២១ ចូរលោកគ្រូ អ្នកគ្រូ សាកល្បងសួរខ្លួនឯង និងស្វែងការពន្យល់នូវចម្លើយចំពោះសំណួរមួយចំនួនខាងក្រោម មុនអានបន្ត ឬវិលត្រឡប់ទៅអានទំព័រដើមវិញ ៖

- ក្នុងរយៈពេលពី១៥ទៅ២០ឆ្នាំទៅមុខទៀត ដល់ពេលកូន ក្មួយ ឬចៅរបស់អ្នកគ្រូ លោកគ្រូកើតនៅថ្ងៃនេះ បានរៀនចប់ពីសាលារៀនចំណោះទូទៅ ឬសាកលវិទ្យាល័យ និងចេញបម្រើការងារតាមឧស្សាហកម្មផ្សេងៗ តើនឹងមានបច្ចេកវិទ្យាថ្មី វិទ្យាសាស្ត្រថ្មី និងពិភពលោកថ្មី កើតឡើងសម្រាប់មនុស្សជំនាន់នោះដែរឬទេ?
- គិតត្រឹមកូនៗ តើអ្នកគ្រូ លោកគញរូចង់ឱ្យកូនចំណោះដឹង បំណិន វិជ្ជាចរិយា គុណតម្លៃ និងចរណមនុស្សប្រភេទអ្វីខ្លះ?
- ពិចារណាបន្តិចអំពីបទពិសោធរៀនរបស់យើងជាគ្រូបង្រៀន កាលពី៥ឬ១០ឬ១៥ឆ្នាំមុន តើយើងបានគិតអំពីចំណោះដឹង បំណិន វិជ្ជា គុណតម្លៃ និងចរណមនុស្សដែលត្រូវប្រើក្នុងពេលបច្ចុប្បន្នដែរឬទេ?
- ចំណោះដឹង បំណិន វិជ្ជា គុណតម្លៃ និងចរណមនុស្សដែលយើងបានរៀនកាលពី១៥ ឬ២០ឆ្នាំមុន ឆ្លើយតបនឹងតម្រូវការបច្ចុប្បន្នឬទេ?
- កាលពី១០ឬ១៥ឆ្នាំមុន តើអ្នកគ្រូ លោកគ្រូធ្លាប់គិតដល់បញ្ញាសិប្បនិម្មិត ឬមនុស្សយន្តមកជំនួសគ្រូបង្រៀនក្នុងដំណើរការរៀនក្នុងថ្នាក់ដែរឬទេ?
- តើកាលពីអ្នកគ្រូ លោកគ្រូរៀននៅសាលាគរុកោសល្យ សាកលវិទ្យាល័យ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន កាលពី១០ឬ១៥ឆ្នាំមុន តើអ្នកគ្រូ លោកគ្រូធ្លាប់គិតថា មានឯកសារមេរៀនដ៏សម្បូរបែបក្នុងអន្តរបណ្តាញអ៊ិនធឺណេតដែរឬទេ?
- ក្រោយរកចម្លើយនៃសំណួរទាំងអស់ខាងលើ លោកគ្រូ អ្នកគ្រូអាចសួរ ៖
- តើជាគ្រូបង្រៀនឬអ្នកអប់រំត្រូវបំពេញកាតព្វកិច្ចអ្វីខ្លះបន្តទៀត?
- តើលោកគ្រូ អ្នកគ្រូ និងអ្នកអប់រំ ត្រូវរៀបចំរចនាសម្ព័ន្ធនៃដំណើរការរៀនយ៉ាងដូចម្តេច ដើម្បីបំពេញតម្រូវការចំណោះដឹង បំណិន វិជ្ជា ចរិយា គុណតម្លៃ និងចរណមនុស្ស សម្រាប់សិស្សក្នុង១០ឬ២០ឆ្នាំទៅមុខទៀត?
- តើគ្រូបង្រៀន កំពុងបង្រៀនក្នុងប្រព័ន្ធអប់រំបច្ចុប្បន្ន ត្រូវការរៀនអ្វីបន្ថែមទៀត ដើម្បីធានាឱ្យសិស្សទាំងអស់បានរៀនពិតប្រាកដ និងរៀនប្រកបដោយគុណភាព?

ក្របខ័ណ្ឌនៃការគិត និងការសរសេរគុណសម្បទាសម្រាប់សតវត្សរ៍ទី២១ មានច្រើនប្រភព តាមរបកគំហើញរបស់អ្នកស្រាវជ្រាវផ្សេងៗគ្នា។ សៀវភៅនេះកើតចេញពីការសំយោគការស្រាវជ្រាវពីច្រើនស្ថាប័ន និងច្រើនប្រទេស។ សៀវភៅនេះត្រូវបានសរសេរ សម្របតាមតម្រូវការ នៃការប្រើភាសាខ្មែរ និងឆ្លើយតបនឹងកាល និងបរិបទអប់រំកម្ពុជានាពេលបច្ចុប្បន្ន។ សៀវភៅនេះត្រូវបានសរសេរ សម្រាប់ជាឃ្លាំងគំនិតឱ្យគ្រូបង្រៀនយកទៅពិចារណា និងប្រើការដើម្បីចម្រើនប្រយោជន៍មនុស្សជាតិជំនាន់ក្រោយៗ។ អ្នកស្រាវជ្រាវក្រោយៗអាចពង្រីក បង្រួម ឬបង្រួញគោលនៃគុណសម្បទាសម្រាប់សតវត្សរ៍ទី២១ អាស្រ័យតាមកាល និងបរិបទផ្សេងទៀត។

ការសំយោគនៃរបកគំហើញបានពីការស្រាវជ្រាវជាច្រើន និងបង្កើតបានក្របខ័ណ្ឌគុណសម្បទា និងគុណតម្លៃមនុស្សសម្រាប់សតវត្សរ៍ទី២១៖

- គុណតម្លៃរៀន
- គុណតម្លៃឌីជីថល
- គុណតម្លៃការងារ
- គុណតម្លៃបុគ្គល
- គុណតម្លៃសង្គម

សៀវភៅនេះ ទម្លាក់ចោលនូវគុណតម្លៃ និងបំណិនមួយចំនួនដែលមានសរសេរ ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាឆ្នាំ២០១៦ របស់ក្រសួង អប់រំ យុវជន និងកីឡា ដូចជា អក្ខរសាស្ត្រ លេខសាស្ត្រ និងវិជ្ជាហិរញ្ញវត្ថុ។ល។

១០.១ គុណតម្លៃនៃការរៀន

ពិភពលោកនៃថ្ងៃម្សិលមិញ និងថ្ងៃនេះប្រែប្រួលឥតឈប់។ ពិភពលោកនៃថ្ងៃស្អែកនឹងខុសពីថ្ងៃនេះ។ ការគិតរបស់មនុស្សម្នាក់នៅវេលានេះនឹងប្តូរខុសពីការគិតរបស់មនុស្សនោះនៅនាទីក្រោយ។ ដើម្បីធានាឱ្យសិស្សរៀននៅថ្ងៃនេះបំពេញតម្រូវការនៃការគិត រៀន ធ្វើការ និងរស់នៅ សម្របជាមួយការរីកចម្រើនលឿននៃបញ្ញាសិប្បនិម្មិត ការស្រាវជ្រាវនេះសំយោគគុណតម្លៃនៃការ

រៀនជាបី ដែលបុគ្គលគ្រប់រូបត្រូវឃ្លាតខ្មី ៖ ១. ការរៀនពេញមួយជីវិត ២. ភាសាអង់គ្លេស ៣. បុច្ឆនវិជ្ជា។

### ១០.១.១ ការរៀនពេញមួយជីវិត

មនុស្សអភិវឌ្ឍន៍ និងសម្បូរទ្រព្យ (សម្ភារៈ និងសុខុមាលភាព) ប្រកាន់ និងប្រតិបត្តិគុណតម្លៃមួយប្រចាំជីវិត គឺ ការសង្វាតរៀនពេញមួយជីវិត។ គុណតម្លៃនៃការសង្វាតរៀនពេញមួយជីវិតជាចរណៈមួយនៃបុគ្គលពូកែ សរសេរក្នុងគម្ពីរព្រះត្រៃបិដក នៃព្រះពុទ្ធសាសនា គឺ ប្រតិបត្តិសិក្ខាទម្លាប់ (Khmer Buddhism Institute , 1931)។ អង្គការយូណេស្កូ (UNESCO) ឆ្នាំ១៩៥២ បានបង្កើតវិទ្យាស្ថានមួយ ឈ្មោះវិទ្យាស្ថានយូណេស្កូ ដើម្បីការរៀនពេញមួយជីវិត (UNESCO Institute of Life Long Learning)។ វិទ្យាស្ថាននេះមានបេសកកម្មលើកកម្ពស់ការរៀនពេញមួយជីវិត សម្រាប់ជួយដល់ប្រជាជនបាត់បង់ឱកាសរៀន នៅតាមប្រទេសក្រីក្រ និងកំពុងអភិវឌ្ឍន៍។ គ្រូបង្រៀនជាម្ចាស់ទាននៃវុឌ្ឍិចរិយា និងសេចក្តីចម្រើនរបស់មនុស្សគ្រប់ជំនាន់ ដូច្នេះ គ្រូបង្រៀនត្រូវប្រកាន់ និងប្រតិបត្តិគុណតម្លៃនៃការរៀនពេញមួយជីវិតជាប្រចាំ។

គ្រាប់ពូជនៃទម្លាប់ និងគុណតម្លៃ នៃការរៀនពេញមួយជីវិត ត្រូវការការបណ្តុះពូជ ដាំ ស្រោចទឹក ថែទាំ ដាក់ជីជាប្រចាំ ដូចការដាំស្រូវ ឬដំណាំផ្សេងៗដែរ។ ការបណ្តុះគ្រាប់ពូជ និងដាំទម្លាប់ និងគុណតម្លៃនៃការរៀនពេញមួយជីវិត ត្រូវផ្តើមពីគ្រូបង្រៀន។ គ្រាប់ពូជនៃទម្លាប់ និងគុណតម្លៃនៃការរៀនពេញមួយជីវិត អាចដុះលូតលាស់ពីការប្តូរទម្លាប់បង្រៀន និងរៀនរបស់គ្រូបង្រៀន។

ការប្តូរទម្លាប់បង្រៀន សំដៅប្តូរពីការបង្រៀនបែបពន្យល់ បកស្រាយ ប្រាប់ រ៉ាយរ៉ាប់ រៀបរាប់ ទៅជាការដឹកនាំសិស្សឱ្យរៀន ដោយឯករាជ្យ និងសេរីភាព។ ការដឹកនាំការរៀន សំដៅផ្តល់សេរីភាព និងឯករាជ្យដល់សិស្សឱ្យច្រើន។ ការផ្តល់សេរីភាព និងឯករាជ្យដល់សិស្សឱ្យច្រើន សំដៅផ្តល់ឱកាសឱ្យសិស្សឆ្ងល់ សង្កេត គិត បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ពីច្រើនប្រភព។

សេចក្តីពិតនៃចំណេះដឹង និងវិជ្ជាត្រូវការឱ្យសិស្សរៀនពីបទពិសោធ។ ការស្វែងសេចក្តីពន្យល់អំពីភាពពិត ច្បាស់លាស់ និងត្រឹមត្រូវចំពោះបញ្ញត្តិ

ព្រឹត្តិការណ៍ ព័ត៌មាន អង្គហេតុក្នុងមេរៀនមួយ សិស្សត្រូវរៀនដោយផ្ដើមពីឆ្ងល់ និងសង្កេត។ គ្រូបង្រៀនអាចបន្ថយទម្លាប់ប្រឹងស្រែកបកស្រាយ ពន្យល់ រាយរាប់ រៀបរាប់ និងប្រាប់អង្គហេតុ ខ្លឹមសារ និងព្រឹត្តិការណ៍ តាមសៀវភៅសិក្សាគោល និងការចេះចាំរបស់គ្រូបង្រៀន។ ក្នុងដំណើរការប្ដូរទម្លាប់បង្រៀននេះ សិស្សជាតួអង្គសំខាន់ក្នុងការគិត សង្កេត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងស្វែងរកអង្គហេតុពីច្រើនប្រភព មកពន្យល់វិញ។

សេចក្ដីភ័យខ្លាចសិស្សរៀនមិនចេះ មិនចាំ និងមិនយល់ ជាបេះដូងបរិសុទ្ធរបស់គ្រូបង្រៀនពិតមែន។ បេះដូងគ្រូបង្រៀន គឺបេះដូងអ្នកជួយដោយបរិសុទ្ធ។ បេះដូងបរិសុទ្ធនេះជំរុញចិត្តគ្រូបង្រៀនឱ្យប្រឹងនិយាយ បកស្រាយ រៀបរាប់ រាយរាប់ និងពន្យល់ ទៅតាមការចេះចាំ និងតាមខ្លឹមសារក្នុងសៀវភៅសិក្សាគោល។ ការភ័យខ្លាចនេះ ជាការដាំបណ្ដុះទម្លាប់ឱ្យសិស្សទន្ទឹងរង់ចាំពីគ្រូបង្រៀនប្រាប់ រាយរាប់ រៀបរាប់ ពន្យល់ និងបកស្រាយ។ ការភ័យខ្លាចរបស់គ្រូបង្រៀន ជំរុញចិត្តសិស្សឱ្យអសកម្ម ក្នុងការគិត សង្កេត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ ពីច្រើនប្រភព។

ជាទូទៅ ក្នុងទម្លាប់នៃការបង្រៀនបែបប្រពៃណី ដែលគ្រូបង្រៀនភ័យសិស្សរៀនមិនចេះ មិនយល់ មិនចាំ គ្រូបង្រៀនច្រើន ៖

- សរសេរចំណងជើងលើក្ដារខៀន
- សម្បូរចំណេះដឹងប្រាប់សិស្ស
- ពូកែចាំអង្គហេតុ និងព័ត៌មានតាមសៀវភៅសិក្សាគោល
- ចាំទ្រឹស្ដីច្រើន និងមានបទពិសោធច្រើនឆ្នាំ
- ចាំធាតុគោលច្រើន ឬទាំងអស់តាមសៀវភៅសិក្សាដែលបង្រៀនយូរឆ្នាំ
- ដឹកនាំសកម្មភាពរៀនមួយសម្រាប់សិស្សមួយថ្នាក់
- ពុំសូវស្គាល់សិស្សរៀនយឺត រៀនខ្សោយ សិស្សមានតម្រូវការពិសេស
- ផ្ដល់រង្វាន់ឱ្យសិស្សពូកែ និងបន្ទោសសិស្សរៀនយឺត ឬរៀនខ្សោយ
- ប្រើសៀវភៅសិក្សាគោលតែមួយមុខ សម្រាប់ការបង្រៀន
- ចាំដាច់ខែ ឬឆមាស ទើបចាត់ចែងការប្រឡង

- បង្រៀនដើម្បីបញ្ចប់សៀវភៅតាមចំណងជើង និងចំណងជើងរង
- ហៅឈ្មោះសិស្សឱ្យអានអត្ថបទមេរៀនបន្តគ្នា បណ្តាក់គ្នា ប្រដេញគ្នា។

គ្រូបង្រៀនហ៊ានលុបសេចក្តីភ័យខ្លាចនេះ គ្រូបង្រៀននឹងប្តូរទម្លាប់នៃការបង្រៀន។ សេចក្តីភ័យខ្លាចនោះ គឺខ្លាចសិស្សរៀនមិនចេះ មិនយល់ មិនចាំ។ វិធីដែលគ្រូបង្រៀនគួរប្រតិបត្តិ ដើម្បីលុបសេចក្តីភ័យខ្លាច ឬការបារម្ភ គឺប្រើវិធីសាស្រ្តសិក្សាបញ្ញត្តិ និងបុច្ឆនសិក្សា។ ប្រតិបត្តិទម្លាប់ដឹកនាំការរៀន តាមសិក្សាបញ្ញត្តិ និងបុច្ឆនសិក្សាជាប្រចាំ សិស្សអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ និងចូលរួមយ៉ាងសកម្ម ក្នុងដំណើរការរៀន។ សិស្សនិងគ្រូបង្រៀនរួមគ្នា អនុវត្តសកម្មភាព៖

- សិស្សនិងគ្រូបង្រៀនរួមគ្នារក និងបង្កើតបញ្ញត្តិសម្រាប់ដំណើរការរៀន
- សិស្សនិងគ្រូបង្រៀនរួមគ្នាបង្កើតលទ្ធផលសិក្សារំពឹងទុក
- សិស្សគិត សង្កេត ឆ្ងល់ ង្កើតសំណួរ និងសួរសំណួរ
- សិស្សស្វែងការរៀន និងការពន្យល់ពីច្រើនប្រភព
- សិស្សពិសោធវិជ្ជារៀនពីសាលា ជាមួយនឹងជីវភាពប្រចាំថ្ងៃ
- សិស្សសរសេរគម្រោងជាបុគ្គលនិងជាក្រុម
- សិស្សសហការរៀនជាមួយមិត្តរួមថ្នាក់
- សិស្សចូលរួមក្នុងសកម្មភាពជួយសហគមន៍
- សិស្សរកព័ត៌មានពីអន្តរបណ្តាញអ៊ិនធឺណែត
- សិស្សចូលរួមវាយតម្លៃលទ្ធផលសិក្សាជាប្រចាំ
- សិស្សប្រើបច្ចេកវិទ្យាព័ត៌មាន និងឧបករណ៍អ៊ិនធឺណេតដើម្បីការរៀន
- សិស្សអភិវឌ្ឍបំណិន និងវិជ្ជាប្រើការក្នុងសង្គម។

អនុវត្តន៍វិធីសាស្រ្តសិក្សាបញ្ញត្តិ និងបុច្ឆនសិក្សា គឺ គ្រូបង្រៀនអនុញ្ញាឱ្យសិស្សរៀនដោយឯករាជ្យ និងសេរីភាព។ សិស្សមានសេរីភាព និងឯករាជ្យក្នុងដំណើរការរៀន សិស្សនឹងអភិវឌ្ឍគុណសម្បទា បំណិន និងគុណតម្លៃមនុស្សច្រើនបែបច្រើនយ៉ាង។

ឧទាហរណ៍ លោកគ្រូ អ្នកគ្រូ ត្រូវបង្រៀនមេរៀនប្រវត្តិវិទ្យាមួយ អំពីរបបកម្ពុជាប្រជាធិបតេយ្យ នៅថ្នាក់ទី៨។ មេរៀននេះផ្តោតការយកចិត្តទុកដាក់

លើជីវិតកុមារអាយុក្រោម៧ឆ្នាំ។ បញ្ញត្តិក្នុងមេរៀននេះ របបអាហារសម្រាប់កុមារអាយុក្រោម៧ឆ្នាំ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ យុទ្ធវិធីដឹកនាំការរៀន គឺសម្ភាសន៍ដើម្បីការរៀន។

លោកគ្រូ អ្នកគ្រូកុំទាន់មានបុរេវិនិច្ឆ័យថា សិស្សថ្នាក់ទី៨ ពុំមានសមត្ថភាពគិតកម្រិតខ្ពស់ ដើម្បីប្រមូលទិន្នន័យតាមការសម្ភាសជាមួយមនុស្សចាស់ ឬក្រុមមនុស្សក្នុងវ័យផ្សេងៗ។ គ្រូបង្រៀនគួរបង្កបរិយាកាសឱ្យសិស្សបង្កើតគម្រោងមួយ។ គម្រោងរបស់សិស្សសំដៅដឹកនាំសិស្សឱ្យសម្ភាសចាស់ៗ មាតាបិតា ឬអ្នកភូមិដែលធ្លាប់រស់ឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ (សម្រាប់ថ្នាក់រៀនក្នុងទសវត្សរ៍ឆ្នាំ២០២០)។ បន្តបន្ទាប់មកទៀត គ្រូបង្រៀនគួរឱ្យសិស្សកត់ត្រាលទ្ធផលសម្ភាសន៍។ គ្រូបង្រៀនពុំគួរខ្វល់អំពីការសរសេរស្អាត ឬមិនស្អាត សរសេរត្រូវច្រើនឬត្រូវតិច។ គ្រូបង្រៀនគួរបារម្ភ និងផ្តោតការយកចិត្តទុកដាក់លើសំណួរមួយចំនួន ដូចជា ៖

- តើសិស្សបានបង្កើតសំណួរត្រៀមសម្ភាសន៍ឬមិនបាន?
- តើសិស្សបានពិភាក្សាគ្នាដើម្បីកែលម្អសំណួរដែរឬទេ?
- តើសិស្សបានសាកល្បងសួរសំណួរដែរឬទេ មុនទៅសម្ភាសន៍ចាស់ៗ?
- តើសិស្សបានសម្ភាសចាស់ៗឬមិនបាន?
- តើសិស្សបានកត់ត្រាលទ្ធផលសម្ភាសន៍ ឬមិនបានកត់ត្រា?
- តើគ្រូបង្រៀនផ្តល់ឱកាសឱ្យសិស្សចែករំលែកលទ្ធផលសម្ភាសន៍ឬអត់?

ក្នុងម៉ោងរៀនបន្តបន្ទាប់ទៀត អ្នកគ្រូ លោកគ្រូ ត្រៀមស្តាប់ការរ៉ាយរ៉ាប់រៀបរាប់ ពន្យល់ និងបកស្រាយរបស់សិស្ស។ អ្នកគ្រូ លោកគ្រូ ត្រូវឱ្យសិស្សផ្សេងទៀតកត់ត្រាគោលគំនិតនៃលទ្ធផលសម្ភាសន៍។ អ្នកគ្រូ លោកគ្រូ ត្រូវកត់ត្រាចំណុចសំខាន់បានពីការសម្ភាសរបស់សិស្ស។ បន្ទាប់មក អ្នកគ្រូ លោកគ្រូ ប្រៀបធៀបព័ត៌មាន ឬអង្គហេតុសរសេរក្នុងសៀវភៅ និងព័ត៌មាន ឬអង្គហេតុបានពីការសម្ភាសរបស់សិស្ស។ អ្នកគ្រូ លោកគ្រូសង្កេតសកម្មភាពដោយឆ្លើយសំណួរ៖

- តើសិស្សពេញចិត្តនឹងការសម្ភាសដែរឬទេ?
- តើសិស្សពេញចិត្តនឹងការសរសេរ កត់ត្រាឬទេ?

- តើសិស្សពេញចិត្តឡើងបង្ហាញលទ្ធផលឬទេ?
- តើសិស្សអភិវឌ្ឍបំណិនអ្វីខ្លះ?
- តើគម្រោងមួយនេះ ដាំបណ្ដុះទម្លាប់ និងគុណតម្លៃអ្វីខ្លះ?

ក្នុងឱកាសនេះ អ្នកគ្រូ លោកគ្រូ ពិតជាសង្កេតឃើញលទ្ធផលមួយចំនួន ៖

- សិស្សមួយចំនួនមិនសកម្មដូចទម្លាប់ធម្មតា
- សិស្សដែលធ្លាប់មិនសកម្ម ក្លាយជាសកម្ម ក្នុងដំណើរការរៀន

អ្នកគ្រូ លោកគ្រូ កុំវាស់សមត្ថភាពចងចាំរបស់សិស្សលើខ្លឹមសារ លេខអង្គហេតុ ព្រឹត្តិការណ៍ ឬឧទាហរណ៍ តាមសៀវភៅ។ អ្នកគ្រូ លោកគ្រូ គួរវាស់បំណិន ទម្លាប់ និងគុណតម្លៃ ដូចជា ការបង្កើតសំណួរ ការសួរសំណួរ ការកត់ត្រាចម្លើយ សកម្មភាពឡើងបង្ហាញ សកម្មភាពពន្យល់ បំណិនសរសេរអត្ថបទសម្ភាសន៍ បំណិនបង្កើតសំណួរ ភាពក្លាហាន និងការសហការ ។ល។

អ្នកគ្រូ លោកគ្រូគួរសួរសំណួរមួយចំនួនចំពោះខ្លួនឯង។ បន្ទាប់មក អ្នកគ្រូ លោកគ្រូប្រៀបធៀបទម្លាប់បង្រៀន និងការដឹកនាំការរៀន ដោយផ្ដល់សេរីភាព និងឯករាជ្យដល់សិស្សឱ្យច្រើន។ ឥឡូវ អ្នកគ្រូ លោកគ្រូ ចំណាយពេលគិត ៥៩វិនាទី! អ្នកគ្រូ លោកគ្រូ ប្រៀបធៀបទម្លាប់នៃការបង្រៀនដែលចាត់ទុកគ្រូបង្រៀន និងសៀវភៅសិក្សាគោលជាមេប្រភពនៃចំណេះដឹង ជាមួយនឹងការដឹកនាំការរៀនដែលសិស្សជាម្ចាស់នៃដំណើរការស្វែងការរៀន និងការពន្យល់។

- តើអ្នកគ្រូ លោកគ្រូ គួរឱ្យសិស្សចាំព្រឹត្តិការណ៍ ទីកន្លែង ឈ្មោះមនុស្ស និងកាលនៃប្រវត្តិសាស្ត្រ ឬឱ្យសិស្សអភិវឌ្ឍបំណិនគិត សង្កេត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ និងបញ្ជាក់ភាពពិត ច្បាស់លាស់ និងត្រឹមត្រូវ ដោយខ្លួនឯងដែរឬទេ?
- តើអ្នកគ្រូ លោកគ្រូ បញ្ជូនកូនទៅរៀនជាមួយគ្រូបង្រៀនដែលដឹកនាំសិស្សឱ្យរៀន ក្នុងភាពម្ចាស់ការ និងប្រកបដោយសេរីភាពឬយ៉ាងណា?
- តើអ្នកគ្រូ លោកគ្រូ បញ្ជូនកូនទៅរៀនជាមួយគ្រូបង្រៀនដែលយកសៀវភៅសិក្សាគោល ជាមេប្រភពនៃចំណេះ និងឱ្យសិស្សទន្ទេញ ចាំ និងសូត្ររត់មាត់ដែរឬទេ?

១០.១.២ ភាសាអង់គ្លេស

អង់គ្លេសជាភាសាចាំបាច់ សម្រាប់ប្រជាជនកម្ពុជា និងប្រជាជាតិអាស៊ាន ក្នុងយុគឧស្សាហកម្ម៤.០។ អ្នកដឹកនាំ អ្នកនយោបាយ អ្នកស្រាវជ្រាវ និងអ្នកបច្ចេកទេសនៃប្រជាជាតិអាស៊ាន ប្រើភាសាអង់គ្លេសជាផ្លូវការ ក្នុងរាល់កិច្ចប្រជុំ រាប់ពីកម្រិតបច្ចេកទេស ដល់កម្រិតនយោបាយ ក្នុងតំបន់អាស៊ាន។ ឯកសារសរសេរក្នុងកិច្ចប្រជុំអាស៊ាន និងអន្តរជាតិ ដូចជារបាយការណ៍ និងកំណត់ហេតុ ឬបទបង្ហាញ ក៏សរសេរជាភាសាអង់គ្លេសដែរ។ ក្នុងយុគនៃឧស្សាហកម្ម៤.0 ព័ត៌មាន ចំណេះដឹងថ្មី និងទាន់សភាពការណ៍ ជាភាសាអង់គ្លេស ឋិតក្នុងបាតដៃ និងម្រាមដៃមនុស្សដែលកាន់ឧបករណ៍អ៊ិនធឺណេត ដូចជាទូរស័ព្ទ កុំព្យូទ័រ Ipad ឬTablet។ល។

មនុស្សមានក្តីស្រឡាញ់ចំពោះការអានឯកសារ អ្នកនោះអាចរកសៀវភៅ ឬអត្ថបទ ពាក់ព័ន្ធនឹងព័ត៌មាន ចំណេះដឹង និងវិជ្ជាក្នុងគ្រប់វិស័យឯកទេស វិជ្ជាជីវៈ និងជំនាញ ពីអន្តរបណ្តាញអ៊ិនធឺណេតជាភាសាអង់គ្លេស។ មនុស្សចូលចិត្តមើលវីដេអូ មើលរូបភាព អាចរកព័ត៌មាន ឬចំណេះដឹងបែបវីដេអូ រូបភាព សំឡេង ឬទម្រង់ផ្សេង ក្នុងអន្តរបណ្តាញអ៊ិនធឺណេត ដូចជា Google, YouTube, Google Scholar និង Pinterest។ ប្រភពព័ត៌មាន ចំណេះដឹង និងវិជ្ជាភាគច្រើន សម្បូរជាភាសាអង់គ្លេស។

១០.១.៣ បុច្ឆនវិជ្ជា

វចនានុក្រមរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យខ្មែរ (1967) ឬវចនានុក្រមខ្មែរ សម្តេចសង្ឃរាជ ជួន ណាត ពន្យល់ថា **បុច្ឆា** មានន័យថា ពាក្យសួរ។ បុច្ឆាជាពាក្យសំស្ក្រឹត សរសេរឡាតាំងជា puccha។ សេចក្តីពន្យល់នៃពាក្យបុច្ឆា (puccha) ដកស្រង់ចេញពីបណ្ណាល័យទូរនិម្មិតរបស់ wisdom library (2008)។ បណ្ណាល័យនេះផ្តល់សេចក្តីពន្យល់លម្អិតលើពាក្យបាលី និងសំស្ក្រឹតយ៉ាងច្រើនសម្បូរបែប ជាភាសាអង់គ្លេស និងសំឡេងអានជាឡាតាំង។ **បុច្ឆា** សំដៅដល់ប្រព័ន្ធនៃចម្លើយ កម្រងនៃសំណួរ ដំណើរនៃការចោទសួរ និងការផ្តល់សេចក្តីពន្យល់តាមការចោទសួរ និងតាមសំណួរ។

**បុច្ឆនវិជ្ជា**ជាការផ្សំផ្គុំនៃពាក្យពីរ បុច្ឆានិងវិជ្ជា។ បុច្ឆនវិជ្ជាក្នុងបរិបទនេះ សំដៅដល់ដំណើរការនៃការបង្កើតពុទ្ធិថ្មី តាមរយៈការឆ្ងល់ គិត បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់លើសេចក្ដីពិត ភាពត្រឹមត្រូវ និងច្បាស់លាស់។

ចូរលោកគ្រូ អ្នកគ្រូ រំឭកបទពិសោធ នៃការរៀនលើចំណេះដឹង និងវិជ្ជាថ្មីមួយ។ តើការរៀនទទួលបានចំណេះដឹង និងវិជ្ជាថ្មីនេះ កើតចេញពីការឆ្ងល់ សង្កេត គិត បង្កើតសំណួរ សួរសំណួរ និងស្វែងសេចក្ដីពន្យល់បន្តដែរឬទេ?

មនុស្សគ្រប់រូបត្រូវការបុច្ឆនវិជ្ជាប្រចាំជីវិត។ បុច្ឆនវិជ្ជាជាឧបករណ៍ ដំណើរការ និងវិទ្យាសាស្ត្រនៃការបង្កើតពុទ្ធិថ្មី។ បុច្ឆនវិជ្ជាជាឧបករណ៍ ដំណើរការ និងវិទ្យាសាស្ត្រនៃការបើកចិត្តឱ្យទូលាយ ស្វែងការពន្យល់លើភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ ឱ្យកើតជាពុទ្ធិថ្មី។ មនុស្សមានបុច្ឆនវិជ្ជា គឺយល់ច្បាស់អំពីដំណើរនៃការឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់។ មនុស្សត្រូវការប្រើបុច្ឆនវិជ្ជាជាប្រយោជន៍ក្នុងជីវភាព ការងារ និងរៀនបន្ត។

អ្នកវិទ្យាសាស្ត្រ និងទស្សនវិទូ រាប់ពីព្រះពុទ្ធ (Siddhartha Gautama, ឆ្នាំ៥៦៣ ឬ ៤៨០មុន គ.ស - ឆ្នាំ៤៨៣ឬ៤០០ មុនគ.ស) ខុងជឺ (Confucius, ឆ្នាំ៥៥១-៤៧៩មុន គ.ស) សូក្រាត (Socrates, ឆ្នាំ៤៧០ - ឆ្នាំ៣៩៩ មុន គ.ស) ប្លាតូ (Plato, ៤២៤/៤២៣ -៣៤៨/៣៤៧ មុន គ.ស), អ៊ីសាក់ ញូតុន (Isaac Newton, ឆ្នាំ១៦៤៣–១៧២៧), ឡេវ វីហ្គុតស្គី (Lev Vygotsky, ឆ្នាំ១៨៩៦-១៩៣៤) និង ព្យ៉ាហ្សេ ហ្សង់ (Piaget Jean, ឆ្នាំ១៨៩៦-១៩៨០), បិនចាមិន ប្លូម (Benjamin BLOOM, ឆ្នាំ១៩១៣-១៩៩៩) ចន ឌូវី (John Dewey, ឆ្នាំ១៨៥៩-១៩៥២) និងជេរ៉ូម ប្រ៊ូណឺ (Jerome Bruner, ឆ្នាំ១៩១៥-២០១៦) បានចាត់ទុកការឆ្ងល់ ការគិត ការបង្កើតសំណួរ និងការសួរសំណួរ ជាបេះដូងនៃដំណើរការរៀនដ៏សកម្ម។

ចូរអ្នកគ្រូ លោកគ្រូ ចំណាយពេល៥៩វិនាទី រំឭកពីសំណួរអ្វីមួយដែលកុមារតូចសួរ ក្នុងគ្រួសារ ឬក្នុងសាលារៀន!

- តើជើងមេឃនៅឯណា?
- ហេតុអ្វីបានជាខ្ញុំយំចេញទឹកភ្នែក?
- ហេតុអ្វីបានជាទឹកភ្នែកខ្ញុំប្រៃ?

- ហេតុអ្វីបានជាខ្ញុំធំ?
- ហេតុអ្វីចាបហោះហើរ ខ្ញុំហោះហើរពុំកើត?

ចម្ងល់ និងសំណួរទាំងនេះ កើតចេញពីការគិតដំបូង និងសម្បូរអំណាចណាស់។ ចម្ងល់ និងសំណួរជាលំនាំនៃចិត្តនាំឱ្យមនុស្សស្វែងភាពជឿនលឿនតាមរយៈការសង្កេត គិត ស្វែងការពន្យល់ និងបង្កើតពុទ្ធិថ្មី។

ឧទាហរណ៍មួយអំពីដំណើរការរៀន និងរៀនក្នុងថ្នាក់រៀនប្រវត្តិវិទ្យា។ ឧបមាថា បារាំងពុំបានមកធ្វើជាអាណាព្យាបាលឱ្យប្រទេសកម្ពុជា ក្នុងចន្លោះឆ្នាំ ១៨៦៣-១៩៤៩ ទេ ៖

- តើប្រវត្តិសាស្ត្រប្រទេសកម្ពុជា អាចមានអ្វីកើតឡើងផ្សេង ខុសពីប្រវត្តិសាស្ត្រ បន្សល់ទុកមកដល់បច្ចុប្បន្នដែរឬទេ?
- តើស្ថានភាពនយោបាយ និងទម្រង់ នៃការគ្រប់គ្រងប្រទេសក្នុងសម័យព្រះបាទអង្គឌួង និងសម័យក្រោយៗ ត្រូវប្រឈមនឹងការឈ្លានពានពីបរទេសកម្រិតណា?
- តើប្រទេសកម្ពុជាអាចបាត់បង់ទឹកដីទៅប្រទេសជិតខាងទាំងស្រុងឬទេ?

សំណួរខាងលើអាចនាំលោកគ្រូ អ្នកគ្រូទៅរកផ្លូវគិតច្រើនសម្បូរបែប។ សំណួរបែបនេះអាចមានប្រតិកម្មពីគ្រូបង្រៀន ដូចជា ពិបាកគិតណាស់ ជ្រៅពេក ប៉ះពាល់នយោបាយ។ ផ្ទុយទៅវិញ សំណួរនេះដឹកនាំសិស្សឱ្យគិតកម្រិតខ្ពស់ និងនាំផ្លូវគិត ឬបើកលំហនៃការគិតរបស់សិស្ស ទៅរកការឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់បន្តទៀត។ សំណួរប្រភេទនេះអភិវឌ្ឍបំណិនប្រមូលទិន្នន័យ វិភាគ វាយតម្លៃ សន្និដ្ឋាន និងប្រមាណអំពីអនាគត។

វេលានេះ ការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់អំពីចម្លើយនៃសំណួរទាំងនេះ ពុំទាន់រកឃើញមែន។ ទោះបីជាយ៉ាងណា សំណួរនេះដាំបណ្តុះទម្លាប់គិត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ សម្រាប់ការរៀនបន្ត ឬស្រាវជ្រាវក្នុងពេលអនាគត។

ទស្សនវិទូ និងអ្នកវិទ្យាសាស្ត្រ ជាទូទៅចាត់ទុកការឆ្ងល់ និងចោទសួរជាបេះដូង នៃដំណើរការរៀនពិតប្រាកដ និងបង្កើតពុទ្ធិថ្មី។ សូក្រាត (Socrates, ឆ្នាំ

៤៧០ - ឆ្នាំ៣៩៩ មុន គ.ស) ពន្យល់អំពីឥទ្ធិពលនៃសំណួរ សម្រាប់នាំផ្លូវចិត្តឱ្យមនុស្សគិតទៅរកច្រើនទិសសម្បូរបែប។ ទិសច្រើនរបស់សូក្រាត សំដៅដល់ការស្វែងការពន្យល់ចំពោះគំនិតស្មុគស្មាញ ត្រដាងសេចក្តីពិត បើកគម្របនៃបញ្ហាកំពុងគ្របជិត និងញែកឱ្យដាច់រវាងការដឹង និងការមិនទាន់ដឹង។

បុច្ឆនវិជ្ជាបង្កើតបានលទ្ធផល និងរបកគំហើញដែលជាចំណេះដឹង និងវិជ្ជាថ្មីៗជាច្រើនសម្រាប់មនុស្សបន្តជំនាន់ ឧទាហរណ៍៖

- ព្រះពុទ្ធ (Siddhartha Gautama, ឆ្នាំ៥៦៣ ឬ ៤៨០មុន គ.ស - ឆ្នាំ៤៨៣ ឬ៤០០ មុនគ.ស) ឆ្ងល់ និងស្វែងការពន្យល់អំពីទុក្ខសច្ចៈ។ ព្រះពុទ្ធបង្រៀនមនុស្សឱ្យរំលុតទុក្ខ និងបង្កើតសុខ។
- អ៊ីសាក់ ញូតុន (Isaac Newton, ឆ្នាំ១៦៤៣-១៧២៧) ស្វែងការពន្យល់អំពីមូលហេតុនៃការធ្លាក់ផ្លែប៉ោម។ លោកពន្យល់ទ្រឹស្តីទម្លាក់សេរី និងបង្កើតបានរូបមន្តកម្លាំងទំនាញមួយឱ្យអ្នកវិទ្យាសាស្ត្ររៀនជាហូរហែ។ ចម្លល់របស់ អ៊ីសាក់ ញូតុន ចាប់ផ្តើមពីការគិត សង្កេត ឆ្ងល់ បង្កើតសំណួរ ចោទសំណួរ និងស្វែងការពន្យល់អំពីទ្រឹស្តីទម្លាក់សេរី។
- គណិតវិទូ ពីតាហ្គ័រ (Pythagoras, ឆ្នាំ៥៧០-៤៩៥មុន គ.ស) បង្កើតទ្រឹស្តីពីតាហ្គ័រ ចេញពីការគិត ឆ្ងល់ បង្កើតសំណួរ និងសួរសំណួរ ស្រាយចម្ងល់។
- បៀលហ្គេត (BILL Gates, ឆ្នាំ១៩៥៥-បច្ចុប្បន្ន) និងភរិយា ម៉េលីនដា Melinda (ឆ្នាំ១៩៦៤-បច្ចុប្បន្ន) ពុំមែនភ្ញាក់ពីដំណេក នឹកឃើញបង្កើតមូលនិធិ BILL and Melinda Gates Foundation និងផ្តល់មូលនិធិជួយដល់ការស្រាវជ្រាវអំពីថ្នាំព្យាបាលជំងឺអេដស៍ និងវេជ្ជសាស្ត្រផ្សេងទេ។
- ស្ទីវចប (Steve Jobs, ឆ្នាំ១៩៥៥-២០១១) បង្កើតបានកុំព្យូទ័រខ្នាតតូចដោយហេតុតែមួយគត។ លោកបានឃើញកុំព្យូទ័រខ្នាតធំពេលនៅក្មេង។ លោកក៏គិត និងឆ្ងល់ ដើម្បីរកវិធីបង្កើតកុំព្យូទ័រខ្នាតតូច។
- បុព្វបុរសខ្មែរកសាងអង្គរវត្ត និងប្រាសាទនានាជាកេរដំណែលខ្មែរ ក៏កើតចេញពីការគិត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ដែរ។

ចម្លល់ និងសំណួរមានឥទ្ធិពល និងបើកផ្លូវចិត្តឱ្យមនុស្សគិតកាន់តែច្រើនមានជម្រើស នៃគំនិត និងគិតស៊ីជម្រៅ។ ចូរលោកគ្រូ អ្នកគ្រូ សាកល្បងសង្កេតសកម្មភាពរបស់ខ្លួនឯង។ លោកគ្រូ អ្នកគ្រូរៀនសង្កេត និងបង្កើតអ្វីមួយថ្មី។ តើលោកគ្រូ អ្នកគ្រូ គិត ឆ្ងល់ និងបង្កើតសំណួរ ដើម្បីសួរខ្លួនឯងជាមុនឬទេ? ក្នុងជីវិតរស់នៅ សំណួរជួយយើងច្រើនណាស់។ យើងភ្លេចគិត និងកត់ត្រាសំណួរដែលយើងបានសួរខ្លួនឯង និងសង្កេតផលបានពីការឆ្ងល់ គិត បង្កើតសំណួរ និងសួរសំណួររបស់ខ្លួនឯង។

របកគំហើញនៃការស្រាវជ្រាវមួយចំនួនពន្យល់ថា ចម្ងល់បង្កើតជាសំណួរចែកជាពីរប្រភេទ គឺ ១. សំណួរវិជ្ជមាន សំណួរស្ថាបនា ឬសំណួរថ្ងៃប្រឌិត ២. សំណួរអវិជ្ជមាន ឬសំណួរទើស។ សៀវភៅនេះពុំផ្តោតការយកចិត្តទុកដាក់លើសំណួរទាំងពីរប្រភេទនេះទេ។ ក្នុងដំណើរការរៀនក្នុងវគ្គនេះ សៀវភៅនេះសង្ខេប និងផ្តោតការយកចិត្តទុកដាក់លើវិជ្ជានុក្រមសំណួរសូក្រាត (Socrates, ឆ្នាំ ៤៧០ - ឆ្នាំ៣៩៩ មុន គ.ស) ដែលមាន៣កម្រិត ៖ ១. សំណួរប្រតិបត្តិប្រចាំថ្ងៃ ២. សំណួរស្វែងបន្ត ៣. សំណួរបញ្ញត្តិ ៖

១. **សំណួរកម្រិត១ ឬ សំណួរប្រតិបត្តិប្រចាំថ្ងៃ** ៖ វិភាគដំណើរប្រព្រឹត្តទៅនៃការគិត ប្រមូលផ្តុំការចងចាំ និងផ្តោតការយកចិត្តទុកដាក់លើការនឹករកព័ត៌មាន ឬរំឭកអង្គហេតុ ឬទិន្នន័យដែលបុគ្គលសួរសំណួរធ្លាប់ឆ្លងកាត់បទពិសោធ។ ឧទាហរណ៍នៃសំណួរកម្រិត១ ៖
   - តើរាជក្សត្រអង្គណាបានសាងសង់ប្រាសាទអង្គរវត្ត?
   - តើរាជធានីនៃអាណាចក្រខ្មែរសម័យចេនឡាឋិតនៅឯណាខ្លះ?
   - តើបារាំងបានដាក់អាណាព្យាបាលលើប្រទេសកម្ពុជាប៉ុន្មានឆ្នាំ?
   - តើមេដឹកនាំកំពូល៣នាក់នៃរបបកម្ពុជាប្រជាធិបតេយ្យឈ្មោះអ្វី?
   - តើប្រជាជនកម្ពុជាត្រូវសាទរការចុះបញ្ជីប្រាសាទព្រះវិហារជាសម្បត្តិបេតិកភណ្ឌពិភពលោក នៅថ្ងៃអ្វី ខែអ្វី និងឆ្នាំណា?

២. **សំណួរកម្រិត២ ឬសំណួរស្វែងបន្ត** ៖ សំដៅស្វែងការពន្យល់លើគំនិតដែលសម្តែងចេញ តាមរយៈការប្រាស្រ័យមនុស្ស និងផ្តោតការយកចិត្តទុកដាក់

លើទម្រង់ ឬទម្លាប់នៃដំណើរប្រព្រឹត្តទៅនៃការគិតរបស់មនុស្ស។ ពេលមនុស្សទទួលបានព័ត៌មាន ស្គាល់អង្គហេតុ ចាំទិន្នន័យក្នុងជំហានដំបូង និងធ្លាប់មានបទពិសោធ មនុស្សសួរសំណួរដើម្បីបញ្ជាក់ឱ្យច្បាស់ និងស្វែងការពន្យល់លើភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃចម្ងល់។ ឧទាហរណ៍នៃសំណួរកម្រិត២ ៖

- តើបារាំងបានមកគ្រប់គ្រងកម្ពុជា ក្នុងទម្រង់ជាអាណាព្យាបាល ឬជាអាណានិគម?
- តើអាណាព្យាបាលឬអាណានិគមមានលក្ខណៈស្រដៀងគ្នាអ្វីខ្លះ?
- តើមានហេតុផលអ្វីមកពន្យល់អំពីការជ្រើសរើសភ្នំពេញជារាជធានីរបស់ខ្មែរក្នុងសម័យចតុមុខ?

៣. **សំណួរកម្រិត៣ ឬសំណួរបញ្ញត្តិ** ៖ មានចេតនាវាយតម្លៃគុណភាពនៃការគិត និងហេតុផលដែលបានពន្យល់ដើម្បីបង្កើតបញ្ញត្តិសម្រាប់ការគិតបន្ត បង្កើតទ្រឹស្តីថ្មី ឬវិធីសាស្ត្រថ្មី។ សំណួរបញ្ញត្តិទាមទារឱ្យសិស្សគិតកម្រិតខ្ពស់ ឬគិតស៊ីជម្រៅ ប្រើវិជ្ជាស្រាវជ្រាវពីកម្រិតមូលដ្ឋាន ដល់កម្រិតវិទ្យាសាស្ត្រ ៖

- តើអ្នកសន្និដ្ឋានយ៉ាងណាអំពីទម្រង់នៃការគ្រប់គ្រងអាណាចក្រខ្មែរ របស់ព្រះបាទជ័យវរ្ម័នទី៧ ក្នុងសម័យអង្គរ?
- ប្រសិនបើអ្នកជាក្សត្រខ្មែរនាសម័យឧដុង្គ តើអ្នកសម្រេចចិត្តបញ្ចៀសជម្លោះផ្ទៃក្នុងដោយវិធីអ្វី ឬដោយរបៀបណា?
- តើបុព្វបុរសខ្មែរពិតជាបានដឹកជញ្ជូនថ្មផ្ទាំងធំៗពីភ្នំគូលែន មកសាងសង់ប្រាសាទអង្គរ និងប្រាសាទនានាមែនដែរឬទេ?
- តើអ្នកសន្និដ្ឋានយ៉ាងដូចម្តេចចំពោះទម្រង់នៃការគ្រប់គ្រងអំណាចរបស់បារាំង មកលើកម្ពុជា ក្នុងសម័យបារាំង?
- តើទម្រង់នៃការគ្រប់គ្រងរបស់បារាំងនៅកម្ពុជា អាចចាត់ចូលជាទម្រង់អាណាព្យាបាលបានដែរឬទេ?
- តើទម្រង់នៃការគ្រប់គ្រងរបស់បារាំងនៅកម្ពុជា អាចចាត់ចូលជាអាណានិគមបានដែរឬទេ?

១០.២ គុណតម្លៃឌីជីថល

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព៤.៤ (SDG Target 4.4) សំដៅបង្កើនចំនួនមនុស្សពេញវ័យ និងយុវវ័យឱ្យមានវិជ្ជាឌីជីថល។ អង្គការ UNESCO បានចងក្រងក្របខ័ណ្ឌអនុវត្តកម្មវិធីអភិវឌ្ឍន៍វិជ្ជា និងគុណតម្លៃឌីជីថល ក្នុងឆ្នាំ ២០១៨ (United Nations Educational, Scientific and Cultural Organization, 2018)។ គ្រូបង្រៀនកម្ពុជាក៏ត្រូវអភិវឌ្ឍវិជ្ជា និងគុណតម្លៃឌីជីថលជាចាំបាច់ ដើម្បីបំពេញតម្រូវការរៀនបន្ត និងដឹកនាំសិស្សរៀនឱ្យដល់កម្រិតវិជ្ជា។ កម្រិតវិជ្ជាសំដៅដល់សមត្ថភាពប្រើឌីជីថលក្នុងវិជ្ជាជីវៈ និងគ្រប់បរិបទ។

គ្រូបង្រៀន និងសិស្សអភិវឌ្ឍវិជ្ជា និងគុណតម្លៃឌីជីថល គឺមានសមត្ថភាពរក និងប្រើឯកសារពីអន្តរបណ្តាញអ៊ីនធឺណែត ប្រកបដោយការទទួលខុសត្រូវ និងក្រមសីលធម៌។ សូមលោកគ្រូ អ្នកគ្រូ សាកល្បងសួរខ្លួនឯង និងស្វែងការពន្យល់ចំពោះសំណួរមួយចំនួន អំពីគុណតម្លៃឌីជីថលសម្រាប់សាលារៀនដែលលោកគ្រូ អ្នកគ្រូកំពុងបង្រៀន៖

- តើមានគ្រូបង្រៀនប៉ុន្មាននាក់ពុំប្រើទូរស័ព្ទពុំប្រើFacebook ពុំចេះបើកYouTube ដើម្បីរកមើលវីដេអូ និងពុំបើកGoogleរកឯកសារ?
- តើមានគ្រូបង្រៀនប៉ុន្មាននាក់ កំពុងប្រើទូរស័ព្ទភ្ជាប់ប្រព័ន្ធអ៊ិនធឺណែត និងប៉ុន្មាននាក់មិនភ្ជាប់ប្រព័ន្ធអ៊ិនធឺណែត?
- តើមានគ្រូបង្រៀនប៉ុន្មាននាក់មានកុំព្យូទ័រយួរដៃ?
- តើមានមន្ត្រី និងថ្នាក់ដឹកនាំសាលារៀនប៉ុន្មាននាក់ ស្ទាត់ជំនាញប្រើកុំព្យូទ័រ វាយអត្ថបទលឿន ប្រើកម្មវិធីច្រើនបែបច្រើនយ៉ាង?
- តើគ្រូបង្រៀនប៉ុន្មាននាក់ស្គាល់ប្រព័ន្ធរកព័ត៌មានតាម Google និងរកឯកសារស្រាវជ្រាវពី Google Scholar?
- តើមានគ្រូបង្រៀន និងថ្នាក់ដឹកនាំសាលារៀនប៉ុន្មាននាក់មានគណនី និងចេះបើកគណនីក្នុង Google scholar, Gmail, Gdrive, Google Classroom, Google Docs, Google Blog, Google Site?

- តើមានអ្នកគ្រូ លោកគ្រូណាខ្លះចេះប្រើMicrosoft Education, Microsoft Project, Microsoft Team និងមានគណនី ឬ Email របស់ Microsoft ឬOutlook, One Drive?
- តើគ្រូបង្រៀនប៉ុន្មាននាក់ មានសមត្ថភាពបង្កើតBLOG សម្រាប់ចែករំលែក និងបង្រៀនសិស្ស តាមមុខវិជ្ជាឯកទេស?

គ្រូបង្រៀនត្រូវមានចំណេះដឹង បំណិន វិជ្ជា ឥរិយាបថ និងទម្លាប់ក្នុងការប្រើប្រព័ន្ធឌីជីថល និងឧបករណ៍ឌីជីថល ប្រកបដោយការទទួលខុសត្រូវ ដោយៈ

- មានគណនីក្នុងអន្តរបណ្តាញអ៊ិនធឺណេត
- ប្រើអន្តរបណ្តាញអ៊ិនធឺណេតឬបណ្ណាល័យទូរនិម្មិត
- រកភស្តុតាងស្រាវជ្រាវពីអន្តរបណ្តាញអ៊ិនធឺណេត
- ចែករំលែកឯកសារដោយការទទួលខុសត្រូវ។

១០.២.១ គណនីក្នុងអន្តរបណ្តាញអ៊ិនធឺណេត

ក្នុងយុគនៃឧស្សាហកម្ម៤.0 មនុស្សគ្រប់រូប និងវ័យ ត្រូវស្ទាត់ប្រើឧបករណ៍ឌីជីថលច្រើនប្រភេទ ដូចជាទូរស័ព្ទ កុំព្យូទ័រ Ipad ឬTablet សម្រាប់ការរៀនបន្ត ដឹកនាំការរៀន ធ្វើជំនួញ ធ្វើការ ស្រាយបញ្ហា ចំណាយហិរញ្ញវត្ថុ គ្រប់គ្រងបុគ្គលិក និងប្រាស្រ័យមនុស្ស។ ដូច្នេះ គ្រូបង្រៀនត្រូវមានវិជ្ជាឌីជីថល និងភ្ជាប់ការងារ ការរៀន និងរស់នៅជាមួយឌីជីថល។ គ្រូបង្រៀនត្រូវស្ទាត់ប្រើឧបករណ៍បច្ចេកវិទ្យាព័ត៌មាន និងឧបករណ៍អ៊ិនធឺណេតច្រើនបែបច្រើនយ៉ាង និងប្រើគណនីក្នុងអន្តរបណ្តាញអ៊ិនធឺណេត ដូចជា ៖

- បង្កើតគណនី គ្រប់គ្រងលេខសម្ងាត់ និងការពារសុវត្ថិភាពគណនី
- ជ្រើសរើសព័ត៌មាន និងទិន្នន័យគួរឱ្យទុកចិត្ត និងប្រើការបាន
- ចែករំលែកព័ត៌មាន និងទិន្នន័យប្រកបដោយការទទួលខុសត្រូវ
- ប្រើវិជ្ជាឌីជីថលសម្រាប់ប្រាស្រ័យមនុស្ស និងដោះស្រាយបញ្ហា
- បង្កើតវេទិកាចែករំលែកចំណេះដឹង ក្នុងប្រព័ន្ធឌីជីថល
- ការពារសុវត្ថិភាព និងសុខភាព ក្នុងពេលប្រើបច្ចេកវិទ្យាព័ត៌មាន
- ស្រាយបញ្ហាបច្ចេកទេសសាមញ្ញពាក់ព័ន្ធនឹងការប្រើឧបករណ៍។

១០.២.២ អន្តរបណ្តាញអ៊ិនធឺណេត ឬបណ្ណាល័យទូរនិម្មិត

បណ្ណាល័យទូរនិម្មិត សំដៅដល់បណ្ណាល័យ សម្រាប់អ្នកប្រើនៅទីឆ្ងាយ និងអាចបើកយកឯកសារជាច្រើនទម្រង់តាមចំណង់ ដូចជា រូបភាព វីដេអូ សំឡេង សំណេរ។

ឃ្លាំងចំណេះដឹង ព័ត៌មាន និងទិន្នន័យថ្មី និងចាស់ មានសម្បូរបែបក្នុងអន្តរបណ្តាញអ៊ិនធឺណេត ពិតនិងមិនពិត ត្រឹមត្រូវនិងកុហក។ នៅបរទេស និងកម្ពុជា ស្ទើរគ្រប់ស្ថាប័នជំនាញ មានគេហទំព័រ សម្រាប់ចែករំលែកចំណេះដឹង។ លើសពីនេះទៀត មានបុគ្គលច្រើននាក់កំពុងប្រើគេហទំព័រ បណ្តាញអ៊ិនធឺណេត ប្រព័ន្ធឌីជីថល ដើម្បីរកប្រាក់ចំណូល ដោយមើលរំលងក្រមសីលធម៌។

ដូច្នេះ ភាពចាំបាច់របស់គ្រូបង្រៀន និងសិស្ស គឺបំណិនវិភាគ និងវាយតម្លៃ ដើម្បីរកភាពពិត ច្បាស់លាស់ និងត្រឹមត្រូវនៃព័ត៌មាន។ សំខាន់ដូចគ្នាផងដែរ គ្រូបង្រៀន និងសិស្សត្រូវមានសមត្ថភាពវាយតម្លៃ ជ្រើសរើសព័ត៌មានយកមកប្រើ និងចែករំលែកប្រកបដោយក្រមសីលធម៌។

អ្នកគ្រូ លោកគ្រូ កំពុងបង្រៀនមុខវិជ្ជាប្រវត្តិវិទ្យា។ អ្នកគ្រូ លោកគ្រូ បង្រៀនមេរៀនមួយ អំពីប្រទេសម៉ុងហ្គោលី ថ្នាក់ទី៩ ក្នុងសម័យ ហ្សង់ហ្ស៊ីខាន់ (Genghis Khan, ឆ្នាំ១១៦២-១២២៧)។ អ្នកគ្រូ លោកគ្រូ អាចរកមើលមេរៀនជាភាសាអង់គ្លេសក្នុងប្រអប់រុករក Google ឬ YouTube ដោយគ្រាន់តែបញ្ចូលអក្សរ Genghis Khan ក្នុង Google ឬYouTube។ បញ្ហាប្រឈមគឺភាពស្ទាត់ខាងភាសាអង់គ្លេស។ ទោះយ៉ាងណា លោកគ្រូ អ្នកគ្រូ កុំទាន់បារម្ភ។ Google Translate អាចជួយសម្រួលការលំបាកក្នុងការបកប្រែបាន។ បំណិនប្រើបណ្ណាល័យទូរនិម្មិត ក្នុងអន្តរបណ្តាញអ៊ិនធឺណេត គ្រូបង្រៀន និងសិស្សត្រូវ ៖

- ប្រើឱកាសរកព័ត៌មាន ទិន្នន័យ និងចំណេះដឹងថ្មី
- វាយតម្លៃ និងជ្រើសរើសព័ត៌មាន ទិន្នន័យ និងចំណេះដឹងថ្មី
- ប្រើព័ត៌មាន ទិន្នន័យ និងចំណេះដឹងថ្មី ត្រូវតាមកាល និងបរិបទ
- ចែករំលែកព័ត៌មាន និងចំណេះដឹងថ្មី ប្រកបដោយក្រមសីលធម៌
- គ្រប់គ្រងលំហូរព័ត៌មាន និងចំណេះដឹងថ្មី ដោយទទួលខុសត្រូវ។

១០.២.៣ ភស្តុតាងស្រាវជ្រាវ

ព័ត៌មាន និងចំណេះដឹងថ្មីដែលអ្នកគិតមិនទាន់ដល់ ឬគិតដល់ ប៉ុន្តែមិនទាន់រកឃើញក្នុងពេលនេះ ប្រហែលជាអ្នកគ្រូ លោកគ្រូរកបានក្នុងអន្តរបណ្តាញអ៊ិនធឺណេត ដូចជា YouTube, Google, Pinterest និងGoogle Scholar។ ឧទាហរណ៍ គ្រូបង្រៀនម្នាក់ប្រាប់ថា ព្យាបាលជំងឺលើសជាតិស្ករ លើសខ្លាញ់ និងចុករោយចង្កេះ អ្នកគ្រូ លោកគ្រូ គ្រាន់តែបង្អត់អាហារ និងទឹកក្នុងរយៈពេលពី៤៨ម៉ោង ទៅ៧២ម៉ោង ក្នុងមួយខែម្តង ឱ្យបានពី៣ ទៅ៥ដង ក្នុងមួយឆ្នាំ។ តើចិត្តរបស់អ្នកគ្រូ លោកគ្រូប្រតិកម្មយ៉ាងដូចម្តេចចំពោះព័ត៌មាននេះ?

មនុស្សទន់ខ្សោយ និងខ្វះវិជ្ជា ឬអវិជ្ជា គឺប្រើតែទិន្នន័យចាស់ ឬអារម្មណ៍ប៉ុណ្ណោះ ដើម្បីប្រតិកម្ម និងសម្រេចចិត្ត។ មនុស្សទន់ខ្សោយ និងខ្វះវិជ្ជា មិនយកព័ត៌មានថ្មីមកគិត ឆ្ងល់ សង្កេត បង្កើតសំណួរ និងសួរសំណួរទេ។ មនុស្សទន់ខ្សោយ និងខ្វះវិជ្ជា មិនស្វែងការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ នៃព័ត៌មានដំបូង ពីច្រើនប្រភព តាមវិធីវិទ្យាសាស្ត្រទេ។

គ្រូបង្រៀនពូកែគឺបរិបូរដោយវិជ្ជា និងចរណៈ។ គ្រូបង្រៀនត្រូវដឹកនាំការរៀនឱ្យសិស្សពង្រីកវិសាលភាពនៃគំនិត ដោយពង្រីកការគិត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់រកភាពពិត ច្បាស់លាស់ និងត្រឹមត្រូវនៃព័ត៌មានពីច្រើនប្រភព និងគួរឱ្យទុកចិត្ត។

ចំណេះដឹងស្ទើរគ្រប់វិស័យ គិតទាំងប្រវត្តិសាស្ត្រកម្ពុជា តំបន់ ប្រទេស និងពិភពលោក មានសម្បូរបែបក្នុងអន្តរបណ្តាញអ៊ិនធឺណេត។ តើលោកគ្រូ អ្នកគ្រូពុំធ្លាប់ឮ ឬដឹងអំពីប្រយោជន៍នៃការបង្អត់អាហារ និងទឹកសម្រាប់សុខភាព និងព្យាបាលជំងឺឬទេ? លោកគ្រូ អ្នកគ្រូ អាចស្វែងការពន្យល់អំពីពាក្យ Autophagy Fasting ក្នុង YouTube និងGoogle Scholar។ លោកគ្រូ អ្នកគ្រូនឹងឃើញ ឯកសារ និងវីដេអូ រាប់ម៉ឺនប្រភេទ ពន្យល់ចម្ងល់អំពីការបង្អត់អាហារដើម្បីលើកកម្ពស់សុខភាព និងព្យាបាលជំងឺ។

សូមលោកគ្រូ អ្នកគ្រូ សាកល្បងបើក YouTube តែ២នាទី តើអ្នកគ្រូ លោកគ្រូអាចរកឃើញអ្វីខ្លះ និងអ្នកឯកទេសណាខ្លះនិយាយអំពី Autophagy Fasting?

តើអ្នកគ្រូ លោកគ្រូ អាចស្តាប់យល់ ឬអានយល់អំពីប្រយោជន៍នៃការបង្អត់ទឹក និងអាហារគ្រប់៧២ម៉ោងដែរឬទេ? តើការនិយាយ និងការបកស្រាយគំនិតអំពី Autophagy Fasting ក្នុងYouTube និងអត្ថបទក្នុង Google Scholar មានលក្ខណៈវិទ្យាសាស្ត្រកម្រិតណា?

អន្តរបណ្តាញអ៊ិនធឺណេតក៏សម្បូរព័ត៌មាន និងចំណេះដឹងថ្មីអំពីប្រវត្តិសាស្ត្រដែរ។ ឧទាហរណ៍ មេរៀនមួយនិយាយអំពីអរិយធម៌ម៉ាយ៉ា (Maya)។ តើអ្នកគ្រូ លោកគ្រូ គិតថា លោកគ្រូ អ្នកគ្រូអាចរកមេរៀនពីYouTube ឬGoogle បានដែរឬទេ? តើការបង្រៀនរបស់លោកគ្រូ អ្នកគ្រូអំពីអរិយធម៌ម៉ាយ៉ា (Maya) ក្នុងអន្តរបណ្តាញអ៊ិនធឺណេត YouTube ឬ Google សិស្សនិងគ្រូស្តាប់ និងអានជាភាសាអង់គ្លេស ពុំយល់មែនដែរឬទេ?

ក្នុងបច្ចុប្បន្ន គ្រូបង្រៀនពិតជាជួបការលំបាកក្នុងការស្តាប់ និងការអានភាសាអង់គ្លេស ប៉ុន្តែកុំបារម្ភ! ការអានភាសាអង់គ្លេស លែងជាឧបសគ្គខ្លាំងពេកហើយ។ អ្នកគ្រូ លោកគ្រូអាចសុំឱ្យGoogle Translate ជួយបកប្រែ និងបញ្ចេញសំឡេងឱ្យស្តាប់ក៏បាន។ អ្នកគ្រូ លោកគ្រូអាចអានសំឡេងឱ្យ Google Translate បកប្រែទៅជាអក្សរសរសេរក៏បាន។ ដូច្នេះ ការរៀនភាសា ឬបកប្រែមួយចំនួនធំត្រូវបានសម្រួលដោយបច្ចេកវិទ្យាសម័យទំនើប និងបញ្ញាសិប្បនិម្មិត។ អ្នកគ្រូ លោកគ្រូ កុំទាន់គិតថា ការរៀនភាសាអង់គ្លេសពិបាក។

គុណតម្លៃនៃឌីជីថល និងឧបករណ៍អ៊ិនធឺណេត ពិតជាជួយគ្រូបង្រៀនបានច្រើនណាស់ ក្នុងការស្វែងរកភស្តុតាង តាមវិធីវិទ្យាសាស្ត្រមកបង្រៀនសិស្ស និងដឹកនាំសិស្សឱ្យរៀនបែបសកម្ម។ គ្រូបង្រៀនមានវិជ្ជាឌីជីថល ពិតជាអាចជួយលើកកម្ពស់គុណភាពនៃការរៀន និងបង្រៀនបាន ដោយពុំបាកពេកទេ។

១០.៣ គុណតម្លៃការងារ

គ្រប់កន្លែងការងារ និងនិយោជកត្រូវការមនុស្សពូកែ។ គម្ពីរព្រះត្រៃបិដកភាសាខ្មែរ នៃព្រះពុទ្ធសាសនា បោះពុម្ពដោយវិទ្យាស្ថានពុទ្ធិសាសនបណ្ឌិត្យ (Khmer Buddhism Institute , 1931) ពន្យល់ថា មនុស្សពូកែ គឺពោរពេញដោយវិជ្ជា និងចរណៈ។ វិជ្ជា ដូចជាវិជ្ជាលេខ វិជ្ជាគរុ (វិជ្ជាបង្រៀនសិស្ស) សំដៅដល់

សេចក្ដីចេះដឹងច្បាស់ ឬការរៀនបានខ្ពង់ខ្ពស់ ឬរៀនរហូតចប់ថ្នាក់។ ចរណៈសំដៅដល់ការប្រព្រឹត្តិ និងចរិយាល្អ។ ចរណៈជាយានដឹកនាំបុគ្គល មិនឱ្យលុះក្នុងគ្រាលំបាក ទលិទ្ទភាព តោកយ៉ាក។ លើសពីនេះទៀត ចរណៈជាយាននាំមនុស្សឱ្យរស់ក្នុងជីវភាពប្រសើរ សម្បូរទ្រព្យ និងសុខុមាលភាព។

គ្រប់កន្លែងការងារ និយោជកត្រូវការបុគ្គលិកពូកែទាំងវិជ្ជាបច្ចេកទេស និងចរណៈ ចរិយា និងការប្រព្រឹត្តិល្អ។ ដូច្នេះ ក្នុងដំណើរការរៀនក្នុងថ្នាក់ សិស្សត្រូវការរៀនទាំងវិជ្ជាឯកទេស ចរិយា និងការប្រព្រឹត្តិល្អ។ ចរិយា និងការប្រព្រឹត្តិល្អ ជាគុណតម្លៃមួយដែលមនុស្សគ្រប់រូបត្រូវប្រើ ក្នុងការបំពេញការងារ និងរស់ក្នុងសង្គម ជាប្រយោជន៍នៃមនុស្សជាតិ។

និយោជក ស្ថាប័នឯកជន រដ្ឋ គ្រឹះស្ថានអប់រំ។ល។ តែងចង់បានបុគ្គលិកដែលរៀនខ្ពង់ខ្ពស់ ទទួលសញ្ញាបត្រពីសាលារៀន ឬសាកលវិទ្យាល័យល្បីៗ។ និយោជកតែងសន្មតថា និយោជិតរៀនបានសញ្ញាបត្រខ្ពស់ ឬរៀនពូកែ មានវិជ្ជាសម្បទា និងបំណិនសម្បទា សម្រាប់បម្រើការងារ។ ទោះជាយ៉ាងណា មានការស្រាវជ្រាវជាច្រើនពន្យល់ថា និយោជកច្រើនបញ្ឈប់និយោជិតពីការងារ ដោយសារចរិយា និងការប្រព្រឹត្តិមិនល្អ ក្នុងការងារ (Partnership for 21st Century Learning, 2016; Trilling & Fadel, 2009; Trought, 2012)។

គុណតម្លៃការងារជាធាតុចាំបាច់សម្រាប់បុគ្គលគ្រប់រូប។ សៀវភៅនេះសំយោគ គុណតម្លៃការងារជា៥ក្រុមខ័ណ្ឌ ៖

- បញ្ញាវិជ្ជា
- ប្រាស្រ័យមនុស្ស និងគ្រប់គ្រងទំនាក់ទំនង
- ភាពជាអ្នកដឹកនាំ និងអាត្មាវិជ្ជា
- គណនេយ្យភាព
- សហការក្រុម

១០.៣.១ បញ្ញាវិជ្ជា (វិជ្ជាស្រាយបញ្ហា)

មនុស្សគ្រប់វ័យ និងភេទ សុទ្ធតែត្រូវប្រឈមនឹងបញ្ហា និងជម្លោះ។ មនុស្សត្រូវរកដំណោះស្រាយចំពោះបញ្ហា និងជម្លោះ ក្នុងគ្រប់ជំហាននៃជីវិត។

បុគ្គលមួយនាក់មានសមត្ថភាពស្រាយបញ្ហា លុះណាបុគ្គលនេះ មានចំណេះដឹង និងវិជ្ជាក្នុងការរកភស្តុតាង វាយតម្លៃឫសនៃបញ្ហា និងកំណត់អាទិភាពនៃបញ្ហា។ មនុស្សគ្រប់រូបត្រូវប្រតិបត្តិទាំងវិជ្ជា និងបញ្ញា មិនមែនហិង្សា ដើម្បីស្រាយបញ្ហា និងជម្លោះ។ ការរៀនពិតប្រាកដ ឬប្រកបដោយគុណភាព សំដៅធានាឱ្យសិស្ស អភិវឌ្ឍវិជ្ជា និងបញ្ញា ក្នុងការស្រាយបញ្ហា និងជម្លោះ។ វិជ្ជានិងបញ្ញា ក្នុងការស្រាយបញ្ហា និងជម្លោះ ហៅថា បញ្ញាវិជ្ជា។

បញ្ញាវិជ្ជាជាឧបករណ៍ និងវិធីសាស្ត្រវិទ្យាសាស្ត្រមួយ សម្រាប់ជីវភាពប្រចាំថ្ងៃ ការងារ និងរៀនបន្តរបស់មនុស្សគ្រប់រូប និងគ្រប់វ័យ។ ការរៀនអំពីបញ្ញាវិជ្ជា សំដៅបំពាក់ចំណេះដឹង វិជ្ជា និងបំណិនច្រើនបែបច្រើនយ៉ាង ដល់អ្នកសិក្សា។ មនុស្សអាចប្រើហិង្សាវិធី និងពង្រីកបញ្ហា និងជម្លោះកាន់តែច្រើន និងកាន់តែស្មុគស្មាញ ប្រសិនបើមនុស្សខ្វះការគិតស៊ីជម្រៅ ពុំពូកែរកភស្តុតាង និងវាយតម្លៃឫសនៃបញ្ហា និងពុំពូកែញែក និងកំណត់អាទិភាពចំពោះជម្រើសនៃដំណោះស្រាយបញ្ហា។

មនុស្សមានវិជ្ជានិងបញ្ញាក្នុងការស្រាយបញ្ហា និងជម្លោះតែងមានជម្រើស និងវិធីច្រើនសម្បូរបែប។ បញ្ញាវិជ្ជាចាប់ផ្តើមពីការគិត ឆ្ងល់ សង្កេត បង្កើតសំណួរ សួរសំណួរ វិភាគ ញែកប្រភេទ និងបរិមាណនៃធាតុបង្កបញ្ហា និងធ្វើផែនការស្រាយបញ្ហាចាប់ពីធាតុបង្កតូចៗ។

សៀវភៅនេះសំយោគដំណើរការបង្កើតវិធាន និងបច្ចេកទេសស្រាយបញ្ហា សម្រាប់សិស្សមធ្យមសិក្សាបឋមភូមិ។ សិស្សមានវិជ្ជាស្រាយបញ្ហា គឺចេះញែកបញ្ហាមួយឱ្យទៅជាភាគល្អិត ឬរាប់បរិមាណនៃបំណែកបញ្ហា។ លើសពីនេះទៀត សិស្សអាចពន្យល់ហេតុ នៃការកើតបញ្ហាពីឫសដើមនៃហេតុរបស់បញ្ហា។

ដំណើរការរៀនដោយបង្កបរិយាកាសឱ្យសិស្សមានវិជ្ជាស្រាយបញ្ហា និងជម្លោះជាដំណើរការរៀនពិតប្រាកដ ប្រកបដោយគុណភាព និងដាំបណ្តុះបំណិនគិតកម្រិតខ្ពស់។ មនុស្សពូកែស្រាយបញ្ហា និងជម្លោះ មានបំណិន៖

- វិភាគ និងវាយតម្លៃស្ថានភាព
- រកឫសគល់ និងធាតុបង្កនៃបញ្ហា

- រាប់ចំនួននៃឫសគល់ និងធាតុបង្កបញ្ហា និងជម្លោះ
- វាយតម្លៃឫសគល់នៃបញ្ហា
- សំយោគទិន្នន័យពាក់ព័ន្ធនឹងបញ្ហា និងជម្លោះ
- បង្កើតវិធានស្រាយបញ្ហា ប្រកបដោយនវកម្មគំនិត
- ប្រមាណទុកអំពីបញ្ហាប្រឈមអាចកើតឡើង
- កំណត់អាទិភាព និងជម្រើសនៃដំណោះស្រាយ
- សង្កេត តាមដានស្ថានភាព
- វាយតម្លៃឧបសគ្គ និងហេតុរារាំងដំណើរការស្រាយបញ្ហា

១០.៣.២ ប្រាស្រ័យមនុស្ស និងគ្រប់គ្រងទំនាក់ទំនង

គុណសម្បទាប្រាស្រ័យមនុស្ស និងគ្រប់គ្រងទំនាក់ទំនងជាតម្រូវការចាំបាច់ ដែលបញ្ញាសិប្បនិម្មិត ឬមនុស្សយន្ត មិនអាចជំនួសមនុស្សបាន។ ក្នុងយុគឧស្សាហាកម្ម៤.០ មនុស្សអាចបញ្ជូនសារឆ្លងទ្វីបក្នុងមួយវិនាទី។ មនុស្សអាចស្រាយជម្លោះបាន ដោយគ្រាន់តែជួបមុខ ញញឹមដាក់គ្នា និងនិយាយជាមួយគ្នាដោយសេចក្ដីពិត និងចិត្តស្មោះ។ មនុស្សពូកែខាងប្រាស្រ័យមនុស្ស និងគ្រប់គ្រងទំនាក់ទំនង អាចស្រាយបញ្ហាបានច្រើនជំពូក ទាន់ពេល និងក្នុងគ្រប់បរិបទ។

ទម្រង់ និងប្រភេទនៃប្រាស្រ័យមនុស្សមានច្រើន ដូចជា ការនិយាយផ្ទាល់មាត់ជាមួយមនុស្សមួយនាក់ ឬមួយក្រុម សរសេរ គូរគំនូរ និងកាយវិការ។ មនុស្សពូកែប្រាស្រ័យមនុស្ស និងគ្រប់គ្រងទំនាក់ទំនង ច្រើនបើកចិត្តទូលាយដើម្បីស្ដាប់ និងទទួលយកនានាភាព ពហុភាពនៃគំនិត ភាពរួម និងភាពដោយឡែកនៃទស្សនៈ។ល។

ក្នុងយុគឧស្សាហាកម្ម៤.០ ការប្រាស្រ័យមនុស្ស និងគ្រប់គ្រងទំនាក់ទំនងអាចមិនជួបមុខគ្នា ប៉ុន្តែអាចដោះស្រាយបញ្ហាបាន។ មនុស្សពូកែប្រាស្រ័យមនុស្ស និងគ្រប់គ្រងទំនាក់ទំនងអាចប្រើបច្ចេកវិទ្យាព័ត៌មាន ក្នុងការទាក់ទងមនុស្ស អាចចែករំលែកគំនិត និងផ្ដល់យោបល់នូវជម្រើសអាទិភាពនៃដំណោះស្រាយបញ្ហា និងជម្លោះ និងចរចាជំនួញ។

ចូរលោកគ្រូ អ្នកគ្រូ សាកល្បងវាស់បំណិនផ្ទាល់ខ្លួន សម្រាប់ការប្រាស្រ័យមនុស្ស និងគ្រប់គ្រងទំនាក់ទំនង ក្នុងស្ថានភាពផ្សេង តាមឧទាហរណ៍ខាងក្រោម។ បន្តបន្ទាប់មកទៀត សូមលោកគ្រូ អ្នកគ្រូ សាកល្បងសួរខ្លួនឯងមួយសំណួរ។ តើយុវជនជំនាន់ក្រោយអាចធ្វើការអ្វីបានខ្លះ ដើម្បីប្រយោជន៍មនុស្ស និងចក្រវាល ប្រសិនបើពួកគេមានគុណសម្បទាប្រាស្រ័យមនុស្ស និងគ្រប់គ្រងទំនាក់ទំនង? ដើម្បីយល់អំពីគុណសម្បទានេះ លោកគ្រូ អ្នកគ្រូ បន្តអានឧទាហរណ៍ខាងក្រោម និងឆ្លុះបញ្ចាំងសេចក្តីពិតនៃខ្លួនឯង។

មិត្តភក្តិ និងអ្នកស្គាល់ខ្ញុំជាច្រើននាក់ ធ្លាប់ប្រាប់ខ្ញុំថា ៖

- ខ្ញុំប្រើពាក្យនិយាយច្បាស់ៗ និងងាយយល់ ពេលនិយាយ
- ខ្ញុំបញ្ចេញសម្តីទំនាក់ទំនងមនុស្ស ប្រកបដោយអារម្មណ៍វិជ្ជមាន
- ខ្ញុំសម្បូរគំនិតបញ្ចេញក្នុងការជែកគ្នាជាក្រុម ឬពេលប្រជុំផ្លូវការ
- ខ្ញុំមិនភ័យរាល់ពេលឡើងនិយាយលើឆាក ឬក្នុងចំណោមមនុស្ស
- ខ្ញុំជាមនុស្សយកចិត្តទុកដាក់ស្តាប់អ្នកដទៃនិយាយរហូតចប់
- បើទោះបីមនុស្សមានទស្សនៈផ្ទុយ ឬខុសអំពីខ្ញុំ ក៏ខ្ញុំនៅតែស្តាប់
- ខ្ញុំរកព័ត៌មានផ្សេងៗ ពីប្រភពអ៊ិនធឺណេត ឱ្យមិត្តភក្តិដែលត្រូវការ
- ខ្ញុំបង្កើតមិត្តភក្តិបានច្រើនឱ្យតែបានជួបមុខនិយាយគ្នា
- ខ្ញុំប្រតិបត្តិសេចក្តីពិត ឬនិយាយតែការពិតជាប្រចាំ
- ខ្ញុំស្ទាត់ប្រើឧបករណ៍អ៊ិនធឺណេត និងបង្កើតទំនាក់ទំនងតាមរយ Email, Facebook, Skype, Telegram, WhatsApp, Line ។ល។
- ខ្ញុំដឹកនាំក្រុមពិភាក្សាស្រាយបញ្ហា ឬជម្លោះបានល្អ
- ខ្ញុំសួរសំណួរចំចំណុច និងងាយយល់
- ខ្ញុំប្រកាន់ជំហរមួយច្បាស់ គឺឱ្យតម្លៃចំពោះនានាភាពនៃគំនិត
- ខ្ញុំតែងផ្តល់ឱកាសឱ្យអ្នកផ្សេងបញ្ចេញយោបល់ឱ្យអស់
- ខ្ញុំពេញចិត្តនឹងចែករំលែកព័ត៌មាន ដោយការទទួលខុសត្រូវ
- ខ្ញុំមានសេចក្តីស្មោះត្រង់ក្នុងការរាប់អានមិត្ត
- ខ្ញុំគិតគ្រប់ជ្រុងជ្រោយទើបចែកចាយព័ត៌មានតាមបណ្តាញសង្គម

- ខ្ញុំតែងចែករំលែកគំនិតអប់រំឱ្យអ្នកផ្សេង ដោយពេញចិត្ត។

១០.៣.៣ ភាពជាអ្នកដឹកនាំ និងអាត្មាវិជ្ជា

ចេតនានៃការសរសេរឡាតាំងនូវឈ្មោះគម្ពីរបុរាណ ដូចជា Vedanta Advaita និង Bhagavad Gita សំដៅទុកឱ្យលោកគ្រូ អ្នកគ្រូ ស្វែងសេចក្តីយល់បន្ថែមក្នុងអន្តរបណ្តាញអ៊ិនធឺណេត។

គម្ពីរទស្សនវិជ្ជាបុរាណ និងគម្ពីរសាសនា ដូចជា គម្ពីរ Vedanta Advaita (P, 2017) គម្ពីរព្រះត្រៃបិដកនៃព្រះពុទ្ធសាសនា និងគម្ពីរ Bhagavad Gita (Easwaran, 2020) ពន្យល់ថា ភាពជាអ្នកដឹកនាំ និងអាត្មាវិជ្ជាជាគុណសម្បទានៃមនុស្សពូកែ។

អាត្មាវិជ្ជា សំដៅដល់វិជ្ជាស្គាល់ខ្លួនឯងច្បាស់ ទាំងចិត្ត កាយ ប្រាណ និងអារម្មណ៍ដើម្បីប្រតិបត្តិសេចក្តីពិត មេត្តា មេត្រីភាព សង្គ្រោះ និងស្រឡាញ់។

ភាពជាអ្នកដឹកនាំសំដៅដល់សិល្បៈ និងវិទ្យាសាស្ត្រនៃថាមពល ក្នុងការអន្ទងចិត្តមនុស្សដទៃជាបុគ្គល និងជាក្រុមឱ្យសម្រេចគោលដៅ និងបង្កើតមាគ៌ាប្រពៃមួយសម្រាប់ស្ថាប័នមួយសម្រេចក្តីសុបិនរួម (Will Peters, 2017; Morial, 2020; Adair, 2018)។

ភាពជាអ្នកដឹកនាំ និងអាត្មាវិជ្ជាកាន់តែត្រូវការ ដើម្បីដឹកនាំជីវិតឱ្យដើរទាន់ជវភាពនៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា ប្រជាសាស្ត្រ សង្គម សេដ្ឋកិច្ច រដ្ឋបាល ពាណិជ្ជកម្ម និងឧស្សាហកម្ម។ល។

ការដឹកនាំអ្នកដទៃ និងអន្ទងចិត្តអ្នកដទៃបាន ត្រូវការអាត្មាវិជ្ជាដោយខានពុំបាន។ អ្នកស្រាវជ្រាវ និងទស្សនវិទូជាច្រើននាក់បានបន្ថែមតម្លៃនៃគំនិតអំពីភាពចាំបាច់នៃទំនាក់ទំនងរវាងភាពជាអ្នកដឹកនាំ និងអាត្មាវិជ្ជាសម្រាប់ការរស់នៅ ធ្វើការ និងរៀនបន្ត ដើម្បីបង្កើតសុខុមាលភាព និងសម្ភារៈ។ អាត្មាវិជ្ជាជាឧបករណ៍ចាំបាច់មួយសម្រាប់យកទៅប្រើក្នុងការដឹកនាំអ្នកដទៃ ដោយផ្តើមចេញពីការស្គាល់ខ្លួនឯង ទាំងកាយ ចិត្ត និងអារម្មណ៍ (Society of Abidance in Truth (SAT), 2019; Nikhilananda, 1947)។

គម្ពីរបុរាណជាច្រើន និងការស្រាវជ្រាវសម័យទំនើបពន្យល់ថា អាត្មាវិជ្ជា ឬការស្គាល់ខ្លួនឯងច្បាស់ជាប្រភពនៃជោគជ័យសម្រាប់ជីវិត។ ភាពជោគជ័យនៃបុគ្គលម្នាក់ដើម្បីរស់ក្នុងសុខុមាលភាព និងសម្ភារៈ ផ្តើមចេញពីអាត្មាវិជ្ជា។ អាត្មាវិជ្ជា និងភាពជោគជ័យ គឺផ្តើមចេញពីការក្តីស្រឡាញ់ ព្យាយាមតាមសេចក្តីពិត និងការប្រើថាមពលពីកាយ និងចិត្តដោយភាពស្មោះត្រង់។ សៀវភៅជាច្រើនអំពីសូក្រាត (Socrates, ឆ្នាំ៤៧០ - ឆ្នាំ៣៩៩ មុន គ.ស) សរសេរប្រយោគមួយគួរចាំទុកក្នុងចិត្ត និងប្រតិបត្តិប្រចាំជីវិត។ សិស្សសូក្រាត (Socrates, ឆ្នាំ៤៧០ - ឆ្នាំ៣៩៩ មុន គ.ស) តែងសួរសំណួរមួយយ៉ាងសាមញ្ញ។ តើខ្ញុំចាប់ផ្តើមពីចំណុចណាដើម្បីជីវិតជោគជ័យ? សូក្រាត (Socrates, ឆ្នាំ៤៧០ - ឆ្នាំ៣៩៩ មុន គ.ស) តបយ៉ាងខ្លី "ស្គាល់ខ្លួនឯង"។ អ្នកស្រាវជ្រាវអំពីភាពជោគជ័យក្នុងអាជីពការងារឈ្មោះ Darren Hardy (2013) ពន្យល់ថា កញ្ចប់នៃភាពជោគជ័យសម្រាប់ជីវិតពឹងលើការស្គាល់ និងកែទម្លាប់របស់ខ្លួនឯង។

គម្ពីរបុរាណជាច្រើន ដូចជាគម្ពីរវេទ គម្ពីរទស្សនវិជ្ជា Bhagavad Gita (Easwaran, 2020) គម្ពីរទស្សនវិជ្ជា Vedanta Advaita គម្ពីរ Upanishad និងគម្ពីរព្រះត្រៃបិដកព្រះពុទ្ធសាសនា ក៏បានសរសេរអំពីសារៈសំខាន់នៃការស្គាល់ខ្លួនឯង ឬអាត្មាវិជ្ជាដែរ។ អាត្មាវិជ្ជាជាយានសម្រាប់ដឹកនាំខ្លួនឯង និងអ្នកដទៃទៅរំដោះទុក្ខ និងបង្កើតសួននៃបីតិ និងសេចក្តីសុខ (Society of Abidance in Truth (SAT), 2019; Easwaran, 2020; Khmer Buddhism Institute , 1931)។

ការរៀនអំពីអាត្មាវិជ្ជា ឬការស្គាល់ខ្លួនឯងសំដៅបណ្តុះបណ្តាលចិត្ត និងបង្ហាត់ចិត្តមនុស្សឱ្យក្លាយជាពលរដ្ឋពូកែ។ ពលរដ្ឋពូកែ គឺមានវិជ្ជា និងចរណៈ។ ពលរដ្ឋពូកែ ដឹកនាំខ្លួនឯងឱ្យប្រតិបត្តិសេចក្តីពិត មេត្តា សង្គ្រោះ មេត្រីភាព និងក្តីស្រលាញ់ជាប្រចាំ។ អាត្មាវិជ្ជាសំដៅដល់ការសិក្សា ចំណេះដឹង និងការប្រើខ្លួនឯងឱ្យដល់សក្តានុពលក្នុងជីវិត (Society of Abidance in Truth (SAT), 2019; Khmer Buddhism Institute , 1931) ដើម្បីប្រយោជន៍នៃផែនដី និងចក្រវាល។

គម្ពីរទស្សនវិជ្ជា Vedanta Advaita គម្ពីរព្រះត្រៃបិដកនៃព្រះពុទ្ធសាសនា និងគម្ពីរ Bhagavad Gita (Easwaran, 2020) ញែកលម្អិតអំពីការស្គាល់ខ្លួនឯង ឬ

អាត្មាវិជ្ជា ដើម្បីឱ្យមនុស្សងាយស្រួលប្រតិបត្តិ រស់ប្រកបដោយសេចក្តីពិត និងសុខ។ អាត្មាវិជ្ជា មានចេតនាបង្រៀនមនុស្សឱ្យយល់អំពីកាយ ចិត្ត ប្រាណ និងអារម្មណ៍។ អាត្មាវិជ្ជាបង្រៀនមនុស្សឱ្យដឹកនាំខ្លួនឯងឱ្យល្អ ប្រកបដោយសេចក្តីមេត្តា មេត្រីភាព សង្គ្រោះ និងស្រលាញ់ ទើបដឹកនាំអ្នកដទៃបានល្អ។

តើអ្នកគ្រូ លោកគ្រូស្គាល់ យល់ និងប្រតិបត្តិអំពីកាយ ចិត្ត ប្រាណ និងអារម្មណ៍របស់ខ្លួនឯងច្បាស់ហើយឬនៅ? ដើម្បីឱ្យងាយយល់ តើអ្នកគ្រូ លោកគ្រូធ្លាប់ចំណាយចិត្តខឹង និងប្រតិកម្មត្រឡប់ ដោយសម្តី កាយ និងអារម្មណ៍អវិជ្ជមានដែរឬទេ? ចូរលោកគ្រូ អ្នកគ្រូសង្កេតខ្លួនឯង និងសួរខ្លួនឯងពីរសំណួរ។

- តើខ្ញុំត្រូវទទួលបានផលអ្វីមកដល់កាយ និងចិត្តរបស់ខ្លួនឯងវិញ?
- តើខ្ញុំបានទទួលដំណោះស្រាយចំពោះបញ្ហាបានប្រសើរឬទេ?

លោកគ្រូ អ្នកគ្រូ សាកល្បងចំណាយពេល៥៩វិនាទីគិតរឿងសាមញ្ញមួយទៀត។ ពេលមនុស្សម្នាក់និយាយមាក់ងាយអ្នកថា អ្នកជាមនុស្សចោលម្សៀត ឬតិះដៀលអ្នកថា អាឆ្កែ ឬមីឆ្កែ។ អ្នកគ្រូ លោកគ្រូ សាកល្បងតប ដោយសម្តីល្អពីរោះ ស្មោះត្រង់ និងញញឹមចំពោះសម្តីតិះដៀល។ បន្ទាប់មក អ្នកគ្រូ លោកគ្រូចាប់ផ្តើមសង្កេត និងរាប់ដំណើរចិត្តរបស់ខ្លួនឯង។ តើអ្នកគ្រូ លោកគ្រូ មានអារម្មណ៍ស្ងប់ ឬមានកំហឹងលើសដើម?

> ពេលមានភ្ញៀវមួយនាក់មកលេងផ្ទះ អ្នកគ្រូ លោកគ្រូទទួលផ្លែឈើ។ ភ្ញៀវនោះពុំបានហូបផ្លែឈើដែលអ្នកគ្រូ លោកគ្រូដាក់ទទួលទេ។ តើផ្លែឈើនោះក្លាយជារបស់ភ្ញៀវ ឬនៅជារបស់អ្នកគ្រូ លោកគ្រូ?
>
> ភ្ញៀវនោះពុំហូប និងមិនខ្ចប់ផ្លែឈើនោះតាមខ្លួនទេ។ ផ្លែឈើនោះនៅជារបស់អ្នកគ្រូ លោកគ្រូ។ ដូចគ្នាដែរ ពាក្យជេរ ប្រមាថ និងមាក់ងាយនោះនៅតែជារបស់អ្នកជេរ ។

ផ្ទុយទៅវិញ មនុស្សដែលបានបញ្ចេញសម្តីតិះដៀល និងប្រមាថ គឺទទួលប្រតិកម្មពង្រីកចិត្តក្រោធកាន់តែធំ។ មនុស្សប្រកាន់ចិត្តក្រោធបែបនេះ អាចយកការគិត និងឆ្ងល់មកពិចារណាលើភាពមិនខឹងរបស់អ្នក និងអាចប្តូរឈប់ខឹង។ អ្នកគ្រូ លោកគ្រូ ឆ្លើយតបដោយកាយវិការញញឹម គឺបានជួយដល់មនុស្សប្រតិកម្ម

ក្រោធ។ អ្នកគ្រូ លោកគ្រូមានមេត្តាចិត្តជ្រៅណាស់។ អ្នកគ្រូ លោកគ្រូរួមចំណែកផ្លាស់ប្តូរទម្លាប់ខឹង ឬចរិតទោសៈរបស់មនុស្សដទៃ និងប្តូរសង្គម។

សូមលោកគ្រូ អ្នកគ្រូសាកល្បងគិតរឿងសាមញ្ញមួយទៀត។ ចិត្តមនុស្សពុំមែនលោតផ្លោះដូចស្វាធម្មតាទេ។ ចិត្តមនុស្សលោតផ្លោះដូចស្វាស្រវឹងស្រា និងត្រូវខ្ទីម៉ាល់ទិច។ ពេលអ្នកគ្រូ លោកគ្រូដាក់ខ្នងដល់កន្ទេល ខំប្រឹងដេក ក៏ដេកមិនលក់។ ចិត្តរបស់អ្នកគ្រូ លោកគ្រូ គិតច្រើនហួសប្រមាណ ឬមានវិតក្កចិត្ត។ តើលោកគ្រូ អ្នកគ្រូត្រូវការរក្សាចិត្តឱ្យស្ងប់ និងដេកស្កប់លក់ស្រួលដែរឬទេ?

- បញ្ចេញដង្ហើមតាមមាត់ ឱ្យអស់ខ្យល់ រហូតពោះផត គឺស៊ើរដាច់ដង្ហើម
- ស្រូបខ្យល់តាមច្រមុះឱ្យពេញ រហូតពោះប៉ោង
- កុំទាន់បញ្ចេញខ្យល់ទៅវិញភ្លាម ដោយរក្សាខ្ទប់ដង្ហើមមួយសន្ទុះ
- រាប់ដង្ហើមឱ្យបានពី១០ដងទៅ២០ដង ឬច្រើនជាងនេះ
- បញ្ចេញដង្ហើមតាមមាត់សន្សឹមៗឱ្យវែង
- ដង្ហើមចេញនិងចូលរ៉ាប់មួយ
- រក្សាដង្ហើមបែបនេះឱ្យបានពី៣ទៅ៥នាទី
- បន្ទាប់មកទៀត បិទភ្នែកសម្ងំដេក
- ស្អែកព្រឹកឡើង លោកគ្រូ អ្នកគ្រូសង្កេតសភាពនៃកាយ និងអារម្មណ៍
- សួរខ្លួនឯងនូវសំណួរពីរ ៖
    - តើខ្ញុំមានដំណេកស្ងប់កម្រិតណា?
    - តើសភាពខុសកាយ និងអារម្មណ៍ខ្ញុំខុសពីសព្វមួយដង?

អ្នកគ្រូ លោកគ្រូ ប្រតិបត្តិដង្ហើមបែបនេះមុនចូលដំណេកឱ្យបាន២៨ថ្ងៃបន្តជាប់ៗគ្នា។ ចូរលោកគ្រូ អ្នកគ្រូសង្កេត និងសម្គាល់ខ្លួនឯងអំពីដំណេក និងសុខភាពនៃរាងកាយ និងអារម្មណ៍របស់អ្នកគ្រូ លោកគ្រូ។

- តើទម្លាប់ដេក និងចិត្តស្ងប់ មានការប្រែប្រួលកម្រិតណា?
- តើសុខភាពនៃរាងកាយ និងអារម្មណ៍ស្រស់ថ្លាកម្រិតណា?

សូមលោកគ្រូ អ្នកគ្រូ សាកល្បងគិត និងប្រតិបត្តិរឿងសាមញ្ញមួយ ប៉ុន្តែពិបាកបំផុត។ ឧបមាថា អ្នកគ្រូ លោកគ្រូកំពុងអានសៀវភៅនេះ មានអាយុ៤០ឬ

៥០ឆ្នាំហើយ។ អ្នកគ្រូ លោកគ្រូ ធ្លាប់តែហូបបាយពីរឬបីពេល មិនដែលដាច់បាយ ដាច់ទឹកមួយថ្ងៃពេញ ឬ២៤ម៉ោងសោះ។ ពេលណាមួយ អ្នកគ្រូ លោកគ្រូមានអារម្មណ៍ថា ក្តៅខ្លួន ស្រៀវស្រាញ់ អស់កម្លាំង ល្វិតល្វៃ ពុំមានមូលហេតុ។ អ្នកគ្រូ លោកគ្រូ សាកល្បងឃាត់ចិត្តខ្លួនឯង ដោយផ្តាច់អាហារ និងទឹក ឬចំណីគ្រប់មុខឱ្យបាន៤៨ម៉ោង។ និយាយភាសាសាមញ្ញ គឺពុំមានអ្វីចូលតាមមាត់ ទៅក្រពះ ក្នុងរយៈពេល៤៨ម៉ោង ឬលើសពីនេះ។

បន្ទាប់មក លោកគ្រូ អ្នកគ្រូ សង្កេតសភាព នៃរាងកាយ។ តើអ្នកគ្រូ លោកគ្រូ បានធូរស្បើយ និងស្រួលខ្លួនកម្រិតណា? មានភាពស្រណុកស្រួលក្នុងខ្លួនប៉ុនណា? សូមលោកគ្រូ អ្នកគ្រូ កុំគិតថា ធ្វើមិនកើត។ ឱ្យតែចិត្តគិត ធ្វើមិនគឺមិនកើត។ ដូច្នេះ អ្នកគ្រូ លោកគ្រូត្រូវប្រកាន់ចិត្តគិតថា ធ្វើកើត។ អ្នកគ្រូ លោកគ្រូចាប់ផ្តើមសាកល្បង និងជម្នះចិត្តធ្វើមិនកើត។ ចិត្តអាចជម្នះបាន មិនបាន ក្នុងសភាពផ្តាច់ទឹក អាហារ៤៨ម៉ោង ឬលើសពីនេះជាការស្គាល់ខ្លួនឯង។

អ្នកគ្រូ លោកគ្រូកុំទាន់ភ័យ! នេះជាវិធីវេជ្ជសាស្ត្រ គួរប្រតិបត្តិ ដើម្បីបញ្ចៀសជំងឺច្រើនមុខ។ វិធីបង្អត់អាហារដើម្បីព្យាបាលជំងឺ ជាវិធីវេជ្ជសាស្ត្រថ្មីក្នុងសតវត្សរ៍ទី២១ ឈ្មោះថា Autophagy (Hayat, 2014)។ បុគ្គលខ្លះចាត់ទុកការបង្អត់អាហារជាអច្ឆរិយវិធី ក្នុងការព្យាបាលជំងឺ។ ទោះបីមនុស្សជាច្រើននាក់ដឹងថា បង្អត់អាហារ និងទឹកជាវិធីវេជ្ជសាស្ត្រក៏ដោយ ក៏មនុស្សមិនងាយ ឬមិនចង់អនុវត្តដែរ។ ទោះបីជាយ៉ាងណា ប្រសិនបើអ្នកគ្រូ លោកគ្រូ ប្រតិបត្តិបាន អ្នកគ្រូ លោកគ្រូពិតជាបានដឹកនាំខ្លួនឯង និងស្គាល់ខ្លួនឯងយ៉ាងច្បាស់។ ការស្គាល់ខ្លួនឯង គឺអាត្មាវិជ្ជានេះ ផ្តើមចេញពីការឃាត់ចិត្តខ្លួនឯង លើរឿងបង្អត់អាហារដើម្បីសុខភាព ឃាត់សេចក្តីលោភរបស់ចិត្តខ្លួនឯងឱ្យបាន។

លទ្ធផលបានពីការពិសោធខាងលើកនេះ អ្នកគ្រូ លោកគ្រូ នឹងស្គាល់ខ្លួនឯងច្បាស់ គឺទាំងកាយ ចិត្ត និងអារម្មណ៍។ ក្នុងជីវិតប្រចាំថ្ងៃរបស់សិស្ស និងគ្រូបង្រៀន គឺដូចគ្នា។ សិស្ស និងគ្រូបង្រៀនត្រូវយល់ និងប្រតិបត្តិអាត្មាវិជ្ជាជាប្រចាំដើម្បីដឹកនាំខ្លួនឯង និងអ្នកដទៃ ឱ្យបានសុខុមាលភាព។

### ១០.៣.៤ ការសហការក្រុម

ការសហការក្រុម គឺលើកកម្ពស់ពហុគុណនៃគុណផលការងារ ឬបង្កើតភាពជោគជ័យរួម និងប្រយោជន៍រួមរបស់ស្ថាប័ន។ សហការក្រុមទាមទារការដាំបណ្ដុះបំណិន និងទម្លាប់ច្រើនក្នុងថ្នាក់ និងក្រៅថ្នាក់ជាប្រចាំ។ ការសហការក្រុមក្នុងចំណោមមនុស្ស គឺមិនអាចមានមនុស្សយន្ត ឬបញ្ញាសិប្បនិម្មិតជំនួសមនុស្សបានទេ។ ការសហការក្រុម សំដៅបែងចែកភារកិច្ច និងការទទួលខុសត្រូវរបស់សមាជិកឱ្យមានតម្លាភាព គណនេយ្យភាព និងសម្រេចគោលបំណងរួម។ សមាជិកក្រុមត្រូវប្រកាន់គោលការណ៍ចម្បងៗ ដូចជា ៖

- ផ្ដល់ការគាំទ្រដល់សមាជិក
- ស្ដាប់គ្នាទៅវិញទៅមក ក្នុងចំណោមប្រធាន និងសមាជិកក្រុម
- ជួយគ្នាមួយដៃមួយជើង
- ផ្ដល់តម្លៃចំពោះនានាភាពនៃគំនិតនិងទស្សនៈរបស់សមាជិកក្រុម
- មានសមានចិត្តចំពោះសុខ និងទុក្ខនៃសមាជិកក្រុម
- ពិភាក្សាគ្នាជាប្រចាំ ដើម្បីបញ្ជាក់ភាពយល់គ្នាច្បាស់ក្នុងក្រុម
- ផ្ដល់ទំនុកចិត្តឱ្យសមាជិកក្រុម
- បើកលំហឱ្យសមាជិកគ្រប់រូប ទទួលស្គាល់តម្លៃនៃសមិទ្ធផលរួម
- ផ្ដល់សិទ្ធិដល់សមាជិកក្រុម ក្នុងការផ្ដើមគំនិត និងច្នៃប្រឌិត
- បង្កើតប្រព័ន្ធការពារសុវត្ថិភាព និងសន្តិសុខឱ្យសមាជិកក្រុម
- លើកទឹកចិត្តសមាជិកក្រុម មិនបំភ័យ មិនបន្ទោស និងមិនបន្លាច
- អន្ទងព្រលឹងសមាជិកដែលអស់សង្ឃឹម ឱ្យចាប់ផ្ដើមឡើងវិញ
- រក្សាសមិទ្ធផលជារបស់រួមនៃក្រុម

### ១០.៣.៥ គណនេយ្យភាព

គណនេយ្យភាពជាគុណតម្លៃមួយ សម្រាប់ធានាភាពជោគជ័យរួមរបស់ស្ថាប័ន។ និយាយភាសាសាមញ្ញ គណនេយ្យភាពសំដៅដល់ការបង្កើតផលិតផលរួមប្រកបដោយគុណភាព និងដើម្បីប្រយោជន៍រួមរបស់ស្ថាប័ន។ គណនេយ្យភាពសំដៅដល់ការមិនមើលបំណាំគ្នា មិនចង្អុលដាក់គ្នា មិនបន្ទោសគ្នា និងមិន

ទម្លាក់កំហុសឱ្យគ្នា។ គណនេយ្យភាព សំដៅដល់ការជួយគ្នា មួយដៃ មួយជើង ដើម្បីសម្រេចសមិទ្ធផលរួមរបស់ស្ថាប័ន ប្រកបដោយគុណភាព។

ប្រតិបត្តិគុណតម្លៃនៃគណនេយ្យភាព គឺដាំបណ្តុះបំណិន និងទម្លាប់ឱ្យសិស្សក្លាយជាពលរដ្ឋពូកែ។ បំណិន និងទម្លាប់ពលរដ្ឋពូកែ គឺចេះឆ្ងល់ សង្កេត គិត បង្កើតសំណួរ សួរសំណួរ និងធ្វើសកម្មភាព ដើម្បីសមិទ្ធផលរួម។ ការដាំ និងបណ្តុះគុណតម្លៃនៃគណនេយ្យភាព គឺបង្ហាត់សិស្សឱ្យអភិវឌ្ឍកញ្ចប់នៃវិជ្ជា និងគុណតម្លៃមនុស្សច្រើនបែប ច្រើនយ៉ាង ដូចជា៖

- បំពេញភារកិច្ចដោយចិត្តវិជ្ជាមាន ពេញចិត្ត និងសេចក្តីស្មោះត្រង់
- ប្រតិបត្តិគោលការណ៍សមាចារ គឺសីលធម៌នៃកាយ វាចា និងចិត្ត
- ធ្វើការច្រើនប្រភេទ ក្នុងពេលតែមួយ ដោយពេញចិត្ត អស់ពីចិត្ត
- ឱ្យតម្លៃចំពោះពេលវេលា ទោះបីតិចក្តី ច្រើនក្តី វែងក្តី ខ្លីក្តី
- សហការ និងទទួលយកជំនួយពីអ្នកដទៃ ដោយពេញចិត្ត
- ដាំបណ្តុះទម្លាប់ជួយអ្នកដទៃ មិនចាំចាប់កំហុស
- ដាំបណ្តុះបំណិន និងទម្លាប់មិនមើលបំណាំ មិនបន្ទោស
- ប្រើចិត្តវិជ្ជមានទទួលយកនានាភាព ពហុភាព ភាពផ្សេងគ្នា។

### ១០.៤ គុណតម្លៃបុគ្គល

មនុស្សខ្ពង់ខ្ពស់ពោរពេញដោយគុណតម្លៃមនុស្ស គឺរស់នៅ ប្រាស្រ័យមនុស្ស ធ្វើការ និងរៀនសូត្រប្រកបដោយធម៌។ គុណតម្លៃបុគ្គលពុំអាចសាបសូន្យ ក្នុងជាតិនេះ និងជាតិមុខ (Khmer Buddhism Institute , 1931)។ បុគ្គលខ្ពង់ខ្ពស់ ប្រកបដោយធម៌តែងនាំមនុស្សទូទៅឱ្យចម្រុងចម្រើន ព្រោះតែងផ្តល់ទានដល់មនុស្សទូទៅ គឺទានជាទ្រព្យ និងទានជាបញ្ញា។ មនុស្សខ្ពង់ខ្ពស់ពោរពេញដោយគុណតម្លៃ តែងប្រព្រឹត្តសេចក្តីល្អ និងសេចក្តីពិតជាប្រចាំ។ បុគ្គលប្រព្រឹត្តសេចក្តីល្អ សេចក្តីពិត និងការពារសុចរិតភាព គឺពោរពេញដោយសុជីវធម៌ សីលធម៌ និងគុណធម៌។ បុគ្គលពោរពេញដោយសុជីវធម៌ សីលធម៌ និងគុណធម៌ តែងរុងរឿង និងពុំធ្លាក់ក្នុងទលទ្ទិភាព សេចក្តីក្រឡើយ និងរស់ក្នុងសុខុមាភាព (Khmer Buddhism Institute , 1931)។

គុណតម្លៃបុគ្គល ក្នុងបរិបទនេះចែកចេញជា៧ក្រុមខ័ណ្ឌ ៖

- សុជីវធម៌
- សីលធម៌
- គុណធម៌
- ការប្រតិបត្តិសេចក្តីពិត និងសុចរិតភាព
- ភាពទន់ភ្លន់ និងសម្របចិត្ត
- ការផ្តើមគំនិតត្រូវធ្វើ
- នវកម្មគំនិត

### ១០.៤.១ សុជីវធម៌

សុជីវធម៌ជាគុណតម្លៃមួយរបស់បុគ្គលខ្ពង់ខ្ពស់ និងសម្រាប់យកទៅប្រាស្រ័យជាមួយមនុស្សក្នុងការងារ រៀន និងរស់នៅដោយសេចក្តីល្អ និងសេចក្តីពិត (Khmer Buddhism Institute , 1931)។ សុជីវធម៌សំដៅដល់ការប្រព្រឹត្តិប្រចាំថ្ងៃ ដូចជា បរិភោគ និយាយ ដេក ដើរ ឈរ និងអង្គុយ ក្នុងសភាពសមរម្យ ឬសមសួន តាមប្រពៃណី និងទម្លាប់ល្អរបស់សង្គម ច្បាប់ជាតិ និងធម្មជាតិ។ បុគ្គលប្រតិបត្តិសុជីវធម៌ជាប្រចាំតែងយល់ និងប្រមាណអំពីសេចក្តីអាក្រក់និងល្អ ភាពសមរម្យនិងពុំសមរម្យ ក្នុងគ្រប់បរិបទសង្គម ជីវភាពប្រចាំថ្ងៃ ការងារ និងការរៀនសូត្រ។ បុគ្គលខ្ពង់ខ្ពស់ដែលពោរពេញដោយសុជីវធម៌ តែងប្រតិបត្តិល្អ និងសេចក្តីពិតជាមួយមនុស្ស និងធម្មជាតិ ដោយ៖

- ចេះឱនលំទោន និងមានចិត្តធំទូលាយ
- ស្តាប់សម្តីនៃអ្នកផ្សេង ដោយយកចិត្តទុកដាក់ និងស្ងៀមស្ងាត់
- និយាយសម្តី និងឆ្លើយតប ដោយមេត្រីភាព និងក្តីស្រឡាញ់
- បញ្ចេញកិរិយា កាយវិការ ក្នុងក្តីស្រឡាញ់ និងជាទីរាប់អាន
- យល់ពីការលំបាក ទុក្ខ និងសុខនៃមនុស្សកំពុងប្រាស្រ័យជាមួយ
- ប្រមាណអំពីសេចក្តីសមរម្យ ពុំសមរម្យ ភាពប្រសើរ ពុំប្រសើរ នៃការប្រព្រឹត្តិ ទាំងការបរិភោគ ដេក ដើរ ឈរ អង្គុយ និយាយ

### ១០.៤.២ សីលធម៌

សីលធម៌ជាធាតុមិនអាចខ្វះបានសម្រាប់បុគ្គលគ្រប់រូប។ របកគំហើញនៃការស្រាវជ្រាវអំពីការអប់រំ និងគម្ពីរទស្សនវិទ្យាបុរាណស្ទើរទាំងអស់ ដូចជា គម្ពីរ Vedanta, គម្ពីរ Bhagavad Gita (Easwaran, 2020) និង គម្ពីរព្រះត្រៃបិដកនៃព្រះពុទ្ធសាសនាឱ្យតម្លៃខ្ពស់ចំពោះសីលធម៌។ ប្រព័ន្ធអប់រំទាំងអស់បង្កើតមុខវិជ្ជារៀនក្នុងសាលា ហៅថា អប់រំសីលធម៌។ កម្មវិធីសិក្សារបស់កម្ពុជា មានមុខវិជ្ជាមួយគឺ សីលធម៌ ពលរដ្ឋវិជ្ជា។ ការបង្កើតសាលារៀន និងការផ្ដល់មុខងារជាគ្រូបង្រៀន សំដៅបំពាក់សីលធម៌ឱ្យសិស្សដើម្បីយកទៅបម្រើការក្នុងសង្គម។ មាតាបិតាបញ្ជូនកូនទៅសាលារៀន ក៏មានចេតនាឱ្យកូនរៀនចេះដឹង មានវិជ្ជា និងសីលធម៌ដែរ។

គម្ពីរព្រះត្រៃបិដកនៃព្រះពុទ្ធសាសនា (Khmer Buddhism Institute , 1931) ពន្យល់ថា បុគ្គលពោរពេញដោយសីលធម៌តែង ៖

- មានសម្ដីពីរោះ
- និយាយពាក្យពីរោះ
- ពោលពាក្យទន់ភ្លន់ ផ្អែមល្ហែម
- ពោលវាចាចាកទោស ដូចជាពុំនិយាយដើមគេ
- ពុំនិយាយឱ្យអ្នកផងព្រួយចិត្ត
- មានសម្ដីញ៉ាំងអ្នកស្ដាប់ឱ្យចូលចិត្តជាក់លាក់
- មានចិត្តត្រេកអរ ដោយឃើញអ្នកផងបានផល និងសេចក្ដីល្អ
- ពិចារណានិងទទួលស្គាល់ជារឿយៗនូវកម្មជាកុសលនិងអកុសល
- ប្រកាន់ចិត្តគិត ដោយសេចក្ដីបរិសុទ្ធ
- រាល់ការប្រព្រឹត្តិ គឺផុតស្រឡះចាកកម្មអកុសល្យ ឬអំពើបាប
- ប្រកាន់ចិត្តអត់ធ្មត់ និងអហិង្សា
- ពុំតិះដៀលខ្លួនឯង និងអ្នកដទៃ
- ពុំប្រមាថ ពុំជេរប្រទេច ផ្ដាសាដល់ខ្លួនឯង និងអ្នកដទៃ
- ពុំកំណាញ់ (មច្ឆរិយៈ)

- ពុំច្រណែន
- ពុំអួតអាង
- ពុំញុះញង់
- ពុំពោលពាក្យចាក់ដោត
- ពុំពោលពាក្យគ្រោតគ្រោះ
- ពុំបំផ្លាញទ្រព្យ ដោយល្បែង
- ពុំទ្រុស្តមិត្ត និង
- ពុំរមិលគុណ

### ១០.៤.៣ គុណធម៌

គុណធម៌ជាសម្បត្តិនៃបុគ្គលខ្ពង់ខ្ពស់ ព្រោះបុគ្គលនោះរមែងមានរូបល្អ និងអាស្រ័យផលនៃវាចា និងការប្រព្រឹត្តិសុចរិត ដោយអង្គនៃសុជីវធម៌ សីលធម៌ និងបញ្ញា។ បុគ្គលពោរពេញដោយគុណធម៌ រមែងជាបុគ្គលមានបេះដូងជាអ្នកឈឺឆ្អាលទើសនឹងទុច្ចរិត និងជាអ្នកជួយ (Khmer Buddhism Institute , 1931)៖

- ប្រកាន់ចិត្តសន្តោស ស្រឡាញ់ និងសង្គ្រោះ
- បំពេញកិច្ច ដោយអស់ពីចិត្ត
- ខ្មៀតខ្មីនឹងការងារ
- ពុំខ្ជិះខ្ជារគ្រប់កិច្ចការ តូចក្តី ធំក្តី
- ពុំប្រមាទចំពោះរាល់កិច្ចការតូចក្តី ធំក្តី
- ព្យាយាមអស់ពីចិត្តក្នុងគ្រប់កិច្ចការ
- ពុំលះបង់ចោលក្តីសង្ឃឹម
- ពុំមាយា
- ពុំទន់ជ្រាយ
- ពុំចុះចាញ់នឹងការលំបាក
- ពុំគិតពីការលំបាក
- ពុំខ្ជិលច្រអូស
- ពុំទ្រមក់

- ពុំតំអូញតំអែរចំពោះគ្រប់កិច្ចការ
- ពុំបំភ្លេចសេចក្តីល្អនៃអ្នកជួយ
- ពុំលើកតម្កើងខ្លួនឯងដើម្បីបំផ្លាញអ្នកដទៃ
- ពុំបង្អាប់ជនដទៃឱ្យមានសេចក្តីភ័យ

បុគ្គលពោរពេញដោយគុណធម៌ ជាបុគ្គលខ្ពង់ខ្ពស់ និងរមែងប្រតិបត្តិធម៌៥យ៉ាងជាប្រចាំ (Khmer Buddhism Institute , 1931) ប៉ុន្តែសៀវភៅនេះពុំបានលម្អិតអំពីបញ្ញត្តិ និងការប្រតិបត្តិចំពោះ ធម៌៥យ៉ាងដូចខាងក្រោមនេះទេ៖

- សទ្ធា
- សីល
- សុតៈ
- ចាគៈ
- បញ្ញា

### ១០.៤.៤ ការប្រតិបត្តិសេចក្តីពិត និងសុចរិតភាព

បុគ្គលពោរពេញដោយធម៌ តែងប្រតិបត្តិ និងការពារសេចក្តីពិត និងសុចរិតភាព។ ស្នូលរួមនៃមេរៀនក្នុងសាសនា គឺប្រតិបត្តិសេចក្តីពិត និងសុចរិតភាព ព្រោះជាធម៌នៃបុគ្គលខ្ពង់ខ្ពស់។ គម្ពីរព្រះត្រៃបិដកភាសាខ្មែរ នៃវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ (1931) និងគម្ពីរ Bhagavad Gita (Easwaran, 2020) បញ្ជាក់ថា ការប្រតិបត្តិសេចក្តីពិត ឬធម្មជាតិនៃសេចក្តីពិត និងសុចរិតភាពពុំទាញបុគ្គលឱ្យធ្លាក់ក្នុងទលិទ្ទភាព ឬសេចក្តីខ្សត់ទ្រព្យទេ ព្រោះមានព្រះនៃសេចក្តីពិត និងធម៌នៃសេចក្តីល្អតាមជួយ។

សេចក្តីពិត និងសុចរិតភាព នឹងដឹកនាំជីវិតថ្លៃថ្លា ទោះបីបុគ្គលនោះពុំបានរៀនចប់សាលាក៏ដោយ។ ការប្រតិបត្តិសេចក្តីពិត និងសុចរិតភាពត្រូវចាប់ផ្តើមពីការស្គាល់តម្លៃនៃជីវិត និងការរស់ជាមួយមនុស្ស ធម្មជាតិ និងមរតកប្រវត្តិសាស្ត្រដោយចិត្តមេត្តា សង្គ្រោះ ស្រឡាញ់ និងមេត្រីភាព។

សូមអ្នកគ្រូ លោកគ្រូ សាកល្បងគិត៥៩វិនាទី លើបញ្ហាសាមញ្ញមួយ! សម្គាល់មនុស្សមួយនាក់ ពីរ បីនាក់ឧស្សាហ៍និយាយដើមគេ។ ការនិយាយដើម

បុគ្គលដទៃជាការសន្មតិ និងការរំលង សេចក្តីពិត និងសុចរិតភាព។ ក្រោយពី បានសង្កេត មួយរយៈពេល យ៉ាងយូរ មួយខែ អ្នកគ្រូ លោកគ្រូ អាចព្យាយាម រកសេចក្តីពិតមួយ មកពន្យល់សេចក្តី ពិត ត្រឹមត្រូវ និងច្បាស់លាស់ នៃ ចម្លើយចំពោះសំណួរមួយ ៖ *តើបុគ្គល និយាយដើមអ្នកដទៃ មានការទុកចិត្តពី មនុស្សជុំវិញខ្លួន និងអ្នកជិតស្និទ្ធឬទេ?*

ចូរអ្នកគ្រូ លោកគ្រូ សង្កេត មនុស្សមានទម្លាប់និយាយដើមគេ ច្រើនឆ្នាំ! តើសុខភាពរបស់មនុស្សនោះ ប្រឈមនឹងជំងឺអ្វីខ្លះ ពេលមនុស្សនោះ ដល់វ័យពាក់កណ្តាលអាយុ? ខ្វះការ

- រក្សាការគិតសុចរិត ព្រោះការគិតសុចរិត នាំឱ្យបញ្ចេញវាចាសុចរិត។
- រក្សាវាចាសុចរិត ព្រោះវាចាសុចរិតបង្កើត បានជាចរិយាសុចរិត
- រក្សាចរិយាសុចរិត ព្រោះចរិយាសុចរិត បង្កើតបានជាទម្លាប់សុចរិត
- រក្សាទម្លាប់សុចរិត ព្រោះទម្លាប់សុចរិត បង្កើតបានជាគុណតម្លៃមនុស្សពូកែ
- រក្សាគុណតម្លៃមនុស្សពូកែ ព្រោះគុណតម្លៃ មនុស្សពូកែ ជាព្រះកំណត់ចរិត និងវាសនា។

ដូច្នេះ បុគ្គលបរិសុទ្ធចិត្ត វាចា និងការប្រព្រឹត្តិពុំ ដែលធ្លាក់ក្នុងអន្លង់នៃសេចក្តីលំបាកទេ។

ប្រភព ៖ (wisdom library, 2008)

និយាយដើមគេ បញ្ចោក់ពី សេចក្តីស្អប់ ច្រណែន ឈ្នានីស ដែលជាហេតុនៃ ទុក្ខ និងជំងឺប្រចាំកាយ។

ប្រតិបត្តិសេចក្តីពិត និងសុចរិភាព គឺមិនត្រឹមបាត់ទំនុក ចិត្ត ប៉ុន្តែក៏នាំមនុស្សនិយាយដើមគេឱ្យធ្លាក់ក្នុងទុក្ខ ច្រើនយ៉ាង និងច្រើនជំពូកដែរ។ ទំនុកចិត្ត និងសុខភាព ជាទុន និងឫសកែវ ធានាចម្រុងចម្រើន នៃការងារ និង ជីវភាព។ ទំនុកចិត្ត និងសុខភាពបង្កើតសួនជីវិត នៃ សុខុមាលភាព (Khmer Buddhism Institute , 1931) ។

ឧបមាមួយទៀត អ្នកគ្រូ លោកគ្រូ ភ្ញាក់ពីដំណេក ម៉ោង៥.០០ព្រឹក ហើយ ក្រោកភ្លាមមិនបង្អង់ និងមិនស្រឡាញ់ខ្នើយឱបពេក។ ចូរអ្នកគ្រូ លោកគ្រូ កំណត់ សកម្មភាពមួយ ក្នុងខួរក្បាល។ សូត្រសកម្មភាពនោះក្នុងខួរក្បាលឱ្យចាំរត់មាត់ថា ***ដល់បន្ទប់ថ្នាក់រៀន ហៅសិស្សបីនាក់ឱ្យឡើងចែករំលែកការពិតមួយនាក់ មួយ រឿងៗ*** (ដោយស្ម័គ្រចិត្ត) ការពិតនោះ គឺនិយាយអំពីកំហុសដែលខ្លួនបានប្រព្រឹត្ត ចំពោះបងប្អូនបង្កើត ម្តាយឪពុក មនុស្សជិតដិត បើទោះបីរឿងនោះតូចក្តី ធំក្តី

តិចក្តី ច្រើនក្តី ក្នុងថ្ងៃម្សិលមិញ ព្រឹកមិញ ឬសប្តាហ៍មុន។ ចូរលោកគ្រូ អ្នកគ្រូ កត់ត្រាកំហុសដែលសិស្សបាននិយាយ។ ការទទួលស្គាល់សេចក្តីពិត នៃកំហុសជាជំហានដំបូងនៃប្តូរការគិត វាចា និងការប្រព្រឹត្តិ។ ការផ្លាស់ប្តូរការគិត វាចា និងការប្រព្រឹត្តិជាលំនាំនៃចិត្ត បើកទ្វារចំហ និងបង្ហាញផ្លូវឱ្យមនុស្សបោះជំហានទៅរកជោគជ័យ គឺបរិបូរណ៍ដោយទ្រព្យ និងសុខុមាលភាព។

### ១០.៤.៥ ភាពទន់ភ្លន់ និងសម្របចិត្ត

ចិត្តទន់ភ្លន់ និងការសម្របចិត្តជាគុណតម្លៃមួយរបស់ពលរដ្ឋពូកែ។ ការរស់នៅ ធ្វើការ និងរៀនបន្ត ក្នុងសង្គមប្រកបដោយជវភាព។ គ្រូបង្រៀន និងសិស្សរៀនចប់ពីសាលារៀន ត្រូវការគុណតម្លៃនៃភាពទន់ភ្លន់ និងសម្របចិត្ត យកទៅប្រតិបត្តិជាប្រចាំ ជាពិសេសក្នុងយុគឧស្សាហកម្ម៤.0 និងបញ្ញាសិប្បនិម្មិត។

ការផ្លាស់ប្តូរ ឬប្រែប្រួលកើតឡើងគ្រប់ពេលបើកភ្នែក បិទភ្នែក និងគ្រប់ដង្ហើមចេញចូល។ គ្រប់ដំណើរលើផែនដី និងជីវិតមនុស្ស មានបម្រែបម្រួលច្រើនប្រភេទ និងពហុទម្រង់។ បម្រែបម្រួលមានទាំងមើលឃើញ និងមើលមិនឃើញ និងធ្វើចំណោលត្រូវ និងមិនត្រូវ។ សូម្បីតែចិត្តរបស់ខ្លួនឯង ក៏ផ្លាស់ប្តូរដោយម្ចាស់របស់ចិត្តតាមមិនទាន់ដែរ។

បុគ្គលមានគុណតម្លៃ នៃភាពទន់ភ្លន់ និងសម្របចិត្ត តែងមានចិត្តទូលាយ និងឱ្យតម្លៃចំពោះសេចក្តីពិត។ ដូច្នេះ ដំណើរការរៀន និងបង្រៀនក្នុងថ្នាក់ត្រូវដាំបណ្តុះគុណតម្លៃ នៃចិត្តទន់ភ្លន់ និងសម្របចិត្តដើម្បីធានាឱ្យសិស្សយកទៅប្រើក្នុងការងារ និងរៀនបន្ត ឱ្យទាន់ជវភាពនៃសង្គម សេដ្ឋកិច្ច ពាណិជ្ជកម្ម នយោបាយ សុខាភិបាល ប្រជាសាស្ត្រ រដ្ឋបាល វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

សូមលោកគ្រូ អ្នកគ្រូ សាកល្បងគិតត្រឡប់ក្រោយ១៥ឬ២០ឆ្នាំមុន!

ដើម្បីអញ្ជើញបងប្អូនចូលរួមមង្គលការកូន ឬបងប្អូន និងត្រូវជូនធៀបការឆ្លងខេត្ត មនុស្សត្រូវធ្វើដំណើរដោយលំបាក។ បច្ចុប្បន្ន ការអញ្ជើញ និងជូនធៀបការ ចាំបាច់ត្រូវឱ្យបងប្អូន ធ្វើដំណើរឆ្លងខេត្ត ឬស្រុក យកធៀបការមកជូនដល់ផ្ទះឬទេ។ បងប្អូនគ្រាន់តែទូរស័ព្ទប្រាប់ និងផ្ញើសាររូបភាពនៃធៀបការតាមសារហ្វេសប៊ុក ឬប្រព័ន្ធបណ្តាញសង្គម? តើអ្នកគ្រូ លោកគ្រូអាចសម្របចិត្ត និង

ទទួលយកបានឬទេ? តើអ្នកគ្រូ លោកគ្រូត្រូវប្រកាន់ចិត្ត ឬមិនសម្របចិត្តទទួលយកទេ? តើលោកគ្រូ អ្នកគ្រូត្រូវផ្ញើចំណងដៃតាមហ្វេសប៊ុកវិញឬក៏ផ្ញើតាមប្រព័ន្ធវេវលុយ? តើលោកគ្រូ អ្នកគ្រូត្រូវផ្ដាច់ការរាប់អាន?

សាកល្បងគិតត្រឡប់ក្រោយ១០ឬ១៥ឆ្នាំមុន។ ការចែកលិខិតអញ្ជើញប្រជុំតាមស្ថាប័នត្រូវមានអ្នករត់សំបុត្រ។ បច្ចុប្បន្ន ស្ថាប័នរាជការ សាលារៀន អង្គការសង្គមស៊ីវិល និងឯកជនកំពុងប្រើទម្រង់នៃបច្ចេកវិទ្យាព័ត៌មាន ដូចជា Email, Line, Telegram, WhatsApp, WeChat ។ល។ ដើម្បីអញ្ជើញ និងចាត់ចែងការប្រជុំ រៀនបន្ត ឬសិក្ខាសាលាកម្រិតស្ថាប័ន ជាតិ តំបន់ និងអន្តរជាតិ។ ក្នុងសម័យកូវីដ-១៩ ការប្រជុំ ការងារ និងការរៀន ត្រូវប្រើប្រព័ន្ធបណ្ដាញសង្គម ដូចជា ZOOM, Google Meet ឬMicrosoft Team ។ល។

ក្នុងយុគឧស្សាហកម្ម៤.០ តើគ្រូបង្រៀនត្រូវប្រកាន់ចិត្តថា មេរៀនត្រូវតែយកតាមសៀវភៅសិក្សាគោល របស់ក្រសួងអប់រំ យុវជន និងកីឡា ឬយ៉ាងណា? តើសិស្សអាចយកឯកសារមេរៀនពីអន្តរបណ្ដាញអ៊ិនធឺណែតដូចជា YouTube, Google បានដែរឬទេ? តើគ្រូបង្រៀនត្រូវប្រកាន់ចិត្តថា ការរៀនបន្តត្រូវជួបមុខគ្រូបង្រៀន ឬយ៉ាងណា? តើការរៀន តាមបណ្ដាញអ៊ិនធឺណែត ឬរៀនតាមទូរនិម្មិតថ្នាក់រៀន រៀនមិនចេះ រៀនមិនចាំ រៀនមិនយល់មែនឬទេ? យកជាការមិនបានមែនឬទេ? ការអនុវត្តការបង្រៀនសិស្ស ដោយប្រើបណ្ដាញអ៊ិនធឺណែត ក្នុងសម័យកូវីដ-១៩ ជាបទពិសោធគួរពិចារណា សម្រាប់ការរៀនបន្តទៅអនាគត។

ភាពទន់ភ្លន់ និងសម្របចិត្តជាគុណសម្បទាមួយដែលមនុស្សគ្រប់រូប ត្រូវប្រើចាំបាច់ គ្រប់កាល លក្ខខណ្ឌ និងបរិបទ។ ការគ្រប់គ្រងវត្តមានសិស្ស ដាក់ពិន្ទុសិស្ស គ្រប់គ្រងទម្លាប់រៀនរបស់សិស្ស និងដាក់កិច្ចការឱ្យសិស្ស។ តើគ្រូបង្រៀនត្រូវប្រើវិជ្ជាឌីជីថលឬទេ? តើគ្រូបង្រៀនត្រូវប្រើទូរស័ព្ទដើម្បីគ្រប់គ្រងវត្តមានសិស្សឬទេ? តើគ្រូបង្រៀនត្រូវប្រើប្រព័ន្ធឌីជីថល ដើម្បីផ្ដល់កិច្ចការឱ្យសិស្សរៀនបានឬទេ? តើគ្រូបង្រៀននៅប្រកាន់ចិត្តថា ត្រូវមានសៀវភៅតាមដាន និងបោះពុម្ពជាទម្រង់សៀវភៅបានងាយស្រួលប្រើ ឬយ៉ាងណា? តើគ្រូបង្រៀនត្រូវប្រើ Google Blog ឬ Google Form ឬទម្រង់ផ្សេងឬទេ?

ដូច្នេះ ភាពទន់ភ្លន់ និងសម្របចិត្ត សំដៅដល់ការដាំបណ្ដុះទម្លាប់សម្របចិត្តទទួលយកការទទួលខុសត្រូវ និងភារកិច្ចថ្មីជាប្រចាំ។ ក្នុងភាសាសាមញ្ញ ភាពទន់ភ្លន់ និងសម្របចិត្ត គឺបើកចិត្តឱ្យទូលាយ និងប្រកាន់ចិត្តវិជ្ជមាន។ តើគ្រូបង្រៀនត្រូវប្រកាន់ចិត្តមាំទាំថា មិនអាចរៀនពីសិស្សបានទេ? រៀនពីសិស្ស ខ្មាសសិស្ស? សម្របចិត្តសំខាន់ផងដែរ គឺទទួលយកការរៀនបន្ថែមពីសិស្ស និងការទិតៀនពីសហការី សហគមន៍ មាតាបិតា ដោយចិត្តវិជ្ជមាន និងពេញចិត្ត។ ភាពទន់ភ្លន់ និងសម្របចិត្ត គឺទទួលយកនានាភាព ពហុភាព ភាពរួម ភាពដោយឡែក និងភាពផ្ទុយគ្នានៃទស្សនៈ និងជំនឿ ដើម្បីឈានដល់ចំណុចរួមនៃដំណោះស្រាយបញ្ហា បន្ធូរសភាពតានតឹង និងសម្រួលស្ថានការណ៍។

ភាពទន់ភ្លន់ និងសម្របចិត្តរបស់គ្រូបង្រៀន គឺ ផ្ដល់ប្រយោជន៍ដល់សិស្សយ៉ាងសម្បូរបែប។ ភាពទន់ភ្លន់ និងសម្របចិត្ត គឺអន្ទងព្រលឹងសិស្ស ឱ្យជាប់អារម្មណ៍នឹងការរៀន និងធ្វើកិច្ចការ ដោយពេញចិត្ត និងក្ដីសង្ឃឹម។ ភាពទន់ភ្លន់ និងសម្របចិត្ត របស់គ្រូបង្រៀន គឺផ្ដល់សេរីភាព និងឱកាសឱ្យសិស្សហ៊ានឡើងបញ្ចេញគំនិតថ្មីៗ ចម្លែក និងចែករំលែកជាមួយមិត្តរួមថ្នាក់។ ភាពទន់ភ្លន់ និងសម្របចិត្ត ជួយសិស្សឱ្យដឹកនាំគំនិតខ្លួនឯងទៅរកសកម្មភាព ជាប្រយោជន៍ដល់មនុស្សជាតិ។ សិស្សនឹងមានសេរីភាព និងឯករាជ្យ ក្នុងការបញ្ចេញគំនិតថ្មីៗ។

ភាពទន់ភ្លន់ និងសម្របចិត្តសំដៅបណ្ដុះគន្លងចិត្តឱ្យបើកទូលាយ និងចិត្តវិជ្ជមាន។ កន្លែងធ្វើការទាំងអស់តែងផ្ដល់ភារកិច្ចថ្មី និងពោរពេញដោយគំនិតថ្មី។ ដូច្នេះ សិស្សត្រូវរៀនបើកចិត្តឱ្យទូលាយទទួលយកគំនិតថ្មី និងភារកិច្ចថ្មីប្រកបដោយចិត្តវិជ្ជមាន និងក្ដីសង្ឃឹម។

### ១០.៤.៦ ការផ្ដើមគំនិតត្រូវធ្វើ

ហេតុនៃបរាជ័យធំក្នុងជីវិតរបស់មនុស្សជាទូទៅ គឺ ១. ចាប់ផ្ដើមធ្វើដោយពុំបានគិត ២. គិតជាហូរហែ មិនចាប់ផ្ដើមធ្វើ។ សម្ដីទូន្មានចាស់បុរាណពោលថា *“ចង់បានផលកុំត្រឹមគិត ត្រូវចាប់ផ្ដើមធ្វើកុំបង្អង់”*។

ប្រសិនបើគិតអំពីរយៈវេលានៃជីវិត ដោយដកម៉ោងដេក ម៉ោងសម្រាក និងម៉ោងធ្វើរឿងមិនបម្រើប្រយោជន៍មនុស្សគឺខ្លីណាស់។ ប្រសិនបើវិនិយោគ

ជីវិតលើតែការរស់ជីវិត និងសុវត្ថិភាពបុគ្គល តើមានអ្វីខុសពីដង្កូវ និងជន្លេន? តើមនុស្សអាចអន់ជាងសត្វគោក្របីស្រែឬទេ ប្រសិនបើការរស់នៅលើផែនដី ត្រឹមស្វែងរកសុវត្ថិភាព និងអាហារ? សូមលោកគ្រូ អ្នកគ្រូសាកល្បងគិត ៥៩វិនាទីមើល! តើខ្ញុំអន់ជាងក្របីឬទេ ប្រសិនបើខ្ញុំខ្វល់តែពីក្រពះ ដើម្បីតែរស់ មិនខ្វល់ពីមនុស្សជុំវិញខ្លួន និងមិនខ្វល់ពីផែនដី?

សំណួរមួយក្នុងបណ្តាញសង្គម Facebook ត្រូវបានចែករំលែកយ៉ាងពេញនិយម។ តើអ្នកមានអាយុ១០ឆ្នាំប៉ុន្មានដង? និយាយភាសាសាមញ្ញ ជីវិតអាចខ្លី និងវែង ប្រសិនបើយើងបានធ្វើអ្វីច្រើនយ៉ាងដើម្បីមនុស្សជំនាន់ក្រោយ ផែនដីចក្រវាល ដូចជា សរសេរសៀវភៅឱ្យក្មេងជំនាន់ក្រោយរៀនបន្ត ឬធ្វើអ្វីម្យ៉ាងជាប្រយោជន៍ដល់មនុស្សជាតិ។

សូមលោកគ្រូ អ្នកគ្រូ សាកល្បងរំឭកបទពិសោធខ្លួនឯង កាលរៀននៅសាលាបឋមសិក្សា ឬមធ្យមសិក្សា! តើអ្នកគ្រូ លោកគ្រូ ចង់បង្ហាញសមត្ថភាពខ្លួនឯងថា ចេះធ្វើនេះ ធ្វើនោះ និងចង់បង្ហាញកិច្ចការអ្វីមួយដែរឬទេ? ប្រសិនបើអ្នកគ្រូ លោកគ្រូនឹករកបទពិសោធខ្លួនឯង មិនបាន សូមសង្កេតសកម្មភាពក្មេងក្នុងសាលារៀន គ្រួសារ ឬក្នុងភូមិ។

គ្រូបង្រៀនពិតជាជួបសិស្សច្រើនប្រភេទក្នុងថ្នាក់រៀន។ សិស្សខ្លះនិយាយតិច មិនធ្វើ។ សិស្សខ្លះនិយាយច្រើនពេក និងមិនធ្វើ។ សិស្សខ្លះធ្វើ មិននិយាយ។ សិស្សខ្លះចង់រៀន។ សិស្សខ្លះមិនចង់រៀន។ តើពិតមែនឬទេ? អ្នកគ្រូលោកគ្រូសម្គាល់មើល! សិស្សភាគច្រើនចង់សម្តែងសមត្ថភាពរបស់ខ្លួនណាស់។ គ្រូបង្រៀនត្រូវប្រតិបត្តិគុណតម្លៃនៃការផ្តើមគំនិតត្រូវធ្វើ ដើម្បីដឹកនាំសិស្សឱ្យរៀនពិតប្រាកដ។

គុណតម្លៃនៃការផ្តើមគំនិតត្រូវធ្វើ គឺអន្ទងព្រលឹងសិស្សឱ្យផ្តល់តម្លៃចំពោះការរៀន និងតម្លៃចំពោះជីវិតខ្លួនឯង និងអ្នកដទៃ។ គុណតម្លៃនេះ អន្ទងព្រលឹងសិស្ស ឬដាស់ចិត្តសិស្សឱ្យសកម្មក្នុងការផ្តើមគំនិត និងអនុវត្តគំនិតរបស់ខ្លួនឯង។ ឧទាហរណ៍ លេងភ្លេង រាំ និងសំដែងកាយវិការ សិល្បៈ កីឡា ល្ខោនអនុញ្ញាតឱ្យសិស្សចុះសហគមន៍ និងធ្វើការជាមួយប្រជាជន ចូលរួមសកម្មភាព

មនុស្សធម៌ គឺផ្តល់ឱកាសឱ្យសិស្សផ្តើមគំនិត និងប្រតិបត្តិគំនិតរបស់ខ្លួន។ សិស្សអាចផ្តើមគំនិត និងប្រតិបត្តិគំនិតរបស់ខ្លួន គឺសិស្សពង្រីកតម្លៃនៃគំនិតដំបូង និងបណ្តុះបំណិន និងទម្លាប់ជាច្រើនសម្បូរបែប ដូចជា ៖

- គ្រប់គ្រង និងប្រើពេលវេលាឱ្យមានប្រយោជន៍
- បង្កើតគោលដៅការងារច្បាស់លាស់
- មានទម្លាប់ធ្វើការដោយឯករាជ្យ
- បណ្តុះចិត្តឱ្យចេះគ្រប់គ្រង និងវាយតម្លៃលទ្ធផលការងារ
- រៀនចំណេះដឹង វិជ្ជាលើសពីសៀវភៅសិក្សា និងពីអ្វីដែលគ្រូប្រាប់
- ពិសោធគំនិតខ្លួនឯងក្នុងជីវភាពប្រចាំថ្ងៃ
- ដាំបណ្តុះទម្លាប់តាំងចិត្តបញ្ចប់ការងារដោយឯករាជ្យ
- ប្រៀបធៀបបញ្ញត្តិរៀនពីសាលា ជាមួយបទពិសោធជីវិត
- ដាំបណ្តុះចិត្តមេត្តា ស្មោះត្រង់ និងជួយអ្នកដទៃ។

### ១០.៤.៧ នវកម្មគំនិត

នវកម្មគំនិតកើតចេញពីការឆ្ងល់ គិត បង្កើតសំណួរ សួរ រកការពន្យល់។ ការឆ្ងល់ គិត បង្កើតសំណួរ និងសួរសំណួរជាចំណុចចាប់ផ្តើមនៃការផ្លាស់ប្តូរ និងបើកផ្លូវគិតទៅរកការបង្កើតថ្មី។ នវកម្មគំនិតបើកផ្លូវនៃការគិត និងពង្រីកវិសាលភាព នៃគំនិតទៅរកបដិវត្តន៍ឧស្សាហកម្មថ្មីៗបន្តទៀត។

នវកម្មគំនិតពុំមែនជាការគិត និងឆ្ងល់ ដោយខ្វះទិន្នន័យ ឬប្រើទិន្នន័យចាស់ទេ។ ការប្រើទិន្នន័យចាស់ និងមិនគ្រប់គ្រាន់ ដើម្បីសន្និដ្ឋានជាការនាំទុក្ខដាក់ខ្លួន និងពុំមែនជានវកម្មគំនិតទេ។ ការសន្មតិអាចនាំមនុស្សឱ្យគិតខុស សម្រេចចិត្តខុស និងប្រាសចាកសេចក្តីពិត និងខាតប្រយោជន៍យូរអង្វែង។

ក្នុងទសវត្សរ៍ ឆ្នាំ១៩៨០ ក្រុមហ៊ុនកុំព្យូទ័រម៉ាក INTEL ប្រឈមនឹងបញ្ហា នៃការប្រកួតពុំឈ្នះក្រុមហ៊ុនកុំព្យូទ័រផ្សេង និងឈានទៅរកក្ស័យធន។ នាយកប្រតិបត្តិក្រុមហ៊ុន INTEL ក្នុងទសវត្សរ៍ឆ្នាំ១៩៨០ Andrew Grove បានផ្តើមគំនិតថ្មីមួយ។ គំនិតថ្មីនោះកើតចេញពីការគិតរកគំនិតច្រើនសម្បូរបែបពីច្រើនជ្រុងនៃទិន្នន័យសម្បូរបែប។ លទ្ធផលនៃការបង្កើតគំនិតថ្មីបានធានាឱ្យក្រុមហ៊ុន INTEL

កែប្រែប្រព័ន្ធល្បឿននៃកុំព្យូទ័រ។ ក្រុមហ៊ុនបានផលិតវត្ថុជួយឱ្យប្រព័ន្ធកុំព្យូទ័រដំណើរការលឿន គឺផលិតផល PENTIUM CHIPS ។ ផលិតផលថ្មីនេះធានាឱ្យក្រុមហ៊ុន INTEL បន្តនិរន្តរភាពរហូតដល់បច្ចុប្បន្ន និងឈរជើងជាក្រុមហ៊ុនជោគជ័យមួយ ក្នុងវិស័យកុំព្យូទ័រ។ រហូតមកដល់វេលានេះ ក្រុមហ៊ុនកុំព្យូទ័រផ្សេង ត្រូវប្រើផលិតផល PENTIUM CHIPS ជាជំនួយល្បឿននៃកុំព្យូទ័រ។

រូបភាព០៣. រូបថត Andrew Grove ក្នុងទសវត្សរ៍ឆ្នាំ១៩៩០




ប្រភព៖ ( Burt, 2016)

ការចែករំលែក និងទទួលយកគំនិតថ្មី ឬនវកម្មគំនិតជាការពិបាក ប៉ុន្តែអាចធ្វើបាន។ ការបង្រៀនសិស្សឱ្យបង្កើត បញ្ចេញគំនិតថ្មី ផ្តើមគំនិតថ្មី ផ្លាស់ប្តូរគំនិតចាស់ទៅរកគំនិតថ្មី ទទួលស្គាល់ ចែករំលែកគំនិតថ្មី ជាការរៀនពិតប្រាកដ ឬរៀនកើតជាវិជ្ជា និងបញ្ញា។

ការដាំបណ្តុះសុទ្ធាចំពោះខ្លួនឯងជាយាននាំមនុស្សឱ្យជោគជ័យ ក្នុងការបង្កើតគំនិតថ្មី និងលុបចោលគំនិតចាស់។ ការដាំបណ្តុះសុទ្ធាចំពោះគំនិតខ្លួនឯងជាការបង្កើតភាពទុកចិត្តលើខ្លួនឯង។ គ្រូបង្រៀនគួរផ្តល់ឱកាសឱ្យសិស្សឡើងបញ្ចេញគំនិត តាមរយៈការនិយាយ សរសេរ គូររូប ឬសួរសំណួរ។ល។ គ្រូបង្រៀន និងសិស្សរួមថ្នាក់ត្រូវប្រកាន់អាកប្បកិរិយា អត់ធ្មត់ក្នុងការស្តាប់ឱ្យចប់ចុងចប់ដើម និងស្វែងការពន្យល់បន្ថែម ចំពោះគំនិតពុំទាន់ច្បាស់លាស់។

ការដាំបណ្តុះសទ្ធាចំពោះខ្លួនឯង ក៏ជួយសិស្សរៀនយឺត និងមានតម្រូវការពិសេសឱ្យមានវុឌ្ឍិវិជ្ជា និងវុឌ្ឍិចរិយាដែរ។ ការស្រាវជ្រាវជាច្រើនពន្យល់ថាសិស្សរៀនពូកែ ឬរៀនលឿនជាទូទៅពិបាកទទួលយក ឬរង់ចាំគំនិតសិស្សរៀនយឺត ឬសិស្សរៀនខ្សោយ។ បញ្ហាប្រឈមមួយនៅត្រង់ថា គ្រូបង្រៀន និងសិស្សរៀនពូកែ ឬរៀនលឿន ច្រើនសន្មតថា សិស្សរៀនខ្សោយ រៀនយឺត ឬសិស្សមានតម្រូវការពិសេស ពុំសូវមានគំនិតថ្មី ឬពិបាកបញ្ចេញ និងពុំសូវចែករំលែកគំនិត

ថ្មីៗ។ សិស្ស និងគ្រូបង្រៀនច្រើនខ្វះការអត់ធ្មត់ ស្វែងការពន្យល់បន្ថែម ស្តាប់ឱ្យចប់សេចក្តី និងអានឱ្យចប់អត្ថបទសំណេរ។

គំនិតចម្លែក ឬគំនិតមួយខុសពីមនុស្សដទៃ របស់សិស្សរៀនខ្សោយ ឬរៀនយឺត ឬសិស្សមានតម្រូវការពិសេសក៏អាចបង្កើតលំនាំនៃការគិត និងពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែប សម្រាប់សិស្សក្នុងថ្នាក់ទាំងមូលបានដែរ។ ដូច្នេះ ការបញ្ចេញគំនិតប្លែក ឬគំនិតផ្ទុយពីមនុស្សដទៃ អាចជាការចាប់ផ្តើមបង្កើតលំហនៃការឆ្លុះ គិត និងបើកផ្លូវគិតទៅរកគំនិតថ្មីសម្រាប់ពន្យល់ភាពពិតច្បាស់លាស់ និងត្រឹមត្រូវ តាមកាល លក្ខខណ្ឌ និងបរិបទ។

ការអនុញ្ញាតឱ្យសិស្សឡើងនិយាយ ធ្វើកាយវិការ គូរគំនូរ ឬសរសេរគំនិតប្លែក ឬគំនិតខុសពីការគិតរបស់គ្រូបង្រៀន ឬរបស់សិស្សផ្សេងទៀត ជាការចាប់ផ្តើមនូវនវកម្មគំនិត និងការរៀនពិតប្រាកដ។ ការសរសេរ ការនិយាយ គូរគំនូរ បង្ហាញកាយវិការ អំពីគំនិតថ្មីមួយផុសចេញពីការគិតដំបូង ឬសួរសំណួរផុសចេញពីការឆ្លុះដំបូង អាចមិនទាន់គ្រប់គ្រាន់ ឬពុំល្អ។ ប្រសិនបើមានគ្រូបង្រៀនចិត្តទូលាយ និងមានសិស្សផ្សេងជួយលើកទឹកចិត្ត និងជួយដឹកនាំ សិស្សអាចគិត ឆ្លុះ និងបង្កើតសំណួរចំពោះគំនិតថ្មីផុសចេញដំបូង។ ការលើកទឹកចិត្តបែបនេះជំរុញសិស្សឱ្យគិតរកគំនិតថ្មីៗ ហើយគំនិតថ្មីនឹងផុសចេញជាបន្តបន្ទាប់ទៀត។ ដូច្នេះ ដំណើរការរៀនពិតប្រាកដនឹងកើតឡើងចំពោះសិស្សចូលអង្គុយរៀនក្នុងថ្នាក់។

ឧទាហរណ៍ សិស្សស្រីមួយនាក់ប្រាប់សំណូមពរមួយដល់គ្រូបង្រៀន។ សិស្សនោះសុំឱ្យគ្រូបង្រៀនដឹកនាំការរៀន ដោយអង្គុយរៀនមេរៀនអំពីបុរេប្រវត្តិសាស្ត្រខ្មែរ ក្រោមដើមឈើនៅក្រៅសាលារៀន។ តើគ្រូបង្រៀនចាប់ផ្តើមគិតអំពីគំនិតនេះ ឬ ត្រូវបដិសេធ ឬសើចចំអក? ដោយសារជ្រុងនៃការគិតខុសគ្នា គ្រូបង្រៀន និងសិស្សផ្សេង អាចផ្តល់ហេតុផលផ្សេង ដោយមិនអនុញ្ញាតឱ្យមានសកម្មភាពក្រៅថ្នាក់តាមសំណើនេះ។

ឥឡូវ លោកគ្រូ អ្នកគ្រូបើកចិត្តឱ្យទូលាយ និងសាកល្បងឱ្យសិស្សពិភាក្សាគ្នាអំពីលំនាំនៃការរៀបចំដំណើរការរៀនក្រៅសាលារៀន។ លោកគ្រូ អ្នកគ្រូអនុញ្ញាតឱ្យសិស្សសរសេរលម្អិតតាមសមត្ថភាពគិតរបស់សិស្ស។ អ្នកគ្រូ លោក

គ្រូ គ្រាន់តែសង្កេតដំណើរការពិភាក្សា និងរង់ចាំលទ្ធផលរបស់សិស្សជជែកគ្នា។ តើលទ្ធផលនឹងបានមកជាអ្វី និងបានលទ្ធផលមក ដោយរបៀបណា? តើផលបានពីការពិភាក្សាអាចយកទៅអនុវត្តតាមសំណើបានដែរឬទេ?

បញ្ហាត្រង់ថា លោកគ្រូ អ្នកគ្រូ អាចមានបទពិសោធជាមួយសិស្សដែលមិនសូវសកម្ម។ ការបណ្តោយឱ្យសិស្សជជែកគ្នា គឺពុំដែល ឬពុំសូវទទួលបានលទ្ធផល។ ដូច្នេះ លោកគ្រូ អ្នកគ្រូ អាចបដិសេធសំណើរបស់សិស្សដើម្បីរៀនក្រៅសាលារៀន។ មុនអ្នកគ្រូ លោកគ្រូ បដិសេធ សូមលោកគ្រូ អ្នកគ្រូ គិត៥៩វិនាទី! ក្នុងមួយឆ្នាំសិក្សាមុន ឬមួយខែមុន ឬមួយត្រីមាសមុន តើខ្ញុំបានប្រតិបត្តិទម្លាប់នេះញឹកញាប់ប៉ុនណា? តើសិស្សខ្ញុំមានទម្លាប់ និងមានសេរីភាពក្នុងការរៀនបែបនេះច្រើនប៉ុនណា?

មនុស្សពូកែច្រើននាក់ដែលមាននវកម្មគំនិត និងចែករំលែកឧត្តមានុវត្តន៍អំពីនវកម្មគំនិតសម្រាប់បម្រើប្រយោជន៍មនុស្ស។ មនុស្សពូកែខាងនវកម្មគំនិតមានបំណិនគិតកម្រិតខ្ពស់ និងប្រតិបត្តិការ ច្រើនបែបច្រើនយ៉ាង ដូចជា ៖

- គិតបែបវិភាគ
- គិតបែបយុទ្ធសាស្ត្រ
- គិតបែបច្នៃប្រឌិត
- គិតតាមប្រព័ន្ធ
- គិតបែបវែកញែក
- គិតលើការគិត

ផ្នែកនេះសំយោគគន្លងនៃការគិតរបស់មនុស្សល្បីៗ ដើម្បីបង្កើតគន្លងនៃនវកម្មគំនិត សម្រាប់ឱ្យមនុស្សជំនាន់ក្រោយៗប្រតិបត្តិ។ ដើម្បីដាំបណ្តុះបំណិន និងទម្លាប់បង្កើតនវកម្មគំនិត មនុស្សត្រូវចាប់ផ្តើមពីការគិត និងអនុវត្តទម្លាប់ និងបំណិនចម្បងៗមួយចំនួន ៖

➢ ការដាំបណ្តុះក្តីស្រឡាញ់

ស្រឡាញ់ ជាការចាប់ផ្តើមអ្វីគ្រប់យ៉ាង។ នវកម្មគំនិតពុំអាចចាប់កំណើតដោយពុំផ្តើមបណ្តុះក្តីស្រឡាញ់ជាមុនបានទេ។ ការបណ្តុះក្តីស្រឡាញ់ចំពោះការ

រៀនមុខវិជ្ជាប្រវត្តិវិទ្យា និងក្លាយជាអ្នកប្រវត្តិសាស្ត្រ គ្រូបង្រៀនត្រូវចាប់ផ្តើមឱ្យសិស្សស្គាល់ យល់ និងផ្តល់តម្លៃ ចំពោះ ប្រវត្តិសាស្ត្រ។ ការរៀនដើម្បីដឹង យល់ និងផ្តល់តម្លៃចំពោះប្រវត្តិសាស្ត្រ គ្រូបង្រៀន និងសិស្សត្រូវយកបញ្ញត្តិប្រវត្តិវិទ្យាទៅអនុវត្តជាប្រចាំ ភ្ជាប់នឹងជីវភាពប្រចាំថ្ងៃ ការងារ និងរៀនបន្ត។

ការដាំបណ្តុះក្តីស្រឡាញ់ចំពោះមុខវិជ្ជាប្រវត្តិវិទ្យា ពិតជាអាចកើតឡើងក្នុងចិត្តរបស់សិស្សជាមិនខាន។ ចូរលោកគ្រូ អ្នកគ្រូ រំឭកអំពីភាពយន្តមួយរឿងដែលធ្លាប់មើល ទោះបីក្នុងរោងភាពយន្ត ទូរទស្សន៍ ឬទូរសព្ទក្តី។ ឧបមាថាលោកគ្រូ អ្នកគ្រូ ពេញចិត្តភាពយន្តនោះណាស់។ តើភាពយន្តមួយរឿងនោះ មានធាតុអ្វីខ្លះ ក្នុងឈុតណាមួយដែលអ្នកគ្រូ លោកគ្រូពេញចិត្តបំផុត។ ការអង្គុយក្នុងថ្នាក់រៀនរបស់សិស្ស ក៏ត្រូវការធាតុដែលចាប់ចិត្ត និងចាប់អារម្មណ៍ដូចគ្នាដែរ។

ធាតុដឹកនាំចិត្តសិស្សឱ្យចាប់អារម្មណ៍ ក្នុងដំណើរការរៀនពិតប្រាកដ និងប្រកបដោយគុណភាព គឺបញ្ញត្តិ (Stern, Lauriault, & Ferraro, 2018; Erickson & Lanning, 2014; Erickson, Lanning, & French, 2017; Giddens & Brady, 2007; Erickson L. H., 2008)។ បញ្ញត្តិជាធាតុរំលេច និងបង្កប់ក្នុងអត្ថបទនៃមេរៀន។ គ្រូបង្រៀន និងសិស្សអាចយកបញ្ញត្តិទៅភ្ជាប់ជាមួយនឹងខ្លឹមសារ ឬអង្គហេតុនៃមុខវិជ្ជាផ្សេង និងជាមួយបទពិសោធរបស់សិស្ស។ សិស្សអាចយកបញ្ញត្តិទៅភ្ជាប់នឹងប្រយោជន៍ក្នុងជីវភាពប្រចាំថ្ងៃ ការងារ និងរៀនបន្ត។ បានចូលសាលារៀនពីបឋមសិក្សាដល់១២ឆ្នាំ សិស្សត្រូវតែមានដុះឫសកែវនៃក្តីស្រឡាញ់ចំពោះមុខវិជ្ជាប្រវត្តិសាស្ត្រ។ ឫសកែវនៃក្តីស្រឡាញ់ប្រវត្តិសាស្ត្រ ពឹងអាស្រ័យលើបញ្ញត្តិដែលលោកគ្រូ អ្នកគ្រូដឹកនាំសិស្សឱ្យរៀនស៊ីជម្រៅ ក្នុងថ្នាក់ និងភ្ជាប់នឹងជីវភាពប្រចាំថ្ងៃ ក្នុងគ្រួសារ សាលារៀន និងសហគមន៍។

សូមលោកគ្រូ អ្នកគ្រូសាកល្បងឱ្យសិស្សស្វែងការពន្យល់លើរឿងពិតមួយ! ហេតុអ្វីបានជា សម្តេចសង្ឃរាជជួន ណាត ដឹកនាំការសរសេរវចនានុក្រមភាសាខ្មែរ សម្រាប់ខ្មែរជំនាន់ក្រោយ? តើការសរសេរសៀវភៅវចនានុក្រមភាសាខ្មែរ កើតចេញពីការស្រឡាញ់ភាសា ស្រឡាញ់ការរៀន និងស្រឡាញ់មនុស្សជំនាន់ក្រោយដែរឬទេ?

សូមលោកគ្រូ អ្នកគ្រូ សាកល្បងដឹកនាំសិស្សឱ្យសម្ភាសកីឡាករដែលពូកែក្នុងសង្គមខ្មែរមួយនាក់ ឬពីរនាក់ ក្នុងបច្ចុប្បន្ន។ អ្នកគ្រូ លោកគ្រូ អាចសួរសំណួរមួយ។ តើភាពជោគជ័យក្នុងអាជីពកីឡា ពិតជាកើតចេញពីការដាំបណ្ដុះក្ដីស្រឡាញ់ជាមុនមែនឬទេ?

➢ ការផ្ដល់តម្លៃចំពោះពហុភាព និងនានាភាពនៃគំនិត

រូបភាព០៤. Steve Jobs, ឆ្នាំ១៩៥៥-២០១១



ប្រភព ៖ ( Wood, 2015)

បុគ្គលឆ្នើម ក្នុងនវកម្ម និងនិម្មិតកម្មគំនិត គឺការបង្កើតគំនិតសម្បូរបែប គំនិតថ្មី និងផ្លាស់ប្ដូរគំនិតចាស់ ទៅរកគំនិតថ្មី។ បុគ្គលប្រភេទនេះតែងភ្ជាប់គំនិតរបស់អ្នកដទៃជាមួយតម្រូវការជាក់ស្ដែង ក្នុងសង្គម និងការរស់នៅ ប្រចាំថ្ងៃ។ លើសពីនេះទៀត មនុស្សប្រភេទនេះ ច្រើនទទួលយកគំនិតពីច្រើនប្រភព ឬពីមនុស្សច្រើនគ្នា។ មនុស្សមាននវកម្មគំនិតតែងវិភាគ វែកញែក សំយោគ និងបង្កើតគំនិតថ្មីបន្តទៀត។

ស្ទីវ ចប (Steve Jobs, ឆ្នាំ១៩៥៥-២០១១) នាយកប្រតិបត្តិនៃក្រុមហ៊ុនទូរស័ព្ទ និងកុំព្យូទ័រ Apple អាចយកជាគំរូ។ ស្ទីវ ចបទទួលយកគំនិតមនុស្ស នៅជុំវិញខ្លួន ដើម្បីបង្កើតបានវត្ថុមួយ សម្រាប់ផ្លាស់ប្ដូរទម្លាប់របស់ពិភពលោក។

លោកធ្លាប់និយាយថា ប្រសិនបើខ្ញុំពុំបានឃើញកុំព្យូទ័រខ្នាតធំ ខ្ញុំក៏ពុំមានគំនិតបង្កើតកុំព្យូទ័រខ្នាតតូចទេ។ លោកធ្លាប់និយាយថា ការគិតរួមគ្នាប្រកបដោយការទទួលខុសត្រូវជាមួយនឹងសហការី ជាចំណុចផ្ដើមនៃការរុករក និងបង្កើតគំនិតថ្មីៗបន្ថែម។

➢ ការបង្កើតទស្សនាទានមួយ

ក្រោយបានដាំបណ្តុះក្តីស្រឡាញ់ និងសមត្ថភាពទទួលយកពហុភាព និងនានាភាពនៃគំនិត មនុស្សសម្បូរនវកម្មគំនិត ច្រើនបង្កើតទស្សនាទានមួយសម្រាប់ផែនទីជីវិត ។

រូបភាព០៥. រូបថត អេឡុន ម៉ាស (Elon Musk)




ប្រភព ៖ www.getwallpapers.com

ទស្សនាទានថ្មីមួយ អាចលម្អវត្ថុដែលមានស្រាប់ ឬបង្កើតថ្មីនូវវត្ថុមិនទាន់កើតមាន។ អេឡុន ម៉ាស (Elon Musk, ឆ្នាំ១៩៧១) នាយកប្រតិបត្តិ នៃក្រុមហ៊ុន SpaceX និងក្រុមហ៊ុនជាច្រើនទៀត មានទស្សនាទានមួយ ត្រឹមឆ្នាំ២០៣០ ក្រុមហ៊ុន SpaceX នឹងនាំមនុស្សទៅរស់នៅភពអង្គារ។

ទស្សនាទាននេះ បានជំរុញឱ្យក្រុមហ៊ុន SpaceX រចនា ផលិត សាកល្បង និងបង្ហោះកាំជ្រួចនិងអវកាស ដើម្បីយកមនុស្សទៅភពអង្គារ ក្នុងឆ្នាំ២០៣០។

➢ ការគិតធំ-ចាប់ផ្តើមពីគំនិតតូច

ការគិតធំបែបសុបិនជាផែនទីបង្ហាញផ្លូវ ប៉ុន្តែដល់គោលដៅដោយមិនពិបាកពេកទេ។ នៅពេលជជែកគ្នាជាមួយមនុស្សគិតខុសគ្នា (ដោយសារទិន្នន័យក្នុងចិត្តខុសគ្នា) គឺ អ្នកគិតធំច្រើនទទួលការទិតៀន។ ការទិតៀនចំពោះអ្នកគិតធំមានដូចជា *កុំឃើញដំរីអាចម៍ធំ ចង់អាចម៍ធំដូចដំរី។ ជន្លេនងើបមិនផុតពីដីទេ។ ងើយខ្ពស់ រោយកណាស់។* ការដឹកនាំសិស្សរៀនគួរដាំបណ្តុះទម្លាប់ចិត្តសិស្សឱ្យគិតធំ។ ចិត្តមនុស្សបង្កើតបានអ្វីទាំងអស់។

គម្ពីរព្រះត្រៃបិដកនៃព្រះពុទ្ធសាសនា និងគម្ពីរទស្សនវិទ្យាបុរាណ Bhagavad Gita (Easwaran, 2020) ពន្យល់ថា ចិត្តពុំមានដែនកំណត់ និងជ្រៅជាងមហាសមុទ្រ។ ប្រវត្តិសាស្ត្រដែលយើងកំពុងរៀន វិទ្យាសាស្ត្រ និងបច្ចេកវិទ្យារីកចម្រើនលឿនដែលយើងកំពុងប្រើ កើតឡើងដោយសារការគិតធំរបស់មនុស្ស។

ដើម្បីសម្រេចទស្សនវិស័យមួយ មនុស្សដែលមាននវកម្មគំនិត តែងបំបែកគំនិតធំៗ ឬសុបិនរបស់ខ្លួនឱ្យទៅជាបំណែកតូចៗ មានបរិមាណ មានហេតុ ផល និងងាយយល់ យកទៅប្រតិបត្តិកើត។ អ្នកខ្លះហៅការបំបែកគំនិតធំឱ្យជាបំណែកតូចៗជា **ផែនការយុទ្ធសាស្ត្រ និងផែនការលម្អិត**។ ការបំបែកគំនិតធំឱ្យជាបំណែកតូចៗសំដៅបង្កើតភាពសាមញ្ញ និងងាយយល់នៃគំនិត។

គំនិតតូចៗច្រើននាំផ្លូវគិតទៅរកការអនុវត្តសកម្មភាពបានច្រើន សាមញ្ញ និងប្រកបដោយគំនិតច្នៃប្រឌិត។ ដូច្នេះ ទស្សនវិស័យនឹងទៅដល់គោលដៅដោយចាប់ផ្តើមអនុវត្តសកម្មភាពលើគំនិតតូចៗ សាមញ្ញ និងងាយយល់។

➢ ការចែករំលែកសុបិន

មនុស្សមាននវកម្មគំនិត តែងគិតទៅរកវត្ថុមិនទាន់កើតមាន វត្ថុដែលប្លែក ខុសពីគំនិតរបស់មនុស្សដទៃ ឬគំនិតក្នុងក្តីសុបិន។ គំនិតប្លែក គំនិតក្នុងក្តីសុបិន ឬគំនិតខុសពីមនុស្សដទៃ ជាចំណុចចាប់ផ្តើមឱ្យមនុស្សមាននវកម្មគំនិតចាប់ផ្តើមគិត ឆ្ងល់ រកភាពប្រសើរ និងភាពចាំបាច់នៃគំនិត។

ការយកគំនិតប្លែកទៅជជែក និងចែករំលែកជាមួយមនុស្សជាច្រើន ជាការចាប់ផ្តើមប្រមូលនូវពហុភាព និងនានាភាពនៃគំនិត។ ការចែករំលែកសុបិននៃគំនិតថ្មី គឺបង្កើនទំនុកចិត្ត សម្រាប់បន្តបង្កើតនវកម្មគំនិតបន្ថែមទៀត និងកែលម្អគំនិតធំ ទៅរកគំនិតថ្មីជាប្រយោជន៍។ ការលាក់បំបាំងសុបិន ឬគំនិតធំ ពុំមែនជាចំណុចចាប់ផ្តើមនៃការបង្កើតនវកម្មគំនិតទេ។

ការជួបជជែកជាមួយមនុស្សជាក្រុម ឬជាបុគ្គលជាការផ្តើមលក់គំនិត ឬផ្សាយគំនិត ទៅរកទីផ្សារធំ។ ការទម្លាក់ចោលតម្លៃនៃការជួបជជែកជាមួយមនុស្សជាក្រុម ឬជាបុគ្គល គឺទម្លាក់ចោលឱកាសបើកលំហាទីផ្សារលក់គំនិតប្លែក ឬគំនិតថ្មីដែលបានគិតមកជាយូរហើយ។

ការចែករំលែកសុបិនជាសញ្ញាណនៃការបើកចិត្តឱ្យទូលាយ។ មនុស្សមានបេះដូង និងចិត្តទូលាយ គឺមនុស្សដែលប្រតិបត្តិតាមគោលការណ៍សុចរិត និងកុសលចិត្ត។ ការចែករំលែកសុបិន ដោយបេះដូង និងចិត្តទូលាយ គឺនាំគំនិតថ្មីដល់ទីផ្សារធំៗ និងបំពេញតម្រូវការទីផ្សារ។

➢ ការផ្សាយគំនិតតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

ជោគជ័យនៃគំនិតសម្រាប់ធុរកិច្ច និងកិច្ចការគ្រប់ប្រភេទអាស្រ័យលើការផ្សាយគំនិតដល់ទីផ្សារធំទូលាយ។ ក្នុងយុគបដិវត្តន៍ឧស្សាហកម្ម៤.០ មនុស្សត្រូវការបំណិនពូផ្សាយគំនិត ដោយបច្ចេកវិទ្យាព័ត៌មាន និងឧបករណ៍ឌីជីថល។ មនុស្សក្នុងយុគបដិវត្តន៍ឧស្សាហកម្ម៤.០ មានឧបករណ៍ទទួល និងចែករំលែកព័ត៌មាន ឬហៅឧបករណ៍អ៊ិនធឺណេត ឬឧបករណ៍ឌីជីថលដូចជាទូរស័ព្ទ កុំព្យូទ័រ ឬឧបករណ៍ក្នុងរូបទម្រង់ផ្សេងៗ។

ឧទាហរណ៍ លោកគ្រូ អ្នកគ្រូមានគំនិតថ្មីមួយដែលអ្នកគ្រូ លោកគ្រូគិតថាល្អ គួរផ្សព្វផ្សាយ។ អ្នកគ្រូ លោកគ្រូអៀន និងខ្លាចអន់ មិនចែករំលែកគំនិតនោះជាមួយអ្នកដទៃ គំនិតនោះនឹងកប់ទុកក្នុងចិត្តម្នាក់ឯង។ គំនិតនោះនឹងបាត់ប្រយោជន៍ក្នុងពេលណាមួយ។ ប្រសិនបើមានគំនិតល្អមួយ មិនចែករំលែក ភ័យខ្លាចគេលួចគំនិត ជាចំណុចរារាំងដល់ការគិតរកគំនិតថ្មីៗបន្តទៀត។

ការបង្រៀនសិស្សឱ្យចែករំលែកគំនិតប្លែកៗ ខុសគេ ផ្ទុយពីគេ ដោយប្រើប្រព័ន្ធផ្សព្វផ្សាយព័ត៌មានវិទ្យា ឬឧបករណ៍អ៊ិនធឺណេត គឺចាប់ផ្តើមបើកច្រកទីផ្សារដើម្បីលើកតម្លៃនៃគំនិតប្លែក និងគំនិតថ្មី។ គំនិតថ្មីនោះនឹងរកបានទីផ្សារក្នុងពេលណាមួយជាពុំខាន។

## ១០.៥ គុណតម្លៃសង្គម

សង្គមប្រជាធិបតេយ្យមួយ តែងបើកលំហឱ្យមានការចូលរួមយ៉ាងសកម្មរបស់ពលរដ្ឋ ដោយមិនប្រកាន់វណ្ណៈ ភេទ ពិការភាព ជាតិ សាសន៍ នយោបាយ ពណ៌ ។ល។ ភាពចម្រុងចម្រើននៃសង្គមមួយ គឺត្រូវការពលរដ្ឋសកម្ម និងចូលរួមបំពេញភារកិច្ច ប្រកបដោយការទទួលខុសត្រូវ និងគណនេយ្យភាព។ បុគ្គលពោរពេញដោយគុណតម្លៃសង្គម រួមចំណែកស្រាយបញ្ហាប្រឈមរបស់សង្គម។

ពិភពលោកកំពុងប្រឈមនឹងបញ្ហារាប់រយ រាប់ពាន់ រាប់លានជំពូកដែលកំពុងទាមទារឱ្យពលរដ្ឋសកលគ្រប់រូប ចូលរួមរកដំណោះស្រាយ ប្រកបដោយគំនិតច្នៃប្រឌិត។ បញ្ហាមានដូចជា ៖

- ជនភាសិក

- អន្តោប្រវេសន៍ការងារ
- ការកាប់បំផ្លាញព្រៃឈើ
- ទឹកជំនន់
- ជម្លោះប្រដាប់អាវុធ
- បម្រែបម្រួលអាកាសធាតុ
- បំពុលបរិយាកាស
- រំលោភសិទ្ធិមនុស្ស
- ការបាត់បង់សិទ្ធិទទួលការអប់រំ
- ភាពក្រីក្រ
- កុមារមិនបានចូលសាលារៀន
- យុវជនខ្វះការងារធ្វើ

១០.៥.១ ភាពជាពលរដ្ឋសកល

ក្នុងយុគនៃបដិវត្តន៍ឧស្សាហកម្ម៤.០ និងសង្គមសម្បូរដោយនវកម្មគំនិត និងពិពិធកម្មសេដ្ឋកិច្ច មនុស្សត្រូវមានអន្តរទំនាក់ទំនងជាមួយមនុស្សផង មរតកប្រវត្តិសាស្ត្រ និងជាមួយធម្មជាតិផង។ អន្តរទំនាក់ទំនងនៃមនុស្ស ឬការប្រាស្រ័យមនុស្ស សំដៅដល់ការចៀសវាងការប្រកាន់សាវតារ នៃជាតិសាសន៍ សាសនា នយោបាយ វប្បធម៌ ប្រពៃណី វណ្ណៈសង្គម ជំនឿ និងសេដ្ឋកិច្ចនៃប្រទេស ឬជនជាតិដទៃ នៅគ្រប់ជ្រុង នៃពិភពលោក។ អន្តរទំនាក់ទំនងនៃមនុស្សជាមួយធម្មជាតិ សំដៅដល់ការផ្តល់ក្តីស្រឡាញ់ សង្គ្រោះ និងរក្សាធម្មជាតិឱ្យមានចីរភាព។ អន្តរទំនាក់ទំនងនៃមនុស្សជាមួយមរតកប្រវត្តិសាស្ត្រ សំដៅដល់ការប្រតិបត្តិសេចក្តីពិត ផ្តល់ក្តីស្រឡាញ់ សង្គ្រោះ និងរក្សាមរតកប្រវត្តិសាស្ត្រជាប្រយោជន៍ដល់មនុស្ស បន្តជំនាន់។

បដិវត្តន៍នៃឧស្សាហកម្ម៤.០ និងបញ្ញាសិប្បនិម្មិត កំពុងជំរុញឱ្យមានការផ្លាស់ប្តូរទម្រង់ ទម្លាប់ និងលក្ខណៈនៃឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងសេវាកម្ម។ ការផ្លាស់ប្តូរនេះសំដៅឆ្លើយតបនឹងតម្រូវការមនុស្ស និងកំណើនប្រជាករក្នុងពិភពលោក។ ការផ្លាស់ប្តូរនេះ ក៏ប្តូរការគិត ការប្រព្រឹត្តិ និងទម្លាប់

របស់មនុស្សដែរ។ ដូច្នេះ ពលរដ្ឋគ្រប់ជាតិសាសន៍ ត្រូវរួមរស់ជាមួយគ្នា និងឱ្យតម្លៃចំពោះភាពរួម ភាពដោយឡែក នានាភាព ភាពចម្រុះ និងពហុភាព នៃនយោបាយ សេដ្ឋកិច្ច សាសនា វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី និងជំនឿ។ ន័យក្នុងភាសាសកល គឺ មនុស្សរស់ក្រោមអត្តសញ្ញាណមនុស្សជាតិរួម។ ក្រោមអត្តសញ្ញាណរួមនេះ មនុស្សនឹងប្រតិបត្តិចិត្តមេត្តា មេត្រីភាព ក្តីស្រឡាញ់ ពេញចិត្ត និងសេចក្តីពិត ចំពោះធម្មជាតិ មនុស្ស និងមរតកប្រវត្តិសាស្ត្រជាប្រចាំ។

១០.៥.២ អន្តរវប្បធម៌

បច្ចេកវិទ្យាព័ត៌មាន និងវិជ្ជាសិប្បនិម្មិត កំពុងបង្រួមពិភពលោកឱ្យកាន់តែរួមតូច។ មនុស្សរាប់លាននាក់កំពុងសប្បាយពេញចិត្តនឹងការធ្វើដំណើរ រៀនបន្ត ប្រាស្រ័យមនុស្ស និងធ្វើការក្រៅប្រទេស ដោយប្រើបច្ចេកវិទ្យា វិជ្ជាសិប្បនិម្មិត និងឧបករណ៍អ៊ិនធឺណេត។ មនុស្សធ្វើការងារ រៀនបន្ត និងធ្វើដំណើរក្រៅប្រទេសតែងប្រឈម និងឆ្លងកាត់នានាភាព ពហុភាព និងភាពផ្សេងគ្នានៃជំនឿ វប្បធម៌ និងទម្លាប់នៃការរស់នៅ ធ្វើការ និងរៀនបន្ត។ដូច្នេះ សិស្សចូលរៀន នៅសាលាត្រូវរៀនអំពីអន្តរវប្បធម៌ជាចាំបាច់ ដើម្បីត្រៀមខ្លួនរស់ក្នុងពិភពលោករួមមួយ និងរក្សាការពារពិភពលោករួម។

ការរៀនចេះស្ទាត់ភាសានៃប្រទេសរស់នៅ រៀនបន្ត និងធ្វើការ ពុំទាន់គ្រប់គ្រាន់ទេ។ ភាពចាំបាច់នៃការរស់នៅ ធ្វើការ និងរៀនបន្តនៅប្រទេសក្រៅ មនុស្សត្រូវប្រតិបត្តិបំណិន និងបង្កើតទម្លាប់ច្រើនបែបច្រើនយ៉ាង ៖

- ឱ្យតម្លៃចំពោះភាពផ្សេងគ្នា នានាភាព និងពហុភាពនៃប្រពៃណី សាសនា ទំនៀមទម្លាប់ និងវប្បធម៌
- ប្រាស្រ័យមនុស្ស ឱ្យស្របតាមប្រពៃណី សាសនា ទំនៀមទម្លាប់ និងវប្បធម៌នៃប្រទេសផ្សេងគ្នា
- រៀនសង្កេតសកម្មភាពមនុស្ស ដោយឆ្ងល់ និងសួរសំណួរ **ហេតុអ្វី**?
- រៀនសម្របចិត្ត និងកាយជាមួយនឹងភាពផ្សេងគ្នា និងនានាភាព
- ស្គាល់ និងយល់ច្បាស់អំពីវប្បធម៌ និងប្រពៃណីនៃជាតិខ្លួនឯង
- រៀនគិតជាលក្ខណៈសកល ដោយចេញពីការសង្កេតជាប្រចាំ

- រក្សាចិត្តអត់ធ្មត់ និងទទួលយកភាពខុសគ្នា នានាភាព និងពហុភាព
- រក្សាចិត្តជាបរិយាបន្នបុគ្គល ជាបុគ្គលធ្វើសេចក្តីល្អចំពោះមនុស្ស។

## ១១. ទស្សនវិជ្ជាអប់រំ និងវិទ្យាសាស្ត្រនៃការរៀន

ទស្សនវិទូ អ្នកស្រាវជ្រាវ និងអ្នកអប់រំជាច្រើននាក់បានសរសេរគោលការណ៍ ទ្រឹស្តី ទស្សនវិជ្ជា និងវិទ្យាសាស្ត្រនៃការរៀន និងបង្រៀនយ៉ាងច្រើនសម្បូរបែប។ គ្រូបង្រៀនដែលមានគុណសម្បទាជាគ្រូបង្រៀនពូកែ តែងប្រើគោលការណ៍ ទ្រឹស្តី ទស្សនវិជ្ជា និងវិទ្យាសាស្ត្រនៃការរៀន និងបង្រៀន យ៉ាងសម្បូរបែប ក្នុងដំណើរការតាក់តែងលំនាំដឹកនាំការរៀន និងកិច្ចតែងការបង្រៀន និងក្នុងដំណើរការរៀន បង្រៀន និងដឹកនាំការរៀនក្នុងថ្នាក់។ សៀវភៅនេះសំយោគគោលការណ៍នៃទស្សនវិជ្ជាអប់រំ និងវិទ្យាសាស្ត្រនៃការរៀននិងបង្រៀនជាបី ១. ពីរ៉ាមីតនៃការរៀន ២. ទស្សនវិជ្ជាអប់រំ ៣. ទស្សនវិជ្ជានៃការបង្រៀន។

### ១១.១ ពីរ៉ាមីតនៃការរៀន

ពាក្យបុរាណមួយពោលថា “ប្រតិបត្តិច្រើនចម្រើនចាំ និងចេះ”។ ដូច្នេះការបង្រៀនដោយភ្លេចគិតទៅលើការដឹកនាំការរៀនដោយឱ្យសិស្សសង្កេត ឆ្លុះគិត បង្កើតសំណួរ សួរ និងរកការពន្យល់ដោយឯករាជ្យ សិស្សមានឱកាសបានត្រឹមស្តាប់ និងអាន។ គ្រូបង្រៀនគ្រាន់តែឱ្យសិស្សអានអត្ថបទមេរៀន និង ស្តាប់គ្រូបង្រៀនបកស្រាយ រ៉ាយរាប់ រៀបរាប់ និងពន្យល់ គឺសិស្សមានឱកាសចាំតិចតួចណាស់។ សកម្មភាពអានបន្ត អានបណ្តាក់ និងអានប្រដេញ មិនសូវចម្រើនចាំ និងចេះទេ (ACRLog, 2014; United Nations Educational, Scientific and Cultural Organization, 2018a)។

ការបង្រៀនផ្តោតលើការអាន និងការស្តាប់ ដឹកនាំសិស្សឱ្យចាំអង្គហេតុ និងព្រឹត្តិការណ៍ ប៉ុន្តែពុំអាចបំពាក់បំណិនសតវត្សរ៍ទី២១ដល់សិស្សបានច្រើនទេ។ យុវជនក្នុងយុគឧស្សាហកម្ម៤.០ត្រូវការបំណិនសតវត្សរ៍ទី២១ បំពេញតម្រូវការការងារ រស់នៅ និងរៀនបន្ត។ លទ្ធផល នៃការវាយតម្លៃការសិក្សាអន្តរជាតិសម្រាប់សិស្សកម្ពុជាអាយុ១៥ឆ្នាំ (PISA-D ២០១៨) បង្ហាញថា សិស្សកម្ពុជា

ខ្សោយបំណិនគណិតវិទ្យា និងបំណិនអាន (OECD, 2018)។ លទ្ធផលវាយតម្លៃនេះនាំផ្លូវចិត្តអ្នកដឹកនាំអប់រំ និងគ្រូបង្រៀនឱ្យគិតរកមធ្យោបាយ វិធីសាស្ត្រ និងយុទ្ធវិធីដឹកនាំការរៀនថ្មីៗដែលនាំឱ្យសិស្សប្រតិបត្តិច្រើនជាងទម្លាប់នៃការអានបណ្ដាក់ អានប្រដេញ និងស្ដាប់ការពន្យល់ បកស្រាយ រ៉ាយរ៉ាប់ និងរៀបរាប់របស់គ្រូបង្រៀន (Education Research Council, 2018)។

រូបភាព០៦. រូបពីរ៉ាមីតនៃការរៀន




Source: ប្រែនិងសម្រួលពី (ACRLog, 2014)

ការទទួលបានវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា គុណតម្លៃ និងចរណាមនុស្សពីដំណើរការរៀន ឬដឹកនាំការរៀន ក្នុងប្រព័ន្ធសាលារៀន ថ្នាក់រៀន និងជាមួយគ្រូបង្រៀន គឺ ប្រៀបប្រដូចនឹងការផ្ដល់ឱកាសឱ្យសិស្សផ្សងព្រេងមិនដល់ទីបញ្ចប់ ក្នុងព្រៃសម្បូរកំណាប់។ សិស្សមិនដឹងចាប់យកវត្ថុមានតម្លៃមួយណាមុន ក្នុងដំណើរផ្សងព្រេងក្នុងព្រៃសម្បូរកំណាប់។ដំណើរការរៀន គឺដឹកនាំមនុស្ស

ឱ្យកើតបញ្ញា។ មនុស្សមានបញ្ញាគឺបានប្រើបទពិសោធជីវិតដើម្បីប្រយោជន៍មនុស្សទូទៅ និងផែនដី។

របកគំហើញនៃការស្រាវជ្រាវជាច្រើនពន្យល់ថា សិស្សអាចចាំ យល់ ប្រតិបត្តិ វិភាគ វាយតម្លៃ និងច្នៃប្រឌិតចំពោះបញ្ញត្តិ គោលគំនិត គំនិតធំ និងគំនិតទូទៅមួយ ទាមទារឱ្យគ្រូបង្រៀនដឹកនាំសិស្សឱ្យគិត ឆ្ងល់ បង្កើតសំណួរ សួរ និងរកការពន្យល់ដោយខ្លួនឯងឱ្យបានច្រើនបំផុត។ ACRLog (2014) និង (United Nations Educational, Scientific and Cultural Organization, 2018a) ពន្យល់ និងលើកហេតុផល ដូចជា ៖

- គ្រូបង្រៀនឱ្យសិស្សអានអត្ថបទ។ សិស្សមានឱកាសចាំអ្វីដែលបានអានតែ១០ភាគរយប៉ុណ្ណោះ។ ការអានឱ្យឮតែសំឡេង តាមពាក្យ ពុំផ្តល់ឱកាសឱ្យសិស្សគិត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងរកការពន្យល់អំពីបញ្ញត្តិពីអត្ថបទ។ ដូច្នេះ សិស្សបានត្រឹមទទួលព័ត៌មានបឋម។ ការរៀនត្រឹមទទួលព័ត៌មាន ពុំមានជាការរៀនពិតប្រាកដ និងជាការរៀនមិនទាន់គ្រប់គ្រាន់ដើម្បីយកទៅប្រើការបានទេ។
- សិស្សបានស្តាប់នូវអ្វីដែលគ្រូនិយាយ រៀបរាប់ រ៉ាយរ៉ាប់ ពន្យល់ បកស្រាយ គឺសិស្សមានលទ្ធភាពចាំបាន២០%។ ជាទូទៅ ការស្តាប់ គឺពីរោះ និងងាយស្រួលសម្រាប់សិស្ស ប៉ុន្តែស្តាប់យូរម៉ោងពេកក៏មានអារម្មណ៍ងងុយដេកដែរ។ សិស្សស្តាប់បានឮ និងបានទទួលព័ត៌មានពីគ្រូបង្រៀនតែមួយប្រភព គឺងាយភ្លេច។
- ការរៀនដោយស្តាប់ការបកស្រាយ និងពន្យល់របស់គ្រូ គឺសិស្សមិនបានប្រើបទពិសោធរបស់ខ្លួនឯង ភ្ជាប់នឹងបញ្ញត្តិក្នុងមេរៀនទេ។ ប្រសិនបើមានតែឱកាសស្តាប់ ពុំមានឱកាសគិត ឆ្ងល់ បង្កើតសំណួរ សួរ រកការពន្យល់ ញែកធាតុនៃព័ត៌មាន សិស្សមានឱកាសតិចណាស់ក្នុងការប្រែក្លាយពីព័ត៌មានទៅជាចំណេះដឹង និងវិជ្ជា។ សិស្សមានឱកាសតិចណាស់ក្នុងការស្វែងការពន្យល់លើភាពត្រឹមត្រូវ ពិត និងច្បាស់លាស់នៃធាតុក្នុងព័ត៌មានបានពីគ្រូបង្រៀនបកស្រាយ រៀបរាប់ រ៉ាយរ៉ាប់ ពន្យល់។ ដូច្នេះ

សិស្សមានឱកាសត្រឹមទទួលព័ត៌មាន និងត្រឹមដឹង។ សិស្សពុំអាចប្រែក្លាយព័ត៌មានបានពីការស្ដាប់ឱ្យទៅជាចំណេះដឹងនិងវិជ្ជា រួចភ្ជាប់ជាមួយនឹងការប្រើប្រាស់ប្រចាំថ្ងៃក្នុងការរៀន និងធ្វើការបានទេ។

- គ្រូបង្រៀនឱ្យសិស្សមើលរូបភាព។ គ្រូបង្រៀនបកស្រាយ រ៉ាយរាប់រៀបរាប់ ពន្យល់ តាមន័យនៃរូបភាព និងការយល់របស់គ្រូបង្រៀន គឺសិស្សមានលទ្ធភាពចាំ៣០ភាគរយ។ ដើម្បីពង្រីកការចងចាំ និងបន្ថែមជម្រៅនៃចំណេះដឹងលើបញ្ញត្តិអ្វីមួយបង្កប់ក្នុងរូបភាព សិស្សគួរទទួលឱកាសគិតច្រើន឴ឆ្លើយ បង្កើតសំណួរ សួរសំណួរ រកការពន្យល់ និងផ្ទៀងផ្ទាត់ ភាពត្រឹមត្រូវ ច្បាស់លាស់ និងពិតនៃបញ្ញត្តិបង្កប់ក្នុងរូបភាព។ សិស្សមានឱកាសឡើងបកស្រាយរូបភាពជាការផ្ដើមដំបូងនៃការរៀន។
- គ្រូបង្រៀនគួរផ្ដល់ឱកាសឱ្យសិស្សគិត ឆ្លើយ បង្កើតសំណួរ សួរសំណួរ កែលម្អសំណួរ និងរកការពន្យល់ឱ្យបានច្រើនប្រភព។ ដំណើរការឆ្លើយ និងសួរ ជាការចាប់ផ្ដើមរក និងបង្កើតបានចំណេះដឹងពិតប្រាកដសម្រាប់ការរៀនបន្ត និងជីវភាពអនាគត។
- សិស្សបានស្ដាប់ផង និងមើលព្រឹត្តិការណ៍ផ្ទាល់ភ្នែកផង សិស្សនឹងមានលទ្ធភាពចាំខ្លឹមសារគោល ឬបញ្ញត្តិបានប្រហែល៥០ភាគរយ។ ការបានស្ដាប់ និងមើលផ្ទាល់ភ្នែក មានមើលវីដេអូ ភាពយន្ត ការសម្ដែង ការតាំងពិព័ណ៌ ឬមើលព្រឹត្តិការណ៍ជាក់ស្ដែង។ ការប្រើត្រចៀក និងភ្នែកដើម្បីទទួលព័ត៌មានក្នុងព្រឹត្តិការណ៍ជាក់ស្ដែង សិស្សមានឱកាសឆ្លើយច្រើន ប៉ុន្តែសិស្សពុំមានឱកាសបង្កើតសំណួរ សួរសំណួរ និងរកការពន្យល់ទេ។ សិស្សពុំមានឱកាសពិចារណាខ្លឹមសារទទួលបានពីការមើល និងស្ដាប់ព្រឹត្តិការណ៍ជាក់ស្ដែងនោះទេ។ ដូច្នេះ ដំណើរការរៀនពិតប្រាកដក៏ពុំទាន់មកដល់ដែរ។ ដើម្បីធានាឱ្យដំណើរការរៀនប្រាកដចាប់ផ្ដើម និងដល់ទីគោលដៅ គ្រូបង្រៀនត្រូវផ្ដល់ឱកាសឱ្យសិស្សឆ្លើយ គិត បង្កើតសំណួរ សួរសំណួរ រកការពន្យល់ និងកត់ត្រាទុកលទ្ធផល។

- សិស្សមានឱកាសរៀបរាប់តាមការដឹង ការចាំ និងការយល់ ក្នុងកម្រិតសមត្ថភាព ពេលគ្រូបង្រៀនអនុញ្ញាតឱ្យសិស្សចូលរួមពិភាក្សា និងឡើងនិយាយ។ សិស្សហ៊ានឡើងនិយាយ សិស្សចាំគំនិតដែលបានឡើងនិយាយ ឬសរសេរប្រហែល៧០ភាគរយ។ ការផ្តល់ឱកាសឱ្យសិស្សឡើងបញ្ចេញគំនិតតាមការនិយាយ និងសរសេរនេះ តាមកម្រិតសមត្ថភាពគិតរបស់សិស្ស គឺលើកទឹកចិត្តសិស្ស និងបណ្តុះភាពក្លាហានឱ្យសិស្ស។ លើសពីនេះទៀត ឱកាសបញ្ចេញគំនិតបង្កបរិយាកាសឱ្យសិស្សអភិវឌ្ឍបំណិនប្រាស្រ័យមនុស្ស និងបំណិនរៀបគំនិតនិយាយ និងសរសេរ។ ដូច្នេះ សិស្សប្រើបំណិនទាំងនេះដើម្បីចូលរួមក្នុងការពិភាក្សា សរសេររបាយការណ៍ ធ្វើបទបង្ហាញ ឬឡើងបង្រៀនក្នុងគ្រប់បរិបទការងារ។
- ការឡើងសម្តែង ធ្វើត្រាប់ និងធ្វើផ្ទាល់ដៃ ជួយសិស្សឱ្យមានឱកាសនិយាយនូវអ្វីដែលសិស្សចាំ ដឹង និងយល់។ ការឡើងសម្តែង ធ្វើត្រាប់ និងធ្វើផ្ទាល់ដៃ ផ្តល់ឱកាស និងលទ្ធភាពឱ្យសិស្សចាំខ្លឹមសារគោល ឬបញ្ញត្តិអ្វីមួយ បានរហូត៩០ភាគរយ។
- ការឡើងសម្តែង ឬធ្វើត្រាប់តាម សំដៅណែនាំឱ្យសិស្សអនុវត្តនូវគំនិតអ្វីមួយដោយផ្ទាល់។ ការឡើងសម្តែង ឬធ្វើត្រាប់តាម ផ្តល់ឱកាសឱ្យសិស្សអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង ដូចជា បំណិនរកព័ត៌មាន ត្រិះរិះពិចារណា កំណត់អាទិភាព ពន្យល់ វិភាគ ប្រៀបធៀប ទាក់ទង វែកញែក និងពិសោធគំនិត។ សិស្សបានយកបញ្ញត្តិអ្វីមួយទៅអនុវត្ត ភ្ជាប់នឹងជីវភាព ឬទម្លាប់ប្រចាំថ្ងៃ សិស្សកាន់តែមានឱកាស និងលទ្ធភាពចងចាំ និងយកទៅចែករំលែកជាមួយអ្នកដទៃបានកាន់តែច្រើន។

### ១១.២ ទស្សនវិជ្ជាអប់រំ

ទស្សនវិជ្ជាសំដៅដល់វិជ្ជាអ្វីមួយដែលត្រូវបានបង្កើតដោយទស្សនៈរបស់បុគ្គលមួយនាក់ (Khmer Buddhism Institute, 1967)។ ទស្សនវិជ្ជាអាចជាជំនឿ ឬវិទ្យាសាស្ត្រ ថែងអំពីទ្រឹស្តី គោលការណ៍ បុព្វហេតុ ឬជីវិតសត្វ និងមនុស្ស (Cambridge Dictionary, 2020)។ ទស្សនវិជ្ជាអប់រំមានភាពប្រកដនិយម និង

ភ្ជាប់ទំនាក់ទំនងជាមួយធម្មជាតិ និងគោលគំនិតនៃការរៀន និងការបង្កើតពុទ្ធិថ្មី (Magrini, 2018)។ ទស្សនវិជ្ជាអប់រំសំដៅដល់ទ្រឹស្ដី ជំនឿ គោលការណ៍ និងបុព្វហេតុនៃការដឹកនាំមនុស្សឱ្យរៀន ដើម្បីបង្កើតបានពុទ្ធិថ្មី មានចំណេះដឹងថ្មី និងប្រតិបត្តិគុណតម្លៃនៃមនុស្សពូកែ (Magrini, 2018)។

ធម្មជាតិនៃការកើតពុទ្ធិ គឺកើតចេញពីបទពិសោធ (Stern, Lauriault, & Ferraro, 2018; Erickson & Lanning, 2014; Erickson, Lanning, & French, 2017; Giddens & Brady, 2007; Erickson L. H., 2008; Curtis, Danquah, & Aunger, 2009; United Nations Educational, Scientific and Cultural Oranization , 1996)។ ពុទ្ធិកើតចេញពីបទពិសោធសំដៅដល់វិញ្ញាណទាំង៥បានឆ្លងកាត់។ មនុស្សម្នាក់ៗឆ្លងកាត់បទពិសោធជីវិត ការងារ និងរៀន តាមបរិបទ និងលក្ខខណ្ឌផ្សេងៗ ដូចជាទីកន្លែង ស្ថានភាពសេដ្ឋកិច្ច ជីវសាស្ត្រ ភូមិសាស្ត្រ និងប្រជាសាស្ត្រ (Curtis, Danquah, & Aunger, 2009)។ ទស្សនវិជ្ជាអប់រំចែកចេញជាច្រើនប្រភេទជាឧទាហរណ៍ ប៉ុន្តែសៀវភៅនេះពុំសំយោគប្រភេទនីមួយៗទេ៖

១. ថ្មីនិយម (Perennialism)
២. អត្ថនិយម (Essentialism)
៣. វឌ្ឍននិយម (Progressivism)
៤. អត្ថិភាពនិយម (Existentialism)
៥. ស្ថាបនានិយម (Constructivism)
៦. មនោនិយម (Idealism)
៧. ពិសោធនិយម (Experientialism)
៨. អាកប្បកិរិយានិយម (Behaviouralism)។

គ្រូបង្រៀនដែលមានសម្រស់នៃចិត្ត និងប្រាជ្ញាភិវឌ្ឍន៍ តែងសម្លឹង និងឱ្យតម្លៃចំពោះទស្សនវិជ្ជា ទ្រឹស្ដី និងវិទ្យាសាស្ត្រនៃការអប់រំ ដើម្បីដឹកនាំការរៀន និងការបង្រៀន (Magrini, 2018)។ គ្រូបង្រៀនប្រើទស្សនវិជ្ជា ទ្រឹស្ដី និងវិទ្យាសាស្ត្រអប់រំជាគោល និងជាឧបករណ៍តែងជ្រើសរើសវិធី និងយុទ្ធវិធី ដើម្បីតាក់តែងលំនាំនៃការរៀន កម្មវិធីសិក្សា កិច្ចតែងការ វិធីសាស្ត្របង្រៀន និង

ដឹកនាំការរៀន (Magrini, 2018)។ គ្រូបង្រៀនតែងប្រើទស្សនវិជ្ជា ទ្រឹស្តី និងវិទ្យាសាស្ត្រអប់រំ ដើម្បីជួយសិស្សក្នុងដំណើរការរៀនសូត្រ ពង្រីកវិសាលភាពនៃគំនិត និងការប្រើចំណេះដឹង និងវិជ្ជា ក្នុងការងារ និងរស់ក្នុងគ្រប់បរិបទ និងកាល។

សៀវភៅនេះលើកយកបញ្ហារបស់ទស្សនវិទូបុរាណ ឬមហាគរុ ដឹកនាំសិស្សឱ្យរៀនដល់កម្រិតមនុស្សពូកែ ដូចជា ៖

### ១១.២.១ ព្រះពុទ្ធ (Siddhartha Gautama, ឆ្នាំ៥៦៣ឬ៤៨០-៤៨៣មុនគ.ស)

ព្រះពុទ្ធ (Siddhartha Gautama, ឆ្នាំ៥៦៣ឬ៤៨០-៤៨៣ឬ៤០០មុនគ.ស) ពុំបានបង្កើតសាសនាទេ។ ព្រះអង្គគ្រាន់តែជាសាស្តា (គ្រូ) ជាបុគ្គលឃើញធម៌ និងប្រកាសធម៌។ ព្រះពុទ្ធប្រកាសថា ព្រះអង្គជាមនុស្សសុទ្ធសាធ។ បុគ្គលគោរពការបង្រៀនរបស់ព្រះពុទ្ធ តែងហៅការបង្រៀននេះថា ទស្សនៈ និងព្រះធម៌។ ការបង្រៀនរបស់ព្រះពុទ្ធសំដៅជួយមនុស្សឱ្យមានធម៌ និងប្រតិបត្តិធម៌ ជាធម្មជាតិនៃសេចក្តីពិត (Khmer Buddhism Institute , 1931)។ ព្រះពុទ្ធបង្រៀនថា បុគ្គលម្នាក់ៗជាម្ចាស់នៃខ្លួនឯង។ សកម្មភាព ទង្វើ ទម្លាប់ ចរិត កម្ម វាសនា និងជីវិត នៃបុគ្គលម្នាក់ពុំមានទេព្តា ឬអំណាចអ្វីណាមួយមកគ្រប់គ្រងទេ។

បុគ្គលម្នាក់ៗជាអ្នកបង្កើតវាសនា និងជីវិតរបស់ខ្លួន ពុំមានអំណាច ឬទេព្តាណាមួយមកកំណត់ទេ។ ព្រះពុទ្ធបង្រៀនថា កម្មឬទង្វើរបស់បុគ្គលម្នាក់ៗជាអង្គហេតុពន្យល់អំពីទម្លាប់ និងបង្កើតជាចរិតរបស់មនុស្ស។ ចរិតកើត និងបន្សល់ទុកតជាតិ។ ចរិតមនុស្សជាអ្នកកំណត់វាសនារបស់មនុស្សក្នុងគ្រប់ជាតិ (Khmer Buddhism Institute , 1931)។

ព្រះពុទ្ធបង្រៀនបុគ្គលគ្រប់រូបឱ្យមានវិជ្ជា ចរណៈ និងគុណតម្លៃ។ បុគ្គលមួយនាក់មានវិជ្ជាខ្ពង់ខ្ពស់ ប៉ុន្តែខ្វះចរណៈ និងគុណតម្លៃ បុគ្គលនោះពុំអាចក្លាយជាបុគ្គលពូកែបានទេ។ ការបង្រៀនរបស់ព្រះពុទ្ធមានច្រើន ប៉ុន្តែសៀវភៅនេះស្វែងយល់អំពីទម្លាប់រៀនដើម្បីក្លាយជាបុគ្គលពូកែ ក្នុងលំនាំនៃការបង្រៀនក្នុងព្រះពុទ្ធសាសនា។

បុគ្គលសិក្សាព្រះធម៌នៃព្រះពុទ្ធសាសនាមួយចំនួន ហៅការបង្រៀនរបស់ព្រះពុទ្ធថា ទស្សនវិជ្ជា *កម្មនិយម*។ តើលោកគ្រូ អ្នកគ្រូ បង្រៀនកូននិងសិស្ស

ដើម្បីគ្រាន់តែដឹងអង្គហេតុ ព័ត៌មាន ឬមានចេតនាប្តូរចរិត ឱ្យទៅជាបុគ្គលពូកែដែរឬទេ? ប្រសិនបើចម្លើយសំដៅប្តូរចរិតឱ្យទៅជាបុគ្គលពូកែ គម្ពីរព្រះត្រៃបិដកនៃព្រះពុទ្ធសាសនាបង្រៀនមនុស្សឱ្យប្តូរចរិត៦យ៉ាង (Khmer Buddhism Institute , 1931) ៖

- រាគចរិត
- ទោសចរិត
- មោហចរិត
- សទ្ធាចរិត
- ពុទ្ធិចរិត ឬញាណចរិត
- វិតក្កចរិត

ការប្តូរចរិត៦យ៉ាងនេះសំដៅដាំបណ្តុះព្រហ្មវិហារធម៌ គឺ ៖

- មេត្តា
- ករុណា
- មុទិតា
- ឧបេក្ខា

សៀវភៅនេះពុំបានសង្ខេប ឬពន្យល់អំពីគោល និងវិធីនៃការប្តូរចរិត និងការដាំបណ្តុះព្រហ្មវិហារធម៌ទេ។ ដើម្បីឱ្យការប្រតិបត្តិក្លាយជាប្រយោជន៍នៃជីវភាព ធ្វើការ និងរៀនបន្ត លោកគ្រូ អ្នកគ្រូសង្កេតសកម្មភាព នៃបុគ្គលនៅក្បែរខ្លួន ដូចជាសមាជិកគ្រួសារ អ្នកជិតខាង សហការី និងអ្នកផ្សេង។ ការសង្កេតរបស់លោកគ្រូ អ្នកគ្រូ គួរផ្តោតការយកចិត្តទុកដាក់លើការគិត វាចា ការប្រព្រឹត្តិ និងវិបាកកម្ម។ ឧទាហរណ៍ បុគ្គលមានរាគចរិត (បុគ្គលចង់បានអត់ខ្មាសបាប)! តើមនុស្សនោះទទួលបានអ្វីជាផលភ្លាមៗ? តើមនុស្សនោះនឹងបានអ្វីជាវិបាកកម្មកើតបន្តបន្ទាប់មកទៀតក្នុងការរស់នៅ? ក្នុងដំណើរការសង្កេត លោកគ្រូ អ្នកគ្រូ ស្វែងសេចក្តីពន្យល់ចំពោះសំណួរមួយចំនួនទៀត ដូចជា ៖

- តើខ្ញុំបានប្រព្រឹត្តបាបអ្វីខ្លះ បានជាជីវិតខ្ញុំកម្សត់ម្លេះ?
- ហេតុអ្វីបានលុយ ម៉ូតូខូច?

- ហេតុអ្វីក្រហើយ ឈឺទៀត?
- ហេតុអ្វីបានលុយ កូនឈឺ ខ្លួនឯងឈឺ បានលុយ ពេទ្យហៅរហូត?
- ធ្វើការបានលុយ មិនទាន់បានចាយផង ចោរគាស់ផ្ទះ លួចខ្ទេច?
- ខ្ញុំធ្វើបុណ្យ ចូលបច្ច័យបុណ្យ និងដាក់ទានផង បុណ្យមិនជួយ
- ខំជួយគេ បែរជាបានទោសទៅវិញ។

### ១១.២.២ សូក្រាត (Socrates, ឆ្នាំ៤៧០ - ឆ្នាំ៣៩៩ មុន គ.ស)

សូក្រាតបង្កើតទស្សនវិជ្ជាមួយហៅថា *បញ្ញានិយម* (Intellectualism)។ សម្ដីសាមញ្ញគួរចាំ និងយកទៅប្រតិបត្តិប្រចាំថ្ងៃគឺ *"គំនិតមានតម្លៃជាងរូបកាយ។ ពុទ្ធិ និងគុណធម៌មានតម្លៃជាងជីវិត"*។ ការសម្រេចចិត្តរបស់សូក្រាត តែងដើរតាមគន្លងនៃទស្សនៈវិជ្ជារបស់គាត់។ សូក្រាតសុខចិត្តស្លាប់ និងពុំព្រមរត់គេចចេញពីគុក និងពីទោសប្រហារជីវិតទេ។ សូក្រាតសុខចិត្តយកថ្នាំពុលផឹកដោយខ្លួនឯង។ សម្ដីសាមញ្ញមួយគួរចាំ មុនសូក្រាតផឹកថ្នាំ *"ខ្ញុំដឹងថា ខ្ញុំពុំចេះអ្វីទេ"* (Magrini, 2018; Gordon, 2009)។ សូក្រាតប្រើទស្សនៈមួយនេះដើម្បីបង្រៀនសិស្សឱ្យក្លាយជាពលរដ្ឋពូកែ សម្បូរទាំងវិជ្ជា និងគុណតម្លៃ សម្រាប់ប្រើគ្រប់កាល និងបរិបទ។

សូក្រាតតែងបង្រៀនសិស្សថា វិជ្ជាមានច្រើនបែប ច្រើនយ៉ាង និងច្រើនទម្រង់។ សូក្រាតបង្រៀនទៀតថា វិជ្ជាមានប្រយោជន៍តិចនិងច្រើន ពុំអាស្រ័យហេតុផលអ្វីទេ។ *"ខ្ញុំដឹងថា ខ្ញុំពុំចេះអ្វីទេ" "គំនិតមានតម្លៃជាងរូបកាយ"* ហើយ *ពុទ្ធិនិងគុណធម៌មានតម្លៃជាងជីវិត* (Magrini, 2018; Gordon, 2009)" ជាទស្សនៈបានដឹកនាំឱ្យសូក្រាតគិត ពង្រីកវិសាលភាពនៃគំនិត និងបំបែកភាគល្អិតនៃគំនិតសម្រាប់ឱ្យមនុស្សប្រតិបត្តិប្រចាំថ្ងៃ។

### ១១.២.៣ ប្លាតូ (Plato, ៤២៤/៤២៣ -៣៤៨/៣៤៧ មុន គ.ស)

ទស្សនវិជ្ជារបស់ប្លាតូ ផ្ដោតការយកចិត្តទុកដាក់លើធម្មជាតិនៃពុទ្ធិព្រលឹង និងសច្ចភាព។ ការបង្រៀនរបស់ប្លាតូ សំដៅឱ្យមនុស្សប្រតិបត្តិធម្មជាតិនៃពុទ្ធិ និងសច្ចភាព ដើម្បីជីវិតល្អ និងរស់ក្នុងយុត្តិធម៌។

ប្លាតូ ជាសិស្សរបស់សូក្រាត។ ប្លាតូបានសរសេរអំពីសូក្រាតមួយប្រយោគ គួរទន្ទេញឱ្យចាំ និងប្រតិបត្តិ *"បញ្ហារបស់សូក្រាតគឺវិជ្ជានៃភាពល្ងង់មិនចេះអ្វីរបស់គាត់។"* សូក្រាតពុំដែលបង្រៀនអ្វីជាទស្សនៈរបស់គាត់ទេ (Magrini, 2018; Gordon, 2009)។ ប្លាតូសរសេរអំពីសូក្រាតថា *"សូក្រាតតែងបង្កើតសំណួរឱ្យសិស្សស្វែងការពន្យល់លើភាពពិត ច្បាស់លាស់ និងត្រឹមត្រូវនៃបញ្ញត្តិអ្វីមួយស្របតាមសមត្ថភាពគិតរបស់សិស្ស"* (Magrini, 2018; Gordon, 2009)។

### ១១.២.៤ ចន ឌូវី (John Dewey, ១៨៥៩-១៩៥២)

ចន ឌូវី (John Dewey, ១៨៥៩-១៩៥២) ត្រូវបានឱ្យតម្លៃ និងផ្តល់ងារជាទស្សនវិទូ និងជាបិតាអប់រំ នៃប្រជាជនអាមេរិក។ ចន ឌូវី ចាត់ទុកទស្សនវិជ្ជាអប់រំជាមធ្យោបាយមួយ សម្រាប់កែទម្រង់សង្គម។ ការកែទម្រង់សង្គមរបស់ ចន ឌូវី សំដៅដល់ការកែប្រែពិភពលោកឱ្យវិលពីសង្គ្រាម ជម្លោះ និងជំងឺ ទៅជាពិភពលោកមួយថ្មី ពោរពេញដោយមនុស្សធម៌ យុត្តិធម៌ និងប្រជាធិបតេយ្យ។

### ១១.២.៥ ប៊ឺរ៉ឺហ៊ុស ហ្វ្រេដឺរិក ស្គីណឺ (Burrhus Frederic Skinner, ១៩០៤-១៩៩០)

ស្គីណឺ (Skinner, ១៩៧៤) សរសេរទ្រឹស្តីអប់រំមួយហៅថា អាកប្បកិរិយានិយម (Behaviouralism)។ ទ្រឹស្តីនេះពន្យល់អំពីគោលការណ៍មួយថា ការរៀនចេះ ចាំ គឺអាស្រ័យលើការប្តូរអាកប្បកិរិយា។ សិស្សរៀនចេះ ចាំ និងយល់ លុះណាកញ្ចប់ព័ត៌មានធំ ត្រូវបានបំបែកឱ្យតូចៗ ដើម្បីឱ្យប្រព័ន្ធខួរក្បាលចងចាំងាយចាប់យកងាយ។ សិស្សរៀនចេះ ចាំ និងយល់ លុះណា ធាតុនៃព័ត៌មានដែលត្រូវរៀន មានភាពស្រដៀង ឬភ្ជាប់នឹងអ្វីដែលអ្នករៀនធ្លាប់ឆ្លងបទពិសោធ។ សិស្សរៀនចេះ ចាំ និងយល់ លុះណា ដំណើរការរៀន ដឹកនាំសិស្សឱ្យធ្វើត្រាប់តាមទន្ទេញចាំ និងសូត្ររត់មាត់។

### ១១.២.៦ ឡេវ វីហ្គុតស្គី (Lev Vygotsky, ១៩៧៨)

ឡេវ វីហ្គុតស្គី (Lev Vygotsky, ១៩៧៨) សរសេរទ្រឹស្តីអប់រំមួយហៅថា ស្ថាបនានិយម (Constructivism)។ ឡេវ វីហ្គុតស្គី ពន្យល់ថា សិស្សរៀនចេះ ល្គឹកណា សិស្សរៀនទទួលបានចំណេះដឹង ឬគ្រូបង្រៀនដឹកនាំសិស្សរៀនឱ្យចេះ លុះ

ណាសិស្សចេះសម្រប និងភ្ជាប់ព័ត៌មានបានថ្មីពីដំណើរការរៀនឱ្យស៊ីគ្នាជាមួយនឹងបទពិសោធ។

### ១១.២.៧ ដេវីដ ខូប (David A. Kolb, ១៩៣៩-បច្ចុប្បន្ន)

ដេវីដ ខូប (Kolb, ឆ្នាំ១៩៨៤) បានសរសេរទ្រឹស្តីអប់រំមួយហៅថា ពិសោធន៍និយម (Experientialism)។ ដេវីដ ខូប ពន្យល់ថា គ្រូបង្រៀនដឹកនាំសិស្សឱ្យរៀនចេះ ល្អិកណាគ្រូបង្រៀនប្រើបទពិសោធរបស់សិស្ស និងដឹកនាំសិស្សឱ្យពិសោធបញ្ញត្តិដែលបានរៀន និងកំពុងរៀន ជាមួយបទពិសោធក្នុងជីវភាពប្រចាំថ្ងៃ។

## ១២. គ្រូបង្រៀនពូកែ

គ្រូបង្រៀនសម្រាប់សិស្សក្នុងសតវត្សរ៍ទី២១ និងយុគឧស្សាហកម្ម៤.០ ត្រូវមានគុណសម្បទាច្រើនបែបច្រើនយ៉ាង។ បន្ថែមពីលើគុណសម្បទាសតវត្សរ៍ទី២១ គុណសម្បទាពលរដ្ឋសកល គុណតម្លៃមនុស្ស និងចរណមនុស្ស គ្រូបង្រៀន ត្រូវយល់អំពី ១. បរិបទសិស្ស ២. ការរៀនបន្តជាមួយសិស្ស។

### ១២.១ បរិបទសិស្ស

- គ្រូបង្រៀនយល់បរិបទសិស្ស សំដៅដល់គ្រូបង្រៀនដែលដឹកនាំសិស្សឱ្យរៀនក្នុងថ្នាក់ និងក្រៅថ្នាក់មានប្រសិទ្ធភាព។ ការយល់អំពីបរិបទសិស្ស សំដៅដល់ការយល់អំពីសាវតារ តម្រូវការ ទម្លាប់ និងឥរិយាបថរបស់សិស្ស។ ក្នុងបរិបទនៃការរៀននៅកម្ពុជា សិស្សខ្លះមិនអាចរៀន ឬធ្វើកិច្ចការសាលានៅផ្ទះបាន។ ចំណែកគ្រូបង្រៀនចង់ឱ្យសិស្សចេះ គ្រូបង្រៀនត្រូវបង្ខំសិស្សឱ្យធ្វើកិច្ចការសាលាកាន់តែច្រើន។ គ្រូបង្រៀនខ្លះខឹងសិស្សមិនធ្វើកិច្ចការ និងមិនដាក់កិច្ចការឱ្យគ្រូបង្រៀនកែ។ គ្រូបង្រៀនមួយចំនួនដាក់ទណ្ឌកម្មសិស្ស។ ការធ្វើបែបនេះកាន់តែបង្កបញ្ហាផ្លូវចិត្តដល់សិស្សដែលមានបញ្ហាកាន់តែខ្លាំង។ សិស្សអាចបោះបង់ការសិក្សា។ សិស្សអាចបាត់បង់អារម្មណ៍ចង់រៀនបន្ត។

- គ្រូបង្រៀនដែលមិនយល់បរិបទសិស្ស អាចបង្ខំសិស្សកាន់តែច្រើន និងកាន់តែខ្លាំង។ របកគំហើញ នៃការស្រាវជ្រាវជាច្រើនពន្យល់ថា ការរៀនពិតប្រាកដពុំអាចកើតឡើង ដោយបង្ខំបានទេ។ ការបង្ខំសិស្សឱ្យធ្វើកិច្ចការសាលា លើសពីការពិតនៃការធ្វើបានរបស់សិស្សគឺបង្កភាពភ័យខ្លាច។ គ្រូបង្រៀនត្រូវយល់ មិនមែនត្រឹមដឹង អំពីដើមហេតុដែលសិស្សមិនធ្វើកិច្ចសាលាទេ។ គ្រូបង្រៀនត្រូវរកដំណោះស្រាយផ្សេង និងក្រៅពីបង្ខំ ដើម្បីឱ្យសិស្សនោះមានចំណាប់អារម្មណ៍ធ្វើកិច្ចសាលាដូចសិស្សផ្សេង។
- ការគ្រប់គ្រងដំណើរការរៀនក្នុងថ្នាក់ និងក្រៅថ្នាក់ អាចជាកិច្ចការលំបាក បន្ទុកធ្ងន់ និងបន្ថែមលើការងារបង្រៀនរបស់គ្រូបង្រៀន។ ជាពិសេស ការគ្រប់គ្រងដំណើរការរៀនជាមួយសិស្សរៀនយឺត រៀនខ្សោយ ឬសិស្សមានតម្រូវការពិសេស ជាការលំបាករបស់គ្រូបង្រៀនមួយជាន់ទៀត។ ការយល់បរិបទសិស្ស រួមចំណែកកាត់បន្ថយបន្ទុក និងការលំបាករបស់គ្រូបង្រៀនបានមួយចំណែក។ ឧទាហរណ៍ សិស្សរៀនខ្សោយ ឬរៀនយឺតចូលចិត្តរៀនជាមួយសិស្សពូកែ ឬជាមួយមិត្តភក្តិជិតដិតបំផុត ក្នុងថ្នាក់។ គ្រូបង្រៀនអាចឱ្យសិស្សពូកែជួយសិស្សរៀនយឺតមួយនាក់ លើបញ្ញត្តិអ្វីមួយតាមបរិបទ និងលក្ខខណ្ឌដែលសិស្សពូកែ ឬមិត្តភក្តិអាចជួយ។ ការជួយគ្នាបែបនេះ អាចបណ្តុះទម្លាប់ចង់រៀន។
- ការយល់អំពីទម្លាប់ តម្រូវការ និងឥរិយាបថផ្សេងគ្នារបស់សិស្ស ជាធាតុមួយជួយដល់ការដឹកនាំការរៀន ឱ្យសិស្សចូលរួមយ៉ាងសកម្មក្នុងថ្នាក់។ ការប្រើទម្លាប់របស់សិស្សក្នុងដំណើរការរៀន អភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង។ សិស្សមួយនាក់មានទម្លាប់និយាយលេងច្រើន និងរៀនខ្សោយ ឬរៀនយឺត។ គ្រូបង្រៀនអាចដឹកនាំសិស្សនោះ ឱ្យសរសេរនូវអ្វីដែលសិស្សនោះចូលចិត្តនិយាយដោយក្តីពេញចិត្ត និងមិនបង្ខំ។ ការប្រែក្លាយពីទម្លាប់និយាយមក

ជាទម្លាប់សរសេរ សំដៅអភិវឌ្ឍបំណិនសរសេរ និងរៀបចំគំនិតតាមសំណេរ។ ក្នុងដំណាក់កាលដំបូង គ្រូបង្រៀនកុំខ្វល់អំពីកំហុស ឬភាពល្អឥតខ្ចោះនៃសំណេររបស់សិស្ស។ គ្រូបង្រៀនខ្វល់តែអំពីការសរសេរ ទោះតិចក្ដី ឬច្រើនក្ដី។

- ការស្ដីបន្ទោស ទណ្ឌកម្ម ការធ្វើឱ្យសិស្សខ្មាស និងដេញសិស្សចេញពីបន្ទប់រៀន ដោយសារទម្លាប់ ឬឥរិយាបថខុសពីការចង់បានរបស់គ្រូបង្រៀន ជាការបំបាក់ទំនុកចិត្តសិស្ស។ ការផ្ដល់ឱកាសឱ្យសិស្សរៀនយឺត ឬសិស្សចូលចិត្តនិយាយច្រើន ប៉ុន្តែមិនចូលចិត្តសរសេរ ឬមិនចង់សរសេរ ចាប់ផ្ដើមសរសេរជាការលំបាក។ អ្នកគ្រូ លោកគ្រូអាចចាប់ផ្ដើម ពីការសរសេរគំនិតជាប្រយោគខ្លីៗ ប៉ុន្តែកុំចប់ត្រឹមសរសេរ។ អ្នកគ្រូ លោកគ្រូត្រូវឱ្យសិស្សនោះរកដៃគូ ឬមិត្តរួមថ្នាក់ផ្ដល់យោបល់ និងកែលម្អប្រយោគរបស់គាត់ និងបន្ថែមយោបល់កែលម្អទៅលើការសរសេររបស់គាត់។

## ១២.២ ការរៀនបន្តជាមួយសិស្ស

- មនុស្សមិនជឿនលឿន គឺមិនចង់រៀនសូត្រពីមនុស្សដទៃ មិនចង់ស្ដាប់គំនិតអ្នកដទៃ និងមិនហ៊ានចាប់ផ្ដើមប្រតិបត្តិវិជ្ជាថ្មីទទួលបានពីអ្នកដទៃ។ មនុស្សទូទៅពិបាកនឹងទទួលយកគំនិតថ្មី ចម្លែកគំនិតផ្ទុយ ឬគំនិតខុសពីខ្លួន។ ដូច្នេះ គ្រូបង្រៀនអាចនឹងពិបាកទទួលយកគំនិតថ្មី ចម្លែកៗ និងគំនិតផ្ទុយរបស់សិស្សថែមទៀត។
- គ្រូបង្រៀនច្រើនសន្មតថា គ្រូបង្រៀនមានចំណេះដឹងច្រើនជាង និងច្បាស់លាស់ជាងសិស្សគ្រប់រឿង។ គ្រូបង្រៀនមានបទពិសោធជីវិតយូរអង្វែងជាង បានបង្រៀនច្រើនឆ្នាំ និងបានរៀនខ្ពង់ខ្ពស់ជាងសិស្ស។ល។ និយាយសាមញ្ញថា គ្រូបង្រៀនបានបើកភ្នែកឃើញពន្លឺព្រះអាទិត្យមុន ស្គាល់ពិភពលោកច្រើនជាងសិស្ស និងស្គាល់ផ្លូវច្បាស់ជាងសិស្ស។

- គ្រូបង្រៀនដែលមានចិត្តទូលាយ និងទទួលយកការទិតៀន គំនិតប្លែកៗ និងគំនិតផ្ទុយរបស់សិស្សជាគុណតម្លៃមួយរបស់គ្រូបង្រៀនពូកែ។ គ្រូបង្រៀនពូកែបានលើកទឹកចិត្តសិស្សឱ្យប្រមូលព័ត៌មានកាន់តែច្រើន អភិវឌ្ឍចំណេះដឹង និងវិជ្ជា សម្រាប់ប្រើប្រាស់ ក្នុងការរៀនបន្ត និងសម្រាប់ជីវភាពប្រចាំថ្ងៃ។ គ្រូបង្រៀនដែលមានចិត្តទូលាយ ច្រើនបង្កបរិយាកាសឱ្យសិស្សពង្រីកសមត្ថភាពឆ្លល់គិត បង្កើតសំណួរ សួរ និងរកព័ត៌មាន ឬស្វែងចំណេះដឹងថ្មីពីច្រើនប្រភព។ គ្រូបង្រៀនចិត្តទូលាយច្រើនផ្តល់ឱកាសឱ្យសិស្សចែករំលែកចំណេះដឹងសម្បូរបែប ក្នុងថ្នាក់។
- ថ្នាក់រៀននៃយុគឧស្សាហកម្ម៤.0 ត្រូវការគ្រូបង្រៀនប្រតិបត្តិសេចក្តីពិតនៃការរៀនបន្តពេញមួយជីវិត។ គ្រូបង្រៀនពុំមែនដឹង ចាំចេះ និងយល់អ្វីៗគ្រប់យ៉ាង និងពូកែជ្រៅជ្រះជាងសិស្សគ្រប់យ៉ាងទេ។ គ្រូបង្រៀនត្រូវត្រៀមខ្លួន និងប្រតិបត្តិទម្លាប់រៀនបន្តជាមួយសិស្ស និងរៀនពីសិស្សជាប្រចាំ។ ក្នុងយុគបច្ចេកវិទ្យាព័ត៌មានសិស្សអាចសួរកញ្ញា Google ឬបុរសសង្ហា Youtube ក្នុងមួយនាទី ឱ្យតែសិស្សស្គាល់ពាក្យបច្ចេកទេសជាភាសាអង់គ្លេសមួយពាក្យ។ បច្ចុប្បន្ន និងថ្ងៃអនាគតអន្តរបណ្តាញអ៊ិនធឺណេតនឹងសម្បូរឯកសារភាសាខ្មែរជាមិនខាន។
- ឥឡូវ សូមអ្នកគ្រូ លោកគ្រូសួរខ្លួនឯងមួយសំណួរ។ តើមេរៀនអ្វីខ្លះក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលមិនមានក្នុង Google ឬ Youtube? គ្រូបង្រៀនអាចសួរសិស្សខ្លួនឯងមួយសំណួរទៀត។ តើសិស្សពេញចិត្តរៀនពី Youtube ជាង ឬពេញចិត្តរៀនពីគ្រូបង្រៀនផ្ទាល់ជាង ក្នុងមេរៀនខ្លះដែរឬទេ?
- មេរៀនប្រវត្តិវិទ្យាមួយ អំពីមនុស្សសំខាន់ៗ ក្នុងប្រវត្តិសាស្ត្រនៃចក្រភពក្រិកបុរាណ កាលពីជាង៣០០ឆ្នាំ មុនគ្រិស្តសករាជ ដូចជាពីតាហ្គ័រ (Pythagoras) ឬ អាឡិចហ្សង់មហារាជ (Alexander the

Great)។ សិស្សពិតជាអាចរកព័ត៌មានបានច្រើនបែបច្រើនយ៉ាង និងចែករំលែកជាមួយសិស្ស និងគ្រូបង្រៀនក្នុងថ្នាក់រៀនទាំងមូល អំពីមនុស្សសំខាន់ៗទាំងពីរនាក់នេះជាមិនខាន។

- គ្រូបង្រៀនបើកចិត្តរៀនបន្តជាមួយសិស្ស ជាគុណសម្បទាមួយរបស់គ្រូបង្រៀនពូកែ។ ការរៀនបន្តជាមួយសិស្ស គឺប្រៀបប្រដូចនឹងការធ្វើដំណើរផ្សងព្រេងមួយលើក ក្នុងព្រៃជាមួយគ្នា រវាងគ្រូបង្រៀន និងសិស្ស។ ក្នុងឱកាសផ្សងព្រេងបែបនេះ សិស្សពិតជាមានឱកាសរកផ្លូវ និងសង្កេតធម្មជាតិដោយខ្លួនឯង។ គ្រូបង្រៀនក៏ត្រូវប្រតិបត្តិទម្លាប់រៀនពីសិស្ស នូវអ្វីដែលសិស្សសង្កេត ឬរកឃើញថ្មីផងដែរ។
- របកគំហើញនៃការស្រាវជ្រាវរបស់ Ganza (2008), Kidman & Casinader (2017), Coffman (2013), Blessinger & Cafora (2014) និង Krauss & Boss (2013) ពន្យល់ថា គ្រូបង្រៀនមានចិត្តទូលាយតែងផ្តល់ឱកាសច្រើនឱ្យសិស្ស គិត ឆ្លើយ បង្កើតសំណួរ សួរ រកព័ត៌មាន និងស្វែងការពន្យល់ដោយឯករាជ្យ។ ដូច្នេះ ទាំងសិស្សរៀនខ្សោយ រៀនយឺត ឬសិស្សអសកម្ម នឹងមានឱកាសបញ្ចេញគំនិត ឆ្លើយ និងសួរសំណួរតាមសមត្ថភាពគិត។ ដូច្នេះ ការរៀនពិតប្រាកដនឹងកើតមានឡើង សម្រាប់សិស្សទាំងអស់ដែលអង្គុយរៀនក្នុងថ្នាក់ជាមួយគ្នា។

## ១៣. វិជ្ជានុក្រមប្លូម (BLOOM) និងរចនាសម្ព័ន្ធនៃពុទ្ធិ

Benjamin BLOOM (1956) បានបង្កើតតារាងមួយហៅថា វិជ្ជានុក្រមប្លូម (BLOOM)។ Anderson, Krathwohl, & Airasian (2001) បានកែសម្រួលតារាងវិជ្ជានុក្រមនេះ ឱ្យមាន៦កម្រិត នៃសមត្ថភាពគិតដូចតារាងវិជ្ជានុក្រមដើម BLOOM (1956)។ Anderson, Krathwohl, & Airasian (2001) បានលើកតម្កើងសមត្ថភាព

គិតដល់កម្រិតខ្ពស់បំផុត ដល់កម្រិតបង្កើតថ្មី។ Anderson, Krathwohl, & Airasian (2001) បានប្ដូរទម្រង់នៃការសរសេរពីនាមស័ព្ទ ទៅជាទម្រង់កិរិយាសព្ទ។

ការប្រើទម្រង់សរសេរជាកិរិយាសព្ទ សំដៅបញ្ជាក់អំពីលំនាំនៃចិត្ត និងបំណិនធ្វើកើត ធ្វើបាន និងសម្រេចបានជាផលឱ្យមានជាបទពិសោធ។

### ១៣.១ វិជ្ជានុក្រម ប្លូម (BLOOM)

ប្រាជ្ញាភិវឌ្ឍន៍ សំដៅដល់សេចក្ដីប្រឹងប្រែង ឬព្យាយាមដើម្បីចម្រើនបញ្ញា។

វិជ្ជានុក្រមប្លូមជាកម្រិត និងប្រភេទ នៃសមត្ថភាពគិតរបស់អ្នកសិក្សា។ Benjamin BLOOM (1956) កំណត់ប្រភេទ និងបែងចែកកម្រិតនៃសមត្ថភាពគិត ឬវិជ្ជានុក្រមជា៦កម្រិត គឺការចេះដឹង ការយល់ ការប្រតិបត្តិ ការវិភាគ ការសំយោគ និងការវាយតម្លៃ ដោយសរសេរជាទម្រង់នាមស័ព្ទ។ Anderson, Krathwohl, & Airasian (2001) បានកែសម្រួលរបកគំហើញ នៃការស្រាវជ្រាវរបស់ប្លូម BLOOM (1956)។ ការប្ដូរកញ្ចប់នៃវិជ្ជានុក្រមប្លូម (BLOOM) ដែលអ្នកសិក្សាត្រូវទទួលបាន និងអភិវឌ្ឍបន្ថែម ក្នុងគ្រប់ដំណាក់កាលនៃដំណើរការរៀន ដើម្បីមានប្រាជ្ញាភិវឌ្ឍន៍។ Anderson, Krathwohl, & Airasian (2001) លើកតម្កើងកម្រិត នៃសមត្ថភាពគិតរបស់មនុស្ស ពីចាំ យល់ ប្រតិបត្តិ វិភាគ វាយតម្លៃ រហូតបង្កើតថ្មី។

ការបង្កើតតារាងវិជ្ជានុក្រមប្លូម (BLOOM) សំដៅបែងចែកកម្រិតសមត្ថភាពគិត និងរៀនជាបីប្រភេទ ៖ ១. ដាំបណ្ដុះចំណេះដឹង និងវិជ្ជា ២. ដាំបណ្ដុះអារម្មណ៍ និងចិត្ត ៣. ដាំបណ្ដុះបំណិន។ សៀវភៅនេះសំយោគលទ្ធផលនៃការស្រាវជ្រាវរបស់ប្លូម (BLOOM) (1956) គម្ពីរព្រះត្រៃបិដក និងការស្រាវជ្រាវជាច្រើនទៀត ដោយបង្កើតបានរចនាសម្ព័ន្ធនៃពុទ្ធិមួយ។

រូបភាព០៧. វិជ្ជានុក្រម BLOOM




ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២០

### ១៣.២ រចនាសម្ព័ន្ធនៃពុទ្ធិ

រចនាសម្ព័ន្ធនៃពុទ្ធិបែងចែកជាកញ្ចប់ និងកម្រិតតាម ១. ព័ត៌មាន ២. ចំណេះដឹង ៣. វិជ្ជា ៤.បញ្ញា។ មនុស្សបានរៀន និងពង្រីកពុទ្ធិ តាមរយៈការរៀនផ្លូវការ ក្រៅផ្លូវការ ឬមិនផ្លូវការ ពីគ្រប់កន្លែង កាល និងបរិបទ។

រូបភាព០៨. រចនាសម្ព័ន្ធនៃពុទ្ធិ




ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២០

១៣.២.១ វិញ្ញាណ និងណឺរ៉ូន

មនុស្សចាំបាច់ត្រូវប្រើធម្មជាតិនៃចិត្ត ដើម្បីរៀនឱ្យបង្កើតបានជាពុទ្ធិ។ ធម្មជាតិនៃចិត្តមនុស្ស គឺវិញ្ញាណទាំង៥ ដែលទទួលខុសត្រូវប្រមូលទិន្នន័យចូល ពីប្រភពក្រៅ។ ទិន្នន័យទទួលតាមរយៈវិញ្ញាណទាំង៥ ចូលតាមមនោ ទៅរក្សាក្នុងចិត្ត និងវិញ្ញាណ។ សរសេរជាភាសាសាមញ្ញ ភ្នែកមើល ត្រចៀកស្តាប់ ច្រមុះហិតក្លិន អណ្តាតភ្លក់ និងកាយប៉ះ ដើម្បីទទួលយក និងភ្ជាប់ជាមួយនឹងទិន្នន័យមានស្រាប់ រក្សាក្នុងចិត្ត និងវិញ្ញាណ សម្រាប់ប្រើការតាមកាល លក្ខខណ្ឌ និងបរិបទ។

វិញ្ញាណមាន៥ ៖
១. ចក្ខុវិញ្ញាណ
២. សោតវិញ្ញាណ
៣. ជិវ្ហាវិញ្ញាណ
៤. ឃានវិញ្ញាណ
៥. កាយវិញ្ញាណ

គម្ពីរព្រះត្រៃបិដកព្រះពុទ្ធសាសនា បញ្ជាក់ថា ប្រព័ន្ធនៃការទទួលព័ត៌មានមួយទៀត របស់មនុស្ស **ផស្សៈ**។ សៀវភៅនេះពុំចូលជ្រៅអំពីផស្សៈទេ។ ផស្សៈសំដៅដល់ការពាល់ត្រូវ ប៉ុន្តែលើសពីការប៉ះពាល់ដោយកាយ គឺប៉ះដោយមនោ ចិត្ត និងវិញ្ញាណ។

> ផស្សៈជាភាសាសំស្ក្រឹត និងបាលី សរសេរជាឡាតាំង phassa ឬ phasso។ ផស្សៈពុំមានន័យថា ប៉ះដោយអវយវៈកាយទេ។ ផស្សៈសំដៅដល់ការប៉ះ និងបង្កើតជាអារម្មណ៍ក្នុងកម្រិតណាមួយ នៃមនោ ចិត្ត និងវិញ្ញាណ។
>
> ប្រភព ៖ (wisdom library, 2008)

មនុស្សមួយនាក់ប្រមាថ និងជេរអ្នកថា *អាឆ្កែ*។ ត្រចៀករបស់អ្នកឮសំឡេងជេរ។ ភ្នែករបស់អ្នកមើលឃើញមាត់ជេរ។ ប្រសិនបើ អ្នកប្រតិកម្មតបវិញដោយវិការខឹង សម្ដីជេរ និងកាយវាយតប់អ្នកជេរនោះ មានន័យថាសម្ដីជេរ និងប្រមាថនោះបានប៉ះដល់មនោរបស់អ្នក។ ប្រសិនបើអ្នកបញ្ចេញវិការខឹង ប៉ុន្តែមិនប្រតិកម្មតប ដោយសម្ដីជេរវិញទេ មានន័យថា សម្ដីជេរនិងប្រមាថនោះ ប៉ះដល់ចិត្តរបស់អ្នក។ ប្រសិនបើអ្នកមិនបញ្ចេញវិការខឹង បែរជាសង្វេគដល់អ្នកជេរ និងតបដោយសម្ដីផ្អែម មានន័យថា សម្ដីជេរនិងប្រមាថនោះ មិនបានប៉ះដល់មនោ ចិត្ត និងវិញ្ញាណរបស់អ្នកទេ។ ចិត្តរបស់អ្នកបានទទួលការបណ្ដុះបណ្ដាល យ៉ាងពេញលេញ មិនប៉ះដោយការជេរប្រមាថទេ។ អ្នកគ្រប់គ្រងស្ថានការណ៍នៃអារម្មណ៍បានយ៉ាងប្រសើរ។

វិទ្យាសាស្ត្រខាងប្រព័ន្ធប្រសាទ ពន្យល់ថា ណឺរ៉ូនបំពេញភារកិច្ចទទួលរក្សា និងបែងចែកព័ត៌មាន។ ណឺរ៉ូនជាធាតុចម្បងនៃខួរក្បាល ឬហៅថាប្រព័ន្ធណឺរ៉ូន។ ប្រព័ន្ធណឺរ៉ូនទទួលព័ត៌មានពីខាងក្រៅតាមវិញ្ញាណទាំង៥ និងបែងចែកទៅតាមកោសិកានៃសរីរាង្គទាំងអស់ក្នុងរាងកាយ។ ការប្រាស្រ័យទាក់ទងគ្នានៃកោសិកាក្នុងប្រព័ន្ធណឺរ៉ូន បញ្ជាក់អំពីប្រភេទមនុស្ស។ ណឺរ៉ូនមានកោសិកាប្រហែល១០០០០០លាន សម្រាប់ប្រាស្រ័យទាក់ទងគ្នាបង្កើតជាចរិត និងទម្លាប់របស់មនុស្ស (Queensland Brain Institute, 2020)។

ដើម្បីឱ្យងាយគិត អ្នកគួរឆ្លើយសំណួរពីរ។ តើណឺរ៉ូនមានរាង ឬទម្រង់យ៉ាងដូចម្ដេច? តើណឺរ៉ូនមានដំណើរប្រព្រឹត្តទៅយ៉ាងដូចម្ដេច ដើម្បីឱ្យកោសិកាក្នុងរាងកាយទាក់ទងគ្នា? យើងសាកល្បងប្រៀបធៀបណឺរ៉ូនជាមួយនឹងដើមឈើមួយដើម។ ដើមឈើមានទាំងមែក ឬស និងគល់ ផ្កា និងផ្លែ។ មែក ឬស និងគល់មានតួនាទីផ្សេងៗគ្នា ដើម្បីឱ្យដើមឈើរស់ ដុះ លូតលាស់ និងមានផ្លែ និងផ្កា។ ចំណែកណឺរ៉ូនពុំមានអ្វីខុសពីដើមឈើដែរ។

១៣.២.២ មនោ ចិត្ត និងវិញ្ញាណ

អ្នកគ្រូ លោកគ្រូធ្លាប់ស្ដាប់ព្រះសង្ឃមួយអង្គទេសនាផ្ទាល់ ក្នុងវិទ្យុ ប្រព័ន្ធអន្តរបណ្ដាញអ៊ិនធឺណែត ឬប្រព័ន្ធទំនាក់ទំនងសង្គម។ អ្នកគ្រូ លោកគ្រូធ្លាប់ឮថា ចិត្តជាប្រធាន ចិត្តបង្កើតឥទ្ធិពលអស្ចារ្យគ្របដណ្ដប់លើវាសនារបស់ម្ចាស់នៃចិត្ត។ អានដល់ត្រឹមកន្លែងនេះ! តើអ្នកគ្រូ លោកគ្រូពិតជាទទួលស្គាល់ថា ចិត្តសំខាន់ មានឥទ្ធិពល និងដឹកនាំផ្លូវជីវិតទៅរកបរាជ័យ និងជោគជ័យឬទេ? តើអ្នកគ្រូ លោកគ្រូទទួលសេចក្ដីដឹងថា អ្នកគ្រូ លោកគ្រូត្រូវធ្វើដូចម្ដេច និងធ្វើអ្វីខ្លះដើម្បីប្រតិបត្តិចិត្ត ឬបណ្ដាលចិត្តឱ្យមានឥទ្ធិពលជួយដឹកនាំវាសនាជីវិត ទៅរកជោគជ័យ ពោរពេញដោយសុខ និងសម្ភារៈដែរឬទេ?

ប្រសិនបើបានស្ដាប់ដំបូង ចិត្តមិនចាប់ផ្ដើមឆ្ងល់ គិត បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់អំពីតួនាទីរបស់ចិត្ត អ្នកគ្រូ លោកគ្រូនៅតែមិនយល់ និងមិនប្រតិបត្តិចិត្ត ដើម្បីឱ្យចិត្តជួយដឹកនាំជីវិតទៅរកជោគជ័យដដែល។

ការរៀនមេរៀនក្នុងមុខវិជ្ជានានានៅសាលារៀន មនុស្សត្រូវប្រើធម្មជាតិនៃចិត្តទៅរៀន ដូចគ្នា គឺទទួលយកព័ត៌មានពីដំណើរការរៀន។ នៅពេលចិត្តទទួលខុសត្រូវឆ្ងល់ គិត បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ ម្ចាស់នៃចិត្តនឹងមានឱកាសបង្កើតបានពុទ្ធិក្នុងកម្រិតជ្រៅ និងសម្បូរបែបជាមិនខាន។

រូបភាព០៩. មនោ ចិត្ត និងវិញ្ញាណ




ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២០

១៣.២.៣ ពុទ្ធិ

គ្រូបង្រៀនកម្ពុជាគ្រប់រូបពិតជាធ្លាប់ឮ សរសេរ អាន និងប្រើពាក្យ **ពុទ្ធិ ព័ត៌មាន ចំណេះដឹង វិជ្ជា និងបញ្ញា** ញឹកញាប់ណាស់។ គ្រូបង្រៀនពិតជាមានចេតនាបង្រៀនសិស្ស និងរៀនដោយខ្លួនឯងឱ្យអភិវឌ្ឍពុទ្ធិដល់កម្រិតបញ្ញា។

បញ្ញាកើតចេញពីការប្រតិបត្តិ។ បញ្ញាកើតចេញពីការទម្លាក់ចោលការចេះដឹង និងបន្តអនុវត្ត។

ទោះបីជាយ៉ាងណា គ្រូបង្រៀនពុំទាន់មានឯកសារសម្បូរបែប វិភាគ វែកញែក រកភាពរួម ភាពដោយឡែក នានាភាព ពហុភាព និងទម្រង់នៃការប្រើពាក្យទាំងនេះឱ្យល្អិតល្អន់ទេ។ ការខ្វះខ្លាំង គឺការប្រើពាក្យទាំងនេះ ក្នុងការសរសេរ

កម្មវិធីសិក្សា គោលបំណង វត្ថុបំណង លទ្ធផលសិក្សាសម្រាប់កិច្ចតែងការ និង កម្មវិធីបណ្ដុះបណ្ដាលក្នុងបរិបទអប់រំ។

សូមលោកគ្រូ អ្នកគ្រូ សាកល្បងសួរខ្លួនឯងនូវសំណួរមួយចំនួន។ តើខ្ញុំឱ្យកូនរបស់ខ្ញុំរៀនដើម្បីទទួលបានពុទ្ធិ ត្រឹមកម្រិតព័ត៌មាន ចំណេះដឹង វិជ្ជា ឬត្រូវអភិវឌ្ឍឡើងហូតដល់ជម្រៅនៃបញ្ញា? ឆ្លើយនឹងសំណួរមួយនេះ តើពុទ្ធិជាអ្វី? ហើយពេលណាខ្ញុំមានពុទ្ធិ ប្រសិនបើខ្ញុំបានទាំងស្ដាប់ អាន សង្កេត និងពិសោធ?

ពុទ្ធិជាកញ្ចប់រួម និងជាបណ្ដុំនៃព័ត៌មាន ចំណេះដឹង វិជ្ជា និងបញ្ញា ទោះក្នុងកម្រិតណាមួយក៏ដោយ។ មនុស្សត្រូវទទួលបានពុទ្ធិ ឱ្យតែមនុស្សនោះបានចូលរួមក្នុងដំណើរការរៀន បើទោះបីរៀនផ្លូវការ ក្រៅផ្លូវការ ឬមិនផ្លូវការ ឬនៅកន្លែងណា ឬវេលាណាក៏ដោយ។

ក្រោយពីបានអានសៀវភៅចប់មួយក្បាល អំពីវិធីសាស្ត្រសិក្សាបញ្ញត្តិ។ តើយើងទទួលបានព័ត៌មាន ចំណេះដឹង វិជ្ជា ឬបញ្ញា? ក្រោយអានចប់ ប្រសិនបើទទួលបានត្រឹមព័ត៌មាន តើគ្រូបង្រៀនយកទៅប្រើការកើតដែរឬទេ? តើត្រូវធ្វើអ្វីបន្តទៀត ដើម្បីយកព័ត៌មានបានពីការអាន យកទៅប្រើ? តើអ្នកគ្រូ លោកគ្រូ ត្រូវប្រើព័ត៌មាននោះនៅពេលណា? តើព័ត៌មានបានពីការអានសៀវភៅនោះ អាចពិត ឬអាចមិនពិត អាចត្រូវឬមិនត្រូវ អាចច្បាស់ ឬមិនច្បាស់? ក្រោយពីបានអានសៀវភៅចប់ តើលោកគ្រូ អ្នកគ្រូ ត្រូវពង្រីកព័ត៌មានឱ្យទៅជាចំណេះដឹង វិជ្ជា ឬបញ្ញាដោយរបៀបណា? សៀវភៅនេះព្យាយាមឆ្លើយសំណួរទាំងនេះ ដើម្បីជាប្រយោជន៍នៃការគិតឆ្លុះ បង្កើតសំណួរសួរសំណួរ និងស្វែងការពន្យល់បន្តទៀត។

> ចិត្តមនុស្សតែងគិតទៅរកភ្ជាប់អ្វីដែលធ្លាប់ដឹង ឬទិន្នន័យចាស់។

ក្នុងយុគឧស្សាហកម្ម៤.០ ទម្រង់នៃការរៀន ដើម្បីបានព័ត៌មាន ចំណេះដឹង និងវិជ្ជា គឺសម្បូរបែបណាស់។ ឧទាហរណ៍ អ្នកគ្រូ លោកគ្រូ មើលវីដេអូ២នាទីក្នុង YouTube អំពីទម្លាប់រៀនរបស់សិស្សរៀនពូកែ។ អ្នកគ្រូ លោកគ្រូវាយអក្សរដោយបញ្ចូលពាក្យថា Learning Habits and Learning Styles អ្នកគ្រូ លោកគ្រូពិតជាឃើញវីដេអូជាច្រើនជាភាសាអង់គ្លេស។ បញ្ហានៅត្រង់ថា តើគ្រូ

បង្រៀនខ្មែរប៉ុន្មាននាក់ស្តាប់យល់អំពីការបង្រៀនក្នុងប្រព័ន្ធ YouTube ដោយប្រើភាសាអង់គ្លេស? តើគ្រូបង្រៀនខ្មែរប៉ុន្មាននាក់ទាញប្រយោជន៍ពី YouTube មកប្រើការកើត ក្នុងថ្នាក់រៀនជាមួយសិស្សក្នុងបរិបទកម្ពុជា ដែលសិស្សភាគច្រើនពុំចេះភាសាអង់គ្លេស?

ឧទាហរណ៍ គ្រូបង្រៀនត្រូវយកមេរៀនមួយអំពីសម័យហ្វូណន មកបង្រៀនសិស្ស។ គ្រូបង្រៀនឱ្យសិស្សអានមេរៀន ដោយប្រើយុទ្ធវិធីអានបន្តអានបណ្តាក់ និងអានប្រដេញ។ ចូរលោកគ្រូ អ្នកគ្រូសាកល្បងសួរខ្លួនឯងមួយសំណួរ! តើសិស្សបានទទួលអ្វីមុនដំបូង ពេលសិស្សមួយនាក់ៗអានចប់ និងបានស្តាប់ឮ តាមលក្ខខណ្ឌរបស់គ្រូបង្រៀន? គ្រូបង្រៀនប្រវត្តិវិទ្យា ពិតជាធ្លាប់ពិសោធរួចហើយ ប៉ុន្តែអាចមិនធ្លាប់គិតស៊ីជម្រៅ អំពីកម្រិតនៃការទទួលបានពុទ្ធិ។ គ្រូបង្រៀនអាចមិនធ្លាប់គិតលើសំណួរមួយនេះ។

ឧទាហរណ៍ ក្រោយឮការនិទានពីមាត់មួយទៅមាត់មួយ អំពីបន្ទាយលង្វែក និងបានចាំចំណុចមួយ។ ចំណុចងាយចាំជាងគេគឺ សៀមបានបាចប្រាក់ដួង បោកខ្មែរឱ្យកាប់ឫស្សី។ តើព័ត៌មានបានពីការឮបែបនេះអាចពិតឬមិនពិត ត្រឹមត្រូវឬមិនត្រឹមត្រូវ? ប្រសិនបើមានអត្ថបទអាន តើអ្នកគ្រូ លោកគ្រូយល់ថា អានចប់អត្ថបទអំពីបន្ទាយលង្វែក អ្នកគ្រូ លោកគ្រូទទួលបានចំណេះដឹង ឬទទួលបានព័ត៌មានអ្វីខ្លះ? តើព័ត៌មានបានពីអត្ថបទនេះ អាចពិត ឬមិនពិត អាចខុសឬអាចត្រូវ?

ដូច្នេះ ពុទ្ធិជាកញ្ចប់ និងកម្រិតនៃព័ត៌មាន ចំណេះដឹង វិជ្ជា និងបញ្ញាដែលមនុស្សបានរៀន និងអភិវឌ្ឍតាមរយៈការរៀនផ្លូវការ ក្រៅផ្លូវការ ឬមិនផ្លូវការពីគ្រប់កន្លែង បរិបទ និងកាល។

### ១៣.២.៤ ព័ត៌មាន

ជាទូទៅ ក្រោយបានអានចប់ ស្តាប់ឮ មើលឃើញ ហិតក្លិន ភ្លក្សឱជារស ឬស្ទាបវត្ថុ មនោ និងវិញ្ញាណទទួលផស្សៈ មនុស្សទទួលបានព័ត៌មានជាបឋម។ ព័ត៌មានអាចជានាមវត្ថុ និងរូបវត្ថុ។ រូបវត្ថុ និងនាមវត្ថុផ្សំផ្ទៃខាងលើ ដែលអ្នកសិក្សាត្រូវទទួលបានដំបូង យកមកចាំទុក ឬសម្គាល់ទុក។

ជាទូទៅ អ្នកសិក្សាចាំទុក ឬសម្គាល់ទុកនូវព័ត៌មាននៃរូបវត្ថុ ឬនាមវត្ថុមួយចំនួន ក្នុងខួរក្បាល (តាមវិទ្យាសាស្ត្រ) ឬក្នុងមនោ វិញ្ញាណ និងចិត្ត (តាមគម្ពីរបុរាណ)។ ព័ត៌មានទាំងអស់ចូលតាមរយៈ ភ្នែក ត្រចៀក អណ្តាត ច្រមុះ និងកាយប៉ះ។ ការចាំទុក ឬសម្គាល់ទុកជាចំណុចចាប់ផ្តើមនៃការរៀន។

ឧទាហរណ៍ គ្រូបង្រៀនឱ្យសិស្សមួយនាក់ អានអត្ថបទមេរៀនមួយអំពីបន្ទាយលង្វែក ដោយប្រើយុទ្ធវិធីអានបន្ត អានបណ្តាក់ និងអានប្រដេញ។ ព័ត៌មានដំបូងសិស្សអាចទទួលបាន គឺបំណែកតូចៗនៃអត្ថបទ ដូចជា ពាក្យគន្លឹះ អង្គហេតុ ភស្តុតាង និងព្រឹត្តិការណ៍។

ព័ត៌មានទទួលបានអាចភ្លេច ឬបាត់ប្រយោជន៍ទៅវិញ ប្រសិនបើបានអានចប់ ប៉ុន្តែគ្មានអ្វីត្រូវឆ្ងល់ និងគិត។ បំណែកនៃព័ត៌មានក្នុងរូបវត្ថុ និងនាមវត្ថុទទួលបានកាន់តែងាយភ្លេចទៅទៀត ប្រសិនបើសិស្សមិនបង្កើតសំណួរ មិនតាមសួរ និងរកការពន្យល់អំពីភាពពិត ច្បាស់លាស់ និងត្រឹមត្រូវ នៃព័ត៌មាន។ មនុស្សអាចសម្រេចចិត្តបានត្រឹមត្រូវ និងដោះស្រាយបញ្ហាប្រដោយយុទ្ធសាស្ត្រ និងនវកម្មគំនិត ដោយសំអាងលើភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃព័ត៌មាន។

ឧទាហរណ៍អំពីព្រឹត្តិការណ៍មួយកើតឡើងក្នុងថ្នាក់រៀនមួយ។ សិស្សប្រុសម្នាក់ស្រែកជេរសិស្សប្រុសមួយនាក់ទៀត។ **ពាន្សៃ**ជាសិស្សរៀនថ្នាក់ទី៨ សុភាព ស្លូត មិនចូលចិត្តនិយាយច្រើន។ **ពាន្សៃ** ជាមនុស្សគិតវែងឆ្ងាយ និងមិនចូលចិត្តឈ្លោះហិង្សា។ សិស្សរួមថ្នាក់ និងសិស្សថ្នាក់ផ្សេងដឹងថា **ហឹសា** ឆេវឆាវ និងប្រើកំហឹងដើម្បីស្រាយបញ្ហាជាញឹកញាប់ ក្នុងសាលារៀន។ វេលាមួយ **ហឹសា** ស្រែកជេរ**ពាន្សៃ**"អាឆ្កែ! ឯងនិយាយដើមអញ។ ឯងថាអញលួចបន្ទាត់**អាដា**?" **ពាន្សៃ**បានត្រឹមនិយាយថា "ខ្ញុំអត់ដឹងទេ។" រឿងកើតឡើងដោយសារ **ហឹសា**បានឮសម្តីមិត្តភក្តិម្នាក់ទៀតនិយាយប្រាប់អំពីរឿងបាត់បន្ទាត់។

**ហឹសា**អាចទទួលបានព័ត៌មានមិនពិត ឬពិត ត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ **ហឹសា** គ្រាន់តែឃើញមុខ**ពាន្សៃ**ភ្លាម ក៏ស្រែកជេរភ្លាម ដោយមិនបានគិត ឆ្ងល់ បង្កើតសំណួរ សួរ និងស្វែងការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាប់លាស់នៃព័ត៌មានទទួលបាន។

តើទង្វើរបស់**ហ៊ឹសា**បណ្ដាលមកពីការគិតខុស ឬខ្វះព័ត៌មាន? **ហ៊ឹសា**សម្រេចចិត្តខុស បានបង្កជម្លោះជាមួយសិស្សរួមថ្នាក់ឬយ៉ាងណា? ប្រសិនបើ**ហ៊ឹសា**ឆ្ងល់ គិត បង្កើតសំណួរ និងសួរ**ពាន់ឡៃ** ដើម្បីបញ្ជាក់ភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ ប្រហែលជាការបញ្ចេញកំហឹងមិនបានកើតឡើងបានទេ។

ដំណើរការរៀន សំដៅឱ្យសិស្សស្វែងភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃព័ត៌មាន។ ផ្ទៀងផ្ទាត់សេចក្ដីពិត ត្រឹមត្រូវ និងច្បាស់លាស់អំពីព័ត៌មានក្នុងសៀវភៅសិក្សាគោល ឬបានពីគ្រូរ៉ាយរ៉ាប់ រៀបរាប់ ពន្យល់ និងបកស្រាយ ទាមទារការរកភស្តុតាងពីច្រើនប្រភព។

ឧទាហរណ៍មួយទៀតអំពីវីរនារីសម័យហ្វូណន។ រូបភាពមួយផ្ទាំង មានរូបនារីរូបឆោមស្រស់ស្អាតមួយនាក់។ នារីរូបស្រស់នោះកាន់លំពែងមួយដើមក្នុងដៃ យ៉ាងស្វាហាប់។ នាងកំពុងប្រយុទ្ធជាមួយមនុស្សប្រុសជាច្រើននាក់ លើសំពៅមួយ។ គ្រូបង្រៀនផ្ដើមបកស្រាយរូបភាព។ រូបភាពនេះជាឆាកប្រយុទ្ធមួយរបស់ព្រះនាងលីវយី ក្នុងសម័យហ្វូណន។ សិស្សបានត្រឹមទទួលបំណែកខ្លះនៃព័ត៌មាន ក្នុងរូបភាព។

សិស្សបានត្រឹមឮពីគ្រូបង្រៀនបកស្រាយ រៀបរាប់ ពន្យល់ និងរ៉ាយរ៉ាប់។ ការរៀបរាប់មានដូចជា ព្រះនាងលីវយីក្លាហាន ស្វាហាប់ និងដឹកនាំទ័ព។ ដូច្នេះ សិស្សទទួលបានព័ត៌មានជាមុនតាមរយៈវិញ្ញាណ ត្រចៀកស្ដាប់សំឡេង និងភ្នែកមើលរូបភាព ប៉ុន្តែរូបភាពនោះពុំមែនជារូបភាពពិតទៀត។ បន្ទាប់មក ប្រសិនបើអ្នកស្ដាប់ជាសិស្សមានសមត្ថភាពឆ្ងល់ និងគិត ទោះកម្រិតទាបក្ដី ខ្ពស់ក្ដី សិស្សនោះប្រហែលជាត្រូវឆ្ងល់ គិត បង្កើតសំណួរ សួរសំណួរ ពាក់ព័ន្ធនឹងព័ត៌មានទទួលបានពីការស្ដាប់ និងការមើលរូប តាមកម្រិតសមត្ថភាពគិត។

> បានទទួលព័ត៌មានហើយ មិនយកព័ត៌មាននោះមកគិត ពិចារណា រកការពន្យល់លើភាគល្អិត ភាពពិត និងភាពត្រឹមត្រូវ ព័ត៌មាននោះនឹងក្លាយជាគ្មានប្រយោជន៍នៅពេលណាមួយ។

គ្រូបង្រៀនបង្ហាញរូបភាពមួយផ្ទាំង ឱ្យសិស្សមើល សិស្សទទួលព័ត៌មានតែមួយគត់ជាដំបូង គឺរូបភាព ប៉ុន្តែមិនទាន់ស្គាល់ធាតុលម្អិត នៃព័ត៌មានបង្កប់

ក្នុងរូបភាពទេ។ រូបភាពនោះអាចបង្កប់អត្ថន័យច្រើនទៀត។ សិស្សក៏មិនទាន់បានបំបែកឱ្យដាច់ និងរកមើលធាតុផ្សេងបង្កប់អត្ថន័យ ក្នុងរូបភាពនោះនៅឡើយទេ។ ដើម្បីប្រែក្លាយព័ត៌មានក្នុងរូបភាពឱ្យមានន័យ គឺក្លាយជាចំណេះដឹង គឺសិស្សត្រូវឆ្ងល់ គិត បង្កើតសំណួរ សួរ និងស្វែងការពន្យល់អំពីភាពពិត ភាពត្រឹមត្រូវ និងភាពច្បាស់លាស់នៃព័ត៌មានក្នុងរូបភាពនោះឱ្យបានច្រើនតាមលទ្ធភាព។

### ១៣.២.៥ ចំណេះដឹង

ក្នុងដំណើរការរៀនដំបូង អ្នកសិក្សាតែងទទួលបានព័ត៌មានជាមុន ស្គាល់ និងចាំទុកធាតុខ្លះ ភាគច្រើន ឬធាតុលម្អិតក្នុងព័ត៌មាន។ បន្ទាប់មក អ្នកសិក្សាត្រូវពង្រីកពីការចាំទុក និងសម្គាល់ទុកធាតុលម្អិតនៃព័ត៌មាន និងមុខងារនៃធាតុនីមួយៗ ទៅជាចំណេះដឹង។ ដើម្បីប្រែក្លាយពីព័ត៌មានទៅជាចំណេះដឹង អ្នកសិក្សាត្រូវរកព័ត៌មានពីច្រើនប្រភពបន្ថែម ដើម្បីផ្ទៀងផ្ទាត់ភាពពិត ភាពត្រឹមត្រូវ និងភាពច្បាស់លាស់នៃធាតុលម្អិតក្នុងព័ត៌មាន។

មានព័ត៌មាន មិនទាន់មានចំណេះដឹងទេ។ មានចំណេះដឹង គឺបានស្វែងភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃព័ត៌មានពីច្រើនប្រភពដែលគួរឱ្យទុកចិត្ត និងប្រើជាការបាន។ មានចំណេះដឹង គឺប្រមូលបានកញ្ចប់នៃធាតុផ្សំ ភាគលម្អិតក្នុងព័ត៌មានជាច្រើន បង្កប់ក្នុងកញ្ចប់ព័ត៌មាន ពីច្រើនប្រភព។ មានចំណេះដឹង សំដៅដល់ការស្គាល់មុខងារ តួនាទី និងរចនាសម្ព័ន្ធនៃធាតុផ្សំនីមួយៗក្នុងកញ្ចប់ព័ត៌មាន ស្របតាមលក្ខខណ្ឌ កាល និងបរិបទ។ មានចំណេះដឹង កើតឡើងដោយប្រើចិត្តយកទៅគិត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ពីច្រើនប្រភព។ មានចំណេះដឹង គឺបានបំបែកធាតុ រាប់បរិមាណ និងមុខងារ នៃធាតុលម្អិតបង្កប់ក្នុងព័ត៌មាន ឬសញ្ញាណដំបូង ឱ្យបានកាន់តែច្រើន។

ប្រសិនបើអ្នកសិក្សាបានត្រឹមតែស្តាប់ បានអានអត្ថបទ មើលរូបភាព ហើយមិនស្វែងការពន្យល់អំពីភាពត្រឹមត្រូវ ភាពច្បាស់លាស់ និងភាពពិតនៃធាតុលម្អិតៗ ឬមុខងារនៃធាតុលម្អិតបង្កប់ក្នុងព័ត៌មាននោះពីច្រើនប្រភពទេ ដំណើរការរៀនពិតប្រាកដនឹងមិនកើតឡើងឡើយ។ ព័ត៌មានដែលទទួលបាននោះក៏មិនអាចប្រែក្លាយឱ្យទៅជាចំណេះដឹងបានដែរ។

ចំណេះដឹងកើតឡើង នៅពេលសិស្សចាប់ផ្តើមឆ្ងល់ គិត បង្កើតសំណួរ សួរសំណួរ និងរកការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃព័ត៌មាន។ ចំណេះដឹងកើតឡើង នៅពេលសិស្សញែកព័ត៌មានពិតឬមិនពិត ពីច្រើនប្រភព

<table><tr><td>សេចក្តីដឹងរបស់មនុស្សពូកែ ពុំចាំបាច់មានភស្តុតាងវិទ្យាសាស្ត្រមកបញ្ជាក់ក៏អាចបង្កើតបានវិជ្ជាដែរ ព្រោះមនុស្សពូកែ អាចប្រើញាណប្បភាស។ ញាណប្បភាសសំដៅដល់សមត្ថភាពគិត ពន្យល់ ឬបកស្រាយ ដោយពុំចាំបាច់ពឹងភស្តុតាងវិទ្យាសាស្ត្រទេ។ ឧទាហរណ៍ ព្រះពុទ្ធប្រើញាណប្បភាស ពន្យល់ប្រាប់អំពីទុក្ខនៃសេចក្តីក្រោធ។ ក្នុងយុគឧស្សាហកម្មក្រោយៗ អ្នកវិទ្យាសាស្ត្រខាងវេជ្ជសាស្ត្រ បានពិសោធឃើញថា មនុស្សផ្ទុកទោសៈក្នុងចិត្ត តែងបញ្ចេញចិត្តក្រោធ មនុស្សនោះភាគច្រើនកើតជំងឺ ច្រើនមុខ ដូចជា មហារីក ជំងឺបេះដូង លើសឈាម ។ល។<br>Hendricks, Bore, Aslinia, & Morriss (2013)</td></tr></table>

លើសពីរូបភាពប្រាប់ និងពីគ្រូបង្រៀនរៀបរាប់ បកស្រាយ និងពន្យល់។

សិស្សដែលយកការស្តាប់ មើល ឬអាន មកគិត ឆ្ងល់ បង្កើតសំណួរ សួរ និងរកការពន្យល់អំពីភាពពិត ច្បាស់លាស់ និងត្រឹមត្រូវនៃធាតុល្អិតៗ និងមុខងារនៃធាតុនីមួយៗ បង្កប់ក្នុងកញ្ចប់ព័ត៌មាន សិស្សនោះនឹងប្រែក្លាយព័ត៌មានឱ្យទៅជាចំណេះដឹងពិតប្រាកដសម្រាប់ប្រើការតាមកាល បរិបទ និងលក្ខខណ្ឌ។

នៅពេលដំណើរការរៀនពិតប្រាកដកើតឡើង សិស្សអភិវឌ្ឍបំណិនឆ្ងល់ គិត បង្កើតសំណួរ សួរសំណួរ និងរកការពន្យល់អំពីភាពពិត ច្បាស់លាស់ និងត្រឹមត្រូវនៃព័ត៌មានទទួលបាន។ មានចំណេះដឹង សិស្សពិតជាអាចយកទៅចែករំលែកជាមួយសិស្ស និងមនុស្សដទៃបានជាប្រយោជន៍។

### ១៣.២.៦ វិជ្ជា

មានចំណេះដឹង មិនទាន់ដល់កម្រិតវិជ្ជានៅឡើយទេ។ មានវិជ្ជា គឺមានទាំងចំណេះដឹង និងបំណិន។ ការប្រែក្លាយចំណេះដឹងទៅវិជ្ជា អ្នកសិក្សាត្រូវភ្ជាប់ការដឹងដោយភស្តុតាងវិទ្យាសាស្ត្រ។ អ្នកសិក្សាមានវិជ្ជា មានន័យថា អ្នកសិក្សានោះមានសមត្ថភាពជ្រើសរើសធាតុលម្អិត និងវាយតម្លៃមុខងារនៃធាតុនីមួយៗបង្កប់ក្នុងចំណេះដឹង ដោយភ្ជាប់ភស្តុតាងវិទ្យាសាស្ត្រ។ មានវិជ្ជា គឺមានភាព

ច្បាស់លាស់ ពិត ត្រឹមត្រូវ និងពិតប្រាកដអំពីរបៀបយកធាតុលម្អិត និងមុខងារនៃធាតុលម្អិតនីមួយៗ ក្នុងចំណេះដឹងទៅអនុវត្ត និងចែករំលែកជាប្រយោជន៍ជាមួយមនុស្សច្រើនគ្នា។ ការប្រើធាតុលម្អិត និងមុខងារនៃធាតុលម្អិតបង្កប់ក្នុងចំណេះដឹងទៅអនុវត្ត គឺបំណិន។

មានវិជ្ជា គឺយល់ច្បាស់ ត្រឹមត្រូវ និងប្រាកដបែបវិទ្យាសាស្ត្រ អំពីលក្ខណវិនិច្ឆ័យ បច្ចេកទេស ទ្រឹស្តី វិធីសាស្ត្រ យុទ្ធវិធី គោលការណ៍ រចនាសម្ព័ន្ធ មុខងារ និងក្បួនពាក់ព័ន្ធ នឹងធាតុលម្អិតរបស់ចំណេះដឹងសម្រាប់ប្រតិបត្តិក្នុងជីវិត និងរំលែកជាប្រយោជន៍មនុស្ស។

ការរៀនប្រវត្តិវិទ្យា នឹងទាក់ទាញសេចក្តីពេញចិត្ត និងការចាប់អារម្មណ៍សិស្ស ប្រសិនបើ មេរៀនប្រវត្តិវិទ្យាភ្ជាប់នឹងជីវភាពប្រចាំថ្ងៃ។ ឧទាហរណ៍ ក្នុងមេរៀនសម័យអង្គរ ប្រសិនបើបង្រៀនសិស្ស ឱ្យផ្តោតការយកចិត្តទុកដាក់លើកាល ព្រឹត្តិការណ៍ អង្គហេតុ ឈ្មោះមនុស្ស និងទីកន្លែង សិស្សមិនសូវចាប់អារម្មណ៍រៀនទេ ហើយសិស្សខ្លះអាចធុញទ្រាន់នឹងមេរៀនទន្ទេញចាំមាត់។

ប្រសិនបើការរៀបចំមេរៀន និងដឹកនាំការរៀន ដោយផ្តល់ឱកាសឱ្យសិស្សភ្ជាប់ទំនាក់ទំនងនៃបញ្ញត្តិអំពីសេរីភាព និងជម្លោះក្នុងសម័យអង្គរ ជាមួយនឹងពុទ្ធិ ឬការចេះចាំរបស់សិស្សស្រាប់ និងភ្ជាប់ជាមួយជីវភាពប្រចាំថ្ងៃរបស់សិស្ស ដំណើរការរៀននឹងទាក់ទាញការចាប់អារម្មណ៍ និងចូលរួមយ៉ាងសកម្មរបស់សិស្សជាមិនខាន។

ដើម្បីបង្កើតបានជាវិជ្ជា មានន័យថា សិស្សត្រូវរកភស្តុតាងវិទ្យាសាស្ត្រមកពន្យល់។ ការរកភស្តុតាងវិទ្យាសាស្ត្រ និងប្រវត្តិសាស្ត្រ សិស្សចាំបាច់ត្រូវមានបុច្ឆនវិជ្ជា។ បុច្ឆនវិជ្ជាជាសិល្បៈ និងវិទ្យាសាស្ត្រនៃការឆ្ងល់ គិត បង្កើតសំណួរសួរសំណួរ និងស្វែងការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់។ ការឆ្ងល់ គិត បង្កើតសំណួរ សួរ និងស្វែងការពន្យល់ ត្រូវប្រើដោយខានពុំបានសម្រាប់ពង្រីកវិសាលភាពនៃគំនិត និងបន្ថែមជម្រៅនៃការគិត និងពុទ្ធិ។

ការឆ្ងល់ គិត បង្កើតសំណួរ សួរសំណួរ កែលម្អសំណួរ និងស្វែងការពន្យល់ ត្រូវបានប្រើគ្រប់ពេល ដើម្បីយកភស្តុតាងវិទ្យាសាស្ត្រមកវែកញែក វិភាគ

វិនិច្ឆ័យ និងជ្រើសរើស។ ការប្រើភស្តុតាងវិទ្យាសាស្ត្រមកពន្យល់ ជាដំណើរការបង្កើតវិជ្ជា សម្រាប់ការរៀនបន្ត ការងារ ជីវិត និងចែករំលែកជាមួយអ្នកដទៃ។

ចំពោះអ្នកសិក្សាដែលមានបំណិនគិត និងពិចារណាកម្រិតខ្ពស់ ឬមានសង្កប្បបំណិន តែងឆ្ងល់ គិត បង្កើតសំណួរ សួរ និងស្វែងការពន្យល់ អំពីភាពត្រឹមត្រូវ ច្បាស់លាស់ និងពិតនៃធាតុលម្អិតបន្តទៀត។

ឧទាហរណ៍ ដំណើរការថ្នាក់រៀនមួយបានផ្តោតការយកចិត្តទុកដាក់លើការអានអត្ថបទមួយអំពីកំណាយស្ថានីយ **អូរកែវ។** មុននឹងឱ្យសិស្សអាន គ្រូបង្រៀនបានរ៉ាយរ៉ាប់ រៀបរាប់ បកស្រាយ និងពន្យល់អំពីល្អាងកំណាយស្ថានីយអូរកែវ។ ប្រសិនបើសិស្សសន្និដ្ឋានអំពីអ្វីដែលគ្រូបង្រៀនបកស្រាយ រ៉ាយរ៉ាប់ រៀបរាប់ ឬពន្យល់ តាមអត្ថបទ និងតាមការចេះចាំរបស់គ្រូបង្រៀន សិស្សទទួលបានត្រឹមព័ត៌មានប៉ុណ្ណោះ។

ផ្ទុយទៅវិញ សិស្សអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង ប្រសិនបើគ្រូបង្រៀនដឹកនាំសិស្សឱ្យស្វែងការអានអត្ថបទស្រាវជ្រាវមួយ ឬច្រើនរបស់ប្រវត្តិវិទូ និងបុរាណវិទូ។ សិស្សមានឱកាសផ្ទៀងផ្ទាត់ភាពពិត ច្បាស់លាស់ និងត្រឹមត្រូវ នៃភស្តុតាងសរសេរក្នុងអត្ថបទសៀវភៅមេរៀន ជាមួយអត្ថបទស្រាវជ្រាវស្តីពីកំណាយនៃល្អាងស្ថានីយប្រវត្តិសាស្ត្រ។

ជាលទ្ធផល សិស្សនឹងបង្កើតបានវិជ្ជាជាប្រយោជន៍សម្រាប់ប្រតិបត្តិ និងចែករំលែកជាមួយមនុស្សដទៃ។ សិស្សអាចពង្រីកវិជ្ជាកាន់តែសម្បូរបែបកាន់តែស៊ីជម្រៅ ត្រឹមត្រូវ និងច្បាស់លាស់ លុះណាសិស្សបានទៅសិក្សានៅល្អាងស្ថានីយអូរកែវ និងផ្ទៀងផ្ទាត់ជាមួយខ្លឹមសារនៃឯកសារស្រាវជ្រាវពីច្រើនប្រភព របស់ប្រវត្តិវិទូ និងបុរាណវិទូបន្តទៀត។

### ១៣.២.៧ បញ្ញា

ពាក្យបញ្ញានេះមានការយល់ បកស្រាយ ពន្យល់ និងប្រើការផ្សេងៗគ្នាតាមបរិបទ។ គម្ពីរព្រះត្រៃបិដកភាសាខ្មែរ (Khmer Buddhism Institute , 1931) ឬ Dhammapada (wisdom library, 2008) ជាភាសាអង់គ្លេសពន្យល់ថា បញ្ញាកើតចេញពីការប្រតិបត្តិ និងការពិសោធ។ ការរៀនចេះចាំ ពុំបានយកទៅអនុវត្ត

បញ្ហាពុំទាន់កើតមានទេ។ ឧបមាថា ខ្ញុំសរសេរប្រយោគមួយថា *"ប្រសិនបើអ្នកចង់កើតជាបញ្ញា អ្នកត្រូវទម្លាក់ការចេះដឹងចោល"*។ ប្រយោគមួយនេះប្រហែលជាអ្នកគ្រូ លោកគ្រូ ពិបាកទទួលយកណាស់។ មនុស្សបានចំណាយដើមទន់ ពេលវេលា កាយ និងចិត្តដើម្បីរៀនតាមរយៈការស្តាប់ ការអាន ការមើល ការស្ទាប ការហិតក្លិន និងចំណាយពេលអស់យូរអង្វែងណាស់ ទើបកើតជាចំណេះដឹង។

ឧទាហរណ៍ មនុស្សគ្រប់រូបដឹងថា ហូបអាហារបំប៉នឱ្យច្រើន អ្នកនឹងមានកម្លាំង? ព្រោះចាប់ពីដឹងក្តី មនុស្សត្រូវប្រឹងហូបឱ្យច្រើន ដើម្បីមានកម្លាំង។ អ្នកសិក្សាដែលមានសមត្ថភាពគិតកាន់តែខ្ពស់ កាន់តែគិត កាន់តែឆ្ងល់ និងកាន់តែចង់រកការពន្យល់ អំពីភាពពិត ត្រឹមត្រូវ ច្បាស់លាស់ នៃការដឹងនេះ។ មនុស្សត្រូវស្វែងការពន្យល់ពីឯកសារស្រាវជ្រាវពីច្រើនប្រភព និងត្រូវពិសោធដោយខ្លួនឯង ទើបកើតជាបញ្ញា។

ក្នុងពេលមួយ មនុស្សម្នាក់ប្រាប់ថា ការបង្អត់អាហារ និងទឹកឱ្យបានយ៉ាងតិច៤៨ម៉ោង ក្នុងមួយខែម្តង ជួយដល់សុខភាព ពង្រឹកថាមពលពីក្នុងឱ្យមនុស្សកាន់តែមានកម្លាំង។ លើសពីនេះទៀត វិធីបង្អត់អាហារ និងទឹកបែបនេះជួយពន្យារអាយុ និងបន្ថយឱកាសកើតជំងឺ។ ចូរលោកគ្រូ អ្នកគ្រូ សាកល្បងសួរខ្លួនឯងមួយសំណួរ។ តើខ្ញុំត្រូវធ្វើតាម ឬមិនត្រូវធ្វើតាម ដែលខ្ញុំកំពុងឋិតក្នុងវ័យ៥០ឆ្នាំទៅហើយ?

ប្រសិនបើអ្នកគ្រូ លោកគ្រូបានពិសោធរួចហើយ ពិសេស មនុស្សក្នុងវ័យ៥០ឆ្នាំឡើង អ្នកគ្រូ លោកគ្រូនឹងបានលទ្ធផលមួយសម្រាប់ចែករំលែក។ ប្រសិនបើមិនបានពិសោធ ប៉ុន្តែបានបដិសេធចាប់ពីជំហានដំបូង អ្នកមិនអាចរកបញ្ញាឃើញទេ។ ក្នុងន័យនេះ អ្នកគ្រូ លោកគ្រូបានត្រឹមព័ត៌មាន ជាប់នឹងចិត្តរបស់ខ្លួន និងអាចភ្លេចនៅពេលណាមួយមិនខាន។ មនុស្សជាទូទៅពុំទាន់មានកូនចិត្តចង់ផ្លាស់ប្តូរទម្លាប់របស់ខ្លួនទេ នៅពេលគ្រាន់តែទទួលបានព័ត៌មាន។ ប្រហែលជាអ្នកគ្រូ លោកគ្រូមួយចំនួន កំពុងអានសៀវភៅនេះគិតថា ដាច់ខ្យល់ស្លាប់បាត់ហើយ អត់បាយអត់ទឹកមិនទាន់គ្រប់៤៨ម៉ោងផងមើលទៅ?

ក្រោយពីបានពិសោធដោយផ្ទាល់រួចហើយ អ្នកសិក្សាតែងរកឃើញអ្វីដែលថ្មី ឬបញ្ជាក់បន្ថែមលើការស្រាវជ្រាវ ឬការចេះដឹងមុនៗ។ លទ្ធផលនៃការពិសោធបញ្ជាក់បន្ថែម និងរកភស្តុតាងបន្ថែម ដើម្បីបញ្ជាក់អំពីទម្លាប់យល់ដឹងចាស់ ឬការខ្វះចន្លោះនៃចំណេះដឹងមុនៗ។ អ្នកសិក្សានោះ អាចបង្កើតបានរបកគំហើញថ្មីផ្សេងទៀត ឬបញ្ជាក់បន្ថែមលើភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃរបកគំហើញមុនៗ។ អ្នកសិក្សានោះបានកើតជាបញ្ញា សម្រាប់ប្រើការ និងចែករំលែកដល់អ្នកដទៃ។

ប្រយោគរួមមួយ ក្នុងគម្ពីរទស្សនវិជ្ជា Bhagavad Gita (Easwaran, 2020) និងគម្ពីរព្រះត្រៃបិដកព្រះពុទ្ធសាសនាសរសេរថា ឃ្លាំងនៃចិត្តផ្ទុកដោយទិន្នន័យបំពុលចិត្ត ទុក្ខរបស់មនុស្សនោះនឹងរត់តាមកាយ និងចិត្តមនុស្សនោះ ដូចគន្លងកង់រទេះសេះរត់តាមកង់រទេះសេះនោះដែរ។ ឃ្លាំងនៃចិត្តផ្ទុកដោយទិន្នន័យបំពុលចិត្ត ដូចជា ទោសៈ ឬក្រោធ មោហៈ និងរាគៈ ជំងឺតែងរត់តាមគន្លងនៃចិត្តជាប់រហូត។

ឧទាហរណ៍ មនុស្សដែលមានឃ្លាំងនៃចិត្តសម្បូរទោសៈ សូម្បីតែច្រលំដៃទុកសោម៉ូតូរកមិនឃើញដោយខ្លួនឯង ក៏បញ្ចេញកំហឹងដាក់ខ្លួនឯង និងឈ្លោះនឹងខ្លួនឯងដែរ។ សូម្បីទូរស័ព្ទដំណើរការយឺត ក៏ខឹងទូរស័ព្ទដែរ ទោះបីដឹងថា ចាំមួយសន្ទុះទូរស័ព្ទនឹងបើកដំណើរការធម្មតា។ ទោះបីដឹងថា ខឹងនឹងទូរស័ព្ទក៏មិនស្រាយបញ្ហាបាន។ មនុស្សមានឃ្លាំងនៃចិត្តផ្ទុកដោយទោសៈ ឬក្រោធ សូម្បីអ្នកជិតដិតប្រាប់ថា ការបញ្ចេញកំហឹងច្រើន នាំអ្នកឱ្យកើតជំងឺច្រើន ដូចជាលើសឈាម ជំងឺបេះដូង មហារីក ក៏ប្រតិកម្មខឹងចំពោះអ្នកប្រាប់ដែរ។

តើធ្វើដូចម្តេច និងធ្វើអ្វីខ្លះដើម្បីកើតបញ្ញា និងលះបង់ចិត្តទោសៈ?

របកគំហើញនៃការស្រាវជ្រាវបែបពិសោធន៍របស់ Hendricks, Bore, Aslinia, & Morriss (2013) បញ្ជាក់ថា មនុស្សមានកំហឹងច្រើនក្នុងចិត្ត មនុស្សនោះត្រូវប្រឈមនឹងបញ្ហាសុខភាព និងកើតជំងឺច្រើនមុខ។ ជំងឺរ៉ាំរ៉ៃកាយរបស់មនុស្សខឹងច្រើន ដូចជា ជំងឺបេះដូង លើសឈាម មហារីក ឬសរសៃប្រសាទ។ សៀវភៅនេះពុំបានយកឧទាហរណ៍ មកបញ្ជាក់អំពីមនុស្សកើតជំងឺដូចខាងលើ

ទេ។ ចូរ អ្នកគ្រូ លោកគ្រូសង្កេត និងសម្គាល់មនុស្ស មួយរយៈពេលយូរបន្តិច។ អ្នកគ្រូ លោកគ្រូនឹងរកភស្តុតាងមកបញ្ជាក់សេចក្តីពិតជាមិនខាន។

ចូរសាកល្បងរឿងសាមញ្ញមួយ! តើអ្នកគ្រូ លោកគ្រូធ្លាប់ខឹងនឹងខ្លួនឯង រឿងភ្លេចសោម៉ូតូ ឬខឹងរឿងផ្សេង ខឹងអ្នកប្រាប់ឱ្យយើងល្អឬទេ? អ្នកគ្រូ លោកគ្រូ សាកល្បង ៖

- អង្គុយដាក់ដងខ្លួនឱ្យត្រង់
- អង្គុយពែនភ្នែនខ្វែងជើង
- ដាក់ម្រាមជើងស្តាប់ក្នុងគន្លាក់ជើងឆ្វេង
- ដាក់ខ្នងដៃឆ្វេងផ្ងារលើជង្គង់ឆ្វេង
- ដាក់ខ្នងដៃស្តាំផ្ងារលើជង្គង់ស្តាំ
- ដកដង្ហើមវែងឱ្យបាន១៥ដង ឬចំណាយពេល៥នាទី
- សូត្រមន្តក្នុងចិត្តថា **ក្រោធបង្កទុក្ខ** ដល់កាយ ឱ្យកើតជំងឺ១៥ចប់។

អ្នកគ្រូ លោកគ្រូនឹងប្តូរចិត្តពីខឹងគ្រប់ពេលខុសចិត្ត មករស់ក្នុងសួននៃសុខជាមិនខាន។ ក្នុងន័យនេះ អ្នកគ្រូ លោកគ្រូនឹងបង្កើតបានបញ្ញា សម្រាប់ប្រតិបត្តិ និងចែករំលែកដល់សិស្ស និងមនុស្សដទៃជាមិនខាន អំពីសេចក្តីសុខដែលកើតចេញពីការរំលត់សេចក្តីក្រោធ។

ក្រោយពិសោធបាន៣លើក ចូរអ្នកគ្រូ លោកគ្រូ សួរខ្លួនឯងមួយសំណួរ។ តើកាយខ្ញុំ និងចិត្តខ្ញុំធូរស្បើយកម្រិតណា ប្រសិនបើធៀបនឹងការមិនទប់កំហឹង?

បញ្ញាកើតចេញពីការប្រតិបត្តិ និងទម្លាក់ចោលនូវការចេះដឹងមួយអន្លើ។ លោកគ្រូអ្នកគ្រូ សាកល្បងគិតបញ្ញត្តិមួយ ក្នុងមេរៀនប្រវត្តិវិទ្យា។ ក្រោយរៀនចប់មេរៀនប្រវត្តិវិទ្យាអំពីសម័យចតុមុខ សួរខ្លួនឯងមួយសំណួរ។ តើខ្ញុំប្រែក្លាយព័ត៌មានទទួលបានពីអត្ថបទទៅជាចំណេះដឹង ទៅជាវិជ្ជា និងទៅជាបញ្ញាយ៉ាងដូចម្តេច? ឧទាហរណ៍ មេរៀននេះបញ្ជាក់ថា ព្រះបាទ ចន្ទរាជា និងបរមេន្ទរាជា មានវីរភាពគួរឱ្យមនុស្សជំនាន់ក្រោយយកជាគំរូ។

ចំពោះមនុស្សដែលមានបំណិនគិតកម្រិតខ្ពស់ តែងចោទជាសំណួរ ៖

- តើធាតុលម្អិតពន្យល់អំពីវីរភាពមានអ្វីខ្លះ?

- តើធាតុនីមួយៗបញ្ជាក់ពីវីរភាពរបស់ព្រះបាទចន្ទរាជា អាចយកមកប្រតិបត្តិក្នុងសម័យកាលនេះបានឬទេ?
- តើខ្ញុំមានធាតុនៃវីរភាពអ្វីខ្លះ ក្នុងជីវិតខ្ញុំបច្ចុប្បន្ន?
- តើខ្ញុំត្រូវពង្រីកធាតុនៃវីរភាពដោយរបៀបណា?
- តើហេតុអ្វីខ្ញុំត្រូវពង្រីកធាតុនៃវីរភាពរបស់ខ្ញុំ?

ដំណើរការរៀនពិតប្រាកដ ឬរៀនប្រកបដោយគុណភាព សំដៅប្រែក្លាយចំណេះដឹងឱ្យទៅជាវិជ្ជា និងទៅជាបញ្ញា និង សំដៅដឹកនាំសិស្សឱ្យយកការចេះដឹងនេះទៅប្រតិបត្តិប្រចាំជីវិត សម្រាប់ការងារ និងរៀនបន្ត។

១៣.៣ ប្រតិបត្តិវិជ្ជានុក្រមប្លូម (BLOOM) និងរចនាសម្ព័ន្ធនៃពុទ្ធិ




Anderson, Krathwohl, & Airasian (2001) បំបែកប្រភេទ និងកម្រិត នៃវិជ្ជានុក្រមប្លូម (BLOOM) និងពន្យល់ភាពចាំបាច់សម្រាប់សរសេរលទ្ធផលសិក្សាកម្មវិធីសិក្សា កិច្ចតែងការបង្រៀន ការវាយតម្លៃការរៀន និងការបង្រៀន។

គ្រូបង្រៀនជាបេះដូង នៃដំណើរការដឹកនាំការផ្លាស់ប្តូរ។ ជាពិសេស គ្រូបង្រៀនដឹកនាំការប្រតិបត្តិសេចក្តីពិតជាប្រចាំ។ ដូច្នេះ គ្រូបង្រៀនគួរពិចារណា

អំពីការដឹកនាំការរៀន ឱ្យច្រើនជាងការបង្រៀនដែលលោកគ្រូ អ្នកគ្រូធ្លាប់ផ្តោតការយកចិត្តទុកដាក់លើការបកស្រាយ រ៉ាយរ៉ាប់ រៀបរាប់ និងពន្យល់។ ដើម្បីធានាឱ្យសិស្សអភិវឌ្ឍចំណេះដឹងឱ្យដល់កម្រិតវិជ្ជា និងជម្រៅនៃបញ្ញាដូចបង្ហាញ និងពន្យល់ ដោយមានឧទាហរណ៍ និងសំណួរពិចារណា ក្នុងតារាងខាង ៖

**តារាង ៖ ប្រតិបត្តិវិជ្ជានុក្រមប្លូម (BLOOM) និងពុទ្ធិ**

**ក. ព័ត៌មាន**

ធាតុផ្សំដំបូង មូលដ្ឋាន ឬផ្ទៃខាងលើនៃធាតុនានាដែលអ្នកសិក្សាត្រូវទទួលបានដំបូង យកមកចាំទុក និងសម្គាល់ទុក។ ជាទូទៅ អ្នកសិក្សាចាំទុក ឬសម្គាល់ទុកនូវរូបវត្ថុ ឬនាមវត្ថុមួយចំនួននៃអង្គហេតុ ឬព្រឹត្តិការណ៍ ក្នុងវិញ្ញាណ តាមរយៈភ្នែក ត្រចៀក អណ្តាត ច្រមុះ ឬរាងកាយ។ ការចាំទុក ឬសម្គាល់ទុកជាចំណុចចាប់ផ្តើមនៃការរៀនដំបូងបំផុត។

| ប្រភេទ និងកម្រិត | ឧទាហរណ៍ ធាតុនៃព័ត៌មាន |
|---|---|
| ក.១ ស្គាល់សញ្ញាណដំបូង<br>ក.២ ស្គាល់ធាតុនានា ក្នុងសញ្ញាណដំបូង<br>ក.៣ ស្គាល់ធាតុបន្ស៊ំបន្ថែម លើសញ្ញាណដំបូង | ▪ លង្វែក ជារាជធានីពិសិដ្ឋមួយរបស់ខ្មែរ<br>▪ រាជធានីលង្វែកកសាងដោយព្រះបាទចន្ទរាជា<br>▪ រាជធានីលង្វែក មានទីតាំងនៅខេត្តកំពង់ឆ្នាំងបច្ចុប្បន្ន<br>▪ ភូមិសាស្ត្រលង្វែកមានអំណោយផលសេដ្ឋកិច្ច<br>▪ សម័យលង្វែករីកចម្រើនគួរកត់សម្គាល់<br>▪ ព្រះបាទចន្ទរាជា ជាក្សត្រមានចក្ខុវិស័យអភិវឌ្ឍប្រទេស<br>▪ ព្រះបាទបរមេន្ទរាជា ជាស្តេចសឹកសង្គ្រាម<br>▪ លង្វែកដឹកនាំដោយព្រះបាទចន្ទរាជា<br>▪ ព្រះបាទចន្ទរាជា ដឹកនាំប្រទេសក្នុងឆ្នាំ ១៥១៦-១៥៦៦<br>▪ រាជការលង្វែកមានទំនាក់ទំនងជាមួយបរទេស ដូចជា អឺរ៉ុប<br>▪ បន្ទាយលង្វែកត្រូវបែកបាក់ ក្នុងឆ្នាំ ១៥៨៨<br>▪ ព្រះបាទចន្ទរាជា និងបរមេន្ទរាជា សាមគ្គីគ្នាស្តារប្រទេស<br>▪ ព្រះបាទចន្ទរាជា និងបរមេន្ទរាជា មានវីរភាពជាគំរូ<br>▪ មានទីកន្លែងសំខាន់ណាទៀត?<br>▪ មានអ្វីសំខាន់ផ្សេងទៀតដែលសិស្សត្រូវដឹងដំបូង? |

| | |
|---|---|
| **ខ. ចំណេះដឹង**<br>មានព័ត៌មាន មិនទាន់មានចំណេះដឹងទេ។ ការមានចំណេះដឹង គឺបានស្វែងភាពពិត ត្រឹមត្រូវ ឬច្បាស់លាស់នៃព័ត៌មានពីច្រើនប្រភពដែលគួរឱ្យទុកចិត្ត និងប្រើការបាន។ ការមានចំណេះដឹង គឺប្រមូលបានកញ្ចប់នៃធាតុផ្សំជាច្រើនបង្កប់ក្នុងកញ្ចប់ព័ត៌មានមូលដ្ឋានពីច្រើនប្រភព។ ការមានចំណេះដឹង គឺស្គាល់មុខងារ តួនាទី និងរចនាសម្ព័ន្ធនៃធាតុផ្សំនីមួយៗក្នុងកញ្ចប់ព័ត៌មាន ស្របតាមលក្ខខណ្ឌ កាល និងបរិបទ។ ការមានចំណេះដឹង គឺកើតឡើងដោយប្រើចិត្តយកទៅគិត ឆ្ងល់ បង្កើតសំណួរ សួរ និងរកការពន្យល់ពីច្រើនប្រភព។ មានចំណេះដឹង គឺបំបែកធាតុនានា និងបរិមាណនៃធាតុបង្កប់ក្នុងព័ត៌មាន ឬក្នុងសញ្ញាណដែលអ្នកសិក្សាទទួលបានក្នុងជំហានដំបូង។ ដើម្បីបានជាចំណេះដឹង សិស្សត្រូវឆ្លើយសំណួរមួយ។ តើព័ត៌មាននោះពិត ត្រឹមត្រូវ និងប្រើការបានកម្រិតណា? | |
| **ប្រភេទ និងកម្រិត** | **ឧទាហរណ៍** |
| ខ.១ ស្គាល់ប្រភេទ ចំណាត់ថ្នាក់ និងទម្រង់នៃធាតុក្នុងសញ្ញាណដំបូងនៃព័ត៌មាន តាមកាល លក្ខខណ្ឌ និងបរិបទ<br>ខ.២ ស្គាល់គោលការណ៍ និងភាពទូទៅនៃធាតុក្នុងសញ្ញាណដំបូង តាមកាលលក្ខខណ្ឌ និងបរិបទ<br>ខ.៣ ស្គាល់ទ្រឹស្តី រចនាសម្ព័ន្ធ និងមុខងារនៃធាតុនានាក្នុងសញ្ញាណដំបូង តាមប្រភេទ ចំណាត់ថ្នាក់ និងទម្រង់តាមលក្ខខណ្ឌ កាល និងបរិបទ | ▪ លង្វែកជារាជធានីពិសិដ្ឋមួយរបស់ខ្មែរ<br>- លក្ខណៈបញ្ជាក់ពីរាជធានីពិសិដ្ឋនៃលង្វែកមានអ្វីខ្លះ?<br>- តើទីកន្លែងប្រវត្តិសាស្ត្រសល់ពីសម័យលង្វែក បញ្ជាក់ពីពិសិដ្ឋភាពនៃរាជធានីលង្វែក មាននៅទីណា?<br>▪ សម័យលង្វែករីកចម្រើនគួរកត់សម្គាល់<br>- លក្ខណៈរីកចម្រើនមានអ្វីខ្លះ?<br>- គោលការណ៍ដឹកនាំប្រទេសក្នុងសម័យលង្វែកដែលនាំឱ្យលង្វែករីកចម្រើន<br>▪ ព្រះបាទចន្ទរាជា និងបរមេន្ទរាជាសាមគ្គីគ្នាស្តារប្រទេស<br>- ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសហការគ្នា<br>- សកម្មភាពអំពីសាមគ្គីភាពបុគ្គល និងសាធារណៈ<br>▪ បន្ទាយលង្វែកបែកបាក់ដោយសារសៀមបាចប្រាក់ដួង?<br>- ប្រាក់ដួង មានហើយឬនៅពេលមានបន្ទាយលង្វែក?<br>- ធាតុបង្កការបែកបាក់មានអ្វីខ្លះ ក្រៅពីប្រាក់ដួង?<br>▪ រាជការលង្វែកមានទំនាក់ទំនងជាមួយបរទេស<br>- ប្រទេសណាខ្លះ? សហការដើម្បីអ្វី និងក្នុងវិស័យអ្វីខ្លះ?<br>- ឯកសារបញ្ជាក់អំពីទំនាក់ទំនងជាមួយបរទេស<br>▪ ព្រះបាទចន្ទរាជា និងបរមេន្ទរាជាមានវីរភាពគួរយកជាគំរូ<br>- សកម្មភាពរបស់ព្រះបាទចន្ទរាជា និងបរមេន្ទរាជាប្រកបដោយវីរភាព |

**គ. វិជ្ជា**

មានវិជ្ជាគឺមានចំណេះដឹង ប៉ុន្តែត្រូវភ្ជាប់ដោយភស្តុតាងវិទ្យាសាស្ត្រ។ មានវិជ្ជា គឺយល់ពីធាតុលម្អិត និងមុខងារនៃធាតុនីមួយៗបង្កប់ក្នុងចំណេះដឹង។ មានវិជ្ជាត្រូវមានភស្តុតាងវិទ្យាសាស្ត្របញ្ជាក់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ នៃធាតុផ្សំនៃចំណេះដឹង។ ការមានវិជ្ជា មនុស្សអាចយកទៅប្រតិបត្តិបាន ស្របតាមកាល បរិបទ និងលក្ខខណ្ឌ។ ការមានវិជ្ជា គឺមានភាពច្បាស់លាស់ ពិត និងត្រឹមត្រូវអំពីរបៀបយកធាតុលម្អិតក្នុងចំណេះដឹងទៅអនុវត្ត និងចែករំលែកជាប្រយោជន៍មនុស្ស។ មានវិជ្ជា គឺយល់ច្បាស់ ត្រឹមត្រូវ និងពិតប្រាកដ អំពីលក្ខណៈវិនិច្ឆ័យ បច្ចេកទេស ទ្រឹស្តី វិធីសាស្ត្រ វិធីយុទ្ធវិធី គោលការណ៍ រចនាសម្ព័ន្ធ មុខងារ និងក្បួន។ល។ ដែលពាក់ព័ន្ធនឹងធាតុលម្អិតរបស់ចំណេះដឹង សម្រាប់យកទៅប្រតិបត្តិប្រចាំជីវិត និងចែករំលែកជាប្រយោជន៍មនុស្ស។

| **ប្រភេទ និងកម្រិត** | **ឧទាហរណ៍** |
|---|---|
| គ.១ ញែកធាតុ និងទ្រឹស្តីនៃចំណេះដឹង ដោយមានភស្តុតាងវិទ្យាសាស្ត្រជាសំអាង | ▪ លង្វែកជារាជធានីពិសិដ្ឋមួយរបស់ខ្មែរ<br>- ពិសិដ្ឋភាពនៃលង្វែកមានភស្តុតាងបញ្ជាក់នៅឯណា?<br>▪ សម័យលង្វែករីកចម្រើនគួរកត់សម្គាល់<br>- ភស្តុតាងប្រវត្តិសាស្ត្របញ្ជាក់ពីភាពរីចម្រើន |
| គ.២ ជ្រើសរើសវិធីសាស្ត្រ យុទ្ធវិធី បច្ចេកទេស វិធាន នីតិវិធី ឬវិធី សមស្របតាមកាល បរិបទ និងលក្ខខណ្ឌ ក្នុងការប្រតិបត្តិ | ▪ ព្រះបាទចន្ទរាជា និងបរមេន្ទរាជារួមគ្នាស្តារប្រទេស<br>- ពេលវេលា និងព្រឹត្តិការណ៍បញ្ជាក់ពីសាមគ្គីភាព<br>- ឯកសារប្រវត្តិសាស្ត្របញ្ជាក់ពីសាមគ្គីភាព<br>- ទម្លាប់គិត វាចា និងការប្រព្រឹត្តិរបស់ព្រះបាទចន្ទរាជា និងបរមេន្ទរាជា ពិតជាគំរូឱ្យសម័យថ្មីរៀនតាម<br>- ស្មារតីសាមគ្គីភាព ពិតជាបេះដូងនៃភាពជោគជ័យ |
| គ.៣ ប្រើវិធីសាស្ត្រ យុទ្ធវិធី បច្ចេកទេស វិធាន នីតិវិធី ឬវិធី សមស្រប តាមកាល បរិបទ និងលក្ខខណ្ឌ | ▪ បន្ទាយលង្វែកបែកបាក់ដោយសារ ៖<br>- ភស្តុតាងបញ្ជាក់ពីប្រាក់ដួងជាធាតុបង្កបែកបាក់លង្វែក<br>- ធាតុបង្កនៃការបែកបាក់លង្វែកខុសពីប្រាក់ដួង<br>▪ រាជការលង្វែកមានទំនាក់ទំនងជាមួយបរទេស<br>- ឯកសារប្រវត្តិសាស្ត្របញ្ជាក់ពីវត្តមានបរទេស<br>- ឯកសារភស្តុតាងបញ្ជាក់ពីការសហការជាមួយបរទេស<br>▪ ចន្ទរាជា និងបរមេន្ទរាជា មានវីរភាពគួរយកជាគំរូ<br>- វីរភាពស្តែងចេញក្នុងព្រឹត្តិការណ៍ ពេល និងកន្លែង |

**ឃ.	បញ្ញា**

ការមានចំណេះដឹង ឬមានវិជ្ជាច្រើនឬជម្រៅប៉ុនណា ដោយសារបានអានច្រើនប៉ុនណា ឬរៀនចប់អស់ថ្នាក់រៀន ក៏ពុំទាន់មានបញ្ញាដែរ។ បញ្ញាកើតចេញពីការប្រតិបត្តិ។ ប្រតិបត្តិសំដៅបញ្ជាក់ភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃចំណេះដឹង និងវិជ្ជា ជាប្រយោជន៍នៃមនុស្ស។ មានបញ្ញា គឺប្រមូលបានទិន្នន័យប្រកបដោយគុណភាព គ្រប់គ្រាន់ ទុកចិត្ត ត្រឹមត្រូវ និងច្បាស់លាស់ពីការប្រតិបត្តិ ឬពីការពិសោធដោយផ្ទាល់ខ្លួន។ មានបញ្ញា គឺបានប្រើទិន្នន័យប្រកបដោយគុណភាព ទៅបង្កើតបានទ្រឹស្តី គោលការណ៍ វិធីសាស្ត្រ លក្ខខណ្ឌថ្មី ស្របតាមកាល និងបរិបទ។

| ប្រភេទ និងកម្រិត | ឧទាហរណ៍ |
|---|---|
| ឃ.១ បង្កើតលក្ខខណ្ឌថ្មីនៃការប្រើវិធាន វិធីសាស្ត្រ យុទ្ធសាស្ត្រ ឬវិធី តាមភស្តុតាងពិសោធន៍ផ្ទាល់ | ▪ លង្វែកជារាជធានីពិសិដ្ឋមួយរបស់ខ្មែរ<br>- ភាពពិសិដ្ឋនៃរាជធានីលង្វែក អាចភ្ជាប់នឹងតម្រូវការក្នុងបច្ចុប្បន្នបាន<br>- ភាពពិសិដ្ឋនៃលង្វែកអាចជាទ្រឹស្តីប្រើក្នុងបច្ចុប្បន្ន<br>▪ សម័យលង្វែករីកចម្រើនគួរកត់សម្គាល់<br>- ភាពរីកចម្រើននៃសម័យលង្វែក ជាគំរូសម្រាប់សម័យបច្ចុប្បន្ន និងអនាគត<br>- លំនាំដឹកនាំប្រទេសសម័យលង្វែកអាចបង្កើតបានជាទ្រឹស្តីសម្រាប់ការដឹកនាំបច្ចុប្បន្ន<br>▪ ព្រះបាទចន្ទរាជា និងបរមេន្ទរាជារួមគ្នាស្តារប្រទេស<br>- សាមគ្គីភាពឱ្យសិស្សយកទៅប្រតិបត្តិបាន<br>- សាមគ្គីភាពបុគ្គល ក្នុងតំណែងជាអ្នកដឹកនាំ ជួយចម្រើនប្រទេសបានយ៉ាងច្រើន<br>▪ បន្ទាយលង្វែកបែកបាក់ដោយសារ ៖<br>- តើធាតុបង្កឱ្យបែកបាក់លង្វែកអាចជាមេរៀន ដើម្បីភាពល្អប្រសើរក្នុងសម័យក្រោយបានដែរឬទេ?<br>▪ រាជការលង្វែកមានទំនាក់ទំនងជាមួយបរទេស<br>- ទំនាក់ទំនងជាមួយបរទេសសម័យលង្វែកជាមេរៀនគួររៀនតាម ឬចៀសវាងសម្រាប់ជំនាន់ក្រោយ<br>▪ ចន្ទរាជា និងបរមេន្ទរាជា មានវីរភាពគួរជាគំរូ<br>- វីរភាពពិតជាជួយស្តារប្រទេស និងជួយសង្គម |
| ឃ.២ បំបែកប្រភេទ និងធាតុនៃវិធាន វិធីសាស្ត្រ និងវិធីឱ្យទៅជាយុទ្ធវិធី ល្បិច ឬសកម្មភាពច្រើនប្រភេទ តាមលទ្ធផលពិសោធឱ្យស្របតាមកាល លក្ខខណ្ឌ និងបរិបទ | |
| ឃ.៣ បង្កើតកញ្ចប់ថ្មីនៃវិធាន វិធីសាស្ត្រ យុទ្ធវិធី វិធី ល្បិចច្រើនប្រភេទ តាមលទ្ធផលពិសោធ ឱ្យស្របតាមកាល លក្ខខណ្ឌ និងបរិបទ | |

## ១៣.៤ ប្រតិបត្តិវិជ្ជានុក្រម ក្នុងការសរសេរលទ្ធផលសិក្សា

| **ចំណាត់ថ្នាក់វិជ្ជានុក្រម** | **សកម្មភាព ឧទាហរណ៍ កិរិយាសព្ទ** | **ឧទាហរណ៍ អំពីការសរសេរលទ្ធផលសិក្សា** (ទម្រង់នៃការសរសេរលទ្ធផលសិក្សាតាមខ្លឹមសារ ពុំមែនតាមបញ្ញត្តិទេ) |
|---|---|---|
| ១. ចងចាំ ៖ សំដៅដល់ចិត្តសម្គាល់ និងរំឭកធាតុរួម ធាតុផ្សំ ឬធាតុលម្អិតនៃព័ត៌មានដែលអ្នកសិក្សាបានទទួល និងអភិវឌ្ឍ ពីដំណើរការរៀន និងជួបផ្ទាល់ និងបានរក្សាទុក ក្នុងឃ្លាំងទិន្នន័យ (ភាសាសាមញ្ញ ៖ ខួរក្បាល និងភាសាអប់រំចិត្ត គឺទិន្នន័យផ្ទុកក្នុងបីកម្រិត ១. ក្នុងមនោ ២. ក្នុងវិញ្ញាណ និង៣. ក្នុងចិត្ត) រយៈពេលខ្លី ឬរយៈពេលយូរសម្រាប់ប្រើតាមកាល លក្ខខណ្ឌ និងបរិបទ។ | | |
| ១.១ សម្គាល់ ចាំទុក | កត់ចំណាំ<br>ដៅចំណាំ<br>រកសញ្ញាសម្គាល់<br>គាងសញ្ញា<br>ដាក់ឈ្មោះ<br>តម្រៀប<br>គូររូប<br>គូរសញ្ញា<br>ចង្អុល | ▪ កត់ចំណាំប្រភេទ និងលក្ខណៈនៃវត្ថុបុរាណបន្សល់ទុកពីសម័យហ្វូណន<br>▪ ដៅចំណាំទីកន្លែងភូមិមូល ក្នុងសម័យហ្វូណន យកភូមិសាស្ត្របច្ចុប្បន្នជាគោល<br>▪ រកសញ្ញាសម្គាល់ទីតាំងរាជធានីនៃនគរខ្មែរសម័យហ្វូណន<br>▪ ដាក់ឈ្មោះទីកន្លែង លើសន្លឹកផែនទី ឬផ្ទាំងគំនូរអំពីទីកន្លែងសំខាន់ៗ ក្នុងសម័យហ្វូណន<br>▪ តម្រៀបកាលបរិច្ឆេទនៃការគ្រប់គ្រងរាជ្យរបស់ក្សត្រប្រទេសក្នុងសម័យហ្វូណនតាមលំដាប់ឆ្នាំ ពីដើមដំបូងដល់ចុងក្រោយបំផុត<br>▪ កត់សម្គាល់ពីទីកន្លែងសំខាន់ៗ និងលក្ខណៈពិសេស របស់រាជធានីលង្វែក ក្នុងផែនទី<br>▪ ចង្អុលឱ្យចំចំណុចនៃទីតាំងក្រុងលង្វែកលើផែនទី<br>▪ គូរសញ្ញាបញ្ជាក់ផ្លូវលើផែនទី ដើម្បីឱ្យមិត្តភក្តិមិនដែលស្គាល់បន្ទាយលង្វែកទៅរកទីកន្លែងពិតឃើញ<br>▪ គូរសញ្ញាសម្គាល់ឱ្យចំកន្លែងលើផែនទី បញ្ជាក់ទីតាំងអូរកែវក្នុងសម័យហ្វូណន<br>▪ គូររូបតំណាងនៃចម្លាក់ព្រះគោក្នុងសម័យលង្វែក |

**ចំណាំ ៖**

កិរិយាសព្ទ **សម្គាល់ ឬចាំទុក**ជាលំនាំចិត្តដំបូងដែលវិញ្ញាណណាមួយបានប៉ះដំបូង។

| | | | |
|---|---|---|---|
| ១.២ | រំឭក នឹករក | ប្រាប់ រ៉ាយរ៉ាប់ រៀបរាប់ | ▪ ប្រាប់ឈ្មោះវត្ថុបុរាណបែបច្នៃប្រឌិត បន្សល់ពីសម័យហ្វូណន<br>▪ ប្រាប់ប្រភេទសិល្បៈច្នៃប្រឌិតបន្សល់ទុកពីសម័យហ្វូណន<br>▪ រ៉ាយរ៉ាប់លក្ខណៈសម្គាល់ផ្សេងៗ នៃវត្ថុសិល្បៈចម្លាក់បន្សល់ទុកពីសម័យហ្វូណន<br>▪ ប្រាប់អំពីស្ថានភាពប្រជាសាស្ត្រសម័យកាលហ្វូណន<br>▪ រៀបរាប់អំពីការបែងចែកសង្គមមនុស្សក្នុងសម័យហ្វូណន<br>▪ ប្រាប់អំពីភាពជឿនលឿនផ្នែកអក្សរ និងការរៀនសូត្ររបស់ខ្មែរសម័យកាលហ្វូណន<br>▪ រៀបរាប់អំពីបម្រែបម្រួល និងភាពរុងរឿងផ្នែកកសិកម្ម សិប្បកម្ម និងពាណិជ្ជកម្មសម័យហ្វូណន<br>▪ រ៉ាយរ៉ាប់អំពីតួនាទីស្ត្រីក្នុងការអភិវឌ្ឍនគរ ក្នុងសម័យហ្វូណន<br>▪ ប្រាប់អំពីវីរភាព និងស្នាព្រះហស្ត របស់ព្រះបាទចន្ទរាជា និងបរមេន្ទរាជាក្នុងសម័យលង្វែក |

**ចំណាំ ៖**

**រំឭកឬនឹករក** ជាកិរិយាសព្ទបញ្ជាក់លំនាំ នៃចិត្តក្នុងការទាញយកព័ត៌មាន ឬធាតុនៃព័ត៌មានដែលបានសម្គាល់ និងចាំទុក សម្រាប់យកប្រើតាមកាល លក្ខខណ្ឌ និងបរិបទ។ ឧទាហរណ៍ សិស្សបានរៀនមេរៀនមួយអំពីវីរភាពរបស់ ព្រះបាទចន្ទរាជា និងបរមេន្ទរាជា។ គ្រូបង្រៀនបានឱ្យសិស្សរំឭក ឬនឹករក សកម្មភាព និងស្នាព្រះហស្តរបស់ព្រះបាទ ចន្ទរាជា និងបរមេន្ទរាជា ដែលបញ្ជាក់អំពីវីរភាព ក្នុងការស្តារប្រទេស។ សិស្សរំឭក និងនឹករកបាន លុះត្រាណាសិស្សប្រាប់ រ៉ាយរ៉ាប និងរៀបរាប់។

| | | | |
|---|---|---|---|
| ២. | យល់ ៖ សំដៅដល់ការបង្កើតអត្ថន័យនៃធាតុរួម ធាតុផ្សំ ឬធាតុលម្អិតដែលទទួលបានតាមរយៈវិញ្ញាណដែលបានសម្គាល់ និងរំឭកក្នុងដំណាក់កាលចងចាំ។ | | |
| ២.១ | ប្រែសម្រួល | លើកហេតុផល<br>តាងជំនួស | ▪ លើកហេតុផលអំពីការប្រើតម្លៃពុទ្ធិរបស់ព្រះបាទជ័យវរ្ម័នទី៧ ក្នុងការបង្រួបបង្រួមប្រទេស<br>▪ តាងជំនួស |
| ២.២ | ភ្ជាប់តំណាង | បង្ហាញរូប<br>បង្ហាញគំរូ | ▪ បង្ហាញរូប<br>▪ បង្ហាញគំរូ |
| ២.៣ | បែងចែក | កំណត់ប្រភេទ<br>ដាក់បញ្ចូលគ្នា<br>ញែកចេញពីគ្នា | ▪ កំណត់ប្រភេទនៃរូបចម្លាក់បីនៃប្រាសាទសំបូរព្រៃគុក<br>▪ ដាក់បញ្ចូលគ្នានូវភាពរួម នៃចរិតលក្ខណៈមនុស្សពូកែរបស់ព្រះបាទចន្ទរាជា និងជ័យវរ្ម័ន៧<br>▪ ញែកចេញពីគ្នានៃចរិតលក្ខណៈមនុស្សពូកែ និងមនុស្សច្រណែន ក្នុងសម័យឧដុង្គ |
| ២.៤ | សង្ខេប | សង្ខិត្ត<br>បំព្រួញ | ▪ សង្ខិត្តន័យនៃអត្ថបទអំពីវីរភាពរបស់ព្រះបាទ ចន្ទរាជា និងបរមេន្ទរាជា<br>▪ បំព្រួញអត្ថបទមេរៀនអំពីទីក្រុងភ្នំពេញសម័យបារាំង |
| ២.៥ | ដាក់រួម | បូកសរុប<br>នឹកប្រមាណ<br>បញ្ចូលបន្ថែម | ▪ បូកសរុបអំពីស្នាព្រះហស្តរបស់ព្រះបាទជ័យវរ្ម័នទី៧ ក្នុងការធានាសុខដុមភាពរបស់ប្រទេស<br>▪ នឹកប្រមាណអំពីផលដែលអាចកើតឡើង ប្រសិនបើព្រះបាទជ័យវរ្ម័ន៧មិនបានបង្រួបបង្រួមប្រទេស<br>▪ បញ្ចូលបន្ថែមនូវព័ត៌មានលើវីរភាពរបស់ព្រះបាទជ័យវរ្ម័ន៧ដែលមានសរសេរក្នុងអត្ថបទ |
| ២.៦ | ពន្យល់ | ផ្តល់ឧទាហរណ៍<br>បញ្ជាក់អង្គហេតុ/ភស្តុតាង | ▪ ផ្តល់ឧទាហរណ៍ឱ្យបានប្រាំចំណុចអំពីចរណមនុស្សពូកែរបស់ព្រះបាទជ័យវរ្ម័ន៧<br>▪ បញ្ជាក់អង្គហេតុអំពីទេពកោសល្យរបស់ព្រះបាទជ័យវរ្ម័ន៧ ក្នុងការដឹកនាំ តាមគោលការណ៍ទសពិត |

<table>
<tr><td colspan="3">៣. ប្រតិបត្តិ ៖ សំដៅដល់ការប្រើប្រាស់ ឬការអនុវត្តវិធាន យុទ្ធវិធី វិធី សកម្មភាព តាមស្ថានភាព លក្ខខណ្ឌ ឬ បរិបទ</td></tr>
<tr><td>៣.១ អនុវត្ត<br><br><br>៣.២ ដំណើរការ</td><td>ប្រើ<br>ចាត់របៀប<br><br>កែសម្រួល<br>កែលម្អ<br>ភ្ជាប់</td><td>▪ ប្រើបញ្ញត្តិអំពីវីរភាពរបស់ព្រះបាទចន្ទរាជា សម្រាប់ភ្ជាប់នឹងការប្រតិបត្តិក្នុងថ្នាក់រៀន<br>▪ ចាត់របៀប<br>▪ កែសម្រួលអត្ថបទអំពីព្រះបាទចន្ទរាជា ដោយផ្តោតការយកចិត្តទុកដាក់លើបញ្ញត្តិសាមគ្គីភាព<br>▪ ភ្ជាប់ទម្លាប់នៃការធ្វើស្រែក្នុងសម័យហ្វូណនជាមួយនឹងទម្លាប់ធ្វើស្រែក្នុងបច្ចុប្បន្ន<br>▪ កែលម្អ ................................................</td></tr>
<tr><td colspan="3">៤. វិភាគ ៖ សំដៅដល់ការបំបែកធាតុនានាឱ្យទៅជាចំណែកតូចៗ ហើយភ្ជាប់ចំណែកតូចៗ ទាំងនោះឱ្យទៅជាសម្ព័ន្ធមួយ ដើម្បីបម្រើគោលបំណងអ្វីមួយ និងបង្កើតបានជាទម្រង់ ឬសម្ព័ន្ធថ្មី</td></tr>
<tr><td>៤.១ ញែកភាពខុសគ្នា</td><td>បំបែក<br>រាយលម្អិត</td><td>▪ បំបែកភាពខុសគ្នានៃចរិយារបស់ព្រះបាទចន្ទរាជា និង ........<br>▪ រាយលម្អិតប្រភេទមុខរបរចិញ្ចឹមជីវិតរបស់ជនជាតិខ្មែរដើម រាប់ពីចរកជនមកជានិសិទ្ធជន<br>▪ ញែកលក្ខណៈខុសគ្នានៃសិល្បៈច្នៃប្រឌិតបន្សល់ទុកពីសម័យលង្វែក និងសម័យអង្គរ</td></tr>
<tr><td>៤.២ ចាត់ចែង</td><td>ពង្រួប<br>បដិសេធ<br>ចងសម្ព័ន្ធ<br>បញ្ជូលគ្នា</td><td></td></tr>
<tr><td>៤.៣ ប្រៀបធៀប</td><td>ផ្ទុំធាតុ/អញ្ញាត<br>បែងប្រភេទ<br>ផ្ទឹមគ្នា<br>ចាត់ថ្នាក់<br>ផ្គូគ្នា<br>ផ្គូផ្គង</td><td></td></tr>
</table>

| ៥. វាយតម្លៃ ៖ សំដៅដល់ការបង្កើតសេចក្តីសន្និដ្ឋាន ដោយប្រើភស្តុតាង ទ្រឹស្តី ឬគោលការណ៍ | | |
| --- | --- | --- |
| ៥.១ ផ្ទៀងផ្ទាត់ | សាកល្បង<br>តាមដាន<br>សង្កេត | |
| ៥.២ សន្ទត | ទិតៀន<br>សន្និដ្ឋានរួម<br>ជ្រើសរើស<br>សរុប | ▪ ទិតៀនគោលគំនិតមួយនៃអត្ថបទមួយដែលសរសេរថា សៀមបានបាចប្រាក់ដួងឱ្យខ្មែរកាប់ឆ្ការព្រៃឫស្សីដើម្បីវាយយកឈ្នះខ្មែរ ក្នុងសម័យលង្វែក<br>▪ សន្និដ្ឋានរួមអំពីគោលប្រយោជន៍នៃវប្បធម៌ និងកសិកម្ម ក្នុងបុរេប្រវត្តិសាស្ត្រខ្មែរ<br>▪ ជ្រើសរើសគុណតម្លៃពីរនៃវីរភាពរបស់ព្រះបាទចន្ទរាជា សម្រាប់ប្រតិបត្តិប្រចាំថ្ងៃក្នុងបច្ចុប្បន្ន<br>▪ សរុបគោលគំនិតនៃអត្ថបទស្តីពីក្រុមសាមគ្គីក្នុងរបបរដ្ឋកម្ពុជា ចាប់ពីឆ្នាំ១៩៧៩ ដល់១៩៨៥ |

| | | |
|---|---|---|
| ៦. បង្កើតថ្មី ៖ ផ្គុំធាតុនានាឱ្យចូលក្នុងទម្រង់ ឬរចនាសម្ព័ន្ធ ឬបែបបទរួមឬថ្មី | | |
| ៦.១ បង្ក | ចែងសម្មតិកម្ម | ▪ ចែងសម្មតិកម្មអំពីជម្រើសនៃដំណោះស្រាយជម្លោះ ក្នុងរាជវង្សខ្មែរ ក្នុងសម័យចតុមុខ |
| ៦.២ ផលិត | ចងក្រង<br>ផ្តើមគំនិត<br>ផ្គុំ | ▪ ចងក្រងជម្រើសនៃដំណោះស្រាយជម្លោះដណ្តើមអំណាច ក្នុងរាជវង្សខ្មែរ ក្នុងសម័យចតុមុខ<br>▪ ផ្តើមគំនិតអំពីវិធីដំណោះស្រាយថ្មី ចំពោះជម្លោះដណ្តើមអំណាច ក្នុងរាជវង្សខ្មែរ ក្នុងសម័យចតុមុខ<br>▪ ផ្គុំជម្រើសនៃដំណោះស្រាយជម្លោះដណ្តើមអំណាច ក្នុងរាជវង្សខ្មែរ ក្នុងសម័យចតុមុខ<br>▪ ផ្តល់ជម្រើសនៃវិធីស្រាយបញ្ហាបែបថ្មី សម្រាប់ប្រតិបត្តិក្នុងសម័យបច្ចុប្បន្ន |
| ៦.៣ ច្នៃ | បង្កើត<br>ស្ថាបនា<br>កែលម្អ | ▪ បង្កើតជម្រើសបីនៃដំណោះស្រាយជម្លោះ ឱ្យខុសពីដំណោះស្រាយជម្លោះដំណើ្តមអំណាចក្នុងរាជវង្សខ្មែរ ក្នុងសម័យចតុមុខ<br>▪ កែលម្អកថាខណ្ឌទី៣ នៃអត្ថបទអំពីជម្លោះដណ្តើមអំណាចក្នុងរាជវង្សខ្មែរ ក្នុងសម័យចតុមុខ ដើម្បីឱ្យឆ្លើយតបនឹងបញ្ញត្តិមួយអំពីជម្លោះ។ |

ប្រភព ៖ ប្រែនិងសម្រួលពី (Anderson, Krathwohl, & Airasian, 2001)។ លទ្ធផលសិក្សាដកស្រង់ចេញពីកម្មវិធីសិក្សាលម្អិត និងសរសេរថ្មីបន្ថែម

## ១៤. គោលវិធី និងវិធីសាស្ត្រ

វាក្យសព្ទប្រើក្នុងប្រព័ន្ធអប់រំ សាលារៀន ក្នុងចំណោមគ្រូបង្រៀន និងអ្នកអប់រំមានច្រើនបែបច្រើនយ៉ាង។ ពាក្យពេញនិយមក្នុងវិធីសាស្ត្រគរុកោសល្យដូចជា គោលវិធី វិធីសាស្ត្រ និងយុទ្ធវិធីបង្រៀន។ ពាក្យគោលវិធីបង្រៀន និងវិធីសាស្ត្របង្រៀន មានការជជែកគ្នា និងយល់ខុសគ្នាច្រើន។

គ្រូបង្រៀនខ្លះជជែកគ្នាថា សិស្សមជ្ឈមណ្ឌលជាគោលវិធីបង្រៀនពុំមែនជាវិធីសាស្ត្របង្រៀនទេ។ គ្រូបង្រៀនខ្លះជជែកគ្នាថា រិះរកជាគោលវិធីបង្រៀន

ពុំមែនវិធីសាស្ត្របង្រៀន។ វិះរកជាវិធីសាស្ត្រពុំមែនជាគោលវិធី។ល។ ការជជែកគ្នារកត្រូវ ឬខុសគឺអាស្រ័យគោលបំណងនៃការប្រើ។

សៀវភៅនេះផ្តោតការយកចិត្តទុកដាក់ច្រើនលើវាក្យសព្ទបី ៖ **១. គោលវិធី ២. វិធីសាស្ត្រ** និង**៣. យុទ្ធវិធី**។ បន្ទាប់មក ពាក្យសំខាន់ប្រើក្នុងដំណើរការរៀបចំកិច្ចតែងការ និងការបង្កើតលំនាំនៃការដឹកនាំការរៀន គឺប្រើ **យុទ្ធវិធី**។

ពាក្យបង្រៀន និងដឹកនាំការរៀន ក៏មានការជជែកគ្នាច្រើន ក្នុងចំណោមគ្រូបង្រៀន។ ការជជែកគ្នា គឺច្រើនផ្តោតការយកចិត្តទុកដាក់លើ ពាក្យ**បង្រៀន**។ ពាក្យ **ដឹកនាំការរៀន** ពុំសូវមានការជជែកគ្នាច្រើនទេ។ គ្រូបង្រៀនខ្លះយល់ថា ការបង្រៀន និងដឹកនាំការរៀនពុំមានអ្វីខុសគ្នាប្លែកពីគ្នាទេ។ ការយល់ឃើញ និងការពន្យល់របស់មនុស្សខុសគ្នា ប្រសិនបើប្រើទិន្នន័យពីជ្រុងផ្សេងគ្នា។ សៀវភៅនេះសំយោគថា ៖

- ការបង្រៀន ផ្តោតការយកចិត្តទុកដាក់ខ្លាំងលើសកម្មភាពរបស់គ្រូបង្រៀនជាធំ។ គ្រូបង្រៀនចំណាយពេលនិយាយ រ៉ាយរ៉ាប់ រៀបរាប់ បកស្រាយ ឬពន្យល់ច្រើនជាងសកម្មភាពសិស្ស។ សិស្សពុំសូវមានឱកាសឆ្លុះ គិតសង្កេត បង្កើតសំណួរ ចោទសួរ និងស្វែងការពន្យល់ដោយឯករាជ្យ ក្នុងដំណើរការរៀន។
- ការដឹកនាំការរៀន ផ្តោតការយកចិត្តទុកដាក់លើសកម្មភាពរបស់គ្រូបង្រៀន ក្នុងការសម្របសម្រួល និងជួយសិស្សឱ្យអនុវត្តសកម្មភាពច្រើនបែបច្រើនយ៉ាង។ សិស្សប្រតិបត្តិទម្លាប់គិត ឆ្លុះ សង្កេត បង្កើតសំណួរ សួរសំណួរ និងរកការពន្យល់ពីច្រើនប្រភព។

សៀវភៅនេះសំយោគអត្ថន័យ និងប្រើពាក្យ **គោលវិធី** និង**វិធីសាស្ត្រ** ៖

- **គោលវិធី**ជាការផ្សំផ្គុំនៃពាក្យពីរ គឺ**គោល** និង**វិធី**។ **គោល**សំដៅដល់រូបពាក្យ ច្បាប់ រូបសេចក្តី មាត្រា មាតិកា........ (Khmer Buddhism Institute, 1967)។ **គោលវិធី** បកប្រែជាភាសាអង់គ្លេស គឺAppraoch។ គោលវិធីក្នុងបរិបទនេះ សំដៅដល់ទស្សនវិជ្ជា ជំនឿ គោលគំនិត ឬការយល់ឃើញជាទ្រឹស្តី អំពីដំណើរប្រព្រឹត្តទៅនៃកិច្ចការអ្វីមួយ។ គោលវិធីបង្រៀន

សំដៅដល់ទស្សនវិជ្ជា ទ្រឹស្ដី គោលគំនិត ជំនឿ និងការយល់ឃើញអំពីដំណើរការ ឬការប្រព្រឹត្តិទៅនៃការបង្រៀនឬការដឹកនាំសិស្សឱ្យរៀន (Cambridge Dictionary , 2020)។

- គោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល សំដៅដល់ដំណើរប្រព្រឹត្តទៅនៃការបង្រៀនដែលយកសិស្សជាស្នូលនៃសកម្មភាពទាំងអស់។
- គោលវិធីគរុកោសល្យគ្រូមជ្ឈមណ្ឌល សំដៅដល់ដំណើរប្រព្រឹត្តទៅនៃការបង្រៀន។ គ្រូបង្រៀនជាស្នូល និងប្រភពផ្ដល់ ផ្ទេរចំណេះដឹង។
- **វិធីសាស្ត្រ**ជាការផ្សំផ្គុំនៃពាក្យពីរ គឺ**វិធី** និង**សាស្ត្រ**។ **វិធី** ឬពិធីសំដៅដល់ បែបធ្វើ បែបរបៀប របៀបកិច្ចការ ក្រឹតិកា (Khmer Buddhism Institute, 1967)។ **សាស្ត្រ ឬសាស្ត្រា**សំដៅដល់វិជ្ជា តម្រា ការសិក្សា ....... (Khmer Buddhism Institute, 1967)។ **វិធីសាស្ត្រ**បកប្រែជាភាសាអង់គ្លេស Methodology។ ក្នុងបរិបទនេះ វិធីសាស្ត្រសំដៅដល់ប្រព័ន្ធ វិធី របៀបនៃការប្រតិបត្តិ ឬការប្រព្រឹត្តិទៅ នៃកិច្ចការអ្វីមួយ។ វិធីសាស្ត្រជាការសិក្សាលម្អិតអំពីវិធី សកម្មភាព និងជំហានដែលត្រូវបំពេញកិច្ចការអ្វីមួយឱ្យបានជាផល (Cambridge Dictionary , 2020)។
- វិធីសាស្ត្របុច្ឆនសិក្សារបស់ Alberta Learning (2004) រាយរាប់លម្អិតអំពីវិធី សកម្មភាព និងជំហានក្នុងដំណើរការដឹកនាំការរៀន រហូតសិស្សទទួលបានផល។ សិស្សទទួលបានផលពីការរៀន គឺសិស្សត្រូវផ្ដើមចេញពីការគិត ឆ្ងល់ សង្កេត បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់។

គោលវិធីបង្រៀន គោលវិធីដឹកនាំការរៀន វិធីសាស្ត្របង្រៀន និងវិធីសាស្ត្រដឹកនាំការរៀនមានច្រើនបែបច្រើនយ៉ាង អាស្រ័យដោយបរិបទនៃការអប់រំ សាលារៀន និងការជ្រើសរើសទ្រឹស្ដីយកមកអនុវត្ត។ មនុស្សមានបទពិសោធក្នុងវិស័យអប់រំច្រើនឆ្នាំ មានភស្តុតាងបញ្ជាក់ការពិតបាន។ ប្រព័ន្ធសាលារៀន គ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូបង្រៀន និងគ្រូបង្រៀនកម្ពុជានៅតាមសាលារៀន ស្គាល់គោលវិធី និងវិធីសាស្ត្របង្រៀនជាច្រើនបែបច្រើនយ៉ាង។ ទោះបីជាយ៉ាងណា គ្រូបង្រៀនកម្រនិយាយពាក្យគោលវិធី និងវិធីសាស្ត្រដឹកនាំការរៀន។

ពាក្យដែលគ្រូបង្រៀននិយមប្រើ គឺគោលវិធីសិស្សមជ្ឈមណ្ឌល (Student-centered teaching approach) គោលវិធីគ្រូមជ្ឈមណ្ឌល (Teacher-centered teaching approach) ។

ការសម្ភាសគ្រូបង្រៀនតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន និង សាលារៀនចំណោះទូទៅ ផ្តល់ភស្តុតាងច្រើនអំពីការស្គាល់វិធីសាស្រ្ត និងគោលវិធីបង្រៀន និងដឹកនាំការរៀនច្រើនបែបច្រើនយ៉ាង។ វិធីសាស្រ្ត និងគោលវិធីបង្រៀន និងដឹកនាំការរៀនមានដូចជា ៖

- វិធីសាស្រ្តបង្រៀនសកម្ម និងអសកម្ម (Active and Passive Learning)
- វិធីសាស្រ្តសិក្សាតាមគម្រោង (Project-based learning)
- វិធីសាស្រ្តរៀនតាមបញ្ហា (Problem-based learning)
- វិធីសាស្រ្តសិក្សាមេរៀន (Lesson study)
- វិធីសាស្រ្តរៀនបែបសហប្រតិបត្តិការ (Cooperative learning)
- វិធីសាស្រ្តរៀនបែបសហការ (Collaborative Learning)
- វិធីសាស្រ្តបង្រៀនបែបរិះរក (Inquiry-based learning)

ទោះបីជាយ៉ាងណា ការសម្ភាសពន្យល់ថា គ្រូបង្រៀនពុំស្គាល់គោលវិធី ឬ វិធីសាស្រ្តសិក្សាបញ្ញត្តិ (Concept-based learning) ទេ។ ប្រសិនបើនិយាយរៀបរាប់ខ្លះៗ អំពីសិក្សាបញ្ញត្តិ គ្រូបង្រៀនភាគច្រើនសំយោគថា សិក្សាបញ្ញត្តិជាវិធីសាស្រ្តអនុមានរួម និងអនុមានញែក។

សៀវភៅនេះ ផ្តល់លំនាំនៃការគិតមួយជ្រុងដល់អ្នកគ្រូ លោកគ្រូឱ្យស្វែងបន្ថែមលើវិធីសាស្រ្តរៀន និងដឹកនាំការរៀនមួយចំនួនដែលជួយសិស្សឱ្យអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ គឺគិតដូចអ្នកវិទ្យាសាស្រ្ត។ លើសពីនេះទៀត អ្នកគ្រូ លោកគ្រូអាចយកលំនាំនៃការគិតនេះទៅបង្រៀនសិស្ស និងដឹកនាំសិស្សឱ្យយល់ និងប្រតិបត្តិគុណសម្បទាសតវត្សរ៍ទី២១ និងពលរដ្ឋសកល។ ដំណើរការរៀន និងដឹកនាំការរៀនដែលអភិវឌ្ឍបំណិន និងគុណសម្បទាសតវត្សរ៍ទី២១ និងពលរដ្ឋសកលជាដំណើរការរៀនពិតប្រាកដ។ ដំណើរការរៀន និងដឹកនាំការរៀន ពិតប្រាកដ គឺបណ្តុះពលរដ្ឋឱ្យក្លាយជាពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ។

សៀវភៅនេះផ្តោតការយកចិត្តទុកដាក់ច្រើន និងស៊ីជម្រៅលើសិក្សាបញ្ញត្តិ Concept-based learning and instruction (Erickson, Lanning, & French, 2017; Wiggins & McTighe, 2005; Stern, Lauriault, & Ferraro, 2018; Erickson & Lanning, 2014)។ សិក្សាបញ្ញត្តិអាចហៅបានថា គោលវិធី ឬវិធីសាស្ត្រ អាស្រ័យដោយគោលបំណង នៃការប្រើ។ សៀវភៅនេះក៏ផ្តោតការយកចិត្តទុកដាក់ច្រើនលើបុច្ឆនសិក្សា (Inquiry-based learning) (Gidman & Casinader, 2017)។ គោលវិធីបុច្ឆនសិក្សា (Inquiry-based learning) ពេញនិយមហៅថាវិធីសាស្ត្រិះរក នៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន។ បុច្ឆនសិក្សាអាចហៅបានថា វិធីសាស្ត្រ ឬគោលវិធី អាស្រ័យលើគោលបំណងនៃការប្រើ។ ចំណែកវិធី ឬយុទ្ធវិធីដឹកនាំការរៀនតាម៥E (Engage, Explore, Explain, Elabrorate and Evaluate) និងយុទ្ធវិធីដឹកនាំការរៀនតាម KWL (KNOW, WANT TO LEARN, LEARNED) មិនបានសិក្សាស៊ីជម្រៅទេ ប៉ុន្តែបានផ្គុំជាមួយវិធីសាស្ត្របុច្ឆនសិក្សា ក្នុងទម្រង់សង្ខិត្តន័យ។

គោលវិធី**បង្រៀន** និងវិធីសាស្ត្រ**បង្រៀន** ជាឃ្លាពេញនិយមជាមួយគ្រូបង្រៀន និងគ្រូឧទ្ទេសតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀននៅកម្ពុជា។ ចំណែកឃ្លា **"គោលវិធីដឹកនាំការរៀន"** មិនសូវពេញនិយមនិយាយ ក្នុងចំណោមគ្រូបង្រៀន និងគ្រូឧទ្ទេសទេ។ ជាក់លាក់ជាងនេះទៀត ពាក្យមិនសូវនិយមក្នុងចំណោមគ្រូបង្រៀនកម្ពុជា គឺយុទ្ធវិធី និងល្បិចបង្រៀន ព្រោះល្អិតល្អន់ពេកអាស្រ័យសិល្បៈ និងកោសល្យរបស់គ្រូបង្រៀនម្នាក់ៗ។

ការតាក់តែងកម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ បង្កលក្ខណៈងាយស្រួលឱ្យគ្រូបង្រៀន និងសិស្សពង្រីកពុទ្ធិដែលមានស្រាប់ និងបង្កើតពុទ្ធិថ្មី ពីបញ្ញត្តិក្នុងមេរៀន លើសពីចាំខ្លឹមសារ និងអង្គហេតុ។ កម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិដឹកនាំសិស្សឱ្យគិត ឆ្ងល់ សង្កេត បង្កើតសំណួរ សួរសំណួរ ត្រិះរិះវិភាគ វាយតម្លៃ សន្និដ្ឋាន និងប្រើភស្តុតាង រកបានពីការស្រាវជ្រាវ (Alberta Learning, 2004; Alfrieri, Brooks, Aldrich, & Harriet , 2011; Blessinger & Cafora, 2014; Erickson, Lanning, & French, 2017)។ កម្មវិធីសិក្សាលម្អិត នៃ

មុខវិជ្ជាប្រវត្តិវិទ្យា ចាប់ពីបឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ អនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៨ បានប្រើបញ្ញត្តិជាគោលនៃការសរសេរគោលបំណង និងលទ្ធផលសិក្សា។

ការរៀបចំ និងអនុវត្តកម្មវិធីសិក្សា និងការដឹកនាំការរៀនក្នុងថ្នាក់ តាមសិក្សាបញ្ញត្តិ និងបុច្ឆនសិក្សាផ្តល់ឱកាសច្រើនសម្បូរបែបដល់សិស្ស (Alberta Learning, 2004; Alfrieri, Brooks, Aldrich, & Harriet , 2011; Blessinger & Cafora, 2014; Erickson, Lanning, & French, 2017)។ សិស្សមានឱកាសភ្ជាប់លទ្ធផលរៀនពីកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ជាមួយនឹងជីវភាពប្រចាំថ្ងៃ ការរៀនបន្ត និងការងារ។ សំខាន់ដូចគ្នាដែរ វិធីសាស្ត្រសិក្សាបញ្ញត្តិ និងវិធីសាស្ត្របុច្ឆនសិក្សា ផ្តល់ឱកាសឱ្យសិស្ស និងគ្រូបង្រៀនពង្រីការគិតដូចអ្នកវិទ្យាសាស្ត្រ និងអភិវឌ្ឍគុណសម្បទាជាពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ។

ជាទូទៅ ចេតនានៃការរៀន ការដឹកនាំការរៀន ការអប់រំ និងការចង់បានរបស់មាតាបិតា និយោជក និងសង្គម សំដៅឱ្យសិស្សទទួលបានគុណសម្បទា ជាពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ។ ពលរដ្ឋពូកែ ត្រូវផ្តើមចេញពីការអភិវឌ្ឍវិជ្ជាឯកទេស គុណសម្បទាសតវត្សរ៍ទី២១ គុណសម្បទាពលរដ្ឋសកល គុណតម្លៃមនុស្ស និងចរណមនុស្ស។ ការអភិវឌ្ឍគុណសម្បទាពលរដ្ឋពេញលេញ សិស្សត្រូវផ្តើមចេញពីការគិត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ ស្វែងការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់មុននឹងសម្រេចចិត្ត។

លើសពីនេះទៀត សិស្សត្រូវភ្ជាប់ពុទ្ធិ និងបំណិនទទួលបានពីដំណើរការរៀននៅសាលារៀនជាមួយនឹងតម្រូវការប្រចាំថ្ងៃ និងអនាគត។ សំខាន់ដូចគ្នាពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែត្រូវប្រតិបត្តិគុណសម្បទាសតវត្សរ៍ទី២១ គុណសម្បទាពលរដ្ឋសកល គុណតម្លៃមនុស្ស និងចរណមនុស្សគ្រប់កាល បរិបទ និងលក្ខខណ្ឌ ដើម្បីបម្រើផលប្រយោជន៍មនុស្ស ។

ការស្រាវជ្រាវជាច្រើនបញ្ជាក់ថា សិស្សអភិវឌ្ឍគុណសម្បទាច្រើនបែបច្រើនយ៉ាង ឱ្យក្លាយជាពលរដ្ឋពូកែ ឬពលរដ្ឋពេញលេញ នៅពេលប្រព័ន្ធសាលារៀនអនុវត្តកម្មវិធីសិក្សា ដោយប្រើ៖

- គោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល
- វិធីសាស្ត្រសិក្សាបញ្ញត្តិ
- វិធីសាស្ត្របុច្ឆនសិក្សា
- ទិសវិធីដឹកនាំការរៀន

១៤.១ គោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល

របកគំហើញ នៃការស្រាវជ្រាវជាច្រើននៅប្រទេសផ្សេង អំពីការអនុវត្តវិធីសាស្ត្របង្រៀន ក៏មិនសូវខុសពីបរិបទកម្ពុជាដែរ។ របកគំហើញជាច្រើនបញ្ជាក់ថា ការលំបាក ក្នុងបន្ទប់រៀន សាលារៀន ការខ្វះខាតបំណិន និងវិជ្ជាអំពីវិធីសាស្ត្រគរុកោសល្យច្រើនបែបច្រើនយ៉ាង គ្រូបង្រៀនត្រូវបង្ខំចិត្តអនុវត្តគោលវិធីគរុកោសល្យគ្រូមជ្ឈមណ្ឌល។ របកគំហើញនៃការស្រាវជ្រាវរបស់ Ganza (2008), Tomlinson (1999) និង Westwood (2008) បញ្ជាក់ថា ការអនុវត្តគោលវិធីគរុកោសល្យគ្រូមជ្ឈមណ្ឌល ផ្តល់ឱកាសឱ្យសិស្សរៀនសើៗ រៀនផ្ទៃខាងលើនៃព័ត៌មានបានពីគ្រូបង្រៀន និងពីសៀវភៅសិក្សាគោល។

Ganza (2008), Tomlinson (1999)និងWestwood (2008) បញ្ជាក់បន្ថែមទៀតថា ការអនុវត្តគោលវិធីគរុកោសល្យគ្រូមជ្ឈមណ្ឌលជាទូទៅ បណ្តុះទម្លាប់សិស្សឱ្យរង់ចាំទទួលព័ត៌មានពីគ្រូបង្រៀន និងសៀវភៅសិក្សា និងបណ្តុះទម្លាប់អសកម្មក្នុងដំណើរការរៀន។ ការទទួលបានផ្ទៃលើនៃព័ត៌មានក្នុងសៀវភៅសិក្សា និងរង់ចាំការបកស្រាយរបស់គ្រូបង្រៀន មិនធានាឱ្យដំណើរការរៀនពិតប្រាកដ កើតឡើងសម្រាប់សិស្សភាគច្រើនបានទេ។ សិស្សមានតម្រូវការពិសេស សិស្សរៀនយឺត និងសិស្សរៀនខ្សោយ កាន់តែពិបាកទទួលបានវិជ្ជា បំណិន និងចរិយាដូចចេតនានៃកម្មវិធីសិក្សាណាស់។

គោលវិធីបង្រៀនដែលគ្រូបង្រៀន និងសៀវភៅសិក្សាគោលជាប្រភពនៃពុទ្ធិ គឺខ្វះការដឹកនាំសិស្សឱ្យអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ ឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃខ្លឹមសារ អង្គហេតុ គោលគំនិត និងបញ្ញត្តិពីច្រើនប្រភព និងគួរឱ្យទុកចិត្ត។

អ្នកស្រាវជ្រាវអំពីវិធីសាស្ត្រគរុកោសល្យ និងអំពីទ្រឹស្តីអប់រំ ដូចជា (Tyler, 1949), Anderson, Krathwohl, & Airasian (2001), Coffman (2013), Andersen & Andersen (2017), Alfrieri, Brooks, Aldrich, & Harriet (2011), Ay (2017), Biggs & Tang (2011), Erickson (2008), Houghton (2004), Westwood (2008), Weinbaum, et al (2004), Watkins, Carnell, & Lodge (2007) បានផ្តល់យោបល់ឱ្យប្រតិបត្តិការដឹកនាំការរៀនដោយទុកសិស្សជាគោល ឬជាស្នូលនៃសកម្មភាពរៀនក្នុងថ្នាក់ និងក្រៅថ្នាក់។ របកគំហើញនៃការស្រាវជ្រាវទាំងអស់នេះផ្តល់យោបល់ថា ការផ្តល់ឱកាសឱ្យសិស្សប្រើបំណិនបង្កើតសំណួរ សួរសំណួរ និងរកការពន្យល់ដោយខ្លួនឯង និងបកស្រាយគំនិតរកឃើញប្រកបដោយឯករាជ្យ និងសេរីភាព គឺគ្រូបង្រៀនដាំបណ្តុះចិត្តទទួលខុសត្រូវ និងចិត្តសកម្ម។ ចិត្តដែលបានបណ្តុះបណ្តាលបែបនេះ គឺសំដៅនាំផ្លូវសិស្សឱ្យបង្កើតពុទ្ធិថ្មី ពង្រីក និងបន្ថែមជម្រៅនៃពុទ្ធិជាប្រចាំ។

ដូច្នេះ ប្រព័ន្ធអប់រំ សាលារៀន ថ្នាក់រៀន គ្រូបង្រៀន និងអ្នកស្រាវជ្រាវអំពីវិធីសាស្ត្រគរុកោសល្យ ឬវិធីសាស្ត្របង្រៀន បង្វែរទិសមកណែនាំគ្រូបង្រៀនឱ្យអនុវត្តគោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល។ ជាច្រើនទសវត្សរ៍កន្លងមកប្រព័ន្ធអប់រំបានបំពាក់គុណសម្បទាច្រើនបែបច្រើនយ៉ាង មានដូចជាវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា ចរណមនុស្ស និងគុណតម្លៃមនុស្សដល់សិស្សសម្រាប់យកទៅបំពេញតម្រូវការជីវិត រៀនបន្ត និងជួយសង្គម។

កម្ពុជាបានណែនាំការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ពីរបីទសវត្សរ៍មកហើយ តាំងពីទសវត្សរ៍ឆ្នាំ១៩៨០ និង១៩៩០។ មនុស្សមួយចំនួនចោទចម្ងល់សាមញ្ញមួយ។ ហេតុអ្វីបានជាសិស្សភាគច្រើនពុំបានរៀនបំណិន និងវិជ្ជាច្រើនបែបច្រើនយ៉ាង? លទ្ធផលវាយតម្លៃលទ្ធផលសិក្សា និងគុណផលសិក្សារបស់សិស្ស ជាច្រើនផ្តល់អំណះអំណាងអំពីភាពខ្សោយ នៃសិស្សកម្ពុជា ដូចជា ៖

- លទ្ធផល នៃការប្រឡងមធ្យមសិក្សាទុតិយភូមិពីឆ្នាំ២០១៤ដល់២០១៩
- តេស្តថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ និងទី៨ លើមុខវិជ្ជាភាសាខ្មែរ វិទ្យាសាស្ត្រ និងគណិតវិទ្យាក្នុងឆ្នាំ២០១៥ ឆ្នាំ២០១៦ និងឆ្នាំ២០១៧

- លទ្ធផលនៃការវាយតម្លៃការសិក្សារបស់សិស្សកម្ពុជាកម្រិតអន្តរជាតិ អាយុ១៥ឆ្នាំ (PISA-D ២០១៨) ជាភស្តុតាង។

លទ្ធផលនៃការវាយតម្លៃទាំងនេះ ផ្តល់អំណះអំណាងយ៉ាងរឹងមាំ ឱ្យកែទម្រង់ការអប់រំច្រើនកន្លែង។ កម្ពុជាត្រូវបង្រៀនសិស្សឱ្យអភិវឌ្ឍបំណិន វិជ្ជាទម្លាប់ និងការប្រព្រឹត្តិច្រើនបែបច្រើនយ៉ាងដើម្បីបំពេញតម្រូវការនៃការងារក្នុងយុគឧស្សាហកម្ម៤.០។ លទ្ធផលនៃការវាយតម្លៃទាំងនេះ ពន្យល់ថា ដំណើរការរៀន ការបង្រៀន ការដឹកនាំការរៀន កម្មវិធីសិក្សា កម្មវិធីបណ្តុះបណ្តាល និងអប់រំគ្រូបង្រៀន និងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលនៅកម្ពុជា ពិតជាមានជំងឺ ឬ កើតរោគក្នុងដំណាក់កាលណាមួយ (Tomlinson , 1999)។

សិស្សភាគច្រើនរៀនចេះ ឬមិនចេះជាបញ្ហាមួយ។ ដើម្បីបញ្ជាក់សេចក្តីពិត សូមអ្នកគ្រូ លោកគ្រូចំណាយពេល៥៩វិនាទីគិត និងរំឮកអំពីទម្លាប់របស់អ្នកគ្រូ លោកគ្រូ។ សូមលោកគ្រូ អ្នកគ្រូរំឮកអំពីការតាក់តែងលំនាំ នៃការដឹកនាំការរៀន កិច្ចតែងការបង្រៀន ការជ្រើសរើសវិធីសាស្ត្រ យុទ្ធវិធីដឹកនាំការរៀន ការបែងចែកប្រភេទសិស្ស ការពន្យល់អំពីទម្លាប់ និងវិធីរៀនរបស់សិស្ស ការវាយតម្លៃលទ្ធផលសិក្សា សមត្ថភាពយល់ខ្លឹមសារ និងបញ្ញត្តិនៃមេរៀន ការប្រើប្រាស់លទ្ធផលនៃការវាយតម្លៃការសិក្សារបស់សិស្ស ដើម្បីប្តូរទម្លាប់បង្រៀន និងដឹកនាំការរៀន។ ចូរអ្នកគ្រូ លោកគ្រូសួរខ្លួនឯង និងឆ្លើយសំណួរខាងក្រោម ៖

- តើខ្ញុំយល់ខ្លឹមសារ និងបញ្ញត្តិនៃមេរៀនក្នុងសៀវភៅសិក្សាកម្រិតណា?
- តើខ្ញុំយកទ្រឹស្តីអ្វីជាគោល សម្រាប់សរសេរលទ្ធផលសិក្សានៃមេរៀន?
- តើខ្ញុំប្រើអ្វីជាគោល និងប្រើទ្រឹស្តីអ្វី សម្រាប់សរសេរគោលបំណងនៃការតាក់តែងកិច្ចតែងការបង្រៀន និងសរសេរមេរៀន?
- តើខ្ញុំសរសេរអ្វីខ្លះ និងប្រើកិរិយាសព្ទប្រភេទអ្វី ក្នុងការសរសេរគោលបំណង និងលទ្ធផលសិក្សាក្នុងមេរៀន?
- មុនសរសេរគោលបំណងក្នុងកិច្ចតែងការ តើខ្ញុំបានគិត និងរកបញ្ញត្តិសម្រាប់ដំណើរការដឹកនាំការរៀនដោយរបៀបណា?

- តើក្នុងគោលបំណងនៃមេរៀន ខ្ញុំបានគិតអំពីលទ្ធផលសិក្សាអ្វីខ្លះដែលសិស្សធ្វើកើតក្រោយចប់មួយមេរៀនៗ?
- តើខ្ញុំបំបែកភាពខុសគ្នារវាងគោលបំណង និងលទ្ធផលសិក្សាបានឬទេ?
- តើខ្ញុំគិតល្អិតល្អន់អំពីបំណិនដែលសិស្សត្រូវចេះ ក្រោយចប់មេរៀនឬទេ?
- តើមេរៀនដែលខ្ញុំបង្រៀនបានជំរុញការផ្លាស់ប្តូរការគិត វាចា និងការប្រព្រឹត្តិរបស់សិស្សកម្រិតណា?
- តើខ្ញុំបានបញ្ចូលបំណិនសតវត្សរ៍ទី២១ ឬបំណិនពលរដ្ឋសកលអ្វីខ្លះ ក្នុងដំណើរការរៀន និងការដឹកនាំការរៀនរបស់ខ្ញុំ?
- តើខ្ញុំគ្រោងប្រើយុទ្ធវិធីដឹកនាំការរៀនអ្វីខ្លះដើម្បីសម្រេចលទ្ធផលសិក្សា?
- តើខ្ញុំប្រើយុទ្ធវិធីអ្វីខ្លះក្នុងការវាយតម្លៃដំណើរការរៀន និងវាស់លទ្ធផលនៃការសិក្សារបស់សិស្ស?
- តើខ្ញុំបានបង្កើតផែនការសម្រាប់ជួយដល់សិស្សដែលមិនបានរៀនពិតប្រាកដ ឬ មិនសម្រេចតាមលទ្ធផលសិក្សាហើយឬនៅ?
- ក្នុងផែនការជួយសិស្សរៀនយឺត រៀនខ្សោយ ឬសិស្សមានតម្រូវការពិសេស តើខ្ញុំបញ្ជាក់ច្បាស់អំពីយុទ្ធវិធី និងសកម្មភាពរបស់សិស្សឬទេ?
- ប្រសិនបានបង្កើតផែនការជួយសិស្សរៀនយឺត រៀនខ្សោយ ឬសិស្សមានតម្រូវការពិសេស តើខ្ញុំបានអនុវត្ត កម្រិតណា?

ការដឹកនាំការរៀន និងការបង្រៀន ដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌល ជាការចាត់ចែង ឬចំណាត់ការលើដំណើរការរៀនរបស់សិស្ស ដោយផ្តល់ឱកាសឱ្យសិស្សប្រើបទពិសោធ ចំណេះដឹង បំណិន និងទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួនឯង។ ការដឹកនាំការរៀន និងការបង្រៀន ដោយប្រើគោលវិធីសិស្សមជ្ឈមណ្ឌល សំដៅបំពេញតម្រូវការ ចំណង់ចំណូលចិត្ត ទម្លាប់ និងវិធីរៀនរបស់សិស្ស។ ដើម្បីឆ្លើយសំណួរខាងលើ តើលោកគ្រូ អ្នកគ្រូចំណាយពេលប៉ុន្មាន? តើអ្នកគ្រូ លោកគ្រូមានភស្តុតាងពន្យល់អំពីសេចក្តីពិត ចំពោះចម្លើយនៃសំណួរខាងលើដែរឬទេ?

១៤.១.១ សិក្សាទ្រឹស្តី

គោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល ឬគោលវិធីសិស្សមជ្ឈមណ្ឌល មានការពេញនិយមតាំងពីទសវត្សរ៍ឆ្នាំ១៩៩០ ក្នុងបរិបទអប់រំកម្ពុជា។ គោលវិធីនេះសំដៅដាក់សិស្សចំកណ្តាលស្នូលនៃដំណើរការរៀន និងដឹកនាំការរៀន។ មកដល់ឆ្នាំ២០២០ ប្រព័ន្ធអប់រំកម្ពុជាពុំសូវមានលទ្ធផលវិភាគ ឬរបកគំហើញនៃការស្រាវជ្រាវអំពីការអនុវត្ត ប្រសិទ្ធភាព គុណផល និងបញ្ហាប្រឈម ពាក់ព័ន្ធនឹងគោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌលនៅឡើយទេ។

របកគំហើញនៃការស្រាវជ្រាវជាច្រើនពន្យល់ថា សិស្សមានឱកាសប្រើពុទ្ធិ បំណិន និងបទពិសោធផ្ទាល់ខ្លួន ក្នុងដំណើរការរៀនជាមួយគ្រូបង្រៀនដែលអនុវត្តគោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល។ ដោយសារហេតុផលនេះ អ្នកស្រាវជ្រាវជាច្រើននាក់បានប្រើទ្រឹស្តីអប់រំ វិទ្យាសាស្ត្រនៃការរៀន និងក្របខ័ណ្ឌនៃពុទ្ធិ ដើម្បីបង្កើតវិធីសាស្ត្រដឹកនាំការរៀន និងការបង្រៀនច្រើនយ៉ាង។ វិធីសាស្ត្រមួយចំនួនដែលជួយគ្រូបង្រៀន ក្នុងការដឹកនាំសិស្សរៀនឱ្យទទួលបានគុណផលខ្ពស់ មានដូចជា៖

- Bonwell & Eison (1991) បង្កើតវិធីសាស្ត្ររៀនសកម្ម (Active Learning) ដើម្បីឱ្យគ្រូបង្រៀនដឹកនាំការរៀន និងបង្រៀនក្នុងថ្នាក់ដែលធានាឱ្យសិស្សទទួលអារម្មណ៍សប្បាយក្នុងដំណើរការរៀន។ លើសពីនេះទៀត សិស្សចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀន និងបានចែករំលែកពុទ្ធិ បទពិសោធ និងបំណិនច្រើនបែបច្រើនយ៉ាង ក្នុងដំណើរការរៀន ជាមួយមិត្តរួមថ្នាក់ ជាមួយគ្រប់ប្រភេទសិស្ស គិតទាំងសិស្សមានតម្រូវការពិសេស និងសិស្សរៀនយឺត។
- Joseph Schwab (1960) បានបង្កើតវិធីសាស្ត្ររៀន និងដឹកនាំការរៀនមួយ **បុច្ឆនសិក្សា** (Inquiry-based Learning) ( CONNELLY, 2013; WESTBURY, 2013)។ របកគំហើញនៃការស្រាវជ្រាវរបស់ Joseph Schwab (1960) បញ្ជាក់ថា ការរៀនពិតប្រាកដត្រូវពឹងអាស្រ័យលើការស្វែងការពន្យល់រកភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ ដោយប្រើពុទ្ធិ បទ

ពិសោធ និងបំណិនរបស់សិស្ស។ របកគំហើញនៃការស្រាវជ្រាវនេះបានបញ្ជាក់បន្ថែមថា សិស្សរៀនតាមបុច្ឆនសិក្សា គឺរំកិលការគិតរបស់សិស្សពីទន្ទេញ សូត្ររត់មាត់ ទៅស្វែងការពន្យល់ដោយឯករាជ្យ ប្រើភស្តុតាងពីច្រើនប្រភព និងគួរឱ្យទុកចិត្ត។ ដើម្បីបំភ្លឺសេចក្តីពិត ត្រឹមត្រូវ និងច្បាស់លាស់លើបញ្ញត្តិមួយ សិស្សត្រូវចាប់ផ្តើមគិត ឆ្ងល់ សង្កេត បង្កើតសំណួរ សួរសំណួរ និងរកប្រភពភស្តុតាង។

- Kenneth A. Bruffee (1998) បានបង្កើតវិធីសាស្ត្ររៀនបែបសហការ (Collaborative Learning) ដោយផ្តោតការយកចិត្តទុកដាក់លើការបង្រៀន និងរៀនភាសា។ វិធីសាស្ត្រនេះពេញនិយមខ្លាំងក្នុងទសវត្សរ៍ឆ្នាំ ១៩៩០។ វិធីសាស្ត្រនេះដឹកនាំសិស្សឱ្យរៀនរួមគ្នាជាមួយមិត្តភក្តិ និងដឹកនាំសិស្សឱ្យអនុវត្តទម្លាប់ស្តាប់ និយាយ និងសរសេររួមគ្នា។ សំខាន់ផងដែរ សិស្សប្រើបទពិសោធ ចំណេះដឹង និងបំណិនផ្ទាល់ខ្លួនក្នុងដំណើរការរៀនក្នុងថ្នាក់រៀនជាមួយមិត្តភក្តិ ក្នុងស្ថានភាព និងទម្រង់ជាច្រើន។
- បងប្អូនពីរនាក់ Johnson, Johnson, & Smith (1991) បង្កើតវិធីសាស្ត្ររៀន និងដឹកនាំការរៀនមួយឈ្មោះថា **សហប្រតិបត្តិការរៀន** (Cooperative learning)។ វិធីសាស្ត្រនេះផ្តោតការយកចិត្តទុកដាក់ធំលើការសិក្សាជាក្រុមតូច ក្នុងចំណោមសិស្ស និងសិស្ស។ របកគំហើញនៃការស្រាវជ្រាវរបស់ Johnson, Johnson, & Smith (1991) ពន្យល់ថា វិធីសាស្ត្ររៀន និងដឹកនាំការរៀនក្នុងលំនាំសហប្រតិបត្តិការ រវាងសិស្ស និងសិស្ស គឺសិស្សជួយគ្នាបានច្រើន និងអភិវឌ្ឍបំណិនសតវត្សរ៍ទី២១។ Johnson, Johnson, & Smith (1991) សរសេរលំនាំនៃការដឹកនាំការរៀនឱ្យងាយយល់ ប្រដូចវិធីសាស្ត្រសហប្រតិបត្តិការរៀន ទៅនឹងការហែលទឹកឆ្លងព្រែកមួយជាមួយគ្នា។
- មនុស្សមួយក្រុម មានអ្នកចេះហែលទឹកស្ទាត់ អ្នកចេះហែលតិចតួច និងអ្នកមិនចេះហែលទឹកសោះ។ ក្នុងសម័យដើម មនុស្សពុំទាន់បង្កើតបានឧបករណ៍ឆ្លងទឹក ដូចជា ក្បូន ឬទូកទេ។ សំណួរសួរថា តើត្រូវទុកឱ្យអ្នក

ខ្លះលង់ទឹកស្លាប់ ជួយបង្ហាត់បង្រៀនគ្នាឱ្យចេះហែលទឹកទាំងអស់គ្នា និងត្រូវហែលទឹកឆ្លងព្រែកជាមួយគ្នា និងទាំងអស់គ្នា? អ្នកចេះហែលទឹកត្រូវហែលទឹកឆ្លងព្រែក ទៅចោលអ្នកមិនចេះហែលទឹកឬយ៉ាងណា? ចម្លើយគឺ មនុស្សត្រូវបង្ហាត់គ្នាឱ្យចេះហែលទឹក។ Johnson, Johnson, & Smith (1991) បញ្ជាក់ថា វិធីសាស្ត្រសហប្រតិបត្តិការរៀននេះ ខុសពីការរៀនជាក្រុម ឬធ្វើការជាក្រុម ក្នុងទម្រង់នៃសកម្មភាព ប៉ុន្តែសិស្សចេះជួយគ្នាក្នុងគ្រប់បរិបទ។

- សាស្ត្រាចារ្យ Howard S. Barrows (ឆ្នាំ១៩២៨-២០១១) បង្កើត**វិធីសាស្ត្ររៀនតាមបញ្ហា** (problem-based learning) សម្រាប់បណ្តុះបណ្តាលគ្រូពេទ្យ ក្នុងទសវត្សរ៍ឆ្នាំ១៩៨០។ របកគំហើញនៃការស្រាវជ្រាវរបស់សាស្ត្រាចារ្យ Howard S. Barrows ត្រូវបានប្រើយ៉ាងពេញនិយម សម្រាប់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ជាបន្តបន្ទាប់ទៀត។
- **វិធីសាស្ត្ររៀនតាមបញ្ហា** (problem-based learning) ស្រដៀងគ្នានឹងវិធីសាស្ត្ររៀនតាមគម្រោង (Project-based learning) (Kilbane & Milman, 2014)។ ការដឹកនាំការរៀនដោយប្រើវិធីសាស្ត្រតាមបញ្ហា សិស្សអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង ដូចជា សហការក្រុម ប្រាស្រ័យមនុស្ស គិតកម្រិតខ្ពស់ ដោះស្រាយបញ្ហា។ Kilbane & Milman (2014) ពន្យល់ថា សិស្សដែលបានរៀនជាមួយគ្រូបង្រៀន ប្រើវិធីសាស្ត្របង្រៀនតាមបញ្ហា (problem-based learning) ឬវិធីសាស្ត្ររៀនតាមគម្រោង (Project-based learning) សិស្សអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង ពិសេសបំណិនរកព័ត៌មានពីច្រើនប្រភព ជ្រើសរើសទិន្នន័យ ធ្វើផែនការ អនុវត្ត តាមដាន និងវាយតម្លៃគុណផលរបស់គម្រោង។
- គោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល មានវិធីសាស្ត្រសម្បូរបែប។ Michaelson, Knight, & Fink (2004) បានបង្កើតវិធីសាស្ត្របង្រៀនមួយហៅថា ការរៀនជាក្រុម (Team-based learning)។ Tien, Roth, & Kampmeier (2001) បង្កើតវិធីសាស្ត្របង្រៀនមួយទៀតហៅ ការរៀនដៃ

គូជាក្រុម (Peer-led team learning)។ Mazur (1997) បង្កើតវិធីសាស្ត្រមួយ ហៅថា ការណែនាំជាដៃគូ (Peer Instruction) ។

១៤.១.២ បញ្ហាប្រឈម

ប្រសិទ្ធភាពនៃការអនុវត្តវិធីសាស្ត្របង្រៀន ដូចបានរៀបរាប់ក្នុងចំណុច ១៤.១.១ គឺពិបាករក ក្នុងបរិបទសាលារៀន និងថ្នាក់រៀននៅកម្ពុជា។ ប្រសិនបើបានសម្ភាសគ្រូបង្រៀន២០នាក់ ដោយឱ្យឆ្លើយសំណួរមួយចំនួនដូចខាងក្រោម ៖

- តើលោកគ្រូ អ្នកគ្រូ ប្រើគោលវិធីសិស្សមជ្ឈមណ្ឌលដែរឬទេ? ចម្លើយពិតជាបានប្រើគោលវិធីសិស្សមជ្ឈមណ្ឌលជាប្រចាំ។
- ប្រសិនបើសួរគ្រូបង្រៀនមួយសំណួរបន្តទៀត។ ក្នុងចំណោមវិធីសាស្ត្ររៀបរាប់ក្នុង១៤.១.១ តើអ្នកគ្រូ លោកគ្រូពិតជាបានប្រើមួយណាកាលពីមួយសប្តាហ៍មុន ឬមួយថ្ងៃមុនឬទេ? ចម្លើយពិតជាបញ្ជាក់ថា គ្រូបង្រៀនបានអនុវត្តញឹកញាប់ណាស់។
- ប្រសិនបន្តសួរសំណួរមួយទៀត។ ក្នុងមួយឆ្នាំសិក្សាកន្លងទៅ តើអ្នកគ្រូលោកគ្រូប្រើវិធីសាស្ត្របង្រៀនតាមគម្រោងបានប៉ុន្មានលើកដែរ? អ្នកស្រាវជ្រាវពិតជាពិបាករក ឬអាចរកមិនបានផងដែរ។

ការអនុវត្តវិធីសាស្ត្រដឹកនាំការរៀនរៀបរាប់ខាងលើ ប្រហែលជាពិបាករកក្នុងបរិបទអប់រំ សាលារៀន និងថ្នាក់រៀននៅកម្ពុជា។ បរិបទអប់រំកម្ពុជាប្រឈមនឹងការលំបាកច្រើនប្រភេទ ច្រើនយ៉ាង ដូចជា ៖

- ថ្នាក់រៀនមានសិស្សច្រើនលើសពី៥០នាក់
- គ្រូបង្រៀនមានគុណវុឌ្ឍិទាប
- គ្រូបង្រៀនខ្លះរៀនមិនចប់មធ្យមសិក្សាទុតិយភូមិ
- គ្រូបង្រៀនខ្លះប្រឡងមិនជាប់មធ្យមសិក្សាទុតិយភូមិ
- សាលារៀនខ្វះសៀវភៅសិក្សាគោល
- គណៈគ្រប់គ្រងសាលារៀន មិនទាន់ច្បាស់អំពីការដឹកនាំសាលារៀន តាមគោលការណ៍គណនេយ្យភាពក្នុងវិស័យអប់រំ

- នាយកសាលា និងថ្នាក់ដឹកនាំសាលារៀន ពុំសូវមានឱកាសទទួលបានការបណ្តុះបណ្តាលអំពីការគ្រប់គ្រងសាលារៀន តាមគោលការណ៍គណនេយ្យភាព ក្នុងវិស័យអប់រំ
- ម្តាយឪពុក និងតំណាងសហគមន៍ ពុំសូវចូលរួមជួយក្នុងដំណើរការធានាគណនេយ្យភាពក្នុងសាលារៀន។

ការអនុវត្តវិធីសាស្ត្របង្រៀន និងយុទ្ធវិធីដឹកនាំការរៀនតាមគោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល មានការពិបាកច្រើន ដូចជា៖

- សាលារៀនអត់មានបណ្ណាល័យ
- បណ្ណាល័យក្នុងសាលារៀនមិនដំណើរការ
- ទម្រង់នៃការចាត់ចែងបន្ទប់រៀន មានលក្ខណៈប្រពៃណីពេក
- ទម្រង់នៃការចាត់ចែងបន្ទប់រៀនមិនសមប្រកបនឹងសិស្សសតវត្សរ៍ទី២១
- ការចាត់ចែងតុអង្គុយ កៅអីអង្គុយ និងក្តារខៀន ប្រពៃណីពេក
- សាលារៀនខ្វះសម្ភារឧបទេស
- សាលារៀនទទួលបានថវិកាទ្រទ្រង់ការអភិវឌ្ឍស្តួចស្តើងពេក។

ពេលជជែកគ្នាអំពីការផ្លាស់ប្តូរ ឬកំណែទម្រង់នៃដំណើរការបង្រៀន ឬដឹកនាំការរៀន គ្រូបង្រៀន និងអ្នកអប់រំច្រើនចោទជាសំណួរផ្សេងៗ។ សំណួរបីពេញនិយមបំផុត គឺ ៖

- តើការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ខុសឆ្គងអ្វីខ្លះ?
- តើគោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌលខុសឆ្គងកន្លែងណា?
- តើការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល សិស្សមិនចេះមែនឬទេ?

ការស្វែងការពន្យល់ចំពោះសំណួរបីខាងលើ ដូចយើងសាកល្បងពន្យល់អំពីនាមវត្ថុ និងរូបវត្ថុដែលរកឃើញ និងរកមិនទាន់ឃើញក្នុងស្រទាប់ផែនដី លើផែនដី ក្នុងសមុទ្រ និងក្នុងរាងកាយមនុស្សយ៉ាងដូច្នេះដែរ។

ដើម្បីបានជាចំណេះដឹង និងវិជ្ជាឱ្យស៊ីជម្រៅអំពីប្រសិទ្ធភាព និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល គ្រូបង្រៀនគួរអានរបកគំហើញនៃការស្រាវជ្រាវឱ្យបានច្រើន ក្នុងអន្តរបណ្តាញអ៊ិនធឺណេត។

Google Scholar ជាប្រភពពន្យល់បន្ថែមអំពីហេតុផលនៃការផ្លាស់ប្តូរលំនាំនៃការដឹកនាំការរៀន វិធីសាស្ត្រ យុទ្ធវិធីបង្រៀន និងសកម្មភាពវាយតម្លៃការសិក្សា និងលទ្ធផលសិក្សារបស់សិស្ស។ លោកគ្រូ អ្នកគ្រូ គួរស្វែងការពន្យល់បន្ថែមអំពីវិធីសាស្ត្រផ្សេងៗ និងគុណផលនៃការរៀនរបស់សិស្ស រៀនក្នុងថ្នាក់ និងរៀនជាមួយគ្រូបង្រៀនដែលអនុវត្តវិធីសាស្ត្រផ្សេងៗដែរ។

១៤.១.៣ គោលការណ៍

សរុបសេចក្តីជារួម ឆ្លើយតបនឹងគោលវិធីសិស្សមជ្ឈមណ្ឌល អ្នកស្រាវជ្រាវជាច្រើននាក់ បោះពុម្ពឯកសារស្រាវជ្រាវជាច្រើនអំពីវិធីសាស្ត្របង្រៀន និងដឹកនាំការរៀនផ្សេងគ្នា។ សៀវភៅនេះសង្ខេបគោលការណ៍មួយចំនួន ក្នុងការប្រើគោលវិធីសិស្សមជ្ឈមណ្ឌល ដែលគ្រូបង្រៀនគ្រប់មុខវិជ្ជា គួរទទួលយក និងប្រតិបត្តិប្រចាំថ្ងៃ។

គោលការណ៍ ០១ ៖ សិស្សនិងគ្រូជាសហការីក្នុងការរៀនជាមួយគ្នា

មនុស្សណាក៏ពិបាកទទួលយកគំនិតចម្លែក ឬគំនិតខុសពីខ្លួនដែរ។ គ្រូបង្រៀនក៏អាចពិបាកទទួលយកគំនិតចម្លែកៗ និងផ្ទុយរបស់សិស្សដែរ។ គ្រូបង្រៀនត្រូវបើកចិត្តឱ្យទូលាយទទួលយកគំនិតចម្លែក និងផ្ទុយរបស់សិស្ស។ គ្រូបង្រៀនគួរប្រតិបត្តិគោការណ៍នេះ ដោយលើកទឹកចិត្តសិស្សឱ្យស្រាវជ្រាវរកអង្គហេតុ ដើម្បីពន្យល់គំនិតចម្លែកៗ និងគំនិតផ្ទុយ។

គ្រូបង្រៀនគួរលុបទស្សនៈថា គ្រូបង្រៀនមានចំណេះដឹង និងវិជ្ជាខ្ពង់ខ្ពស់ និងច្បាស់លាស់ជាងសិស្ស។ គ្រូបង្រៀនអាចមានបទពិសោធជីវិតយូរអង្វែងជាង និងបានរៀនច្រើនជាងសិស្សមែន។ គ្រូបង្រៀនពុំមែនដឹង ចាំ ចេះ និងយល់អ្វីៗគ្រប់យ៉ាងច្រើនជាងសិស្សទេ ជាពិសេសក្នុងយុគឌីជីថល។ គ្រូបង្រៀនត្រូវត្រៀមខ្លួន និងប្រតិបត្តិទម្លាប់រៀនជាមួយសិស្ស និងរៀនពីសិស្សជាប្រចាំ។

ចំណេះដឹង និងវិជ្ជាថ្មីនៅជាមួយម្រាមដៃ។ ក្នុងយុគនៃបច្ចេកវិទ្យាព័ត៌មាន សិស្សអាចសួរបុរសសង្ហា Youtube ឬកញ្ញាស្រស់ Google ក្នុងមួយនាទីឱ្យតែសិស្សមានបំណិនប្រើពាក្យបច្ចេកទេសជាភាសាអង់គ្លេស។ ក្នុងថ្ងៃអនាគតឯកសារជាភាសាខ្មែរនឹងមានច្រើនសម្បូរបែប។ ឧទាហរណ៍ មេរៀនមួយអំពី

មនុស្សសំខាន់ៗ កាលពី៣០០ឆ្នាំមុនគ្រិស្តសករាជក្នុងចក្រភពក្រិកបុរាណ ដូចជា ពីតាហ្គ័រ (Pythagoras) ឬអាឡិចហ្សង់មហារាជ (Alexander the Great)។ សិស្សពិតជារកព័ត៌មានបានច្រើន មកចែករំលែកជាមួយសិស្ស និងគ្រូបង្រៀន ក្នុងថ្នាក់រៀន អំពីមនុស្សសំខាន់ៗទាំងនេះ។ ឧទាហរណ៍ គ្រូបង្រៀនចង់ឱ្យសិស្សរកចំណេះដឹងថ្មីអំពីប្រវត្តិនៃការកកើតផែនដី ឬគម្លាតនៃទ្វីបអាស៊ី និងអឺរ៉ុបកាលពី ២លានឆ្នាំមុនគ.ស. ឬគម្លាតនៃប្រទេសអូស្ត្រាលី និងប្រទេសម៉ាឡេស៊ី កាលពី១លានឆ្នាំមុនគ.ស.។

គ្រូបង្រៀនមានទម្លាប់ប្រតិបត្តិគោលការណ៍នេះ គឺគ្រូបង្រៀនជួយសិស្សឱ្យអភិវឌ្ឍបំណិន ទម្លាប់ និងការប្រព្រឹត្តិច្រើនបែបច្រើនយ៉ាង ដូចជា ៖

- ប្រតិបត្តិទម្លាប់ស្មោះត្រង់
- និយាយសម្ដី ក្នុងមេត្រីភាព
- បើកចិត្តឱ្យទូលាយ
- ចុះសម្រុងនឹងអ្នកដទៃ
- ទទួលស្គាល់តម្លៃនៃសេចក្ដីពិត
- ឱ្យតម្លៃគំនិតដើម
- ខ្វល់ពីអ្នកដទៃ
- ប្រតិបត្តិគោលការណ៍សុជីវធម៌ សីលធម៌ គុណធម៌
- ប្រតិបត្តិទម្លាប់ជាអ្នកដឹកនាំ
- ទទួលយកការផ្លាស់ប្ដូរ
- ស្ដាប់ឱ្យកើតបញ្ញា (សុតមយប្បញ្ញា)

គោលការណ៍០២ ៖ ស្វាគមន៍គំនិតទិតៀន

ស្វាគមន៍គំនិតទិតៀនពីសិស្ស បង្កបរិយាកាសឱ្យសិស្សរៀនពិតប្រាកដ។ ការបង្កបរិយាកាសទិតៀនគំនិត បង្កបរិយាកាសមេត្រីភាព និងទាក់ទាញការចូលរួមរបស់សិស្សក្នុងដំណើរការរៀនពិតប្រាកដ។ គ្រូបង្រៀនចិត្តទូលាយ ទទួលយកការទិតៀន ឬគំនិតប្លែកៗរបស់សិស្ស ឬគំនិតផ្ទុយ។ ដូច្នេះ គ្រូបង្រៀនបានបង្កបរិយាកាសឱ្យសិស្សពង្រីកសមត្ថភាពគិត រកព័ត៌មាន ឬចំណេះដឹងថ្មីពីច្រើន

ប្រភព មកចែករំលែកជាមួយមិត្តរួមថ្នាក់ និងគ្រូបង្រៀន។ គ្រូបង្រៀនមានទម្លាប់ប្រតិបត្តិគោលការណ៍នេះ គឺគ្រូបង្រៀនជួយសិស្សឱ្យអភិវឌ្ឍបំណិនទម្លាប់ និងការប្រព្រឹត្តិច្រើនបែបច្រើនយ៉ាង ដូចជា ៖

- គិតដោយមានហេតុផល
- គិតចេញជាគំនិតថ្មីៗច្រើន
- គិតបែបយុទ្ធសាស្ត្រ
- គិតបែបច្នៃប្រឌិត
- គិតឱ្យបានច្រើនជម្រើស
- គិតហើយបន្តគិតទៀត
- គិតរកដំណោះស្រាយ
- គិតដើម្បីសម្រេចចិត្ត
- គិតលើការគិត (គិតរកភាពល្អប្រសើរ)

គោលការណ៍០៣ ៖ ប្រតិបត្តិទម្លាប់រៀនជាមួយសិស្ស និងរៀនពីសិស្ស

ការរៀនពិតប្រាកដ គឺស្រដៀងគ្នានឹងការធ្វើដំណើរផ្សងព្រេងក្នុងព្រៃជាមួយគ្នា រវាងគ្រូបង្រៀន និងសិស្ស។ ក្នុងដំណើរផ្សងព្រេង គ្រូបង្រៀន និងសិស្សមានភារកិច្ចផ្សេងគ្នា ដើម្បីទៅដល់គោលដៅរួមគ្នា។ ក្នុងឱកាសផ្សងព្រេងបែបនេះ សិស្សពិតជាមានឱកាសរកផ្លូវ និងសង្កេតធម្មជាតិដោយខ្លួនឯង។ ចំណែកគ្រូបង្រៀនក៏ត្រូវប្រតិបត្តិទម្លាប់រៀនពីសិស្ស នូវអ្វីដែលសិស្សសង្កេតឃើញ និងរកឃើញថ្មីដែរ។

សៀវភៅសិក្សាគោលនៃកម្មវិធីសិក្សារបស់ប្រព័ន្ធអប់រំទូទៅ បញ្ចូលវិជ្ជា និងបំណិនតិចតួចស្តួចស្តើង ប្រសិនបើធៀបនឹងតម្រូវការក្នុងសង្គម ការរស់នៅ រៀនបន្ត និងការងារ។ ដំណើរការរៀនបន្តជាប្រចាំជាមួយសិស្ស ជួយអភិវឌ្ឍបំណិន និងវិជ្ជាច្រើនបែបច្រើនយ៉ាង។ លោកគ្រូ អ្នកគ្រូសួរសំណួរមួយ។ តើសិស្សក្នុងថ្នាក់ទាំងមូលនឹងពង្រីកការចេះដឹងកម្រិតណា និងជម្រៅណា ប្រសិនបើសិស្សច្រើននាក់រកព័ត៌មានពីច្រើនប្រភព និងចែករំលែកគ្នាក្នុងថ្នាក់រៀន?

ដើម្បីបានព័ត៌មានយកមកប្រើការ និងចែករំលែកជាមួយសិស្សរួមថ្នាក់ និងគ្រូបង្រៀន តើសិស្សត្រូវអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាងកម្រិតណា?

ការផ្ដល់ឱកាសកាន់តែច្រើនឱ្យសិស្សជាដំណើរការរៀនពិតប្រាកដ និងរៀនទាំងអស់គ្នា (Ganza, 2008; Gidman & Casinader, 2017; Coffman, 2013; Blessinger & Cafora, 2014; Krauss & Boss, 2013)។ ការផ្ដល់ឱកាសកាន់តែច្រើនឱ្យសិស្ស រួមទាំងសិស្សរៀនយឺត សិស្សអសកម្ម សិស្សគ្រប់ប្រភេទនឹងចូលរួម ក្នុងសកម្មភាពរៀន បញ្ចេញសមត្ថភាពរកព័ត៌មាន និងចំណេះដឹងថ្មីពីប្រភពផ្សេង។ ការអនុវត្តគោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល គ្រូបង្រៀនគួរសួរសំណួរគោលពីរ ៖

- តើសិស្សមានជម្រើសអ្វីខ្លះក្នុងការរកវិជ្ជា និងបំណិនដោយខ្លួនឯង?
- តើគ្រូបង្រៀនបានផ្ដល់ការណែនាំ និងលំនាំសកម្មភាពអ្វីខ្លះឱ្យសិស្សស្វែងព័ត៌មាន ចំណេះដឹង និងវិជ្ជាពីច្រើនប្រភព?

គ្រូបង្រៀនមានទម្លាប់ប្រតិបត្តិគោលការណ៍នេះ គឺគ្រូបង្រៀនជួយសិស្សឱ្យអភិវឌ្ឍបំណិន ទម្លាប់ និងការប្រព្រឹត្តិច្រើនបែបច្រើនយ៉ាង ដូចជា ៖

- ស្វែងយល់គោលបំណងរួម
- ទទួលស្គាល់សេចក្ដីពិត
- ប្រតិបត្តិទម្លាប់ស្មោះត្រង់
- បើកចិត្តឱ្យទូលាយ
- ទទួលស្គាល់កំហុស
- ស្វ័យម្ចាស់ការ
- បកស្រាយគំនិត
- វាយតម្លៃគំនិត
- ឱ្យតម្លៃគំនិតដើម
- ប្រតិបត្តិទម្លាប់ជាអ្នកដឹកនាំ
- ចាប់ផ្ដើមគិត គឺចាប់ផ្ដើមសកម្មភាព
- និយាយសម្ដី ក្នុងមេត្រីភាព

គោលការណ៍០៤ ៖ ចំណាយពេលស្តាប់ការនិយាយរបស់សិស្សឱ្យចប់

ការតម្រៀបគំនិតសម្រាប់និយាយ ដោយមានអង្គហេតុ និងឧទាហរណ៍ ដើម្បីធានាឱ្យអ្នកស្តាប់យល់ និងទទួលយកគំនិតថ្មីៗ ពុំមែនជាការងាយស្រួលទេ។ សិស្សរៀនយឺត រៀនខ្សោយ សិស្សអៀន សិស្សខ្សោយការទំនាក់ទំនងខាងនិយាយ កាន់តែពិបាកថែមទៀត។ ដូច្នេះ គ្រូបង្រៀនគួរសាកល្បងឱ្យសិស្សប្រាប់អំពីបញ្ញត្តិអ្វីមួយ ឬគោលគំនិតអ្វីមួយទៅតាមអារម្មណ៍របស់សិស្ស និងទៅតាមសមត្ថភាព និងល្បឿននៃការគិត និងការរៀបលំដាប់នៃគំនិតរបស់សិស្ស។

របកគំហើញនៃការស្រាវជ្រាវជាច្រើនបញ្ជាក់ថា គ្រូបង្រៀន និងសិស្សដទៃច្រើនខ្វះការអត់ធ្មត់ និងស្តាប់សម្តីសិស្សខ្សោយឱ្យចប់សេចក្តី។ ទម្លាប់របស់លោកគ្រូ អ្នកគ្រូអនុញ្ញាតឱ្យសិស្សរៀនយឺត រៀនខ្សោយ អៀន មានតម្រូវការពិសេសសឡើងនិយាយ គឺជួយអភិវឌ្ឍបំណិនប្រាស្រ័យមនុស្ស និងពង្រីកទំនុកចិត្តចំពោះខ្លួនឯង (Roth & Lee, 2006; Carter, Ferzli, & Wiebe, 2007)។

គ្រូបង្រៀន និងសិស្សចំណាយចិត្តអត់ធ្មត់ស្តាប់ ជាការដាំបណ្តុះចិត្តខ្លួនឯងឱ្យចេះមានវីរយចិត្តក្នុងការរៀនបន្ត។ គ្រូបង្រៀនមានទម្លាប់ប្រតិបត្តិគោលការណ៍នេះ គឺគ្រូបង្រៀនជួយសិស្សឱ្យអភិវឌ្ឍបំណិន ទម្លាប់ និងការប្រព្រឹត្តិច្រើនបែបច្រើនយ៉ាង ដូចជា ៖

- ឱ្យតម្លៃនានាភាព ពហុភាព និងភាពផ្សេងគ្នានៃគំនិត
- ចែករំលែកក្តីស្រលាញ់ និងសុចរិតភាព
- ឱ្យតម្លៃចំពោះគោលបំណងរួមនៃដំណើរការរៀន
- ទទួលស្គាល់ការពិត
- បើកចិត្តទូលាយ និងទទួលយកភាពផ្សេងគ្នា
- លើកទឹកចិត្តសមាជិកនៃថ្នាក់រៀន
- ប្រតិបត្តិទម្លាប់ស្មោះត្រង់
- ចុះសម្រុងនឹងអ្នកដទៃ
- ប្រតិបត្តិគោលការណ៍សុជីវធម៌ សីលធម៌ គុណធម៌
- ឱ្យតម្លៃគំនិតដើម

- ចូលរួមសកម្មក្នុងដំណើរការរៀន
- ឱ្យតម្លៃចំពោះតួនាទី និងភារកិច្ចផ្សេងគ្នា
- រក្សាចិត្តស្ងៀមស្ងាត់

គោលការណ៍០៥ ៖ ចែករំលែកចំណេះដឹង

សិស្សចម្រាញ់យកវិជ្ជា បំណិន ចរិយា គុណតម្លៃមនុស្ស និងគុណតម្លៃសង្គមពីគ្រូបង្រៀន (គ្រូបង្រៀនជាគំរូ) ពីសៀវភៅ និងមិត្តរួមថ្នាក់។ ក្នុងថ្នាក់រៀន សិស្សមិនត្រឹមស្តាប់ការពន្យល់ រ៉ាយរ៉ាប់ បកស្រាយ និងរៀបរ៉ាប់របស់គ្រូបង្រៀន ការបង្ហាញរបស់សិស្សរួមថ្នាក់ ឬអានសៀវភៅតាមការណែនាំរបស់គ្រូបង្រៀនប៉ុណ្ណោះទេ។ ក្នុងដំណើរការរៀនពិតប្រាកដ សិស្សយកទម្លាប់របស់គ្រូបង្រៀនមកអនុវត្តតាម។ ទម្លាប់អានសៀវភៅ និងការចែករំលែកចំណេះដឹងវិជ្ជា ចរិយា និងគុណតម្លៃមនុស្ស ជាតម្រូវការចាំបាច់របស់គ្រូបង្រៀន។

ការស្រាវជ្រាវជាច្រើនរកឃើញថា គ្រូបង្រៀនមានទម្លាប់អានសៀវភៅច្រើន និងចែករំលែកចំណេះដឹងជាមួយសិស្ស ជួយបណ្តុះទម្លាប់សិស្សឱ្យអានសៀវភៅច្រើនដែរ (Roth & Lee, 2006)។

ការស្រាវជ្រាវរបស់ Carter, Ferzli, & Wiebe (2007) ពន្យល់ថា ការរៀនសរសេរ ដើម្បីចែករំលែក ជាដំណើរការនៃការអភិវឌ្ឍបំណិនពន្យល់ តាមការសរសេរ រកព័ត៌មានពីច្រើនប្រភព និងរៀបគំនិតក្នុងទម្រង់សរសេរ។

សិស្សអាចកសាងទម្លាប់សរសេរ ចេញពីថ្នាក់រៀនដែលមានគ្រូបង្រៀនជាអ្នកដឹកនាំការសរសេរញឹកញាប់ និងមានទម្លាប់សរសេរក្នុងមុខវិជ្ជាជំនាញ។

> ការសន្ទនាមួយរបស់គ្រូបង្រៀនពីរនាក់ ៖
>
> គ្រូបង្រៀនទី១ ៖
>
> តើឯងធ្វើដូចម្តេចដើម្បីបណ្តុះចិត្តសិស្សឱ្យមានទម្លាប់ចំណាយពេលអានសៀវភៅមួយថ្ងៃកន្លះម៉ោង?
>
> គ្រូបង្រៀនទី២៖
>
> តើក្នុងមួយថ្ងៃ ឯងមានទម្លាប់អានសៀវភៅប៉ុន្មាននាទី? តើឯងដែលប្រាប់ចំណងជើងសៀវភៅល្អៗដែលសិស្សគួរអានដែរឬទេ?
>
> គ្រូបង្រៀនទី១៖
>
> ខ្ញុំអត់ដែលអានសោះ ប៉ុន្តែខ្ញុំមើលតែទូរស័ព្ទសប្បាយជាមួយនឹង Facebook .......។

ការដាំបណ្ដុះទម្លាប់សរសេរ ត្រូវការការលើកទឹកចិត្តពីគ្រូបង្រៀន។ គ្រូបង្រៀនពុំគួរខ្វល់អំពីការសរសេរអត្ថបទវែងឬខ្លី ប៉ុន្តែបណ្ដុះទម្លាប់សរសេរប្រយោគ និងកថាខណ្ឌខ្លី។ សិស្សបណ្ដុះការគិតបានពីការអាន និងការសរសេរដោយរៀនពីទម្លាប់អាន និងសរសេរពីគ្រូបង្រៀន។ ការរៀនពិតប្រាកដនឹងកើតឡើងចំពោះសិស្សគ្រប់ប្រភេទ ដោយមិនបារម្ភ សិស្សមិនបានរៀន។

គ្រូបង្រៀនមានទម្លាប់ប្រតិបត្តិគោលការណ៍នេះ គឺគ្រូបង្រៀនជួយសិស្សឱ្យអភិវឌ្ឍបំណិន ទម្លាប់ និងការប្រព្រឹត្តិច្រើនបែបច្រើនយ៉ាង ដូចជា ៖

- បើកចិត្តទូលាយ
- ទទួលយកការផ្លាស់ប្ដូរ
- ហ៊ានប្រឈមនឹងហានិភ័យ
- ពន្យល់ហេតុផល ដោយនិយាយ និងសរសេរ
- ឆ្ងល់ និងចង់ចេះចង់ដឹង
- បង្កើតសំណួរ
- រកអង្គហេតុសម្បូរបែប

គោលការណ៍០៦ ៖ ផ្តល់ឱកាសឱ្យសិស្សឡើងបង្រៀន

សិស្សដែលបានឡើងបង្រៀន ពិតជាបានត្រៀមលក្ខណៈក្នុងការបង្រៀន និងបានអភិវឌ្ឍបទពិសោធមួយពីការបង្រៀននោះ។ សិស្សបានឡើងបង្រៀន គឺសិស្សបានបង្កើនវិជ្ជាថ្មីលើប្រធានបទដែលត្រូវបង្រៀន។ លើសពីនេះទៀត ការឡើងបង្រៀន គឺបណ្ដុះទំនុកចិត្តសម្រាប់ការប្រាស្រ័យមនុស្ស និយាយក្នុងចំណោមមនុស្សច្រើន និងអភិវឌ្ឍបំណិនទំនាក់ទំនងសង្គម។

គ្រូបង្រៀន ពុំមែនឱ្យសិស្សម្នាក់ឡើងបង្រៀនសិស្សមួយថ្នាក់ ជំនួសគ្រូបង្រៀនទេ។ គ្រូបង្រៀនគួរផ្តល់ឱកាសឱ្យសិស្សឡើងបង្រៀនដល់សិស្សក្នុងក្រុមតូច។ ឧទាហរណ៍ ក្នុងក្រុមតូចមួយ មានសិស្សម្នាក់មានព័ត៌មានច្រើនជាងគេ ឬបានអានសៀវភៅថ្មីអ្វីមួយ។ ដូច្នេះ គ្រូបង្រៀនគួរផ្តល់ឱកាសឱ្យសិស្សនោះឡើងបង្រៀនមិត្តភក្តិក្នុងក្រុម។

គ្រូបង្រៀនដែលប្រតិបត្តិគោលការណ៍នេះ ជួយអភិវឌ្ឍបំណិន វិជ្ជាទម្លាប់ និងការប្រតិបត្តិច្រើនបែបច្រើនយ៉ាងដល់សិស្ស ដូចជា ៖

- ចរចា
- ពន្យល់ហេតុផល ដោយនិយាយ និងសរសេរ
- ទទួលយកការផ្លាស់ប្តូរ
- ប្រតិបត្តិទម្លាប់ជាអ្នកដឹកនាំ
- ហ៊ានប្រឈមនឹងហានិភ័យ
- បើកចិត្តទូលាយ
- ប្រើឧបករណ៍បច្ចេកវិទ្យាបង្រៀន
- គូររូបភាព និងផែនទីគំនិត
- ឆ្ងល់ និងចង់ចេះចង់ដឹង
- បង្កើតសំណួរ
- រកអង្គហេតុសម្បូរបែប
- រក្សាចិត្តស្ងៀមស្ងាត់
- ទទួលស្គាល់កំហុស

គោលការណ៍០៧ ៖ ដាំបណ្តុះទម្លាប់អាន

អានច្រើនចម្រើនចាំ និងយល់ ព្រមទាំងបើកផ្លូវទៅកការបង្កើតបញ្ញា។ ការអានបានពង្រីកសាខានៃវិជ្ជា បំណិន និងចរិយាសម្រាប់ការងារ និងជីវិតល្អប្រសើរ។ គ្រូបង្រៀន ឬសិស្សដែលបានអានសៀវភៅថ្មីមួយ ឬមេរៀនមួយ ឬអត្ថបទស្រាវជ្រាវមួយ ត្រូវសរសេរចំណងជើងសៀវភៅ ឬចំណងជើងមេរៀន ឬឯកសារនោះ ចំណុចល្អ ឬចំណុចពិសេសមួយឬពីរ នៅលើក្រដាសតូចមួយទំហំប្រហែល១០សង់ទីម៉ែត្រគុណនឹង២០សង់ទីម៉ែត្រ។ បន្ទាប់មក គ្រូបង្រៀន និងសិស្សត្រូវបិទក្រដាសសំណេរនៅលើជញ្ជាំងថ្នាក់ (ក្នុងថ្នាក់រៀន គួរមានក្តារខៀនព័ត៌មានមួយភ្ជាប់នឹងជញ្ជាំងដើម្បីឱ្យសិស្សបិទចំណងជើងសៀវភៅល្អៗ ខ្លឹមសារល្អៗ។ល។)

ឧទាហរណ៍ សុធារី អានសៀវភៅមួយក្បាលដែលមានចំណងជើងថា "ស្គាល់ប្រវត្តិសាស្ត្រ ស្គាល់អនាគត"។ អត្ថបទនេះមានគំនិតធំគួរចងចាំ និងប្រតិបត្តិក្នុងជីវិត គឺការដឹកនាំប្រកបដោយក្តីស្រឡាញ់ និងមេត្រីភាពចំពោះពលរដ្ឋគ្រប់ៗគ្នាជាយានបង្កើតសុខជូនពលរដ្ឋ និងសន្តិភាពជូនជាតិ និងមនុស្សជាតិ។ គ្រូបង្រៀនសុំឱ្យសុធារី អានគំនិតធំមួយគួរចងចាំដែលបានដកស្រង់ចេញពីការអានរបស់គាត់ គឺ "ក្តីស្រឡាញ់ និងមេត្រីភាពជារឿងសំខាន់សម្រាប់ជីវិតមនុស្សគ្រប់ៗរូប។" គ្រូបង្រៀនឱ្យសុធារី បិទក្រដាសសរសេរខ្លឹមសារគោល លើក្តារខៀនព័ត៌មានប្រចាំថ្នាក់។

ប្រសិនបើមួយថ្ងៃ មានសិស្សពីរ ឬបីនាក់បានអានសៀវភៅ ឬអត្ថបទ និងស្រង់គោលគំនិតល្អៗ សរសេរបិទលើក្តារខៀន សិស្សមិនបានអាន អាចរៀនគំនិតល្អៗទាំងនោះបាន។ គ្រូបង្រៀនគួរដឹកនាំសិស្សឱ្យសរសេរជាប្រចាំ គ្រូបង្រៀនសរសេរ និងបិទលើក្តារខៀន។

គោលការណ៍០៨ ៖ ដាំបណ្តុះទម្លាប់សរសេរ (កាលិកបត្រថ្នាក់រៀន)

ការបង្កើតកាលិកបត្រ (អត្ថបទស្រាវជ្រាវមានចេញដោយទៀងទាត់) ជាប្រយោជន៍ដល់ការអភិវឌ្ឍបំណិនសរសេរ។ ការរៀនមុខវិជ្ជាសិក្សាសង្គម ជាពិសេសប្រវត្តិវិទ្យា ត្រូវការការអាន និងការសរសេរច្រើន។ ដូច្នេះ គ្រូបង្រៀនត្រូវបង្កើតឱកាសឱ្យសិស្សបានសរសេរអត្ថបទខ្លីៗ និងចងក្រងក្នុងកាលិកបត្រថ្នាក់រៀន។ អត្ថបទត្រូវសរសេរដោយសិស្សម្នាក់ៗ និងត្រូវកែសម្រួលឬកែលម្អដោយសិស្សគ្នាឯង និងចងក្រងជាប្រចាំឱ្យបានមួយលេខ ក្នុងមួយត្រីមាស។ ការសរសេរអត្ថបទបែបនេះ ត្រូវសរសេរដោយដៃផ្ទាល់។ លោកគ្រូ អ្នកគ្រូកុំខ្វល់ច្រើនរឿងគុណភាពនៃអត្ថបទ អក្ខរាវិរុទ្ធ ឬវេយ្យាករណ៍ពេក។ កាលិកបត្រថ្នាក់រៀន គឺសៀវភៅអត្ថបទស្នាដៃរបស់សិស្ស សរសេរដោយដៃ និងចេញផ្សព្វផ្សាយដោយទៀងទាត់កម្រិតថ្នាក់រៀន។

គ្រប់វិស័យការងារត្រូវការមនុស្សដែលមានបំណិន និងវិជ្ជាសរសេរ។ គ្រូបង្រៀនដែលប្រតិបត្តិគោលការណ៍នេះ ជួយអភិវឌ្ឍបំណិន វិជ្ជា និងទម្លាប់ច្រើនបែបច្រើនយ៉ាងដល់សិស្ស ដូចជា ៖ ពន្យល់ហេតុផលដោយសរសេរ

- វាយតម្លៃព័ត៌មានពីច្រើនប្រភព
- សរសេរគំនិតងាយយល់
- បង្កើតសំណួរ
- សួរសំណួរ និងស្វែងរកសេចក្តីពន្យល់
- រកអង្គហេតុសម្បូរបែប
- គិតបែបវិភាគ
- គិតបែបវែកញែក
- គិតលើការគិត
- វាយតម្លៃអង្គហេតុ
- ប្រតិបត្តិទម្លាប់ជាអ្នកដឹកនាំ
- ចេះចាត់ចែងការងារតាមអាទិភាព
- ចេះបង្កើតផែនការ

គោលការណ៍០៩ ៖ អន្តរទំនាក់ទំនងរវាងសិស្សនិងសិស្ស

ការបង្កើតទំនាក់ទំនងល្អក្នុងចំណោមសិស្ស ជាវិធានមួយ ជួយបង្កើតបរិយាកាសរៀនជាមួយគ្នាក្នុងចំណោមសិស្សនិងសិស្ស ដូចជាសិស្សរៀនយឺតសិស្សដែលមានតម្រូវការពិសេស និងសិស្សរៀនលឿន។

មានការសង្កេតមួយ អំពីសកម្មភាពសិស្សលេងល្បែងលោតអន្ទាក់ក្រៅថ្នាក់។ សិស្សសហការគ្នាយ៉ាងល្អ។ សមត្ថភាពលោតរបស់សិស្សម្នាក់ៗខុសៗគ្នា ប៉ុន្តែហេតុអ្វីបានជាសិស្សលេងជាមួយគ្នាកើត? ថ្នាក់រៀនមួយតែងមានសិស្សដែលមានកម្រិតសមត្ថភាពគិត ចរិយា ស្ថានភាពសង្គម សេដ្ឋកិច្ច ទម្លាប់រៀន និងវិធីរៀនខុសៗគ្នា។ទោះបីជាយ៉ាងណា សិស្សមករៀនក្នុងថ្នាក់ ឬក្នុងសាលា គឺមានចេតនាដូចគ្នា និងរួមគ្នាមួយ គឺ មកបណ្តុះវិជ្ជា បំណិន និងចរិយាសម្រាប់យកទៅប្រើការក្នុងជីវភាពប្រចាំថ្ងៃ ធ្វើការ និងរៀនបន្ត។

ដូច្នេះ គ្រូបង្រៀនគួរលើកទឹកចិត្ត ឬបង្កលក្ខណៈងាយស្រួលឱ្យសិស្សចូលរួមយ៉ាងសកម្ម ដូចជា រកព័ត៌មានរួមគ្នា ជជែកគ្នា សួរសំណួរគ្នា កែសំណួរគ្នា និងធ្វើផែនការរួមគ្នា ដើម្បីចែករំលែកការចងចាំផ្នែកចំណេះដឹង បទពិសោធ និង

បំណិនជាមួយគ្នា ក្នុងថ្នាក់រៀន និងក្រៅថ្នាក់។ ដូច្នេះ បរិយាកាសថ្នាក់រៀនដែលបង្កឱកាសឱ្យសិស្ស និងសិស្សមានអន្តរទំនាក់ទំនងរួមគ្នា ក្នុងដំណើរការរៀន គឺសិស្សគ្រប់ៗរូប ក្លាយជាម្ចាស់នៃសកម្មភាពរៀន និងមានឱកាសអភិវឌ្ឍបំណិនទំនាក់ទំនងមនុស្ស និងបំណិនច្រើនបែបច្រើនយ៉ាងទៀត។ សំខាន់ដូចគ្នាដែរ សិស្សបណ្ដុះចិត្ត និងបើកចិត្តឱ្យទូលាយ សម្រាប់ជាជំនួយដល់មនុស្សដទៃ។

គ្រូបង្រៀនដែលដឹកនាំថ្នាក់រៀនឱ្យសិស្សមានអន្តរទំនាក់ទំនង រវាងសិស្សនិងសិស្ស ជួយអភិវឌ្ឍបំណិន វិជ្ជា និងទម្លាប់ច្រើនបែបច្រើនយ៉ាង ៖

- សរសេរ និងនិយាយមានគោលគំនិត និងអង្គហេតុ
- ចរចា
- ពន្យល់ហេតុផល
- ទទួលយកការផ្លាស់ប្តូរ
- ប្រតិបត្តិទម្លាប់ជាអ្នកដឹកនាំ
- ស្ដាប់ដោយបេះដូង
- ទទួលស្គាល់តម្លៃនៃសេចក្ដីពិត
- ខ្វល់ជួយអ្នកដទៃ
- យល់គោលបំណងរួមរបស់ក្រុម
- ចូលរួមសកម្មក្នុងក្រុម
- បើកចិត្តឱ្យទូលាយ
- លើកទឹកចិត្តសមាជិកក្រុម
- ចុះសម្រុងនឹងអ្នកដទៃ
- ប្រតិបត្តិចិត្ត និងទម្លាប់ស្មោះត្រង់
- យល់អំពីតួនាទី និងភារកិច្ចក្នុងក្រុម

គោលការណ៍១០ ៖ ស្វ័យភាព និងឯករាជ្យក្នុងដំណើរការៀន

របកគំហើញនៃការស្រាវជ្រាវជាច្រើនពន្យល់ថា សិស្សមានស្វ័យភាព និងឯករាជ្យ ក្នុងដំណើរការរៀន គឺសិស្សអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង។ អ្នករៀនគ្រប់វ័យ មានចេតនាបង្កើតនូវភាពម្ចាស់ការលើដំណើរការរៀនរបស់

ខ្លួនឯង និងស្វែងលទ្ធផលតាមការព្យាយាម តាមថាមពលនៃចិត្ត។ សិស្សមានចេតនាចែករំលែកចំណេះដឹងជាមួយសិស្សរួមថ្នាក់ និងជាមួយអ្នកដទៃ។ គ្រូបង្រៀនគួរបង្កលក្ខណៈងាយស្រួលដល់សិស្សគ្រប់ៗរូប ឬគ្រប់ប្រភេទសិស្ស ឱ្យស្វែងព័ត៌មានថ្មីៗ ឬអង្គហេតុដោយខ្លួនឯង និងប្រកបដោយភាពឯករាជ្យ។ នៅពេលសិស្សពេញចិត្ត និងចូលរួមក្នុងដំណើរការរៀនយ៉ាងសកម្ម សិស្សនឹងអភិវឌ្ឍពុទ្ធិគ្រប់កម្រិត និងភ្ជាប់ជាមួយបទពិសោធក្នុងជីវិត ការងារ និងរៀន។

នៅពេលសិស្សទទួលបានស្វ័យភាព និងឯករាជ្យ ក្នុងដំណើរការរៀន សិស្សច្រើនកាត់បន្ថយការរំពឹងរង់ចាំទទួលព័ត៌មានពីគ្រូបង្រៀន និងពីសៀវភៅសិក្សាគោល (Westwood, 2008)។ ក្នុងចេតនានេះ សិស្សបង្កើតឱកាសដោយខ្លួនឯង ដើម្បីស្វែងរក និងអភិវឌ្ឍវិជ្ជា បំណិន និងចរិយា សម្រាប់រៀនបន្ត ជីវភាពប្រចាំថ្ងៃ និងការងារ។ គ្រូបង្រៀនដែលប្រតិបត្តិគោលការណ៍នេះ ជួយអភិវឌ្ឍបំណិន វិជ្ជា ទម្លាប់ និងការប្រតិបត្តិច្រើនបែបច្រើនយ៉ាងដល់សិស្ស ដូចជា៖

- រកព័ត៌មាន
- ញែកព័ត៌មានទៅតាមអាទិភាព
- វាយតម្លៃភាពពិត និងត្រឹមត្រូវនៃព័ត៌មាន
- ប្រើព័ត៌មានប្រកបដោយការទទួលខុសត្រូវ
- គ្រប់គ្រងអារម្មណ៍
- គោរពវិន័យ
- ឱ្យតម្លៃគំនិតដើម
- រក្សាភាពស្ងៀមស្ងាត់
- ឱ្យតម្លៃនានាភាព និងពហុភាព
- លើកទឹកចិត្តសមាជិកក្រុម
- បើកចិត្តឱ្យទូលាយ
- ស្វ័យម្ចាស់ការ

គោលការណ៍១១៖ ភ្ជាប់វិជ្ជារៀនពីសាលាជាមួយជីវភាពប្រចាំថ្ងៃ

ផលបានពីការរៀន ត្រូវយកទៅប្រើ ក្នុងការរស់នៅប្រចាំថ្ងៃ រៀនបន្ត និងធ្វើការ។ អ្នកគ្រូ លោកគ្រូ គួរចំណាយពេល៥៩វិនាទី គិត និងឆ្លើយសំណួរសាមញ្ញមួយ។ ក្នុងម៉ោងមេរៀនអំពីសម័យចតុមុខ តើសិស្សទទួលបានចំណេះដឹងអ្វី បំណិនប្រភេទណា គុណតម្លៃបែបណា និងចរណៈអ្វីខ្លះ សម្រាប់យកទៅប្រើការ ក្នុងការរៀន រស់ក្នុងជីវភាពប្រចាំថ្ងៃ និងធ្វើការ?

ក្នុងដំណើរគិតមួយដង្ហើមដំបូង អ្នកគ្រូ លោកគ្រូ អាចសន្មតថា អ្វីដែលសិស្សបានរៀន ពីមេរៀនសុទ្ធតែយកទៅប្រើការកើត។ ចូរលោកគ្រូ អ្នកគ្រូ សួរសំណួរដេញបន្តទៀត។ ក្នុងសៀវភៅសិក្សាគោល តើមេរៀនសម័យចតុមុខផ្តល់វិជ្ជាអ្វីខ្លះ បំណិនអ្វីខ្លះ និងចរិយាប្រភេទណាខ្លះដែលត្រូវយកទៅប្រើការកើតក្នុងជីវភាពប្រចាំថ្ងៃ ការងារ និងរៀនបន្ត?

អ្នកគ្រូ លោកគ្រូ គួររំឭកឡើងវិញអំពីនិយមន័យ និងសេចក្តីពន្យល់ អំពីចំណេះដឹង វិជ្ជា និងចរិយាតាមការចេះចាំ ដូចរៀបរាប់ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាអនុម័តដោយរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៦។ ដើម្បីភ្ជាប់ចំណេះដឹង និងវិជ្ជា រៀនពីសាលាជាមួយជីវភាពប្រចាំថ្ងៃ ការរៀនបន្ត និងធ្វើការសិស្សត្រូវ ៖ ១. ស្គាល់បញ្ញត្តិ ២. យល់បញ្ញត្តិ និងឱ្យតម្លៃចំពោះបញ្ញត្តិ ៣. ភ្ជាប់បញ្ញត្តិទៅនឹងតម្រូវការ ក្នុងគ្រប់បរិបទ កាល និងលក្ខខណ្ឌ។ តើបញ្ញត្តិជាអ្វី?

ឧទាហរណ៍ ចូរលោកគ្រូ អ្នកគ្រូអានប្រយោគមួយក្នុងមេរៀនអំពីសម័យចតុមុខ នៃសៀវភៅមេរៀនថ្នាក់ទី៨របស់ក្រសួងអប់រំ យុវជន និងកីឡា។ ប្រយោគនេះសរសេរថា “ព្រះបាទចន្ទរាជា និងព្រះបាទបរមេន្ទរាជារួមគ្នាស្តារប្រទេស។” តើអ្វីជាបញ្ញត្តិ ក្នុងប្រយោគនេះ? សាមគ្គីភាពជាបញ្ញត្តិមួយដែលត្រូវរៀន ក្នុងមេរៀនសម័យចតុមមុខ។

អ្នកគ្រូ លោកគ្រូចំណាយពេល៥៩វិនាទីទៀត។ ចូរលោកគ្រូ អ្នកគ្រូ សួរខ្លួនឯង និងឆ្លើយសំណួរមួយចំនួន ដោយខ្លួនឯង។ តើសិស្សស្គាល់ពាក្យសាមគ្គីភាពដែរឬទេ? តើសិស្សធ្លាប់ឆ្លងកាត់បទពិសោធអំពីសាមគ្គីភាពឬទេ? តើសិស្សឱ្យតម្លៃចំពោះសាមគ្គីភាពឬទេ? តើសិស្សអាចយល់អំពីសាមគ្គីភាពឬទេ? តើសាមគ្គីភាព

អាចប្រើបានក្នុងបរិបទ កាល និងស្ថានភាពបែបណាខ្លះ? តើសាមគ្គីភាពក្នុងសម័យចតុមុខ អាចប្រើបានក្នុងបច្ចុប្បន្ន និងអនាគតដែរឬទេ?

គ្រូបង្រៀនដែលបានប្រតិបត្តិគោលការណ៍នេះ គឺបានជួយអភិវឌ្ឍបំណិនទម្លាប់ និងការប្រព្រឹត្តិរបស់សិស្សដូចជា ៖

- គិតបែបវិភាគ
- គិតបែបច្នៃប្រឌិត
- គិតបែបរិះគន់
- គិតតាមប្រព័ន្ធ
- គិតលើការគិត
- ពន្យល់ហេតុផល
- វាយតម្លៃអង្គហេតុ
- ទទួលយកការផ្លាស់ប្តូរ
- ឱ្យតម្លៃគំនិតដើម
- វាយតម្លៃភាពពិត និងត្រឹមត្រូវនៃព័ត៌មាន
- ប្រតិបត្តិចិត្ត និងទម្លាប់ស្មោះត្រង់

គោលការណ៍១៣ ៖ នានាភាព ពហុភាព និងបម្រែបម្រួលនៃតម្រូវការ

រាល់សកម្មភាពរៀន ដឹកនាំការរៀន និងបង្រៀនក្នុងថ្នាក់ ការរៀនជាមួយគ្រូ និងសិស្សរួមថ្នាក់ គឺត្រូវការសិស្សបើកចិត្តមើល យល់ត្រូវ និងឱ្យតម្លៃនៃភាពផ្សេងៗគ្នា និងតម្រូវការផ្សេងៗគ្នា ពហុភាព និងនានាភាពនៃគំនិតរបស់សិស្ស។

តម្រូវការ ស្ថានភាព និងទម្លាប់របស់សិស្ស គឺសម្បូរបែបណាស់។ ដូច្នេះបរិយាកាសថ្នាក់រៀនដែលមានគ្រូបង្រៀនផ្តល់តម្លៃចំពោះនានាភាព ពហុភាព ភាពផ្សេងគ្នា ភាពខុសគ្នា ភាពផ្ទុយគ្នា បម្រែបម្រួលនៃតម្រូវការ ការគិត ស្ថានភាព និងទម្លាប់របស់សិស្ស គឺគ្រូបង្រៀនផ្តល់ឱកាសឱ្យសិស្សអភិវឌ្ឍបំណិនគិត។

គ្រូបង្រៀនដែលបានប្រតិបត្តិគោលការណ៍នេះ គឺបានជួយអភិវឌ្ឍបំណិនទម្លាប់ និងការប្រព្រឹត្តិរបស់សិស្សដូចជា ៖

- រកអង្គហេតុសម្បូរបែប

- វាយតម្លៃអង្គហេតុ
- ពន្យល់ហេតុផល
- ទទួលយកការផ្លាស់ប្តូរ
- ស្តាប់ដោយយកចិត្តទុកដាក់បំផុត
- ប្រតិបត្តិទម្លាប់ជាអ្នកដឹកនាំ
- ខ្វល់អំពីអ្នកដទៃ
- ប្រតិបត្តិគោលការណ៍គុណធម៌
- ញែកព័ត៌មានទៅតាមអាទិភាព
- វាយតម្លៃភាពពិត និងត្រឹមត្រូវនៃព័ត៌មាន

គោលការណ៍១៣៖ ចំណាត់ការបន្ទប់រៀន និងបរិក្ខារក្នុងបន្ទប់រៀន

ទំហំបន្ទប់រៀន និងចំណាត់ការបរិក្ខារក្នុងបន្ទប់រៀន អាចបង្កបរិយាកាសងាយស្រួល និងលំបាក់សម្រាប់ដំណើរការរៀន ដឹកនាំការរៀន និងបង្រៀន។ ការអនុវត្តវិធីសាស្ត្រដឹកនាំការរៀន និងបង្រៀននានាក្នុងគោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល រៀបរាប់ខាងលើ គឺត្រូវការចំណាត់ការបន្ទប់រៀន និងបរិក្ខារក្នុងបន្ទប់រៀនឱ្យត្រូវតាមបរិបទ។ គ្រូបង្រៀន និងថ្នាក់ដឹកនាំសាលារៀន គួរមានគំនិតច្នៃប្រឌិត ចាត់ចែងចំណាត់ការបន្ទប់រៀន និងបរិក្ខារក្នុងបន្ទប់រៀន សម្រាប់មុខវិជ្ជាប្រវត្តិវិទ្យា។ ភាសាអប់រំ គឺបន្ទប់ប្រវត្តិវិទ្យា។

ចំណាត់ការបន្ទប់រៀន និងបរិក្ខារក្នុងបន្ទប់រៀន គួរប្រតិបត្តិតាមគោលការណ៍មួយក្នុងចំណោមគោលការណ៍ នៃការបង្កើតបរិយាកាសរៀនប្រកបដោយគុណភាព (Organisation for Economic Co-operation and Development, OECD) (2006)។

អ្នកអប់រំ គ្រូបង្រៀន មាតាបិតា និយោជក អ្នកនយោបាយ សុទ្ធតែទទួលស្គាល់ថា បរិយាកាសសហការ ច្នៃប្រឌិត និងប្រឡងប្រណាំង ក្នុងដំណើរការរៀន ដើម្បីលើកកម្ពស់គុណផលរៀន។ ដោយសារហេតុផលនេះ អង្គការដើម្បីសហប្រតិបត្តិការសេដ្ឋកិច្ច និងអភិវឌ្ឍន៍ OECD (2006) បង្កើតសេចក្តីណែនាំមួយអំពីបរិយាកាសរៀនក្នុងសតវត្សរ៍ទី២១។ សេចក្តីណែនាំនេះត្រូវបាន

សម្រាយឱ្យមានសាមញ្ញភាព ជាភាសាអនុវត្ត កម្រិតប្រទេស តំបន់ និងសាលារៀននៅ ។

សេចក្តីណែនាំមួយក្នុងចំណោមសេចក្តីណែនាំនានា គឺបង្កើតកន្លែងរៀនតាមបរិបទ នៃតម្រូវការរៀន និងធនធានសាលារៀន OECD (2006) ៖

- កន្លែងរៀនជាក្រុម ៖ ទីធ្លាទូលាយចែកជាចំណែកតូចៗ ដើម្បីងាយស្រួលឱ្យសិស្សធ្វើការជាក្រុម សិក្សារួមមុខវិជ្ជា និងខុសមុខវិជ្ជា សម្រាប់បំពេញតម្រូវការរបស់សិស្សតាមប្រភេទ ដូចជាសិស្សរៀនយឺត រៀនខ្សោយ និងសិស្សមានតម្រូវការពិសេស។
- កន្លែងរៀនម្នាក់ៗ ៖ សាលារៀនពិតជាមានទីធ្លា ឬកន្លែងទំនេរ។ ដូច្នេះការចាត់ចែងឱ្យមានកន្លែងសម្រាប់សិស្សអង្គុយម្នាក់ឯង ដើម្បីរៀនដោយឯករាជ្យជាការប្រសើរ។
- កន្លែងរៀនពហុបំណង និងបើកសេរី ៖ ត្រូវបង្កើតឡើងសម្រាប់អន្តរទំនាក់ទំនងមនុស្ស ក្នុងសាលារៀន និងសម្រាប់សិស្ស និងសិស្ស ឬអ្នកឯកទេសមកចែករំលែកចំណេះដឹងជាសាធារណៈ។
- បន្ទប់រៀន ឬកន្លែងរៀនតាមមុខវិជ្ជាឯកទេស ៖ ការស្រាវជ្រាវជាច្រើនបញ្ជាក់ថា ការចាត់ចែងឱ្យមានបន្ទប់រៀនតាមមុខវិជ្ជាឯកទេស ឬតាមជំនាញ ដូចជា បន្ទប់ប្រវត្តិវិទ្យា វិទ្យាសាស្ត្រ គណិតវិទ្យា កីឡា វិជ្ជាជីវៈ សិល្បៈ ឬបំណិនច្រើនបែបច្រើនយ៉ាងទៀត បង្កបរិយាកាសរៀន ឱ្យសិស្សចូលចិត្ត។ ការបែងចែកបន្ទប់រៀនតាមមុខវិជ្ជាឯកទេស បង្កបរិយាកាសឱ្យគ្រូឯកទេសមុខវិជ្ជាតុបតែបន្ទប់រៀនតាមសិល្បៈ និងតម្រូវការនៃមុខវិជ្ជា។ អ្នកគ្រូ លោកគ្រូ អាចចាត់ចែងបន្ទប់មុខវិជ្ជាប្រវត្តិវិទ្យាតាមបរិបទ កាល និងលក្ខខណ្ឌនៃការរៀន និងបង្រៀនប្រវត្តិវិទ្យា។

សរុបសេចក្តីជារួម តើអ្នកគ្រូ លោកគ្រូ គោរពគោលការណ៍នីមួយៗ ក្នុងដំណើរការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលកម្រិតណា?

១៤.១.៤ គុណប្រយោជន៍

របកគំហើញនៃការស្រាវជ្រាវជាច្រើនពន្យល់ពីប្រយោជន៍ នៃការអនុវត្តគោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌលក្នុងការបង្រៀន ក្នុងគ្រប់កម្រិត និងគ្រប់មុខវិជ្ជា។ គោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល គឺផ្តល់ឱកាសឱ្យសិស្សធ្វើសកម្មភាពដោយខ្លួនឯងច្រើន តាមលទ្ធភាពដែលគ្រូបង្រៀនអាចជួយណែនាំសម្របសម្រួល និងដឹកនាំ (Simsek & Kabapinar, 2010; Jacobs, Renandya, & Power, 2016; Stern, Lauriault, & Ferraro, 2018)។

គោលវិធីគរុកោសល្យសិស្សមជ្ឈមណ្ឌល ពេញនិយមជាសកល ឬ ហៅគោលវិធីសិស្សមជ្ឈមណ្ឌល ពេញនិយមនៅកម្ពុជា តាំងពីទសវត្សរ៍ឆ្នាំ១៩៩០។ កម្ពុជា បានផ្លាស់ប្តូរកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលថ្មី ក្នុងឆ្នាំ១៩៩៥និងឆ្នាំបន្តបន្ទាប់ ដើម្បីឆ្លើយតបនឹងរបត់នយោបាយ និងបម្រែបម្រួលប្រជាសាស្ត្រ។ ការផ្លាស់ប្តូរកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលក៏ផ្លាស់ប្តូរវិធីសាស្ត្រ និងទម្លាប់បង្រៀនរបស់គ្រូបង្រៀនដែរ។ ក្នុងដំណើរការផ្លាស់ប្តូរនេះ ការសរសេរកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ផ្តោតការយកចិត្តទុកដាក់លើការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល។

គោលវិធីសិស្សមជ្ឈមណ្ឌល មានសរសេរក្នុងសៀវភៅសិក្សាសង្គម ភាសាខ្មែរ វិទ្យាសាស្ត្រ គណិតវិទ្យា និងមុខវិជ្ជាផ្សេងៗទៀត ពីកម្រិតបឋមសិក្សាដល់មធ្យមសិក្សាទុតិយភូមិ របស់ក្រសួងអប់រំ យុវជន និងកីឡា ចាប់ពីទសវត្សរ៍ឆ្នាំ១៩៩០ និងសៀវភៅណែនាំអំពីវិធីសាស្ត្របង្រៀនតាមភូមិសិក្សា និងតាមមុខវិជ្ជា ក្នុងប៉ុន្មានទសវត្សរ៍ចុងក្រោយ។

របកគំហើញនៃការស្រាវជ្រាវនៅបរទេសជាច្រើន ពន្យល់ពីប្រយោជន៍នៃការអនុវត្តគោលវិធីគុរកោសល្យសិស្សមជ្ឈមណ្ឌល។ សិស្សមានឱកាសអភិវឌ្ឍបំណិន និងវិជ្ជាច្រើនបែបច្រើនយ៉ាង។ ចំណែកនៅកម្ពុជា សិស្សភាគច្រើនពុំបានអភិវឌ្ឍបំណិន និងវិជ្ជាច្រើនបែបច្រើនយ៉ាងទេ។ លទ្ធផលនៃការប្រឡងមធ្យមសិក្សាទុតិយភូមិថ្នាក់ជាតិ និងការធ្វើតេស្តថ្នាក់ជាតិ និងកម្រិតអន្តរជាតិ បង្ហាញលទ្ធផលស្រដៀងៗគ្នា។ ការប្រឡងមធ្យមសិក្សាទុតិយភូមិឆ្នាំ

២០១៤ដល់២០១៩ សិស្សប្រហែល៥០%ប្រឡងមិនជាប់។ ពីឆ្នាំ២០១៥ដល់ ២០១៨ សិស្សក្រោម៥០%ប្រឡងមិនជាប់តេស្តថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ និងទី៨ លើមុខវិជ្ជាភាសាខ្មែរ វិទ្យាសាស្ត្រ និងគណិតវិទ្យា។ ការវាយតម្លៃការសិក្សារបស់សិស្សកម្ពុជាកម្រិតអន្តរជាតិ អាយុ១៥ឆ្នាំ (PISA-D ២០១៨) បានបញ្ជាក់ថា សិស្សកម្ពុជាពុំទាន់អភិវឌ្ឍបំណិន និងវិជ្ជាច្រើនបែបច្រើនយ៉ាង គ្រប់គ្រាន់បំពេញតម្រូវការការងារក្នុងឧស្សាហកម្មគ្រប់ប្រភេទបានទេ។

លទ្ធផលទាំងនេះពន្យល់ថា ដំណើរការរៀន និងដឹកនាំការរៀនអាចមានជំងឺ ឬកើតរោគក្នុងដំណាក់កាលណាមួយ។ លទ្ធផលរៀនរបស់សិស្សបែបនេះជាលេសរបស់គ្រូបង្រៀនមួយចំនួនពន្យល់ថា ការបង្រៀនតាមគោលវិធីសិស្សមជ្ឈមណ្ឌល បង្រៀនមិនចប់មេរៀន និងសិស្សរៀនមិនចេះ ប្រឡងមិនជាប់។

ការសម្ភាសគ្រូបង្រៀន អំពីការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល គ្រូបង្រៀនឆ្លើយថាបានអនុវត្ត។ ប្រសិនបើសួរលម្អិតបន្តិចទៀតប្រហែលជាពិបាករកចម្លើយ។ ឧទាហរណ៍ តើអ្នកគ្រូ លោកគ្រូធ្លាប់ប្រើវិធីសាស្ត្រមួយណា ក្នុងចំណោមវិធីសាស្ត្រមួយចំនួនខាងក្រោម? ចម្លើយប្រហែលជាពិបាករកណាស់ថា គ្រូបង្រៀនបានអនុវត្ត។

- វិធីសាស្ត្របុច្ឆនសិក្សា (Inquiry-based Learning)
- វិធីសាស្ត្ររៀនសហការ (Collaborative Learning)
- វិធីសាស្ត្ររៀនសហប្រតិបត្តិការ (Cooperative learning)
- វិធីសាស្ត្ររៀនតាមគម្រោង (project-based learning)
- វិធីសាស្ត្ររៀនតាមបញ្ហា (problem-based learning)
- វិធីសាស្ត្ររៀនជាក្រុម (Team-based learning)
- វិធីសាស្ត្ររៀនដៃគូជាក្រុម (Peer-led team learning)
- វិធីសាស្ត្ររៀនតាមការណែនាំជាដៃគូ (Peer Instruction)។ល។

ដូច្នេះ សៀវភៅនេះបើកផ្លូវគិត និងពង្រីកវិសាលភាពនៃគំនិត របស់អ្នកគ្រូ លោកគ្រូអំពីវិធីសាស្ត្រមួយ ក្នុងចំណោមនេះ គឺវិធីសាស្ត្របុច្ឆនសិក្សា។

១៤.២ បុច្ឆនសិក្សា

ទស្សនវិទូ និងអ្នកវិទ្យាសាស្ត្រ ចាត់ទុកការឆ្លល់ និងចោទសួរជាបេះដូង នៃដំណើរការរៀនពិតប្រាកដ និងបង្កើតពុទ្ធិថ្មី។ សូក្រាត (Socrates, ឆ្នាំ៤៧០ - ឆ្នាំ ៣៩៩ មុន គ.ស) និយាយថា សំណួរនាំផ្លូវគិតទៅរកច្រើនទិសសម្រាប់អ្នករៀន។ ទិសនៃការគិតរបស់សូក្រាត គឺ ពន្យល់គំនិតស្មុគស្មាញ លាតត្រដាងសេចក្តីពិត ដែលកប់ជ្រៅក្នុងចិត្ត បើកគម្រូបនៃបញ្ហា និងញែកឱ្យដាច់រវាងការដឹង និងការ មិនទាន់ដឹង។

បុច្ឆនសិក្សា ជាដំណើរការរៀនពិតប្រាកដ ផ្តើមចេញពីការឆ្ងល់ សង្កេត គិត បង្កើតសំណួរ និងសួរសំណួរ។ វិធីសាស្ត្របុច្ឆនសិក្សា ត្រូវបានអនុវត្តជាច្រើន សតវត្សរ៍មកហើយ។ Gautama Buddha ឬ ព្រះពុទ្ធ (ឆ្នាំ៥៦៣ or ៤៨០មុន គ.ស- ឆ្នាំ៤៨៣ or ៤០០ មុន គ.ស) បានបង្រៀនមនុស្ស ដោយប្រើបុច្ឆនវិធី មានចម្ងល់ ចោទសួរ និងស្វែងការពន្យល់។

តាមគម្ពីរព្រះត្រៃបិដកភាសាខ្មែរ និងDhammapada ភាសាអង់គ្លេស ព្រះ ពុទ្ធបានបង្រៀនមនុស្សឱ្យយល់ និងប្រតិបត្តិសេចក្តីពិត អំពីជីវិត ទុក្ខ ស្លាប់ និង សុខដោយប្រើបុច្ឆនវិធី។

ឧទាហរណ៍ រឿងនាងកេសា គោតមី និងគ្រាប់ស្ពៃខ្មៅ រឿងអង្គុលីមារ អ្នកប្រម៉ាញ់ រឿងបុរសប្រចណ្ឌប្រពន្ធ និងរឿងនិទានជាច្រើនទៀត ជាគំរូបញ្ជាក់ អំពីដំណើរការរៀនតាមវិធីសាស្ត្របុច្ឆនសិក្សា។

សូក្រាត (Socrates, ឆ្នាំ៤៧០-ឆ្នាំ៣៩៩ មុនគ.ស) ប្រើវិធីសង្កេត គិត ឆ្ងល់ បង្កើតសំណួរ និងសួរសំណួរជាច្រើនទសវត្សរ៍ ដើម្បីដឹកនាំសិស្សឱ្យរៀន។ អ្នក វិទ្យាសាស្ត្រ អ្នកអប់រំ និងទស្សនវិទូជាច្រើននាក់ទៀតក៏បានប្រើវិធីឆ្ងល់ និងចោទ សួរ ដើម្បីពង្រីកពុទ្ធិ និងបង្កើតពុទ្ធិថ្មី ដូចជា ខុងជឺ (Confucius, ឆ្នាំ៥៥១-៤៧៩ មុន គ.ស) ផ្លាតូ (Plato, ៤២៤/៤២៣ -៣៤៨/៣៤៧ មុន គ.ស) អ៊ីសាក់ ញូតុន (Isaac Newton, ឆ្នាំ១៦៤៣–១៧២៧) ចន ឌូវី (John Dewey, ឆ្នាំ១៨៥៩-១៩៥២), បិនចាមីន ប្លូម (Benjamin BLOOM, ឆ្នាំ១៩១៣-១៩៩៩) និង ជេរ៉ូម ប្រុណឺ (Jerome

Bruner, ឆ្នាំ១៩១៥-២០១៦) ឡេវ វៃហ្កុតស្គី (Lev Vygotsky, ឆ្នាំ១៨៩៦-១៩៣៤) និង ព្យាហ្សេ ហ្សង់ (Piaget Jean, ឆ្នាំ១៨៩៦-១៩៨០)។

ព្រះពុទ្ធប្រើបុច្ឆនវិធីដើម្បីដឹកនាំ នាង កេសា គោតមី ឱ្យរៀនអំពីជីវិត ស្លាប់ និងទុក្ខ។ រឿងនាង កេសា គោតមី និងគ្រាប់ស្ពៃខ្មៅ តំណាលថា៖ *“ទារក របស់នាង កេសា គោតមី បានស្លាប់។ នាងបានយំឱបសពកូន មិនដាក់ចុះ សោះ។ នាងមិនហូបបាយនិងមិនផឹកទឹក។ មានបុរសចំណាស់មួយនាក់បាន ប្រាប់នាងឱ្យទៅរកព្រះពុទ្ធ ដើម្បីជួយជីវិតកូនរបស់នាងឱ្យរស់ឡើងវិញ។ នាង កេសា គោតមី ម្នីម្នាទៅជួបព្រះពុទ្ធ។ ព្រះពុទ្ធបានផ្តល់ចំណោទមួយឱ្យនាង ដើម្បីស្វែងការពន្យល់ អំពីភាពពិត ច្បាស់លាស់ និងត្រឹមត្រូវនៃសេចក្តីស្លាប់ ដោយខ្លួនឯង។*

*ព្រះអង្គបានឱ្យនាង គោតមី ទៅរកសុំគ្រាប់ពូជស្ពៃខ្មៅ នៅតាមគ្រួសារ នានាក្នុងភូមិ។ ព្រះអង្គបានដាក់លក្ខខណ្ឌមួយ។ “ចូរនាងទៅរកគ្រាប់ពូជស្ពៃ ខ្មៅពីគ្រួសារនានាក្នុងភូមិឱ្យបានមួយកញ្ចប់តូច ប៉ុន្តែយកពីគ្រួសារដែលពុំធ្លាប់ មានសាច់ញាតិស្លាប់។ ពេលបានគ្រាប់ពូជស្ពៃខ្មៅ ព្រះអង្គនឹងជួយជីវិតកូនប្រុស របស់នាងរស់ឡើងវិញ។”*

*នាងកេសា គោតមី បានដើរកាត់ផ្ទះមួយទៅផ្ទះមួយ និងពីភូមិមួយទៅ ភូមិមួយ ដោយមិនគិតអំពីការថមថយកម្លាំងដើម្បីសុំគ្រាប់ស្ពៃខ្មៅឱ្យបាន។ នាង អាចរកគ្រាប់ស្ពៃខ្មៅបានពីស្ទើរគ្រប់គ្រួសារ ប៉ុន្តែគ្រួសារណាក៏មានសាច់ញាតិ ស្លាប់ដែរ។ នាងបានវិលត្រឡប់មកជួបព្រះពុទ្ធវិញ។ នាងពុំអាចរកគ្រាប់ស្ពៃខ្មៅ ពីគ្រួសារណាបានទេ។ គ្រួសារណាក៏មានសាច់ញាតិស្លាប់ដែរ។ គ្រួសារខ្លះ មិន ទាន់ដោះសម្លៀកបំពាក់កាន់ទុក្ខផង។ មានសមាជិកគ្រួសារខ្លះយំស្រែកយ៉ាង ខ្លាំង គ្រាន់តែឮសំណួរនាងសួរ។ តើក្នុងគ្រួសារអ្នកមានមនុស្សស្លាប់ដែរឬទេ?*

*ទទួលបានការបំពេញបន្ថែមលើការស្វែងយល់អំពីសេចក្តីស្លាប់ពីព្រះពុទ្ធ នាងបានស្រាយចម្ងល់ និងយល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃសេចក្តី ស្លាប់។ នាងបានផ្លាស់ប្តូរការគិត និងការប្រព្រឹត្តិ អំពីការទាមទារឱ្យកូនរស់ឡើង*

*វិញ។ នាងក៏បញ្ឈប់ទុក្ខទួញសោកអំពីការស្លាប់នៃកូនប្រុសជាទីស្រឡាញ់ដែរ។ នាងបានយកសពកូនប្រុសរបស់នាងទៅបូជា តាមពិធីសាសនាជាធម្មតា។"*

១៤.២.១ សិក្សាទ្រឹស្តី

ការស្រាវជ្រាវជាច្រើនអំពីបុច្ឆនសិក្សា បានពន្យល់អំពីវាក្យសព្ទ ទ្រឹស្តី និយមន័យ បញ្ញត្តិ គោលការណ៍ និងលំនាំនៃការអនុវត្ត។ គោលបំណងនៃការស្រាវជ្រាវទាំងអស់ សំដៅផ្តល់ការពន្យល់ និងអនុសាសន៍ឱ្យគ្រូបង្រៀន និងអ្នកអប់រំ យកទៅអនុវត្ត ដើម្បីលើកកម្ពស់គុណផលសិក្សារបស់សិស្ស (Pedaste, Maeots, Siiman, & Jong, 2015; Kidman & Casinader, 2017; Kuhlthau, Leslie, & Caspari, 2007; Chu, Reynolds, Tavares, Notari, & Wing Yi Lee, 2017; Blessinger & Cafora, 2014; King, Erickson, & Sebranek, 2012; Alfrieri, Brooks, Aldrich, & Harriet , 2011; Biggs & Tang, 2011; Weinbaum, និងផ្សេងៗទៀត, 2004)។

### ក. ការស្រាវជ្រាវ០១ ៖

Pedaste, Maeots, Siiman, & Jong (2015) វិភាគឯកសារស្រាវជ្រាវ៣២អត្ថបទ អំពីលំនាំអនុវត្តវិធីសាស្ត្របុច្ឆនសិក្សា។ ការស្រាវជ្រាវនេះ រកឃើញថា ដំណើរការរៀនតាមបុច្ឆនសិក្សា ប្រើវាក្យសព្ទបច្ចេកទេសចំនួន១០៩ពាក្យ ដើម្បីបញ្ជាក់សកម្មភាពដែលត្រូវអនុវត្តក្នុងគ្រប់ដំណាក់កាល នៃការអនុវត្តវិធីសាស្ត្របុច្ឆនសិក្សា។ Pedaste, Maeots, Siiman, & Jong (2015) បានសំយោគការរកឃើញលើវាក្យសព្ទដែលមានបញ្ញត្តិជាន់គ្នា និងសង្ខិត្តន័យនៃការរកឃើញពី១២ជំហាន មកនៅត្រឹម៤ជំហាន (រូបភាព១០) និងជ្រើសរើសយកវាក្យសព្ទអំពីសកម្មភាពបន្ថែម ដើម្បីអនុវត្តជំហាននីមួយៗ ឱ្យមានប្រសិទ្ធភាពក្នុងថ្នាក់រៀនជាមួយសិស្សក្នុងបរិបទច្រើនប្រភេទ សម្រាប់មុខវិជ្ជាផ្សេងៗគ្នា។

លទ្ធផលនៃសំយោគរបស់ Pedaste, Maeots, Siiman, & Jong (2015) គឺឆ្លើយតបនឹងតម្រូវការរៀន និងទម្លាប់រៀនរបស់សិស្សក្នុងបរិបទផ្សេងៗគ្នា។ Watkins, Carnell, & Lodge (2007) សំយោគរបកគំហើញអំពីតម្រូវការរៀន និងទម្លាប់រៀនរបស់សិស្សដែលបង្កបរិយាកាសឱ្យសិស្សរៀនបានច្រើនបំផុតពេល ៖

- សិស្សមានការទទួលខុសត្រូវចេញពីបេះដូង ចំពោះការរៀន
- សិស្សចូលរួមយ៉ាងសកម្ម ក្នុងដំណើរការរៀនចេញពីបេះដូង
- ដំណើរការរៀនសកម្ម និងមានអន្តរទំនាក់ទំនងរវាងសិស្ស និងគ្រូ
- សិស្សឱ្យតម្លៃចំពោះខ្លួនឯងពេលចូលរួមក្នុងដំណើរការរៀន
- សិស្សសម្លឹងភាពជោគជ័យរបស់ខ្លួនក្នុងថ្ងៃខាងមុខ ដោយការរៀនពិតៗ

ទ្រឹស្តីនៃការរៀនរបស់ ចន ឌូវី (John Dewey, ឆ្នាំ១៨៥៩-១៩៥២), បិនចាមីន ប្លូម (Benjamin BLOOM, ឆ្នាំ១៩១៣-១៩៩៩) និង ជេរ៉ូម ប្រុណឺ (Jerome Bruner, ឆ្នាំ១៩១៥-២០១៦) ឡេវ វៃហ្កុតស្គី (Lev Vygotsky, ឆ្នាំ១៨៩៦-១៩៣៤) និង ព្យាហ្សេ ហ្សង់ (Piaget Jean, ឆ្នាំ១៨៩៦-១៩៨០) ពន្យល់ថា ការរៀនពិតប្រាកដកើតឡើងដោយការបើកចិត្តទូលាយ សហការ និងប្រាស្រ័យមនុស្ស។ ដំណើរការរៀនពិតប្រាកដ គឺ ផ្តើមចេញពីឆ្ងល់និងគិត ឬគិតនិងឆ្ងល់ និងសួរសំណួរដោយចិត្តស្មោះត្រង់ និងពោរពេញដោយសេចក្តីពិត។ ដូច្នេះ គ្រូបង្រៀនត្រូវផ្តល់ឱកាសឱ្យសិស្សសហការជាមួយសិស្ស មនុស្សក្នុងសហគមន៍ និងមនុស្សក្នុងជំនាញឯកទេស ដើម្បីពង្រីកការរៀនពិតប្រាកដ និងប្រកបដោយគុណភាព។ គ្រូបង្រៀនត្រូវដឹកនាំសិស្សឱ្យបើកចិត្តទូលាយទទួលយកគំនិតថ្មី និងគំនិតប្លែក។

Pedaste, Maeots, Siiman, & Jong (2015) សំយោគរបកគំហើញជារូបបំព្រួញ (រូបភាព១០) និងផ្តល់យោបល់ឱ្យគ្រូបង្រៀនគិត និងស្វែងការពន្យល់ឱ្យស៊ីជម្រៅ លើគោលការណ៍៤។ Pedaste, Maeots, Siiman, & Jong (2015) បញ្ជាក់ថា ការអនុវត្តគោលការណ៍នីមួយៗ ក្នុងវិធីសាស្រ្តបុច្ឆនសិក្សា ធានាឱ្យសិស្សរៀនបានច្រើនបំផុត និងពង្រីកគុណផលសិក្សាធំបំផុត។

ហេតុផល និងភស្តុតាងនៃការពិសោធរបស់ Pedaste, Maeots, Siiman, & Jong (2015) ចំពោះគុណផលសិក្សារបស់សិស្ស ដោយផ្តោតលើគោលការណ៍ចំនួនបួន នៃការដឹកនាំការរៀនតាមបុច្ឆនសិក្សា ៖

រូបភាព១០. វិធីសាស្ត្របុច្ឆនសិក្សារបស់Pedaste, Maeots, Siiman, & Jong




ប្រភព ៖ បកប្រែ និងសម្រួលពី Pedaste, Maeots, Siiman, & Jong (2015)

គោលការណ៍០១ ៖ លំនាំគិត

ក្នុងការអនុវត្តគោលការណ៍នេះ អ្នកសិក្សាផ្ដើមគំនិត និងឆ្ងល់លើប្រធានបទ ឬចំណោទបញ្ហាដែលត្រូវពង្រីកសេចក្ដីដឹងបន្ថែម និងចម្ងល់ដែលត្រូវស្រាយបំភ្លឺ។ ប្រធានបទ ឬចំណោទបញ្ហាជាធាតុធំទូលាយ សម្រាប់ការគិតនិងឆ្ងល់ ឬឆ្ងល់និងគិត ក្នុងជំហានដំបូង។ ប្រធានបទនៃការគិត ឬចំណោទបញ្ហានៃការគិតសំដៅដល់ធាតុអ្វីមួយ ឬសកម្មភាពអ្វីមួយសម្រាប់នាំផ្លូវចិត្តសិស្សឱ្យគិត។

ឧទាហរណ៍ អ៊ីសាក់ ញូតុន (Isaac Newton, ឆ្នាំ១៦៤៣-១៧២៧) រកឃើញទ្រឹស្ដីវិទ្យាសាស្ត្រមួយ កើតចេញពីលំនាំនៃការគិត គឺផ្លែប៉ោមធ្លាក់ពីលើដើម។

បន្ទាប់មក លោកបានពិសោធលំនាំនៃការទម្លាក់សេរី នូវវត្ថុជាច្រើនប្រភេទដោយទម្លាក់ពីលើចុះក្រោម។ លំនាំនៃការគិត គឺចលនាទម្លាក់ផ្លែប៉ោម និងចលនានៃការធ្លាក់វត្ថុផ្សេងៗ។

គ្រូបង្រៀនក៏អាចបង្កើតលំនាំនៃការគិតបាន ឬសិស្សក៏អាចរកបាន។ សិស្សនិងគ្រូរួមគ្នាបង្កើតលំនាំនៃការគិត។ ក្នុងបរិបទនៃការរៀនដែលអាស្រ័យលើសៀវភៅសិក្សាគោលជាប្រភពនៃចំណេះដឹង គ្រូបង្រៀន និងសិស្សត្រូវធ្វើការរួមគ្នាដើម្បីបង្កើតលំនាំនៃការគិតពីសៀវភៅសិក្សាគោលក៏បានដែរ។ សិស្ស និងគ្រូបង្រៀនរួមគ្នារកចំណោទបញ្ហា ឬប្រធានបទនៃការឆ្ងល់និងគិត ឬគិតនិងឆ្ងល់។

គោលការណ៍០២៖ បង្កើតបញ្ញត្តិ

អ្នកសិក្សាចាប់ផ្ដើមបង្កើតសំណួរតាមការឆ្ងល់ ការគិត និងសន្ទតិរបស់ខ្លួនចំពោះចំណោទបញ្ហា ឬប្រធានបទដែលបានរកឃើញ ក្នុងគោលការណ៍០១។ អ្នកសិក្សាអាចចាប់អារម្មណ៍លើប្រធានបទមួយ ឬចំណោទបញ្ហាមួយ ដូចបានកំណត់ក្នុងគោលការណ៍០១។ គ្រូបង្រៀន និងសិស្សអាចបង្កើតសំណួរ កំណត់អាទិភាពនៃគំនិតដែលត្រូវស្វែងសេចក្ដីពន្យល់ ឬស្រាយចម្ងល់ធំៗ។ ដូច្នេះ ធាតុចម្បងៗ ឬកម្មវត្ថុសម្រាប់ការឆ្ងល់ ការគិត ការបង្កើតសំណួរ ការសួរ និងការសន្ទតិ ដើម្បីការរៀនស៊ីជម្រៅ និងពង្រីកវិសាលភាពនៃគំនិត គឺបញ្ញត្តិ។

ឧទាហរណ៍ អ៊ីសាក់ ញូតុន (Isaac Newton, ឆ្នាំ១៦៤៣-១៧២៧) សួរសំណួរមួយ។ តើផ្លែប៉ោមធ្លាក់ពីលើមកក្រោមត្រូវមានកម្លាំងអ្វីទាញទម្លាក់? ដូច្នេះ បញ្ញត្តិដែលត្រូវស្វែងការពន្យល់អំពីភាពត្រឹមត្រូវ ពិត និងច្បាស់លាស់ គឺ**កម្លាំង**នៃការធ្លាក់ផ្លែប៉ោម ឬវត្ថុផ្សេងៗ មកពីលើដល់ដី។

ក្នុងមុខវិជ្ជាប្រវត្តិវិទ្យា លោកគ្រូ អ្នកគ្រូ សាកល្បងយកប្រធានបទ ឬចំណោទបញ្ហាមួយមកសិក្សាគឺ គំនិតច្នៃប្រឌិតរបស់មនុស្សសម័យហ្វូណន។

គោលការណ៍០៣៖ ស្វែង

អ្នកសិក្សាត្រូវធ្វើការច្រើនដំណាក់កាល និងអនុវត្តសកម្មភាពចម្បងៗជាច្រើន។ អ្នកសិក្សាត្រូវបង្កើតផែនការដើម្បីស្វែងការពន្យល់ និងស្រាយចម្ងល់ក្នុង

គោលការណ៍០៣។ អ្នកសិក្សាត្រូវពន្យល់ភាពពិត ច្បាស់លាស់ និងត្រឹមត្រូវនៃបញ្ញត្តិ ដែលអ្នកសិក្សាបានឆ្ងល់ និងគិត បានគិតនិងឆ្ងល់ ក្នុងគោលការណ៍០២។

បន្ថែមលើសេចក្តីនេះ សិស្សបង្កើតផែនការមួយ ដោយមានការដឹកនាំពីគ្រូបង្រៀន។ ផែនការនោះសំដៅផ្តោតការយកចិត្តទុកដាក់លើសកម្មភាពធំៗ៖

- រកអង្គហេតុបញ្ជាក់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃបញ្ញត្តិ។
- ប្រើអង្គហេតុ ទិន្នន័យ ភស្តុតាងដើម្បីពន្យល់ ស្រាយចម្ងល់។
- ពិសោធបញ្ញត្តិ ដើម្បីបញ្ជាក់ភាពពិត ត្រឹមត្រូវ និងច្បាស់លាស់។

អ្នកសិក្សាសង្កេតបន្តទៀតចំពោះសេចក្តីពន្យល់ និងចម្លើយនៃការស្រាយចម្ងល់នេះ។ អ្នកសិក្សាត្រូវឆ្លើយនឹងសំណួរមួយ។ តើសម្រាយនៃចម្ងល់ និងការគិតនេះ មានភាពត្រឹមត្រូវ ពិត និងច្បាស់លាស់កម្រិតណា? អ្នកសិក្សាអាចពិសោធដោយប្រើបំណិនច្រើន ជាពិសេសបំណិនសម្រាប់ប្រើការក្នុងដំណើរការស្រាវជ្រាវ ដើម្បីវាស់កម្រិតនៃភាពពិត ច្បាស់លាស់ និងត្រឹមត្រូវ។

គោលការណ៍០៤៖ សន្និដ្ឋាន (បូកសរុបលទ្ធផល)

អ្នកសិក្សាបានប្រមូលទិន្នន័យគ្រប់គ្រាន់ គួរឱ្យទុកចិត្ត និងប្រើការបានក្នុងគោលការណ៍០៣។ អ្នកសិក្សាអាចសន្និដ្ឋានរកចំណុចរួមមួយនៃលទ្ធផលដែលបានរកឃើញ។ អ្នកសិក្សាអាចចែករំលែកលទ្ធផលនៃការសន្និដ្ឋានជាមួយអ្នកដទៃ។ ការចែករំលែកនេះ ជាដំណើរការរៀនពិតប្រាកដ។ ចន ឌូវី (John Dewey, ឆ្នាំ១៨៥៩-១៩៥២), បិនចាមីន ប្លូម (Benjamin BLOOM, ឆ្នាំ១៩១៣-១៩៩៩) និង ជេរ៉ូម ប្រុណឺ (Jerome Bruner, ឆ្នាំ១៩១៥-២០១៦) ឡេវ វៃហ្គុតស្គី (Lev Vygotsky, ឆ្នាំ១៨៩៦-១៩៣៤) និងព្យាហ្សេ ហ្សង់ (Piaget Jean, ឆ្នាំ១៨៩៦-១៩៨០) ផ្តល់ទ្រឹស្តីអំពីការរៀនពិតប្រាកដ ឬទ្រឹស្តីនៃការរៀន គឺសហការ និងចែករំលែកជាមួយមនុស្សដទៃដើម្បីជាប្រយោជន៍បន្តទៀត។

### ខ. ការស្រាវជ្រាវ០២៖

របកគំហើញនៃការស្រាវជ្រាវមួយរបស់ Kuhlthau, Leslie, & Caspari (2007) ផ្តោតលើគោលការណ៍ វិធី និងការអនុវត្តវិធីសាស្ត្របុច្ឆនសិក្សា សម្រាប់ដឹកនាំការរៀនលើមុខវិជ្ជាច្រើន តាមសាលារៀន។ របកគំហើញនេះពន្យល់ថា

សិស្សអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ និងបំណិនសតវត្សរ៍ទី២១ តាមរយៈការរៀនតាមវិធីសាស្ត្របុច្ឆនសិក្សា។ Kuhlthau, Leslie, & Caspari (2007) បានសង្ខេបការស្រាវជ្រាវជាច្រើន និងសំយោគលំនាំនៃការដឹកនាំការរៀនតាមវិធីសាស្ត្របុច្ឆនសិក្សា ប្រកបដោយប្រសិទ្ធភាព។

Kuhlthau, Leslie, & Caspari (2007) បញ្ជាក់ថា ការដឹកនាំការរៀនតាមវិធីសាស្ត្របុច្ឆនសិក្សា គឺត្រូវផ្ដើមចេញពីការឆ្ងល់ និងគិត ឬគិតនិងឆ្ងល់ ឈានទៅបង្កើតសំណួរ សួរ រកព័ត៌មាន ឬទិន្នន័យថ្មីៗ ដើម្បីពន្យល់ ដោយមានហេតុផលភស្តុតាង និងឧទាហរណ៍ ដើម្បីបង្កើតពុទ្ធិថ្មី។

Kuhlthau, Leslie, & Caspari (2007) បានបញ្ជាក់បន្ថែមថា វិធីសាស្ត្របុច្ឆនសិក្សាផ្តល់ឱកាសឱ្យសិស្សឆ្ងល់ និងគិតគ្រប់កាល លក្ខខណ្ឌ និងបរិបទ។ សិស្សមានសមត្ថភាពបង្កើតសំណួរច្រើនប្រភេទ និងច្រើនកម្រិតចំពោះចម្ងល់ និងការគិត។ សិស្សស្វែងការពន្យល់លើភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ ចំពោះចម្ងល់ ឬស្រាយចម្ងល់ ប្រកបដោយគុណភាព និងតាមវិធីវិទ្យាសាស្ត្រ។

Kuhlthau, Leslie, & Caspari (2007) ពន្យល់ថា វិធីសាស្ត្របុច្ឆនសិក្សាដឹកនាំសិស្សឱ្យបង្កើត និងប្រើឱកាស ដើម្បីស្រាយចម្ងល់ និងរកដំណោះស្រាយនៃបញ្ហាជាក្រុម និងខ្លួនឯង ប្រកបដោយឯករាជ្យ ច្នៃប្រឌិត និងនវកម្មគំនិត។

មើលរូបភាពបំព្រួញ (រូបភាព១១) ដោយយកចិត្តទុកដាក់ ប្រសិនបើអ្នកគ្រូ លោកគ្រូធ្លាប់រៀន និងយល់អំពីយុទ្ធវិធីដឹកនាំការរៀនមួយឈ្មោះថា តារាង KWL (KNOW, WANT TO LEARN, LEARNED) ប្រហែលជាអ្នកគ្រូ លោកគ្រូឃើញភាពស្រដៀងគ្នាខ្លះ។ រូបគំនូសបំព្រួញនេះផ្គុំនូវរបកគំហើញនៃយុទ្ធវិធីដឹកនាំការរៀនពីរបែបរួមគ្នា ដើម្បីបង្កើតវិធីសាស្ត្របុច្ឆនសិក្សា គឺ ១. តាមKWL និង ២. ការរៀនពីបទពិសោធ (Experience-based learning)។ ការផ្សំផ្គុំយុទ្ធវិធីពីរនេះ Kuhlthau, Leslie, & Caspari (2007) បង្កើតវិធីសាស្ត្រមួយ គឺ បុច្ឆនសិក្សា។

Kuhlthau, Leslie, & Caspari (2007) បង្កើតគោលការណ៍៦ដើម្បីឱ្យគ្រូបង្រៀនពិចារណាអំពីការអនុវត្តវិធីសាស្ត្របុច្ឆនសិក្សា ឱ្យមានប្រសិទ្ធភាពជាមួយសិស្ស និងនៅកម្រិតថ្នាក់រៀន ដូចរូបភាព (រូបភាព១១) ពន្យល់។

រូបភាព១១. វិធីសាស្ត្របុច្ឆនសិក្សាKuhlthau, Leslie, & Caspari (2007)




ប្រភព ៖ បកប្រែ និងសម្រួលពី Kuhlthau, Leslie, & Caspari (2007)

គោលការណ៍០១ ៖ ប្រើបទពិសោធសិស្សដើម្បីការរៀន

គោលការណ៍នេះចាប់ផ្តើមពីសំណួរមួយ។ តើខ្ញុំបានដឹង និងស្គាល់អ្វីខ្លះពាក់ព័ន្ធនឹងបញ្ញត្តិដែលត្រូវរៀន? ក្រោយពីរកការពន្យល់អំពីភាពច្បាស់លាស់ ត្រឹមត្រូវ និងពិត នៃចម្លើយចំពោះសំណួរនេះ គ្រូបង្រៀន ពិតជាយល់ច្បាស់អំពីបញ្ញត្តិ និងបំណិនដែលសិស្សត្រូវរៀន។ សិស្សត្រូវពង្រីកការដឹង និងបន្ថែមធាតុនៃការដឹង ឬបទពិសោធដែលមាន ដោយប្រើលទ្ធផលពីការៀននៅសាលា។

សិស្សនឹងរៀនស៊ីជម្រៅលើបញ្ញត្តិដែលសិស្សធ្លាប់ដឹង ឬស្គាល់ពីបទពិសោធនៃជីវិត ឬរៀនពីមុខវិជ្ជាផ្សេងៗ។ ដូច្នេះ គ្រូបង្រៀនត្រូវរកឱ្យឃើញនូវចំណេះដឹង ឬបទពិសោធដែលសិស្សមានផ្សេងគ្នា ទាក់ទងនឹងបញ្ញត្តិដែលត្រូវរៀន។ បទពិសោធក្នុងន័យនេះ សំដៅក្តោបទាំងព័ត៌មាន ចំណេះដឹង វិជ្ជា និងបញ្ញារបស់សិស្ស។

ឧទាហរណ៍ ម៉ោងនេះ អ្នកគ្រូ លោកគ្រូត្រូវបង្រៀនមេរៀនមួយអំពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ដោយសារពេលវេលាខ្លី-មួយម៉ោង អ្នកគ្រូលោកគ្រូជ្រើសយកអត្ថបទមួយអំពីតំបន់រំដោះតាមព្រំដែនកម្ពុជាថៃ។ អត្ថបទសរសេរដូចខាងក្រោម ៖

*"ដើម្បីការពារសន្តិសុខ ប្រជាជន និងមន្ត្រីរដ្ឋការគ្រប់គ្រងគ្រប់ជាន់ថ្នាក់បានចូលរួមជាមួយកម្លាំងប្រដាប់អាវុធ ក្នុងការយាមកាមតាមតំបន់ដែលខ្លួនរស់នៅ។ រាល់រដូវប្រាំង រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាតែងវាយសម្រុកទៅលើពួកខ្មែរក្រហម និងគ្រប់គ្រងតំបន់មួយចំនួនតាមព្រំដែន ប៉ុន្តែរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ត្រូវដកទ័ពមកវិញនៅរដូវវស្សា ជាហេតុធ្វើឱ្យពួកខ្មែរក្រហមដណ្តើមយកបានវិញមកនូវទីតាំងដែលវាយដណ្តើមយកបាន។"*

ប្រសិនបើអ្នកគ្រូ លោកគ្រូដឹកនាំសិស្សឱ្យរៀនដោយផ្តោតតែលើអត្ថបទលើពាក្យពិបាក ពាក្យគន្លឹះ និងឱ្យសិស្សអានបន្តគ្នា អានបណ្តាក់ និងអានប្រដេញ ដំណើរការរៀនពិតប្រាកដមិនបានកើតឡើងចំពោះសិស្សទេ។ ដំណើរការរៀនពិតប្រាកដ គឺសំដៅឱ្យសិស្សអភិវឌ្ឍពីការដឹងទៅជាការយល់ស៊ីជម្រៅ និងដឹកនាំសិស្សឱ្យយកការយល់ស៊ីជម្រៅទៅប្រើ ក្នុងគ្រប់បរិបទ លក្ខខណ្ឌ និងកាល។ ដើម្បីយកការយល់ស៊ីជម្រៅទៅប្រើការកើត លុះណាការរៀនផ្តោតលើបញ្ញត្តិបង្កប់ក្នុងអត្ថបទនេះ។ តើក្នុងអត្ថបទនេះ អ្វីជាបញ្ញត្តិ? តើអត្ថបទនេះមានចំណុចណាដែលបញ្ជាក់ថា សិស្សធ្លាប់មានបទពិសោធ ឬធ្លាប់ដឹង ដើម្បីទាញយកមកបង្រៀន និងដឹកនាំការរៀន?

គោលការណ៍០២ ៖ ពង្រីក និងបន្ស៊ីបទពិសោធជាមួយបញ្ញត្តិ

បទពិសោធក្នុងន័យនេះ គឺក្តោបទាំងព័ត៌មាន ចំណេះដឹង វិជ្ជា និងបញ្ញារបស់សិស្ស។ គោលការណ៍នេះចាប់ផ្តើមដោយសំណួរមួយថា តើខ្ញុំត្រូវរៀនអ្វីបន្ថែមលើបទពិសោធដែលខ្ញុំមាន ឬកំពុងប្រើ? ការភ្ជាប់ចំណេះដឹង វិជ្ជា និងបទពិសោធមកពីផ្ទះ ឬជីវភាពប្រចាំថ្ងៃជាមួយនឹងបញ្ញត្តិរៀនពីសៀវភៅ និងពីក្នុងថ្នាក់ជាមួយសិស្ស និងគ្រូបង្រៀន គឺសំដៅអភិវឌ្ឍគុណសម្បទាជាពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ។

គោលការណ៍នេះដឹកនាំសិស្សឱ្យសិក្សាស៊ីជម្រៅ និងពង្រីកចំណេះដឹង វិជ្ជា និងបទពិសោធដែលមានស្រាប់។ គោលបំណងនៃការអនុវត្តគោលការណ៍នេះ សំដៅលើកទឹកចិត្តសិស្សឱ្យស្វែងការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ លើចំណេះដឹង វិជ្ជា និងបទពិសោធដែលបានពាំនាំពីជីវភាពប្រចាំថ្ងៃ។

ឧទាហរណ៍ បញ្ញត្តិបង្កប់ក្នុងអត្ថបទស្តីពីតំបន់រំដោះតាមព្រំដែនកម្ពុជា-ថៃ ដូចជា៖ ១. ជម្លោះ ២. សុវត្ថិភាព ៣. សន្តិសុខ ៤. សហការ ៥. ដំណោះស្រាយ ៥. រដូវវស្សា ៦. តំបន់ព្រំដែនខ្មែរថៃ។ យើងយកបញ្ញត្តិ "**ជម្លោះ**" ក្នុងចំណោមបញ្ញត្តិ៦ មកសិក្សាដើម្បីបន្ថែមជម្រៅនៃការគិត ឬពង្រីកវិសាលភាពនៃគំនិតរបស់សិស្ស។ ការសិក្សាស៊ីជម្រៅលើបញ្ញត្តិនេះ សំដៅភ្ជាប់បញ្ញត្តិរៀនពីសៀវភៅសិក្សា និងពីថ្នាក់រៀនជាមួយនឹងបទពិសោធរបស់សិស្ស។ ដូច្នេះ សិស្សអាចភ្ជាប់បញ្ញត្តិជម្លោះ ក្នុងប្រវត្តិសាស្ត្រដែលធ្លាប់រៀនក្នុងមេរៀនមុនៗ ជម្លោះក្នុងសហគមន៍ ក្នុងគ្រួសារ និងជម្លោះ រវាងមិត្តភក្តិ និងមិត្តភក្តិ ជាមួយជម្លោះមានសរសេរក្នុងមេរៀនអំពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា។

គោលការណ៍០៣ ៖ ប្រើទម្លាប់ និងវិធីរៀនផ្សេងគ្នារបស់សិស្ស

ដំណើរការរៀន ទម្លាប់រៀន និងវិធីរៀនរបស់មនុស្ស មានច្រើនបែបច្រើនយ៉ាង។ ការស្រាវជ្រាវជាច្រើនបញ្ជាក់ថា គ្រូបង្រៀនយល់អំពីទម្លាប់ និងវិធីរៀនរបស់សិស្ស មានឥទ្ធិពលធំធេងជួយដល់ដំណើរការរៀនពិតប្រាកដ។

ក្នុងការអនុវត្តគោលការណ៍នេះឱ្យមានប្រសិទ្ធភាព គ្រូបង្រៀនគួរចាប់ផ្តើម ដោយសំណួរមួយ។ តើសិស្សត្រូវរកអ្វីបន្តទៀតដើម្បីបញ្ជាក់ភាពពិត ត្រឹមត្រូវ និងច្បាស់លាស់លើបញ្ញត្តិដែលបានរៀន និងធ្លាប់មានបទពិសោធ? ការ

ឆ្លើយនឹងសំណួរនេះឱ្យបានល្អិតល្អន់ សំដៅពង្រីកសេចក្ដីយល់ស៊ីជម្រៅអំពីសកម្មភាព ទម្លាប់ និងវិធីរៀនរបស់សិស្ស ក្នុងបរិបទ និងលក្ខខណ្ឌផ្សេងៗគ្នា។

ការស្រាវជ្រាវមួយរបស់ Ay (2017) រកឃើញថា គ្រូបង្រៀនយល់ និងឱ្យសិស្សអនុវត្តទម្លាប់ និងវិធីរៀនតាមទម្រង់ និងទម្លាប់របស់ខ្លួន មានឥទ្ធិពលវិជ្ជមានដល់លទ្ធផលសិក្សា។ Ay (2017) បន្តរកឃើញថា ការផ្ដល់ឱកាសឱ្យសិស្សជ្រើសរើស ប្រើទម្លាប់ និងវិធីរៀនរបស់ខ្លួនឯង គឺដាំបណ្ដុះក្ដីស្រឡាញ់ចំពោះការរៀន ហើយសិស្សរៀនបានលទ្ធផលល្អ។

គោលការណ៍០៤ ៖ បញ្ជាក់ភាពពិត ភាពច្បាស់លាស់ និងភាពត្រឹមត្រូវ

ដំណើរការរៀនពិតប្រាកដ គឺស្វែងការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់លើធាតុលម្អិត បច្ច័យ អង្គហេតុ ឬភស្តុតាង បង្កប់ក្នុងបញ្ញត្តិដែលត្រូវរៀន។ ការដឹកនាំការរៀន តាមគោលការណ៍នេះ សំដៅពន្យារការសន្និដ្ឋាន ឬបើកផ្លូវចិត្តរបស់មនុស្សឱ្យទូលំទូលាយ កុំឱ្យមនុស្សសន្មត ឬសន្និដ្ឋាន ដោយពុំទាន់មានភស្តុតាងគ្រប់គ្រាន់ ត្រឹមត្រូវ និងគួរឱ្យទុកចិត្ត។

ក្នុងយុគឧស្សាហកម្ម៤.០ សិស្សអាចរកព័ត៌មាន និងចំណេះដឹងពីច្រើនប្រភព មានទាំងកុហក និងមានទាំងពិត ដោយគ្រាន់តែប្រើម្រាមដៃ។ ដូច្នេះ គ្រូបង្រៀននិងសិស្សត្រូវប្រតិបត្តិគោលការណ៍រកភាពពិត ច្បាស់លាស់ និងត្រឹមត្រូវជាប្រចាំ សន្និដ្ឋានប្រកបដោយភស្តុតាង។

ផ្ដើមអនុវត្តគោលការណ៍នេះ សិស្សត្រូវស្វែងការពន្យល់ចំពោះសំណួរមួយចំនួន? តើខ្ញុំបានពង្រីកពុទ្ធិបន្ថែមកម្រិតណា ឬស៊ីជម្រៅកម្រិតណា? តើខ្ញុំបានរកភស្តុតាងគ្រប់គ្រាន់ដើម្បីជួយពង្រីក និងបន្ថែមជម្រៅ នៃពុទ្ធិរបស់ខ្ញុំឬនៅ? ប្រើគោលការណ៍នេះ សិស្សបានពង្រីកឱកាសច្រើនក្នុងការអភិវឌ្ឍគុណសម្បទាពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ។

គោលការណ៍០៥ ៖ សហការ និងប្រើពុទ្ធិ

ដំណើរការរៀនពិតប្រាកដពុំមែនចប់ត្រឹមរកបានភាពពិត ភាពត្រឹមត្រូវ និងភាពច្បាស់លាស់នៃព័ត៌មាន ចំណេះដឹង និងវិជ្ជាម្នាក់ឯងទេ។ ការរៀនពិតប្រាកដ គឺពង្រីកកិច្ចសហការជាមួយមនុស្សផ្សេង ដើម្បីយកព័ត៌មាន ចំណេះដឹង

និងវិជ្ជាដែលមានភាពច្បាស់លាស់ ពិត និងត្រឹមត្រូវ ទៅប្រើជាប្រយោជន៍នៃមនុស្សបន្តទៀត។

ការអនុវត្តគោលការណ៍សហការ និងប្រើពុទ្ធិ សិស្សបានរៀនពិតប្រាកដ និងបានអភិវឌ្ឍគុណសម្បទាពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ។

គោលការណ៍០៦ ៖ ចែករំលែកពុទ្ធិ និងអភិវឌ្ឍបន្ត

ចន ឌូវី John Dewey (១៨៥៩-១៩៥២), បិនចាមីន ប្លូម Benjamin ប្លូម (BLOOM) (១៩១៣-១៩៩៩) និង ជេរ៉ូម ប្រុណឺ Jerome Bruner (១៩១៥-២០១៦) ឡេវ វៃហ្គុតស្គី Lev Vygotsky (១៨៩៦-១៩៣៤) និង ហ្សង់ ព្យាហ្សេ Piaget Jean (១៨៩៦-១៩៨០) ពន្យល់ថា ការរៀនពិតប្រាកដ កើតឡើងដោយការបើកចិត្តទូលាយ សហការ និងប្រាស្រ័យមនុស្ស។ ដូច្នេះ ចូរអ្នកគ្រូ លោកគ្រូសាកល្បងគិតត្រឡប់ក្រោយនូវពុទ្ធិមួយដែលធ្លាប់មាន និងចែករំលែកជាមួយសហការី។ ឧទាហរណ៍ ពុទ្ធិនោះឋិតក្នុងកម្រិតព័ត៌មាន ឬចំណេះដឹង តើលោកគ្រូបានអភិវឌ្ឍបន្តទៀតដែរឬទេ? ឧទាហរណ៍ អ្នកគ្រូ លោកគ្រូដឹងថា ប្រសិនបើឱ្យសិស្សសម្ភាសន៍ចាស់ៗក្នុងភូមិដែលធ្លាប់ឆ្លងកាត់របបកម្ពុជាប្រជាធិបតេយ្យ សិស្សនឹងទទួលបានព័ត៌មាន និងចំណេះដឹងច្រើនជាងរៀនពីសៀវភៅ។ តើអ្នកគ្រូ លោកគ្រូ ប្រតិបត្តិទម្លាប់អនុញ្ញាតឱ្យសិស្សពង្រីកសេចក្តីយល់ដឹងជាបន្តបន្ទាប់ ដោយខ្លួនឯងរបៀបនេះ ញឹកញាប់ប៉ុនណា?

**គ. ការស្រាវជ្រាវ០៣ ៖**

របកគំហើញនៃការស្រាវជ្រាវរបស់ Kidman & Casinader (2017) បានសំយោគរបកគំហើញនៃការស្រាវជ្រាវជាច្រើនតាំងពីឆ្នាំ១៩០០។ Kidman & Casinader (2017) សំយោគរបកគំហើញនៃការស្រាវជ្រាវរបស់ John Dewey (១៨៥៩-១៩៥២), National Research Council (2000) របស់ Australian Education Council (2006), National Academy of Sciences (2011) នៃបណ្តារដ្ឋនៃសហរដ្ឋអាមេរិក និងអ្នកស្រាវជ្រាវជាច្រើននាក់ទៀត។ របកគំហើញនៃការស្រាវជ្រាវរបស់ Kidman & Casinader (2017) សំយោគទៅតាមប្រភេទនៃមុខវិជ្ជាដែលរៀន និងបង្រៀនតាមសាលារៀន ដូចជា វិទ្យាសាស្ត្រ ប្រវត្តិវិទ្យា

និងភូមិវិទ្យា។ ការសំយោគរបស់ Kidman & Casinader (2017) មាន៥គោលការណ៍សម្រាប់គ្រប់មុខវិជ្ជា។ គោលការណ៍សម្រាប់មុខវិជ្ជានីមួយៗ ចាប់ផ្តើមដោយឆ្ងល់ បង្កើតសំណួរ សួរ ធ្វើចំណោល ធ្វើផែនការ ប្រមូលព័ត៌មាន ញែកប្រភេទទិន្នន័យ វិភាគទិន្នន័យ វាយតម្លៃគុណភាព នៃរបកគំហើញ ចែករំលែក និងផ្សព្វផ្សាយរបកគំហើញ។

រូបភាព១២. វិធីបុច្ចនសិក្សារបស់ Kidman & Casinader (2017)




ប្រភព ៖ បកប្រែ និងសម្រួលពី Kidman & Casinader (2017)

គោលការណ៍១៖ ឆ្ងល់ សួរ និងសន្មតិ

ដំណើរនៃការរៀន ពិតប្រាកដ ឬរៀនប្រកបដោយគុណភាព ផ្តើមចេញពីឆ្ងល់ គិត សង្កេត បង្កើតសំណួរ សួរសំណួរ និង រកការពន្យល់។ អ្នកអប់រំ អ្នកវិទ្យាសាស្ត្រ និងទស្សនវិទូ ចាត់ទុកការឆ្ងល់ សង្កេត បង្កើតសំណួរ សួរ បញ្ចេញគំនិត និងសន្មតជាបេះដូងនៃដំណើរការរៀនពិតប្រាកដ ដើម្បីបង្កើតពុទ្ធិថ្មីសម្បូរបែប

( Scardamalia & Bereiter, 2006; Anderson, Krathwohl, & Airasian, 2001; Agarwal & Bain, 2019)។

Goossen (2002) បំពេញបន្ថែមឱ្យគំនិតខាងលើ។ ដំណើរការរៀន និងដឹកនាំការរៀនតាមវិធីសាស្ត្របុច្ឆនសិក្សា សិស្សនិងគ្រូបង្រៀនចាំស្ទាត់អំពីយុទ្ធវិធីបង្កើតសំណួរ និងសួរសំណួរ។ ការបង្កើតសំណួរ និងសួរសំណួរបែងចែកតាមកម្រិត ពីការចងចាំអង្គហេតុ ទៅរកកម្រិតពិបាក កម្រិតក្របខ័ណ្ឌបញ្ញត្តិ។ សំណួរកម្រិតពិបាក ត្រូវគិតពីប្រធានបទ គំនិតទូទៅ បញ្ញត្តិ និងត្រូវគិតអំពីវិជ្ជានុក្រមប្លូម (BLOOM)ផងដែរ។

សំណួរតែងបើកផ្លូវគិតឱ្យស៊ីជម្រៅ និងនាំមនុស្សឱ្យគិតកាន់តែច្រើន។ សូមលោកគ្រូ អ្នកគ្រូ សាកល្បងសង្កេតសកម្មភាពរបស់យើងផ្ទាល់។ យើងរៀនសង្កេត និងបង្កើតអ្វីមួយថ្មី តើយើងគិត ឆ្ងល់ និងបង្កើតសំណួរដើម្បីសួរខ្លួនឯងឬទេ? ក្នុងមួយជីវិតរបស់យើង សំណួរបានជួយយើងច្រើនណាស់ ប៉ុន្តែយើងភ្លេចគិត និងភ្លេចកត់ត្រាទុកនូវសំណួរដែលយើងបានសួរខ្លួនឯង និងសង្កេតអំពីផលបានពីសំណួររបស់យើង។

របកគំហើញនៃការស្រាវជ្រាវមួយចំនួនពន្យល់ថា សំណួរចែកជាពីរប្រភេទ គឺ១. សំណួរវិជ្ជមាន ឬសំណួរស្ថាបនា ឬសំណួរច្នៃប្រឌិត និង២. សំណួរអវិជ្ជមាន ឬសំណួរទើស។ ក្នុងដំណើរការរៀនក្នុងសៀវភៅនេះ យើងផ្តោតការយកចិត្តទុកដាក់លើវិជ្ជានុក្រម នៃសំណួររបស់សូក្រាត (Socrates, ឆ្នាំ៤៧០-ឆ្នាំ៣៩៩មុនគ.ស)៖ ១. សំណួរប្រតិបត្តិប្រចាំថ្ងៃ ២. សំណួរស្វែងបន្ត ៣. សំណួរបញ្ញត្តិ (គិតកម្រិតស៊ីជម្រៅ និងពង្រីកគំនិតឱ្យសម្បូរបែប)។

គោលការណ៍០២៖ ធ្វើផែនការប្រមូលព័ត៌មាន

ដំណើរការរៀនពិតប្រាកដ រៀនប្រកបដោយគុណភាព សិស្សធ្វើដោយខ្លួនឯង ជាដៃគូឬជាក្រុម ដើម្បីពន្យល់ភាពពិត ភាពត្រឹមត្រូវ និងភាពច្បាស់លាស់នៃចំណេះដឹង។ ចំណេះដឹង និងខ្លឹមសារក្នុងសៀវភៅសិក្សាគោលនៃមុខវិជ្ជាប្រវត្តិវិទ្យា ឬមុខវិជ្ជាផ្សេង តែងផ្តល់ព័ត៌មាន អង្គហេតុ ឧទាហរណ៍ ព្រឹត្តិការណ៍ ឬតួលេខ។ល។ ដើម្បីបញ្ជាក់ភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃចំណេះដឹង និងខ្លឹមសារ និងយកលទ្ធផលនៃការរៀនទៅប្រើការកើត សិស្សត្រូវប្រមូលព័ត៌មាន ទិន្នន័យ ឬអង្គហេតុឱ្យបានគ្រប់គ្រាន់ ពីប្រភពគួរឱ្យទុកចិត្ត។ សិស្សត្រូវមានផែនការមួយច្បាស់លាស់ ដើម្បីប្រមូលព័ត៌មាន ទិន្នន័យ និងអង្គហេតុឱ្យបានច្រើន។ អនុវត្តគោលការណ៍នេះ សិស្សអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាងដូចជា បង្កើតសំណួរ កំណត់អាទិភាពនៃសំណួរ ជ្រើសរើសប្រភេទសំណួរ សម្ភាសដោយសួរសំណួរ និងរកប្រភពផ្តល់ប្រមូលទិន្នន័យគួរឱ្យទុកចិត្ត។

គោលការណ៍០៣ ៖ ចែកប្រភេទ និងវិភាគទិន្នន័យ

ព័ត៌មាន ចំណេះដឹង ទិន្នន័យមានច្រើនប្រភេទណាស់ ក្នុងបាតដៃ។ ព័ត៌មាន ចំណេះដឹង ឬទិន្នន័យមួយចំនួនត្រឹមត្រូវ និងពិត ហើយមួយចំនួនទៀតមិនពិត និងកុហក។ ទិន្នន័យមាន ១. ទិន្នន័យគុណវិស័យ និង២. ទិន្នន័យបរិមាណវិស័យ។ ទិន្នន័យគុណវិស័យ និងបរិមាណវិស័យ ត្រូវបែងចែកទៅតាមអថេរ និងទម្រង់បន្តទៀត។

ក្នុងដំណើរការរៀន សិស្សត្រូវអភិវឌ្ឍបំណិនបែងចែកប្រភេទ ឬចាត់ថ្នាក់នៃអាទិភាពរបស់ព័ត៌មាន ចំណេះដឹង និងទិន្នន័យប្រមូលបាន។ ក្នុងគោលការណ៍០១និង០២ សិស្សប្រមូលបានព័ត៌មានច្រើនប្រភេទ ពីច្រើនប្រភព។ ព័ត៌មាន ឬទិន្នន័យខ្លះពិតជាប្រើការបាន និងខ្លះប្រើការមិនបាន។ ក្នុងការអនុវត្តគោលការណ៍នេះ សិស្សអភិវឌ្ឍបំណិនញែកភាពខុសគ្នា ប្រៀបធៀបប្រភេទព័ត៌មាន និងទិន្នន័យ និងបែងចែកចំណាត់ថ្នាក់នៃព័ត៌មាន និងទិន្នន័យសម្រាប់យកទៅវិភាគ និងចេញជារបាយការណ៍។

គោលការណ៍០៤៖ វាយតម្លៃគុណភាពនៃទិន្នន័យ

អ្នកស្រាវជ្រាវបានញែក ប្រៀបធៀប វិភាគ និងសំយោគទិន្នន័យរួចហើយ អ្នកស្រាវជ្រាវពុំទាន់ប្រាកដថា លទ្ធផលនៃការសំយោគនោះ មានគុណភាព ឬពុំទាន់មានគុណភាពកម្រិតណាទេ។ ប្រសិនបើ អ្នកស្រាវជ្រាវសន្និដ្ឋានដោយប្រើទិន្នន័យដែលពុំមានគុណភាព អ្នកស្រាវជ្រាវពុំអាចបង្កើតតម្លៃនៃការសន្និដ្ឋានរបស់ខ្លួនបានទេ។

គោលការណ៍០៥៖ ចែករំលែករបកគំហើញ

ក្រោយពីវាយតម្លៃគុណភាពនៃទិន្នន័យរួចហើយ សិស្សអាចសន្និដ្ឋាន ឬអាចបង្កើតបានមូលគំនិតមួយថ្មី។ សិស្សបង្ហាញគំនិតរបស់ខ្លួន ក្នុងទម្រង់ផ្សេងៗ ដូចជារូបភាព តារាង ក្រាហ្វ ឬបន្ទាត់ទិន្នន័យ ។ល។ ការរៀនពិតប្រាកដ គឺពុំមែនបានរបកគំហើញហើយ យកមកទុកចោលទេ។ របកគំហើយដែលមានតម្លៃ គឺត្រូវយកទៅចែករំលែកជាមួយមនុស្សដទៃ ក្នុងវិស័យផ្សេងៗ។

**ឃ. ការស្រាវជ្រាវ០៤ ៖**

ស្ថាប័ន Alberta Education (2004) នៃប្រទេសកាណាដា សំយោគការស្រាវជ្រាវជាច្រើន និងសរសេរជាសៀវភៅណែនាំមួយឱ្យគ្រូបង្រៀនអនុវត្តគោលវិធីបុច្ឆនសិក្សាតាមសាលារៀន។ សៀវភៅនេះពន្យល់ថា ការដឹកនាំការរៀនតាមបុច្ឆនសិក្សា ជួយសិស្សឱ្យអភិវឌ្ឍបំណិន និងវិជ្ជាច្រើនបែបច្រើនយ៉ាង និងចែកចេញជា ៦ជំហាន ៖

ជំហាន០១ ៖ បង្កើតផែនការ

ការបង្កើតផែនការជាដំណើរការដំបូងបំផុត និងសំខាន់មិនអាចខ្វះបានសម្រាប់ដំណើរការរៀនតាមវិធីសាស្ត្របុច្ឆនសិក្សា។ ផែនការជារចនាសម្ព័ន្ធនៃការគិត និងសម្រាប់អនុវត្តសកម្មភាពជាលំដាប់តាមពេល និងចង្វាក់នៃការបង្កើតលទ្ធផល។ ផែនការសំដៅបង្កើតរចនាសម្ព័ន្ធនៃសកម្មភាព ដើម្បីធានាឱ្យសិស្សរៀនដើម្បីទទួលបានលទ្ធផលសិក្សា។ លទ្ធផលសិក្សាសំដៅអភិវឌ្ឍចំណេះដឹង និងវិជ្ជាឱ្យបានសម្បូរបែប។ សិស្សត្រូវចាប់ផ្ដើមដោយជ្រើសរើស

ប្រធានបទ ឬចំណោទបញ្ហាមួយដែលត្រូវស្វែងការពន្យល់ ឬការស្រាយបំភ្លឺប្រកបដោយភស្តុតាង។

ជំហាន០២ ៖ រំពូក និងរក

សិស្សមកអង្គុយរៀនក្នុងថ្នាក់ ពុំមែនជាប្រអប់ទទេទេ។ ដូច្នេះ ការចាប់ផ្ដើមរៀន សិស្សត្រូវគិតនិងឆ្លល់លើបទពិសោធធ្លាប់មាន។ បទពិសោធនេះគ្របដណ្ដប់ទាំងព័ត៌មាន ចំណេះដឹង និងវិជ្ជាពាក់ព័ន្ធនឹងប្រធានបទ ឬចំណោទបញ្ហាដែលត្រូវស្វែងការពន្យល់ ឬស្រាយចម្ងល់។ លើសនេះទៀត សិស្សត្រូវគិត និងឆ្ងល់ឬឆ្ងល់និងគិតទៅលើប្រធានបទ ឬចំណោទបញ្ហាថ្មី។ ប្រធានបទ ឬចំណោទបញ្ហាថ្មី មានន័យថា សិស្សទើបប្រទះថ្មី ឬទើបមានសញ្ញាណដំបូង ហើយសិស្សចង់ស្វែងការពន្យល់បន្ថែម ឬពង្រីកសេចក្ដីដឹង។ ប្រសិនបើសិស្សចង់ពង្រីកសេចក្ដីដឹងបន្ថែម និងឱ្យស៊ីជម្រៅលើចំណោទបញ្ហាថ្មី ឬប្រធានបទថ្មីនេះ ក៏ជាការចាប់ផ្ដើមបានដែរ។

ជំហាន ០៣៖ ដំណើរការ

សិស្សបានជ្រើសរើសប្រធានបទ ឬចំណោទបញ្ហាតាមចំណាប់អារម្មណ៍ ឬចំណង់ចំណូលចិត្តរួចហើយ។ ប្រធានបទ ឬចំណោទបញ្ហាដំបូងភាគច្រើនធំទូលំទូលាយពេក។ ចំណោទបញ្ហាធំទូលាយពេក បង្កការលំបាកក្នុងការស្វែងការពន្យល់ឱ្យល្អិតល្អន់។ ចំណោទបញ្ហាធំមួយ អាចមានអញ្ញាតច្រើនពេក។ សិស្សអាចពិបាករកការពន្យល់ឱ្យល្អិតល្អន់ និងច្បាស់លាស់ក្នុងពេលខ្លី។ ដូច្នេះ សិស្សត្រូវចាប់ផ្ដើម ដោយបង្កើតសំណួរ ដើម្បីបញ្ចូលសេចក្ដីនៃប្រធានបទ ឬចំណោទបញ្ហា ឱ្យកាន់តែងាយយល់ និងងាយស្វែងសេចក្ដីពន្យល់។ ដំណើរការបំបែកប្រធានបទ ឬចំណោទបញ្ហាឱ្យទៅជាបំណែកតូចៗ ឬបរិមាណច្រើន ក្នុងដំណាក់កាលនេះ គឺត្រូវង្កើតសំណួរ តាមសមត្ថភាពគិត ជាក្រុម ឬជាបុគ្គល។

បន្ទាប់មកសិស្សសន្មត ឬកំណត់សម្មតិកម្ម ដើម្បីស្វែងការពន្យល់បន្ត។ ភាសាសាមញ្ញ គឺសិស្សជ្រើសរើសធាតុ ឬអញ្ញាតដែលត្រូវស្វែងការពន្យល់។

ជំហាន០៤៖ បង្កើត

សិស្សកំណត់សម្មតិកម្ម ដើម្បីបញ្ជូលសេចក្ដីនៃប្រធានបទ ចម្ងល់ ឬចំណោទបញ្ហា។ សិស្សត្រូវចាប់ផ្ដើមគិតអំពីសកម្មភាពដើម្បីប្រមូលព័ត៌មាន ឬទិន្នន័យ អង្គហេតុសម្រាប់ពន្យល់។ ក្រោយបញ្ចប់ជំហាន០៣ សិស្សប្រមូលបានព័ត៌មាន ឬទិន្នន័យច្រើនប្រភេទណាស់។ ព័ត៌មាន ឬទិន្នន័យពីប្រភពដើមដូចជាសម្ភាសន៍មនុស្ស ឬដកស្រង់គោលគំនិតពីឯកសារស្រាវជ្រាវ សម្បូរពាក្យពិបាកយល់។ ដូច្នេះ ជំហាននេះ សិស្សត្រូវសំយោគគំនិតពីច្រើនប្រភពដើម្បីបង្កើតបញ្ញត្តិមួយសម្រាប់ស្វែងការពន្យល់បន្តទៀត។

ជំហាន ០៥ ៖ ចែករំលែក

ក្រោយអនុវត្តបួនជំហានដំបូងរួចរាល់ សិស្សពិតជាទទួលបានព័ត៌មាន ឬទិន្នន័យច្រើន និងគួរឱ្យទុកចិត្ត ពីច្រើនប្រភព។ ដូច្នេះ សិស្សត្រូវយកលទ្ធផលបានពីការរកឃើញ និងសំយោគឱ្យទៅជារបកគំហើញថ្មី និងចែករំលែកដល់មនុស្សដទៃ មិត្តរួមថ្នាក់ គ្រូបង្រៀន។

ជំហាន ០៦ ៖ វាយតម្លៃ

ជំហានចុងក្រោយបញ្ជាក់ថា ពេលចប់ការស្រាវជ្រាវ សិស្សសប្បាយចិត្តណាស់ ព្រោះសិស្សបានបង្កើតលទ្ធផលមួយដោយខ្លួនឯង។ លទ្ធផលបានពីការស្រាវជ្រាវ ឬបានពីការផលិតអ្វីទាំងអស់ សម្រាប់ចែករំលែក ឱ្យមានការពេញនិយមប្រើប្រាស់ ចាំបាច់ត្រូវធានាឱ្យមានគុណភាព។ ដូច្នេះ សិស្សនិងគ្រូបង្រៀនត្រូវរួមគ្នាវាយតម្លៃលទ្ធផលបានពីការស្រាវជ្រាវ និងវាស់អំពីតម្លៃនៃគុណភាពដោយអនុវត្តតាមសូចនាករណ៍ ឬស្តង់ដាគុណភាពច្បាស់លាស់។

**ង. ការស្រាវជ្រាវ០៥ ៖**

Contant, Tweed, Bass, & Carin (2018) សិក្សាល្អិតល្អន់អំពីស្តង់ដារកម្មវិធីសិក្សា ឬCommon Core Standards នៃមុខវិជ្ជាវិទ្យាសាស្ត្ររបស់រដ្ឋនានានៃសហរដ្ឋអាមេរិក។ Contant, Tweed, Bass, & Carin (2018) បានសំយោគ និងបង្កើតលំនាំនៃការដឹកនាំការរៀនតាមវិធីសាស្ត្របុច្ឆនសិក្សាពីរ៖ ១. យុទ្ធវិធីវិទ្យាសាស្ត្រ និង២. យុទ្ធវិធីវិស្វកម្ម។

យុទ្ធវិធីវិទ្យាសាស្ត្រ អនុវត្តតាមគោលការណ៍មាន៥ជំហាន ដោយផ្ដើមពីកិរិយាសព្ទបញ្ជាក់ពីគោលបំណង ១. ឆ្ងល់និងសួរសំណួរ ២. ធ្វើផែនការ និងស្វែងការពន្យល់ ៣. ប្រមូលនិងវិភាគទិន្នន័យ ៤. ពន្យល់ដោយមានភស្តុតាង ឬទិន្នន័យគ្រប់គ្រាន់ និង៥. ចែករំលែកឬផ្សព្វផ្សាយរបកគំហើញ។ បានអនុវត្តជំហានទាំង៥ សិស្សចេះឆ្ងល់ និងបង្កើតសំណួរ រកព័ត៌មានសម្បូរប្រយោជន៍ ចេះប្រើព័ត៌មានជាប្រយោជន៍ និងពង្រីកជម្រៅនៃពុទ្ធិ ពីកម្រិតចាំអង្គហេតុ ឬព័ត៌មានទៅដល់បង្កើតបានចំណេះដឹង និងវិជ្ជាដែលយកទៅប្រើការបាន តាមកាល បរិបទ និងលក្ខខណ្ឌ។

យុទ្ធវិធីវិស្វកម្ម អនុវត្តតាមគោលការណ៍មាន៥ជំហាន ចាប់ផ្ដើមពីការប្រើកិរិយាស័ព្ទបញ្ជាក់ពីគោលបំណង ១. បញ្ជាក់អំពីចំណោទបញ្ហា ២. ជ្រើសរើសគោលវិធីដោះស្រាយបញ្ហា ៣. អនុវត្តដំណោះស្រាយ ៤. វាយតម្លៃដំណោះស្រាយ និង៥. ផ្សព្វផ្សាយអំពីចំណោទបញ្ហា ជម្រើសនៃគោលវិធីដោះស្រាយបញ្ហា និងអាទិភាពនៃដំណោះស្រាយ។

Contant, Tweed, Bass, & Carin (2018) សន្និដ្ឋានរួមថា ដើម្បីធានាឱ្យការដឹកនាំការរៀនមានប្រសិទ្ធភាព ផ្តល់គុណផលនៃការសិក្សារបស់សិស្ស ហើយសិស្សរៀនពិតប្រាកដ គ្រូបង្រៀនគួរឆ្លើយនឹងសំណួរមួយ។ តើចម្ងល់និងសំណួរពិតជាបេះដូងនៃការដឹកនាំការរៀនតាមបុច្ឆនសិក្សា ដើម្បីបន្ថែមជម្រៅនៃពុទ្ធិពិតមែនឬទេ? ដើម្បីស្វែងការពន្យល់ឱ្យល្អិតល្អន់ចំពោះសំណួរនេះ សាកល្បងគិត រំឭក និងសង្កេតសំណួរមួយចំនួនដែលយើងឆ្ងល់ចំពោះខ្លួនឯង ឬកុមារតូចៗឆ្ងល់និងសួរចាស់ៗ។ តើជើងមេឃចុះនៅឯណា? ហេតុអ្វីបានជាមនុស្សដើរជើងពីរ? ហេតុអ្វីគោដើរជើងបួន? តើសំណួរនេះពិបាកស្វែងរកការពន្យល់ប៉ុនណា? តើអ្នកគ្រូ លោកគ្រូឆ្លើយយករួចខ្លួន កុហក់ក្មេងឬត្រូវផ្តល់ការពន្យល់ដោយរបៀបណា ដើម្បីដាំបណ្ដុះការរៀនពិតប្រាកដ?

១៤.២.២ គុណប្រយោជន៍

ការស្រាវជ្រាវជាច្រើនបានរកឃើញថា ការរៀន និងការដឹកនាំការរៀនតាមវិធីសាស្ត្របុច្ឆនសិក្សា លើកកម្ពស់គុណផលសិក្សារបស់សិស្ស ឆ្លើយតបទៅ

និងលទ្ធផលសិក្សារំពឹងទុកកំណត់សរសេរក្នុងកម្មវិធីសិក្សារបស់សាលារៀន និងអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង (Hughes & Acedo, 2016; Blessinger & Cafora, 2014; Coffman, 2013; King, Erickson, & Sebranek, 2012; ERGÜL, et al., 2011; Alfrieri, Brooks, Aldrich, & Harriet , 2011)។

ឥឡូវពិសោធរឿងមួយដើម្បីដឹងការពិត។ ការផ្ដល់ឱកាសឱ្យសិស្សឆ្លល់គិត បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ ជាឧបករណ៍បំពាក់ស្លាបឱ្យគំនិតរបស់សិស្សហោះហើរលើវេហា។ តើពិតមែនដែរឬទេ?

ក្រោយបានអនុញ្ញាតឱ្យសិស្សចេញទៅស្វែងការពន្យល់ក្រៅពីសៀវភៅ និងពីការរៀបរាប់ ពន្យល់ និងបកស្រាយរបស់គ្រូបង្រៀនក្នុងថ្នាក់រៀន គឺសិស្សមានអារម្មណ៍ដូចមានស្លាបហោះហើរលើវេហា។ តើអ្នកគ្រូ លោកគ្រូពិតជារកភស្តុតាងបញ្ជាក់បាន? ហេតុអ្វីបានជាការរៀនដោយឱ្យសិស្សគិត ឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ គំនិតសិស្សនឹងមានស្លាបហោះហើរ?

យុទ្ធវិធី៥E ៖

១. Engage ៖ អន្ទងសិស្សឱ្យចូលរួម

២. Explore ៖ ស្វែង និងរក

៣. Explain ៖ ពន្យល់

៤. Elaborate ៖ បំពេញបន្ថែម

៥. Evaluate ៖ វាយតម្លៃ

របកគំហើញ នៃការស្រាវជ្រាវរបស់ Abdi (2014) ពន្យល់ថាការប្រើវិធីសាស្ត្របុច្ឆសិក្សា ដោយបញ្ចូលគ្នាជាមួយយុទ្ធវិធីដឹកនាំការរៀន៥E សិស្សពង្រីកការយល់អំពីបញ្ញត្តិ នៃមេរៀនច្បាស់លាស់ និង ប្រឡងបានលទ្ធផលខ្ពស់ជាង សិស្សរៀនជាមួយគ្រូបង្រៀនប្រើយុទ្ធវិធីប្រពៃណី។ យុទ្ធវិធីប្រពៃណីសំដៅដល់យុទ្ធវិធី ក្នុងគោលវិធីគ្រូមជ្ឈមណ្ឌល ឬយុទ្ធវិធីរ៉ាយរ៉ាប់ រៀបរាប់ ពន្យល់ និងបកស្រាយ។

Simsek & Kabapinar (2010) បានរៀបចំតេស្តដើមគ្រាមួយ មុនអនុវត្តវិធីសាស្ត្របុច្ឆនសិក្សា។ លទ្ធផលបង្ហាញថា សិស្ស៤៧.៥% បានបំពេញសំណួរតេស្ត និងសិស្សប្រឡងជាប់តែ ៦៥%ប៉ុណ្ណោះ។ Simsek & Kabapinar (2010) បានរៀបចំតេស្តចុងគ្រាមួយ ក្រោយអនុវត្តវិធីសាស្ត្របុច្ឆនសិក្សាមួយឆ្នាំ។ លទ្ធផលតេស្តចុងគ្រាបង្ហាញថា សិស្ស៩២.៧៥%បានបំពេញសំណួរតេស្ត និងសិស្ស៨៥% បានប្រឡងជាប់។

> ១. តេស្តដើមគ្រា សំដៅដល់ការរៀបចំតេស្តមុនចាប់ផ្តើមបង្រៀនកម្មវិធីមួយ។
> ២. តេស្តចុងគ្រាសំដៅដល់ការរៀបចំតេស្ត ក្រោយបង្រៀនចប់កម្មវិធីមួយ។

ការស្រាវជ្រាវរបស់ Kidman & Casinader (2017) រកឃើញថា គ្រូបង្រៀនដឹកនាំការរៀនតាមវិធីសាស្ត្របុច្ឆនសិក្សាក្នុងមុខវិជ្ជាជាច្រើន ដូចជាវិទ្យាសាស្ត្រ ប្រវត្តិវិទ្យា និងភូមិវិទ្យា សិស្សអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង។ សិស្សបានអភិវឌ្ឍបំណិនមូលដ្ឋាន ដូចជា ឆ្ងល់ បង្កើតសំណួរ សួរសំណួរ និងរកព័ត៌មាន។ លើសពីនេះទៀត សិស្សអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់បែបអ្នកវិទ្យាសាស្ត្រ ដូចជាតម្រៀប បែងចែក និងចាត់ប្រភេទព័ត៌មាន ឬទិន្នន័យ។ សិស្សមានសមត្ថភាពវែកញែក ផ្ទៀងផ្ទាត់ និងពន្យល់បញ្ញត្តិនៃមេរៀនដោយមានហេតុផលអង្គហេតុ និងឧទាហរណ៍។ សិស្សប្រើបំណិនការពារទស្សនៈ ដោយប្រើភស្តុតាង និងចែករំលែកលទ្ធផលរកឃើញជាមួយមនុស្សដទៃ។

របកគំហើញនៃការស្រាវជ្រាវរបស់ Gormally, Brickman, Hallar, & Armstrong (2009), Hughes & Acedo (2016) និង ERGÜL, និងផ្សេងៗ (2011) បានពន្យល់ថា ការដឹកនាំការរៀនតាមវិធីសាស្ត្របុច្ឆនសិក្សា ក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ សិស្សអភិវឌ្ឍបំណិនអក្ខរកម្ម ដោះស្រាយបញ្ហា និងគិតកម្រិតខ្ពស់។ Gormally, Brickman, Hallar, & Armstrong (2009), Hughes & Acedo (2016) និង ERGÜL, និងផ្សេងៗទៀត (2011) បន្ថែមថា សិស្សចេះបង្កើតសំណួរច្រើនកម្រិត ទម្រង់ និងប្រភេទ។ ក្នុងដំណើរការរៀន ក្នុងគ្រប់មេរៀន សិស្សយកបញ្ញត្តិនៃមេរៀនជាគោលសម្រាប់ការគិត បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់

ដោយឯករាជ្យ។ លើសពីនេះទៀត សិស្សហ៊ានយកបញ្ញត្តិរៀនពីសាលាទៅពិសោធគំនិតរបស់ខ្លួន ក្នុងជីវភាពប្រចាំថ្ងៃ និងការងារ។

### ១៤.៣ សិក្សាបញ្ញត្តិ

រូបភាព១៣. គោលការណ៍សិក្សាបញ្ញត្តិ




#### ១៤.៣.១ លំនាំដើម

សិស្សរៀនមេរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ មានសមត្ថភាពប្រែក្លាយព័ត៌មានឱ្យទៅជាចំណេះដឹង ទៅជាវិជ្ជា និងបន្ថែមជម្រៅរហូតដល់បញ្ញា។ សិស្សមានសមត្ថភាពគិត និងប្រើព័ត៌មានជាប្រយោជន៍គ្រប់កាល និងបរិបទ។ សិស្សអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ ដូចជាវិភាគ វាយតម្លៃ និងច្នៃប្រឌិត ដោយផ្ដើមចេញពីទិន្នន័យគ្រប់ជ្រុងជ្រោយ និងព័ត៌មានពិតប្រាកដ និងច្បាស់លាស់។

ក្នុងដំណើរការរៀនដោយប្រើវិធីសាស្ត្រសិក្សាបញ្ញត្តិ និងការតាក់តែងកម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ អ្នកអប់រំត្រូវប្រើទ្រឹស្ដីអប់រំ និងគោល

ការណ៍ជាច្រើន។ មុននឹងយល់អំពីវិធីសាស្ត្រដឹកនាំការរៀនតាមសិក្សាបញ្ញត្តិ អ្នកគ្រូ លោកគ្រូ ត្រូវយល់ និងញែកឱ្យដាច់គ្នានៃពាក្យ**ទ្រឹស្តី គោលការណ៍ ការយល់ទូទៅ គោលគំនិត បញ្ញត្តិ ប្រធានបទ និងអង្គហេតុ**។ពាក្យទាំងនេះនិយមប្រើក្នុងការសរសេរកម្មវិធីសិក្សា និងគោលនយោបាយពាក់ព័ន្ធនឹងអប់រំ៖

- **ទ្រឹស្តី** ៖ ជាប្រព័ន្ធនៃគំនិតដែលមានបំណងពន្យល់បាតុភូតអ្វីមួយ។ បំណងនៃការពន្យល់បាតុភូតត្រូវពឹងអាស្រ័យលើគោលការណ៍។ ប្រព័ន្ធនៃគំនិតសំដៅដល់ការរៀបចំគំនិតជាប្រព័ន្ធ សម្រាប់យកទៅពន្យល់ទ្រឹស្តី។ ទ្រឹស្តីជាកញ្ចប់នៃគោលការណ៍ជាច្រើនផ្សំផ្គុំគ្នា ដើម្បីណែនាំឱ្យមនុស្សអនុវត្តតាម (Cambridge Dictionary, 2020)។ ឧទាហរណ៍ ៖
    - ទ្រឹស្តីអប់រំរបស់ Skinner (១៩៧៤) ឬទ្រឹស្តីអាកប្បកិរិយានិយម (Behavioursim) ចែងថា សិស្សរៀនចាំ ចេះ និងយល់ លុះណា គ្រូបង្រៀនដឹកនាំសិស្សឱ្យធ្វើត្រាប់តាម ទន្ទេញចាំ និងសូត្ររត់មាត់ក្នុងដំណើរការរៀន និងបង្រៀន។
    - ទ្រឹស្តីស្ថាបនានិយម (constructivism) Lev Vygotsky (១៩៧៨) ពន្យល់ថា ការរៀនទទួលបានចំណេះដឹង ឬបង្រៀនសិស្សឱ្យចាំ ចេះ និងយល់ សិស្សត្រូវសម្រួបការគិត និងបំពេញព័ត៌មានទទួលបានថ្មីពីដំណើរការរៀនជាមួយបទពិសោធរបស់សិស្ស។
    - Charles Darwin (១៨០៩-១៨៨២) ពន្យល់ទ្រឹស្តីសង្គមមួយថា មនុស្សវិវត្តពីសត្វស្វា។
- **គោលការណ៍** ៖ ជាសំណើបឋមមួយសម្រាប់បញ្ជាក់លក្ខណៈពិតរបស់ច្បាប់មួយ ជំនឿមួយ ឬបទបញ្ជាមួយដែលមានតម្លៃសម្រាប់មនុស្សក្រុមណាមួយ ឬមនុស្សម្នាក់ តម្រូវតាមកាល លក្ខខណ្ឌ និងបរិបទ (Cambridge Dictionary , 2020)។ ឧទាហរណ៍ ៖
    - គោលការណ៍របស់ខ្ញុំ គឺស្មោះត្រង់។ ភាពស្មោះត្រង់ជាសេចក្តីពិត ឬជាសំណើមួយសម្រាប់បញ្ជាក់អំពីលក្ខណៈពិតរបស់ខ្ញុំ។ នៅពេលមនុស្សនិយាយអំពីខ្ញុំ គឺនិយាយអំពីភាពស្មោះត្រង់របស់ខ្ញុំ។

- ○ គោលការណ៍របស់មនុស្សដែលមើលសម្ភារៈជាធំ តែងចាត់ទុកឡាន វីឡា លុយជាភាពជោគជ័យនៃជីវិត។ មនុស្សដែលប្រកាន់គោលការណ៍នេះតែងចាត់ទុកថា មានសម្ភារៈសម្បូរបែបជាមុនទើបសុខុមាលភាពមកដល់តាមក្រោយ។
- ○ គោលការណ៍របស់មនុស្សដែលសម្លឹងមើលធាតុព្រះខាងក្នុង នៃចិត្តមនុស្ស តែងចាត់ទុកចិត្តមនុស្សជារឿងធំ សំខាន់។ មនុស្សក្រុមនោះតែងចាត់ទុកសុខុមាលភាពផ្លូវចិត្ត ជាយាននាំជោគជ័យមកឱ្យតាមក្រោយ។ មនុស្សក្រុមនេះយល់ថា ពេលមនុស្សមានសុខុមាលភាព សម្ភារៈនឹងមកដល់តាមក្រោយ។
- ○ គោលការណ៍របស់ការដ្ឋានសំណង់នេះ ពុំអាចអនុញ្ញាតឱ្យកម្មករដែលអត់មានពាក់កាតចូលបរិវេណខាងក្នុងបានទេ។ ដូច្នេះ គ្រប់កាល មនុស្សគ្រប់រូបមិនត្រូវបានអនុញ្ញាតឱ្យចូលក្នុងការដ្ឋាន។
- ○ គោលការណ៍មូលដ្ឋានរបស់ក្រុមហ៊ុន គឺបុគ្គលិកប្រឹងធ្វើការបំពេញសូចនាករគុណផលលើសពី២ភាគរយ ទទួលបានលាភការ១០ភាគរយនៃប្រាក់ខែ។
- ○ គោលការណ៍របស់ក្រុមហ៊ុននេះ គឺផ្តល់រង្វាន់លើកទឹកចិត្តជាប្រាក់ឧត្តម្ភស្មើមួយខែ ដល់បុគ្គលិកដែលមិនបញ្ចេញកំហឹងមួយដងសោះក្នុងមួយខែពេញ។

▪ **ការយល់ទូទៅ** ៖ ការយល់ទូទៅគ្របដណ្តប់ពាក្យបីដែលត្រូវប្រើផ្លាស់ប្តូរគ្នាក្នុងសៀវភៅនេះ (រូបភាព១៣) ៖ ១. គោលគំនិត ២. គំនិតទូទៅ ៣. គំនិតធំ។ ការយល់ទូទៅជាការសន្មតិ ឬសន្និដ្ឋាន ក្នុងទម្រង់សរសេរ និយាយ ឬគំនូរ។ ការយល់ទូទៅជាប្រយោគពេញលេញ ឬជាកថាខណ្ឌដែលអ្នកស្តាប់ ឬអ្នកអានចាប់យកគំនិតទូទៅ គោលគំនិត ឬគំនិតធំរបស់អ្នកសរសេរ និយាយ ឬគូរបាន។ ការយល់ទូទៅតែងមានអង្គហេតុមួយចំនួនគាំទ្រ។ ការយល់ទូទៅជាការផ្សំផ្គុំគំនិតទូទៅ គោលគំនិត ឬគំនិតធំ។ គំនិតទូទៅ គោលគំនិត ឬគំនិតធំ អាចផ្សំផ្គុំ ដោយបញ្ញត្តិពីរ ឬច្រើន

ឬផ្តុំដោយប្រធានបទពីរឬច្រើន ឬផ្តុំដោយប្រធានបទផង និងបញ្ញត្តិផងក៏មាន។ បញ្ញត្តិ ឬប្រធានបទក្នុងប្រយោគ ឬកថាខណ្ឌ នៃសេចក្តីសន្និដ្ឋាន ឬសន្និដ្ឋាន ឬការយល់ទូទៅ ត្រូវតែមានទំនាក់ទំនងគ្នា។ ឧទាហរណ៍ មនុស្សត្រូវការដេកយ៉ាងតិច ៦ម៉ោង ទើបមានសុខភាពល្អ។

- **បញ្ញត្តិ** ៖ បញ្ញត្តិមានបង្កប់ក្នុងប្រយោគនៃការនិយាយ ឬសរសេរ អាចជាពាក្យមួយ ឬការផ្សំផ្តុំពាក្យពីរ ឬឃ្លាខ្លីមួយ។ បញ្ញត្តិអាចរំលេចចេញក្នុងប្រយោគ នៃគោលគំនិត គំនិតទូទៅ ឬគំនិតធំ។ បញ្ញត្តិអាចយកទៅប្រើការបាន និងភ្ជាប់បាននឹងតម្រូវការគ្រប់កាល និងបរិបទ។ ពាក្យ ឬឃ្លាខ្លីមួយអាចចាត់ទុកជាបញ្ញត្តិ ត្រូវគោរពលក្ខខណ្ឌ ៖ ១. លក្ខណៈសកល ២. អរូបី ៣. តំណភ្ជាប់ ៤. គ្រប់កាល។

រូបភាព១៤. ភាពខុសគ្នានៃបញ្ញត្តិ និងប្រធានបទ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

- **បញ្ញត្តិ**ត្រូវមានលក្ខណៈសកល។ លក្ខណៈសកលនៃបញ្ញត្តិមួយសំដៅដល់សេចក្តីពិតនិងភាពមិនប្រែប្រួល ក្នុងគ្រប់បរិបទ និងកាល។ លក្ខណៈ

សកលនៃបញ្ញត្តិមួយសំដៅដល់ការយល់ដូចៗគ្នា ក្នុងចំណោមមនុស្សក្នុងក្រុមផ្សេងគ្នា។ ការយល់ដូចគ្នា សំដៅដល់សេចក្តីពិតមួយមិនប្រែប្រួល ទោះបីជាមនុស្ស១០នាក់ ច្រើនពាន់នាក់ក៏ដោយ ក៏នៅតែផ្តល់សេចក្តីពន្យល់ដូចៗគ្នា។ លក្ខណៈសកលនៃបញ្ញត្តិមួយ សំដៅដល់ការយកសេចក្តីពិតទៅប្រើក្នុងគ្រប់វិស័យនៃពុទ្ធិ ឬចំណេះដឹង និងវប្បធម៌។

- **បញ្ញត្តិ**មួយ ក្នុងមេរៀនមួយ មានតំណភ្ជាប់ជាមួយបញ្ញត្តិមួយ ក្នុងមុខវិជ្ជាមួយទៀត។ ឧទាហរណ៍ បម្រែបម្រួលអាចមានរៀនក្នុងមុខវិជ្ជាជីវវិទ្យា ប្រវត្តិវិទ្យា គណិតវិទ្យា។ល។
- **បញ្ញត្តិ**ប្រើបានគ្រប់កាល។ ការប្រើបានគ្រប់កាលនៃបញ្ញត្តិមួយសំដៅដល់ទំនាក់ទំនងនៃបញ្ញត្តិក្នុងជីវភាពប្រចាំថ្ងៃ ការរៀនបន្ត និងការងារ។ ឧទាហរណ៍ កុមារអាយុក្រោម៥ឆ្នាំរៀននៅមត្តេយ្យ អាចរៀនអំពីបម្រែបម្រួលនៃរាងកាយរបស់មនុស្ស និងសត្វ។ កុមារនោះឡើងដល់ថ្នាក់ទី៧ មានអាយុប្រហែល១៣ឆ្នាំ កាន់តែយល់ច្បាស់អំពីបម្រែបម្រួលនៃរាងកាយ ក្នុងមេរៀនជីវវិទ្យា។
- **បញ្ញត្តិ**មានលក្ខណៈអរូបី។ លក្ខណៈអរូបី នៃបញ្ញត្តិមួយ សំដៅដល់ពាក្យមួយ ឬឃ្លាមួយខ្លីដែលជានាមធាតុ។ លក្ខណៈអរូបីនៃបញ្ញត្តិមួយ នាំចិត្តមនុស្សឱ្យឆ្ងល់ និងគិតស៊ីជម្រៅ (Erickson, Lanning, & French, 2017)។ មេរៀនមួយក្នុងមុខវិជ្ជាប្រវត្តិវិទ្យា គឺមេរៀនសម័យលង្វែក និយាយអំពីព្រះបាទ ចន្ទរាជា។ ព្រះបាទចន្ទរាជា ជាបុគ្គលមានវីរភាពគួរចង់ចាំ និងយកគំរូ។ មេរៀននេះ មានពាក្យមួយគួរជាបញ្ញត្តិដែលត្រូវរៀនអំពីព្រះបាទចន្ទរាជា គឺវីរភាព។
- **ប្រធានបទ** ៖ ពាក្យប្រធានបទក្នុងវិធីសាស្ត្រសិក្សាបញ្ញត្តិនេះខុសពីទម្លាប់ប្រើទូទៅកន្លងមក ដូចជា ប្រធានបទប្រឡង ឬប្រធានបទពិភាក្សា។ល។ ប្រធានបទក្នុងការសិក្សាតាមបញ្ញត្តិដែលមានក្នុងប្រយោគនិយាយ ឬសរសេរ ជាពាក្យ ឬឃ្លាខ្លីមួយ។ ការប្រាស្រ័យគ្នានៃគំនិតរបស់មនុស្សត្រូវ

មានប្រធានបទ ប្រធានបទរង ឬអង្គហេតុ ឬគំនិតដើមច្រើនរបស់អ្នកនិយាយ ឬអ្នកសរសេរ។

- **ប្រធាន**បទរៀនក្នុងមេរៀនមួយនៃមុខវិជ្ជាមួយ មិនអាចមានតំណភ្ជាប់ជាមួយប្រធានបទសម្រាប់ការរៀនក្នុងមេរៀនមួយនៃមុខវិជ្ជាមួយផ្សេងទៀតបានទេ។ ប្រធានបទ រៀនពីសៀវភៅ និងពីសាលាពុំអាចយកទៅភ្ជាប់នឹងជីវភាពប្រចាំថ្ងៃ គ្រប់កាល បរិបទ និងលក្ខខណ្ឌបានទេ។ ប្រធានបទពុំមានលក្ខណៈជាសកលទេ។ ប្រធានបទប្រែប្រួលតាមកាល និងបរិបទ។ ឧទាហរណ៍ ជោគជ័យជាប្រធានបទ (ពន្យល់ខាងក្រោយ)។
- **អង្គហេតុ** ៖ ជាឧទាហរណ៍អំពីទីកន្លែង មនុស្ស ព្រឹត្តិការណ៍ បទពិសោធ ឬវត្ថុ។ អង្គហេតុត្រូវបានប្រើសម្រាប់បញ្ជាក់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃបញ្ញត្តិ ប្រធានបទ គំនិតទូទៅ គោលគំនិត ឬគំនិតធំ។

១៤.៣.២ កម្មវិធីសិក្សាបុរាណ

រូបភាព១៥. ឧទាហរណ៍កម្មវិធីសិក្សាលម្អិតប្រវត្តិវិទ្យា




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

អ្នកអប់រំ និងគ្រូបង្រៀននៅកម្ពុជា និងបរទេស បាននិងកំពុងប្រឈម នឹងជម្រើសនៃការសរសេរ តាក់តែង អភិវឌ្ឍកម្មវិធីសិក្សា និងការអនុវត្តកម្មវិធីសិក្សាបុរាណ សម្រាប់សិស្សសតវត្សរ៍ទី២១។ កម្មវិធីសិក្សាបុរាណ សំដៅដល់ការប្រើខ្លឹមសារជាគោល ដើម្បីភ្ជាប់ជាមួយនឹងកិរិយាសព្ទសកម្ម មានសរសេរក្នុងតារាងវិជ្ជានុក្រមប្លូម (BLOOM) (Stern, Lauriault, & Ferraro, 2018; Erickson & Lanning, 2014; Erickson, Lanning, & French, 2017; Erickson L. H., 2008; Ignatavicius, 2017; Erickson L. H., 2008)។

ក្របខ័ណ្ឌកម្មវិធីសិក្សា ឬកម្មវិធីសិក្សាលម្អិតសម្រាប់សាលារៀនជាច្រើនកន្លែងរបស់ប្រព័ន្ធអប់រំជាច្រើនកន្លែង បញ្ចូលមុខវិជ្ជាច្រើនសម្បូរបែបពេក ខ្វះតំណភ្ជាប់បញ្ញត្តិនៃការរៀនជាមួយនឹងតម្រូវការ ក្នុងសង្គម។ ការស្រាវជ្រាវជាច្រើនពន្យល់ថា មេរៀនច្រើនមុខពេក បង្កបរិយាកាសតឹងតែងសម្រាប់សិស្សក្នុងដំណើរការរៀន និងបង្រៀន។ ការអនុវត្តកម្មវិធីសិក្សាបុរាណ ខ្វះតំណចងភ្ជាប់ពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងទៀត ដូចជាមេរៀនមួយក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ និងគណិតវិទ្យា ជាមួយមុខវិជ្ជាសិក្សាសង្គម។ Stern, Lauriault, & Ferraro (2018)ពន្យល់ថា កម្មវិធីសិក្សាបុរាណ ជាទូទៅបង្ខំឱ្យសិស្សទន្ទេញចាំរត់មាត់ ដើម្បីបំពេញតម្រូវការនៃការប្រឡងប៉ុនណោះ។

ការសរសេរកម្មវិធីសិក្សា ការរៀបចំកិច្ចតែងការបង្រៀន និងការដឹកនាំការរៀន គឺពឹងអាស្រ័យជាធំលើរបកគំហើញ នៃការស្រាវជ្រាវរបស់ Tyler (1949), Benjamin ប្លូម (BLOOM) (1956), Anderson, Krathwohl, & Airasian (2001) និង Marzano & Kendall (2008) ជាច្រើនទសវត្សរ៍កន្លងមកហើយ។

ការសរសេរក្របខ័ណ្ឌកម្មវិធីសិក្សា ឬកម្មវិធីសិក្សាលម្អិត សម្រាប់សាលារៀន តែងប្រើទ្រឹស្តី គោលការណ៍ និងវិទ្យាសាស្ត្រនៃការរៀន និងបង្រៀន។ ក្របខ័ណ្ឌកម្មវិធីសិក្សាផ្តោតការយកចិត្តទុកដាក់លើតម្រូវការរបស់អ្នកសិក្សា និងពន្យល់អំពីគោលការណ៍ វិធីសាស្ត្រ យុទ្ធវិធី និងនីតិវិធី សម្រាប់ឱ្យគ្រូបង្រៀន និងអ្នកអប់រំអនុវត្ត ដើម្បីឱ្យទទួលបានផល (Tyler, 1949)។ ផលនៃការរៀនរបស់

សិស្ស គឺសិស្សមានវិជ្ជា និងចរណៈ (Khmer Buddhism Institute , 1931) និងសិស្សទទួលបានចំណេះដឹង បំណិន និងឥរិយាបថ (Tyler, 1949)។

ដើម្បីឱ្យសិស្សរៀនបានផល Tyler (1949) ពន្យល់ថា ការរៀបចំកម្មវិធីសិក្សា សំដៅផ្តោតការយកចិត្តទុកដាក់លើដំណើរប្រព្រឹត្តទៅនៃកិច្ចការពីរ ៖ ១. ដំណើរការ ២. ផលរំពឹងបានពីការអនុវត្តកម្មវិធីសិក្សាជាមួយសិស្សនៅសាលា។

ការរៀបកម្មវិធីសិក្សាបុរាណ ផ្តោតការយកចិត្តទុកដាក់លើវិមាត្រពីរ (រូបខាងលើ)។ ទម្រង់នៃកម្មវិធីសិក្សាលម្អិតរបស់ប្រព័ន្ធអប់រំកម្ពុជាគ្រប់មុខវិជ្ជាលើកលែងប្រវត្តិវិទ្យា គឺផ្តោតការយកចិត្តទុកដាក់លើវិមាត្រពីរ ដូចប្រទេសជាច្រើនដែរ៖ ១. មាតិកា (ចំណងជើង និងចំណងជើងរង) ២. លទ្ធផលសិក្សា (បញ្ជាក់អំពីការធ្វើតាមកិរិយាសព្ទក្នុងតារាងវិជ្ជានុក្រមប្លូម BLOOM)។ កម្មវិធីសិក្សាវិមាត្រពីរ ខ្វះការយកចិត្តទុកដាក់លើបញ្ញត្តិ និងការយល់ស៊ីជម្រៅលើគំនិតទូទៅ គោលគំនិត ឬគំនិតធំ ដែលសិស្សត្រូវសិក្សាស៊ីជម្រៅ និងភ្ជាប់ជាមួយនឹងតម្រូវការក្នុងជីវភាពប្រចាំថ្ងៃ ការងារ និងរៀនបន្ត។

របកគំហើញនៃការស្រាវជ្រាវមួយរបស់ Marzano & Kendall (2008) បានបំពេញបន្ថែមទៅលើកំណែលម្អនៃវិជ្ជានុក្រម ប្លូម (BLOOM, ១៩៥៦) របស់ Anderson, Krathwohl, & Airasian (2001) ដើម្បីផ្តល់យោបល់ឱ្យអ្នកអប់រំ និងគ្រូបង្រៀនពិចារណាកែលម្អដំណើរការតាក់តែងកម្មវិធីសិក្សា លំនាំនៃការដឹកនាំការរៀន និងការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស។

ការសរសេរកម្មវិធីសិក្សាដោយផ្តោតលើការប្រើកិរិយាសព្ទសកម្ម និងមាតិកា (ចំណងជើង និងចំណងជើងរង) នៃមេរៀន មានការពេញនិយមច្រើន ប៉ុន្តែមិនអាចដឹកនាំសិស្សឱ្យគិតដូចអ្នកវិទ្យាសាស្ត្រ និងបំពេញតម្រូវការការងារ និងជីវភាពរស់នៅ ក្នុងយុគឧស្សាហកម្ម៤.0 បានទេ (Stern, Lauriault, & Ferraro, 2018; Erickson, Lanning, & French, 2017; Erickson & Lanning, 2014; Ignatavicius, 2017) ។

ឧទាហរណ៍ កម្មវិធីសិក្សាសម្រាប់សាលារៀន របស់សហរដ្ឋអាមេរិក ក៏ផ្តោតការយកចិត្តទុកដាក់លើការប្រើកិរិយាស័ព្ទសកម្មកំណត់សរសេរ ក្នុងតារាង

វិជ្ជានុក្រមប្លូម (BLOOM, ១៩៥៦) និងផ្គុំជាមួយមាតិកានៃមេរៀនដែរ។ សេចក្ដីថ្លែងនៃសំណេរខាងក្រោមជាការបកប្រែលទ្ធផលសិក្សា សរសេរក្នុងស្ដង់ដារនៃកម្មវិធីសិក្សានៃមុខវិជ្ជាប្រវត្តិវិទ្យា កម្រិតបឋមសិក្សា ថ្នាក់ទី៣-៥ និងមធ្យមសិក្សារបស់សហរដ្ឋអាមេរិក (Common Core U.S., 2014) ៖

- *"សិស្សគួរដឹងថា យុគដែកបានជំនួសយុគសំរិទ្ធក្នុងសហស្សវត្សរ៍ទី១ នៅមុនគ.ស.។ ការជំនួសនេះបានជួយឱ្យមានអត្ថិភាពនៃបច្ចេកវិទ្យាជឿនលឿនជាងមុន និងសង្គ្រាមកាន់តែខ្លាំង។ សិស្សគួរតែដឹងដែរថា យុគដែកបានឆ្លងកាត់ការកកើតឡើងនៃវប្បធម៌ យ៉ាងច្រើនសម្បូរបែបដែរ។ វប្បធម៌ទាំងនោះ កំពុងមានឥទ្ធិពលយ៉ាងខ្លាំងក្លារហូតមកដល់សព្វថ្ងៃ។ វប្បធម៌សម្បូរបែប រួមមាន ជនជាតិអ៊ីស្រាអែលបុរាណ បុព្វបុរសនៃពួកយូដាសម័យទំនើប និងអ្នកបង្កើតសាសនា។ វប្បធម៌សម្បូរបែបនេះបង្កើតឱ្យមានសាសនានានា ដូចជា គ្រិស្តសាសនា សាសនាអ៊ិស្លាម និងក្រិកបុរាណ។ វប្បធម៌ទាំងនោះក៏បានបន្សល់ទុក នូវមរតកជាច្រើនខាងសិល្បៈ ស្ថាបត្យកម្ម ទស្សនវិជ្ជា និងប្រជាធិបតេយ្យផងដែរ។ មរតកទាំងនេះកំពុងមានឥទ្ធិពលខ្លាំងក្លាលើពិភពលោករហូតដល់សព្វថ្ងៃ។ ការរៀនអំពីចំណុចកំពូលនៃក្រិកបុរាណ គឺមានន័យថា កំពុងរៀនក្នុងទម្រង់សង្ខិត្តន័យប៉ុណ្ណោះ។"*
- *"រកមូលហេតុនៃការចូលរួមរបស់សហរដ្ឋអាមេរិក ក្នុងសង្គ្រាមលោកលើកទី២ គិតទាំងការរីកដុះដាលនៃរបបផ្ដាច់ការ និងការវាយប្រហារមកលើកំពង់ផែ Pearl Harbor។"*
- *"វិភាគបញ្ហា វិបត្តិ និងព្រឹត្តិការណ៍ចម្បងៗនៃសង្គ្រាមលោកទី២ ដូចជាសមរភូមិជួរមុខក្នុងសង្គ្រាម ការប្រើទាហានអាមេរិកដើមកំណើតជប៉ុន និងការទម្លាក់គ្រាប់បែកបរមាណូ។"*
- *"ពន្យល់ពីតួនាទីរបស់មេដឹកនាំយោធាសំខាន់ៗ ក្នុងកំឡុងសង្គ្រាមលោកទី២ ដូចជា Omar Bradley, Dwight Eisenhower, Douglas MacArthur, George Marshall និង George Patton។"*

- *ពិពណ៌នាអំពីបញ្ហាប្រឈមផ្នែកពាណិជ្ជកម្មរបស់ NEW ENGLAND ។*

ទម្រង់នៃការសរសេរកម្មវិធីសិក្សាបុរាណនេះ ផ្ដោតលើផលរំពឹងទទួលពីកម្មវិធីសិក្សា ប៉ុន្តែដំណើរការដឹកនាំការរៀនត្រូវកែលម្អ ដើម្បីឱ្យសិស្សរៀនយល់ស៊ីជម្រៅ និងបង្កើតរចនាសម្ព័ន្ធ នៃពុទ្ធិ សម្រាប់ជីវភាពប្រចាំថ្ងៃ ធ្វើការ និងរៀនបន្ត ក្នុងយុគឧស្សាហកម្ម៤.០ ។

ប្រព័ន្ធអប់រំរបស់កម្ពុជា មិនខុសពីបរិបទ នៃការអភិវឌ្ឍកម្មវិធីសិក្សា នៅបរទេសក្នុងបច្ចុប្បន្នដែរ។ ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងបច្ចេកទេសរបស់កម្ពុជា អនុម័តដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៦ មានរហូត១៣មុខវិជ្ជា។ កម្មវិធីសិក្សាលម្អិតគ្រប់មុខវិជ្ជា និងគ្រប់កម្រិតដែលរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានអនុម័ត ក្នុងឆ្នាំ២០១៨ ផ្ដោតការយកចិត្តទុកដាក់លើវិមាត្រពីរ និងខ្វះការយកចិត្តទុកដាក់លើបញ្ញត្តិ ៖ ១. ខ្លឹមសារ (ចំណងជើងនិងចំណងជើងរង) ២. លទ្ធផលសិក្សាដែលបានប្រើកិរិយាសព្ទ ក្នុងតារាងវិជ្ជានុក្រមប្លូម (BLOOM, ១៩៥៦)។

១៤.៣.៣ តើសិក្សាបញ្ញត្តិជាអ្វី?

សិក្សាបញ្ញត្តិ អាចជាគោលវិធី ឬជាវិធីសាស្ត្រ អាស្រ័យ ដោយគោលបំណង និងតម្រូវការរបស់អ្នកប្រើ។ សៀវភៅនេះផ្តល់សេចក្តីពន្យល់ចំពោះសិក្សាបញ្ញត្តិ សម្រាប់បំពេញតម្រូវការក្នុងការសរសេរ តាក់តែង និងអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់សាលារៀន និងតាក់តែងលំនាំនៃការដឹកនាំការរៀននៃមុខវិជ្ជាប្រវត្តិវិទ្យា សម្រាប់គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ ឬទុតិយភូមិដើម្បីដឹកនាំសិស្សឱ្យរៀន និងដើម្បីបង្កើតបញ្ញា។

សិក្សាបញ្ញត្តិជាគោលវិធី សំដៅដល់ទស្សនវិជ្ជា ជំនឿ គោលគំនិត ឬការយល់ឃើញជាគោលការណ៍ ទ្រឹស្តី ឬការសន្មតិអំពីដំណើរប្រព្រឹត្តិទៅនៃការប្រើបញ្ញត្តិ សម្រាប់តាក់តែងកម្មវិធីសិក្សា។ សំខាន់ដូចគ្នាដែរ សិក្សាបញ្ញត្តិជាគោលវិធីសំដៅបញ្ជាក់អំពីគោលការណ៍ សម្រាប់អនុវត្តក្នុងដំណើរការសរសេរ តាក់តែង ឬអភិវឌ្ឍកម្មវិធីសិក្សា។

សៀវភៅនេះផ្តល់លំនាំ នៃការគិតបែបសង្ខិត្តន័យ អំពីគោលវិធីសិក្សាបញ្ញត្តិ សម្រាប់តាក់តែងកម្មវិធីសិក្សាសម្រាប់សាលារៀន និងលម្អិតអំពីវិធីសាស្ត្រសិក្សាបញ្ញត្តិ សម្រាប់តាក់តែងលំនាំនៃការដឹកនាំការរៀន ដើម្បីឱ្យសិស្សរៀនកើតជាវិជ្ជា និងបញ្ញា និងអភិវឌ្ឍចំណេះដឹង វិជ្ជា ចរណៈ គុណតម្លៃមនុស្ស គុណសម្បទាសតវត្សរ៍ទី២១ និងគុណសម្បទាពលរដ្ឋសកល។

សិក្សាបញ្ញត្តិជាវិធីសាស្ត្រ សំដៅដល់ប្រព័ន្ធប្រតិបត្តិ និងការប្រព្រឹត្តិទៅនៃការប្រើបញ្ញត្តិ ដើម្បីដឹកនាំការរៀនឱ្យសិស្សពេញចិត្ត និងទទួលបានផល។ ផលបានពីការរៀន គឺការប្តូរការគិត វាចា ការប្រព្រឹត្តិ និងប្រតិបត្តិបំណិនសតវត្សរ៍ទី២១ សម្រាប់ការរៀនបន្ត រស់នៅ និងធ្វើការ។ វិធីសាស្ត្រសិក្សាបញ្ញត្តិ ជាការសិក្សាលម្អិតអំពីយុទ្ធវិធី ជំហាន និងសកម្មភាពដែលត្រូវប្រើបញ្ញត្តិ សម្រាប់ដឹកនាំការរៀនឱ្យសិស្សអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ ដូចអ្នកវិទ្យាសាស្ត្រ និងប្រតិបត្តិបំណិនសតវត្សរ៍ទី២១ ក្នុងគ្រប់កាល លក្ខខណ្ឌ និងបរិបទ។

ការរៀនតាមគោលវិធីសិក្សាបញ្ញត្តិ និងរៀនជាមួយគ្រូបង្រៀនប្រើវិធីសាស្ត្រសិក្សាបញ្ញត្តិ សិស្សក្លាយជាពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ។ សិស្សរៀនចប់ចេញពីសាលារៀនប្រកបដោយគុណភាព និងគុណសម្បទាជាពលរដ្ឋពូកែ គឺពោរពេញដោយវិជ្ជានិងចរណៈ។ សិស្សចេញទៅបម្រើការងារ ក្នុងគ្រប់វិស័យឧស្សាហកម្មដោយមោទនភាព។ ដូច្នេះ សិស្សនឹងក្លាយជាពលរដ្ឋសកម្ម និងចូលរួមលើកតម្កើងគុណតម្លៃសង្គម។ សិស្សនឹងបំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ និងមានគណនេយ្យភាព។ កម្ពុជានឹងទៅដល់ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅមុន ឬត្រឹមឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់នៅមុន ឬត្រឹមឆ្នាំ២០៥០។

១៤.៣.៤ សិក្សាបញ្ញត្តិ និងតម្រូវការសង្គម

យើងយកសំបុកពីងពាង ជាគោលសម្រាប់ការពិចារណា។ សំបុកពីងពាងស្មុគស្មាញ ប្រទាក់ក្រឡា។ មនុស្សរស់នៅ ធ្វើការ និងរៀន ត្រូវប្រឈម នឹងបញ្ហាច្រើនស្រទាប់ ស្មុគស្មាញ និងប្រទាក់ក្រឡា អាចច្រើនជាង និងស្មុគស្មាញជាងសំបុកពីងពាង។

យើងមើលឃើញភាពប្រទាក់ក្រឡា និងស្មុគស្មាញ នៃសំបុកពីងពាងនឹងភ្នែក។ យើងពិបាកមើលឃើញភាពប្រទាក់ក្រឡា និងស្មុគស្មាញនៃបញ្ហាសង្គម នយោបាយ ប្រជាសាស្ត្រ សេដ្ឋកិច្ច ជនជាតិ អប់រំ ការដឹកនាំ វប្បធម៌ សុខាភិបាល រដ្ឋបាល បម្រែបម្រួលអាសកាសធាតុ បរិយាកាស គ្រឿងញៀន ចិត្តមនុស្ស ជំងឺឆ្លង មេរោគឆ្លង ប្រវត្តិសាស្ត្រ សត្វ សមុទ្រ ណាស់។

រូបភាព១៦. សំបុកពីងពាង



ប្រភព៖ www.freepik.com

ឧទាហរណ៍ ការផ្ទុះមេរោគកូរ៉ូណា ឬជំងឺកូវីដ១៩ ក្នុងចុងឆ្នាំ២០១៩ ពិតជាប្រទាក់ក្រឡា និងស្មុគស្មាញ។ អ្នកវិទ្យាសាស្ត្រសុខាភិបាលពិបាករកថ្នាំព្យាបាល និងថ្នាំវ៉ាក់សាំងការពារ។ ជំងឺនេះបានចម្លងមនុស្សរាប់លាននាក់ និងបង្កឱ្យមនុស្សស្លាប់រាប់ម៉ឺននាក់។ តើបញ្ហានៃជំងឺកូវីដ១៩ ស្មុគស្មាញ និងប្រទាក់ក្រឡាជាងសំបុកពីងពាងដែរឬទេ?

ការស្រាយក្រឡានៃភាពជាប់ប្រទាក់គ្នា និងស្មុគស្មាញ ក្នុងសង្គមមនុស្សពិតជាពិបាករកដំណោះស្រាយមែន ប៉ុន្តែលោកគ្រូ អ្នកគ្រូកុំមានកូនចិត្តគិតថា ពុំមានដំណោះស្រាយ។ អ្នកគ្រូ លោកគ្រូ អាចទទួលយកទស្សនៈមួយសិន *“មានបញ្ហា មានដំណោះស្រាយ។ ពុំមានដំណោះស្រាយ ពុំមែនជាបញ្ហា។”* ផ្ដើមចេញពីទស្សនៈមួយនេះ បញ្ហាប្រឈមប្រទាក់ក្រឡា និងស្មុគស្មាញដូចសំបុកពីងពាង ឬច្រើនជាងសំបុកពីងពាង ក្នុងសង្គមមនុស្ស ត្រូវតែមានដំណោះស្រាយ សម្រាប់មនុស្សមាននវកម្មគំនិត។

ក្រោយរៀនចប់ និងចេញពីសាលារៀនទៅបម្រើការ ក្នុងសង្គម សិស្សនឹងមានអាជីពផ្សេងៗគ្នា ក្នុងគ្រប់វិស័យ។ ដូច្នេះ សិស្សនឹងត្រូវចូលរួមក្នុងសង្គម

ដើម្បីស្រាយភាពប្រទាក់ក្រឡានៃបញ្ហាសង្គម ប្រជាសាស្ត្រ នយោបាយ វប្បធម៌ ពាណិជ្ជកម្ម រដ្ឋាបាល សេដ្ឋកិច្ច បច្ចេកទេស វិទ្យាសាស្ត្រ និងសុខាភិបាល។ល។ ដូច្នេះ ដំណើរការរៀនរបស់សិស្ស ត្រូវការកម្មវិធីសិក្សា និងការដឹកនាំការរៀន តាមសិក្សាបញ្ញត្តិ ដោយខានពុំបាន។ ដំណើរការរៀនតាមសិក្សាបញ្ញត្តិនឹងជួយសិស្សឱ្យស្រាយចំណងនៃបញ្ហាប្រឈម ឬរកច្រកចេញពីបញ្ហាប្រទាក់ក្រឡា និងស្មុគស្មាញ គ្រប់កាល បរិបទ និងលក្ខខណ្ឌ។

ទ្រឹស្តីនៃគុណតម្លៃផលប្រយោជន៍ (Expectancy Value Theory) របស់ Martin Fishbein (ឆ្នាំ១៩៣៦-២០០៩) ពន្យល់អំពីឥរិយាបថ និងទម្លាប់របស់មនុស្ស នាំឱ្យការតាក់តែងកម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ និងដំណើរការរៀន និងដឹកនាំការរៀន តាមវិធីសាស្ត្រសិក្សាបញ្ញត្តិ កាន់តែចាំបាច់ថែមទៀត។ Martin Fishbein (ឆ្នាំ១៩៣៦-២០០៩) ពន្យល់ថា ទម្លាប់ និងឥរិយាបថរបស់មនុស្ស គឺរង់ចាំ មានជំនឿ និងឱ្យតម្លៃចំពោះផលប្រយោជន៍។ នៅពេលមនុស្សប្រមាណឃើញប្រយោជន៍ ទទួលបានក្នុងអនាគត មនុស្សនឹងប្រឹង និងប្រើចំណេះដឹង បទពិសោធ និងសមត្ថភាព។ ការដឹកនាំការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ គឺនាំសិស្សឱ្យគិតមុនអំពីផលដែលត្រូវទទួលបានពីការរៀន។ ផលបានពីការរៀន គឺប្រើបញ្ញត្តិរៀនពីសៀវភៅ គ្រូបង្រៀន មិត្តរួមថ្នាក់ និងពីសាលារៀន ជាមួយការងារ រស់នៅ និងរៀនបន្ត ក្នុងគ្រប់បរិបទ លក្ខខណ្ឌ និងកាល។

### ១៤.៣.៥ សិក្សាបញ្ញត្តិ និងរចនាសម្ព័ន្ធនៃពុទ្ធិ

សិក្សាបញ្ញត្តិពុំមែនទើបតែចាប់ផ្តើមពីការស្រាវជ្រាវរបស់ Taba (1962), Erickson (2008) , Giddens, Wright, & Gray (2012), Erickson & Lanning (2014), Erickson, Lanning, & French (2017), Kluwer (2017), និងStern, Lauriault, & Ferraro (2018)ទេ។ ព្រះពុទ្ធបានដឹកនាំការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ ដើម្បីឱ្យមនុស្សមានវិជ្ជា និងបញ្ញាអំពីជីវិត ស្លាប់ សុខ និងទុក្ខ រាប់សតវត្សរ៍មកហើយ។ ព្រះអង្គក៏បានបង្រៀនមនុស្សឱ្យផ្លាស់ប្តូរចរិត ទៅជាមនុស្សបរិសុទ្ធ ដោយប្រើបញ្ញត្តិដើម្បីផ្តល់សេចក្តីពន្យល់ដែរ។

ឧទាហរណ៍ រឿងនាង កេសា គោតមី និងគ្រាប់ស្ពៃខ្មៅ។ ក្នុងដំណើររឿង ដូចសង្ខេបក្នុងផ្នែកបុច្ឆនសិក្សា មានពាក្យបីដែលគួររៀន ៖ **ជីវិត ទុក្ខ** និង**ស្លាប់**។ ការសិក្សាអំពីដំណើររឿង នាងកេសា គោតមី និងគ្រាប់ស្ពៃខ្មៅ បញ្ជាក់ថា **ស្លាប់** ជាបញ្ញត្តិសម្រាប់ដឹកនាំការរៀនរបស់ព្រះពុទ្ធ។

ឧទាហរណ៍មួយទៀត ក្នុងគម្ពីរព្រះត្រៃបិដក (Burma Tipitaka Association , 2020; Khmer Buddhism Institute , 1931) ព្រះពុទ្ធបង្រៀនបុរសប្រចណ្ឌប្រពន្ធជាមួយព្រះអង្គ។ ព្រះអង្គក៏បានបង្រៀនប្អូនប្រុសរបស់បុរសប្រចណ្ឌប្រពន្ធអំពីសុខ និងសេចក្ដីក្រោធ។ ដោយខឹងនឹងប្រពន្ធមកជួប ថ្វាយបង្គំគាល់ និងប្រគេនចង្ហាន់ដល់ព្រះពុទ្ធ និងព្រះសង្ឃមិនដាច់មួយពេលសោះ។

បុរសជាប្ដីធ្វើដំណើរយ៉ាងតក់ក្រហល់មកកាន់វត្តចេតវន្ត ដើម្បីជួប និងវាយប្រហារលើព្រះពុទ្ធ។ មុនសម្រេចចិត្តវាយប្រហារលើព្រះអង្គ បុរសនោះសួរព្រះពុទ្ធមួយសំណួរ។ តើខ្ញុំត្រូវសម្លាប់អ្វីមុនគេ ដើម្បីរស់ប្រកបដោយសុខ? មួយថ្ងៃៗ ប្រពន្ធខ្ញុំមកនៅជាមួយព្រះអង្គ ពុំខានមួយពេលណាសោះ។ ព្រះអង្គមានពុទ្ធដីកាតបយ៉ាងសាមញ្ញ។ ព្រាហ្មណ៍ចង់រស់ក្នុងសុខ ចូរម្នាលព្រាហ្មណ៍សម្លាប់សេចក្ដីក្រោធសិន! សេចក្ដីក្រោធជាហេតុសម្លាប់សេចក្ដីសុខរបស់ម្នាលព្រាហ្មណ៍។ ក្រោយស្ដាប់ចប់ការបង្រៀនរបស់ព្រះពុទ្ធ អំពីសេចក្ដីក្រោធ ព្រាហ្មណ៍នោះបានបួសជាភិក្ខុ និងសម្រេចសោតា ក្លាយជាព្រះអរហន្ត។

ចំណែកប្អូនប្រុសព្រាហ្មណ៍នោះ មានសេចក្ដីក្រោធចំពោះព្រះពុទ្ធកាន់តែខ្លាំងទៀត ដោយសារបងថ្លៃផង និងបងប្រុសទៅបួសជាសង្ឃផង។ បុរសជាប្អូនបានតិះដៀលព្រះពុទ្ធយ៉ាងអសុរសបន្តទៀត។ ក្រោយចប់សម្ដីប្រមាថ អសុរសព្រះពុទ្ធបានសួរត្រឡប់ទៅបុរសនោះវិញ *"ប្រសិនបើមានភ្ញៀវមួយនាក់មកផ្ទះព្រាហ្មណ៍ ហើយព្រាហ្មណ៍បានផ្ដល់អាហារឱ្យភ្ញៀវនោះ។ ភ្ញៀវនោះមិនបានហូបអាហាររបស់ព្រាហ្មណ៍ទេ។ តើអាហារទាំងនោះនៅជារបស់ព្រាហ្មណ៍ ឬបានក្លាយជារបស់ភ្ញៀវនោះទៅហើយ?"* បុរសនោះឆ្លើយដោយគិតលើសំណួរមួយនោះយ៉ាងយកចិត្តទុកដាក់បំផុត។

បុរសនោះតបថា *“អាហារទាំងនោះនៅតែជារបស់ខ្ញុំ។”* ព្រះអង្គបានតបយ៉ាងសាមញ្ញថា *“កំហឹងព្រាហ្មណ៍ចោលមកលើតថាគត តថាគតមិនទទួលទេ។ ដូច្នេះ សេចក្តីក្រោធទាំងអស់ជារបស់ព្រាហ្មណ៍ដដែល។”* ក្រោយស្តាប់ចប់ និងយល់អំពីព្រះធម៌ បុរសជាប្អូននោះក៏បានបួសជាសង្ឃ។ បញ្ញត្តិដែលព្រះពុទ្ធបានបង្រៀនបុរសជាប្អូន គឺសេចក្តីក្រោធ។

១៤.៣.៦ សិក្សាបញ្ញត្តិក្នុងបរិបទថ្មី

ការអនុញ្ញាតឱ្យសិស្សរៀនពីកម្មវិធីសិក្សាដែលសរសេរឡើង ដោយប្រើគោលវិធីសិក្សាបញ្ញត្តិ និងរៀនពីដំណើរការដឹកនាំការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ សិស្សអភិវឌ្ឍសមត្ថភាពគិតដូចអ្នកវិទ្យាសាស្ត្រ (Stern, Lauriault, & Ferraro, 2018)។ ការគិតដូចអ្នកវិទ្យាសាស្ត្រ សំដៅដល់ការគិត ការឆ្ងល់ បង្កើតសំណួរ សួរសំណួរ ស្វែងការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ នៃទ្រឹស្តី គោលការណ៍ គំនិតទូទៅ គោលគំនិត បញ្ញត្តិ ប្រធានបទ និងអង្គហេតុ។ ដំណើរការគិតបែបនេះនាំសិស្សឱ្យរៀនប្រកបដោយគុណភាព និងរៀនពិតប្រាកដ (Erickson, Lanning, & French, 2017; Stern, Lauriault, & Ferraro, 2018; Kluwer, 2017; Giddens, Wright, & Gray, 2012)។

អ្នកគ្រូ លោកគ្រូសាកល្បងនឹករក ឬរំឭកអំពីការប្រាស្រ័យគ្នារបស់មនុស្សក្នុងគ្រប់ទម្រង់ ដូចជានិយាយ សរសេរ គូររូប គូសសញ្ញា ឬកាយវិការ។ តើរាល់ទម្រង់នៃការប្រាស្រ័យមនុស្ស មានបង្កប់ទ្រឹស្តី គោលការណ៍ គំនិតទូទៅ គោលគំនិត បញ្ញត្តិ គំនិតធំ ប្រធានបទ ឬអង្គហេតុឬទេ? ដើម្បីឱ្យមនុស្សយល់គ្នាក្នុងទម្រង់ផ្សេងៗនៃការប្រាស្រ័យគ្នា អ្នកសរសេរ អ្នកនិយាយ ឬអ្នកគូររូបត្រូវរកប្រធានបទ និងអង្គហេតុចំនួនច្រើន តាមសមត្ថភាពដើម្បីបញ្ជាក់អំពីគំនិតធំ គោលគំនិត ឬគំនិតទូទៅរបស់ខ្លួន។

អ្នកគ្រូ លោកគ្រូសម្គាល់ពេលប្រជុំបច្ចេកទេសកម្រិតសាលារៀន ក្នុងសាលាជាប្រចាំ ឬពេលជជែកគ្នាលេងក្នុងពេលសម្រាក ឬក្នុងពិធីជួបជុំជជែកគ្នាណាមួយ។ ឧទាហរណ៍ អ្នកគ្រូប្រវត្តិវិទ្យាមួយរូបបញ្ចេញយោបល់មួយក្នុងកិច្ចប្រជុំបច្ចេកទេស។ *“ការបង្រៀនសិស្សរៀនខ្សោយ ឬសិស្សខ្ជិលឱ្យចូលរួមក្នុង*

*សកម្មភាពថ្នាក់រៀន គ្រូបង្រៀនត្រូវស្គាល់ និងយល់ពីបរិបទរបស់សិស្សនោះឱ្យច្បាស់លាស់ជាមុនសិន ។"*

យោបល់របស់អ្នកគ្រូមួយប្រយោគនេះបញ្ជាក់អំពីគំនិតទូទៅ គំនិតធំ ឬគោលគំនិតរបស់គាត់ ឬជាការយល់ទូទៅសម្រាប់ឱ្យអ្នកស្តាប់ទទួលយកក្នុងជំហានដំបូង ។ ក្នុងដំណើរការជជែកគ្នាជាបន្តទៀត ប្រហែលជាអ្នកគ្រូនោះអាចផ្តល់ជូនបន្ថែមនូវអង្គហេតុ ឬប្រធានបទដើម្បីឱ្យអ្នកស្តាប់យល់ និងចាប់យកបានបន្តទៀត។ អ្នកគ្រូអាចបន្តទៀតថា *"ការស្គាល់បរិបទសិស្ស សំដៅដល់ការស្គាល់ស្ថានភាព ទម្លាប់ ឬ ឥរិយាបថរបស់សិស្ស។ ឧទាហរណ៍ មុនមករៀនសិស្សត្រូវរវល់ការងារផ្ទះជាច្រើន ដូចជា ដឹកគោទៅស្រែ ឬជួយជញ្ជូនចានឆ្នាំងម្តាយទៅលក់បបរសិន ។ រាល់ពេលចូលផ្ទះ កុមារជួបហិង្សាក្នុងគ្រួសារជាប្រចាំ។ មកដល់សាលារៀន មានគ្រូបង្រៀនខ្លះប្រើហិង្សាបន្ថែមទៀត។ រាល់ពេលចូលផ្ទះ ឃើញតែឪពុកស្រវឹង ។ សិស្សរកអ្នកជួយពន្យល់មេរៀននៅផ្ទះមិនបាន ។ សិស្សងងុយដេករហូត រាល់ពេលមកដល់ថ្នាក់ ។ សិស្សចូលចិត្តលេងសើច និងប្រលែងគ្នាលេងច្រើន ។ សិស្សខាំខ្មៅដៃ ជាយអាវពេលកំពុងរៀន ។ សិស្សបាត់ប៊ិកខ្មៅដៃ ក្នុងថ្នាក់រៀនរាល់ពេល ។ សិស្សអង្គុយមិនស្ងៀម ។ សិស្សប្រាប់អក្សរ ក ភ្លេចអក្សរ ខ ប្រាប់អក្សរ ខ ភ្លេចអក្សរ ក ។"*

ប្រសិនបើការជជែកគ្នាត្រឹមឮសម្តីរបស់អ្នកគ្រូ ហើយអ្នកចូលរួមពុំបានគិតឱ្យស៊ីជម្រៅ ឬពង្រីកវិសាលភាពនៃគំនិតទៅលើសម្តីរបស់អ្នកគ្រូនោះទេ ការប្រជុំ គឺចប់ត្រឹមឮ និងភ្លេចទៅវិញនៅពេលណាមួយ ។ អ្នកចូលរួម ត្រូវយកពាក្យ ឬឃ្លាមួយជាបញ្ញត្តិមកពិចារណា។ ប្រសិនបើមិនដូច្នេះទេ អ្នកគ្រូបានត្រឹមបញ្ចេញមតិចោលក្នុងអង្គប្រជុំ។ ក្រោយចប់អង្គប្រជុំ គ្រូបង្រៀនផ្សេងទៀតអាចមិនដឹងថា ចាប់ផ្តើមគិតឱ្យស៊ីជម្រៅ ឬពង្រីកវិសាលភាពនៃគំនិតពីចំណុចណា។ លោកគ្រូ អ្នកគ្រូផ្សេងពុំអាចយកសម្តីរបស់អ្នកគ្រូទៅអនុវត្តកើត ក្នុងថ្នាក់។ គ្រូបង្រៀនខ្លះទៀត អាចសន្មតថា ការបង្រៀនសិស្សមិនចាំបាច់ស្គាល់ និងយល់អំពីបរិបទសិស្សអ្វីទេ ព្រោះគ្រូបង្រៀនមានបទពិសោធរាប់ឆ្នាំហើយ ។

ដំណើរការរៀនពិតប្រាកដ ឬប្រកបដោយគុណភាព សំដៅដល់ការពង្រីកសេចក្ដីយល់ស៊ីជម្រៅលើគំនិតទូទៅ គោលគំនិត គំនិតធំ បញ្ញត្តិ ប្រធានបទ និងអង្គហេតុដែលអ្នកគ្រូប្រវត្តិវិទ្យាបានចែករំលែកក្នុងអង្គប្រជុំ។ គំនិតធំ គោលគំនិត ឬគំនិតទូទៅ របស់អ្នកគ្រូប្រវត្តិវិទ្យា គឺ**ត្រូវយល់អំពីបរិបទសិស្សឱ្យច្បាស់**។ ប្រធានបទ បញ្ញត្តិ និងអង្គហេតុអ្នកគ្រូបានបន្ថែម ដូចជា ៖

- *មុនមករៀន សិស្សរវល់ការងារផ្ទះច្រើន*
- *ដឹកគោទៅស្រែ*
- *ជួយជញ្ជូនចានឆ្នាំងម្ដាយទៅលក់បបរសិន*
- *រាល់ពេលចូលផ្ទះ សិស្សជួបហិង្សាក្នុងគ្រួសារជាប្រចាំ*
- *រាល់ពេលចូលផ្ទះ ឃើញតែឪពុកស្រវឹង*
- *រកអ្នកជួយពន្យល់មេរៀននៅផ្ទះមិនបាន*
- *រាល់ពេលមកដល់ថ្នាក់ សិស្សងងុយដេក*
- *សិស្សចូលចិត្តលេងសើចច្រើន*
- *សិស្សខាំខ្មៅដៃ ឬជាយអាវពេលកំពុងរៀន*
- *សិស្សអង្គុយមិនស្ងៀម*
- *សិស្សប្រាប់អក្សរ ក ភ្លេចអក្សរ ខ ប្រាប់អក្សរ ខ ភ្លេចអក្សរ ក។*

យើងសាកល្បងបំបែកលំនាំនៃការគិតតាមរូបភាព១៧ ៖

រូបភាព១៧. សិក្សាបញ្ញត្តិ និងចរនាសម្ព័ន្ធនៃពុទ្ធិ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

ដំណើរការរៀនពិតប្រាកដ អាស្រ័យជាធំលើដំណើរការស្វែងការពន្យល់ឱ្យស៊ីជម្រៅចំពោះគំនិតទូទៅ គោលគំនិត ឬគំនិតធំរបស់អ្នកគ្រូប្រវត្តិវិទ្យាដោយប្រើអង្គហេតុ និងប្រធានបទជាភស្តុតាង។ ដើម្បីយល់គំនិតទូទៅ គោលគំនិត ឬគំនិតធំរបស់អ្នកគ្រូ អ្នកស្តាប់ចាំបាច់ត្រូវឆ្ងល់ គិត បង្កើតសំណួរ សួរសំណួរ និងស្វែងការពន្យល់ឱ្យស៊ីជម្រៅទៅលើបញ្ញត្តិនោះបន្តទៀត។ ប្រសិនបើអ្នកគ្រូពុំបានពន្យល់បន្ថែម ដោយផ្តល់ប្រធានបទ ឬអង្គហេតុបន្ថែម អ្នកស្តាប់ត្រូវគិត ឆ្ងល់ បង្កើតសំណួរ និងសួរសំណួរដើម្បីស្វែងការពន្យល់បន្តទៀត។

ដើម្បីពង្រីកសេចក្ដីយល់ស៊ីជម្រៅ និងវិសាលភាពនៃគំនិតអំពីគោលគំនិតរបស់អ្នកគ្រូ អ្នកស្ដាប់ត្រូវញែករកបញ្ញត្តិដែលអ្នកគ្រូផ្ដោតការយកចិត្តទុកដាក់ក្នុងសម្ដីរបស់គាត់ ដូចក្នុងរូបភាពខាងលើ (ទម្លាប់ និងឥរិយាបថជាបញ្ញត្តិ ហើយបរិបទសិស្សជាប្រធានបទ)។

ក្នុងដំណើរការគិត យើងអាចស្រង់បញ្ញត្តិបានពីរបង្កប់ក្នុងគោលគំនិត ឬគំនិតទូទៅរបស់អ្នកគ្រូ ១. ទម្លាប់ និង២. ឥរិយាបថ។ ប្រធានបទក្នុងគំនិតទូទៅរបស់អ្នកគ្រូប្រវត្តិវិទ្យា គឺ បរិបទសិស្ស។ អ្នកគ្រូប្រវត្តិវិទ្យាបានផ្ដល់អង្គហេតុជាច្រើន ដូចជារវល់កិច្ចការផ្ទះ ភ្លេចច្រើន លេងសើចច្រើន ប្រឈមហិង្សាក្នុងគ្រួសារ បរិយាកាសក្នុងគ្រួសារមិនអំណោយផលក្នុងការរៀន ឪពុកស្រវឹង។

រូបភាព១៨. លក្ខណៈនៃបញ្ញត្តិ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

ឧទាហរណ៍មួយទៀត ក្នុងជីវភាពប្រចាំថ្ងៃ ម្ដាយប្រាប់កូន *"កូនត្រូវលាងដៃនឹងសាប៊ូ មុនពេលហូបអាហារ"*។ និយាយអំពីគំនិតទូទៅ ឬគំនិតធំ ឬគោលគំនិត គឺម្ដាយតម្រូវឱ្យកូនលាងដៃនឹងសាប៊ូ។ ប្រសិនបើលោកគ្រូអ្នកគ្រូ បង្រៀន

សិស្ស ឬដឹកនាំការរៀន ត្រឹមប្រាប់សិស្សឱ្យដឹងអំពីគំនិតទូទៅ គំនិតធំ ឬគោលគំនិត គឺចប់ត្រឹមលាងដៃនឹងសាប៊ូ។

រូបភាព១៩. សិក្សាបញ្ញត្តិអំពីមេរោគ និងអនាម័យ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

គោលបំណងនៃដំណើរការរៀនពិតប្រាកដ ឬប្រកបដោយគុណភាព គឺលើសពីការដឹង ស្គាល់ និងចប់ត្រឹមគំនិតធំ គំនិតទូទៅ ឬគោលគំនិត "លាងដៃនឹងសាប៊ូ"។ ដំណើរការរៀនពិតប្រាកដ សំដៅដឹកនាំសិស្សឱ្យគិតស៊ីជម្រៅ និងពង្រីកវិសាលភាពនៃគំនិតឱ្យដល់ប្រធានបទ បញ្ញត្តិ និងអង្គហេតុឱ្យច្រើនមកពន្យល់។ ដំណើរការរៀនពិតប្រាកដ សំដៅដឹកនាំសិស្សឱ្យភ្ជាប់បញ្ញត្តិនៃការរៀន ក្នុងមុខវិជ្ជាមួយជាមួយមុខវិជ្ជាផ្សេង និងភ្ជាប់ទៅស្ថានភាពសង្គមគ្រប់កាល លក្ខខណ្ឌ និងបរិបទ។ ដូច្នេះ ក្នុងគំនិតធំ គោលគំនិត ឬគំនិតទូទៅរបស់ម្ដាយដែលត្រូវគិតឱ្យហួសពីការលាងដៃនឹងសាប៊ូ ក្នុងជម្រៅនៃការគិតរបស់ម្ដាយចង់និយាយអំពីអនាម័យ សុខភាព មេរោគ សុវត្ថិភាព និងការកើតជំងឺ។ តើពិតឬទេ?

ប្រយោគខាងលើបង្កប់គោលគំនិត ប្រធានបទ និងបញ្ញត្តិ ប៉ុន្តែពុំមានបញ្ជាក់អង្គហេតុទេ។ ឥឡូវ យើងចំណាយពេល៥៩វិនាទី គិតបន្តិចទៀត ដើម្បីសិក្សាឱ្យស៊ីជម្រៅលើពាក្យ"អនាម័យ" ឬ "មេរោគ" ដែលយើងទទួលស្គាល់ជាបញ្ញត្តិសិន។ ដូច្នេះ សិស្សអាចស្គាល់សញ្ញាណដំបូង និងទទួលយក **អនាម័យ ឬមេរោគ** ជាបញ្ញត្តិសម្រាប់ដំណើរការរៀនឱ្យស៊ីជម្រៅ ឬឱ្យសិស្សគិត ឬពង្រីកវិសាលភាពនៃគំនិត និងឆ្លល់ច្រើនឱ្យដូចការគិតរបស់អ្នកវិទ្យាសាស្ត្រ។

ដូចបានសរសេរខាងដើម គោលបំណងនៃការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ សំដៅធានាឱ្យសិស្សស្គាល់បញ្ញត្តិ យល់ស៊ីជម្រៅលើបញ្ញត្តិ ភ្ជាប់បញ្ញត្តិនៃមេរៀនមួយ ឬមុខវិជ្ជាមួយជាមួយនឹងមេរៀននៃមុខវិជ្ជាផ្សេង និងយកបញ្ញត្តិទៅអនុវត្ត ក្នុងគ្រប់បរិបទ កាល និងលក្ខខណ្ឌ។

ដំណើរការដឹកនាំការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ សំដៅដឹកនាំសិស្សឱ្យគិតស៊ីជម្រៅ និងពង្រីកវិសាលភាពនៃគំនិត ឱ្យលើសពីត្រឹមដឹងថា លាងដៃនឹងសាប៊ូ។ សិស្សពង្រីកវិសាលភាពនៃគំនិត ភ្ជាប់ជាមួយអនាម័យ និងមេរោគ ប្រចាំកាយ គ្រួសារ និងសង្គម។ សិស្សអាចភ្ជាប់បញ្ញត្តិ "**អនាម័យ**" និង "**មេរោគ**" ជាមួយមេរៀននៃមុខវិជ្ជាផ្សេង ដូចជាប្រវត្តិវិទ្យា គេហវិជ្ជា ភូមិវិទ្យា គណិតវិទ្យា សេដ្ឋកិច្ច ជីវវិទ្យា និងវិទ្យាសាស្ត្រ។ល។ ដូច្នេះ ការរៀនឱ្យចាំខ្លឹមសារ គឺ សិស្សចាំត្រឹម "លាងដៃនឹងសាប៊ូ"។ សិស្សពុំអាចរំកិលការគិតឱ្យដល់បញ្ញត្តិអំពីអនាម័យ និងមេរោគបានទេ។ សិស្សពុំអាចយកបញ្ញត្តិអំពីអនាម័យ និងមេរោគ ទៅភ្ជាប់នឹងតម្រូវការជាក់ស្តែង និងប្រតិបត្តិ តាមលក្ខខណ្ឌ បរិបទ និងកាលបានទេ។

សំខាន់ដូចគ្នាដែរ ក្នុងការអនុវត្តការរៀន និងដឹកនាំការរៀន តាមវិធីសាស្ត្រសិក្សាបញ្ញត្តិ សិស្សមានឱកាសពង្រីកចំណេះដឹងមានស្រាប់ និងពន្យល់អំពីបទពិសោធពាក់ព័ន្ធនឹង មេរោគ ឬអនាម័យក្នុងបរិបទ លក្ខខណ្ឌ និងកាល។

ឧទាហរណ៍ អនាម័យបន្ទប់ដេក។ ការរៀបចំបន្ទប់ដេក គ្រែដេក បត់មុង បត់ភួយ ទុកដាក់ខ្នើយឱ្យមានរបៀបរៀបរយ ជាភាពចាំបាច់សម្រាប់សុខភាព។ ការបោកគក់សម្លៀកបំពាក់ ជាប្រចាំ កុំទុកខោអាវចោលយូរថ្ងៃ និងធានាកំចាត់មេរោគ និងអនាម័យ។ ការសម្អាតបន្ទប់ទឹកក្នុងផ្ទះជាប្រចាំ គ្រប់ពេលចេញចូល

ធានាឱ្យគ្រួសារមានផាសុកភាព គឺអនាម័យបន្ទប់ទឹក និងកម្ចាត់មេរោគ។ ការសម្អាតបន្ទប់ទឹកសាធារណៈជាប្រចាំគ្រប់ពេលចេញចូល ធានាផាសុកភាពមនុស្សទូទៅ។ ការមិនស្ដោះទឹកមាត់តាមដងផ្លូវផ្ដេសផ្ដាសពេលជិះម៉ូតូ ជិះឡានគឺលើកកម្ពស់សុខភាពសាធារណៈ។ ការមិនចោលសំរាមពេញវាល ពាសកាលគ្រប់ពេលហូបអាហារតាមទីសាធារណៈ រួមចំណែកថែសម្រស់ភូមិស្រុក តាមដងផ្លូវ គឺធានាអនាម័យទីសាធារណៈ។ អ្នកគ្រូ លោកគ្រូក៏អាចឱ្យសិស្សប្រាប់ អំពីអនាម័យផ្ទាល់ខ្លួន អនាម័យសម្រាប់គ្រួសារ អនាម័យដើម្បីសង្គមមានប្រយោជន៍អ្វីខ្លះដល់ខ្លួនឯង គ្រួសារ និងសង្គមទាំងមូល។

ការសិក្សាស៊ីជម្រៅបន្តទៀត លើពាក្យមេរោគ។ តើមេរោគអាចរៀនក្នុងមុខវិជ្ជាផ្សេងអ្វីខ្លះ? ការរៀន និងស្វែងយល់ស៊ីជម្រៅអំពីមេរោគ តើសិស្សតូចៗ ឬកុមារមត្តេយ្យអាចរៀនបានឬទេ? តើការរៀនស៊ីជម្រៅ ឬពង្រីកវិសាលភាពនៃការគិតអំពីមេរោគ មានប្រយោជន៍អ្វីខ្លះសម្រាប់សិស្ស ក្នុងការប្រតិបត្តិជីវិតលើសពីលាងដៃនឹងសាប៊ូឬទេ? ការងារបន្ត អ្នកគ្រូ លោកគ្រូពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែបដោយរកអង្គហេតុមកពន្យល់អំពីបញ្ញត្តិ“មេរោគ”។

រូបភាព២០. បញ្ញត្តិ មេរោគ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

ឧទាហរណ៍ ប្រយោគមួយសរសេរថា *"មនុស្សជោគជ័យ ត្រូវមានតុល្យភាពនៃជីវិត។"* ប្រយោគនេះជាការយល់ទូទៅ និងគ្របដណ្ដប់លើគំនិតទូទៅ គោលគំនិត ឬគំនិតធំ ឬការសន្និដ្ឋានរបស់អ្នកសរសេរ។ ការសន្និដ្ឋានមានការប្រទាញប្រទង់គ្នា ក្នុងចំណោមមនុស្សក្នុងក្រុមផ្សេងៗគ្នា ដោយទាញរកហេតុ និងផលឱ្យត្រូវតាមក្រុមរៀងៗខ្លួន។ ក្រុមខ្លះអាចយល់ទៅជ្រុងផ្សេង និងក្រុមខ្លះទៀតអាចយល់ទៅជ្រុងផ្សេងទៀត អាស្រ័យដោយភស្តុតាង ឬទិន្នន័យមានពីជ្រុងផ្សេងគ្នា។ ប្រយោគនេះជាការសន្និដ្ឋានដែលផ្គុំឡើងដោយប្រធានបទពីរ មានទំនាក់ទំនងគ្នា ៖ ១. ជោគជ័យ និង ២. តុល្យភាពនៃជីវិត។

រូបភាព២១. សិក្សាបញ្ញត្តិ ៖ តម្រូវការ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

យើងអាចពង្រីកឱ្យល្អិតល្អន់លើឧទាហរណ៍នៃប្រយោគអំពី**ប្រធានបទ** និង**បញ្ញត្តិ** សម្រាប់ដឹកនាំការរៀនឱ្យសិស្សគិតស៊ីជម្រៅ ដូចអ្នកវិទ្យាសាស្ត្រ។

ការគិតដូចអ្នកវិទ្យាសាស្ត្រសំដៅដល់ការអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់ និងគុណសម្បទាសតវត្សរ៍ទី២១របស់សិស្ស។

ប្រយោគ *"**មនុស្សជោគជ័យ ត្រូវមានតុល្យភាពនៃជីវិត។**"* មានឃ្លាមួយ គឺ**តុល្យភាពនៃជីវិត** និងពាក្យសំខាន់មួយ គឺ**ជោគជ័យ**។ ឥឡូវ លោកគ្រូ អ្នកគ្រូ សាកល្បងបន្ថែមជម្រៅនៃការគិត និងពង្រីកវិសាលភាពនៃគំនិតទៅលើឃ្លា **តុល្យភាពនៃជីវិត**។

តើជីវិតត្រូវមានធាតុ វត្ថុ សម្ភារៈ ឬបទពិសោធអ្វីខ្លះ ទើបជីវិតមានតុល្យភាព? តើមនុស្សទូទៅយល់ដូចម្ដេចចំពោះ តុល្យភាពនៃជីវិត?

អ្នកគ្រូ លោកគ្រូព្យាយាមរកឧទាហរណ៍ជាអង្គហេតុ គំនិតដើម ឬជាប្រធានបទរង ឱ្យបានច្រើនតាមលទ្ធភាព ពាក់ព័ន្ធនឹងឃ្លាខ្លីប្រធានបទ **តុល្យភាពនៃជីវិត**។ ឧទាហរណ៍ មនុស្សមួយក្រុមយល់ថា ៖

- មានលុយផឹកស្រារាល់ថ្ងៃ ទើបជីវិតមានតុល្យភាព
- មានលុយ ឡាន វីឡា ក៏ជីវិតមិនទាន់មានតុល្យភាពដែរ
- មួយឆ្នាំ ត្រូវលម្ហែកាយមាត់សមុទ្រម្ដង ទើបជីវិតមានតុល្យភាព
- មួយឆ្នាំ ត្រូវទៅដើរលេងប្រទេសក្រៅម្ដង ជីវិតមានតុល្យភាព

បន្ថែមជម្រៅនៃការគិត និងពង្រីកវិសាលភាពនៃគំនិតមួយជ្រុងទៀតចំពោះមនុស្សមួយក្រុមទៀត។ មនុស្សមួយក្រុមនេះ អាចយល់ ឬសន្មតថា ៖

- មានគ្រួសារល្អ កូនដោយគន្លងធម៌ ទើបជីវិតមានតុល្យភាព
- ប្ដីប្រពន្ធស្រឡាញ់គ្នាស្មោះ ទើបជីវិតមានតុល្យភាព
- មានសុខភាពផ្លូវកាយល្អ ទើបជីវិតមានតុល្យភាព
- មានសុខភាពផ្លូវចិត្តល្អ ទើបជីវិតមានតុល្យភាព
- មានទំនាក់ទំនងមនុស្សល្អៗច្រើន ទើបជីវិតមានតុល្យភាព
- កូនបានរៀនចប់មហាវិទ្យាល័យ ទើបជីវិតមានតុល្យភាព
- មានការងារធ្វើ មានប្រាក់ចំណូលខ្ពស់ ទើបជីវិតមានតុល្យភាព។

សិក្សាស៊ីជម្រៅលើឃ្លា **តុល្យភាពនៃជីវិត** យើងរកឃើញគំនិតដើម ប្រធានបទរង អង្គហេតុច្រើនបង្កប់ និងពន្យល់ពីជីវិតមានតុល្យភាព។ តុល្យភាព

នៃជីវិត ជាប្រធានបទដែលត្រូវរៀន។ ប្រធានបទនេះមានគំនិតដើម ប្រធានបទរង និងអង្គហេតុច្រើនណាស់ និងយល់ផ្សេងៗគ្នាតាមក្រុមមនុស្សផ្សេងគ្នា។

ក្រោមប្រធានបទនេះ មនុស្សយល់ឃើញផ្សេងគ្នា តាមជ្រុងនៃការគិត និងទិន្នន័យ ឬអាស្រ័យបរិបទ និងកាលផ្សេងគ្នា។ មនុស្សអាចរកប្រធានបទរង អង្គហេតុ ឬគំនិតដើមជាច្រើនទៀត មកពន្យល់អំពីប្រធានបទនេះ។ ដូច្នេះ ឃ្លា "តុល្យភាពនៃជីវិត" ពុំមានលក្ខណៈជាសកលទេ។ "តុល្យភាពនៃជីវិត"ក៏មិនអាចប្រើបានគ្រប់កាល បរិបទ និងលក្ខខណ្ឌដែរ។ ប្រើមិនបានគ្រប់កាល បរិបទ និងលក្ខខណ្ឌ សំដៅដល់ការយល់ និងការប្រតិបត្តិផ្សេងគ្នានៃក្រុមមនុស្សផ្សេងគ្នា។

ហេតុអ្វី "តុល្យភាពនៃជីវិត" ពុំមានលក្ខណៈសកល និងពុំអាចប្រើគ្រប់កាល បរិបទ និងលក្ខខណ្ឌ? តើអ្នកគ្រូ លោកគ្រូ អាចសន្មតថា គំនិតដើម ឬការយល់ឃើញ របស់មនុស្សក្រុមណាត្រូវ និងក្រុមណាខុស? ប្រសិនអ្នកគ្រូ លោកគ្រូ សន្មតថា ក្រុមមួយខុស ឬក្រុមមួយទៀតត្រូវ។ មានន័យថា អ្នកគ្រូ លោកគ្រូ គាំទ្រគំនិតដើមរបស់មនុស្សក្រុមមួយទៀត និងបដិសេធគំនិតដើមរបស់មនុស្សមួយក្រុមទៀត។ ដូច្នេះ ការរៀនពិតប្រាកដមិនទាន់កើតឡើង និងឈានដល់កម្រិតនៃការយល់អំពីបញ្ញត្តិនៅឡើយទេ។

ការរៀនត្រឹមផ្តោតលើគំនិតទូទៅ គោលគំនិត គំនិតធំ ឬប្រធានបទ មនុស្សនៅតែយល់ខុសៗគ្នា អាស្រ័យជ្រុងនៃការគិត ឬការប្រើទិន្នន័យពីជ្រុងផ្សេងគ្នា។ អ្នកគ្រូ លោកគ្រូ សង្កេត និងសម្គាល់ការប្រាស្រ័យគ្នារបស់មនុស្សក្នុងគ្រប់ស្ថានការណ៍។ ហេតុអ្វីមនុស្សចេះតែឈ្លោះខ្វែងគំនិតគ្នារឿងការយល់ឃើញខុសៗគ្នា? ការយល់ឃើញខុសគ្នា ដោយសារមនុស្សផ្តោតការពន្យល់លើគំនិតទូទៅ គោលគំនិត ឬគំនិតធំ ដែលជាការសន្មតិ។ ដូច្នេះ ការដឹកនាំការរៀនឱ្យសិស្សបន្ថែមជម្រៅនៃការគិត និងពង្រីកវិសាលភាពនៃគំនិតឱ្យដល់ការយល់បញ្ញត្តិ ការខ្វែងគំនិតគ្នា ប្រហែលជាមិនអាចកើតឡើងបានទេ។ ដើម្បីស្វែងការពន្យល់អំពីភាពពិត និងត្រឹមត្រូវនៃប្រធានបទ យើងសាកល្បងគិតស៊ីជម្រៅ និងពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែបលើប្រធានបទ "**ជោគជ័យ**" បន្តទៀត។

យើងគិតឱ្យស៊ីជម្រៅមួយជំហានទៀតលើពាក្យ **ជោគជ័យ**។ ពាក្យ "**ជោគជ័យ**" មានគំនិតដើម ប្រធានបទរង ឬ អង្គហេតុច្រើន។ មនុស្សមួយក្រុមយល់ និងសន្មតថា ៖

- មានលុយ មានឡាន មានវីឡា ទើបជីវិតជោគជ័យ
- មានកូនរៀនបានខ្ពង់ខ្ពស់ មានការងារធ្វើ ទើបជីវិតជោគជ័យ
- កូនបានរៀបការជាមួយដៃគូល្អ ទើបជីវិតជោគជ័យ
- មានការងារអាជីព និងប្រាក់ចំណូលថេរ ទើបជីវិតជោគជ័យ។

យើងគិតឱ្យស៊ីជម្រៅ និងពង្រីកវិសាលភាពនៃគំនិតមួយជំហានទៀតលើពាក្យ **ជោគជ័យ**សម្រាប់មនុស្សមួយក្រុមទៀត។ តើមនុស្សក្រុមនេះរកភស្តុតាង ឬឧទាហរណ៍អ្វីខ្លះមកពន្យល់? តើប្រធានបទរង អង្គហេតុ គំនិតដើមសម្រាប់ពន្យល់អំពីជោគជ័យមានអ្វីខ្លះ? ឧទាហរណ៍ មនុស្សក្រុមនេះយល់និងសន្មតថា ៖

- មានគ្រួសារល្អ ស្រឡាញ់គ្នា ទើបជីវិតជោគជ័យ
- មានសុខភាពផ្លូវចិត្តល្អ ទើបជីវិតជោគជ័យ
- មានសុខភាពផ្លូវកាយល្អ ទើបជីវិតជោគជ័យ
- មួយថ្ងៃ ធ្វើអំពើល្អជាមួយមនុស្សម្នាក់ ទើបជីវិតជោគជ័យ។

សិក្សាតែប្រយោគមួយ អំពីជីវិតជោគជ័យ និងតុល្យភាពជីវិត ដូចជាពិបាកយល់បន្តិច ប៉ុន្តែអ្នកគ្រូ លោកគ្រូ កុំទាន់អស់សង្ឃឹម។ យើងនឹងបន្តរកវិធីឱ្យអ្នកគ្រូ លោកគ្រូងាយយល់ និងញែកឱ្យដាច់អំពីគំនិតទូទៅ ប្រធានបទ បញ្ញត្តិ និងអង្គហេតុ។ ក្រោយពីយល់អំពីគំនិតទូទៅ គោលគំនិត គំនិតធំ គោលការណ៍ ទ្រឹស្តី ឬប្រធានបទ អ្នកគ្រូ លោកគ្រូពិតជាអាចបង្កើត ឬកំណត់រកបញ្ញត្តិពីគ្រប់ទម្រង់នៃការប្រាស្រ័យគ្នារបស់មនុស្ស ដូចជាទម្រង់សរសេរ និយាយ រូបភាព កាយវិការ វីដេអូ និងទម្រង់សំឡេង។

យើងវែកញែកប្រយោគ *"មនុស្សជោគជ័យត្រូវមាន**តុល្យភាពនៃជីវិត**។"* ឱ្យល្អិតល្អន់បន្តទៀត។ ឃ្លា"***តុល្យភាពនៃជីវិត***" និងពាក្យ "**ជោគជ័យ**" ដូចបានរៀបរាប់ខាងលើ ពុំមែនជាបញ្ញត្តិទេ ប៉ុន្តែជាប្រធានបទ។ តើអ្វីជាបញ្ញត្តិ អ្វីជាប្រធានបទ និងអ្វីជាអង្គហេតុ ក្នុងគំនិតទូទៅ ឬគំនិតដើមមួយនេះ?

វែកញែកឃ្លា“***តុល្យភាពនៃជីវិត” និង***“**ជោគជ័ យ**” តើយើងអាចបង្កើត ឬ រកបញ្ញត្តិសម្រាប់សិក្សាស៊ីជម្រៅ ឬពង្រីកវិសាលភាពនៃគំនិតបានដែរឬទេ?

វិភាគឱ្យល្អិតល្អន់លើប្រយោគ *“មនុស្សជោគជ័យ ត្រូវមាន**តុល្យភាពនៃជីវិត*** យើងរកឃើញប្រធានបទពីរ **តុល្យភាពនៃជីវិត និងជោគជ័យ**។ ដូចពន្យល់ខាងលើ មនុស្សក្នុងក្រុមនីមួយៗនិយាយអំពីតម្រូវការផ្សេងគ្នាសម្រាប់ជីវិត។ ដូច្នេះ **តម្រូវការ** (ដូចរូបភាពពន្យល់) ជាបញ្ញត្តិដែលត្រូវសិក្សាស៊ីជម្រៅ ឬត្រូវពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែប។

រូបភាព២២. ឧទាហរណ៍បញ្ញត្តិ ៖តម្រូវការ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

ដើម្បីញែកឱ្យដាច់គ្នា ឱ្យឃើញភាពខុសគ្នារវាងបញ្ញត្តិ និងប្រធានបទ លោកគ្រូ អ្នកគ្រូ គិតលើឧទាហរណ៍មួយទៀត។ អត្ថបទប្រវត្តិសាស្ត្រមួយ *“ព្រះបាទចន្ទរាជាមានវីរភាព និងដឹកនាំសង្គ្រាមឈ្នះសមរភូមិជាច្រើនកន្លែង។ ព្រះអង្គដឹកនាំសង្គ្រាម ដណ្ដើម**អាណាចក្រទិសខាងកើត ឬ ស្រឡប់ដូនតីពិជ័យ ព្រៃនគរ** មកវិញ។”* *ព្រះអង្គបានផ្លាស់ប្ដូររាជធានីទៅលង្វែកដែលមានព្រៃឫស្សីហ៊ុមព័ទ្ធយ៉ាងក្រាស់*។ កថាខណ្ឌនេះមានសរសេរគំនិតទូទៅ គោលគំនិត ឬគំនិតធំច្រើនរបស់អ្នកនិពន្ធ។ សំណេរនេះចង់ឱ្យអ្នកអានយល់ទូទៅអំពីវីរភាពរបស់

ព្រះបាទចន្ទរាជា។ យើងសាកល្បងញែកគំនិតធំ ឬគោលគំនិតរបស់អ្នកនិពន្ធ។ ១. *ព្រះបាទចន្ទរាជាមានវីរភាព និងដឹកនាំសង្គ្រាម ដណ្តើម***អាណាចក្រទិសខាងកើត ឬ ស្រឡប់ដូនតីពិជ័យព្រៃនគរមកវិញ,** ២. *ព្រះបាទចន្ទរាជាបានផ្លាស់ប្តូររាជធានីទៅលង្វែកដែលមានព្រៃឫស្សីហ៊ុមព័ទ្ធយ៉ាងក្រាស់។*

រូបភាព២៣. ឧទាហរណ៍សិក្សាបញ្ញត្តិ វីរភាព សង្គ្រាម ទីកន្លែង




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

ប្រសិនបើអ្នកគ្រូ លោកគ្រូឱ្យសិស្សអានអត្ថបទនេះចប់ និងសួររកពាក្យគន្លឹះ និងខ្លឹមសារទូទៅ គំនិតទូទៅ គោលគំនិត ឬគំនិតធំរបស់អ្នកនិពន្ធ សិស្សពុំអាចពង្រីកវិសាលភាពនៃគំនិត បន្ថែមជម្រៅនៃការគិត ឬបន្ថែមកម្លាំងនៃចិត្តឱ្យសិស្សគិត ឆ្ងល់ ឬនឹករកអង្គហេតុមកពន្យល់ឱ្យបានច្រើនទេ។ សំខាន់ដូចគ្នា សិស្សពុំអាចយកខ្លឹមសារទូទៅ គំនិតទូទៅ គោលគំនិត គំនិតធំរបស់អ្នកនិពន្ធទៅភ្ជាប់នឹងតម្រូវការប្រើប្រចាំថ្ងៃ តាមលក្ខខណ្ឌ បរិបទ និងកាលបានទេ។

ដើម្បីឱ្យការរៀនកាន់តែគួរជាទីចាប់អារម្មណ៍ និងដឹកនាំសិស្សឱ្យភ្ជាប់កថាខណ្ឌនេះជាមួយតម្រូវការក្នុងការរៀនបន្ត និងជីវភាពប្រចាំថ្ងៃ គ្រូបង្រៀនគួរបង្រៀនសិស្សឱ្យញែកដាច់នៃភាពខុសគ្នារវាងប្រធានបទ និងបញ្ញត្តិ។

កថាខណ្ឌនេះ មានប្រយោគពេញលេញពីរ។ គំនិតទូទៅ គោលគំនិត ឬគំនិតធំរបស់អ្នកនិពន្ធមានពីរ។ ប្រយោគទី១ *“ព្រះបាទចន្ទរាជាមានវីរភាព និងដឹកនាំសង្គ្រាម ដណ្តើម**អាណាចក្រទិសខាងកើត ឬ ស្រឡប់ដូនតីពិជ័យព្រៃនគរមកវិញ។”*** ក្នុងគោលគំនិតរបស់អ្នកនិពន្ធ មានពាក្យគួរពិចារណាសម្រាប់ការរៀនស៊ីជម្រៅ និងពង្រីកវិសាលភាពនៃគំនិត ដូចជា ១. ការដឹកនាំ ២. ជ័យជម្នះ ៣. សង្គ្រាម ៤. វីរភាព ៥. ទីកន្លែង។ ក្នុងចំណោមពាក្យទាំង៥ តើមួយណាជាបញ្ញត្តិ ឬមួយណាជាប្រធានបទ?

- រូបភាពពន្យល់បញ្ញត្តិបី និងប្រធានបទពីរ។ ការដឹកនាំសិស្សឱ្យសិក្សាស៊ីជម្រៅលើពាក្យមួយក្នុងចំណោមពាក្យ៥ “**វីរភាព**”។ អ្នកគ្រូ លោកគ្រូអាចគិតឱ្យស៊ីជម្រៅលើបញ្ញត្តិមួយទៀត គឺសង្គ្រាម ឬទីកន្លែងក៏បាន។
- ដំណើរការរៀនផ្តោតការយកចិត្តទុកដាក់លើបញ្ញត្តិ **វីរភាព** បង្កើតចម្ងល់មួយ។ ចម្ងល់នោះសួរថា តើព្រះបាទចន្ទរាជា មានគុណសម្បត្តិ ឬគុណតម្លៃអ្វីខ្លះ? អ្នកនិពន្ធសន្និដ្ឋាន ***ព្រះអង្គមានវីរភាព និងដឹកនាំទ័ពដណ្តើមអាណាចក្រទិសខាងកើត ឬ ស្រឡប់ដូនតីពិជ័យព្រៃនគរ មកវិញ?***
- គោលគំនិតរបស់អ្នកនិពន្ធនៃប្រយោគទី២*“ព្រះបាទចន្ទរាជាបានផ្លាស់ប្តូររាជាធានីទៅលង្វែកដែលមានព្រៃឫស្សីហ៊ុមព័ទ្ធយ៉ាងក្រាស់។”* សំដៅបញ្ជាក់អំពីទីកន្លែងសំខាន់ៗក្នុងសម័យលង្វែក និងការផ្លាស់ប្តូររាជធានី។
- ការដឹកនាំការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ ពុំមែនត្រឹមឱ្យសិស្សចាំប្រយោគមួយថា *“ព្រះបាទចន្ទរាជា មានវីរភាពគួរយកគំរូតាមទេ។”* ឬ *“ព្រះបាទចន្ទរាជាបានផ្លាស់ប្តូររាជធានី”*ទេ។ ការរៀនស៊ីជម្រៅ និងពង្រីកវិសាលភាពនៃគំនិត សិស្សត្រូវរកអង្គហេតុមកពន្យល់អំពីវីរភាពរបស់ព្រះបាទចន្ទរាជា ឬការផ្លាស់ប្តូររាជធានី ឬទីកន្លែងសំខាន់ក្នុងសម័យលង្វែក។ ការសរសេរ ឬនិយាយ ដោយខ្វះអង្គហេតុមកពន្យល់គំនិតទូទៅ គំនិតធំ គោលគំនិត របស់អ្នកនិពន្ធ អ្នកនិយាយអាចមិនពិត និងមិនត្រូវ ព្រោះគ្រាន់តែជាការសន្មតិដំបូងប៉ុណ្ណោះ។

- សិស្សអាចភ្ជាប់បញ្ញត្តិអំពីវីរភាពរបស់ព្រះបាទចន្ទរាជ ជាមួយវីរភាពក្នុងមុខវិជ្ជាអក្សរសាស្ត្រខ្មែរ និងមេរៀនប្រវត្តិវិទ្យាសម័យអង្គរ ឬសម័យផ្សេងទៀតបាន។ សិស្សក៏អាចភ្ជាប់បញ្ញត្តិអំពីការផ្លាស់ប្តូរ និងទីកន្លែងជាមួយនឹងមុខវិជ្ជាផ្សេង និងជីវភាពប្រចាំថ្ងៃក៏បាន។
- ការសិក្សាស៊ីជម្រៅលើបញ្ញត្តិ **វីរភាព** ៖ គុណតម្លៃ និងគុណសម្បត្តិនៃបុគ្គលមានវីរភាព មានច្រើនបែបច្រើនយ៉ាង ដូចជា ក្លាហាន ព្យាយាម អត់ធ្មត់ អង់អាច រឹងប៉ឹង មានវិជ្ជា និងមោះមុត។ ព្រះបាទចន្ទរាជា បានដឹកនាំទ័ពដណ្តើម ***អាណាចក្រទិសខាងកើត ឬ ស្រឡប់ដួនតីពិជ័យព្រៃនគរ មកវិញ***។ តើព្រះអង្គមានគុណសម្បត្តិ និងគុណតម្លៃទាំងនេះឬទេ?
- សិស្សអាចភ្ជាប់បញ្ញត្តិ "វីរភាព" ជាមួយនឹងការប្រើប្រាស់ប្រចាំថ្ងៃ ដូចជាសកម្មភាពក្នុងថ្នាក់ នៅផ្ទះ និងក្នុងសហគមន៍។ សិស្សក៏អាចភ្ជាប់បញ្ញត្តិវីរភាពជាមួយវីរភាពរបស់ភ្នាក់ងារនគរបាលណាម្នាក់ គ្រូបង្រៀនណាម្នាក់ ឬរបស់កុមារណាម្នាក់ ក្នុងសហគមន៍ សាលារៀន ឬវីរភាពរបស់បុគ្គលផ្សេងទៀត ក៏បាន។

រូបភាព២៤. ឧទាហរណ៍បញ្ញត្តិ ៖ វីរភាព និងសង្គ្រាម




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

ក្នុងបរិបទនៃការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ គ្រូបង្រៀន និងសិស្សច្រើនច្រលំគ្នា រវាងប្រធានបទ និងបញ្ញត្តិ។ អ្នកគ្រូ លោកគ្រូ ចំណាយពេល៥៩វិនាទីរំឭក និងនឹករកសម្ដីមនុស្សនិយាយប្រាប់យើងអំពីអ្វីមួយ អានអត្ថបទមួយ អានកថាខណ្ឌមួយ ឬច្រើន ឬមើលរូបភាពមួយផ្ទាំង។ តើអ្នកនិយាយ សរសេរ និងអ្នកគូរគំនូរផ្ដល់គំនិតទូទៅ គោលគំនិត ឬគំនិតធំមួយ ឬច្រើនឱ្យយើងចាប់យកអ្វីខ្លះ? ដើម្បីយល់អំពីបញ្ញត្តិ និងប្រធានបទ អ្នកគ្រូ លោកគ្រូអានឧទាហរណ៍មួយបន្តទៀត។

*ប្រជាជនខ្មែរជាច្រើននាក់ និងច្រើនជំនាន់ចាត់ទុកការបន់ស្រន់ជាការសុំសេចក្ដីសុខ និងសុំឱកាសដើម្បីរកទ្រព្យ។* វិភាគប្រយោគនេះ យើងរកឃើញថា គំនិតទូទៅ គោលគំនិត គំនិតធំរបស់អ្នកសរសេរ អ្នកនិយាយ គឺការបន់ស្រន់ជារឿងចាំបាច់សម្រាប់ប្រជាជនខ្មែរច្រើនជំនាន់មកហើយ។ ប្រជាជនខ្មែរយល់ទូទៅថា ការបន់ស្រន់ជាទង្វើផ្ទាល់ខ្លួនដើម្បីនាំឱកាស លាភ និងសុខមកឱ្យខ្លួន និងគ្រួសារ។

រូបភាព២៥. ឧទាហរណ៍សិក្សាបញ្ញត្តិ និងរចនាសម្ព័ន្ធនៃពុទ្ធិ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

- គិតរឿងបន់ស្រន់ព្រះ យើងនឹកឃើញការប្រតិបត្តិសាសនា។ គិតអំពីការប្រតិបត្តិសាសនា យើងគិតឃើញដល់ពាក្យមួយទៀត គឺជំនឿ។ **ជំនឿ**ជាបញ្ញត្តិសម្រាប់ដឹកនាំការរៀន។ ប្រសិនបើ គ្រូបង្រៀនដឹកនាំការគិត និងការរៀនផ្តោតលើបន់ស្រន់ព្រះ គឺចប់ត្រឹមបន់ស្រន់ព្រះ។ សិស្សមិនអាចពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែបបានទេ។ លើសពីនេះទៅទៀត សិស្សពុំអាចវិភាគអំពីការប្រតិបត្តិជំនឿ ទៅតាមសាសនាផ្សេងបានទេ។ សិស្សនៅតែជជែកគ្នាតាមជ្រុងនៃការសន្មតិ និងសាសនារៀងខ្លួន។

រូបភាព២៦. ឧទាហរណ៍បញ្ញត្តិ ៖ ជំនឿ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

- សិក្សាលម្អិតបន្តទៀត ប្រសិនបើអ្នកគ្រូ លោកគ្រូ ដឹកនាំសិស្សជជែកគ្នាអំពីសាសនា ការពិភាក្សានឹងផ្តោតការយកចិត្តទុកដាក់លើការបង្រៀននៃសាសនានីមួយៗ ដូចជា សាសនាព្រះពុទ្ធ សាសនាគ្រិស្ត សាសនាហិណ្ឌូ សាសនាអ៊ិស្លាម។ល។ ដូច្នេះ ដំណើរការរៀននិងដឹកនាំសិស្សឱ្យរៀនផ្ទៃខាងលើនៃព័ត៌មានអំពីសាសនានីមួយៗ និងខ្វះការតភ្ជាប់នឹងតម្រូវការប្រចាំថ្ងៃ និងការរៀនបន្តរបស់សិស្ស។

- បន្តទៀត អ្នកគ្រូ លោកគ្រូសាកល្បងឱ្យសិស្សជជែកគ្នាឱ្យសកម្មលើជំនឿ និងសាសនា។ អ្នកគ្រូ លោកគ្រូនឹងទទួលលទ្ធផលគួរកត់សម្គាល់ ទាក់ទងនឹងការប្រតិបត្តិប្រចាំថ្ងៃរបស់សិស្ស និងបទពិសោធរបស់សិស្ស។

ដើម្បីពង្រីកសេចក្ដីយល់ស៊ីជម្រៅអំពីបញ្ញត្តិ និងប្រធានបទ អ្នកគ្រូ លោកគ្រូសិក្សាឧទាហរណ៍មួយអំពីសម័យចតុមុខ ដោយផ្ដោតលើ**សាសនា** និង**ជំនឿ**។

មានព្រឹត្តិការណ៍មួយគួរឱ្យឆ្ងល់ និងគិតឱ្យច្រើន សម្រាប់មនុស្សសម័យនេះ។ ព្រឹត្តិការណ៍នោះ គឺការផ្លាស់ប្ដូរពីពុទ្ធសាសនាមហាយាន មកពុទ្ធសាសនាថេរវាទ។ ក្នុងកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជាប្រវត្តិវិទ្យា ថ្នាក់ទី៨ អនុម័តដោយរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា ក្នុងឆ្នាំ២០១៨ មានសំណួរត្រិះរិះមួយ។ *"តើការផ្លាស់ប្ដូរពីពុទ្ធសាសនាមហាយាន មកពុទ្ធសាសនាថេរវាទបានធ្វើឱ្យកម្ពុជាមានការផ្លាស់ប្ដូរយ៉ាងដូចម្ដេចខ្លះ?"*

ប្រសិនបើអានរកពាក្យសំខាន់ៗ យើងរកឃើញពាក្យ និងឃ្លាសម្រាប់ឱ្យសិស្សគិត និងរៀនឱ្យស៊ីជម្រៅ និងពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែប មានច្រើន ដូចជា ៖

- សាសនា
- ពុទ្ធសាសនា
- ការប្រែប្រួលស្ថានភាព
- ពុទ្ធសាសនាថេរវាទ
- ពុទ្ធសាសនាមហាយាន
- ការផ្លាស់ប្ដូរ

ដកស្រង់ចេញពីសំណួរមួយនេះ តើអ្នកគ្រូ លោកគ្រូ និងសិស្សគួរធ្វើអ្វីបន្តទៀត ដើម្បីពង្រីកការគិត និងឆ្ងល់ ការឆ្ងល់និងគិត ឬដឹកនាំការរៀនឱ្យស៊ីជម្រៅ និងដឹកនាំសិស្សឱ្យពង្រីកវិសាលភាពនៃគំនិត ដោយកុំគិតថា សិស្សថ្នាក់ទី៨ ក្មេងពេក រៀនជ្រៅពេកពិបាកយល់។

ការរកបញ្ញត្តិ និងប្រធានបទចេញពីសំណួរនេះ ជារឿងសំខាន់សម្រាប់ដឹកនាំសិស្សឱ្យរៀន និងអភិវឌ្ឍសមត្ថភាពគិតដូចអ្នកវិទ្យាសាស្ត្រ។ សំអាងលើ

សំណួរនេះ តើគ្រូបង្រៀន និងសិស្សរកបញ្ញត្តិ និងប្រធានបទសម្រាប់ការរៀនមានអ្វីខ្លះ? សូមអ្នកគ្រូ លោកគ្រូគិតបន្ត និងកំណត់ពាក្យ និងឃ្លា៦ខាងលើ ដើម្បីយល់ច្បាស់អំពីប្រធានបទ ឬ បញ្ញត្តិ។

### ១៤.៣.៧ កម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ

ទម្រង់នៃការតាក់តែងកម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ ដែលយកគោលការណ៍ នៃរបកគំហើញនៃស្រាវជ្រាវរបស់ Erickson L. H (2008), Giddens & Brady (2007), Erickson, Lanning, & French (2017), Erickson & Lanning (2014), Stern, Lauriault, & Ferraro (2018), និង Ignatavicius (2017) ផ្តោតលើវិមាត្របីដើម្បីបង្កើតរចនាសម្ព័ន្ធនៃពុទ្ធិ ៖

- បញ្ញត្តិ
- បំណិន និងដំណើរការ
- អង្គហេតុ

រូបភាព២៧. បញ្ញត្តិ និងដំណើរការរៀន




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

ចេតនានៃការរៀនរបស់មនុស្ស គឺអភិវឌ្ឍពុទ្ធិឱ្យដល់កម្រិតបញ្ញា ពុំមែនត្រឹមចាំអង្គហេតុ និងដឹងប៉ុនណោះទេ។ សិស្សត្រូវយកផលពីការរៀនទៅប្រតិបត្តិក្នុងការរៀនបន្ត ធ្វើការ និងជីវភាពរស់នៅ ក្នុងគ្រប់បរិបទ លក្ខខណ្ឌ និងកាល។ របកគំហើញនៃការស្រាវជ្រាវរបស់ Kluwer (2017), Ignatavicius (2017) និងGiddens & Brady (2007) ក្នុងវិស័យពេទ្យ ផ្អែកគិលានុបដ្ឋាន ពន្យល់អំពីប្រយោជន៍នៃការរៀនតាមកម្មវិធីសិក្សាបញ្ញត្តិ។ របកគំហើញនៃការស្រាវជ្រាវនេះពន្យល់ថា ការដឹកនាំនិស្សិតពេទ្យឱ្យរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ គឺបានផ្តល់ឱកាសឱ្យសិស្សអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង សម្រាប់ប្រើការក្នុងការងារ រៀនបន្ត និងរស់នៅ។

រូបភាព២៨. ការយល់ទូទៅ និងសិក្សាបញ្ញត្តិ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

ការស្រាវជ្រាវរបស់ Kluwer (2017), Ignatavicius (2017) និងGiddens & Brady (2007) ពន្យល់ហេតុផលច្រើនទៀតដើម្បីដឹកនាំសិស្សឱ្យរៀនតាមសិក្សាប

ញ្ញត្តិ។ និស្សិតយល់ស៊ីជម្រៅលើគោលគំនិត គំនិតធំ គំនិតទូទៅ និងបញ្ញត្តិនៃមេរៀនចេញពីសាលា ដោយភ្ជាប់ជាមួយនឹងបទពិសោធក្នុងជីវភាពប្រចាំថ្ងៃ។

លើសពីនេះទៀត និស្សិតមានសមត្ថភាពភ្ជាប់បញ្ញត្តិរៀនពីសាលាជាមួយនឹងការងារជាក់ស្តែងក្នុងវិស័យពេទ្យ។ Ignatavicius (2017), Giddens & Brady (2007), Kluwer (2017) Erickson L. H (2008), Erickson, Lanning, & French (2017), Erickson & Lanning (2014), និងStern, Lauriault, & Ferraro (2018) បញ្ជាក់បន្ថែមថា ការដឹកនាំសិស្សឱ្យរៀនតាមកម្មវិធីសិក្សាផ្តោតលើបញ្ញត្តិ សិស្សពេញចិត្តចូលរួមក្នុងដំណើរការរៀន ដោយសារ៖

១. សិស្សបន្ថយការរៀនបែបចូលត្រចៀកស្តាំ ចេញត្រចៀកឆ្វេង
២. សិស្សប្រើព័ត៌មានសម្បូរបែបពីច្រើនប្រភព និងគួរឱ្យទុកចិត្ត
៤. សិស្សបានអភិវឌ្ឍបំណិនច្រើនយ៉ាង គិតកម្រិតខ្ពស់ ស្រាយបញ្ហា
៥. សិស្សអភិវឌ្ឍសមត្ថភាពគិតដូចអ្នកវិទ្យាសាស្ត្រ ដោយប្រើបញ្ញត្តិ
៦. សិស្សមានសេរីភាព និងឯករាជ្យក្នុងដំណើរការរៀន
៧. សិស្សអភិវឌ្ឍសមត្ថភាពច្នៃប្រឌិត។
៨. សិស្សក្លាយជាបុគ្គលពូកែឆ្ងល់ និងសួរសំណួរ
៩. សិស្សក្លាយជាបុគ្គលមានជម្រើសនៃការស្រាយបញ្ហា

ចេតនារបស់អ្នករៀន មាតាបិតា និងនិយោជក ចង់បានមនុស្សដែលអភិវឌ្ឍសមត្ថភាពគិតកម្រិតខ្ពស់។ ផ្តល់យោបល់ថា ការអនុវត្តកម្មវិធីសិក្សាតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ ជួយសិស្សឱ្យអភិវឌ្ឍសមត្ថភាពគិតដូចអ្នកវិទ្យាសាស្ត្រ។

ផលរំពឹងទទួលបានពីការរៀន មិនត្រឹមតែឱ្យសិស្សទទួលព័ត៌មានពីគ្រូបង្រៀន ពីមេរៀន និងបំណិនធ្វើកើតតាមកិរិយាសព្ទ ក្នុងតារាងវិជ្ជានុក្រមប្លូម (BLOOM) ទេ។ Tyler (1949) ពន្យល់ថា ការរៀបចំកម្មវិធីសិក្សា ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់លើរចនាសម្ព័ន្ធនៃពុទ្ធិ និងបំពេញតម្រូវការរបស់អ្នកសិក្សា និងឆ្លើយតបនឹងបម្រែបម្រួលនៃតម្រូវការរបស់សង្គម។

ឆ្លើយតបនឹងយោបល់របស់ Tyler (1949) Erickson, Lanning & French (2017) បានផ្តល់និយមន័យចំពោះរចនាសម្ព័ន្ធនៃពុទ្ធិ គួរពិចារណា។ ពុទ្ធិមាន

រចនាសម្ព័ន្ធមួយ ដោយភ្ជាប់ពីប្រធានបទ អង្គហេតុទៅបញ្ញត្តិ គំនិតទូទៅ ឬការយល់ទូទៅ។ ប្រធានបទ និងអង្គហេតុជាធាតុផ្សំផ្ទុំរបស់បញ្ញត្តិ ប្រធានបទ និងការយល់ទូទៅ។ បញ្ញត្តិ ប្រធានបទ និងអង្គហេតុត្រូវបានប្រើជាភស្តុតាងសម្រាប់ពន្យល់សេចក្តីពិត ភាពត្រឹមត្រូវ និងច្បាស់លាស់នៃគំនិតទូទៅ។

Tyler (1949) ផ្តល់យោបល់ថា ការរៀបចំ ឬអភិវឌ្ឍកម្មវិធីសិក្សាសម្រាប់សិស្សរៀន ត្រូវផ្តោតការយកចិត្តទុកដាក់លើធាតុចម្បង៦ ៖

- ទស្សនវិទ្យាអប់រំ
- គោលបំណង និងគោលដៅរបស់កម្មវិធីសិក្សា
- វត្ថុបំណងនៃការដឹកនាំការរៀន
- លទ្ធផលរំពឹងទទួល
- វិភាគអំពីខ្លឹមសារ
- សកម្មភាពរៀន និងបទពិសោធរបស់សិស្ស។

ឆ្លើយតបនឹងធាតុចម្បងទាំង៦ អ្នកសរសេរកម្មវិធីសិក្សា អ្នកគ្រូ លោកគ្រូ ត្រូវត្រៀមឆ្លើយនឹងសំណួរមួយចំនួន ដូចជា ៖

១. តើដំណើរការរៀនរបស់សិស្សត្រូវសម្រេចបំណង និងគោលដៅអប់រំអ្វី?

- ស្វែងការពន្យល់ចំពោះសំណួរនេះ មានសំណួរមួយចោទសួរបន្តទៀត។ តើគោលបំណង និងគោលដៅអប់រំជាអ្វី និងត្រូវសរសេរយ៉ាងដូចម្តេច?
- បង្កើតបានគោលបំណង និងគោលដៅអប់រំ អ្នកអប់រំអាចសរសេរ ឬបង្កើតវត្ថុបំណងនៃកម្មវិធីសិក្សាបាន។ វត្ថុបំណងនៃកម្មវិធីសិក្សាជាឧបករណ៍ឱ្យអ្នកអប់រំបង្កើតកម្មវិធីសិក្សា ដោយផ្តោតលើខ្លឹមសារ ឬប្រធានបទ បញ្ញត្តិ បំណិន លទ្ធផលសិក្សា យុទ្ធវិធីដឹកនាំការរៀន និងវិធីសាស្ត្រវាយតម្លៃលទ្ធផលនៃការរៀនរបស់សិស្ស។
- ការសរសេរវត្ថុបំណង នៃកម្មវិធីសិក្សា ត្រូវផ្តោតលើលទ្ធផលសិក្សាដែលសិស្សនឹងទទួលបាន។ លទ្ធផលសិក្សាត្រូវតែវាស់វែងបាន ដោយប្រើឧបករណ៍វាយតម្លៃជាចាំបាច់។ លទ្ធផលសិក្សាត្រូវតែបញ្ជាក់អំពីការផ្លាស់ប្តូរទង្វើ ឬឥរិយាបថរបស់សិស្ស។ ការផ្លាស់ប្តូរទង្វើ ឬឥរិយាបថ

សំដៅដល់ការប្តូរចិត្ត វាចា និងសកម្មភាព។ ការសរសេរលទ្ធផលសិក្សាគួរប្រើកិរិយាសព្ទស្រង់ចេញពីតារាងវិជ្ជានុក្រមប្លូម (BLOOM)។

២. តើការអនុវត្តកម្មវិធីសិក្សានៅកម្រិតថ្នាក់រៀន ផ្តល់បទពិសោធអប់រំអ្វីខ្លះដល់សិស្ស សម្រាប់យកទៅប្រើការក្នុងការងារ រស់នៅ និងរៀនបន្ត?

៣. តើបទពិសោធអប់រំប្រភេទអ្វីខ្លះដែលសិស្សទទួលបានពីការរៀន តាមរយៈការអនុវត្តកម្មវិធីសិក្សា?

៤. តើការអនុវត្តកម្មវិធីសិក្សា សម្រេចគោលបំណង និងគោលដៅអប់រំបានកម្រិតណា?

៥. ដំណើរការដឹកនាំការរៀន ឬបទពិសោធបានពីសាលារៀន ត្រូវចាត់ចែងឱ្យសិស្សអនុវត្ត ក្នុងជីវភាព ការងារ និងរៀនបន្តដោយរបៀបណា?

៦. តើអ្នកអប់រំប្រើមធ្យោបាយ និងវិធីសាស្ត្រអ្វី ដើម្បីវាយតម្លៃ អំពីការសម្រេចគោលបំណង និងគោលដៅអប់រំ និងវត្ថុបំណងនៃកម្មវិធីសិក្សា?

ការសរសេរកម្មវិធីសិក្សា ដោយផ្តោតការយកចិត្តទុកដាក់លើបញ្ញត្តិសំដៅបើកចំហ និងចែករំលែកគំនិត ដើម្បីរៀនស៊ីជម្រៅ និងពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែប។ ការពង្រីកវិសាលភាពនៃគំនិត និងបន្ថែមជម្រៅនៃការគិត សំដៅញែកគំនិតទូទៅ គោលគំនិត គំនិតធំ និងប្រធានបទ ឱ្យល្អិតល្អន់ ដោយប្រើអង្គហេតុជាភស្តុតាង។

បញ្ញត្តិសម្រាប់សរសេរក្នុងកម្មវិធីសិក្សា អាចភ្ជាប់នឹងតម្រូវការរបស់អ្នកសិក្សាគ្រប់កាល បរិបទ និងលក្ខខណ្ឌ។ បញ្ញត្តិក្នុងមេរៀននៃមុខវិជ្ជាមួយអាចភ្ជាប់ជាមួយបញ្ញត្តិនៃមុខវិជ្ជាផ្សេង។ កម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ ពុំ មានចេតនា ត្រឹមផ្តល់អង្គហេតុឱ្យសិស្ស ទន្ទេញចាំរត់មាត់ទេ។ កម្មវិធីសិក្សាតាមគោលវិធីសិក្សា



បញ្ញត្តិ សំដៅនាំសិស្ស ឱ្យប្រើអង្គហេតុជាឧបករណ៍ ឬភស្តុតាង សម្រាប់បញ្ជាក់ភាពត្រឹមត្រូវ ច្បាស់លាស់ និងពិតនៃបញ្ញត្តិ គំនិតទូទៅ និងគោលគំនិត។

ដំណើរការរៀន ដោយប្រើកម្មវិធីសិក្សា តាមគោលវិធីសិក្សាបញ្ញត្តិ ប្រៀបប្រដូចនឹងការឱ្យសិស្សមួយក្រុម និងគ្រូបង្រៀន បើកកាបូបមួយរួមគ្នា។ សិស្សរកមើលវត្ថុធ្លាប់ស្គាល់ និងមិនធ្លាប់ស្គាល់? វត្ថុនីមួយៗមានប្រយោជន៍អ្វីខ្លះតាមកាល បរិបទ និងលក្ខខណ្ឌ។

មុនបើកកាបូបនេះ សិស្សអាចគិត ឆ្ងល់ បង្កើតសំណួរ និងសួរគ្នា ដើម្បីបើកផ្លូវគិត ឬភាសាសាមញ្ញហៅថា ទាយ ឬសន្និដ្ឋាន។ តើសិស្ស និងគ្រូបង្រៀនត្រូវធ្វើយ៉ាងដូចម្ដេច នៅពេលបើកកាបូបរួច ឃើញវត្ថុមិនដែលស្គាល់ ឬទាយខុសទាំងអស់? បើកមក គ្រូបង្រៀន និងសិស្សឃើញវត្ថុអត់ប្រយោជន៍សម្រាប់បុគ្គលម្នាក់ ឬពីរនាក់ពេលដែលមិនស្គាល់? តើអាចមានប្រយោជន៍សម្រាប់មនុស្សដទៃឬទេ?

ដូច្នេះ សេចក្ដីសន្និដ្ឋានមួយអាចទាញបានថា ការរៀបចំកម្មវិធីសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ សំដៅបន្ថែមជម្រៅនៃការគិត និងពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែប។ តាមរយៈសកម្មភាពបើកកាបូប យើងសង្កេតឃើញថា ក្នុងកាបូបមានវត្ថុច្រើនណាស់។ ដូច្នេះ ក្នុងដំណើរការរៀន គឺមានគំនិតទូទៅ គោលគំនិត គំនិតធំ ប្រធានបទ ឬបញ្ញត្តិ និងអង្គហេតុ យ៉ាងច្រើនសម្បូរបែបណាស់។

ដំណើរការរៀន និងដឹកនាំការរៀនតាមខ្លឹមសារមេរៀន សំដៅឱ្យសិស្សទន្ទេញរត់មាត់ ចាំខ្លឹមសារមេរៀន។ ខ្លឹមសារមេរៀនមាន អង្គហេតុ ឧទាហរណ៍ ព្រឹត្តិការណ៍ តួលេខ រូបមន្ត គំនិតទូទៅ ទ្រឹស្ដី ព័ត៌មាន និងទិន្នន័យ (Erickson & Lanning, 2014; Stern, Lauriault, & Ferraro, 2018; Erickson, Lanning, & French, 2017)។ ការរៀនទន្ទេញចាំរត់មាត់ គឺសម្រាប់ឆ្លើយសំណួរកម្រិតទាបបំពេញតម្រូវការប្រឡងតែប៉ុណ្ណោះ។ ការរៀនតាមខ្លឹមសារ សិស្សមានសមត្ថភាពប្រើបំណិនតាមកិរិយាសព្ទសកម្ម កំណត់ក្នុងតារាងវិជ្ជានុក្រមប្លូម (BLOOM, ១៩៥៧) (Stern, Lauriault, & Ferraro, 2018; Kluwer, 2017; Erickson & Lanning, 2014)។

ដំណើរការរៀន និងការដឹកនាំការរៀនតាមគោលវិធីសិក្សាបញ្ញត្តិ សំដៅឱ្យសិស្ស ១. ស្គាល់ ២. យល់ និង៣. ធ្វើ (Erickson, Lanning, & French, 2017)។

រូបភាព២៩. ដំណើរការរៀនតាមសិក្សាបញ្ញត្តិ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

- **សិស្សស្គាល់** សំដៅឱ្យសិស្សប្រើបទពិសោធ និងចំណេះដឹងមានស្រាប់
- **សិស្សស្គាល់**សំដៅឱ្យសិស្សភ្ជាប់ជាមួយបញ្ញត្តិ ប្រធានបទ គំនិតទូទៅ គោលគំនិត គំនិតធំ ទ្រឹស្តី ឬគោលការណ៍រៀនពីសាលាជាមួយបទពិសោធ ឬការធ្លាប់ស្គាល់
- **សិស្សយល់** សំដៅឱ្យសិស្សពង្រីកសេចក្តីយល់ស៊ីជម្រៅលើគំនិតទូទៅ គោលគំនិត ឬគំនិតធំ ទ្រឹស្តី ឬគោលការណ៍ និងបញ្ញត្តិ។
- **សិស្សយល់** សំដៅដល់ការបំបែក និងញែកធាតុ ឬផ្គុំធាតុនៃបញ្ញត្តិ ប្រធានបទ គំនិតទូទៅ គោលគំនិត គំនិតធំ គោលការណ៍ ឬទ្រឹស្តី។
- **សិស្សធ្វើ ឬប្រតិបត្តិ** សំដៅឱ្យសិស្សភ្ជាប់បញ្ញត្តិរៀនពីសៀវភៅ ពីគ្រូបង្រៀន និងសាលារៀន ជាមួយនឹងតម្រូវការប្រចាំថ្ងៃ ធ្វើការ និងរៀនបន្តក្នុងគ្រប់បរិបទ លក្ខខណ្ឌ និងកាល។

សិស្សយកបញ្ញត្តិមួយទៅអនុវត្តក្នុងជីវភាពប្រចាំថ្ងៃ ការងារ និងរៀនបន្ត សិស្សត្រូវពឹងអាស្រ័យលើការយល់ស៊ីជម្រៅ។ ការយល់ស៊ីជម្រៅ សំដៅដល់

សមត្ថភាពសិស្ស ក្នុងការពន្យល់តាមអនុមានរួម និងអនុមានញែក។ សិស្សយល់ស៊ីជម្រៅ សិស្សមានសមត្ថភាព៖

- សម្លឹងជ្រុងផ្សេងនៃបញ្ញត្តិ ប្រធានបទ អង្គហេតុ និងគំនិតទូទៅ
- ផ្ដល់ហេតុផលដើម្បីបញ្ជាក់ភាពពិត ត្រឹមត្រូវ និងច្បាស់លាស់
- ឆ្លល់បន្តលើអង្គហេតុ ប្រធានបទ បញ្ញត្តិ និងគំនិតទូទៅ
- ភ្ជាប់ជាមួយការដឹង ឬបទពិសោធ
- ស្រាយភាពស្មុគស្មាញមកសាមញ្ញនៃគំនិតទូទៅ
- បង្ហាញចំណុចស្នូល ឬភាពចាំបាច់នៃបញ្ញត្តិ និងអង្គហេតុ
- ពន្យល់ដោយមានឧទាហរណ៍ ឬភស្តុតាង
- ពិពណ៌នាតាមជ្រុង និងលក្ខខណ្ឌផ្សេង។

រូបភាព៣០. យល់បញ្ញត្តិ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

ចូរលោកគ្រូ អ្នកគ្រូ ចំណាយពេល៥៩វិនាទីទៀត! ចូរលោកគ្រូ អ្នកគ្រូរំឭកអំពីដំណើរការរៀនពិតប្រាកដរបស់យើងកន្លងមក ទៅលើខ្លឹមសារ ឬបញ្ញត្តិអ្វីមួយ។ ការរៀនពិតប្រាកដ ជាដំណើរការគិត រហូតដល់ចំណុចមួយ គឺស្វែងការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់ អំពីខ្លឹមសារ ឬបញ្ញត្តិនោះ ដោយឯករាជ្យលើការដឹងដំបូង។ តើពិតមែនឬទេ? ដំណើរការគិតរបស់យើង ផ្ដើមពី ៖

- ដឹង ឬស្គាល់
- យល់
- ធ្វើ (ក្នុងគ្រប់បរិបទ លក្ខខណ្ឌ និងកាល)

មេរៀនប្រវត្តិវិទ្យាថ្នាក់ទី៨ អំពីសម័យលង្វែកផ្ដោតលើ **សាមគ្គីភាព**។ សូមអ្នកគ្រូ លោកគ្រូសាកល្បងអនុវត្តសកម្មភាពដឹកនាំការរៀនមួយ ដោយប្រើកម្មវិធីសិក្សាតាមបញ្ញត្តិ! តើសិស្សពេញចិត្ត និងសប្បាយចិត្តរៀន និងចូលរួមពេញលេញ ក្នុងសកម្មភាពថ្នាក់រៀនឬទេ?

ឧទាហរណ៍ បញ្ញត្តិសម្រាប់ដឹកនាំការរៀនអំពីសម័យលង្វែក ផ្ដោតការយកចិត្តទុកដាក់លើ**សាមគ្គីភាព** រវាងព្រះបាទចន្ទរាជានិងបរមេន្ទរាជាក្នុងការស្ដារប្រទេស។ បញ្ញត្តិ **សាមគ្គីភាព** ក៏អាចភ្ជាប់នឹងមេរៀនផ្សេង ក្នុងមុខវិជ្ជាផ្សេង ដូចជា អក្សរសាស្ត្រខ្មែរ សីលធម៌ ពលរដ្ឋវិជ្ជា មុខវិជ្ជាផ្សេងៗ។ បញ្ញត្តិសាមគ្គីក៏អាចភ្ជាប់ជាមួយមេរៀនអំពីសម័យរដ្ឋកម្ពុជា និយាយអំពីក្រុមសាមគ្គី។ បញ្ញត្តិសាមគ្គីភាពក៏អាចភ្ជាប់ជាមួយទម្លាប់សាគ្គីភាពរវាងសិស្ស និងសិស្សក្នុងថ្នាក់។ បញ្ញត្តិសាមគ្គីភាព ក៏អាចកើតឡើងរវាងសមាជិកគ្រួសារ មនុស្សក្នុងសហគមន៍ និងសហការីក្នុងកន្លែងធ្វើការដែរ។

គ្រូបង្រៀនអាចឆ្ងល់ថា រៀនតាមកម្មវិធីសិក្សាបញ្ញត្តិ អាចបាត់រសជាតិនៃប្រវត្តិវិទ្យាទេដឹង។ ការៀន និងដឹកនាំការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិនេះ គឺគ្រូបង្រៀនៅតែប្រើខ្លឹមសារមេរៀន ដូចជា កាលប្រវត្តិ ឈ្មោះក្សត្រ ទីកន្លែង និងព្រឹត្តិការណ៍ ក្នុងសៀវភៅសិក្សាប្រវត្តិវិទ្យា និងឯកសារពីប្រភពផ្សេង ផ្នែកប្រវត្តិសាស្ត្រ ដើម្បីពន្យល់ភាពពិត និងត្រឹមត្រូវនៃបញ្ញត្តិ **សាមគ្គីភាព** ដដែល។

ដំណើរការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ អ្នកគ្រូ លោកគ្រូអាចផ្តើមដោយសំណួរនាំមុខមួយចំនួន។ ឧទាហរណ៍៖

- ក្នុងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសម័យលង្វែក តើសាមគ្គីភាពរវាងព្រះបាទចន្ទរាជា និងបរមេន្ទរាជា ផ្តល់ប្រយោជន៍អ្វីខ្លះដល់ការស្តារប្រទេសជាតិ និងជួយការពារប្រយោជន៍ប្រជាជន?
- តើសាមគ្គីគ្នារវាងព្រះបាទចន្ទរាជា និងបរមេន្ទរាជា កើតឡើងពេលណា និងនៅកន្លែងណា ឬក្នុងព្រឹត្តិការណ៍អ្វីខ្លះ?

ការដឹកនាំការរៀនដោយប្រើកម្មវិធីសិក្សាតាមបញ្ញត្តិ សិស្សបានដឹងមុនអំពីប្រយោជន៍នឹងទទួលបាន។ សិស្សនឹងយកបញ្ញត្តិរៀនពីសៀវភៅ និងពីថ្នាក់រៀនទៅប្រតិបត្តិក្នុងជីវភាពប្រចាំថ្ងៃ រៀនបន្ត និងការងារ។ មានរបកគំហើញនៃស្រាវជ្រាវមួយចំនួន បញ្ជាក់ថា ការតាក់តែងលំនាំដឹកនាំការរៀន ឬកិច្ចតែងការតាមសិក្សាបញ្ញត្តិ ជួយគ្រូបង្រៀន និងសិស្សឱ្យអភិវឌ្ឍគុណសម្បទាសម្បូរបែប រួមទាំងបំណិនគិតកម្រិតខ្ពស់ និងភ្ជាប់បញ្ញត្តិទទួលបានពីដំណើរការរៀនជាមួយនឹងជីវភាពប្រចាំថ្ងៃ ការរៀនបន្ត និងការងារ (Stern, Lauriault, & Ferraro, 2018; Erickson, Lanning, & French, 2017; Giddens, Wright, & Gray, 2012; Ignatavicius, 2017; Mathematics Learning Study Committee, 2001; Morey, 2016; Erickson L. H., 2008; Giddens & Brady, 2007)។

ដំណើរការរៀនតាមកម្មវិធីសិក្សាបញ្ញត្តិ សិស្សមានលទ្ធភាពប្រើវិជ្ជាបានពីមេរៀន ជាមួយនឹងបទពិសោធជីវិត ភ្ជាប់ជាមួយចំណេះដឹងបានពីមេរៀននៃមុខវិជ្ជាផ្សេង និងពីជីវិតប្រចាំថ្ងៃ។ ដំណើរការរៀនដោយប្រើកម្មវិធីសិក្សាតាមបញ្ញត្តិ សិស្សអភិវឌ្ឍបំណិនរកព័ត៌មាន អង្គហេតុ និងភស្តុតាង បំណិនគិត តាមវិជ្ជានុក្រមប្លូម (BLOOM) រហូតដល់ម្រិតបង្កើតថ្មី (Stern, Lauriault, & Ferraro, 2018; Erickson, Lanning, & French, 2017; Giddens, Wright, & Gray, 2012; Ignatavicius, 2017; Mathematics Learning Study Committee, 2001; Morey, 2016; Erickson L. H., 2008; Giddens & Brady, 2007)។

ដំណើរការរៀន និងដឹកនាំការរៀនតាមកម្មវិធីសិក្សាតាមបញ្ញត្តិ សំដៅបង្កបរិយាកាសថ្នាក់រៀនឱ្យសកម្ម សម្បូរសិស្សគិត ឆ្ងល់ និងសួរសំណួរ។ ដូច្នេះសិស្ស និងគ្រូបង្រៀន ប្រើកម្លាំងនៃចិត្តឱ្យពង្រីកវិសាលភាពនៃគំនិត បន្ថែមជម្រៅនៃការរគិត និងអភិវឌ្ឍបំណិនគិតកម្រិតខ្ពស់។ លើសពីនេះទៀត ការដឹកនាំការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិជួយសិស្សឱ្យអភិវឌ្ឍគុណសម្បទាសតវត្សរ៍ទី២១ គុណសម្បទាពលរដ្ឋសកល គុណតម្លៃ និងចរណាមនុស្ស តាមរយៈសកម្មភាពរបស់សិស្ស។ សកម្មភាពសិស្សត្រូវចាប់ផ្ដើមពីឆ្ងល់ គិត បង្កើតសំណួរ សួរសំណួរ និងស្វែងសេចក្ដីពន្យល់។

ដំណើរការរៀន និងដឹកនាំការរៀនតាមកម្មវិធីសិក្សាតាមបញ្ញត្តិ គឺនាំសិស្សឱ្យគិតដូចអ្នកវិទ្យាសាស្ត្រ (Stern, Lauriault, & Ferraro, 2018; Giddens, Wright, & Gray, 2012; Erickson L. H., 2008; Erickson, Lanning, & French, 2017; Erickson & Lanning, 2014)។ គ្រូបង្រៀនដឹកនាំសិស្សឱ្យរៀនតាមកម្មវិធីសិក្សាបញ្ញត្តិ សំដៅប្ដូរលំនាំនៃការរៀនបែបទន្ទេញចាំមាត់ រង់ចាំទទួលព័ត៌មានពីគ្រូបង្រៀន និងសៀវភៅសិក្សាគោលទៅជាការយល់បរិបទ និងឆ្លើយតបនឹងតម្រូវការរបស់សិស្ស (Giddens, Wright, & Gray, 2012; Erickson, Lanning, & French, 2017; Ignatavicius, 2017; Stern, Lauriault, & Ferraro, 2018)។

## ១៥. ប្រតិបត្តិសិក្សាបញ្ញត្តិ

> ការរៀនតាមសិក្សាបញ្ញត្តិ ជាការតម្រៀបអង្គហេតុ ឬព័ត៌មានឱ្យមានរចនាសម្ព័ន្ធ។ ព័ត៌មាន ឬអង្គហេតុមានរចនាសម្ព័ន្ធ ជាគ្រឹះនៃដំណើរការរៀនដើម្បីអភិវឌ្ឍបំណិនគិត ឆ្ងល់ សួរសំណួរ ដូចអ្នកវិទ្យាសាស្ត្រ។

ការរៀន និងដឹកនាំការរៀនតាមសិក្សាបញ្ញត្តិ និងបុច្ចនសិក្សាបង្កក្ដីបារម្ភច្រើនចំពោះគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកដឹកនាំប្រព័ន្ធអប់រំ។ ការបារម្ភមានដូចជា គ្រូបង្រៀនត្រូវការស្រាវជ្រាវច្រើន ត្រូវការឯកសារយោងច្រើន ត្រូវការអានច្រើន គិតច្រើន និងមានចិត្តទូលាយរៀនពីសិស្ស និងរៀនជាមួយសិស្ស។ល។

គ្រូបង្រៀន អ្នកអប់រំ និងអ្នកដឹកនាំសាលារៀននៅកម្ពុជា ក៏ប្រឈមដូចក្ដីបារម្ភនេះ។ការបារម្ភអាចកើតឡើងដោយសារ គុណវុឌ្ឍិគ្រូបង្រៀនកម្ពុជាមានកម្រិតទាប និងឥរិយាបថមិនសូវចូលចិត្តអានច្រើន (Education Research Council, 2018)។ កម្ពុជាពុំមានឯកសារយោងច្រើនជាខេមរភាសា។ បណ្ណាល័យតាមសាលារៀនភាគច្រើនមិនដំណើរការ។ កម្មវិធីសិក្សា និងសៀវភៅសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា កំពុងអនុវត្តតាមសាលារៀន ពុំមានកំណត់ ឬពន្យល់អំពីបញ្ញត្តិ និងសិក្សាបញ្ញត្តិទេ។ គ្រូបង្រៀននៅតាមសាលារៀនពុំដែលមានឱកាសចូលរៀន ឬចូលវគ្គវិក្រឹតការ ឬសុក្រឹតការអំពីគោលវិធីសិក្សាបញ្ញត្តិ និងបុច្ឆនសិក្សាដែរ។

ប្រសិនបើយកការបារម្ភនេះមកគិត តើប្រព័ន្ធសាលារៀនកម្ពុជាត្រូវដើរផ្លូវណា? មិនចាប់ផ្ដើមដើរក្នុងជំហានទី១នៃផ្លូវថ្មី គឺឈរទីដដែល។ ដូច្នេះ យើងជាគ្រូបង្រៀនត្រូវចាប់ផ្ដើមមុនគេ ដើម្បីផ្លាស់ប្ដូរសកម្មភាព ពីការគិត រហូតដល់ការប្រព្រឹត្តិ។ លទ្ធផលនៃការផ្លាស់ប្ដូរនេះនឹងបំពាក់គុណសម្បទាពលរដ្ឋពូកែ ១. វិជ្ជា, ២. ចរណៈ, ៣. បំណិនសតវត្សរ៍ទី២១, ៤. ពលរដ្ឋសកល ដល់សិស្ស សម្រាប់រួមចំណែកដល់ចីរភាពអភិវឌ្ឍន៍ និងសន្តិភាព។

រៀនតាមគោលវិធីសិក្សាបញ្ញត្តិ និងជាមួយគ្រូបង្រៀនប្រើវិធីសាស្ត្រគរុកោសល្យតាមសិក្សាបញ្ញត្តិ សិស្សក្លាយជាពលរដ្ឋពេញលេញ ឬពលរដ្ឋពូកែ។ សិស្សរៀនចប់ចេញពីសាលារៀនប្រកបដោយគុណភាព ពោរពេញដោយវិជ្ជា និងចរណៈ។ សិស្សនឹងចេញទៅបម្រើការងារ ក្នុងគ្រប់វិស័យឧស្សាហកម្មដោយមោទនភាព។ ដូច្នេះ សិស្សនឹងក្លាយជាពលរដ្ឋសកម្ម និងចូលរួមលើកតម្កើងគុណតម្លៃសង្គម។ សិស្សនឹងបំពេញការងារប្រកបដោយការទទួលខុសត្រូវខ្ពស់ និងមានគណនេយ្យភាពចំពោះផែនដី និងមនុស្សជាតិ។ កម្ពុជានឹងទៅដល់ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅមុន ឬត្រឹមឆ្នាំ២០៣០ និងប្រទេសចំណូលខ្ពស់ នៅមុន ឬត្រឹមឆ្នាំ២០៥០។

១៥.១ ឧទាហរណ៍បញ្ញត្តិ

| **ការយល់ទូទៅ ៖**<br>**គំនិតទូទៅ គោលគំនិត ឬគំនិតធំ** | **បញ្ញត្តិ** | **ប្រធានបទ** | **អង្គហេតុ** |
|---|---|---|---|
| ព្រះបាទមហិន្ទ្រវរ្ម័ន (៦០០-៦១៥ នៃ គ.ស.) ក្នុងសម័យចេនឡា បានបន្តនយោបាយពង្រីកទឹកដី ពីព្រះរាមរបស់ព្រះអង្គ គឺព្រះបាទភវវរ្ម័នទី១។ | **ទីកន្លែង** | ទឹកដី<br>ភូមិសាស្ត្រ | បុរីរម្យ<br>(ថៃបច្ចុប្បន្ន)<br>សុរិន្ទ<br>(ថៃបច្ចុប្បន្ន)<br>ភូល្វោន<br>(ឡាវបច្ចុប្បន្ន)<br>ទន្លេមូន<br>(ថៃបច្ចុប្បន្ន) |
| ព្រះបាទជ័យវរ្ម័នទី១ (៦៥៥-៦៨១ នៃ គ.ស.) បែងចែកអាណាចក្រជាតំបន់គ្រប់គ្រង ៖<br>▪ តំបន់វត្តភូ ៖ ចាប់ពីវត្តភូ ស្ទឹងត្រែង បាភ្នំ ព្រៃនគរ ក្រុងសម្ភុបុរៈ (ក្រចេះ) ..................................<br>▪ ខាងលិច ៖ ចាប់ពីអាងទន្លេមេគង្គ អង្គរបុរី បាត់ដំបង និងខាងជើងទន្លេសាប ...................... | **តំបន់** | ទឹកដី<br>ភូមិសាស្ត្រ | វត្តភូ<br>អាងទន្លេមេគង្គ<br>អង្គរបុរី<br>បាត់ដំបង<br>ខាងជើង<br>ទន្លេសាប<br>ស្ទឹងត្រែង<br>ព្រៃនគរ |
| នៅសតវត្សរ៍ទី៨ ចេនឡាទឹកលិច មានវិបត្តិធ្ងន់ធ្ងរ ៖<br>▪ សមន្តរដ្ឋតូចៗ ដណ្តើមទឹកដី និងអំណាចគ្នាកាន់កាប់។<br>▪ បរទេសមើលងាយ និងឆក់ឱកាសចូលមកត្រួតត្រាទឹកដីខ្មែរ។ | **នយោបាយក្នុងប្រទេស**<br>ជម្លោះ | សមន្តរដ្ឋ<br>អំណាច<br>ទឹកដី | វិបត្តិ<br>ដណ្តើមអំណាច |
| នយោបាយក្រៅប្រទេសរបស់អាណាចក្រចេនឡា គឺចងមិត្តភាពជាមួយប្រទេសធំៗ ដូចជា ចិន ឥណ្ឌា ចាម្ប៉ា តុងកឹង .................។ | **នយោបាយក្រៅប្រទេស** | គោលនយោបាយ<br>ទំនាក់ទំនង | ចិន<br>ឥណ្ឌា<br>ចាម្ប៉ា<br>តុងកឹង |

| **ការយល់ទូទៅ ៖<br>គំនិតទូទៅ គោលគំនិត ឬគំនិតធំ** | **បញ្ញត្តិ** | **ប្រធានបទ** | **អង្គហេតុ** |
|---|---|---|---|
| ទឹកដីនៃរដ្ឋចាម្ប៉ាលាតសន្ធឹងពីតំបន់ង៉ែតអាននៃប្រទេសវៀតណាមខាងជើង សណ្តូកបណ្តោយឆ្នេរសមុទ្រចិនរហូតដល់ប៊ីញថ្វាញ់ វៀតណាមខាងត្បូង។ រដ្ឋចាម្ប៉ាមានក្រុងធំៗបួន ៖ ក្រុងវិជ័យ (រាជធានី) ក្រុងឥន្ទ្របុរៈ ក្រុងបាណ្ឌុរង្គ និងក្រុងកៅឋារៈ។ | **តំបន់**<br>ទីកន្លែង | ភូមិសាស្ត្រ | ទំនប់ង៉ែតអាន<br>ប្រទេសវៀត<br>ណាម<br>ឆ្នេរសមុទ្រចិន |
| នៅពេលអរិយធម៌ឥណ្ឌាមិនទាន់ចូលមកដល់ ជនជាតិចាមគោរពជំនឿបែបធម្មជាតិ (ជីវចលនិយម) គឺគោរពដើមឈើ ភ្លៀង ខ្យល់ ទឹក ដីជាដើម។ លុះប្រមាណជាសតវត្សរ៍ទី៧ នៃគ.ស. ជនជាតិចាមធ្លាប់ទទួលឥទ្ធិពលព្រហ្មញ្ញសាសនា។ នៅប្រមាណសតវត្សរ៍ទី៨ នៃគ.ស. ពុទ្ធសាសនាក៏បានចូលមកបន្តទៀត។ ព្រះរាជាចាមស្វាគមន៍ព្រះពុទ្ធសាសនា ព្រមទាំងសាងបដិមាពីថ្ម និងមាសថែមទៀតផង។ | **ជំនឿ**<br>ការផ្លាស់ប្តូរ | សាសនា | គោរពធម្មជាតិ<br>ព្រហ្មញ្ញសាសនា<br>ព្រះពុទ្ធសាសនា<br>សាសនាអ៊ិស្លាម |
| រាជវង្សលី និងជិន ខិតខំពង្រឹងរដ្ឋអំណាចដោយបង្កើតអង្គការរដ្ឋបាលត្រួតពិនិត្យក្នុងគោលបំណងធ្វើឱ្យមានការឯកភាពជាគ្រឹះសង្គម ដើម្បីគ្រប់គ្រងកិច្ចការនយោបាយ សេដ្ឋកិច្ច និងវប្បធម៌។ ការរៀបចំនេះ គឺពួកអភិជន និងរាជវង្សានុវង្សមានតួនាទីសំខាន់ជាងគេ។ ពួកអ្នកអង្គម្ចាស់ជានាយករដ្ឋមន្ត្រី ជាមេបញ្ជាការកងទ័ព និងជាចៅហ្វាយខេត្ត ឬស្តេចត្រាញ់។ ពួកបុព្វជិតមានតួនាទីយ៉ាងសំខាន់ ក្នុង | **រដ្ឋាភិបាល**<br>តំបន់<br>ទីកន្លែង<br>ឥទ្ធិពល<br>ស្ថាប័នរដ្ឋ<br>នយោបាយ<br>ក្នុងប្រទេស | រដ្ឋបាល<br>ការគ្រប់គ្រង<br>ធនធានមនុស្ស<br>សេដ្ឋកិច្ច<br>វប្បធម៌<br>អង្គការរដ្ឋបាល<br>អំណាច | រាជវង្ស<br>អភិជន<br>បុព្វជិត<br>ឧបការី<br>ទីប្រឹក្សា<br>មន្ត្រីជ្រើសតាំង<br>ច្បាប់ |

| **ការយល់ទូទៅ ៖**<br>**គំនិតទូទៅ គោលគំនិត ឬគំនិតធំ** | **បញ្ញត្តិ** | **ប្រធានបទ** | **អង្គហេតុ** |
|---|---|---|---|
| ឋានៈជាឧបការី ឬទីប្រឹក្សារបស់ព្រះរាជា។ រាជការអនុវត្តការងារបែបការិយាធិបតេយ្យ។ ចំពោះមន្ត្រី ជ្រើសតាំងក្នុងចំណោមអ្នកចេះដឹងជ្រៅជ្រះខាងលទ្ធិខុងជឺ។ | | | |
| ក្រុងអយុធ្យាបានវាយដណ្តើមយកបណ្តាខេត្តខ្មែរ និងវាយលុកចូលក្រុងអង្គរជាច្រើនលើកច្រើនសា ព្រមទាំងប្រមូលយកវត្ថុមានតម្លៃ កៀរប្រជាជននិងអ្នកប្រាជ្ញបណ្ឌិតខ្មែរ យកទៅប្រទេសខ្លួន ថែមទាំងបានកម្ទេចសំណង់ប្រាសាទ និងប្រព័ន្ធធារាសាស្ត្រជុំវិញអង្គរឱ្យខ្ទេចខ្ទី ស្ទើរគ្មានសល់។ | **ទីកន្លែង**<br>សង្គ្រាម<br>ជម្លោះ<br>វត្ថុបុរាណ | ប្រជាជន<br>វត្ថុមានតម្លៃ<br>អ្នកប្រាជ្ញ<br>ធារាសាស្ត្រ | ក្រុងអាយុធ្យា<br>ក្រុងអង្គរ<br>តំបន់ប្រាសាទ<br>អង្គរវត្ត<br>ប្រទេសសៀម |
| នៅខែមីនា ឆ្នាំ១៨៦៤ សន្ធិសញ្ញាខ្មែរ-បារាំងត្រូវបានផ្ញើត្រឡប់ពីបារាំងមកវិញ។ ផ្អែកលើសន្ធិសញ្ញានេះ លោកទេសាភិបាលបារាំងកូសាំងស៊ីនបានតម្រូវឱ្យព្រះចៅសៀម បញ្ជូនគ្រឿងសម្រាប់រាជ្យ មកក្រុងឧដុង្គ យ៉ាងឆាប់រហ័ស ហើយធ្វើពិធីអភិសេកព្រះបាទនរោត្តម នៅថ្ងៃទី៣ ខែមិថុនា ឆ្នាំ១៨៦៤។ ប្រទេសកម្ពុជាបានធ្លាក់ក្នុងកណ្តាប់ដៃបារាំងវិញ។ | **សន្ធិសញ្ញា**<br>ទេសាភិបាល<br>ទីកន្លែង<br>ពីធីអភិសេក<br>អាណានិគម<br>នយោបាយ | ការតែងតាំង<br>ការគ្រប់គ្រង<br>ឥទ្ធិពល<br>អំណាច | កូសាំងស៊ីន<br>ក្រុងឧដុង្គ<br>នរោត្តម<br>ទេសាភិបាល<br>ព្រះចៅសៀម |

១៥.២ លំនាំដឹកនាំការរៀនតាមសិក្សាបញ្ញត្តិ

អាជីពការងារបច្ចុប្បន្នមានច្រើនសម្បូរបែប។ អាជីពការងារមួយចំនួនអាចរលត់បាត់នៅថ្ងៃណាមួយ។ អាជីពការងារមួយចំនួនអាចជំនួសដោយបញ្ញាសិប្បនិម្មិត និងមនុស្សយន្ត។ ក្នុងពេលអនាគត អាជីពការងារថ្មីអាចកើតឡើងឱ្យឆ្លើយតបនឹងតម្រូវការ នៃយុគឧស្សាហកម្ម៤.០។ ដូច្នេះ មនុស្សជំនាន់ថ្មីត្រូវការបំណិន វិជ្ជា និងចរិយាច្រើនបែបច្រើនយ៉ាងខុសពីបច្ចុប្បន្ន។ បំណិន វិជ្ជា និងចរិយាដែលសិស្សទទួលបានពីការរៀន អាស្រ័យមួយផ្នែកធំលើគុណសម្បទារបស់គ្រូបង្រៀនពូកែ។ សិស្សក្នុងយុគឧស្សាហកម្ម៤.០ ត្រូវការបំណិន វិជ្ជា និងចរិយាដែលមនុស្សយន្ត ឬបញ្ញាសិប្បនិម្មិតពុំអាចជំនួសបាន។

ដើម្បីដឹកនាំសិស្សរៀនឱ្យទទួលបានបំណិន វិជ្ជា និងចរិយាសម្រាប់យុគឧស្សាហកម្ម៤.០ សៀវភៅនេះផ្ដុំវិធីសាស្ត្រដឹកនាំការរៀនពីរ ដើម្បីបង្កើតជាគោលវិធីមួយ សម្រាប់អនុវត្តក្នុងបរិបទអប់រំនៅកម្ពុជា និងសម្រាប់មុខវិជ្ជាប្រវត្តិវិទ្យា។ គោលវិធីនេះហៅ **សិក្សាបញ្ញត្តិ** ដូចរូបភាពខាងក្រោមពន្យល់។

រូបភាព៣១. សិក្សាបញ្ញត្តិជាបង្គុំនៃបញ្ញត្តិ និងបុច្ឆនសិក្សា




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

តើលោកគ្រូ អ្នកគ្រូគិតថា ខ្លឹមសារមេរៀនក្នុងសៀវភៅសិក្សាគោល និងចំណេះដឹងរបស់គ្រូបង្រៀន អាចអត់មានប្រសិទ្ធភាពប្រើក្នុងពេលអនាគតឬទេ? តើសិស្សរៀនមិនចេះ មិនចាំ និងមិនយល់មេរៀន ក្នុងបច្ចុប្បន្នអាចប្រឈមបញ្ហាអ្វីខ្លះ ក្នុងពេលអនាគត?

លំនាំនៃការដឹកនាំការរៀន និងបង្រៀនឱ្យសិស្សទទួលបានគុណផលល្អមានច្រើនបែបច្រើនយ៉ាង។ របកគំហើញនៃការស្រាវជ្រាវរបស់ Tomlinson (1999), Alberta Learning (2004), Conklin (2006), Association of Teacher Educators and Rowman & Littlefield Education, (2009), Kilbane & Milman (2014), Blomeke, Olsen, & Suhl (2016), Agarwal & Bain (2019) ពន្យល់ថា គ្រូបង្រៀនយល់អំពីលំនាំ និងវិធីសាស្ត្រនៃការដឹកនាំការរៀន និងការបង្រៀនសម្បូរបែប សិស្សរៀនបានលទ្ធផលល្អ។

លំនាំ គោលវិធី និងវិធីសាស្ត្រនៃការដឹកនាំការរៀន និងការបង្រៀនមានច្រើនសម្បូរបែប ដូចជា លំនាំអនុមានញែក និងអនុមានរួមរបស់ Sir. Francis Bacon (១៥៦១-១៦២៦) លំនាំបង្រៀនផ្ទាល់ពីគ្រូ (Direct Instruction) កើតចេញពីទ្រឹស្តីអាកប្បកិរិយានិយមរបស់ Skinner (១៩៧៤) លំនាំយល់បញ្ញត្តិ (Concept Attainment) របស់ Bruner និងសហការី (១៩៥៦) លំនាំគិតបញ្ញត្តិរបស់ Hilda Taba (១៩៦៧) លំនាំADDIE របស់ Gustafson (2002), លំនាំ DICK & Carey របស់ Dick, Carey, & Carey (2008), និងលំនាំ ASSURE របស់ Heinich, Molenda, Russell, & Smaldino (1999)។

លំនាំ និងវិធីសាស្ត្រ នៃការដឹកនាំការរៀន និងបង្រៀន ក្នុងទម្រង់ខាងក្រោម ត្រូវបានសំយោគពីលទ្ធផលនៃការស្រាវជ្រាវអន្តរជាតិជាច្រើន។ សៀវភៅនេះសំយោគលទ្ធផលនៃការស្រាវជ្រាវរបស់ Tyler (1949), Tomlinson (1999), Anderson, Krathwohl, & Airasian (2001), Alberta Learning (2004), Conklin (2006), Marzano & Kendall (2008), Rosenshine (2010), Jackson (2011), Kilbane & Milman (2014), Redfern (2015), Erickson & Lanning (2014), Erickson, Lanning, & French (2017), Stern, Lauriault, & Ferraro (2018), Lang (2019) និង Agarwal & Bain (2019)។

ការសំយោគនៃលទ្ធផលស្រាវជ្រាវទាំងនេះ បង្កើតជាក្របខ័ណ្ឌទ្រឹស្តីមួយ ដើម្បីធានាឱ្យការរៀន ការដឹកនាំការរៀន និងបង្រៀនមានប្រសិទ្ធភាព និងគ្របដណ្តប់ធាតុចម្បងចំនួន៤ ៖

១. ការដឹកនាំសកម្មភាពរៀន

២. ការចូលរួមរបស់សិស្ស

៣. ការវាយតម្លៃការសិក្សា

៤. ការលើកទឹកចិត្ត ឬអន្ទងព្រលឹងសិស្ស

**លំនាំដឹកនាំការរៀនតាមសិក្សាបញ្ញត្តិ និងបុច្ឆនសិក្សា**

សៀវភៅនេះបង្កើតទម្រង់ នៃការគិតសម្រាប់បង្កើតលំនាំ នៃការដឹកនាំការរៀន (រូបខាងក្រោម) ដោយផ្តោតការយកចិត្តទុកដាក់លើជំហាន ៣ ៖

១. គោលបំណង

២. ដំណើរការរៀន និងដឹកនាំការរៀន

៣. ការវាយតម្លៃ ។

គោលនីមួយៗ ផ្តោតលើធាតុសំខាន់ និងតួនាទីផ្សេងគ្នា ក្នុងដំណើរការដឹកនាំការរៀន ដើម្បីបណ្តុះសិស្សឱ្យមានទម្លាប់គិតដូចអ្នកវិទ្យាសាស្ត្រ និងអនុវត្តកាតព្វកិច្ចរៀនជាប្រចាំ ៖

១. គោលបំណង ផ្តោតលើធាតុ៤ ៖

១.១ មេរៀន

១.២ បញ្ញត្តិ

១.៣ លទ្ធផលសិក្សា

១.៤ បំណិនដើម្បីជោគជ័យ

២. ដំណើរការរៀន និងដឹកនាំការរៀន ផ្តោតលើធាតុពីរ ៖

២.១ សំណួរត្រិះរិះ

២.២ យុទ្ធវិធី

៣. វាយតម្លៃការសិក្សាផ្តោតលើធាតុ២ ៖

៣.១ វាយតម្លៃដើម្បីការរៀនបន្ត

៣.២ ផែនការសម្រេចលទ្ធផលសិក្សា ។

| ១. គោលបំណង | ១.២ បញ្ញត្តិ | ១.៣ លទ្ធផលសិក្សា | ១.៤ បំណិនដើម្បីជោគជ័យ |
|---|---|---|---|
| ១.១ មេរៀនទី២ | វីរភាព សង្គ្រាម ជម្លោះ នយោបាយ អំណាច ធនធាន តំបន់ ទីកន្លែង ភាពជាពលរដ្ឋ អធិបតេយ្យភាព ការចូលរួម | សូមអានសេចក្តីពន្យល់ | ▪ បង្កើតសំណួរ<br>▪ កែលម្អសំណួរ<br>▪ សួរសំណួរ<br>▪ កត់ត្រាចម្លើយ<br>▪ វាយការណ៍លទ្ធផល |

| ២. ដំណើរការរៀន និងដឹកនាំការរៀន | ២.១ សំណួរគ្រឹះ | ២.២ យុទ្ធវិធី |
|---|---|---|
| | សំណួរ០១.<br>សំណួរ០២.<br>សំណួរ០៣.<br>សូមអានសេចក្តីពន្យល់ | យុទ្ធវិធី០១៖<br>យុទ្ធវិធី០២៖<br>យុទ្ធវិធី០៣៖<br>សូមអានសេចក្តីពន្យល់ |

| ៣. វាយតម្លៃការសិក្សា | ៣.១ វាយតម្លៃដើម្បីការរៀនបន្ត | ៣.២ ផែនការជួយសិស្សរៀនយឺត |
|---|---|---|
| | វាយតម្លៃ០១.<br>វាយតម្លៃ០២.<br>វាយតម្លៃ០៣.<br>សូមអានសេចក្តីពន្យល់ | ផែនការ០១.<br>ផែនការ០២.<br>ផែនការ០៣.<br>សូមអានសេចក្តីពន្យល់ |

## ជំហាន០១. គោលបំណង

ជំហាន០១ នៃដំណើរការតាក់តែងលំនាំដឹកនាំការរៀន អ្នកគ្រូ លោកគ្រូត្រូវពិចារណាអំពីគោលបំណងនៃម៉ោងរៀននីមួយៗតាមមេរៀន គោលបំណងនៃមេរៀន ឬជំពូក។ គោលបំណងក្នុងដំណើរការតាក់តែងលំនាំដឹកនាំការរៀនមានធាតុ៤ដែលអ្នកគ្រូ លោកគ្រូត្រូវយល់ឱ្យច្បាស់ និងប្រើការកើត ក្នុងដំណើរការដឹកនាំការរៀនក្នុង និងក្រៅថ្នាក់ ៖ ១. មេរៀន ២. បញ្ញត្តិ ៣. លទ្ធផលសិក្សា និង៤. បំណិនដើម្បីជោគជ័យ។

### ១.១ មេរៀន ឬជំពូក (ចំណេះដឹង)

ដើម្បីបំពេញតម្រូវការ ឬកម្មវិធីកំណត់របស់ប្រព័ន្ធអប់រំ និងការវាយតម្លៃការសិក្សារបស់សិស្ស តាមកាលកំណត់ ដូចជា ប្រចាំសប្តាហ៍ ខែ ត្រីមាស ឆមាស និងឆ្នាំ អ្នកគ្រូ លោកគ្រូត្រូវបង្រៀនមេរៀនតាមលំដាប់ក្នុងសៀវភៅសិក្សាគោល ឬកម្មវិធីសិក្សាដែលប្រព័ន្ធអប់រំកំណត់ឱ្យ។ ក្នុងដំណើរការតាក់តែងលំនាំដឹកនាំការរៀននេះ យើងយកមេរៀនថ្នាក់ទី៨ អំពីសម័យលង្វែក ក្នុងទំព័រ ១១៤ នៃសៀវភៅសិក្សាសង្គមបោះពុម្ពឆ្នាំ២០២០។

### ១.២ បញ្ញត្តិ

អ្នកគ្រូ លោកគ្រូ បានរៀនរួចហើយអំពីការកំណត់ និងជ្រើសរើសបញ្ញត្តិ សម្រាប់ដឹកនាំការរៀន។ បញ្ញត្តិជាធាតុសម្រាប់ដឹកនាំចិត្ត នាំផ្លូវគិតរបស់សិស្ស និងភ្ជាប់ជាមួយតម្រូវការរៀនបន្ត រស់នៅ និងធ្វើការ។ បញ្ញត្តិអាចបង្កប់ក្នុងគំនិតទូទៅ គោលគំនិត ឬគំនិតធំរបស់អ្នកនិពន្ធ ឬអាចបង្ហាញក្នុងគំនិតទូទៅ គំនិតធំ ឬគោលគំនិតរបស់អ្នកនិពន្ធ។ ដូច្នេះ អ្នកគ្រូ លោកគ្រូត្រូវកំណត់រកបញ្ញត្តិចេញពីមេរៀន ឯកសារអំណាន ឬកម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជាតាមកម្រិតថ្នាក់ដែលអ្នកគ្រូ លោកគ្រូត្រូវបង្រៀន។ ក្នុងដំណើរការកំណត់រកបញ្ញត្តិ អ្នកគ្រូ លោកគ្រូអាចដឹកនាំសិស្សឱ្យគិតរកបញ្ញត្តិក៏បានដែរ។

> បញ្ញត្តិជាគ្រឿងសង្ហារិមនៃចិត្ត។ ចិត្តដែលមានបំពាក់គ្រឿងសង្ហារិមល្អៗ ជាប្រភពផ្តល់បីតិ ជោគជ័យ និងភាពជាពលរដ្ឋពូកែ (Parker, 2012 )។

ឧទាហរណ៍ ០១ ៖ អត្ថបទមួយដកស្រង់ចេញពីសៀវភៅប្រវត្តិសាស្ត្រសម័យលង្វែក មានគំនិតទូទៅមួយរបស់អ្នកនិពន្ធសរសេរថា *"ព្រះបាទចន្ទរាជាមានវីរភាពនិងដឹកនាំសង្គ្រាម ឈ្នះសមរភូមិជាច្រើនកន្លែង ។ ព្រះអង្គបានដឹកនាំសង្គ្រាមដណ្តើម**អាណាចក្រទិសខាងកើត ឬ ស្រឡប់ដូនតីពិជ័យព្រៃនគរ** មកវិញ និងផ្លាស់ប្តូររាជធានីទៅលង្វែកដែលមានព្រៃឫស្សីហ៊ុមព័ទ្ធយ៉ាងក្រាស់។"*

ឧទាហរណ៍០២ ៖ អត្ថបទមេរៀនទី៣ ព្រះរាជាសម័យលង្វែក ថ្នាក់ទី៨ មានគំនិតទូទៅ គោលគំនិត ឬគំនិតធំមួយរបស់អ្នកនិពន្ធសរសេរថា៖ *"ព្រះបាទចន្ទរាជាជាស្តេចសឹកសង្គ្រាមដ៏ល្បីល្បាញមួយព្រះអង្គ ក្នុងសតវត្សរ៍ទី១៦។ ព្រះអង្គបានរំដោះទឹកដីខ្មែរមកវិញ រហូតដល់ក្រុងអាយុធ្យា។ ព្រះអង្គបានសាងសង់វត្តអារាមជាច្រើន បដិមា ត្រលែងកែង ព្រះគោ។ ព្រះអង្គប្រមូលអ្នកប្រាជ្ញ កវី .....ឱ្យចងក្រង និងសរសេរឯកសារគ្រប់ប្រភេទ សម្រាប់កុលបុត្រកុលធីតាខ្មែរជំនាន់ក្រោយ។ ក្នុងឆ្នាំ១៥៦៦ ព្រះបាទចន្ទរាជាទ្រង់ចូលទិវង្គតនៅក្រុងលង្វែក។ ព្រះចេតិយតម្កល់អដ្ឋិធាតុរបស់ព្រះអង្គឋិតលើភ្នំព្រះរាជទ្រព្យសព្វថ្ងៃ។"*

- បញ្ញត្តិសម្រាប់ដឹកនាំការរៀនដកស្រង់ចេញពីកថាខណ្ឌ នៃអត្ថបទទាំងពីរ មានមួយចំនួនដូចជា ៖ ១. វីរភាព ២. សង្គ្រាម ៣. ជម្លោះ ៤. នយោបាយ ៥. អំណាច ៦. ធនធាន ៦. តំបន់ ៧. កន្លែង ៨. ភាពជាពលរដ្ឋ ៩. អធិបតេយ្យភាព ១០. ការចូលរួម។
- អ្នកគ្រូ លោកគ្រូប្រហែលជាឆ្ងល់ថា បញ្ញត្តិច្រើនយ៉ាងនេះ តើអាចរៀនចប់មួយម៉ោងឬទេ? ចម្លើយសាមញ្ញបំផុត គឺក្នុងមេរៀនភាគច្រើនមានបង្កប់បញ្ញត្តិទាំងអស់នេះ និងមានបញ្ញត្តិថ្មីថែមទៀត។ អ្វីដែលសិស្សត្រូវរៀន ហើយគ្រូបង្រៀនត្រូវដឹកនាំការរៀន គឺសកម្មភាពស្វែងការពន្យល់អំពីបញ្ញត្តិនីមួយៗ ដោយមានប្រធានបទ អង្គហេតុជាភស្តុតាង និងឧទាហរណ៍មកពន្យល់។
- តើបញ្ញត្តិ១០ ខាងលើ អាចភ្ជាប់នឹងជីវភាពប្រចាំថ្ងៃរបស់សិស្សអ្វីខ្លះ និងមានសរសេរក្នុងមេរៀនមុនៗដែរឬទេ?
- តើបញ្ញត្តិ១០ ខាងលើ សិស្សធ្លាប់រៀនក្នុងមុខវិជ្ជាផ្សេង និងធ្លាប់ជួបក្នុងជីវភាពប្រចាំថ្ងៃដែរឬទេ?

- តើបញ្ញត្តិនីមួយៗមានលក្ខណៈសកលដែរទេ?

ឧទាហរណ៍ ៖ វីរភាពជាបញ្ញត្តិសម្រាប់ដឹកនាំការរៀន

- តើបញ្ញត្តិ (វីរភាព) ភ្ជាប់នឹងជីវភាពប្រចាំថ្ងៃបានឬទេ?
- តើបញ្ញត្តិ (វីរភាព) សិស្សធ្លាប់រៀនក្នុងមុខវិជ្ជាផ្សេងឬទេ?
- តើបញ្ញត្តិ (វីរភាព) សិស្សធ្លាប់ជួបក្នុងជីវភាពប្រចាំថ្ងៃឬទេ?
- តើបញ្ញត្តិ (វីរភាព) អាចប្រើក្នុងការរៀនបន្ត ធ្វើការ និងរស់នៅបានដែរឬទេ?
- តើបញ្ញត្តិ (វីរភាព) អាចប្រើក្នុងបរិបទ ឬស្ថានភាពបែបណាខ្លះ?

### ១.៣ លទ្ធផលសិក្សា

កម្មវិធីសិក្សាបច្ចុប្បន្នផ្តោតលើវិមាត្រពីរ ១. មាតិកាមេរៀន ឬប្រធានបទ និង២. លទ្ធផលសិក្សា ឬបំណិនតាមកិរិយាសព្ទក្នុងវិជ្ជានុក្រម BLOOM។ ដូច្នេះ ទម្លាប់នៃការតាក់តែងកិច្ចតែងការបង្រៀនក្នុងប្រព័ន្ធអប់រំកម្ពុជាបច្ចុប្បន្ន ក៏ដូចប្រទេសផ្សេងដែរ។ គ្រូបង្រៀនពឹងលើលទ្ធផលសិក្សា មាតិកាក្នុងសៀវភៅ និងវត្ថុបំណងមេរៀនដែលមានស្រាប់ក្នុងសៀវភៅសិក្សាគោល ឬកម្មវិធីសិក្សាលម្អិត ឬឯកសារផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា។

រូបភាព៣២. ដំណើរការរៀនតាមសិក្សាបញ្ញត្តិ




ក្រសួងអប់រំ យុវជន និងកីឡា ២០២១

ការសរសេរលទ្ធផលសិក្សាតាមគោលវិធីសិក្សាបញ្ញត្តិ គ្រូបង្រៀនត្រូវសរសេរតាមបញ្ញត្តិ និងប្រើកិរិយាស័ព្ទក្នុងតារាងវិជ្ជានុក្រមប្លូម (BLOOM, ១៩៥៧) ឬតារាងកិរយាសព្ទសកម្មផ្សេងៗទៀត។ គ្រូបង្រៀនគួរប្រើដំណើរការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិជាគោល (រូបភាព)។ លទ្ធផលសិក្សាតាមកម្មវិធីសិក្សាបែបបញ្ញត្តិត្រូវបានចែកចេញជាបីកម្រិត ៖ ១៖ កម្រិតដឹងឬស្គាល់ ២. កម្រិតយល់ ៣. កម្រិតធ្វើឬប្រតិបត្តិ។

ឧទាហរណ៍ ៖ ក្នុងដំណើរការនេះ យើងយកបញ្ញត្តិមួយមករៀន គឺ វិរភាព (សម្គាល់ ៖ ក្នុងមួយម៉ោង គ្រូបង្រៀនអាចសម្របសម្រួលឱ្យសិស្សរៀនច្រើនបញ្ញត្តិក៏បាន។ ក្នុងដំណើរការតាក់តែងលំនាំដឹកនាំការរៀនក្នុងវគ្គនេះ បញ្ញត្តិតែមួយគឺ **វីរភាព** ត្រូវបានយកមកលម្អិត)។

- លទ្ធផលសិក្សាកម្រិតដឹង ឬស្គាល់ ៖ សិស្សដឹង ឬស្គាល់ ៖
    - វីរភាព ឬភាពពូកែរបស់ព្រះបាទចន្ទរាជា ក្នុងការដឹកនាំទ័ព និងឈ្នះសត្រូវក្នុងសមរភូមិជាច្រើនកន្លែង រហូតឈ្នះសង្គ្រាម ដណ្តើមទឹកដីមកវិញ។ ភាពខ្លាំង ឬភាពពូកែរបស់ព្រះបាទចន្ទរាជា រួមមាន ៖
        - ក្លាហាន
        - ចិត្តព្យាយាម
        - អង់អាច
        - រឹងប៉ឹង
        - មោះមុត
        - រៀនចេះដឹងច្រើន និង
        - មានវិជ្ជាខ្ពង់ខ្ពស់

សម្គាល់ ៖ អ្នកគ្រូ លោកគ្រូពុំចាំបាច់សរសេរ លម្អិតក្នុងកិច្ចតែងការ ឬលំនាំដឹកនាំការរៀនទេ។ អ្នកគ្រូ លោកគ្រូអាចទុកឱ្យសិស្សពិភាក្សា ឬរកសេចក្តីពន្យល់លម្អិតលើភាពខ្លាំងមួយចំនួននេះក៏បានដែរ។

- លទ្ធផលសិក្សាកម្រិតយល់ ៖ សិស្សនឹងយល់ថា ៖

- ○ ប្រទេស សហគមន៍ គ្រួសារមួយមានបុគ្គល ឬមេដឹកនាំមួយនាក់ ឬច្រើននាក់ពោរពេញដោយវីរភាព ប្រទេស សហគមន៍ គ្រួសារនោះនឹងជឿនលឿន និងពោរពេញដោយមនុស្សពូកែ។ សិស្សនឹងយល់ថា វីរភាពរបស់ពលរដ្ឋនៃប្រទេសមួយ សម្បូរបែប មិនអាចមានសត្រូវណាមកឈ្លានពានបានទេ។

▪ លទ្ធផលសិក្សាកម្រិតធ្វើ ឬប្រតិបត្តិ ៖ សិស្សនឹងធ្វើកើត ដោយ ៖

- ○ ជួយមិត្តភក្តិក្នុងថ្នាក់ សាលា សមាជិកគ្រួសារ សហគមន៍
- ○ ព្យាយាមរៀនដើម្បីបានចំណេះដឹងច្រើន និងវិជ្ជាខ្ពង់ខ្ពស់
- ○ ជួយអ្នកដទៃ ក្នុងសាលារៀន សហគមន៍ កន្លែងផ្សេងៗ
- ○ ជួយសមាជិកគ្រួសារ ក្នុងការងារផ្ទះជាច្រើនប្រភេទ
- ○ ប្តេជ្ញា មិនចុះចាញ់ភាពលំបាក ក្នុងការរៀន និងការងារ
- ○ បញ្ជាក់ជំហរច្បាស់លាស់ចំពោះគំនិតត្រឹមត្រូវ
- ○ ប្រើភស្តុតាងវិទ្យាសាស្ត្រដើម្បីសម្រេចចិត្ត ដោយសារមានចំណេះដឹងច្រើន និងវិជ្ជាខ្ពស់។

## ១.៤ បំណិនដើម្បីជោគជ័យ

ការរៀនតាមគោលវិធីសិក្សាបញ្ញត្តិ សិស្សអាចអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង។ មនុស្សត្រូវការបំណិនច្រើនបែប ច្រើនយ៉ាង និងពហុទម្រង់ក្នុងជីវភាពរស់នៅ ការងារ និងរៀនបន្ត។ គុណសម្បទាសតវត្សរ៍ទី២១ និងពលរដ្ឋសកល ដូចបានពន្យល់ខាងដើម មានបំណិនច្រើនបែបច្រើនយ៉ាង។ ដំណើរការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ គ្រូបង្រៀនត្រូវគិតរឿងបីដើម្បីអភិវឌ្ឍបំណិនដើម្បីជោគជ័យ ៖ ១. បញ្ញត្តិ ២. អង្គហេតុ ៣. បំណិន។



បំណិនដើម្បីជោគជ័យសំដៅដល់បំណិនគិតរបស់សិស្ស ពីកម្រិតទាបឡើងដល់កម្រិតខ្ពស់។ បំណិនគិតជាឧបករណ៍នាំផ្លូវចិត្ត របស់សិស្សឱ្យចូលរួមយ៉ាងសកម្ម និងមានន័យបំផុត ក្នុងដំណើរការរៀន និងយកទៅប្រើការក្នុងជីវភាពប្រចាំថ្ងៃ ការងារ និងរៀនបន្ត។ ដំណើរការរៀនដោយមានចិត្ត មានក្តីស្រឡាញ់ សំដៅស្វែងការពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់នៃអង្គហេតុ ប្រធានបទ បញ្ញត្តិ និងការយល់ទូទៅ។

ដើម្បីសម្រួលដល់អ្នកគ្រូ លោកគ្រូ ក្នុងការជ្រើសរើសបំណិនដើម្បីជោគជ័យ សៀវភៅនេះផ្តល់ឧទាហរណ៍មួយចំនួនសម្រាប់អ្នកគ្រូ លោកគ្រូគិត និងសិក្សាបន្ថែម។ បំណិនដើម្បីជោគជ័យ សំអាងលើគុណសម្បទាសតវត្សរ៍ទី ២១ និងគុណសម្បទាពលរដ្ឋសកល ដូចបានពន្យល់ខាងលើ។

អ្នកគ្រូ លោកគ្រូសាកល្បងគិតរឿងតូចមួយ។ នៅពេលយើងយកចិត្តរបស់យើងគិតលើវត្ថុអ្វីមួយ។ តើចិត្តរបស់យើងងាយនឹងចំណាំវត្ថុនោះឬទេ? ដូច្នេះ ការដឹកនាំការរៀនតាមសិក្សាបញ្ញត្តិ សំដៅឱ្យសិស្សដាំបណ្តុះទម្លាប់គិតលើបញ្ញត្តិនៃមេរៀន ដើម្បីអភិវឌ្ឍបំណិនដើម្បីជោគជ័យ។ ឧទាហរណ៍មួយចំនួនអំពីវិជ្ជា និងបំណិនដើម្បីដឹកនាំឱ្យមនុស្សជោគជ័យ ក្នុងការរៀនបន្ត ការងារ និងជីវិត ដោយរំឭកឡើងវិញ ៖

១. បុច្ឆនវិជ្ជា

គ្រូបង្រៀនក៏មានចេតនាសួរសំណួរដែលមានប្រសិទ្ធភាពដែរ។ សំណួរមានប្រសិទ្ធភាពសំដៅដល់ សំណួរងាយយល់ និងលើកទឹកចិត្តសិស្សឱ្យចូលរួមឆ្លើយ។ សិស្សមកអង្គុយរៀនក្នុងថ្នាក់ជាមួយអ្នកគ្រូ លោកគ្រូ ក៏មានចេតនាអភិវឌ្ឍបំណិនបង្កើតសំណួរ និងសួរសំណួរឱ្យមានប្រសិទ្ធភាពដែរ។ សំណួរដែលមានប្រសិទ្ធភាព សំដៅដល់សំណួរដាស់ផ្លូវចិត្តឱ្យមនុស្សចង់ឆ្លើយ គិតកម្រិតខ្ពស់ និងពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែប។ សំណួរមានប្រសិទ្ធភាពសំដៅដល់ការបង្កើតសំណួរតាមទ្រឹស្តីសូក្រាត ដូចបានរៀនខាងលើហើយ។

២. បំណិនគិត

តារាងវិជ្ជានុក្រមប្លូម (BLOOM, ១៩៥៧) ជាមូលដ្ឋានទ្រឹស្តីសម្រាប់ការគិតក្នុងដំណើរការរៀន។ បុគ្គលមួយនាក់មានបំណិនគិតកម្រិតខ្ពស់ គឺគិតលើសពី

ភ្នែកមើលឃើញ ត្រចៀកស្តាប់ឮ កាយប៉ះត្រូវ ច្រមុះហិតក្លិន និងអណ្តាតភ្លក្ស។ មនុស្សមានបំណិនគិតកម្រិតខ្ពស់ សំដៅដល់ការគិតដោយសំអាងភស្តុតាង និងយកចិត្តទៅសម្លឹងហួសផ្ទៃក្រៅ ហួសពីការឆ្លងកាត់តាមវិញ្ញាណទាំង៥។

មនុស្សមានបំណិនគិតកម្រិតខ្ពស់ មានសមត្ថភាពស្វែងភាពពិត ច្បាស់លាស់ និងត្រឹមត្រូវ។ មនុស្សមានបំណិនគិតកម្រិតខ្ពស់បញ្ចៀសការសម្រេចចិត្តមិនប្រាកដប្រជា បានច្រើន។ មនុស្សមានបំណិនគិតកម្រិតខ្ពស់មិនលង់នឹងការផ្សាយពាណិជ្ជកម្ម និងសម្តីមនុស្សពូកែវោហារ។ មនុស្សមានបំណិនគិតកម្រិតខ្ពស់តែងឆ្ងល់ និងវែកញែក ប៉ុន្តែមិនជ្រេញចិត្ត។ មនុស្សមានបំណិនគិតកម្រិតខ្ពស់តែងបើកចិត្តទូលាយ និងស្តាប់ហេតុផល ប៉ុន្តែមិនឆាប់ជឿ។

សិស្សមានបំណិនគិតកម្រិតខ្ពស់ មានសមត្ថភាព ៖

- ញែកភាពស្រដៀង និងភាពខុសគ្នា
- ញែកនិងកំណត់អាទិភាពនៃព័ត៌មាន
- វែកញែកគំនិតដោយមានភស្តុតាង
- វាយតម្លៃព័ត៌មាន
- គិតបញ្ច្រាស់ទិស ឬគិតផ្ទុយពីគំនិតដើម
- ទទួលយក និងចែករំលែកព័ត៌មានដោយសំអាងភស្តុតាង
- ចែករំលែកព័ត៌មានតាមទម្រង់ច្នៃប្រឌិតថ្មី
- ភ្ជាប់ព័ត៌មានទទួលបានជាមួយនឹងបទពិសោធ។

៣. នវកម្មគំនិត

នវកម្មគំនិត ជាសមត្ថភាពគិតកម្រិតខ្ពស់បំផុត តាមតារាងវិជ្ជានុក្រម ប្លូម (BLOOM, ១៩៥៧)។ នវកម្មគំនិតសំដៅដល់ ៖ ១. បង្កើតគំនិតថ្មី ២. ប្តូរគំនិតពីចាស់មកថ្មី ៣. រកគំនិតថ្មី ឬបញ្ចេញថ្មី។ និយាយក្នុងភាសាសាមញ្ញ គឺមនុស្សមាននវកម្មគំនិត ពុំមានពាក្យថា ធ្វើមិនកើត ពុំមានលទ្ធភាព ពុំមានសមត្ថភាព និងខ្វះធនធានទេ។ នវកម្មគំនិត ពឹងជាធំលើដង្ហើមចេញ និងដង្ហើមចូល ប្រសិនបើប្រៀបធៀបនឹងការរស់ប្រចាំថ្ងៃរបស់មនុស្ស។

មនុស្សមាននវកម្មគំនិត គឺរក្សាចិត្ត ៖

- ឆ្ងល់

- ស្រមៃ
- បញ្ចេញគំនិតប្លែកៗ និងគំនិតថ្មី
- ភ្ជាប់គំនិតថ្មីជាមួយនឹងបទពិសោធ
- គិតលើការគិតដោយសំអាងភស្តុតាងថ្មីៗ
- សង្ខេប និងសំយោគគំនិត
- អន្ទងព្រលឹង ឬអន្ទងចិត្តមនុស្សឱ្យទទួលយកគំនិតថ្មី
- ប្រើភស្តុតាងវិទ្យាសាស្ត្រ

៤. បញ្ញាវិជ្ជា (បំណិនស្រាយបញ្ហា)

មនុស្សគ្រប់វ័យ និងគ្រប់ភេទសុទ្ធតែត្រូវប្រឈមនឹងបញ្ហា តូចក្តី ធំក្តី។ ដូច្នេះ មនុស្សត្រូវមានមធ្យោបាយ និងវិធីសាស្ត្រស្រាយបញ្ហា តាមកាល លក្ខខណ្ឌ និងបរិបទ។ ដំណោះស្រាយត្រូវតែប្រកបដោយនវកម្មគំនិត។ ដូច្នេះ មនុស្សគ្រប់រូបត្រូវប្រើវិធីស្រាយបញ្ហាដោយប្រើវិជ្ជា និងបញ្ញា មិនមែនហិង្សា។ ការរៀនពិតប្រាកដសំដៅធានាឱ្យសិស្សអភិវឌ្ឍវិជ្ជា និងពង្រីកបញ្ញាក្នុងការដោះស្រាយបញ្ហា និងឈានទៅប្រើនវកម្មគំនិតដើម្បីដោះស្រាយបញ្ហា។

បញ្ញាវិជ្ជាសំដៅបំពាក់ចំណេះដឹង បំណិន និងវិជ្ជាច្រើនបែបច្រើនយ៉ាងដល់អ្នកសិក្សា សម្រាប់យកទៅប្រើការក្នុងការដោះស្រាយបញ្ហា ប្រកបដោយនវកម្មគំនិត។ បញ្ញាវិជ្ជាជាចំណែកមួយមិនអាចខ្វះបាន ក្នុងដំណើរជីវភាពប្រចាំថ្ងៃ រៀនបន្ត និងការងារ របស់មនុស្សគ្រប់រូប និងគ្រប់វ័យ។ ការខ្វះវិជ្ជាក្នុងការដោះស្រាយបញ្ហា មនុស្សអាចប្រើហិង្សាវិធី និងពង្រីកបញ្ហាកាន់តែច្រើន និងបង្កបញ្ហាកាន់តែស្មុគស្មាញ។ ការខ្វះការគិត និងការយល់អំពីជម្រើសនៃដំណោះស្រាយ មនុស្សត្រូវបង្កើតបញ្ហាផ្សេងទៀតកាន់តែច្រើន និងស្មុគស្មាញ។

បំណិនដែលសិស្សត្រូវរៀនក្នុងការដោះស្រាយបញ្ហា រួមមាន ៖

- បង្កើតសំណួរ ៖ ការឆ្ងល់ និងការបង្កើតសំណួរជាជំហានដំបូងក្នុងការគិតរកដំណោះស្រាយបញ្ហា។ ការគិតសំដៅដល់ការស្វែងយល់ និងវិភាគអំពីឫសគល់នៃបញ្ហា និងធាតុលម្អិតបង្កបញ្ហា។
- ធ្វើផែនការ ៖ ក្រោយបានគិតអំពីឫសគល់ និងធាតុបង្កនៃបញ្ហា មនុស្សត្រូវបង្កើតគោលបំណង ឬវត្ថុបំណងនៃការរកដំណោះ

ស្រាយបញ្ហា។ បន្ទាប់មក មនុស្សត្រូវធ្វើផែនការប្រមូលព័ត៌មានឱ្យគ្រប់ជ្រុងជ្រោយ។ មនុស្សត្រូវកំណត់ពេលវេលា រកធនធាន និងមធ្យោបាយដើម្បីប្រមូលព័ត៌មាន ជ្រើសរើសឧបករណ៍ និងប្រភពផ្តល់ព័ត៌មានដោយមិនលម្អៀង។

- ស្រាវជ្រាវ ៖ ការស្រាវជ្រាវត្រូវការពេលវេលា ធនធាន និងឧបករណ៍ប្រមូលព័ត៌មាន ប្រភពផ្តល់ទិន្នន័យ។
- បង្កើតដំណោះស្រាយ ៖ ការបង្កើតជម្រើសនៃដំណោះស្រាយទាមទារការសំយោគគំនិតឱ្យបានគ្រប់ជ្រុងជ្រោយ និងប្រកបដោយនវកម្មគំនិត។
- កែលម្អ ៖ ជម្រើសនៃដំណោះស្រាយមានរួចរាល់ ប៉ុន្តែអ្នកមិនទាន់ច្បាស់អំពីប្រសិទ្ធភាព និងភាពសមប្រកបនៃជម្រើសទាំងនោះទេ។ ដូច្នេះ អ្នករកដំណោះស្រាយត្រូវវាយតម្លៃជម្រើសនៃដំណោះស្រាយម្តងមួយៗ។ ក្រោយវាយតម្លៃ អ្នកត្រូវជ្រើសរើសអាទិភាព នៃដំណោះស្រាយ។ អ្នកត្រូវផ្គូផ្គងជម្រើសនៃដំណោះស្រាយជាមួយធាតុនានាបង្កឱ្យកើតជាបញ្ហា។
- បង្ហាញជម្រើសអាទិភាពនៃដំណោះស្រាយ ៖ ជម្រើសនៃដំណោះស្រាយបញ្ហាតែងមានផលប៉ះពាល់ ទាំងល្អនិងអាក្រក់។ ចាំបាច់មនុស្សត្រូវច្បាស់ទាំងទ្រឹស្តី និងជម្រើសនៃការស្រាយបញ្ហា ដើម្បីធានាឱ្យគ្រប់ភាគីទទួលយក។ អ្នកអាចជ្រើសរើសយកដំណោះស្រាយដែលមានប្រសិទ្ធភាពបំផុត។

៥. ប្រាស្រ័យមនុស្ស

ប្រាស្រ័យមនុស្ស ជាតម្រូវការចាំបាច់ដែលបញ្ញាសិប្បនិម្មិត ឬមនុស្សយន្តមិនអាចជំនួសមនុស្សបាន។ មនុស្សអាចបញ្ជូនសារជារូបភាព វីដេអូ សំឡេង អក្សរ គំនូរ ឆ្លងទ្វីបក្នុងមួយវិនាទី ដោយប្រើបច្ចេកវិទ្យាព័ត៌មាន។ គ្រាន់តែជួបមុខគ្នា ញញឹមដាក់គ្នា និងនិយាយជាមួយគ្នា មនុស្សអាចដោះស្រាយជម្លោះបានយ៉ាងប្រសើរ។ ប្រាស្រ័យមនុស្សជាវិជ្ជាមួយសម្រាប់ប្រើក្នុងការស្រាយបញ្ហា ធ្វើការ និងរស់ក្នុងសង្គមប្រកបដោយមេត្រីភាព។

ទម្រង់ និងប្រភេទនៃប្រាស្រ័យមនុស្សមានច្រើន ដូចជា ការនិយាយផ្ទាល់មាត់ជាមួយមនុស្សមួយនាក់ ឬមួយក្រុម  សរសេរ គូរគំនូរ និងកាយវិការ។ ការប្រាស្រ័យមនុស្សទាមទារឱ្យមនុស្សបើកចិត្តឱ្យទូលាយដើម្បីស្តាប់  និងទទួលយកនានាភាព ពហុភាព ភាពរួម និងភាពដោយឡែកនៃទស្សនៈ និងគំនិត។

សៀវភៅនេះចែកបំណិនប្រាស្រ័យមនុស្សជា៤ក្របខ័ណ្ឌ ៖

- កាយវិកា៖ ការប្រើ ទឹកមុខ និងសំឡេង វិជ្ជមាន ឬអវិជ្ជមាន
- វាក្យសព្ទ៖ ប្រើពាក្យ ឃ្លា ឬប្រយោគមានអត្ថន័យ ផ្លូវការ មិនផ្លូវការ សមរម្យ ស្របតាមបរិបទ
- គំនិត៖ បញ្ចេញគំនិត ចោទសំណួរ និងសង្ខេបគំនិត ឱ្យងាយយល់
- អារម្មណ៍៖ បញ្ចេញអារម្មណ៍វិជ្ជមាន ដោយគិតដល់អ្នកប្រាស្រ័យ

តើអ្នកគ្រូ  លោកគ្រូធ្លាប់ប្រឈមនឹងបញ្ហាមួយក្នុងកិច្ចប្រជុំឬទេ?  បញ្ហានោះគឺនិយាយសម្តីទៅអ្នកស្តាប់ក្នុងអង្គប្រជុំ  សមាជិក  និងប្រធានអង្គប្រជុំមិនចាប់អារម្មណ៍ ឬមិនស្តាប់។ ប្រសិនបើជួបបញ្ហាបែបនេះ អ្នកគ្រូ លោកគ្រូកុំតូចចិត្ត។ អ្នកគ្រូ លោកគ្រូត្រូវដកថយបន្តិច និងរំឭកអំពីកាយវិការ វាក្យសព្ទ គំនិត និងអារម្មណ៍របស់យើងវិញ។ អ្នកគ្រូ លោកគ្រូសួរខ្លួនឯងនូវសំណួរមួយចំនួន៖

- តើកាយវិការរបស់ខ្ញុំវិជ្ជមាន
- តើសម្តីរបស់ខ្ញុំបំផុសចិត្តដល់អ្នកស្តាប់ដែរឬទេ?
- តើសម្តីរបស់ខ្ញុំអន្ទងចិត្តគ្រប់គ្រាន់ដល់អ្នកស្តាប់ដែរឬទេ?
- តើវាក្យសព្ទ ដូចជាឃ្លា ប្រយោគ ពាក្យគន្លឹះងាយយល់ឬទេ?
- តើសម្តីរបស់ខ្ញុំមានបញ្ញត្តិថ្មក់ការចាប់អារម្មណ៍ដល់អ្នកស្តាប់កម្រិតណា?
- តើសម្តីរបស់ខ្ញុំមានអត្ថន័យធំប៉ុនណា?
- តើខ្ញុំបានសង្ខេបគំនិត ឬចោទជាសំណួរងាយយល់កម្រិតណា?
- តើក្នុងដំណើរការប្រជុំ ខ្ញុំបញ្ចេញអារម្មណ៍?

អ្នកគ្រូ លោកគ្រូអាចដឹកនាំសិស្ស ឱ្យអភិវឌ្ឍបំណិនប្រាស្រ័យមនុស្ស ៖

- ស្តាប់ និងនិយាយសង្ខេប
- ស្តាប់ និងសរសេរសង្ខេប

- អាន និងនិយាយសង្ខេប
- អាន និងសរសេរសង្ខេប
- ស្ដាប់ និងគូររូប ឬដ្យាក្រាមសង្ខេប
- អាន និងគូររូប ឬដ្យាក្រាមសង្ខេប

គុណសម្បទាសតវត្សរ៍ទី២១ ត្រូវបានរៀបរាប់ និងពន្យល់ច្រើនគួរសម អំពីវិជ្ជា និងបំណិនចាំបាច់សម្រាប់ទទួលបានភាពជោគជ័យក្នុងជីវភាពរស់នៅ ការងារ និងការរៀនបន្ត ក្នុងយុគឧស្សាហកម្ម៤.០។ ក្នុងការតាក់តែងលំនាំដឹកនាំការរៀន អ្នកគ្រូ លោកគ្រូ គួរពិគ្រោះជាមួយផ្នែកខាងដើមបរិយាយច្រើនអំពីគុណសម្បទាសតវត្សរ៍ទី២១។

**ជំហានទី០២. ដំណើរការរៀន និងដឹកនាំការរៀន**

ជំហាន០២ នៃដំណើរការរៀន និងដឹកនាំការរៀន ផ្ដោតការយកចិត្តទុកដាក់លើការតាក់តែងលំនាំដឹកនាំការរៀន ឱ្យសិស្សទទួលបានគុណផលខ្ពស់។ ដំណើរការនេះផ្ដល់យោបល់ឱ្យអ្នកគ្រូ លោកគ្រូពិចារណានាមវត្ថុពីរ ៖១. សំណួរត្រិះរិះ ២. យុទ្ធវិធី។ គុណផលនៃការរៀនរបស់សិស្ស ដូចជា សិស្សអង្គុយរៀនមិនអវត្តមាន លទ្ធផលប្រឡងបានខ្ពស់ ថ្នាក់រៀនសម្បូរអ្នកគិត និងអ្នកឆ្លល់ដូចអ្នកវិទ្យាសាស្ត្រ។ គុណផលនៃការរៀន ពឹងអាស្រ័យលើយុទ្ធវិធីដឹកនាំការរៀនរបស់គ្រូបង្រៀន និងសំណួរ។ យុទ្ធវិធីដឹកនាំការរៀន និងសំណួរជាសិល្បៈ និងវិទ្យាសាស្ត្រនៃការដាស់អារម្មណ៍សិស្សឱ្យចូលរួមក្នុងសកម្មភាពថ្នាក់រៀន។

ដំណើរការរៀន និងដឹកនាំការរៀនប្រកបដោយក្ដីពេញចិត្ត និងបីតិ គ្រូបង្រៀនត្រូវពិចារណាអំពីនាមវត្ថុបី ៖ ១. ការដឹកនាំការរៀនជាក្រុមធំ ២. ការដឹកនាំការរៀនជាក្រុមតូច ៣. ការដឹកនាំការរៀនសម្រាប់សិស្សម្នាក់ៗ។

**២.១ សំណួរត្រិះរិះ**

ទស្សនវិទូ និងអ្នកវិទ្យាសាស្ត្រ ចាត់ទុកការឆ្ងល់ និងចោទសួរ ជាបេះដូងនៃដំណើរការរៀនពិតប្រាកដ និងបង្កើតពុទ្ធិថ្មី។ សូក្រាតពន្យល់ថា សំណួរនាំផ្លូវគិតទៅរកច្រើនទិស។ ទិសច្រើនដែលសូក្រាតនិយាយសំដៅគឺ ស្វែងការពន្យល់ចំពោះគំនិតស្មុគស្មាញ ត្រដាងសេចក្ដីពិត បើកគម្រូបនៃបញ្ហា និងញែកឱ្យដាច់រវាងការដឹង និងការមិនដឹង។

របកគំហើញនៃការស្រាវជ្រាវជាច្រើនពន្យល់អំពីប្រភេទនៃសំណួរ និង ដំណើរការបង្កើតសំណួរ។ សៀវភៅនេះសំយោគប្រភេទសំណួរជាបីកម្រិត ដើម្បីឱ្យអ្នកគ្រូ លោកគ្រូពេញចិត្តយកទៅប្រើ។ ទ្រឹស្តីរបស់សូក្រាតបែងចែក សំណួរជាបីកម្រិត (សៀវភៅខ្លះអាចចែកជា៥ប្រភេទ) សម្រាប់ដំណើរការរៀន៖ ១. សំណួរកម្រិត១ ឬ សំណួរប្រតិបត្តិប្រចាំថ្ងៃ ២. សំណួរកម្រិត២ ឬសំណួរស្វែងបន្ត ៣. សំណួរកម្រិត៣ ឬសំណួរបញ្ញត្តិ។ ក្នុងការបង្កើតសំណួរ ដូចឧទាហរណ៍ខាងក្រោម អ្នកគ្រូ លោកគ្រូ ពុំចាំបាច់បង្កើតទាំងអស់ទេ។ អ្នកគ្រូ លោកគ្រូ អាចចាត់ទុកថា ការបង្កើតសំណួរជាសកម្មភាពរបស់សិស្ស។ អ្នកគ្រូ លោកគ្រូ ត្រូវបង្រៀនសិស្សអំពីប្រភេទ និងកម្រិតនៃការបង្កើតសំណួរ។

- សំណួរកម្រិត១ ឬ សំណួរប្រតិបត្តិប្រចាំថ្ងៃ ៖ ផ្តោតការយកចិត្តទុកដាក់លើការរំឭក ឬនឹករកព័ត៌មាន អង្គហេតុ បទពិសោធ ព្រឹត្តិការណ៍ ឬទិន្នន័យ។
  - តើព្រះបាទចន្ទរាជា វាយឈ្នះសង្គ្រាមនៅឯណាខ្លះ និងឆ្នាំណា?
  - តើព្រះបាទចន្ទរាជមានភាពខ្លាំងអ្វីខ្លះទើបឈ្នះសង្គ្រាម?
  - តើព្រះបាទចន្ទរាជារៀននៅឯណា ទើបមានវិជ្ជាខ្ពង់ខ្ពស់?
  - តើព្រះបាទចន្ទរាជា បានឡើងសោយរាជ្យ នៅឆ្នាំណា?
  - តើព្រះបាទចន្ទរាជាសោយរាជ្យក្នុងស្ថានភាពនយោបាយដូចម្តេច?
  - តើខ្មែរបច្ចុប្បន្ន បានទទួលមរតក (ជាទីកន្លែង ប្រាសាទ ស្នាព្រះហស្ត) អ្វីខ្លះបន្សល់ពីការដឹកនាំរបស់ព្រះបាទចន្ទរាជា ក្នុងសម័យលង្វែក?
- សំណួរកម្រិត២ ឬសំណួរស្វែងបន្ត ៖ សំដៅស្វែងការពន្យល់លើគំនិតដែលសម្តែងចេញ តាមរយៈការប្រាស្រ័យមនុស្ស និងផ្តោតការយកចិត្តទុកដាក់លើទម្រង់ ឬទម្លាប់នៃដំណើរប្រព្រឹត្តទៅនៃចិត្ត ឬការគិតរបស់មនុស្ស។ ពេលមនុស្សទទួលបានព័ត៌មាន មានបទពិសោធ ស្គាល់អង្គហេតុ ឬទិន្នន័យក្នុងជំហានដំបូង មនុស្សត្រូវសួរសំណួរដើម្បីបញ្ជាក់ និងពន្យល់អំពីភាពពិត ត្រឹមត្រូវ និងច្បាស់លាស់បន្តទៀត។ គំនិតទូទៅក្នុងកថាខណ្ឌមួយបញ្ជាក់ថា ព្រះបាទចន្ទរាជា មានវីរភាព និងឈ្នះសង្គ្រាមច្រើនសមរភូមិ ដូច្នេះសំណួរស្វែងការពន្យល់បន្តមានដូចជា ៖

- តើគុណតម្លៃនៃវីរភាពរបស់ព្រះបាទចន្ទរាជា ផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ប្រជាជន និងប្រទេសជាតិ ក្នុងសម័យគ្រងរាជរបស់ព្រះអង្គ?
- តើហេតុអ្វីបានជារាស្ត្រខ្មែរបានសុំឱ្យព្រះបាទចន្ទរាជា ឡើងសោយរាជ្យ នៅឆ្នាំ១៥១៦?
- តើក្នុងអំឡុងឆ្នាំ១៥១៦ រាស្ត្រខ្មែរមានជម្រើសនៃព្រះរាជាអង្គផ្សេងឱ្យឡើងគ្រងរាជ្យដែរឬទេ?
- តើព្រះបាទចន្ទរាជាមានទម្លាប់រៀនយ៉ាងណា ទើបព្រះអង្គមានចំណេះដឹងច្រើន និងវិជ្ជាខ្ពង់ខ្ពស់?
- តើភាពក្លាហានរបស់បុគ្គលម្នាក់ ឬច្រើននាក់ អាចជួយអ្វីខ្លះ និងមានប្រយោជន៍អ្វីខ្លះសម្រាប់បុគ្គល គ្រួសារ និងប្រទេសជាតិ?
- តើចិត្តព្យាយាមនៃបុគ្គលមួយនាក់ និងច្រើននាក់អាចជួយអ្វីខ្លះ និងមានប្រយោជន៍អ្វីខ្លះសម្រាប់បុគ្គល គ្រួសារ សហគមន៍ និងប្រទេសជាតិ?

▪ សំណួរកម្រិត៣ ឬសំណួរបញ្ញត្តិ ៖ សំដៅវាយតម្លៃគុណភាពនៃការគិត និងហេតុផលដែលបានពន្យល់។ សំណួរបញ្ញត្តិ សួរដើម្បីគិតបន្ត និងរកទ្រឹស្តី ឬវិធីសាស្ត្រថ្មី។ សំណួរបញ្ញត្តិទាមទារឱ្យសិស្សគិតកម្រិតខ្ពស់ ឬគិតស៊ីជម្រៅដោយប្រើវិជ្ជាស្រាវជ្រាវ។ អត្ថបទប្រវត្តិវិទ្យាមួយបានផ្តល់អង្គហេតុមួយចំនួន ដូចជា ស្ថានភាពនយោបាយវឹកវរ ពេលសង្គ្រាម។ ពេលព្រះបាទចន្ទរាជឡើងគ្រងរាជ្យ ព្រះអង្គបានកសាង និងអភិវឌ្ឍប្រទេសជាច្រើនវិស័យ។

- តើអ្នកសន្និដ្ឋានយ៉ាងណាចំពោះស្ថានភាពនយោបាយ និងការដឹកនាំប្រទេសក្នុងសម័យលង្វែក ក្នុងឆ្នាំ១៥១៦ដល់១៥២៦ ក្រោមការដឹកនាំរបស់ព្រះបាទចន្ទរាជា?
- តើអ្នកសន្និដ្ឋានបានយ៉ាងដូចម្តេច ចំពោះសកម្មភាពសេដ្ឋកិច្ចកម្រិតគ្រួសារ ក្នុងសម័យលង្វែក ក្រោយឆ្នាំ១៥២៦ ពេលព្រះបាទចន្ទរាជាឡើងសោយរាជ្យ?
- ប្រសិនបើ អ្នករស់ក្នុងសម័យលង្វែក តើអ្នកគួរធ្វើអ្វីខ្លះដើម្បីចូលរួមស្តារប្រទេសក្រោយដណ្តើមទឹកដីពីបរទេសមកវិញ?

- តើវីរភាព និងការដឹកនាំរបស់ព្រះបាទចន្ទរាជា អាចជាទ្រឹស្តី ឬជាគោលការណ៍ សម្រាប់ឱ្យមនុស្សជំនាន់ក្រោយ រៀនសូត្រ ឬយកជាគំរូបានដែរឬទេ?

## ២.២ យុទ្ធវិធីដឹកនាំការរៀន

គុណផលសិក្សារបស់សិស្សបញ្ជាក់អំពីការរៀនចេះ ឬរៀនមិនចេះ។ ការរៀនចេះ ឬរៀនមិនចេះរបស់សិស្ស ពឹងអាស្រ័យធំលើយុទ្ធវិធីដឹកនាំការរៀន និងដំណើរការរៀនដែលធានាឱ្យសិស្សចូលរួមយ៉ាងសកម្ម និងដោយក្តីពេញចិត្ត។

គ្រូបង្រៀនត្រូវចាប់ផ្តើមដោយយុទ្ធវិធីអន្ទងព្រលឹង ដើម្បីទាក់ទាញចិត្តសិស្សឱ្យចូលរួមយ៉ាងសកម្ម និងដោយពេញចិត្តក្នុងដំណើរការរៀន។ ពាក្យអន្ទងព្រលឹងអាចនាំចិត្តអ្នកគ្រូ លោកគ្រូសើច ព្រោះមនុស្សពុំមែនអន្ទងព្រលឹងដូចអន្ទងខ្មោចទេ។ តាមបទពិសោធរបស់អ្នកគ្រូ លោកគ្រូ តើមានសិស្សមកអង្គុយក្នុងថ្នាក់មានតែខ្លួន ប៉ុន្តែអត់បានស្ពាយព្រលឹង ឬវិញ្ញាណមកអង្គុយក្នុងថ្នាក់ និងរៀនជាមួយគ្រូបង្រៀន និងសិស្សរួមថ្នាក់ដែរឬទេ? តើលោកគ្រូអ្នកគ្រូធ្លាប់ប្រឹងស្រែកនិងពន្យល់សិស្សយ៉ាងក្បោះក្បាយ ប៉ុន្តែសិស្សនៅតែមិនយល់ដែរឬទេ?

យុទ្ធវិធីមានច្រើនបែប ច្រើនយ៉ាង និងច្រើនទម្រង់ ដោយអនុវត្តតាមទ្រឹស្តីអប់រំ ឬវិទ្យាសាស្ត្រនៃការរៀនជាច្រើន។ សៀវភៅនេះ សំយោគរបកគំហើញនៃការស្រាវជ្រាវជាច្រើន និងបង្កើតយុទ្ធវិធីឱ្យសមប្រកប សម្រាប់ដឹកនាំការរៀនមុខវិជ្ជាប្រវត្តិវិទ្យា ក្នុងបរិបទថ្នាក់រៀនរបស់កម្ពុជា។ ប្រសិនបើ លទ្ធផលនៃការសំយោគនេះពុំទាន់បំពេញចិត្ត ឬមិនទាន់នាំចិត្តអ្នកគ្រូ លោកគ្រូឱ្យបីតិទេ អ្នកគ្រូលោកគ្រូអាចស្រាវជ្រាវ និងសរសេរក្នុងទម្រង់ថ្មីក៏បាន។ សៀវភៅនេះសូមផ្តល់យុទ្ធវិធីមួយចំនួនដូចជា ៖

យុទ្ធវិធី០១ ៖ ឆ្ងល់និងសួរដើម្បីការរៀន

មនុស្សរស់ក្នុងសង្គមត្រូវមានក្តីស្រមៃ និងក្តីសង្ឃឹម។ ក្តីស្រមៃ និងក្តីសង្ឃឹមជាផែនទីបង្ហាញផ្លូវនៃជីវិត។ សិស្សត្រូវតែគិតច្រើន ឆ្ងល់ច្រើន សួរច្រើនរកព័ត៌មានបន្ថែម និងស្វែងការពន្យល់អំពីភាពពិត ច្បាស់លាស់ និងត្រឹមត្រូវកាន់តែខ្លាំង ក្នុងយុគឧស្សាហកម្ម៤.០។ អ្នកគ្រូ លោកគ្រូគួរពិចារណា លើសកម្មភាពមួយចំនួន ដើម្បីធានាប្រសិទ្ធភាព នៃដំណើរការរៀន និងដឹកនាំការរៀន ដូចជា ៖

លំនាំសកម្មភាព១ ៖ បង្កើតសំណួរ

ក្រោយពីឆ្ងល់និងគិត ឬ គិតនិងឆ្ងល់ គឺមនុស្សត្រូវបង្កើតសំណួរ ជាទម្រង់សរសេរ ផ្ទាល់មាត់ ក្នុងខួរក្បាល ជាគំនូរ ឬទម្រង់ផ្សេង។ ការបង្កើតសំណួរពុំមែនជាការងាយទេ។ ការរៀនអំពីគំនិតថ្មី និងការបង្កើតទម្រង់ថ្មី កើតចេញពីការឆ្ងល់ គិត និងបង្កើតសំណួរ ដើម្បីស្វែងការពន្យល់អំពីភាពច្បាស់លាស់ ត្រឹមត្រូវ និងពិតអំពីគំនិតថ្មីនោះ។ អ្នកវិទ្យាសាស្ត្រ ដូចជា Albert Einstein (ឆ្នាំ1879 - 1955) និង Isaac Newton (ឆ្នាំ1643–1727) បានបង្កើតទ្រឹស្តី សម្រាប់មនុស្សជំនាន់ក្រោយរៀន ដោយប្រើការឆ្ងល់ គិត បង្កើតសំណួរ និងសួរសំណួរ។

ឧទាហរណ៍ សិស្សមួយនាក់ឆ្ងល់ និងសួរអំពីគំនិតច្នៃប្រឌិត របស់បុព្វបុរសខ្មែរក្នុងសម័យហ្វូណន ដោយផ្តើមនូវសំណួរមួយចំនួនដូចជា ៖

- តើមានភស្តុតាង បញ្ជាក់ពីគំនិតច្នៃប្រឌិតនៃបុព្វបុរសខ្មែរសម័យហ្វូណន?
- តើផលបានពីគំនិតច្នៃប្រឌិតក្នុងសម័យហ្វូណនមានអ្វីខ្លះ?

ការឆ្ងល់មិនបានសរសេរសំណួរ អាចមិនបង្កើតបានសំណួរល្អទេ។ ដូច្នេះ គ្រូបង្រៀនគួរដឹកនាំសិស្សឱ្យបង្កើតសំណួរ សរសេរសំណួរ និងកែលម្អសំណួរ តាមសមត្ថភាពគិតរបស់សិស្ស និងឱ្យសិស្សផ្តល់យោបល់ និងកែលម្អសំណួរគ្នាឯង។

បញ្ហាប្រឈមមួយត្រង់ថា គ្រូបង្រៀនច្រើនចង់ឱ្យសិស្សបង្កើតសំណួរតាមការចង់បានរបស់ខ្លួនឯង ឬសិស្សសួរមិនចំចំណុចគ្រូបង្រៀនចង់បាន។ គ្រូបង្រៀនពុំគួរខ្វល់អំពីសំណួរល្អ ឬមិនល្អ សួរដោតចំចំណុច ឬមិនដោតចំចំណុច។ ការសួរសំណួរដោតចំចំណុច ឬសំណួរល្អពុំមែនជាបញ្ហានៃការរៀន និងបង្រៀនក្នុងជំហាននេះទេ។ ការរៀន និងបង្រៀនពិតប្រាកដ ក្នុងជំហាននេះ គឺសិស្សមិនចេះបង្កើតសំណួរ មិនសរសេរសំណួរ មិនបានឡើងសួរសំណួរ មិនកែលម្អសំណួរ។ ចំណុចគួរចងចាំគឺ គិតឃើញអ្វី ត្រូវឆ្ងល់។ ឆ្ងល់អ្វី ត្រូវបង្កើតសំណួរតាមការឆ្ងល់។ សំណួរត្រូវតែបង្កើតក្នុងទម្រង់សំណេរ។ បង្កើតបានសំណួរ ត្រូវសុំយោបល់មិត្តរួមថ្នាក់ ដើម្បីកែលម្អ។ បានសំណួរល្អ ត្រូវយកទៅសួរ ដើម្បីបានព័ត៌មាន។

លំហាត់ ៖ អ្នកគ្រូ លោកគ្រូឱ្យសិស្សបង្កើត៥សំណួរជាក្រុមតូច (៤ឬ៥នាក់ក្នុងមួយក្រុម) ពិភាក្សាពាក់ព័ន្ធនឹងវីរភាព និងទីកន្លែងសង្គ្រាមក្នុងសម័យលង្វែក។

លំនាំសកម្មភាព២៖ យកសំណួរទៅសួរសិស្សផ្សេង

ការឆ្លល់និងសួរ ជាសកម្មភាពជួយសិស្សឱ្យអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង។ ក្នុងជីវិតប្រចាំថ្ងៃ មនុស្សតែងឆ្ងល់ សួរសំណួរ ស្វែងការពន្យល់ និងបញ្ជាក់សេចក្តីពិត។ ការឆ្ងល់ជារឿងមួយ ប៉ុន្តែប្រសិនបើត្រឹមឆ្ងល់មិនបង្កើតសំណួរដើម្បីសួរ ឆ្ងល់មិនទាន់អស់។ ការបង្កើតសំណួរហើយមិនបានយកសំណួរទៅប្រើដើម្បីសួរ អ្នកឆ្ងល់និងអ្នកសួរ មិនទាន់ដឹងច្បាស់ថា តើសំណួរបង្កើតហើយនោះ មានប្រយោជន៍ឬអត់នោះទេ។ អ្នកសួរ គឺសួរទៅរកអ្នកឆ្លើយ និងសង្កេតមើលថា តើអ្នកឆ្លើយនោះយល់សំណួរឬមិនយល់។

ដូច្នេះ ការកាន់សំណួរទៅសួរសិស្សដទៃ ឬមនុស្សដទៃ ជាដំណើរការស្វែងយល់ការពិតមួយ អំពីសំណួរដែលបានបង្កើត។ ការអនុវត្តសកម្មភាពសួរសំណួរដល់សិស្សដទៃជាដំណើរការរៀនពិតប្រាកដ។ សិស្សមានឱកាសស្វែងការពន្យល់អំពីភាពពិត និងត្រឹមត្រូវនៃចម្លើយ និងផ្លូវសម្រាប់កែលម្អសំណួរ។

មនុស្សត្រូវប្រើសំណួរជាប្រចាំក្នុងគ្រប់វិជ្ជាជីវៈ រស់នៅ និងរៀនបន្ត។ គ្រូបង្រៀនត្រូវដឹកនាំសិស្សបង្កើតសំណួរ។ ដំណើរការបង្កើតសំណួរ និងសួរសំណួរជំរុញចិត្តសិស្សឱ្យគិតច្រើន និងឆ្ងល់ច្រើន។ ដូច្នេះ ការគិតរបស់មនុស្សត្រូវភ្ជាប់នឹងអ្វីដែលធ្លាប់ដឹង ឬឆ្លងកាត់បទពិសោធ នៃវិញ្ញាណទាំង៥។ អ្នកគ្រូ លោកគ្រូអាចដឹកនាំសិស្សអនុវត្តសកម្មភាព ដូចជា៖

- ព្រាងសំណួរ
- សរសេរសំណួរ
- សាកល្បងសួរសំណួរ
- កែលម្អសំណួរ
- វាយតម្លៃសំណួរ តាមកម្រិតនីមួយៗ (សំណួរតាមទ្រឹស្តីសូក្រាត)

យុទ្ធវិធី០២៖ រំឭកការចងចាំដើម្បីការរៀន

ការរំឭកជាសកម្មភាពនៃចិត្តក្នុងការផ្ទេរ ឬភ្ជាប់អ្វីដែលមនុស្សធ្លាប់មានបទពិសោធ។ មនុស្សធ្លាប់មានបទពិសោធតាមវិញ្ញាណទាំង៥ ប៉ុន្តែមិនបានយកចិត្តទុកដាក់ក៏ត្រូវភ្លេចទៅវិញ។ ក្នុងដំណើរការរំឭកការចងចាំ ចិត្តរបស់មនុស្សតែងនឹករកព័ត៌មាន ឬបទពិសោធនៃចិត្តធ្លាប់ជួប និងរក្សាទុក។ សកម្មភាពនៃការរំឭកការចងចាំមានច្រើនប្រភេទ និងច្រើនទម្រង់ណាស់។ សៀវភៅនេះសំយោគរបកគំហើញ

នៃការស្រាវជ្រាវ និងបង្កើតសកម្មភាពមួយចំនួនសម្រាប់ប្រតិបត្តិក្នុងថ្នាក់រៀន។ ប្រសិនបើសកម្មភាពមួយចំនួនក្នុងសៀវភៅនេះពុំទាក់ទាញចិត្ត អ្នកគ្រូ លោកគ្រូអាចបង្កើតសកម្មភាពបន្ថែមសម្រាប់ចែករំលែកដល់គ្រូបង្រៀនផ្សេងទៀត។ ក្នុងដំណើរការរំឭកការចងចាំនេះ គ្រូបង្រៀនដឹកនាំសិស្សឱ្យអនុវត្តសកម្មភាពមួយចំនួនដូចជា ៖

លំនាំសកម្មភាព១៖ ក្ដារខៀនបញ្ញត្តិ

ថ្នាក់រៀនដោយប្រើវិធីសាស្រ្តសិក្សាបញ្ញត្តិ និងបុច្ឆនសិក្សា គួរមានក្ដារខៀនមួយព្យួរលើជញ្ជាំង នៃជ្រុងណាមួយនៃបន្ទប់រៀន។ ក្ដារខៀននេះទុកសម្រាប់ឱ្យសិស្ស និងគ្រូបង្រៀនបិទតាំងសំណេរ ជាប្រយោគពេញ ដើម្បីបញ្ជាក់អំពីគំនិតទូទៅមួយគួររៀនសូត្រ និងយកទៅប្រតិបត្តិ ក្នុងជីវិត ការងារ និង រៀន (រូប)។

រូបភាព៣៣. ឧទាហរណ៍ សិក្សាបញ្ញត្តិ ៖ ការសម្រេចចិត្ត




ប្រភព ៖ សម្រួលពី Erickson, Lanning, & French, (2017)

ឧទាហរណ៍ សុធានីបានអានអត្ថបទមួយ។ អត្ថបទនោះផ្ដោតលើវីរភាពរបស់ព្រះបាទចន្ទរាជា។ សុធារីសរសេរគំនិតទូទៅមួយដែលគួររៀន និងប្រតិបត្តិ។ *"មេដឹកនាំមានវីរភាពជាបង្គោលទ្រទ្រង់ឱ្យប្រជារាស្ត្របានសុខ ប្រទេសចម្រើន។"*

ពិជិតបានអានអត្ថបទមួយអំពីប្រយោជន៍ នៃការអាន។ ពិជិត សរសេរប្រយោគពេញមួយ។ *"ពលរដ្ឋពូកែត្រូវប្រតិបត្តិការអានជាប្រចាំ យ៉ាងតិចមួយម៉ោងក្នុងមួយថ្ងៃ។"* ប្រយោគទាំងពីររបស់សុធារី និងពិជិត ត្រូវបិទលើក្តារខៀនបញ្ញត្តិ។

ការរៀនពុំមែនចប់ត្រឹមបិទបញ្ញត្តិលើក្តារខៀនក្នុងបន្ទប់រៀនទេ។ អ្នកគ្រូ លោកគ្រូ អាចបង្កើតសៀវភៅបញ្ញត្តិមួយ សម្រាប់ប្រចាំឆ្នាំ និងផ្សព្វផ្សាយដល់ឪពុកម្តាយសិស្ស និងក្នុងពិធីជួបជុំតំណាងសហគមន៍ និងមាតាបិតា ក្នុងសាលារៀនដែរ។

លំនាំសកម្មភាព២ ៖ កាតបញ្ញត្តិ

រូបភាព៣៤. ឧទាហរណ៍ សិក្សាបញ្ញត្តិ ៖ ជំនឿ




ប្រភព ៖ សម្រួលពី Erickson, Lanning, & French, (2017)

របកគំហើញនៃការស្រាវជ្រាវរបស់ Wissman, Rawson, & Pyc (2012) ពន្យល់ថា សកម្មភាពរៀនដោយប្រើកាត សរសេរជាប្រយោគ ឬពាក្យ ទាញការចាប់អារម្មណ៍ដល់សិស្សច្រើន។ លើសពីនេះទៀត សិស្សងាយដាក់តាមកាបូប

ដៃ និងដកមើលពេលទំនេរ។ ដូច្នេះ ជាទម្លាប់ អ្នកគ្រូ លោកគ្រូគួរឱ្យសិស្សម្នាក់ៗ កាត់ក្រដាសជាកាត (ទំហំ ១០ស.ម x ៥ស.ម) ៤ ឬ៥ សន្លឹកក្នុងមួយម៉ោងសិក្សា។ ជាទម្លាប់ អ្នកគ្រូ លោកគ្រូអាចដាក់កិច្ចការផ្ទះ ឬការងារក្នុងថ្នាក់ក៏បាន អ្នកគ្រូ លោកគ្រូឱ្យសិស្ស ៖

- សរសេរប្រយោគពេញជាគំនិតទូទៅ លើក្រដាសកាត
- សរសេរបញ្ញត្តិ ប្រធានបទ និងអង្គហេតុ លើក្រដាស
- ចែករំលែកកាតបញ្ញត្តិទៅមិត្តភក្តិក្នុងថ្នាក់ពីរឬបីនាក់ឱ្យអាន
- កែលម្អ និងពន្យល់អំពីប្រធានបទ បញ្ញត្តិ និងអង្គហេតុ ក្នុងកាត

យុទ្ធវិធី០៣ ៖ សហការដើម្បីការរៀន

ក្នុងការរស់នៅ ធ្វើការ និងរៀនបន្ត មនុស្សត្រូវសហការជាមួយមនុស្ស និងធម្មជាតិ។ ការសហការសំដៅដាំបណ្តុះទម្លាប់ និងឥរិយាបថសិស្សអំពីការធ្វើការជាក្រុម ឱ្យតម្លៃចំពោះនានាភាព ភាពផ្សេងគ្នា ពហុភាពនៃគំនិត និងទទួលយកការសម្រេចចិត្តរួម។ ការសហការក្នុងថ្នាក់រៀន និងក្រៅថ្នាក់ ជួយសិស្ស និងគ្រូបង្រៀនឱ្យគិតរកគំនិតសម្បូរបែប ឬពង្រីកវិសាលភាពនៃគំនិត សម្រាប់ដំណើរការរៀនរួមគ្នា។ អ្នកគ្រូ លោកគ្រូ អាចដឹកនាំសិស្សឱ្យអនុវត្តសកម្មភាពមួយចំនួន ដើម្បីបណ្តុះចិត្តសហការ ៖

- បង្កើតក្រុមពិភាក្សា មាន៤ឬ៥នាក់
- ជ្រើសរើសបញ្ញត្តិមួយ (ពីតារាងបញ្ញត្តិ ប្រសិនបើមាន)
- រក ឬបង្កើតបញ្ញត្តិមួយ ពីការអានអត្ថបទ
- អនុញ្ញាតឱ្យសមាជិកមួយនាក់ៗ ធ្វើការផ្សេងគ្នា រកអង្គហេតុ
- ផ្តល់ឱកាសឱ្យសិស្សពិភាក្សាដើម្បីសម្រេចយកអង្គហេតុរួម
- អនុញ្ញាតឱ្យសិស្សបង្ហាញលទ្ធផលពិភាក្សាក្រុម និងកែលម្អ

យុទ្ធវិធី០៤ ៖ ពិភាក្សាដើម្បីការរៀន

ពាក្យជាបញ្ញត្តិ និងប្រធានបទស្រង់ចេញពីអត្ថបទមេរៀន មានបង្កប់គំនិត និងអង្គហេតុច្រើន សម្រាប់ការគិត និងរៀនបន្ត។ ដូច្នេះ គ្រូបង្រៀនគួរតែផ្តល់ឱកាសឱ្យសិស្សប្រតិបត្តិសមត្ថភាពគិតរបស់ខ្លួន តាមកម្លាំងនៃចិត្ត ដើម្បីចូល

រួមពិភាក្សា។ ដើម្បីឱ្យដំណើរការពិភាក្សាសកម្ម និងចូលរួមសិស្ស (គិតទាំងសិស្សមានតម្រូវការពិសេសស) អ្នកគ្រូ លោកគ្រូគួរអនុវត្តសកម្មភាព ដូចជា ៖

- បង្កើតក្រុមតូច កុំឱ្យលើស៥នាក់ក្នុងមួយក្រុម
- សិស្សជ្រើសរើសប្រធានបទ ឬបញ្ញត្តិមកពិភាក្សាក្នុងក្រុម
- បង្កើតសំណួរសម្រាប់ការពិភាក្សាលើប្រធានបទ និងបញ្ញត្តិ
- សមាជិកមួយនាក់ៗ ត្រូវរកអង្គហេតុសម្រាប់ខ្លួនឯង
- ចែករំលែកគំនិតក្នុងក្រុម ដោយមានទាំងអង្គហេតុ និងបញ្ញត្តិ
- អនុញ្ញាតឱ្យសិស្សឡើងបង្ហាញលទ្ធផលនៃការពិភាក្សាក្រុម។

យុទ្ធវិធី០៥ ៖ វែកញែកគំនិតដើម្បីការរៀន

យុវវ័យក្នុងយុគឧស្សាហកម្ម៤.០សម្បូរព័ត៌មានណាស់។ ការវែកញែកគំនិតជាដំណើរការរៀនមួយជួយអភិវឌ្ឍបំណិនច្រើនបែបច្រើនយ៉ាង។ ដំណើរការវែកញែកគំនិត ជាទម្រង់សរសេរ និងនិយាយ អាចអនុវត្តក្នុង និងក្រៅថ្នាក់។ ដូច្នេះ គ្រូបង្រៀនដឹកនាំសិស្សឱ្យមានការវែកញែកគំនិត។ ដំណើរការវែកញែកគំនិតជួយសិស្សអភិវឌ្ឍបំណិន ដូចជា សង្កប្បបំណិន ឬបំណិនគិត សរសេរនិយាយសាធារណៈ បំណិនប្រមូល វិភាគ និងសំយោគព័ត៌មាន។ ដំណើរការវែកញែកគំនិតបង្រៀនសិស្សឱ្យបង្កើនទំនុកចិត្តចំពោះខ្លួនឯង។ ដំណើរការវែកញែកគំនិតជួយសិស្សអភិវឌ្ឍបំណិនជាច្រើន ដូចជា សហការ បំណិនស្តាប់ និងអានគំនិតអ្នកដទៃ។ គ្រូបង្រៀនអាចដឹកនាំសិស្សអនុវត្តសកម្មភាពមួយចំនួន ៖

- ដាក់ប្រធានបទ ឬបញ្ញត្តិ ឱ្យសិស្សត្រៀមជជែកគ្នា តាមក្រុម
- ជ្រើសរើសគណៈកម្មការ៤ ឬ៥នាក់វាយតម្លៃការវែកញែកគំនិត
- គ្រូបង្រៀនត្រូវកំណត់និទ្ទេសបទ (លក្ខខណ្ឌដាក់ពិន្ទុ)
- ក្រុមមួយជ្រើសយកគំនិតជំទាស់ និងមួយទៀតយកគំនិតស្រប
- តំណាងក្រុមឡើងវែកញែកគំនិតជាមួយតំណាងក្រុមមួយទៀត
- ជួយគាំទ្រគំនិតរបស់ក្រុមខ្លួន និងជំទាស់ជាមួយក្រុមមួយទៀត

បន្តអនុវត្តសកម្មភាពបែបនេះប្រហែលបីឬបួនដុំ និងរាល់សប្តាហ៍ សិស្សនឹងមានភាពច្បាស់លាស់អំពីការអនុវត្តសកម្មភាព ដើម្បីពង្រីកបំណិនវែកញែកគំនិតជាពុំខាន និងចែករំលែកដល់សិស្សដទៃផងដែរ។

យុទ្ធវិធី០៦ ៖ ស្តាប់ដើម្បីការរៀន

ការតម្រៀបគំនិតដើម្បីនិយាយឱ្យអ្នកស្តាប់ងាយយល់ និងទទួលយកគំនិតថ្មី ពុំមែនជាការងាយស្រួលទេ។ សិស្សរៀនយឺត រៀនខ្សោយ ឬសិស្សអៀន សិស្សខ្សោយខាងការនិយាយ កាន់តែពិបាកថែមទៀត។ ដូច្នេះ គ្រូបង្រៀនគួរសាកល្បងឱ្យសិស្សរៀនយឺត រៀនខ្សោយ ឬសិស្សអៀន សិស្សខ្សោយទំនាក់ទំនងខាងនិយាយ ប្រាប់អំពីគោលគំនិតមួយ តាមអារម្មណ៍ ល្បឿននៃការគិត ការតម្រៀបគំនិតរបស់សិស្ស។ គ្រូបង្រៀន ឬសិស្សក្នុងថ្នាក់ពុំត្រូវកាត់សម្តីសិស្សដទៃទេ។

របកគំហើញនៃការស្រាវជ្រាវរបស់ Roth & Lee (2006) និង Carter, Ferzli, & Wiebe (2007) បានបញ្ជាក់ថា ក្នុងថ្នាក់រៀន គ្រូបង្រៀននិងសិស្សដទៃច្រើនខ្វះការអត់ធ្មត់ក្នុងការស្តាប់ គិត និយាយ បញ្ចេញគំនិតរបស់សិស្សរៀនខ្សោយ សិស្សរៀនយឺត ឬសិស្សមានតម្រូវការពិសេសឱ្យចប់សេចក្តី ទោះខុសឬត្រូវក្តី។ ទម្លាប់អនុញ្ញាតឱ្យសិស្ស ជាពិសេសសិស្សខ្សោយ រៀនយឺត សិស្សខ្សោយខាងបញ្ចេញគំនិតតាមការនិយាយ និងសិស្សអៀនឡើងនិយាយបញ្ចេញគំនិត ជួយអភិវឌ្ឍបំណិនទំនាក់ទំនង និងទំនុកចិត្ត។ លើសពីនេះទៀត សិស្សផ្សេងក៏អភិវឌ្ឍបំណិនស្តាប់ សហការ និងទម្លាប់យោគយល់ និងទទួលយកគំនិតផ្សេងៗគ្នាដែរ។

លទ្ធផលនៃការស្តាប់គំនិតសិស្ស គឺលើកទឹកចិត្តសិស្ស ជាពិសេសសិស្សរៀនខ្សោយ សិស្សរៀនយឺត និងសិស្សខ្សោយបញ្ញា ចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀន និងមានទំនុកចិត្តលើខ្លួនឯង ក្នុងការបញ្ចេញគំនិត និងការនិយាយ។

បញ្ហាប្រឈមរបស់គ្រូបង្រៀនត្រង់ថា ប្រសិនបើទុកពេលឱ្យសិស្សខ្សោយនិយាយយឺត និងចាំស្តាប់រហូតចប់ គឺបង្រៀនមិនចប់មេរៀន។ Tomlinson (1999) លើកអារម្មណ៍សោកស្តាយថា គ្រូបង្រៀនគិតអំពីការបញ្ចប់មេរៀនទៅតាមទំព័រដោយភ្លេចគិតថា សិស្សមិនបានរៀន មិនបានទទួលវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដូចកំណត់ក្នុងកម្មវិធីសិក្សា។ ការបារម្ភនេះជាបញ្ហាធំ និងជារោគនៃការអប់រំ ឬជំងឺនៃដំណើរការរៀន និងបង្រៀន។ ដូច្នេះ ការផ្តល់ឱកាសឱ្យសិស្សខ្សោយ ឬសិស្សរៀនយឺត និយាយអំពីគំនិតរបស់ខ្លួនទាមទារឱ្យសិស្សក្នុងថ្នាក់ទាំងអស់ចូលរួមក្នុងសកម្មភាពជាចាំបាច់។

១. សិស្សទី១និយាយថា ៖ ប្តូរទម្លាប់អាក្រក់មួយ ពីបញ្ចាំគ្នាទៅជួយគ្នា ត្រូវចាប់ផ្តើម ដោយក្រោកពីដំណេកឱ្យទៀងទាត់ជាប្រចាំ នៅម៉ោង៥.០០ព្រឹកកុំបង្អង់ និងចាប់ផ្តើមអានសៀវភៅកន្លះម៉ោង

២. សិស្សទី២និយាយថា ៖ រៀនងាយចាំពីការអាន យើងត្រូវប្តូរទម្លាប់ពីអានមិនបានកត់ត្រា ទៅទម្លាប់កត់ត្រា ឬស្រង់ប្រយោគជាគំនិតទូទៅដាក់ក្រដាស ឬទូរស័ព្ទ

៣. សិស្សទី៣និយាយថា ៖ មួយថ្ងៃបានជួយម្តាយលាងចាន គឺសប្បាយចិត្តបំផុត។

ដើម្បីធានាឱ្យដំណើរការរៀន និងការដឹកនាំការរៀន ប្រកបដោយការចូលរួមពីសិស្សគ្រប់ប្រភេទ អ្នកគ្រូ លោកគ្រូអាចអនុវត្តសកម្មភាពមួយចំនួន ៖

- អនុញ្ញាតឱ្យសិស្សរៀនយឺត រៀនខ្សោយ ឬសិស្សមានតម្រូវការពិសេស ២ ឬ ៣នាក់ និយាយគំនិតទូទៅអ្វីមួយ ម្តងម្នាក់ៗ ដូចឧទាហរណ៍ខាងលើ
- សិស្សផ្សេងកត់ត្រាគំនិតទូទៅ លើក្រដាស
- សិស្សផ្សេងកំណត់រកបញ្ញត្តិ និងប្រធានបទ ចេញពីគំនិតទូទៅ
- ហៅសិស្ស៤ ឬ ៥នាក់ឡើងសរសេរគំនិតទូទៅលើក្តារខៀន
- ហៅសិស្ស៤ ឬ៥នាក់ឡើងសរសេរពាក្យជាបញ្ញត្តិ និងប្រធានបទ
- គ្រូបង្រៀនសំយោគ ដោយញែកឱ្យដាច់រវាងពាក្យជាប្រធានបទ និងបញ្ញត្តិ

យុទ្ធវិធី០៧ ៖ អានដើម្បីការរៀន

ទម្លាប់អានសៀវភៅ ឬអត្ថបទថ្មីៗរបស់គ្រូបង្រៀន ជាចលករនាំចិត្តសិស្សឱ្យចង់អាន។ សិស្សចម្រាញ់យកចំណេះដឹង វិជ្ជា បំណិន និងទម្លាប់ពីគ្រូបង្រៀន ពីសៀវភៅ និងពីមិត្តភក្តិ។ ការស្រាវជ្រាវជាច្រើន បានរកឃើញថា គ្រូបង្រៀនដែលមានទម្លាប់អានសៀវភៅច្រើន បណ្តុះទម្លាប់សិស្សឱ្យអានសៀវភៅច្រើនផងដែរ (Roth & Lee, 2006)។

ពាក្យស្លោកខ្មែរបុរាណច្រើននិយាយថា “អានច្រើនចម្រើនវិជ្ជា”។ ពាក្យស្លោកនេះ បញ្ជាក់ថា ការអាន គឺពង្រីកសាខានៃចំណេះដឹងសម្រាប់ការងារ រៀន

បន្ត និងជីវិតល្អប្រសើរ។ ទម្លាប់មួយចំនួនដែលគ្រូបង្រៀនគួរ ចែករំលែកជាមួយសិស្សសម្រាប់ការអានមកពីផ្ទះ ៖

- ប្រាប់ចំណងជើងសៀវភៅឬចំណងជើងអត្ថបទដែលបានអាន
- ប្រាប់គោលគំនិត តែមួយឬពីរចំណុចបានពីសៀវភៅឬអត្ថបទដែលបានអាន
- ហៅសិស្សមួយនាក់ ឬពីរនាក់ដែលបានអានអត្ថបទ ឬ សៀវភៅថ្មី ប្រាប់ចំណងជើងនៃសៀវភៅ ឬអត្ថបទដែលសិស្សបានអាន
- ហៅសិស្សឱ្យប្រាប់គោលគំនិតមួយ ឬពីរបានពីសៀវភៅឬអត្ថបទ។

ឧទាហរណ៍ សុធារី អានសៀវភៅមួយក្បាលមានចំណងជើងថា "**ស្គាល់ប្រវត្តិសាស្ត្រច្បាស់ ស្គាល់អនាគតច្បាស់**"។ អត្ថបទមានគំនិតទូទៅមួយគួរចងចាំ និងយកទៅប្រតិបត្តិក្នុងជីវិត *"ការដឹកនាំប្រកបដោយក្ដីស្រឡាញ់ និងមេត្រីភាពចំពោះពលរដ្ឋគ្រប់ៗរូប ជាយានបង្កើតសុខជូនពលរដ្ឋ និងចម្រើនប្រទេស។"*

គ្រូបង្រៀនហៅសុធារីអានគំនិតទូទៅមួយ សរសេរជាប្រយោគគួរចងចាំ **"ក្ដីស្រឡាញ់ និងមេត្រីភាពជាយាននាំមនុស្សឱ្យជោគជ័យ។"**

ប្រសិនបើមានសិស្សណាម្នាក់ទៀតបានអានអត្ថបទនេះដែរ និងអាចរកគំនិតទូទៅមួយខុសពីនេះ គ្រូបង្រៀនឱ្យសិស្សនោះឡើងចែករំលែកផងដែរ។ អ្នកគ្រូ លោកគ្រូប្រមាណអំពីអនាគតបន្តិចមើល។ ប្រសិនបើមួយថ្ងៃ មានសិស្សពីរនាក់ធ្វើបែបនេះ ក្នុងមួយសប្ដាហ៍ដំបូង និងមួយខែដំបូង ៖

- តើក្នុងសប្ដាហ៍ក្រោយ ឬខែក្រោយ មានសិស្សផ្សេងទៀត ស្វែងរកការអានអត្ថបទមកចែករំលែកដែរឬទេ?
- តើអាចមានសិស្សផ្សេងបង្កើតគំនិតច្នៃប្រឌិតផ្សេងទៀតដែរឬទេ?

សមិទ្ធផលរបស់សិស្សមិនត្រូវចប់ត្រឹមបិទ ឬតាំងក្នុងថ្នាក់រៀនទេ។ គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀនគួរចងក្រងកម្រងស្នាដៃសិស្ស សម្រាប់ផ្សព្វផ្សាយ ក្នុងពិធីនានាក្នុងសាលារៀន និងក្នុងសហគមន៍។

យុទ្ធវិធី០៨៖ សរសេរដើម្បីការរៀន

លំនាំសកម្មភាព១៖ ចែករំលែកការអានតាមសំណេរ

របកគំហើញនៃការស្រាវជ្រាវរបស់ Carter, Ferzli, & Wiebe (2007) ពន្យល់ថា ការសរសេរជាដំណើរការមួយ រៀបចំគំនិតក្នុងទម្រង់សរសេរឱ្យមានរចនាសម្ព័ន្ធ និងបណ្ដុះទម្លាប់គិតរបស់សិស្ស។ ដំណើរការសរសេរជួយសិស្សឱ្យអភិវឌ្ឍបំណិនរកព័ត៌មាន ឬអង្គហេតុពីច្រើនប្រភព។ សិស្សបណ្ដុះទម្លាប់សរសេរចេញពីថ្នាក់រៀនដែលមានគ្រូបង្រៀនដឹកនាំការសរសេរជាប្រចាំ។ គ្រូបង្រៀនកុំគួរខ្វល់អំពីការសរសេរវែងអន្លាយពេក។ គ្រូបង្រៀនផ្ដល់ឱកាសឱ្យសិស្សជ្រើសរើសពាក្យគន្លឹះជាប្រធានបទ និងបញ្ញត្តិមួយ។ បន្ទាប់មក លោកគ្រូអ្នកគ្រូឱ្យសិស្សសរសេរប្រយោគពេញលេញចេញជាគំនិតទូទៅ។ ប្រយោគសរសេរនេះអាចឱ្យអ្នកអានយល់ខ្លះ អ្នកអានខ្លះមិនយល់។

ការរៀនពិតប្រាកដនឹងកើតឡើង ប្រសិនបើសិស្សមានឱកាសសរសេរគំនិតទូទៅ ឬគោលគំនិតជាប្រយោគ។ សិស្សនឹងបានរៀនបំណិនច្រើន ប្រសិនបើសិស្សបានចែករំលែកប្រយោគសរសេរនោះជាមួយមិត្តរួមថ្នាក់ និងគ្រូបង្រៀន។

គ្រូបង្រៀនលែងបារម្ភអំពីការដែលសិស្សមកអង្គុយក្នុងថ្នាក់រៀន និងមិនបានរៀនទៀតហើយ។ សិស្សនឹងអភិវឌ្ឍបំណិនជាច្រើន តាមរយៈការសរសេរបន្តិចបន្តួច ជាប្រយោគពេញលេញបញ្ជាក់អំពីគំនិតទូទៅ ស្រង់ពាក្យជាបញ្ញត្តិពាក្យជាប្រធានបទ។ ទម្លាប់ដែលគ្រូបង្រៀនគួរចែករំលែកជាមួយសិស្ស ដូចជា ៖

- សរសេរចំណងជើងសៀវភៅ ចំណងជើងអត្ថបទ
- បិទលើក្ដារខៀនបញ្ញត្តិ ឬក្ដារខៀនព័ត៌មាន
- ឱ្យសិស្សស្រង់ពាក្យជាប្រធានបទ ឬបញ្ញត្តិមួយលើក្រដាសកាត
- ឱ្យសិស្សបិទក្រដាសកាតលើក្ដារខៀនព័ត៌មាន ឬក្ដារខៀនបញ្ញត្តិ
- ឱ្យសិស្សសរសេរជាប្រយោគដោយប្រើពាក្យជាបញ្ញត្តិ ប្រធានបទ
- សរសេរគំនិតទូទៅមួយឬពីរ និងបិទលើក្ដារខៀន
- កុំទើសសិស្ស ចំពោះការជ្រើសរើសប្រភេទក្រដាសសរសេរ
- ក្រដាសសរសេរ ខ្នាតតូច ទំហំប្រហែល១០x ២០សង់ទីម៉ែត្រ។

ឧទាហរណ៍ សុធារី អានអត្ថបទមួយដែលមានចំណងជើងថា "ស្គាល់ប្រវត្តិសាស្ត្រច្បាស់ ស្គាល់អនាគតច្បាស់"។ អត្ថបទមានចំណុចគោលមួយគួរចងចាំ និងប្រតិបត្តិក្នុងជីវិត គឺ*ក្រោកពីដំណេកម៉ោង៥.០០ ព្រឹកជាប្រចាំ បណ្ដុះចិត្តអច្ឆរិយៈនៃភាពជោគជ័យសម្រាប់ជីវិត។*

អ្នកគ្រូ លោកគ្រូអាចស្រមៃ ឬប្រមាណអំពីអនាគត៥៩វិនាទី។ ប្រសិនបើមួយថ្ងៃមានសិស្សតែពីរនាក់ធ្វើបែបនេះ។

- តើផលនឹងរីកធំប៉ុនណា សម្បូរបែបយ៉ាងណា ក្នុងមួយសប្ដាហ៍ដំបូង និងមួយខែដំបូង?
- ក្នុងមួយ ពីរ ឬបីសប្ដាហ៍ក្រោយ ឬមួយខែ ឬពីរខែក្រោយ នឹងមានសិស្សផ្សេងទៀត ស្វែងរកការអានអត្ថបទថ្មី ឬសៀវភៅថ្មីមកចែករំលែកក្នុងថ្នាក់ដែរឬទេ?
- តើអាចមានសិស្សផ្សេងបង្កើតគំនិតច្នៃប្រឌិតផ្សេងទៀតដើម្បីចែករំលែកក្នុងថ្នាក់ ឬក្នុងសាលារៀនដែរឬទេ?

លំនាំសកម្មភាព២៖ ចម្លងសំណេរដើម្បីការរៀន

អត្ថបទអំណានត្រូវមានពាក្យគន្លឹះ ខ្លឹមសារ តួលេខ បញ្ញត្តិ ឬគោលគំនិត។ ការផ្ដល់ឱកាសឱ្យសិស្សខ្សោយ សិស្សរៀនយឺត និងសិស្សទាំងអស់ចម្លងពាក្យជាបញ្ញត្តិ និងប្រធានបទ និងគោលគំនិត ឬគំនិតទូទៅ លើក្រដាសសន្លឹកតូច ឬចូលសៀវភៅសំណេរ គឺដាំបណ្ដុះទម្លាប់សរសេរ។ លោកគ្រូ អ្នកគ្រូត្រូវចៀសវាងការដាក់ទណ្ឌកម្មចំពោះសិស្សមិនបានសរសេរ។

ការបារម្ភរបស់គ្រូបង្រៀន គឺភ័យខ្លាចសិស្សសរសេរលើកូនក្រដាសបានមួយភ្លែតហើយបោះចោល ហើយសិស្សងាយភ្លេច។ ជាគ្រូបង្រៀន យើងមានបទពិសោធរៀនយូរឆ្នាំហើយ។ តើក្រោយពីបានចម្លងចូលសៀវភៅសំណេរ តើអ្នកគ្រូ លោកគ្រូបានរំឭកអ្វីខ្លះពីសៀវភៅសំណេរ និងញឹកញាប់ប៉ុនណា?

ដូច្នេះ គ្រូបង្រៀនកុំគួរភ័យរឿងសិស្សចម្លងដាក់សៀវភៅ ឬក្រដាស ឱ្យតែសិស្សបានចម្លង និងបង្ហាញលទ្ធផលចម្លងដល់គ្រូបង្រៀន និងចែករំលែកលទ្ធផលចម្លងឱ្យសិស្សក្នុងថ្នាក់បានអាន និងផ្ដល់យោបល់សម្រាប់កែលម្អជាការប្រសើរបំផុត។ ទម្លាប់ដែលគ្រូបង្រៀនគួរដឹកនាំសិស្សឱ្យប្រតិបត្តិ ៖

- បែងចែកសិស្សឱ្យអានអត្ថបទតាមកថាខណ្ឌ ដោយដាក់លេខរៀងតាមកថាខណ្ឌ
- សិស្សស្រង់ប្រយោគជាគំនិតទូទៅ ឬគោលគំនិតរបស់អ្នកនិពន្ធ
- សិស្សរកពាក្យជាបញ្ញត្តិ និងប្រធានបទ
- អនុញ្ញាតឱ្យសិស្សរកដៃគូ និងចែករំលែកគំនិតអំពីបញ្ញត្តិ ក្នុងគំនិតទូទៅ និងគោលគំនិត។

លំនាំសកម្មភាព៣៖ សង្ខេបដើម្បីការរៀន

ការសង្ខេបអត្ថបទជាការគិតកម្រិតខ្ពស់ ប៉ុន្តែគ្រូបង្រៀនកុំគួរបារម្ភអំពីការសង្ខេបអត្ថបទវែងៗ។ ការចាប់ផ្តើមដោយឱ្យសិស្សម្នាក់ជ្រើសរើសកថាខណ្ឌណាមួយ និងសរសេរតាមកម្រិតចាំ និងយល់របស់សិស្ស។

ថ្នាក់រៀនមិនថានៅជនបទ ឬទីក្រុង នៅកម្ពុជាឬប្រទេសផ្សេង តែងមានសិស្សចម្រុះសមត្ថភាព។ ថ្នាក់រៀនក្នុងគ្រប់បរិបទតែងមានសិស្ស មានសមត្ថភាពគិតកម្រិតខ្ពស់ សិស្សខ្ជិលគិត សិស្សខ្លះឱ្យគិតឈឺក្បាល សិស្សមកអង្គុយក្នុងថ្នាក់មានតែខ្លួនអត់មានព្រលឹងមករៀន។ គ្រូបង្រៀនកុំខ្វល់ចង់បានលទ្ធផលសរសេរច្រើន ឬសរសេរវែង។ ប្រសិនបើសិស្សខ្សោយ រៀនយឺត ឬខ្ជិល បានសរសេរមួយបន្ទាត់ឬក៏មួយពាក្យ ជាការចូលរួមក្នុងសកម្មភាពថ្នាក់រៀនដែរ។

គ្រូបង្រៀនត្រូវបត់បែន ទន់ភ្លន់ និងចេះលើកទឹកចិត្តសិស្សខ្ជិល ឬសិស្សខ្សោយ ឬសិស្សរៀនយឺតឱ្យសរសេរតាមអារម្មណ៍ និងសមត្ថភាព។ គ្រូបង្រៀនត្រូវចេះសរសើរ និងលើកទឹកចិត្តសិស្សរៀនយឺត ខ្សោយ ខ្ជិល ឬមានតម្រូវការពិសេសចូលរួម ក្នុងដំណើរការរៀន។

លំនាំសកម្មភាព៤៖ សរសេរតាមការយល់

ការបង្កើតកាលិកបត្រថ្នាក់រៀន (សារព័ត៌មានចេញដោយទៀងទាត់ប្រចាំថ្នាក់រៀន ឬប្រចាំមុខវិជ្ជា) ជាប្រយោជន៍ដល់ការអភិវឌ្ឍបំណិនសរសេរ។ ការរៀនមុខវិជ្ជាសិក្សាសង្គម ជាពិសេសប្រវត្តិវិទ្យា ត្រូវការឱ្យសិស្សអាន និងសរសេរច្រើន។ គ្រូបង្រៀនត្រូវបង្កើតឱកាសឱ្យសិស្សបានសរសេរអត្ថបទខ្លីៗ និងបោះពុម្ពក្នុងកាលិកបត្រថ្នាក់រៀន។ អត្ថបទត្រូវសរសេរដោយសិស្ស និងត្រូវកែសម្រួល

ឬកែលម្អដោយសិស្សគ្នាឯង។ គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន ត្រូវចងក្រងជាប្រចាំឱ្យបានមួយលេខ យ៉ាងតិច ក្នុងមួយត្រីមាស។

ការសរសេរអត្ថបទខ្លីបែបនេះ ត្រូវសរសេរដោយដៃផ្ទាល់ កុំបារម្ភរឿងគុណភាពនៃអត្ថបទ អក្ខរាវិរុទ្ធ ឬវេយ្យាករណ៍ច្រើនពេក និងសំណេរស្អាតពេក។ ការបារម្ភធំបំផុតរបស់គ្រូបង្រៀន ឱ្យតែសិស្សបានសរសេរ ទោះបីជាអានយល់ខ្លះមិនយល់ខ្លះក៏ដោយ។ ការដាំបណ្ដុះទម្លាប់សរសេរនេះ ជាការពិបាកសម្រាប់គ្រូបង្រៀនណាស់ ជាពិសេសជាមួយសិស្សរៀនខ្សោយ រៀនយឺត និងខ្ជិលអាន។

គ្រូបង្រៀនកុំបារម្ភថា សិស្សប៉ុន្មាននាក់បានសរសេរ។ គ្រូបង្រៀនគួរបារម្ភរឿងយកស្នាដៃសរសេររបស់សិស្សណាម្នាក់ ឬពីរនាក់ ឬច្រើននាក់ដែលបានចូលរួមសរសេរ មកចងក្រង និងផ្សព្វផ្សាយ។ ការផ្សព្វផ្សាយកាលិកបត្ររបស់សិស្សអាចធ្វើក្នុងពិធីជួបជុំមាតាបិតាជាមួយគ្រូបង្រៀន ឬកម្មវិធីសាលារៀន។ គណៈគ្រប់គ្រងសាលារៀន គួរដំកល់កាលិកបត្ររបស់សិស្សក្នុងបណ្ណាល័យ ជាការលើកទឹកចិត្តឱ្យសិស្សចូលរួមក្នុងការសរសេរ និងដាំបណ្ដុះទម្លាប់សរសេរ។ ក្នុងកម្មវិធីបើកបវេសនាកាល នាយកគួរហៅសិស្សដែលមានអត្ថបទល្អ ឡើងអានក្នុងពិធី និងផ្ដល់កិត្តិយសចំពោះការប្រឹងប្រែង។

ឧទាហរណ៍ ភូមិស្រុករបស់អ្នកគ្រូ លោកគ្រូ មានកន្លែងប្រវត្តិសាស្ត្រពីរកន្លែងដែលអ្នកភូមិស្គាល់គ្រប់ៗគ្នា។ គ្រូបង្រៀនគួរផ្ដល់ឱកាសឱ្យសិស្សសរសេរប្រវត្តិនៃទីកន្លែងប្រវត្តិសាស្ត្រណាមួយ។ ឧទាហរណ៍ ភូមិត្នោតមានអ្នកតាដើមពោធិ៍មួយកន្លែង និងមានរឿងនិទានអំពីដើមពោធិ៍ និងភូមិ។ ប្រសិនបើមួយខែមានសិស្សពីរនាក់សរសេរពីរអត្ថបទខ្លីៗ ក្នុងមួយឆមាស គ្រូបង្រៀនអាចបានអត្ថបទ ៣ ឬ៤ សម្រាប់ចងក្រងយ៉ាងសាមញ្ញ។ ដើម្បីលើកទឹកចិត្តសិស្ស គ្រូបង្រៀនគួររក្សាស្នាដៃសិស្សក្នុងបណ្ណាល័យ និងផ្សព្វផ្សាយក្នុងពិធីរបស់សាលារៀន ដើម្បីធានាឱ្យសិស្សថ្នាក់ផ្សេងបានអានផង។

យុទ្ធវិធី០៩៖ បង្រៀនដើម្បីការរៀន

ការឡើងបង្រៀនសិស្សគ្នាឯង ជាការត្រៀមចិត្តរៀនបន្ត និងអភិវឌ្ឍបទពិសោធ បំណិន និងវិជ្ជាជាច្រើនបានពីការបង្រៀន។ ការអនុញ្ញាតឱ្យសិស្សឡើងបង្រៀនសិស្សមិត្តរួមថ្នាក់ គឺដាំបណ្ដុះបទពិសោធ បំណិន និងវិជ្ជា ដូចជា ប្រាស្រ័យ

មនុស្ស និយាយសាធារណៈ រៀបចំគំនិត និងបណ្ដុះភាពក្លាហាន។ល។ បំណិនដំបូងទទួលបានពីការឡើងបង្រៀន គឺបណ្ដុះទម្លាប់គិត ឆ្លុះ បង្កើតសំណួរ និងស្វែងការពន្យល់នូវគំនិត ឬបញ្ញត្តិដែលត្រូវឡើងបង្រៀន។

ការផ្ដល់ឱកាសឱ្យសិស្សឡើងបង្រៀនក្នុងក្រុមតូចជាវិធានមួយ ជួយបង្កើតបរិយាកាសរៀនជាមួយគ្នារវាងសិស្ស និងសិស្ស គិតទាំងសិស្សរៀនខ្សោយ សិស្សរៀនយឺត សិស្សមានតម្រូវការពិសេស និងសិស្សរៀនលឿន។ ការស្រាវជ្រាវជាច្រើនរកឃើញថា សិស្សដែលខ្លាចគ្រូ ច្រើនមិនហ៊ានសួរគ្រូបង្រៀននូវចម្ងល់របស់ខ្លួនទេ ប៉ុន្តែហ៊ានសួរមិត្តរួមថ្នាក់។

គ្រូបង្រៀនគួរសាកល្បងសង្កេតសកម្មភាពសិស្សមួយក្រុម។ សកម្មភាពសិស្សលេងល្បែងលោតអន្ទាក់ក្រៅថ្នាក់។ តើសិស្សសហការគ្នាបានល្អឬទេ? ប្រសិនបើអ្នកគ្រូ លោកគ្រូសង្កេតឱ្យហ្មត់ចត់ និងឱ្យបានយូរ អ្នកគ្រូ លោកគ្រូនឹងមើលឃើញថា សមត្ថភាពគិត និងលោតរបស់សិស្សម្នាក់ៗ គឺខុសៗគ្នា ប៉ុន្តែហេតុអ្វីបានជាសិស្សលេងជាមួយគ្នាកើត ទុកចិត្តគ្នា និងសប្បាយជាមួយគ្នា?

ថ្នាក់រៀននីមួយៗតែងមានសិស្សដែលមានកម្រិតសមត្ថភាព លក្ខខណ្ឌ និងស្ថានភាពខុសគ្នា។ សមត្ថភាពគិត ឆ្លុះ សួរ និងនិយាយគឺខុសគ្នា។ សិស្សមានចរិយា កាយវិការ ស្ថានភាពសេដ្ឋកិច្ច និងសង្គម ទម្លាប់រៀន និងវិធីរៀនខុសៗគ្នា។

គ្រូបង្រៀនត្រូវចាំថា សិស្សមកអង្គុយរៀនក្នុងថ្នាក់ ក្នុងសាលា មានចេតនាដូចគ្នា។ សិស្សមករៀន ត្រូវការបណ្ដុះវិជ្ជាសម្បទា បំណិនសម្បទា ចរិយាសម្បទា គុណតម្លៃមនុស្ស និងចរណៃមនុស្ស សម្រាប់យកទៅប្រើក្នុងជីវភាពប្រចាំថ្ងៃ និងដើម្បីភាពរីកចម្រើនដូចគ្នា។

ដូច្នេះ គ្រូបង្រៀនត្រូវលើកទឹកចិត្ត ឬបង្កលក្ខណៈងាយស្រួលឱ្យសិស្សគិតឆ្លុះ រកព័ត៌មាន ឬចំណេះដឹងរួមគ្នា ជជែកគ្នា ធ្វើផែនការរួមគ្នា ចែករំលែកការចងចាំនូវចំណេះដឹង បទពិសោធ និងបំណិនជាមួយគ្នា ក្នុងថ្នាក់និងក្រៅថ្នាក់។

គ្រូបង្រៀន ត្រូវបង្កបរិយាកាសថ្នាក់រៀនមួយ ប្រកបដោយការចូលរួមគ្រប់ប្រភេទសិស្ស។ គ្រូបង្រៀនផ្ដល់ឱកាសឱ្យសិស្សនិងសិស្សមានអន្តរទំនាក់ទំនងជាមួយគ្នា។ ក្នុងការរៀន និងបង្រៀនគ្នាទៅវិញទៅមក សិស្សគ្រប់ៗរូបក្លាយជាម្ចាស់នៃដំណោះស្រាយបញ្ហា។ សិស្សចូលរួមក្នុងដំណើរការបង្រៀន បានគិត ឆ្លុះ

បង្កើតសំណួរ សួរ និងអនុវត្តសកម្មភាពរៀនរួមគ្នា។ ជាលទ្ធផល សិស្សគ្រប់ប្រភេទនឹងចូលរួម និងមានឱកាសអភិវឌ្ឍបទពិសោធ បំណិន និងវិជ្ជា ដូចជា ប្រាស្រ័យមនុស្ស និយាយសាធារណៈ រៀបចំគំនិត និងបណ្ដុះភាពក្លាហានសម្រាប់ប្រើក្នុងជីវភាពប្រចាំថ្ងៃ និងការងារក្នុងពេលអនាគត។

ការអនុញ្ញាតឱ្យសិស្សឡើងបង្រៀន គឺ ពុំមែនឱ្យសិស្សម្នាក់ឡើងបង្រៀនសិស្សមួយថ្នាក់ជំនួសគ្រូបង្រៀនទាំងស្រុង ទៅលើមេរៀនមួយទេ។ គ្រូបង្រៀនត្រូវអនុញ្ញាតឱ្យបង្រៀនសិស្សក្នុងក្រុមតូចៗ។ ឧទាហរណ៍ បញ្ញត្តិមួយផ្ដោតលើការច្នៃប្រឌិតក្នុងសម័យហ្វូណន។ គ្រូបង្រៀនគួរផ្ដល់ឱកាសឱ្យឡើងបង្រៀនក្នុងក្រុមជាមួយគ្នាអំពីគំនិតច្នៃប្រឌិត។ ក្នុងដំណើរការរៀននៅថ្ងៃបន្តបន្ទាប់ទៀត គ្រូបង្រៀនគួរប្រាប់សិស្សរៀនខ្សោយ រៀនយឺត ឬមានតម្រូវការពិសេស ឱ្យត្រៀមមេរៀនណាមួយដើម្បីឡើងបង្រៀន ក្នុងក្រុម។

របកគំហើញនៃការស្រាវជ្រាវមួយរបស់ Education Research Council (2018) បញ្ជាក់ថា បញ្ហាប្រឈមក្នុងបរិបទអប់រំកម្ពុជាបច្ចុប្បន្ន គឺ សិស្សភាគច្រើនមិនបានអានមេរៀនមុន។ គ្រូបង្រៀនពិបាករកសិស្សឱ្យឡើងបង្រៀន។ ការអនុញ្ញាតឱ្យសិស្សឡើងបង្រៀន អាចមិនចប់មេរៀន តាមកម្មវិធីកំណត់។ ការអនុញ្ញាតសិស្សឱ្យឡើងបង្រៀន ត្រូវប្រឈមនឹងអធិការកិច្ចគ្រប់កម្រិត។ ជួនកាលនាយក ឬគណៈគ្រប់គ្រងសាលាមិនអនុញ្ញាត។ បញ្ហាប្រឈមត្រូវតែមាន។ គ្រូបង្រៀនដែលពូកែ គឺដឹកនាំការផ្លាស់ប្ដូរទៅរកវិជ្ជាមាន និងសេចក្ដីល្អ។

យុទ្ធវិធី១០ ៖ ពន្យល់ដើម្បីការរៀន

ដើម្បីបញ្ជាក់អំពីការយល់លើគំនិតទូទៅ គំនិតធំ គោលគំនិត ទ្រឹស្ដី ឬគោលការណ៍មួយ សិស្សត្រូវមានសមត្ថភាពពន្យល់។ ក្នុងដំណើរការរៀន ឬវិទ្យាសាស្ត្រនៃការពន្យល់ សិស្សត្រូវមានសមត្ថភាពច្រើនបែបច្រើនយ៉ាង ដូចជា ៖

- សម្លឹងជ្រុងផ្សេងនៃគំនិត
- ផ្ដល់ហេតុផលគ្រប់គ្រាន់ទៅលើគំនិត
- ឆ្លល់បន្ត
- ភ្ជាប់គំនិតថ្មីជាមួយនឹងបទពិសោធ ឬការធ្លាប់ដឹង
- ស្រាយភាពស្មុគស្មាញមកសាមញ្ញ

- បង្ហាញចំណុចស្នូល ឬភាពចាំបាច់
- ពន្យល់ដោយមានឧទាហរណ៍ និងភស្តុតាង
- ពណ៌នាតាមលក្ខខណ្ឌផ្សេង។

ការពន្យល់ហេតុផលជាទូទៅ ត្រូវបានចែកជាពីរប្រភេទគឺ ១. អនុមានរួម និង ២. អនុមានញែក ៖

១. អនុមានរួមជាបំណិនប្រចាំជីវិត

- ការពន្យល់ហេតុផលតាមអនុមានរួម សំដៅលើកហេតុផលទៅរកសេចក្ដីសន្និមួយឈានទៅរកការបញ្ជាក់សេចក្ដីពិតចំពោះការសន្និនោះ
- ការពន្យល់តាមអនុមានរួម ត្រូវផ្ដើមចេញពីក្រោម និងប្រៀបធៀបអង្គហេតុ និងវិធានអំពីធាតុលម្អិតពាក់ព័ន្ធ
- ការពន្យល់តាមអនុមានរួម ត្រូវធានាឱ្យមានសរណភាព និងសង្គតិភាព ដោយចាប់ផ្ដើមពីអង្គហេតុមួយរហូតដល់អង្គហេតុក្រោយៗ
- ការពន្យល់តាមអនុមានរួម សំដៅកាត់បន្ថយភាពមិនទាន់ច្បាស់
- ការពន្យល់តាមអនុមានរួម លើសពីការវិភាគទិន្នន័យ
- ការពន្យល់តាមអនុមានរួម សំដៅសំយោគទិន្នន័យ ដើម្បីទាញរកទំនាក់ទំនងនៃទិន្នន័យ
- ការពន្យល់តាមអនុមានរួមសន្និដ្ឋានទៅរកសេចក្ដីពិតនៃការសន្និ

សរុបជារួម ការសន្និដ្ឋាននៃគំនិតរបស់មនុស្សម្នាក់ ឬមួយក្រុមតែងមានមនុស្សផ្សេងជំទាស់។ ដូច្នេះ ដំណើរការពន្យល់ហេតុផលតាមអនុមានរួម ធានាឱ្យការសន្និដ្ឋាន ឬការសន្និ មានភាពខ្លាំង និងមានអង្គហេតុសម្បូរបែប។

ឧទាហរណ៍ លោកគ្រូ អ្នកគ្រូស្រាវជ្រាវរកភស្តុតាង អំពីភាពចម្រុងចម្រើននៃប្រទេស ឬជាតិសាសន៍ចំនួន២០ ពីប្រវត្តិសាស្ត្រច្រើនសម័យកាល។ ភស្តុតាងប្រវត្តិសាស្ត្របញ្ជាក់ថា ប្រទេសទី១ ប្រទេសទី២ ............... ដល់ប្រទេសទី១៤ សុទ្ធតែមានមេដឹកនាំប្រទេស ប្រកបដោយចិត្តមេត្តា និងក្ដីស្រឡាញ់ ជាប្រទេសជឿនលឿន។ ដូច្នេះ អ្នកគ្រូ លោកគ្រូ អាចសន្និដ្ឋានថា ប្រទេសទាំង២០ដែលមានមេដឹកនាំប្រកបដោយចិត្តមេត្តា និងក្ដីស្រឡាញ់ ជាប្រទេសជឿនលឿន។

ការពន្យល់ហេតុផលតាមអនុមានរួមអាចមានអង្គហេតុមិនទាន់គ្រប់គ្រាន់ ដូច្នេះ សេចក្ដីសន្និដ្ឋាន ក៏អាចពិត ឬមិនពិតដែរ។

ឧទាហរណ៍ ខ្ញុំហូបប្រហុក ខ្ញុំក្អក និងរលាកបំពង់ក នៅលើកទី១ លើកទី២ និង លើកទី៣ ដូច្នេះ ខ្ញុំសន្និដ្ឋានថា ខ្ញុំអាឡែស៊ីជាមួយប្រហុក។ លើកក្រោយ ខ្ញុំឈប់ហូបប្រហុកហើយ។

ឧទាហរណ៍ ពេលព្រឹកលើកទី១ លើកទី២ និងលើកទី៣ ខ្ញុំចេញពីផ្ទះនៅម៉ោង៦.៣០នាទីទៅសាលារៀន ខ្ញុំទៅដល់សាលារៀនយឺត១០នាទី។ ដូច្នេះ ចាប់ពីថ្ងៃស្អែក ខ្ញុំត្រូវចេញពីផ្ទះទៅធ្វើការ នៅម៉ោង ៦.០០ ឬ៦.១៥ នាទីព្រឹក។

លោកគ្រូ អ្នកគ្រូអាចអនុវត្តយុទ្ធវិធីនេះជាមួយសិស្សគ្រប់ប្រភេទ និងគ្រប់កម្រិតថ្នាក់។ មនុស្សត្រូវការបំណិនពន្យល់ ដោយប្រើអនុមានរួម ក្នុងគ្រប់មេរៀន និងជីវិតប្រចាំថ្ងៃ។ ទម្លាប់ដែលលោកគ្រូ អ្នកគ្រូគួរដឹកនាំសិស្សឱ្យរៀន តាមការពន្យល់ដោយប្រើអនុមានរួម ដូចជា ៖

- គ្រូបង្រៀនជ្រើសរើសគោលគំនិត ឬគំនិតទូទៅមួយ
- ចែកសិស្សជាក្រុម ក្នុងមួយក្រុមមាន ៤ឬ៥នាក់
- មួយក្រុមៗរកអង្គហេតុយ៉ាងតិចបីបញ្ជាក់សេចក្ដីពិតនៃគំនិតទូទៅ
- គ្រូបង្រៀនឬសិស្សសរុបអង្គហេតុ បញ្ជាក់សេចក្ដីពិតនៃគំនិតទូទៅ
- ក្រោយឯកភាពគ្នា គ្រូបង្រៀន និងសិស្សបង្កើតបញ្ញត្តិមួយឬច្រើន

២. អនុមានញែកជាបំណិនប្រចាំជីវិត

ការពន្យល់តាមអនុមានញែក ជាទម្រង់វិចារមូលដ្ឋានមួយ សម្រាប់ផ្ដល់ហេតុ និងផល ដោយផ្ដើមចេញពីធំមកតូច ពីគោលការណ៍ ឬទ្រឹស្ដីមកអង្គហេតុ។

- ការពន្យល់ហេតុផលតាមអនុមានញែក សំដៅដល់ការពិសោធសេចក្ដីសន្និដ្ឋាន ឬការសន្មតិនៃទ្រឹស្ដីមួយ ឬគោលការណ៍មួយ
- ការពន្យល់ហេតុ និងផលតាមអនុមានញែក សំដៅដល់ការទស្សន៍ទាយផលនៃការសង្កេត ឬផលនៃព្រឹត្តិការណ៍ដែលនឹងកើតឡើង។

សរុបជារួម ការសន្និដ្ឋាននៃគំនិតរបស់មនុស្សម្នាក់ ឬមួយក្រុមតែងមានមនុស្សផ្សេងជំទាស់។ ដូច្នេះ ដំណើរការពន្យល់ហេតុផលតាមអនុមានញែកសំដៅធានារកភាពពិត និងភាពត្រឹមត្រូវនៃគោលការណ៍ ទ្រឹស្ដី ឬវិចារសន្និដ្ឋាន។

ឧទាហរណ៍ មនុស្សប្រកាន់ចិត្តចាគៈ ជាមនុស្សជោគជ័យ សម្បូរសម្ភារៈ និងសុខុមាលភាព។ មនុស្សប្រកាន់ចិត្តចាគៈ តែងគិតប្រយោជន៍សាធារណៈមុនប្រយោជន៍បុគ្គល និងបក្សពួក។ ដូច្នេះ គ្រូបង្រៀនគួរដឹកនាំសិស្សញែកគំនិតទូទៅមួយនេះ ក្នុងដំណើរការរៀន។

បញ្ហានៃការប្រើអនុមានញែក គឺមនុស្សឆាប់សន្និដ្ឋាន ដោយមានភស្តុតាងអង្គហេតុពីរបីមកពន្យល់ ឬរកអង្គហេតុមកពន្យល់ពុំទាន់គ្រប់គ្រាន់។ ឧទាហរណ៍ក្នុង១០០ឆ្នាំចុងក្រោយ ពិភពលោកប្រឈមនឹងវិបត្តិនៃការឆ្លងរោគឆ្លងមួយដងយ៉ាងតិច ក្នុងមួយទសវត្សរ៍។ ក្នុងទសវត្សរ៍ឆ្នាំ២០០០ ពិភពលោកកើតជំងឺឆ្លងមួយដង គឺជំងឺផ្តាសាយជ្រូក។ ក្នុងទសវត្សរ៍ឆ្នាំ២០១០ ពិភពលោកកើតជំងឺឆ្លងមួយដង គឺជំងឺអេបូឡា ជំងឺមើ (MEUR) ជំងឺផ្តាសាយបក្សី។ ក្នុងទសវត្សរ៍ឆ្នាំ២០២០ ពិភពលោកបានកើតជំងឺកូវីដ ១៩។

ការដឹកនាំការរៀន ដើម្បីដាំបណ្តុះសមត្ថភាពគិតដូចអ្នកវិទ្យាសាស្ត្រ ឬបំណិនគិតកម្រិតខ្ពស់ គ្រូបង្រៀនគួរបង្កើតយុទ្ធវិធីឱ្យបានច្រើនទៅតាមបរិបទ និងលក្ខខណ្ឌនៃសាលារៀន ថ្នាក់រៀន តម្រូវការ និងសមត្ថភាពរបស់សិស្ស។ តារាងខាងក្រោមគ្រាន់តែជាជម្រើសមួយចំនួន ដែលលោកគ្រូ អ្នកគ្រូ គួរពិចារណា។

យុទ្ធវិធី១១ ៖ យល់បញ្ហាដើម្បីការរៀន
យុទ្ធវិធី១២ ៖ ប្រើបទពិសោធដើម្បីការររៀន
យុទ្ធវិធី១៣ ៖ រកអង្គហេតុដើម្បីការររៀន
យុទ្ធវិធី១៤ ៖ ចែករំលែកដើម្បីការរៀន
យុទ្ធវិធី១៥ ៖ ឡើងសម្តែងដើម្បីការរៀន
យុទ្ធវិធី១៦ ៖ ស្រាវជ្រាវដើម្បីការបង្រៀន
យុទ្ធវិធី១៧ ៖ ប្រើបណ្ណាល័យដើម្បីការរៀន
យុទ្ធវិធី១៨ ៖ ពិសោធដើម្បីការរៀន
យុទ្ធវិធី១៩ ៖ សម្ភាសដើម្បីការរៀន
យុទ្ធវិធី២០ ៖ រកបញ្ញត្តិដើម្បីការរៀន
យុទ្ធវិធី២១ ៖ បង្កើតគម្រោងដើម្បីការរៀន
យុទ្ធវិធី២២ ៖ សង្កេតធម្មជាតិដើម្បីការរៀន

**ជំហាន០៣៖ វាយតម្លៃ**

ការវាយតម្លៃលទ្ធផលសិក្សារំពឹងទុក (វិជ្ជាសម្បទា បំណិនសម្បទា និង ចរិយាសម្បទាកំណត់ក្នុងកម្មវិធីសិក្សា) ជាដំណើរការនិរន្តរ៍សម្រាប់ប្រមូល វិភាគ និងឆ្លុះបញ្ចាំងភស្តុតាងអំពីកម្រិតនៃការទទួលវិជ្ជាសម្បទា បំណិនសម្បទា និង ចរិយាសម្បទារបស់សិស្ស។ ការវាយតម្លៃសំដៅរកព័ត៌មាន ទិន្នន័យ ឬភស្តុតាង ដើម្បីសន្និដ្ឋាន សម្រេចចិត្តអំពីដំណើរការរៀន និងការដឹកនាំការរៀន។ ការវាយតម្លៃសំដៅរកវិធី និងផ្តល់ធាតុចូល ដើម្បីជួយដល់ការកែលម្អដំណើរការរៀនរបស់សិស្ស និងដំណើរការបង្រៀនរបស់គ្រូ។ ការវាយតម្លៃសំដៅដល់ការពិនិត្យឡើងវិញលើទម្រង់ ទម្លាប់ និងវិធាននៃការគ្រប់គ្រងថ្នាក់រៀន និងប្រព័ន្ធអប់រំ។

ការវាយតម្លៃដើម្បីវាស់លទ្ធផលសិក្សារបស់សិស្ស តាមវិធីសាស្ត្រសិក្សាបញ្ញត្តិ និងបុច្ឆនសិក្សា សំដៅវាស់កម្រិតដឹង យល់ និងប្រតិបត្តិ។ ការវាយតម្លៃអាចប្រៀបប្រដូចនឹងការជិះកង់លើដងផ្លូវដែលមមាញឹកសម្បូរដោយរថយន្ត តូច ធំ ម៉ូតូ កង់ និងអ្នកថ្មើរជើង។ អ្នកគ្រូ លោកគ្រូ សាកល្បងកំណត់គោលដៅ មុនចេញដំណើរដោយម៉ូតូ។ តើអ្នកគ្រូ លោកគ្រូ បានគិតអំពីផ្លូវដែលត្រូវធ្វើដំណើរមុនឬទេ? តើអ្នកគ្រូ លោកគ្រូត្រូវគិតអំពីវត្ថុដែលត្រូវយកតាមខ្លួនឬទេ? ប្រសិនបើអ្នកគ្រូ លោកគ្រូចេញដំណើរដោយម៉ូតូ ប៉ុន្តែមិនដឹងទិសដៅ និងគោលដៅទៅណា តើអ្នកគ្រូ លោកគ្រូជ្រើសរើសផ្លូវណាដែលត្រូវទៅ?

ការរៀនក៏ដូចគ្នានឹងការជិះម៉ូតូធ្វើដំណើរដែរ។ គោលបំណងនៃមេរៀន ជាគោលដៅសម្រាប់អ្នកគ្រូ លោកគ្រូទៅឱ្យដល់ដូចបានរៀបរាប់ខាងលើ។ ដូច្នេះ ដើម្បីវាស់លទ្ធផលសិក្សារបស់សិស្ស កម្រិតមេរៀន អ្នកគ្រូ លោកគ្រូ ត្រូវជ្រើសយកវិធានវាយតម្លៃដើម្បីការរៀនបន្ត។ ការវាយតម្លៃដើម្បីការរៀនបន្តជាដំណើរការបន្តអត់ឈប់ ក្នុងការស្វែងយល់អំពីគុណផល និងលទ្ធផលសិក្សារបស់សិស្សក្នុងថ្នាក់ តាមកម្រិតនៃលទ្ធផលសិក្សាកំណត់ក្នុងមេរៀន។ ការវាយតម្លៃនេះសំដៅលើកកម្ពស់គុណភាព នៃការរៀនរបស់សិស្សក្នុងថ្នាក់។ ការវាយតម្លៃដើម្បីការរៀន សំដៅផ្តល់ភស្តុតាងសម្រាប់កែលម្អទម្លាប់ និងសកម្មភាពរបស់សិស្ស និងការបង្រៀនរបស់គ្រូ ។

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងថ្នាក់រៀន ត្រូវរៀបចំរួមគ្នាដោយគ្រូ សិស្សនិងមិត្តរួមថ្នាក់។ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងថ្នាក់រៀន ជាធាតុដ៏សំខាន់មួយនៃដំណើរការលើកកម្ពស់ ឬផ្លាស់ប្តូរឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពរៀន និងបង្រៀនក្នុងថ្នាក់ និងក្រៅថ្នាក់។ ការវាយតម្លៃលទ្ធផលសិក្សាដើម្បីការរៀនបន្ត ផ្តោតការយកចិត្តទុកដាក់លើលទ្ធផលសិក្សាតាមមេរៀន និងតាមជំពូក ធ្វើមិនផ្លូវការ ឬធ្វើផ្លូវការ ធ្វើបន្តជាប្រចាំ។

គ្រូបង្រៀនអាចធ្វើភ្លាមៗ ដើម្បីតាមដានឥរិយាបថ ទម្លាប់ វិធី និងសកម្មភាពនៃការរៀនរបស់សិស្ស។ ការវាយតម្លៃភ្លាមៗ សំដៅផ្ទៀងផ្ទាត់លទ្ធផលនៃការបង្រៀនរបស់គ្រូឱ្យឆ្លើយតបនឹងលទ្ធផលសិក្សារំពឹងទុក កំណត់ក្នុងកម្មវិធីសិក្សា។ ការវាយតម្លៃជួយគ្រូបង្រៀនច្រើន ៖

- ជួយគ្រូបង្រៀនឱ្យស្គាល់បរិបទសិស្សច្បាស់
- ជួយគ្រូបង្រៀនប្រើព័ត៌មានអំពីការចងចាំ ការយល់ និងឥរិយាបថ
- ជួយគ្រូបង្រៀនរកព័ត៌មានពីលទ្ធផលសិក្សា តាមប្រភេទសិស្ស
- ជួយគ្រូឱ្យស្គាល់ច្បាស់អំពីឥរិយាបថ ទម្លាប់ និងវិធីរៀនរបស់សិស្ស
- ជួយសិស្សកែលម្អឥរិយាបថ ទម្លាប់ និងវិធីរៀនក្នុង និងក្រៅថ្នាក់
- ជួយគ្រូឱ្យធ្វើផែនការរយៈពេលខ្លី ក្នុងការកែលម្អឥរិយាបថ ទម្លាប់ និងវិធីរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ
- ជួយគ្រូឱ្យកែលម្អទម្លាប់ និងវិធីបង្រៀន ក្នុងថ្នាក់ និងក្រៅថ្នាក់។

ការប្រើគោលការណ៍ពង្រីកពុទ្ធិរបស់WEBB ក្នុងដំណើរការវាយតម្លៃការសិក្សា និងលទ្ធផលសិក្សារបស់សិស្ស មានភាពចាំបាច់មួយដែរ។ ទោះបីជាយ៉ាងណា គោលវិធី និងវិធីសាស្រ្តវាយតម្លៃការសិក្សា និងលទ្ធផលសិក្សាមានច្រើន។ សៀវភៅនេះជ្រើសយកគោលការណ៍របស់ WEBB (1997)។

អ្នកស្រាវជ្រាវ WEBB (1997) បានបង្កើតគោលការណ៍មួយឱ្យសិស្សរៀនដើម្បីពង្រីក ឬបន្ថែមជម្រៅនៃពុទ្ធិ និងយកទៅប្រើការតាមកាល និងបរិបទ។ ជម្រៅនៃពុទ្ធិសំដៅដល់ការយល់ និងការប្រតិបត្តិផលបានពីការរៀននៅសាលារៀន ក្នុងការងារ ជីវភាព និងការរៀនបន្ត។ គោលបំណងចម្បងនៃគោលការណ៍ពង្រីកពុទ្ធិនេះ សំដៅដល់ការផ្គូផ្គងការរៀនរបស់សិស្សជាមួយស្តង់ដាអប់រំដែល

បានកំណត់តាមប្រព័ន្ធអប់រំ និងការវាយតម្លៃលើលទ្ធផលសិក្សារបស់សិស្ស តាមស្តង់ដានៃកម្មវិធីសិក្សា។

គោលការណ៍របស់ WEBB (1997) បង្កើតឡើងដោយសន្មតថា ការរៀនត្រូវចាប់ផ្តើមពីការរំឭកការចងចាំ និងពង្រីកការចងចាំឱ្យបានជាផលសម្រេច សម្រាប់ប្រើការ រស់នៅ ធ្វើការ និងរៀនបន្ត។ ក្រោយពីការចាំខ្លឹមសារ សិស្សត្រូវអភិវឌ្ឍបំណិនច្រើន និងជាបន្តបន្ទាប់ ដោយប្រើបញ្ញត្តិជាគោល សម្រាប់ការគិតពីកម្រិតទាបដល់កម្រិតខ្ពស់ និងភ្ជាប់ជាមួយតម្រូវការជាក់ស្តែង។

ជាទូទៅ មនុស្សតែងបន្ថែមជម្រៅនៃការគិត និងពង្រីកវិសាលភាពនៃគំនិតឱ្យសម្បូរបែប ដោយប្រើបទពិសោធ និងការស្រាវជ្រាវបន្ថែម។ ដូច្នេះ មនុស្សត្រូវគិតបែបយុទ្ធសាស្ត្រសម្រាប់យកទៅប្រើការតាមកាល និងបរិបទ។ មនុស្សពង្រីកវិសាលភាពនៃគំនិត និងបន្ថែមជម្រៅនៃការគិតក្នុងជំហានដំបូង មនុស្សពុំទាន់ឈានដល់ការគិតបែបយុទ្ធសាស្ត្ររយៈពេលវែងនៅឡើយទេ។

រូបភាព៣៥. គោលការណ៍ពង្រីកពុទ្ធិរបស់ WEBB




ប្រភព ៖ សម្រួលពី WEBB (1997)

ធាតុនៃកម្មវិធីសិក្សាតាមសាលារៀន មានកំណត់ភារកិច្ចមួយចំនួនដែលសិស្សត្រូវតែទន្ទេញចាំមាត់ មុនចាប់ផ្ដើមយល់ បន្ថែមជម្រៅនៃការគិត និងពង្រីកវិសាលភាពនៃគំនិត។ ដូច្នេះ សិស្សត្រូវតែរំឭក និងពង្រីកការចងចាំខ្លឹមសារមេរៀន តាមមុខវិជ្ជា។ ការរំឭក និងការចងចាំខ្លឹមសារមេរៀន គឺឋិតក្នុងកម្រិតព័ត៌មាន និងចំណេះដឹង ក្នុងរចនាសម្ព័ន្ធនៃពុទ្ធិ និងវិជ្ជានុក្រមប្លូម (Bloom, ១៩៥៧)។ សិស្សទទួលបានព័ត៌មាន និងចំណេះដឹង លើពាក្យគន្លឹះ និយមន័យ បញ្ញត្តិ នីតិវិធី ប្រធានបទ អង្គហេតុ និងព្រឹត្តិការណ៍។ គោលបំណងនៃការវាយតម្លៃកម្រិត១ សំដៅរំឭក និងពង្រីកការចងចាំរបស់សិស្សកម្រិតព័ត៌មាន និងចំណេះដឹង។ សិស្សចាំព័ត៌មាន និងចំណេះដឹង ក្នុងអត្ថបទ ផែនទី រូបភាព តារាង និងគំនូរ។ គ្រូបង្រៀន គួរប្រើ ១. ឧបករណ៍វាយតម្លៃ ២. យុទ្ធវិធីវាយតម្លៃ ៖

## ការវាយតម្លៃរំឭក និងពង្រឹការចងចាំ

| ឧបករណ៍វាយតម្លៃ | យុទ្ធវិធីវាយតម្លៃ |
|---|---|
| ▪ កម្រងសំណួរពហុចម្លើយ | ▪ គូស និងសរសេរចម្លើយ ជាបុគ្គល<br>▪ គូស និងសរសេរចម្លើយ ជាដៃគូ |
| ▪ តារាងផ្គូផ្គងពាក្យ និង អត្ថាធិប្បាយ ឬពន្យល់ | ▪ គូស និងសរសេរចម្លើយ ជាបុគ្គល<br>▪ គូស និងសរសេរចម្លើយ ជាដៃគូ |
| ▪ តារាងសំណួរសម្រាប់ តេស្តសរសេរ | ▪ សរសេរចម្លើយ ជាបុគ្គល<br>▪ សរសេរចម្លើយ ជាដៃគូ |
| ▪ តារាងសំណួរផ្ទាល់មាត់ | ▪ សំណួរផ្ទាល់មាត់ ជាបុគ្គល<br>▪ សំណួរផ្ទាល់មាត់ ជាដៃគូ |
| ▪ ក្រដាសបំពេញចន្លោះ | ▪ សំណួរសរសេរ ជាបុគ្គល |
| ▪ អត្ថបទខ្លីសរសេរមានកំហុស | ▪ សំណួរសរសេរ ជាបុគ្គល<br>▪ សំណួរសរសេរ ជាដៃគូ |
| ▪ ប្រយោគខុសមានកំហុស | ▪ សំណួរសរសេរ ជាបុគ្គល<br>▪ សំណួរសរសេរ ជាដៃគូ |
| ▪ តារាងខ្លឹមសារចងចាំ | ▪ សំណួរផ្ទាល់មាត់ ជាបុគ្គល<br>▪ សំណួរផ្ទាល់មាត់ ជាដៃគូ |
| ▪ តារាងព័ត៌មាន អង្គហេតុ សម្រាប់ផ្ទៀងផ្ទាត់ | ▪ សំណួរផ្ទាល់មាត់ ជាបុគ្គល<br>▪ សរសេរសង្ខេប ជាបុគ្គល |
| ▪ ក្រដាសកិច្ចការផ្ទះ | ▪ សរសេរអត្ថបទខ្លី ជាបុគ្គល |
| ▪ ផែនទីគំនិត (បញ្ញត្តិ ប្រធានបទ និងអង្គហេតុ) | ▪ សរសេរជាបុគ្គល គូ ឬក្រុម |
| ▪ កាតបញ្ញត្តិ ប្រធានបទ និងអង្គហេតុ | ▪ សរសេរជាបុគ្គល គូ ឬក្រុម |
| ▪ អ័ក្សកាល និងព្រឹត្តិការណ៍ | ▪ សរសេរជាបុគ្គល គូឬក្រុម |

កម្រិត២ ៖ បំណិន និងបញ្ញត្តិ

កម្មវិធីសិក្សា និងដំណើរការដឹកនាំការរៀនក្នុងថ្នាក់ សំដៅអភិវឌ្ឍ និងប្រើបំណិន និងបញ្ញត្តិរៀនពីសាលា ក្នុងជីវភាព ការងារ និងរៀនបន្ត។ សិស្សរៀនពីគ្រូបង្រៀន និងសៀវភៅ ត្រូវការទាំងរូបវត្ថុ និងនាមវត្ថុសម្រាប់ការលូតលាស់ផ្នែកឃ្លាំងនៃពុទ្ធិ និងកាយ។ រូបវត្ថុមានអាហារ និងនាមវត្ថុជាការលើកទឹកចិត្ត។ កុមារ និងយុវវ័យលូតលាស់ដូចដំណាំស្រូវ។ ការរៀន និងបង្រៀនដើម្បីឱ្យសិស្សបានផលទៅជាវុឌ្ឍិវិជ្ជា វុឌ្ឍិបំណិន និងវុឌ្ឍិចរិយា (បញ្ញាចម្រុងចម្រើន) ប្រៀបប្រដូចនឹងការដាំស្រូវ ដើម្បីទទួលផល។ ផលបានពីការរៀន គឺអ្នករៀន និងគ្រូបង្រៀនត្រូវបណ្ដុះ ដាំ ពង្រីក និងផ្សារភ្ជាប់វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា កំណត់ក្នុងកម្មវិធីសិក្សា សៀវភៅសិក្សា ទៅតម្រូវការសង្គម។

ដំណើរការរៀនតាមវិធីសាស្ត្រសិក្សាបញ្ញត្តិ សំដៅអភិវឌ្ឍសមត្ថភាពគិតរបស់សិស្សពីកម្រិតរំពូក និងពង្រីកការចងចាំ។ បន្ទាប់មក សិស្សត្រូវញែកចំណេះដឹង និងវិជ្ជា សម្រាប់ប្រើការតាមកាល បរិបទ និងលក្ខខណ្ឌ។ ការញែកចំណេះដឹង និងវិជ្ជា កើតឡើងក្នុងចិត្តសិស្ស លុះណាសិស្សយល់ស៊ីជម្រៅលើបញ្ញត្តិ និងភ្ជាប់បញ្ញត្តិសម្រាប់ប្រើការ ក្នុងជីវភាព ការងារ និងការរៀនបន្ត។

គ្រូបង្រៀនត្រូវដឹកនាំសិស្សឱ្យចូលរួម និងរៀនគិតកម្រិតខ្ពស់។ ការគិតកម្រិតខ្ពស់ សំដៅដល់ការពង្រីកសមត្ថភាពគិតរបស់សិស្សឱ្យចេះប្រៀបធៀបមនុស្ស ទីកន្លែង ព្រឹត្តិការណ៍ ទ្រឹស្ដី គោលការណ៍ នីតិវិធី បញ្ញត្តិ និងនិយមន័យ។ ការគិតកម្រិតខ្ពស់ សំដៅដល់ការប្រែក្លាយព័ត៌មាន ពីទម្រង់មួយទៅទម្រង់មួយទៀត និងងាយយល់ជាងទម្រង់ដើម។ ការគិតកម្រិតខ្ពស់សំដៅដល់ការចាត់ថ្នាក់និងប្រភេទនៃមនុស្ស ទីកន្លែង ទ្រឹស្ដី ព្រឹត្តិការណ៍ គោលការណ៍ នីតិវិធី និងនិយមន័យឱ្យស្របតាមគោល និងបរិបទ។ ការគិតកម្រិតខ្ពស់សំដៅដល់ការពន្យល់គោលគំនិត ឬគំនិតទូទៅ ដោយមានអង្គហេតុសម្បូរបែប។ ការពន្យល់ត្រូវប្រើទាំងអនុមានរួម និងអនុមានញែក។

លើសពីនេះទៀត សិស្សដែលបានអភិវឌ្ឍបំណិនសម្បូរបែប និងយល់ស៊ីជម្រៅលើបញ្ញត្តិ សិស្សនឹងក្លាយជាមនុស្សពូកែ។ មនុស្សពូកែអាចវិភាគស្ថានភាព រកឫសគល់ នៃបញ្ហា និងធាតុបង្កនៃបញ្ហា វាប់បរិមាណនៃឫសគល់ និងធាតុ

បង្កនៃបញ្ហា។ មនុស្សពូកែខាងស្រាយបញ្ហា គឺពូកែបំបែកធាតុ រាប់បរិមាណ ឬប្រភេទនៃឫសគល់នៃបញ្ហា និងប្រមាណទុកអំពីបញ្ហាប្រឈមអាចកើតឡើង។ មនុស្សពូកែខាងស្រាយបញ្ហា ពូកែកំណត់ និងជ្រើសរើសអាទិភាពនៃបញ្ហា និងដំណោះស្រាយ។ មនុស្សពូកែខាងស្រាយបញ្ហាពូកែសង្កេត តាមដាន និងវាយតម្លៃស្ថានភាព នៃដំណើរការស្រាយបញ្ហាគ្រប់ជំហាន។

**ការវាយតម្លៃបំណិន និងបញ្ញត្តិ**

| **ឧបករណ៍វាយតម្លៃ** | **យុទ្ធវិធីវាយតម្លៃ** |
|---|---|
| ▪ រូបភាព រូបគំនូរ រូបថត | ▪ សរសេរ ឬផ្ទាល់មាត់ ជាបុគ្គល<br>▪ សរសេរ ឬផ្ទាល់មាត់ ជាដៃគូ<br>▪ សរសេរ ឬផ្ទាល់មាត់ ជាក្រុម |
| ▪ ផែនទីគំនិត (បញ្ញត្តិ ប្រធានបទ និងអង្គហេតុ) | ▪ សរសេរ ឬផ្ទាល់មាត់ ជាបុគ្គល<br>▪ សរសេរ ឬផ្ទាល់មាត់ ជាដៃគូ<br>▪ សរសេរ ឬផ្ទាល់មាត់ ជាក្រុម |
| ▪ អត្ថបទកាលិកបត្រ | ▪ សរសេរ ឬផ្ទាល់មាត់ ជាបុគ្គល<br>▪ សរសេរ ឬផ្ទាល់មាត់ ជាដៃគូ<br>▪ សរសេរ ឬផ្ទាល់មាត់ ជាក្រុម |
| ▪ អត្ថបទខ្លី ឬអត្ថបទវែង | ▪ សរសេរ ឬផ្ទាល់មាត់ ជាបុគ្គល<br>▪ សរសេរ ឬផ្ទាល់មាត់ ជាដៃគូ<br>▪ សរសេរ ឬផ្ទាល់មាត់ ជាក្រុម |
| ▪ កម្រងសំណួរសម្ភាសន៍ | ▪ សរសេរ ឬផ្ទាល់មាត់ ជាបុគ្គល<br>▪ សរសេរ ឬផ្ទាល់មាត់ ជាដៃគូ<br>▪ សរសេរ ឬផ្ទាល់មាត់ ជាក្រុម |
| ▪ អត្ថបទបំពេញចន្លោះ | ▪ សរសេរ ឬផ្ទាល់មាត់ ជាបុគ្គល/គូ |
| ▪ អត្ថបទសម្រាប់ឡើងបង្រៀន | ▪ សរសេរ និងផ្ទាល់មាត់ ជាបុគ្គល |
| ▪ អត្ថបទសរសេរក្នុងបណ្ដាញសង្គម | ▪ និយាយផ្ទាល់មាត់ ជាដៃគូ |

កម្រិត៣ ៖ គិតបែបយុទ្ធសាស្ត្ររយៈពេលខ្លី

កម្មវិធីសិក្សាគ្រប់កម្រិត សំដៅអភិវឌ្ឍសមត្ថភាពគិតកម្រិតខ្ពស់ ដល់សិស្ស។ មនុស្សពូកែសម្បូរដោយគំនិត មាននវកម្មគំនិត ឬមានសមត្ថភាពគិតកម្រិតខ្ពស់។ មនុស្សពូកែតែងមានច្រកចេញ សម្រាប់ស្រាយបញ្ហាច្រើនជំពូក។ គ្រូបង្រៀនពិតជាមានចេតនា បង្ហាត់សិស្សឱ្យចេះប្រើគំនិតសម្បូរបែប ដើម្បីបង្កើតបានផលិតផលថ្មី និងបែបច្នៃប្រឌិត។ សមត្ថភាពគិតបែបយុទ្ធសាស្ត្រ សំដៅដល់ការញែកបញ្ហាឱ្យល្អិតល្អន់ និងរាប់បរិមាណធាតុនៃបញ្ហា ប្រកបដោយហេតុផល។សមត្ថភាពគិតបែបយុទ្ធសាស្ត្រ សំដៅដល់វិជ្ជានុក្រម និងរចនាសម្ព័ន្ធនៃពុទ្ធិកម្រិតវិភាគ និងវាយតម្លៃ។ សមត្ថភាពគិតបែបយុទ្ធសាស្ត្រសំដៅដល់វិជ្ជាស្រាយបញ្ហា ក្នុងសង្គមជាក់ស្តែង ប្រកបដោយហេតុផល និងច្នៃប្រឌិត។ ការវាយតម្លៃកម្រិតនេះសំដៅវាស់សមត្ថភាពគិតកម្រិតខ្ពស់របស់សិស្ស ក្នុងការរកដំណោះស្រាយចំពោះបញ្ហាប្រកបដោយនវកម្មគំនិត។

**វាយតម្លៃសមត្ថភាពគិតបែបយុទ្ធសាស្ត្ររយៈពេលខ្លី**

| **ឧបករណ៍វាយតម្លៃ** | **យុទ្ធវិធីវាយតម្លៃ** |
|---|---|
| ▪ រូបភាព រូបគំនូរ រូបថត | ▪ សរសេរ ផ្ទាល់មាត់កម្រិតវាយតម្លៃ ជាបុគ្គល |
| ▪ ក្រាហ្វស្ថិតិ | ▪ សរសេរសង្ខេប កម្រិតវាយតម្លៃ ជាបុគ្គល |
| ▪ តារាងស្ថិតិ | ▪ សរសេរពន្យល់ កម្រិតវាយតម្លៃ ជាបុគ្គល |
| ▪ អត្ថបទកាលិកបត្រ | ▪ សរសេរអត្ថបទខ្លី កម្រិតវាយតម្លៃ ជាបុគ្គល |
| ▪ អត្ថបទវែង | ▪ សរសេរសង្ខេប កម្រិតវាយតម្លៃ ជាបុគ្គល |
| ▪ របាយការណ៍ | ▪ សរសេរសង្ខេប កម្រិតវាយតម្លៃ ជាបុគ្គល |
| ▪ កម្រងសំណួរសម្ភាសន៍ | ▪ សរសេរ បកស្រាយ កម្រិតវាយតម្លៃ ជាបុគ្គល |

កម្រិត៤ ៖ ពង្រីកវិសាលភាពនៃគំនិតយុទ្ធសាស្ត្រ

មាតាបិតា និងអណាព្យាបាលបញ្ជូនកូនទៅសាលារៀន តែងចង់ឱ្យកូនទទួលបានវិជ្ជាសម្រាប់ប្រើការ ក្នុងជីវភាពប្រចាំថ្ងៃ ការងារ និងរៀនបន្ត ប្រកបដោយនវកម្មគំនិត។ បំពេញចេតនានេះ សិស្សត្រូវមានសមត្ថភាពពង្រីកវិសាលភាពនៃគំនិតបែបយុទ្ធសាស្ត្រ ឬបន្ថែមជម្រៅនៃការគិត។ ដូច្នេះ សិស្សត្រូវអភិវឌ្ឍបំណិនសំយោគ និងសន្និដ្ឋានគំនិត។ បំណិនសំយោគ និងសន្និដ្ឋានគោលគំនិត ឬគំនិតធំ ប្រកបដោយភស្តុតាងវិទ្យាសាស្ត្រ។ បំណិនសំយោគជាផ្នែកមួយនៃវិជ្ជាស្រាវជ្រាវ។

**វាយតម្លៃសមត្ថភាពគិតបែបយុទ្ធសាស្ត្ររយៈពេលវែង**

| **ឧបករណ៍វាយតម្លៃ** | **យុទ្ធវិធីវាយតម្លៃ** |
|---|---|
| ▪ ផែនការ | ▪ សរសេរ ជាបុគ្គល គូ ឬក្រុម |
| ▪ គម្រោង | ▪ សរសេរ ជាបុគ្គល គូ ឬក្រុម |
| ▪ កំណាព្យ | ▪ សរសេរ ជាបុគ្គល គូ ឬក្រុម |
| ▪ ចម្រៀង | ▪ សរសេរ ជាបុគ្គល គូ ឬក្រុម |
| ▪ អត្ថបទសារព័ត៌មាន | ▪ សរសេរ ជាបុគ្គល គូ ឬក្រុម |
| ▪ រឿងនិទាន | ▪ សរសេរ ជាបុគ្គល គូ ឬក្រុម |
| ▪ អត្ថបទប្រវត្តិសាស្ត្រ | ▪ សរសេរ ជាបុគ្គល គូ ឬក្រុម |

# ឯកសារពិគ្រោះ


Jennifer M. Wood. (2015, 9 8). *The 13 Most Unflattering Revelations in the New Steve Jobs Documentary*. យកមកវិញពី Steve Jobs: The Man in the Machine explores the Apple mastermind's more controversial qualities.: https://www.esquire.com/entertainment/movies/a37752/steve-jobs-man-in-the-machine/

ACRLog. (2014, January 13). *https://acrlog.org/2014/01/13/tales-of-the-undead-learning-theories-the-learning-pyramid/comment-page-1/*. យកមកវិញពី www://acrlog.org/: https://acrlog.org/2014/01/13/tales-of-the-undead-learning-theories-the-learning-pyramid/comment-page-1/

Alberta Learning. (2004). *Focus on inquiry: a teacher's guide to implementing inquiry-based learning.* Alberta: Alberta Learning.

Alexander Weinbaum, David Allen, Tina Blythe, Catherine Simon, Steve Seidel, & Catherine Rubin. (2004). *Teaching as Inquiry. Asking hard questions to Improve Practice and Student Achievement .* New York: Teacher Collect Press.

Ali Abdi. (2014). The effect of inquiry-based learning methods on students'academic achivement in scicence course. *Universal Journal of Educational Research*, 37-41.

Andrew Redfern. (2015). *200+ strategies for outstanding teaching and learning.* New York: Routledge.

Asia Pacific University of Malaysia. (2019, March 9). *http://www.apu.edu.my/APU-industry-revolution-40.* យកមកវិញពី http://www.apu.edu.my: http://www.apu.edu.my/APU-industry-revolution-40

Asian Development Bank. (2015). *Cambodia addressing the skills gap: employment diagnostic study.* Minila: Asian Development Bank.

Association of Teacher Educators and Rowman & Littlefield Education. (2009). *Visions for Teacher Educators.* Plymouth, UK: Association of Teacher Educators and Rowman&Littlefield Education.

Australian Education Council. (2006, August 17). *A statement of learning for science*. យកមកវិញពី Australian Curriculum Web Site: www.curriculum.edu.au

Barak Rosenshine. (2010). *Principles of Instruction .* Paris: IBE UNESCO.

Benjamin Bloom. (1956). *Taxonomy of Educational Objectives: The Classification of Educational Goals.* London: BY DAVID McKAY COMPANY, INC.

Bernie Trilling, & Charles Fadel. (2009). *21st Century Skills: Learning for life in our times.* Washington DC.: JOSSY-BASS A Viley Imprint.

Bruce Joyce, & Mashar Wei. (2003). *Model of Teaching. Fith edition.*

Burma Tipitaka Association . (2020, May 5). *Dhammapada*. យកមកវិញពី Dhammapada: Verses and Stories: http://www.tipitaka.net/tipitaka/dhp/

Byron REESE . (2018). *The Forth Age: Smart Robbots, Conscious Computers and the Future of Humanity .* New York: ATRIA Books.

Cambridge Dictionary . (2020, 3 4). *About Principles* . យកមកវិញពី Cambridge Dictionary : https://dictionary.cambridge.org/dictionary/english/principle?q=principles

Cambridge Dictionary. (2020, 3 4). *About Theory*. យកមកវិញពី dictionary cambridge website: https://dictionary.cambridge.org/dictionary/english/theory

Cara Gormally, Peggy Brickman, Brittan Hallar, & Norris Armstrong. (2009). Effects of inquiry-based learning on students' science literacy skills and confidence. *International Journal for the Scholarship of Teaching and Learning*, 1-22.

Carol Ann Tomlinson . (1999). *The Differentiated Classroom: Responding to the Needs of All Learners.* Alexandria, VA: Association for Supervision and Curriculum Development.

Carol C Kuhlthau, Maniotes K Leslie, & Ann K Caspari. (2007). *Guided Inquiry: Learning in the 21st Century.* London: Libraries Unlimited.

Charles G Bonwell, & James A Eison. (1991). *Active Learning: Creating Excitement in the Classroom.* Wahsington, DC: George Washington University.

Chris Watkins, Eileen Carnell, & Caroline Lodge. (2007). *Effective Learning in Classroom.* London: Paul Chapman Publishing.

Chris Kyriacou. (2009). *Effective Teaching in Schools: Theory and Practice.* Cheltenham: Nelson Thornes .

Clare R Kilbane, & Natalie B Milman. (2014). *Teaching Models: Designing Instruction for 21st Century Learners.* New York: Pearson.

Common Core U.S. (2014). *Common Core Curriculum: United State History, Grades 3-5.* San Francisco,: Jossey-Bass.

Conrad Hughes, & Clementina Acedo. (2016). *Guiding Principles for Learning in the Twenty-first Century.* Geneva: UNESCO, IBE.

Crystal Morey. (2016, 01 22). *BLOG*. យកមកវិញពី www.teachingchannel.com: https://www.teachingchannel.com/blog/develop-conceptual-understanding-math

Darren Hardy. (2013). *The Compound Effect.* New York: Da Capo Press.

Donna Ignatavicius. (2017). *Teaching and Learning in a Concept-Based Nursing Curriculum: A How-To Best Practice Approach.* MA: Jones & Bartlett Learning.

Education Research Council. (2018). *Teaching history in Cambodia.* Phnom Penh: Education Research Review.

Eknath Easwaran. (2020). *The Bhagavad Gita for Daily Living.* New Delhi: Blue Mountain Center of Meditation.

F. MICHAEL CONNELLY. (2013). Joseph Schwab, curriculum, curriculum studies and educational reform. *JOURNAL OF CURRICULUM STUDIES*, 622–639.

Frances Trought. (2012). *Brilliant Employability Skills.* Londo: Pearson Education Limited.

George M Jacobs, Willy A Renandya, & Michael Power. (2016). *Simple, Powerful and Strategies for Student Centered Learning.* Switzerland: Springer Nature.

Gillian Kidman, & Niranjan Casinader. (2017). *Inquiry-Based Teaching and Learning across Disciplines. Comparative Theory Practice in Schools.* Melbourne, Australia: Springer Nature.

Grant Wiggins, & Jay McTighe. (2005). *Understanding by Design.* Alexandria: Association for Supervision and Curriculum Development.

Hilda Taba. (1962). *Curiculum and Development. Theory and Practice. .*

IAN WESTBURY. (2013). Reading Schwab's the 'Practical' as an invitation to a curriculum enquiry. *JOURNAL OF CURRICULUM STUDIES*, 640–651.

Ida Gran Andersen, & Simon Calmar Andersen. (2017). Student-Centered Instruction and Academic Achievement: Linking Mechanisms of Educational Inequality to Schools' Instructional Strategy. *British Journal of Sociology of Education*, 533-550.

ILO & World Bank. (2016). *Enhancing Employability.* Washington, DC: World Bank.

James M Lang. (2019). *Small Teaching: Everyday Lessons from the Science of Learning.* San Francisco: JOSSEY-BASS.

James M Magrini. (2018). *Plato's Socrates, Philosophy and Education.* Glen Ellyn, USA: Martino Publishing.

Jan Van Baren Nawrocka, & Sanne Dekker. (2018). Chapter 1. Guide for a project-inquiry based learning . ក្នុង *Scientific Breakroughs in the Classroom .*

Jane Krauss, & Suzie Boss. (2013). *Thinking Through PROJECT-BASED LEARNING. Guided Deeper Inquiry .* California: CORWIN .

Jean F. Giddens, & Debra P. Brady. (2007, February 01). *Journal of Nursing Education*. យកមកវិញពី Journal of Nursing Education Web site: http://www.harapnuik.org

Jean Foret Giddens, Mary Wright, & Irene Gray. (2012). Selecting concepts for a concept-based curriculum: application of a benchmark approach. *Journal of Nursing Education*.

Jeff Burt. (2016, 03 23). *Andy Grove Helped Make Intel the Dominant Chip Maker It Is Today*. យកមកវិញពី PC Hardware: https://www.eweek.com

John Adair. (2018). *Lessons in leadership: 12 key concepts .* London: Bloomsbury Business.

John Biggs , & Catherine Tang. (2011). *Teaching for Quality Learning.* London: Bell and Bain Ltd, Glasgow.

Julie Stern, Nathalie Lauriault, & Krista Ferraro. (2018). *Tools for Teaching Conceptual Understanding, Elementary .* London: Corwin.

Kathryn T Wissman, Katherine A Rawson, & Mary A Pyc. (2012). How and when do students use flashcards? *MEMORY*, 568-579.

Khmer Buddhism Institute . (1931). *Tripitaka.* Phnom Penh: Khmer Buddhism Institute .

Khmer Buddhism Institute. (1967). *Khmer Dictionary .* Phnom Penh: Khmer Buddhism Institute.

Killian Gidman, & Naranjan Casinader. (2017). *Inquiry-Based Teaching and Learning across Disciplines. Comparative Theory Practice in Schools.* Melbourne, Australia: Springer Nature.

LaVelle Hendricks, Sam Bore, Dean Aslinia, & Guy Morriss . (2013). The effects of anger on the brain and body. *NATIONAL FORUM JOURNAL OF COUNSELING AND ADDICTION*, 1-12.

Linda Darling-Hammond. (1999). *Teacher Quality and Student Achievement: A Review of State Policy Evidence.* Washington: Center for the Study of Teaching and Policy, University of Washington.

Linda Hale Goossen. (2002). *Classroom Questionning Strategies as Indicators of Inquiry-Based Science Instruction.* Michigan: Western Michigan University.

Lorin W Anderson, David R Krathwohl, & Peter W Airasian. (2001). *A Taxonomy for Learning, Teaching and Assessing: A revision of Bloom's Taxonomy of Educational Objectives .* New York: Addison Wesley Longman, Inc.

Louis Alfrieri, Patricia J Brooks, Naomi J Aldrich, & Tenenbaum R Harriet . (2011). Does Discovery-Based Instruction Enhance Learning? *Journal of Educational Psychology*, 1–18.

Lynn Erickson, & Lois A Lanning. (2014). *Transitioning to Concept-based curriculum and instruction: How to bring content and process together .* London: Corwin.

Lynn H Erickson. (2008). *String the Head, Heart, and Soul.* London: Corwin.

Lynn H. Erickson, Lois A. Lanning, & Rachel French. (2017). *Concept-Based Curriculum and Instruction for the Thinking Classroom.* London: Sage Publications, Inc.

M A Hayat. (2014). *Authophagy: Cancer, Other pathologies, inflamation, immunity, infection, and aging.* New York: Elsevier.

Mahnaz Moallem. (2019). Effects of problem-based learning on learning outcomes, knowledge acquisition, and high order thinking skills. ក្នុង Mahnaz Moallem, Woei Hung, & Nada Dabbagh, *The Wiley Handbook of Problem-based learning* (ទំព័រ 107-134). MA: John Wiley & Sons, Inc. .

Marc Morial. (2020). *Ten Leadership Lessons that help you inspire, unite and achieve.* New York: HarperCollins Leadership.

Margus Pedaste, Mario Maeots, Leo A Siiman, & Ton de Jong. (2015). Phases of inquiry-based learning: Definitions and the inquiry cycles . *Educational Research Review*, 47-61.

Marlene Scardamalia, & Carl Bereiter. (2006). *Knowledge Building: Theory, Pedagogy, and Technology.* New York:: Cambridge University Press.

Mary Boyd Ratzer , & Paige Jaeger. (2014). *RX for the Common Core: Toolkit for Implementing Inquiry Learning.* Oxford: Libraries Unlimited.

Mathematics Learning Study Committee. (2001). *Adding It UP: Helping children learn mathematics.* Washington, DC: National Academy Press.

Michael Carter, Miriam Ferzli, & Eric N Wiebe. (2007). Writing to Learn by Learning to Write in the Disciplines . *Journal of Business and Technical Communication*, 278-302.

Ministry of Education, Youth and Sport. (2018). *Congress Report.* Phnom Penh: Ministry of Education, Youth and Sport.

Ministry of Education, Youth and Sport. (2018). *Curriculum Details for Lower Secondary Education: History Subject.* Phnom Penh: Ministry of Education, Youth and Sport.

Ministry of Education, Youth and Sport. (2018). *National Assessment Grade 3.* Phnom Penh: Ministry of Education, Youth and Sport.

Mogens Niss. (2002, October 15). *http://www.math.chalmers.se/.* យកមកវិញពី Oct 15, 2002 : http://www.math.chalmers.se/Math/Grundutb/CTH/mve375/1112/docs/KOMkompetenser.pdf

Muavia Gallie, & James Keevy. (2014). *Standards Framework for Teachers and School Leaders.* London: Commonwealth Secretariat.

Nada Dabbagh. (2019). Effects of project-based learning on critical thinking skills. ក្នុង Mahnaz Moallem, Woei Hung, & Nada Dabbagh, *The Wiley Handbook of Problem-based learning* (ទំព័រ 135-156). MA: John Wiley & Sons,, Inc.

National Academy of Sciences . (2011). *A Framework for K-12 Science Education: Practices, Crosscutting Concepts, and Core Ideas.* Washington, D.C.: National Academies Press.

Norman L Webb. (1997). *Research Monograph No. 8: Criteria for Alignment of Expectations and Assessments in Mathematics and Science Education.* Washington, DC: Council of Chief State School Officers.

OECD. (2006). *21st Century Learning Environments.* Paris: OECD.

OECD. (2013). *Teachers for the 21st Century: Using evaluation to improve teaching.* Paris: OECD.

OECD. (2018). *Education in Cambodia: Findings from Cambodia's experience in PISA for Development.* Paris: OECD.

Partnership for 21st Century Learning. (2016, February 10). *21st Century Learning Fraemwork*. យកមកវិញពី Frameworks & Resources: http://static.battelleforkids.org

Patrick Blessinger, & John M Cafora. (2014). *Inquiry-Based Learning for the Arts, Humanities, and Social Sciences* (វ៉ុល្លូម 2). Emerald Group Publishing Limited.

Patrick J McEwan. (2014). Improving learning in primary schools of developing countries: a meta-analysis of randomized experiments. *Review of Educational Research* , 353-394.

Peter Westwood. (2008). *What teachers need to know about teaching methods .* Victoria: ACER Press.

Pinar Simsek, & Filiz Kabapinar. (2010). The effects of inquiry-based learning on elementary students' conceptual understanding of matter, scientific process skills and science attitudes. *ScienceDirect*, 1990-1994.

Pooja K Agarwal , & Patrice M Bain. (2019). *Powerful Teaching: Unlease the Science of Learning.* San Francisco: Jossey-Bass.

Queensland Brain Institute. (2020, 04 22). *What is a neuron?* យកមកវិញពី Queensland Brain Institute: https://qbi.uq.edu.au

Ralph W Tyler. (1949). *Basic Principles of Curriculum and Instruction.* London: University of Chicago Press.

Remziye ERGÜL, Yeter SIMSEKLI, Sevgul CALIS, Zehra OZDILEK, Sirin GOCMENCELEBI, & Meral SANLI. (2011). The effects of inquiry-based science teaching on elementary school students' science process skills and science attitudes. *Bulgarian Journal of Science and Education Policy (BJSEP)*, 48-68.

Robert W Maloy, & Irene LaRoche. (2010). Student-centered teaching methods in the history classroom: ideas, issues and insights for new teachers . *Social Studies Research and Practice*, 46-61.

Robert J Marzano, & John S Kendall. (2008). *Designing and Assessing Educational Objectives: Applying New Taxonomy.* London: Corwin Press.

Robert King, Christopher Erickson, & Janae Sebranek. (2012). *Inquire: a guide to 21st century learning.* Wisconsin: Thoughtful Learning.

Robyn R Jackson. (2011). *How to Plan Rigorous Instruction: Mastering the principles of great teaching.* Virginia : ASCD, Alexandria .

Sabine Hoidn. (2017). *Student-centered learning environment in higher education classrooms.* New York: Springer Nature.

Samuel Kai Wah Chu, Rebecca B. Reynolds, Nicole J. Tavares, Michele Notari, & Celina Wing Yi Lee. (2017). *21st Century Skills Development through Inquiry-Based Learning.* Singapore : Springer.

Shanmugam P. (2017). *The Truth About Spiritual Enlightment.* Tamil Nadu: Vedanta Advaita .

Sigrid Blomeke, Rolf Vegar Olsen, & Ute Suhl. (2016). Relation of sstudent achievement to the quality of their teachers and instrucitonal quality. ក្នុង Trude Nilsen, & Jan Eric Gustafsson, *Teacher Quality, Instructional Quality and Student Outcomes* (ទំព័រ 21-47). AG Switzerland: IEA Research for Education .

Society of Abidance in Truth (SAT). (2019). *Five Flowers of Self-Knowledge.* Santa Cruz, USA: Society of Abidance in Truth (SAT).

Sophie Haroutunian Gordon. (2009). *Learning To Teach Through Discussion .* Pennsylvania: Yale University Press .

Swami Nikhilananda. (1947). *Self-Knowledge.* Adyar Madras : C. Subbarayudu.

Teresa Coffman. (2013). *Inquiry in the classroom: Developing creative thinkers and information literate students.* Plymouth, UK: Rowman & Littlefield Education.

Terry L Contant, Anne L Tweed, Joel E Bass, & Arthur A Carin. (2018). *Teaching Science Through Inquiry-based instruction .* New York: Pearson.

Trude Nilsen, Jan Eric Gustafsson, & Sigrid Blomeke. (2016). Conceptual Framework and Methodology . ក្នុង Trude Nilsen, & Jan Eric Gustafsson, *Teacher Quality, Instructional Quality and Student Outcomes* (ទំព័រ 1-20). AG Switzerland: IEA Research for Education.

United Nations Development Program . (2011). *Human Capital Implications of the Future Economic Growth in Cambodia.* Phnom Penh: United Nations Development Program (UNDP).

United Nations Educational, Scientific and Cultural Oranization . (1996). *Learning: The treasure within.* Paris: United Nations Educational, Scientific and Cultural Oranization .

United Nations Educational, Scientific and Cultural Organization . (2015). *Global Citizenship Education.* Paris: UNESCO.

United Nations Educational, Scientific and Cultural Organization. (2018). *A Global Framework of Reference on Digital Skills for Indicator 4.4.2.* Paris: United Nations Educational, Scientific and Cultural Organization.

United Nations Educational, Scientific and Cultural Organization. (2018, March 19). *http://uis.unesco.org/en/blog/global-framework-measure-digital-literacy*. យកមកវិញពី www.uis.unesco.org: http://uis.unesco.org/en/blog/global-framework-measure-digital-literacy

United Nations Educational, Scientific and Cultural Organization. (2018a). *Learning at the bottom of the pyramid: science, measurement and policy in low-income countries.* Paris: International Institute for Educational Planning.

Valerie A Curtis, Lisas O Danquah, & Robert V Aunger. (2009). Planned, motivated and habitual hygiene behaviour: an elevent country review. *Health Education Research*, 655–673.

Violet H Harada, & Joan A Yoshina. (2010). *Assessment for Learning.* Oxford: Libraries Unlimited.

Walter Parker. (2012 , 11 26). *Home*. យកមកវិញពី Concept Formation: https://teachinghistory.org

Warren Houghton. (2004). *Learning and Teaching Theory.* Engineering Subject Center.

Wendy Conklin. (2006). *Instructional Strategies for Diverse Learners .* Washington, DC: Shell Education.

Will Peters. (2017). *Leadership Lessons: Warren Buffett, Walt Disney, Thomas Edison, Katharine Graham, Steve Jobs, Ray Kroc.* New York: New Word City, Inc.

William Arthur Ward . (1970). *Fountains of faith; the words of William Arthur Ward.* New York: Droke House.

William La Ganza. (2008). Learner autonomy – teacher autonomy: Interrelating and the will to empower. ក្នុង Terry Lamb, & Hayo Reinders, *Learner and Teacher Autonomy: Concepts, Realities and Responses* (ទំព័រ 63-82). Philadelphia pa: John Benjamins Publishing Company.

wisdom library. (2008, August 31). *Puccha, Pucchā: 7 definitions*. យកមកវិញពី Wisdom Library: http://www.wisdomlib.org/

Wolff-Michael Roth, & Yew-Jin Lee. (2006). Contradictions in theorizing and implementing communities in education. *Educational Research Review*, 27-40.

Wolters Kluwer. (2017, November 07). *Top 3 Reasons Why Concept-Based Learning Helps Students Learn Better*. យកមកវិញពី Lippincott Nursing Education Blog: http://nursingeducation.lww.com/blog.entry.html/2017/11/06/top_3_reasons_whyco-9FqF.html

World Bank. (2015). *Educating the next generation: Improving teacher quality in Cambodia.* Phnom Penh: World Bank.

World Economic Forum. (2016, March 10). *Industry Agenda Workforce and Employment* . យកមកវិញពី What are the 21st-century skills every student needs?: http://www.weforum.org

Yusuf Ay. (2017). The Effect of Learning Types/Styles on Student Achievement. ក្នុង Engin Karadag, *The Factors Effecting Student Achievement* (ទំព័រ 309-324). Geneva: Springer Nature .